# សេចក្តីពន្យល់

# ក្រមរដ្ឋប្បវេណី

# ភាគ ២

រៀបចំដោយ

ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាល

នៅសាលាតួមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

ការកែសម្រួលលើការបោះពុម្ពលើកទី ១

រាជធានីភ្នំពេញ ខែមេសា ឆ្នាំ២០១៣

ក្រសួងយុត្តិធម៌

Ministry of Justice



ស្វែងរក

ទំព័រដើម | ឯកសារច្បាប់និងបទប្បញ្ញត្តិ | បណ្ណាល័យវិស័យយុត្តិធម៌ | ស្វែងរកពាក្យគន្លឹះក្នុងច្បាប់និងបទប្បញ្ញត្តិ | វិចិត្រសាល | ទំនាក់ទំនងយើង

ឈ្មោះឯកសារ

ឈ្មោះឯកសារ

ប្រភេទឯកសារ

សូមជ្រើសរើស

តាមស្ថាប័ន

សូមជ្រើសរើស

ស្វែងរក

សូមចូលទៅកាន់គេហទំព័រក្រសួងយុត្តិធម៌
**ww.moj.gov.kh**
សម្រាប់ការស្រាវជ្រាវក្នុងវិស័យយុត្តិធម៌
១.បណ្ណាល័យវិស័យយុត្តិធម៌
២.ឯកសារច្បាប់និងបទប្បញ្ញត្តិ
៣.ស្វែងរកពាក្យគន្លឹះក្នុងច្បាប់និងបទប្បញ្ញត្តិ
ដែលកំពុងធ្វើបច្ចុប្បន្នភាពជារៀងរាល់ថ្ងៃ
សូមអរគុណ!

www.moj.gov.kh

បណ្ណាល័យ



# សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី

## ភាគ ២

រៀបរៀងដោយ

**ក្រុមការងារនៃអនាគតគ្រូបង្គោល នៅសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ**

ការកែសម្រួលលើការបោះពុម្ពលើកទី ១

រាជធានីភ្នំពេញ ខែ មេសា ឆ្នាំ ២០១៣

បោះពុម្ពនៅរាជធានីភ្នំពេញ
ដោយគម្រោងអភិវឌ្ឍវិស័យច្បាប់ និង តុលាការ
របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ឆ្នាំ ២០១៣

សិទ្ធិអ្នកនិពន្ធ © រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ឆ្នាំ២០១៣
ISBN-13: 978-99963-26 – 05 - 9

## អារម្ភកថា

សៀវភៅនេះ ត្រូវបានចងក្រងឡើងតាមផ្នែកនៃ "**ក្រមរដ្ឋប្បវេណី**" ហើយនេះ គឺជាសៀវភៅភាគទី ២ ដែលគ្របដណ្តប់លើ ***មូលដ្ឋាននៃកិច្ចសន្យាសំខាន់ៗ កាតព្វកិច្ចដែលកំណត់ដោយច្បាប់ និង ការធានាកាតព្វកិច្ច*** ។

សៀវភៅនេះ ត្រូវបានបង្កើតឡើងដោយសមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD) ។

សមាជិកនៃក្រុមការងារមានដូចខាងក្រោម :

| | | |
|---|---|---|
| លោក **អ៊ិន វ៉ាន់វិបុល** | លោកស្រី **ចាំង ស៊ីណាត** | លោកស្រី **សែម សក្តិកុន្ឡា** |
| លោក **សេង នាង** | លោក **ប្លង់ សំណាង** | លោក **តាំង ស៊ុនឡាយ** |
| លោក **យូ ម៉ិនណា** | លោក **ងួន វេតនា** | លោក **គង់ តារាឆាត** |
| លោក **ម៉ុង មុនីសោភា** | លោក **ហួត ហ៊ាង** | លោក **ជា សុខហៀង** |
| លោក **ហេង សុខណា** | លោកស្រី **យ៉េត ម៉ូលីន** | លោក **ងួន ឧត្តី** |
| កញ្ញា **ថ្លាង ផាវណែត** | លោកស្រី **ស្រ៊ុន ឈយទ័លកន្ទណ៍** | កញ្ញា **ស៊ី លីនណា** |
| លោក **កេត សុជាតិ** | លោក **ចំនួ រឌ្ឍី** | លោកស្រី **ខៀវ សុខា** |
| លោក **រស់ ពិសិដ្ឋ** | លោក **ស៊ិន សុវណ្ណរ័ត្ន** | លោក **ហេង ចន្ទស៊ីបុរិន** |
| លោក **តែ វិរៈ** | លោក **អ៊ុំ ថាវរៈ** | លោក **កេង សុម៉ារិទ្ធ** |
| លោក **ឈុន ចំនួសីហា** | លោក **យាប់ មេត្តា** | លោក **តែ វិទន្សនៈ** |
| លោកស្រី **វ៉ា សត្ថា** | លោក **សំម ឫទ្ធីវាសនា** | |

សមាជិកក្រុមការងារទាំងអស់ សង្ឃឹមថាកម្រងភាគទីមួយៗ នេះ អាចនឹងជួយដល់អ្នកអានឱ្យយល់ដឹង និង សិក្សាអំពីមូលដ្ឋាននៃក្រមរដ្ឋប្បវេណីនាពេលបច្ចុប្បន្ន ។

**កំណត់សម្គាល់ :** ខ្លឹមសារនៃសៀវភៅនេះ ត្រូវបានចងក្រងឡើង ដោយសមាជិកក្រុមការងារ និង មិនបានឆ្លុះបញ្ចាំងពីទស្សនៈផ្លូវការរបស់អាជ្ញាធរពាក់ព័ន្ធណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ។

សៀវភៅនេះ បានបោះពុម្ពលើកទី ១ នៅក្នុងខែ មីនា ឆ្នាំ ២០១២ ។

ការកែសម្រួលលើការបោះពុម្ពលើកទី ១ នេះ មិនបានផ្លាស់ប្តូរចំណុចសារធាតុសំខាន់ៗ នៃខ្លឹមសារដើមឡើយ ។ ប៉ុន្តែ កំហុសអក្ខរាវិរុទ្ធជាក់ស្តែងនៅក្នុងការបោះពុម្ពលើកទី ១ ត្រូវបានកែតម្រូវ ។ ទន្ទឹមនឹងនេះ លំដាប់លំដោយនៃជំពូកមួយចំនួន ក៏ត្រូវបានផ្លាស់ប្តូរផងដែរ ។ លើសពីនេះទៅទៀត ការកែសម្រួលនេះ ត្រូវបានបោះពុម្ពឡើងវិញជា ៣ ភាគ ដើម្បីជាការងាយស្រួលដល់អ្នកអាន ដែលការបោះពុម្ពលើកទី ១ ត្រូវបានធ្វើឡើងជា ៦ ភាគ ។

សៀវភៅនេះ ត្រូវបានកែសម្រួល និង បោះពុម្ពឡើងវិញ នៅខែ មេសា ឆ្នាំ ២០១៣ ។

ចំពោះមិត្តអ្នកអាន

សៀវភៅនេះ ត្រូវបានចងក្រងឡើងទៅតាមផ្នែកនីមួយៗនៃក្រមរដ្ឋប្បវេណី ដែលរួមមានទាំងអស់ចំនួន ៣ (បី) ភាគ។ ភាគទី ១ និយាយអំពី *មូលដ្ឋាននៃបទប្បញ្ញត្តិទូទៅ សិទ្ធិប្រត្យក្ស និង កាតព្វកិច្ច* ភាគទី ២ និយាយអំពី *មូលដ្ឋាននៃកិច្ចសន្យាសំខាន់ៗ កាតព្វកិច្ចដែលកំណត់ដោយច្បាប់ និង ការធានាកាតព្វកិច្ច* និងភាគទី ៣ និយាយអំពី *មូលដ្ឋាននៃញាតិ* និង *សន្តតិកម្ម*។

សៀវភៅនេះ ត្រូវបានបង្កើតឡើងដោយសមាជិក សមាជិកាក្រុមការងារ ដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយមានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវនិងបណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD)។

រាល់សិទ្ធិអ្នកនិពន្ធទាំងអស់ដែលពាក់ព័ន្ធនឹងសៀវភៅទាំងនេះ គឺជាកម្មសិទ្ធិរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)។

គ្មានផ្នែកណាមួយនៃឯកសារ ដែលទទួលបានការការពារដោយសេចក្តីជូនដំណឹងអំពីសិទ្ធិអ្នកនិពន្ធនេះ អាចត្រូវបានបោះពុម្ពឡើងវិញ ឬ ប្រើប្រាស់ក្នុងទម្រង់ណាមួយ ឬ តាមមធ្យោបាយផ្សេងៗ តាមរយៈប្រព័ន្ធអេឡិចត្រូនិច ឬ តាមរយៈម៉ាស៊ីន រួមបញ្ចូលទាំងការថតចម្លង ការកត់ត្រាទុក ឬ ដោយប្រព័ន្ធរក្សាទុក និង ប្រព័ន្ធទទួលព័ត៌មានផ្សេងណាមួយ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធក្នុងគោលបំណងពាណិជ្ជកម្ម ឬ ការចំណេញផលប្រយោជន៍ហិរញ្ញវត្ថុបានឡើយ។ ករណីលើកលែងគឺ សម្រាប់តែគោលបំណងស្រាវជ្រាវ បង្រៀន សិក្ខាសាលា ការសិក្សាឯកជន ឬ សម្រាប់គោលបំណងការងារ ជាងនេះទៅទៀត សៀវភៅទាំងនេះ គឺមិនមែនសម្រាប់លក់ទេ។

ការសាកសួរទាំងឡាយ ទាក់ទងនឹងការផលិតឡើងវិញនៅក្រៅពីលក្ខខណ្ឌខាងលើ អាចទំនាក់ទំនងតាមរយៈអ៊ីម៉ែល ៖ admin@rajp.gov.kh ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមបង្ហាញពីការកោតសរសើរ យ៉ាងជ្រាលជ្រៅចំពោះ កិច្ចសហប្រតិបត្តិការដ៏ជោគជ័យរបស់សមាជិក សមាជិកាក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ជាមួយនឹងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)។

យើងខ្ញុំសង្ឃឹមថា ឯកសារនេះ នឹងក្លាយជាប្រទីបថ្មីមួយបន្ថែមសម្រាប់ជាជំនួយដល់ការយល់ដឹង ការសិក្សាស្រាវជ្រាវដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍ ការអនុវត្ត ក៏ដូចជាការតាក់តែងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងៗនាពេលអនាគត។

ភ្នំពេញថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣

ប្រធានទីប្រឹក្សាផ្នែកច្បាប់
គម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និង តុលាការ

Legal and Judicial Development Project * JICA Cambodia Office

松原禎夫

ម៉ាស៊ុបារ៉ា សាដាអុ

ប្រធាន
រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

ឯកឧត្តម ឈន ព្រលឹង

# មាតិកា

**ជំពូកទី ៤ កិច្ចសន្យាសំខាន់ៗ** ........ **១**

**ផ្នែកទី ១ កិច្ចសន្យាលក់ទិញ** ........ **១**

១. គោលគំនិត ........ ១

២. លក្ខខណ្ឌ ........ ១

២.១. ការព្រមព្រៀង ........ ១

២.២. ថ្លៃលក់ទិញដែលត្រូវបានកំណត់ ........ ១

២.៣. សោហ៊ុយក្នុងការលក់ទិញ ........ ២

៣.ករណីយកិច្ច និង សិទ្ធិរបស់អ្នកលក់ ........ ២

៣.១. ករណីយកិច្ចទូទៅរបស់អ្នកលក់ ........ ៣

៣.២. ករណីយកិច្ចត្រូវពន្យល់ ........ ៥

៣.៣. ករណីយកិច្ចផ្ទេរសិទ្ធិ ........ ៥

៤. ការទទួលខុសត្រូវក្នុងការធានា ........ ៥

៤.១. ទិដ្ឋភាពទូទៅនៃការទទួលខុសត្រូវក្នុងការធានា ........ ៦

៤.២. ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់ ក្នុងករណីដែលសិទ្ធិដែលត្រូវបានលក់ជាសិទ្ធិរបស់អ្នកដទៃ ........ ៦

៤.៣. ការទទួលខុសត្រូវក្នុងការធានាចំពោះវិការៈ ........ ៧

៤.៤. ក្នុងករណីដែលសិទ្ធិដែលត្រូវបានលក់ ត្រូវបានកម្រិតដោយច្បាប់ ........ ១២

៥. ករណីយកិច្ច និង សិទ្ធិរបស់អ្នកទិញ ........ ១៧

៥.១. ករណីយកិច្ចទូទៅរបស់អ្នកទិញ ........ ១៧

៥.២. សិទ្ធិទូទៅរបស់អ្នកទិញ ........ ១៩

៥.៣. សិទ្ធិបដិសេធមិនបង់ថ្លៃទិញ ........ ១៩

**ផ្នែកទី ២ ប្រទានកម្ម** ........ **២២**

១. គោលគំនិតនៃប្រទានកម្ម ........ ២២

២. លក្ខខណ្ឌ ........ ២២

៣. ករណីយកិច្ចរបស់ទាយក ........ ២៣

៣.១. កាតព្វកិច្ចផ្ទេរសិទ្ធិ ........ ២៣

៣.២. ការបន្ថយនូវការទទួលខុសត្រូវក្នុងការធានា........................................................ ២៣
៤. ការលុបចោលប្រទានកម្ម........................................................................................ ២៤
៤.១. នៅក្នុងករណីប្រទានកម្ម ដែលមិនធ្វើជាលាយលក្ខណ៍អក្សរ........................................ ២៤
៤.២. នៅក្នុងករណីនៃការរំលោភលើទំនុកចិត្ត ជាអាទិ៍.................................................. ២៥
៤.៣. នៅក្នុងករណីភាពទីទ័លក្ររបស់ទាយក................................................................ ២៥
៤.៤. អានុភាពនៃការលុបចោលប្រទានកម្ម.................................................................. ២៦
៥. ប្រភេទពិសេសនៃប្រទានកម្ម................................................................................. ២៦
៥.១. ប្រទានកម្មដោយមានកំណត់ពេល...................................................................... ២៦
៥.២. ប្រទានកម្មដែលមានភ្ជាប់បន្ទុក.......................................................................... ២៧
៥.៣. ប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក.................................................. ២៨
**ផ្នែកទី ៣ ភតិសន្យា**........................................................................................ **៣១**
១. គោលគំនិតនៃភតិសន្យា......................................................................................... ៣១
១.១. និយមន័យ................................................................................................... ៣១
១.២. លក្ខខណ្ឌ.................................................................................................... ៣១
១.៣. លក្ខខណ្ឌតតាំង........................................................................................... ៣១
១.៤. អំឡុងពេលជួល............................................................................................. ៣២
២. សិទ្ធិ និង ករណីយកិច្ចរបស់ភតិបតី.......................................................................... ៣២
២.១. ករណីយកិច្ចធ្វើឱ្យភតិកៈប្រើប្រាស់ និង អាស្រ័យផល ដោយផ្អែកតាមវិធីប្រើប្រាស់ ........... ៣២
២.២. ករណីយកិច្ចជួសជុល....................................................................................... ៣២
២.៣. ករណីយកិច្ចសងវិញនូវសោហ៊ុយចំណាយ............................................................. ៣៣
២.៤. ការទទួលខុសត្រូវក្នុងការធានារបស់ភតិបតី......................................................... ៣៥
៣. សិទ្ធិ និង ករណីយកិច្ចរបស់ភតិកៈ.......................................................................... ៣៧
៣.១. ករណីយកិច្ចបង់ថ្លៃឈ្នួល.................................................................................. ៣៧
៣.២. សិទ្ធិ និង ករណីយកិច្ចនៃការប្រើប្រាស់ និង អាស្រ័យផល ផ្អែកតាមវិធីប្រើប្រាស់.............. ៣៧
៣.៣. ករណីយកិច្ចរបស់ភតិកៈ នៅក្នុងការថែរក្សាវត្ថុជួល ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ........................................................................................................ ៣៨
៣.៤. សិទ្ធិទាមទារឱ្យសងវិញ នូវសោហ៊ុយរបស់ភតិកៈ................................................... ៣៨
៣.៥. សិទ្ធិទាមទារឱ្យបន្ថយថ្លៃឈ្នួល ឬ សិទ្ធិរំលាយភតិសន្យា.......................................... ៣៨
៣.៦. អនុប្បទានសិទ្ធិជួល និង ការជួលបន្តនូវវត្ថុជួល...................................................... ៤០

៤. ការរំលាយភតិសន្យា........................................................................................ ៤២

៤.១. ប្រភពនៃការបញ្ចប់ភតិសន្យា........................................................................ ៤២

៤.២. ការបញ្ចប់ភតិសន្យា ដោយសារការផុតអំឡុងពេលកំណត់ .......................................... ៤២

៤.៣. ការស្នើសុំឱ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល..................................... ៤៤

៤.៤. ការបញ្ចប់ដោយសារបាត់បង់នូវវត្ថុជួល ............................................................ ៤៥

៤.៥. ការរំលាយភតិសន្យា ដោយសារការមិនអនុវត្តកាតព្វកិច្ច ........................................ ៤៥

**ផ្នែកទី ៤ ការខ្ចីបរិភោគ**........................................................................................**៤៦**

១. គោលបំណង.................................................................................................. ៤៦

២. លក្ខខណ្ឌ..................................................................................................... ៤៦

៣. កាតព្វកិច្ច និង សិទ្ធិរបស់អ្នកឱ្យខ្ចី..................................................................... ៤៧

៣.១. កាតព្វកិច្ចឱ្យខ្ចីវត្ថុដែលជាកម្មវត្ថុ ..................................................................... ៤៧

៣.២. ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចី.......................................................... ៤៧

៣.៣. ការទាមទារឱ្យសងមកវិញ នៅក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី បានធ្លាក់ចុះយ៉ាងខ្លាំង.............................................................................................................. ៤៩

៤. កាតព្វកិច្ចរបស់អ្នកខ្ចី.......................................................................................... ៥០

៤.១. ករណីយកិច្ចត្រូវសងវត្ថុ ..................................................................................... ៥០

៤.២. កាតព្វកិច្ចបង់ការប្រាក់ ...................................................................................... ៥២

៥. ការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់..................................................................... ៥២

៥.១. គោលគំនិត .................................................................................................. ៥២

៥.២. អត្រាការប្រាក់................................................................................................ ៥៣

៥.៣. ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយច្បាប់.................... ៥៦

**ផ្នែកទី ៥ អាណត្តិ**..............................................................................................**៥៨**

១. គោលគំនិត.................................................................................................... ៥៨

២. លក្ខខណ្ឌ....................................................................................................... ៥៩

៣. ទំនាក់ទំនងជាមួយនឹងការតំណាង.......................................................................... ៥៩

៤. កាតព្វកិច្ចរបស់អាណត្តិគាហក ............................................................................. ៦០

៤.១. ករណីយកិច្ចប្រុងប្រយ័ត្ន ...................................................................................... ៦០

៤.២. ករណីយកិច្ចរាយការណ៍....................................................................................... ៦១

៤.៣. កាតព្វកិច្ចប្រគល់................................................................................................ ៦១

៤.៤. ការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតដែលបានប្រើប្រាក់ ........ ៦២
៤.៥. ករណីយកិច្ចសង្គ្រោះបន្ទាន់នៅក្រោយពេលបញ្ចប់អាណត្តិ ........ ៦២
៥. កាតព្វកិច្ចរបស់អាណត្តិទាយក ........ ៦៣
៥.១. ករណីយកិច្ចបង់កម្រៃ ........ ៦៣
៥.២. ករណីយកិច្ចបង់សោហ៊ុយជាមុន ........ ៦៣
៥.៣. ករណីយកិច្ចសងវិញនូវសោហ៊ុយដែលបានចំណាយ ........ ៦៤
៥.៤. ករណីយកិច្ចសងសំណងនៃការខូចខាត ........ ៦៥
៦. ការរំលាយកិច្ចសន្យាអាណត្តិ ........ ៦៥
៦.១. មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ ........ ៦៥
៦.២. អានុភាពនៃការរំលាយ ........ ៦៦
**ផ្នែកទី ៦ កិច្ចសន្យាម៉ៅការ ........ ៦៨**
១. គោលគំនិត ........ ៦៨
២. លក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យាម៉ៅការ ........ ៦៨
៣. កាតព្វកិច្ចរបស់អ្នកម៉ៅការ ........ ៦៨
៣.១. ករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈ ........ ៦៨
៣.២. ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ ........ ៧២
៤. កាតព្វកិច្ចរបស់ម្ចាស់ការ ........ ៧៣
៤.១. ករណីយកិច្ចបង់កម្រៃ ........ ៧៣
៤.២. ករណីយកិច្ចទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ........ ៧៤
៥. ការបញ្ចប់កិច្ចសន្យាម៉ៅការ ........ ៧៤
៥.១. សិទ្ធិរំលាយរបស់ម្ចាស់ការ ក្នុងពេលដែលការងារមិនទាន់បានសម្រេច ........ ៧៤
៥.២. ការរំលាយកិច្ចសន្យា ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ........ ៧៤
**ជំពូកទី ៥ កាតព្វកិច្ចដែលកំណត់ដោយច្បាប់ ........ ៧៥**
**ផ្នែកទី ១ ការគ្រប់គ្រងដោយឈឺឆ្អាល ........ ៧៥**
១. សេចក្តីផ្តើម ........ ៧៥
២. លក្ខខណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្អាល ........ ៧៦
២.១. គ្មានសិទ្ធិអំណាច ........ ៧៦
២.២. ដើម្បីបុគ្គលដទៃ ........ ៧៦
២.៣. អ្នកគ្រប់គ្រងចាប់ផ្តើមគ្រប់គ្រង ........ ៧៦

២.៤. ការគ្រប់គ្រងដោយធ្វើឡើងតាមវិធីដែលសមរម្យជាងគេ និង ដោយផ្អែកតាមឆន្ទៈ ..........៧៧
៣. ករណីយកិច្ច ........................................................................................................៧៨
៣.១. ករណីយកិច្ចគ្រប់គ្រងតាមវិធីដែលសមរម្យជាងគេដើម្បីជាប្រយោជន៍ និង អនុវត្តតាមឆន្ទៈរបស់សាមីខ្លួន........................................................................................................៧៨
៣.២. ករណីយកិច្ចជូនដំណឹង........................................................................................៧៨
៣.៣. ករណីយកិច្ចបន្តការគ្រប់គ្រង ..................................................................................៧៨
៣.៤. ករណីយកិច្ចធ្វើសេចក្តីរាយការណ៍...........................................................................៧៨
៣.៥. ករណីយកិច្ចទាមទារសំណងចំពោះប្រាក់ដែលបានចំណាយ ............................................ ៧៩
៤. អានុភាព............................................................................................................ ៧៩
៤.១. សិទ្ធិទាមទារឱ្យសងសោហ៊ុយ ជាអាទិ៍..................................................................... ៧៩
៤.២. សិទ្ធិទាមទារកម្រៃ.............................................................................................. ៧៩
**ផ្នែកទី ២ សេចក្តីចម្រើនដោយឥតហេតុ**.............................................................**៨១**
១. សេចក្តីផ្តើម........................................................................................................៨១
២. លក្ខខណ្ឌទូទៅ ....................................................................................................៨១
២.១. ផលប្រយោជន៍.....................................................................................................៨២
២.២. ការបាត់បង់ផលប្រយោជន៍......................................................................................៨២
២.៣. ទំនាក់ទំនងហេតុ និង ផល ...................................................................................... ៨៣
២.៤. ការទទួលផលប្រយោជន៍ដោយគ្មានមូលហេតុលើផ្លូវច្បាប់.............................................. ៨៤
៣. អានុភាព............................................................................................................. ៨៤
៣.១. បទប្បញ្ញត្តិទូទៅ.................................................................................................. ៨៤
៣.២. បញ្ញត្តិពិសេសនៅក្នុងករណីទុច្ចរិត ........................................................................... ៨៥
៤. ករណីពិសេស....................................................................................................... ៨៦
៤.១. ការសងដោយគ្មានកាតព្វកិច្ច................................................................................... ៨៦
៤.២. ការសងមុនកំណត់ពេល ...........................................................................................៨៧
៤.៣. ការសងកាតព្វកិច្ចអ្នកដទៃ.......................................................................................៨៧
៤.៤ ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់................................................................ ៨៩
**ផ្នែកទី ៣ អំពើអនីត្យានុកូល**.................................................................................**៩១**
១. តើអ្វី គឺជាការទទួលខុសត្រូវខាងអំពើអនីត្យានុកូល? ................................................... ៩១
២. ទស្សនៈជាមូលដ្ឋាននៃការទទួលខុសត្រូវខាងអំពើអនីត្យានុកូល ...................................... ៩១

៣. លក្ខខណ្ឌ ........ ៩២
៣.១. អំពើដោយកំហុសចេតនា ឬ កំហុសអចេតនា ........ ៩៣
៣.២. ភាពខុសច្បាប់ ........ ៩៦
៣.៣. ការខូចខាត ........ ១០០
៣.៤. ទំនាក់ទំនងរវាងហេតុ និង ផល ........ ១០០
៣.៥. សមត្ថភាពក្នុងការទទួលខុសត្រូវ ........ ១០០
៤. អានុភាព ........ ១០២
៤.១. គោលការណ៍នៃសំណងការខូចខាតជាប្រាក់ ........ ១០២
៤.២. ទំហំនៃការខូចខាត ........ ១០៣
៤.៣. ការបន្ថយសំណងនៃការខូចខាត ........ ១០៨
៥. ទម្រង់ពិសេសនៃអំពើអនីត្យានុកូល ........ ១១០
៥.១. សេចក្តីផ្តើម ........ ១១០
៥.២. ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ ........ ១១១
៥.៣. ការទទួលខុសត្រូវរបស់និយោជក ........ ១១១
៥.៤. អំពើអនីត្យានុកូលរបស់នីតិបុគ្គល ........ ១១២
៥.៥. អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ ........ ១១៣
៥.៦. ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ ........ ១១៤
៥.៧. ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ ........ ១១៥
៥.៨. ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់ ........ ១១៥
៥.៩. ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី ........ ១១៦
៥.១០. អំពើអនីត្យានុកូលរួម ........ ១១៦
៦. បញ្ញត្តិដែលទាក់ទងដទៃផ្សេងទៀតស្តីពីអំពើអនីត្យានុកូល ........ ១១៨
៦.១. ទារកក្នុងគភ៌ ........ ១១៨
៦.២. អាជ្ញាយុកាលនៃការរំលត់ ........ ១១៨
**ជំពូកទី ៦ ការធានាកាតព្វកិច្ច ........ ១១៩**
**ផ្នែកទី ១ ហ៊ីប៉ូតែក ........ ១១៩**
១. និយមន័យហ៊ីប៉ូតែក ........ ១២០
២. ការបង្កើតហ៊ីប៉ូតែក ........ ១២០
២.១. លក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាហ៊ីប៉ូតែករវាងគូភាគី ........ ១២០

២.២. លក្ខខណ្ឌតាំងនៃកិច្ចសន្យាហ៊ីប៉ូតែក ...... ១២២
៣. អានុភាពនៃហ៊ីប៉ូតែក ...... ១២៣
៣.១. ទំហំនៃអានុភាពហ៊ីប៉ូតែក ...... ១២៣
៣.២. ឧបាទេសកម្ម ...... ១២៤
៣.៣. សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ ...... ១២៥
៣.៤. លំដាប់នៃហ៊ីប៉ូតែក ...... ១២៦
៣.៥. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ...... ១២៩
៤. ការអនុវត្តហ៊ីប៉ូតែក ...... ១៣០
៤.១. អ្នកទិញ ...... ១៣១
៤.២. វិធានដើម្បីសម្របសម្រួលការអនុវត្តដោយបង្ខំ នៅពេលដែលមានម្ចាស់សិទ្ធិលើបំណុលច្រើន លើអចលវត្ថុដែលជាកម្មវត្ថុហ៊ីប៉ូតែក ...... ១៣២
៥. ការចាត់ចែងហ៊ីប៉ូតែក ...... ១៣៨
៥.១. ហ៊ីប៉ូតែកបន្ត ...... ១៣៨
៥.២. អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក ...... ១៣៨
៥.៣. អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក ...... ១៤០
៦. ការរលត់ហ៊ីប៉ូតែក ...... ១៤១
៦.១. សេចក្តីផ្តើម ...... ១៤១
៦.២. ការសងដោយថ្លៃលក់ ...... ១៤២
៦.៣. អាជ្ញាយុកាលនៃការរលត់ ...... ១៤២
**ផ្នែកទី ២ សិទ្ធិឃាត់ទុក ...... ១៤៤**
១. និយមន័យ ...... ១៤៤
២. លក្ខខណ្ឌនៃសិទ្ធិឃាត់ទុក ...... ១៤៤
២.១. ការកាន់កាប់វត្ថុរបស់អ្នកដទៃ ...... ១៤៤
២.២. សិទ្ធិលើបំណុលបានកើតឡើងដោយទាក់ទងនឹងវត្ថុនោះ ...... ១៤៥
២.៣. សិទ្ធិលើបំណុលដល់ពេលកំណត់ត្រូវសង ...... ១៤៥
២.៤. ការកាន់កាប់មិនត្រូវបានចាប់ផ្តើមដោយសារអំពើអនីត្យានុកូល ...... ១៤៥
៣. អានុភាព ...... ១៤៥
៣.១. សិទ្ធិឃាត់ទុក ...... ១៤៥
៣.២. សិទ្ធិទទួលសំណងពីផលដោយមានអាទិភាព ...... ១៤៦

៣.៣. ករណីយកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុក ............ ១៤៦

៣.៤. សិទ្ធិទាមទារឱ្យសងសោហ៊ុយមកវិញ ............ ១៤៦

៤. អាជ្ញាយុកាលនៃការរំលត់សិទ្ធិ ............ ១៤៦

៥. ការរំលត់សិទ្ធឃាត់ទុក ............ ១៤៦

**ផ្នែកទី ៣ សិទ្ធិលើការបញ្ចាំ ............ ១៤៨**

១. សេចក្ដីផ្ដើម ............ ១៤៨

២. ប្រភេទនៃកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ............ ១៤៨

៣. លក្ខណៈទូទៅ ............ ១៤៨

៣.១. លក្ខខណ្ឌ ............ ១៤៨

៣.២. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ............ ១៤៨

៣.៣. អានុភាព ............ ១៤៨

៣.៤. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ............ ១៤៩

៣.៥. ការបញ្ចាំបន្ត ............ ១៥០

៣.៦. ការហាមកិច្ចសន្យាបញ្ចាំផ្ដាច់ ............ ១៥០

៤. ការបញ្ចាំចលនវត្ថុ ............ ១៥១

៤.១. លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ ............ ១៥១

៤.២. ការប្រើប្រាស់ ឬ ការអាស្រ័យផលពីវត្ថុបញ្ចាំដោយម្ចាស់សិទ្ធិលើការបញ្ចាំ ............ ១៥១

៤.៣. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ............ ១៥១

៤.៤. លំដាប់នៃសិទ្ធិលើការបញ្ចាំ ............ ១៥២

៥. ការបញ្ចាំអចលនវត្ថុ ............ ១៥២

៥.១. សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ............ ១៥២

៥.២. ការគោរពតាមវិធីប្រើប្រាស់ធម្មតា ............ ១៥៣

៥.៣. បទបញ្ញត្តិពិសេសស្ដីពីដីសម្រាប់ធ្វើកសិកម្ម ............ ១៥៣

៥.៤. បន្ទុកសោហ៊ុយគ្រប់គ្រងវត្ថុបញ្ចាំ ............ ១៥៤

៥.៥. ការប្រាក់នៃសិទ្ធិលើបំណុល ............ ១៥៤

៥.៦. ការសន្យាពិសេសនៅក្នុងកិច្ចសន្យាបញ្ចាំ ............ ១៥៤

៥.៧. អំឡុងពេលនៃសិទ្ធិលើការបញ្ចាំដែលមានអត្ថិភាព ............ ១៥៥

៥.៨. ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីហ៊ីប៉ូតែក ............ ១៥៥

៦. ការបញ្ចាំសិទ្ធិ ............ ១៥៦

៦.១. លក្ខខណ្ឌសុពលភាព/អានុភាពនៃការបញ្ចាំសិទ្ធិលើបំណុលចំពោះគូភាគី ........................ ១៥៧
៦.២. លក្ខខណ្ឌតតាំងនៃការបញ្ចាំសិទ្ធិលើបំណុលចំពោះតតិយជន ........................ ១៥៧
៦.៣. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយប្រមូលសិទ្ធិលើបំណុល ........................ ១៥៨
**ផ្នែកទី ៤ ប្រាតិភោគដោយអនុប្បទាន ........................ ១៦០**
១. សេចក្ដីផ្ដើម ........................ ១៦០
២. លក្ខខណ្ឌ ........................ ១៦០
៣. អានុភាព ........................ ១៦១
៣.១. ទំហំនៃអានុភាព ........................ ១៦១
៣.២. អានុភាពចំពោះផល ........................ ១៦១
៣.៣. ឧបាទេសកម្ម ........................ ១៦២
៣.៤. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ........................ ១៦២
៣.៥. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ និង ម្ចាស់សិទ្ធិប្រាតិភោគប្រត្យក្ស. ១៦៣
៣.៦. បញ្ញត្តិពិសេសនៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុ ........................ ១៦៤
៤. ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន ........................ ១៦៤
៤.១. ការប្តូរជាប្រាក់ ........................ ១៦៥
៤.២. អនុប្បទានជាស្ថាពរ ........................ ១៦៥
៤.៣. ករណីយកិច្ចត្រូវបង់ទឹកប្រាក់ដែលលើស ........................ ១៦៥
៤.៤. សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត ........................ ១៦៥
**ផ្នែកទី ៥ ការធានា ........................ ១៦៦**
១. សេចក្ដីផ្ដើម ........................ ១៦៦
២. ការបង្កើតកិច្ចសន្យាធានា ........................ ១៦៦
២.១. លក្ខខណ្ឌជាមូលដ្ឋាន ........................ ១៦៦
២.២. ការការពារអ្នកធានា ........................ ១៦៦
៣. អានុភាពនៃកិច្ចសន្យាធានា ........................ ១៦៧
៣.១. ទំហំនៃកាតព្វកិច្ចធានា ........................ ១៦៧
៣.២. លក្ខណៈនៃការធានា ........................ ១៦៨
៣.៣. សិទ្ធិរបស់អ្នកធានា ........................ ១៦៩
៣.៤. លក្ខណៈសម្បត្តិរបស់អ្នកធានា ........................ ១៧០

៣.៥. គោលការណ៍នៃការធានាដោយសាមគ្គីភាព ............................................ ១៧០

៣.៦. អានុភាពនៃហេតុដែលកើតឡើងចំពោះអ្នកធានា............................................ ១៧០

៣.៧. អ្នកធានារួម ............................................ ១៧១

៤. ប្រភេទនៃការធានា............................................ ១៧២

៤.១. ការធានាធម្មតា............................................ ១៧២

៤.២. ការធានាការខូចខាត............................................ ១៧២

៤.៣. ការធានាបំណុលអណ្ដែត............................................ ១៧២

៥. សិទ្ធិទាមទារសំណង............................................ ១៧៣

៥.១. លក្ខខណ្ឌនៃការទាមទារសំណង............................................ ១៧៣

៥.២. ទំហំនៃការទាមទារសំណង ............................................ ១៧៤

៥.៣. ការទាមទារសំណងជាមុន............................................ ១៧៤

៥.៤. សិទ្ធិទាមទាររបស់អ្នកធានារួម............................................ ១៧៤

៦. ឧបាទេសកម្ម............................................ ១៧៥

**ឧបសម្ព័ន្ធ**

# ជំពូកទី ៤

# កិច្ចសន្យាសំខាន់ៗ

## ផ្នែកទី ១

## កិច្ចសន្យាលក់ទិញ

### ១. គោលគំនិត

មាត្រា ៥១៥ នៃក្រមរដ្ឋប្បវេណីបានចែងថា : កិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា "អ្នកលក់" មានករណីយកិច្ចត្រូវផ្ទេរនូវកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិទៅឱ្យភាគីម្ខាងទៀត ហៅថា "អ្នកទិញ" ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឱ្យអ្នកលក់វិញ។

ផ្អែកតាមមាត្រានេះ យើងឃើញថា អ្នកលក់ និង អ្នកទិញ មានករណីយកិច្ចចំពោះគ្នាទៅវិញទៅមក ហើយចំពោះអ្នកលក់ មិនត្រឹមតែមានករណីយកិច្ចត្រូវផ្ទេរនូវកម្មសិទ្ធិប៉ុណ្ណោះទេ គឺត្រូវផ្ទេរសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិទៅឱ្យអ្នកទិញ ប្រសិនបើសិទ្ធិនោះមានដូចជា : សិទ្ធិជួលអចិន្ត្រៃយ៍ (មាត្រា ២៥២) និង សិទ្ធិលើបំណុល (មាត្រា ៥០១) ជាដើម។

កិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាដែលយកតម្លៃថ្នូរ និង ជាកិច្ចសន្យាទ្វេភាគី។

បញ្ញត្តិនៃកិច្ចសន្យាលក់ទិញ ត្រូវយកមកអនុវត្តដូចគ្នា ចំពោះកិច្ចសន្យាដែលយកតម្លៃថ្នូរ ក្រៅពីកិច្ចសន្យាលក់ទិញ ដូចជា កិច្ចសន្យាដូរ ភតិសន្យា កិច្ចសន្យាម៉ៅការ និង កិច្ចសន្យាការងារ ជាអាទិ៍ (មាត្រា ៥២៣)។

### ២. លក្ខខណ្ឌ

#### ២.១. ការព្រមព្រៀង

ជាគោលការណ៍ ឱ្យតែមានការព្រមព្រៀងគ្នារវាងគូភាគី នោះកិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើត ឡើងបាន ហើយគូភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬ លិខិតឯកជនជាលក្ខខណ្ឌសម្រាប់បង្កើតកិច្ចសន្យា តាមការជ្រើសរើសរបស់ខ្លួនក៏បាន ប៉ុន្តែមានករណីលើកលែង ដែលមានបញ្ញត្តពិសេសនៅក្នុងច្បាប់។ ឧទាហរណ៍ កិច្ចសន្យាលក់ទិញអចលនវត្ថុ នៅក្នុងមាត្រា ៣៣៦ កថាខណ្ឌទី ២ បានកំណត់ថាកិច្ចសន្យាលក់ទិញអចលនវត្ថុត្រូវធ្វើដោយលិខិតយថាភូត។ ដូចនេះ នៅក្នុងករណីនៃកិច្ចសន្យាលក់ទិញអចលនវត្ថុ ការព្រមព្រៀងរវាងគូភាគី តែមួយនោះពុំមានអានុភាពទេ ទាល់តែគូភាគីធ្វើជាលិខិតយថាភូត។

#### ២.២. ថ្លៃលក់ទិញដែលត្រូវបានកំណត់

នៅក្នុងកិច្ចសន្យាលក់ទិញ ភាគីនៃកិច្ចសន្យាត្រូវកំណត់ចំនួនប្រាក់នៃថ្លៃលក់ទិញ ឬ វិធីកំណត់ចំនួនប្រាក់នោះនៅក្នុងកិច្ចសន្យា។ ចំនួនប្រាក់នៃថ្លៃលក់ទិញ អាចត្រូវបានកំណត់ដោយយោងទៅលើតម្លៃនៃទំនិញណាមួយ

លើទីផ្សារក្នុងពេលបច្ចុប្បន្ន ឬ ពេលអនាគត ឬ ដោយផ្អែកលើការវាយតម្លៃដែលធ្វើដោយតតិយជន ដែលត្រូវបានជ្រើសរើសតាមរបៀបកំណត់ដោយគូភាគី។ ក្នុងករណីដែលការវាយតម្លៃរបស់តតិយជន ត្រូវបានធ្វើឡើងដោយកាន់ច្រឡំ ឬ ករណីដែលការវាយតម្លៃនោះច្បាស់ជាផ្ទុយនឹងគោលការណ៍នៃភាពយុត្តិធម៌ ភាគីនៃកិច្ចសន្យាដែលទទួលរងការខូចខាតផលប្រយោជន៍របស់ខ្លួន ដោយសារការវាយតម្លៃនោះ អាចតវ៉ាចំពោះការវាយតម្លៃនោះបាន (មាត្រា ៥២១)។

ថ្លៃលក់ទិញ ជាកត្តាមួយសំខាន់ណាស់នៅក្នុងកិច្ចសន្យាលក់ទិញ ដូចនេះ កិច្ចសន្យានឹងមិនកើតមានឡើយ បើមិនកំណត់នូវថ្លៃលក់ទិញ។ ម្យ៉ាងទៀត ភាគីនៃកិច្ចសន្យាក៏អាចកំណត់ចំនួនថ្លៃលក់ទិញ ដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ ឬ ដោយឱ្យអ្នកទិញបង់ធនលាភដែលមិនកំណត់ពេល ឬ ធនលាភមួយជីវិតបាន។ ឧទាហរណ៍ លក់ដី ដែលឱ្យបង់ប្រាក់ដោយភាគរហូតដល់អ្នកលក់ពេញចិត្ត ឬ មរណភាពរបស់អ្នកលក់ ឬ អ្នកទិញ។ ក្នុងករណីនេះ តតិយជនដែលត្រូវបានជ្រើសរើសដោយវិធីដែលបានកំណត់ដោយគូភាគី អាចកំណត់នូវចំនួននៃថ្លៃលក់ទិញបាន ប៉ុន្តែ ថ្លៃលក់ទិញនេះ ត្រូវបានកំណត់ដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ លើកលែងតែករណីដែលគូភាគីប្រគល់សិទ្ធិទៅឱ្យតតិយជនដោយជាក់លាក់ (មាត្រា ៥២១ កថាខណ្ឌទី ៣)។

### ២.៣. សោហ៊ុយក្នុងការលក់ទិញ

ក្នុងការធ្វើកិច្ចសន្យាលក់ទិញ ភាគីទាំងសងខាងត្រូវចេញស្មើគ្នានូវសោហ៊ុយធ្វើលិខិត ឬ សោហ៊ុយផ្សេងៗ ដែលត្រូវចំណាយ ក្នុងការធ្វើកិច្ចសន្យាលក់ទិញលើកលែងតែមានការកំណត់ផ្សេងរបស់គូភាគី (មាត្រា ៥២២)។ ឧទាហរណ៍ សោហ៊ុយក្នុងការជួលមេធាវី ធ្វើឯកសារកិច្ចសន្យាលក់ទិញ គឺជាសោហ៊ុយក្នុងការលក់ទិញ។

ចំពោះសោហ៊ុយ សម្រាប់នីតិវិធីចាំបាច់ដើម្បីឱ្យអ្នកទិញ បានធ្វើលទ្ធកម្មនូវសិទ្ធិដោយពិតប្រាកដ ដូចជាការចុះបញ្ជី ដែលជាលក្ខខណ្ឌតតាំងនៃការផ្ទេរសិទ្ធិប្រត្យក្ស ដែលនេះជាសោហ៊ុយសម្រាប់អនុវត្តកាតព្វកិច្ចមិនមែនជាសោហ៊ុយសម្រាប់បង្កើតកិច្ចសន្យាទេ ហេតុនេះបើគ្មានការព្រមព្រៀងរវាងភាគីទេ នេះជាបន្ទុករបស់អ្នកលក់ (តាមមាត្រា ៤៤៦ សោហ៊ុយនៃការសង)។ សោហ៊ុយនៃការសង ជាសោហ៊ុយសម្រាប់ចាយវាយក្នុងការអនុវត្តកាតព្វកិច្ច។

មូលហេតុដែលសោហ៊ុយក្នុងការលក់ទិញ ត្រូវជាបន្ទុកស្មើគ្នារបស់គូភាគី គឺដោយសារកិច្ចសន្យាលក់ទិញត្រូវធ្វើឡើងសម្រាប់ផលប្រយោជន៍របស់ភាគីទាំងសងខាង។

## ៣. ករណីយកិច្ច និង សិទ្ធិរបស់អ្នកលក់

នៅក្នុងកិច្ចសន្យាលក់ទិញ ភាគីទាំងសងខាងត្រូវមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក ព្រោះកិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាទ្វេភាគី។

## ៣.១. ករណីយកិច្ចទូទៅរបស់អ្នកលក់

### ៣.១.១. ករណីយកិច្ចទូទៅ

ករណីយកិច្ចទូទៅរបស់អ្នកលក់ មានចែងចាប់ពីមាត្រា ៥២៩ ដល់មាត្រា ៥៣១ និង ពីមាត្រា ៥៤៩ ដល់មាត្រា ៥៥៣ នៃក្រមរដ្ឋប្បវេណី។ ករណីយកិច្ចទាំងនោះ មានដូចតទៅ :

#### ក. ករណីយកិច្ចផ្ទេរសិទ្ធិ

អ្នកលក់ត្រូវមានករណីយកិច្ចផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ ដែលខ្លួនបានលក់ (មាត្រា ៥៣០)។ ការផ្ទេរកម្មសិទ្ធិនេះ នាំឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធិករនៃទ្រព្យផងដែរ។

ការផ្ទេរកម្មសិទ្ធិ គឺជាករណីយកិច្ចដ៏សំខាន់នៅក្នុងកិច្ចសន្យាលក់ទិញ ពីព្រោះកិច្ចសន្យាលក់ទិញធ្វើឡើងក្នុងគោលបំណង ដើម្បីផ្ទេរកម្មសិទ្ធិពីអ្នកលក់ទៅឱ្យអ្នកទិញ ដូចនេះ អ្នកលក់មានករណីយកិច្ចត្រូវតែផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញទៅឱ្យអ្នកទិញ (មាត្រា ៥៣១ កថាខណ្ឌទី ១)។ ការផ្ទេរកម្មសិទ្ធិក្នុងកិច្ចសន្យាលក់ទិញត្រូវអនុវត្តតាមគោលការណ៍ទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ១៣៣ មាត្រា ១៣៤ មាត្រា ១៣៥ មាត្រា ១៦០ និង មាត្រា ១៨៧ លើកលែងតែកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ជាសិទ្ធិលើ ទ្រព្យសម្បត្តិក្រៅពីកម្មសិទ្ធិ ដែលការផ្ទេរសិទ្ធិទាំងនោះត្រូវអនុវត្តតាមគោលការណ៍ទូទៅ ដែលទាក់ទងនឹងការផ្ទេរសិទ្ធិនីមួយៗនោះ (មាត្រា ៥២៨ កថាខណ្ឌទី ១)។

ដូចនេះ ជារួមមក សិទ្ធិដែលខ្លួនបានលក់ត្រូវបានផ្ទេរ ដូចនៅក្នុងករណីខាងក្រោម :

- កិច្ចសន្យាលក់ទិញលើកម្មសិទ្ធិនៃអចលនវត្ថុ : នៅពេលផ្ទេរ ការចុះបញ្ជីត្រូវបានធ្វើឡើង
- កិច្ចសន្យាលក់ទិញក្រៅពីកម្មសិទ្ធិនៃអចលនវត្ថុ : នៅពេលព្រមព្រៀង។

#### ខ. ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ

ការប្រគល់វត្ថុ ត្រូវបានធ្វើឡើងតាមវិធីច្រើនយ៉ាងដូចខាងក្រោម (មាត្រា ៥៥០ វាក្យខណ្ឌទី ១ និង មាត្រា ២២៩) :

- ការប្រគល់ជាក់ស្តែង
- ការប្តូរលក្ខណៈនៃការកាន់កាប់
- ការប្រគល់ដោយសង្ខេប
- ការផ្ទេរការកាន់កាប់ដោយបញ្ជា

ទន្ទឹមនឹងនេះ មាត្រា ៥៥០ វាក្យខណ្ឌទី ២ ក៏បានចែងដូចខាងក្រោម :

- ការប្រគល់ជាពិសេសសម្រាប់អចលនវត្ថុ : ការប្រគល់សោនៃអាគារ ឬ ប្រគល់ប័ណ្ណបញ្ជាក់សិទ្ធិ។

"ប័ណ្ណបញ្ជាក់សិទ្ធិ" សំដៅទៅលើឯកសារ ដែលបញ្ជាក់ពីសិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់វត្ថុនោះ ។ "សិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត" សំដៅទៅលើសិទ្ធិ ដែលធ្វើឱ្យការក្តាប់ទុកវត្ថុមានភាពត្រឹមត្រូវតាមច្បាប់ ដូចជា កម្មសិទ្ធិ សិទ្ធិជួល ( មាត្រា ២៤១ កថាខណ្ឌទី ១) ។ ឧទាហរណ៍ ប័ណ្ណសម្គាល់កម្មសិទ្ធិ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អាចត្រូវបានចាត់ទុកថាជា "ប័ណ្ណបញ្ជាក់សិទ្ធិ" ។

### គ. ករណីយកិច្ចរក្សាទុកវត្ថុដែលជាកម្មវត្ថុ

អ្នកលក់ត្រូវមានករណីយកិច្ចថែរក្សាទុកវត្ថុ ដែលជាកម្មវត្ថុនៃការលក់ទិញ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះទៅឱ្យអ្នកទិញ ( មាត្រា ៥៥២ កថាខណ្ឌទី ១) ។ ក្នុងករណីដែលអ្នកលក់ធ្វើឱ្យបាត់បង់ ឬ ធ្វើឱ្យខូចខាតកម្មវត្ថុដោយសារខ្លួនធ្វេសប្រហែស អ្នកលក់ត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាត ( មាត្រា ៥៥២ កថាខណ្ឌទី ២) ។ ផ្ទុយទៅវិញ ប្រសិនបើការខូចខាតដោយករណីប្រធានសក្តិ នោះអ្នកលក់ត្រូវរួចផុតពីការទទួលខុសត្រូវ ។

### ឃ. ករណីយកិច្ចប្រគល់លិខិតផ្សេងៗ ដែលចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ

អ្នកលក់មានកាតព្វកិច្ចត្រូវប្រគល់រាល់លិខិតផ្សេងៗ ដែលចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ ( មាត្រា ៥៣០) ។ "លិខិតផ្សេងៗ ដែលចាំបាច់ដើម្បីបញ្ជាក់សិទ្ធិ" គឺជាប័ណ្ណបញ្ជាក់សិទ្ធិដែលមានចែងនៅក្នុងមាត្រា ៥៥០ លិខិតកិច្ចសន្យា ឬ ឯកសារចាំបាច់សម្រាប់ចុះបញ្ជី ។

## ៣.១.២. សិទ្ធិទូទៅ

### ក. សិទ្ធិទាមទារឱ្យបង់ប្រាក់ថ្លៃទិញ

បើអ្នកទិញមិនទាន់បង់ប្រាក់ទៅឱ្យអ្នកលក់ទេ នោះអ្នកលក់មានសិទ្ធិទាមទារប្រាក់ថ្លៃទិញបាន ។

### ខ. ការតវ៉ា

#### ការតវ៉ាឱ្យអនុវត្តព្រមគ្នា

អ្នកលក់អាចប្រកែកមិនព្រមផ្ទេរសិទ្ធិដែលជាកម្មវត្ថុ និង មិនព្រមប្រគល់វត្ថុដែលជាកម្មវត្ថុទៅអ្នកទិញ បានរហូតដល់អ្នកទិញបានផ្តល់ការសង ចំពោះកាតព្វកិច្ចបង់ថ្លៃលក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកទិញ ពុំទាន់ដល់ពេលកំណត់ត្រូវសង ឬ ករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តករណីយកិច្ចផ្ទេរសិទ្ធិ ឬ កាតព្វកិច្ចប្រគល់ជាមុន ។

#### ការតវ៉ាដោយមានការបារម្ភ

មាត្រា ៥៥១ កថាខណ្ឌទី ២ បានចែងយ៉ាងលម្អិតទៅលើមាត្រា ៣៨៧ ។ អត្ថន័យនៃឃ្លា "អ្នកលក់បានអនុញ្ញាតឱ្យអ្នកទិញមានពេលកំណត់ ដើម្បីសងថ្លៃកម្មវត្ថុ" គឺថា អ្នកលក់បានអនុញ្ញាតឱ្យបង់ក្រោយពេលធ្វើការប្រគល់ចលនវត្ថុ ។

### គ. សិទ្ធិទទួលផល

លើកលែងតែមានការព្រមព្រៀងគ្នា អ្នកលក់អាចទទួលបានផលធម្មជាតិ ឬ ផលស៊ីវិល នៅមុនពេលប្រគល់។ មាត្រានេះ រក្សានូវតុល្យភាពរវាងមាត្រា ៥៥៦ ដែលបញ្ញត្តថា អ្នកទិញមិនចាំបាច់បង់ការប្រាក់នៃថ្លៃទិញរហូតដល់គាត់ទទួលនូវការប្រគល់វត្ថុដែលជាកម្មវត្ថុ។

### ៣.២. ករណីយកិច្ចត្រូវពន្យល់

អ្នកលក់មានកាតព្វកិច្ចត្រូវពន្យល់ឱ្យបានច្បាស់លាស់ អំពីព័ត៌មានសំខាន់ទាក់ទងនឹងកម្មវត្ថុ (មាត្រា ៥២៩)។ "ខ្លឹមសារនៃកាតព្វកិច្ច ដែលត្រូវទទួលបន្ទុកដោយអ្នកលក់" សំដៅទៅលើឧទាហរណ៍ដូចជា ថាតើអ្នកលក់ធានាថា វត្ថុដែលជាកម្មវត្ថុនៃការលក់នោះ ត្រូវស្របនឹងគោលបំណងធម្មតាក្នុងអំឡុងពេលដែលបានកំណត់ក្រោយការប្រគល់ (មាត្រា ៥៤០ កថាខណ្ឌទី ៣) ឬ អ្នកលក់ធានានូវភាពត្រឹមត្រូវនៃទំហំដែលបានបញ្ជាក់ (មាត្រា ៥៤៦ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ជាអាទិ៍។

ប្រសិនបើអ្នកលក់បំពានលើករណីយកិច្ចនេះ ហើយធ្វើឱ្យមានការខូចខាតនោះ អ្នកលក់ត្រូវទទួលខុសត្រូវសងនូវសំណងការខូចខាត។ នៅក្នុងករណីដែលអ្នកលក់ប្រាប់នូវហេតុផលមិនពិត ឬ លាក់បាំងនូវហេតុពិតប្រាកដដោយចេតនា ហើយអ្នកទិញបានបង្ហាញឆន្ទៈ ដោយផ្អែកទៅលើការយល់ច្រឡំនេះ នោះអ្នកទិញអាចរំលាយកិច្ចសន្យាលក់ទិញ ដោយផ្អែកលើមាត្រាដែលទាក់ទងនឹងវិការៈនៅក្នុងការបង្ហាញឆន្ទៈ។

### ៣.៣. ករណីយកិច្ចផ្ទេរសិទ្ធិ

ករណីយកិច្ចដែលសំខាន់បំផុតរបស់អ្នកលក់ គឺជាករណីយកិច្ចផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតនៅលើទ្រព្យសម្បត្តិទៅឱ្យអ្នកទិញ (មាត្រា ៥៣១ កថាខណ្ឌទី ១)។

ទោះបីជាអ្នកលក់បានលក់នូវកម្មវត្ថុ ដែលជាកម្មសិទ្ធិរបស់តតិយជននោះ កិច្ចសន្យាលក់ទិញនោះផ្ទាល់ គឺមានសុពលភាព ព្រោះវាអាចមានលទ្ធភាពដែលអ្នកលក់អាចធ្វើលទ្ធកម្មលើសិទ្ធិនោះ ហើយផ្ទេរសិទ្ធិនោះទៅឱ្យអ្នកទិញ។

ឧទាហរណ៍ វាអាចមានលទ្ធភាពដែល **ក** លក់រថយន្តឱ្យទៅ **ខ** ដែលរថយន្តនោះ គឺជាកម្មសិទ្ធិរបស់ **គ**។ ក្នុងករណីនេះ **ក** មានកាតព្វកិច្ចត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើរថយន្តនោះពី **គ** ហើយផ្ទេរសិទ្ធិនោះទៅឱ្យ **ខ**។ ប្រសិនបើ **ក** មិនអាចផ្ទេរកម្មសិទ្ធិលើរថយន្តនោះបានទេ **ក** ត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច។

## ៤. ការទទួលខុសត្រូវក្នុងការធានា

សូមមើលឧបសម្ព័ន្ធ **៤**

## ៤.១. ទិដ្ឋភាពទូទៅនៃការទទួលខុសត្រូវក្នុងការធានា

ការទទួលខុសត្រូវក្នុងការធានា គឺជាប្រព័ន្ធមួយដែលផ្ដល់ឱ្យភាគីនូវប្រតិបត្តិការជំនួញមួយ ដែលមានភាពយុត្តិធម៌ ព្រោះកិច្ចសន្យាលក់ទិញ គឺជាការដោះដូររវាងទ្រព្យសម្បត្តិ និង ប្រាក់ដែលមានតម្លៃស្មើគ្នា។

ឧទាហរណ៍ នៅក្នុងករណីដែលអ្នកទិញបានរកឃើញថា កម្មវត្ថុមានវិការៈបន្ទាប់ពីការបង់ប្រាក់ និង ការប្រគល់ នោះវានឹងមានភាពអយុត្តិធម៌ ប្រសិនបើអ្នកទិញមិនអាចទាមទារអ្វីបានទាល់តែសោះពីអ្នកលក់។ ប្រាក់ថ្លៃទិញ និង តម្លៃនៃកម្មវត្ថុនៅក្នុងកិច្ចសន្យាលក់ទិញ គឺមានតម្លៃស្មើគ្នា។ ដូច្នេះ ក្រមរដ្ឋប្បវេណីបានចែងពីការទទួលខុសត្រូវនៅក្នុងការធានា ដើម្បីកែតម្រូវវិសមភាពនេះ។

## ៤.២. ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់ ក្នុងករណីដែលសិទ្ធិដែលត្រូវបានលក់ជាសិទ្ធិរបស់អ្នកដទៃ

### ៤.២.១. នៅក្នុងករណីដែលសិទ្ធិទាំងមូលជាសិទ្ធិរបស់តតិយជន

**១. អ្វីដែលអ្នកទិញអាចទាមទារបាន ប្រសិនបើអ្នកលក់មិនអាចទទួលបាននូវសិទ្ធិ គឺ :**

***ក. អ្នកទិញមានសិទ្ធិរំលាយកិច្ចសន្យា :*** ប្រសិនបើអ្នកលក់មិនអាចអនុវត្តករណីយកិច្ចផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការលក់ទិញទៅឱ្យអ្នកទិញបាន។ ម្យ៉ាងទៀត ទោះបីអ្នកទិញបានដឹង ឬ មិនបានដឹងនៅពេលធ្វើកិច្ចសន្យាថា អ្នកលក់មិនមែនជាកម្មសិទ្ធិករលើវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញក៏ដោយ ក៏អ្នកទិញនោះអាចទាមទារឱ្យរំលាយកិច្ចសន្យានេះបានដែរ (ចែងក្នុងមាត្រា ៥៣១ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១)។

***ខ. ករណីអ្នកទិញមានភាពសុចរិត :*** អ្នកទិញក៏អាចទាមទារសំណងនៃការខូចខាត គ្រាន់តែបង្ហាញថាពេលធ្វើកិច្ចសន្យាខ្លួនមិនបានដឹងថា សិទ្ធិដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ មិនមែនជាសិទ្ធិរបស់អ្នកលក់ទេ។ ក្រៅពីសិទ្ធិរំលាយកិច្ចសន្យា អ្នកទិញអាចទាមទារសំណងនៃការខូចខាតបាន (ចែងក្នុងមាត្រា ៥៣១ កថាខណ្ឌ ទី ៣ វាក្យខណ្ឌទី ២)។

**២. អ្វីដែលអ្នកលក់សុចរិតអាចធ្វើបាន គឺ :**

អ្នកលក់មានករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុ ដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញនោះ ហើយផ្ទេរកម្មសិទ្ធិនោះទៅឱ្យអ្នកទិញ ។ ប៉ុន្តែ ប្រសិនបើអ្នកលក់មិនអាចធ្វើបានទេ នោះអ្នកលក់អាចរំលាយកិច្ចសន្យាដើម្បីរួចផុតពីករណីយកិច្ចផ្ទេរសិទ្ធិនោះបានតែក្នុងករណីដែល ***"អ្នកលក់សុចរិត"*** ប៉ុណ្ណោះ។ ដូច្នេះ អ្នកលក់សុចរិតមានករណីយកិច្ចទទួលសិទ្ធិជាអាទិ៍ :

- ***អ្នកលក់សុចរិត*** អាចរំលាយកិច្ចសន្យានោះបាន តែត្រូវសងការខូចខាត (មាត្រា ៥៣២ កថាខណ្ឌ ទី ១)។
- ***អ្នកលក់សុចរិត*** អាចរំលាយកិច្ចសន្យានោះបាន ដោយមិនចាំបាច់សងការខូចខាតទេ ប្រសិនបើអ្នកទិញបានដឹងនៅពេលធ្វើកិច្ចសន្យាថា សិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទិញ មិនមែនជាសិទ្ធិរបស់អ្នកលក់ទេ (មាត្រា ៥៣២ កថាខណ្ឌទី ២)។

### ៤.២.២. ក្នុងករណីដែលសិទ្ធិមួយភាគ គឺជាសិទ្ធិរបស់តតិយជន

ក្នុងករណីសិទ្ធិមួយភាគក្នុងចំណោមសិទ្ធិ ដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ គឺជាសិទ្ធិរបស់អ្នកដទៃ ហើយបើអ្នកលក់មិនអាចទទួលសិទ្ធិនៃភាគនោះដើម្បីផ្ទេរឱ្យទៅអ្នកទិញបានទេ ករណីនេះគឺជាការមិនអនុវត្តកាតព្វកិច្ចមួយភាគរបស់អ្នកលក់។ ដូច្នេះ បញ្ញត្តិនៃការមិនអនុវត្តកាតព្វកិច្ចត្រូវយកមកអនុវត្ត។ ក៏ប៉ុន្តែ ប្រសិនបើអ្នកទិញអាចសម្រេចគោលបំណងនៃកិច្ចសន្យា វាមិនមានលក្ខណៈសមរម្យក្នុងការទទួលស្គាល់ឱ្យរំលាយកិច្ចសន្យាទាំងមូលនោះ។ ដូច្នេះ ការទទួលខុសត្រូវក្នុងការធានាចំពោះករណីដែលសិទ្ធិមួយភាគជាសិទ្ធិរបស់អ្នកដទៃមានជាអាទិ៍ :

- ***អ្នកលក់*** ត្រូវមានកាតព្វកិច្ចទទួលនូវសិទ្ធិដែលនៅខ្វះ ហើយត្រូវផ្ទេរទៅឱ្យអ្នកទិញ ( មាត្រា ៥៣១)

- ***អ្នកទិញ*** អាចទាមទារឱ្យបន្ថយនូវតម្លៃតាមសមាមាត្រទៅនឹងភាគដែលខ្វះនោះ ប្រសិនបើអ្នកលក់មិនអាចទទួលបាននូវសិទ្ធិនោះ ហើយមិនអាចផ្ទេរទៅឱ្យអ្នកទិញ ( មាត្រា ៥៣៣ កថាខណ្ឌទី ១) ។

- ***អ្នកទិញសុចរិត*** អាចរំលាយកិច្ចសន្យាបាន ប្រសិនបើធ្វើការវិនិច្ឆ័យថា អ្នកទិញនឹងមិនទិញតែភាគដែលសល់តែប៉ុណ្ណោះ ( មាត្រា ៥៣៣ កថាខណ្ឌទី ២) ។

- ***អ្នកទិញសុចរិត*** អាចទាមទារសំណងនៃការខូចខាត ( មាត្រា ៥៣៣ កថាខណ្ឌទី ៣) ។

***សិទ្ធិ*** ដែលបានបញ្ញត្តនៅក្នុងមាត្រា ៥៣៣ កថាខណ្ឌទី ១ ទី ២ និង ទី ៣ ត្រូវអនុវត្តក្នុងអំឡុងពេល ១ ឆ្នាំ គិតចាប់ពីពេលដែលអ្នកទិញបានដឹងការណ៍នោះ ប្រសិនបើអ្នកទិញ គឺជាជនសុចរិត ឬ ក្នុងអំឡុងពេល ១ ឆ្នាំ គិតចាប់ពីពេលធ្វើកិច្ចសន្យា ប្រសិនបើអ្នកទិញបានដឹងថា សិទ្ធិមួយភាគជាសិទ្ធិរបស់អ្នកតតិយជន ( មាត្រា ៥៣៣ កថាខណ្ឌទី ៤) សម្រាប់ជាប្រយោជន៍នៃការដោះស្រាយវិវាទឱ្យបានលឿន ។ ម្យ៉ាងទៀត មាត្រា ៥៣៣ កថាខណ្ឌទី ៤ បានកំណត់អំឡុងពេលសម្រាប់ប្រើសិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់ទិញ សិទ្ធិរំលាយ និង សិទ្ធិទាមទារសំណងនៃការខូចខាត មានរយៈពេលខ្លីជាងករណីធម្មតានៃការទទួលខុសត្រូវ ចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យានោះផងដែរ ។

## ៤.៣. ការទទួលខុសត្រូវក្នុងការធានាចំពោះវិការៈ

### ៤.៣.១. បញ្ញត្តិទូទៅ

***អ្នកលក់*** ត្រូវមានកាតព្វកិច្ចប្រគល់វត្ថុដែលគ្មានវិការៈទៅឱ្យអ្នកទិញ ( មាត្រា ៥៣៩ កថាខណ្ឌទី ១) ។ វត្ថុដែលបានប្រគល់ទៅឱ្យអ្នកទិញត្រូវចាត់ទុកថាមានវិការៈ ប្រសិនវាត្រូវនឹងចំណុចដែលមានចែងក្នុងមាត្រា ៥៣៩ កថាខណ្ឌទី ២ លើកលែងតែគូភាគីបានកំណត់ផ្សេង។ ក្នុងករណីនេះ ***អ្នកទិញ*** ត្រូវទទួលបានការទទួលខុសត្រូវក្នុងការធានាពីអ្នកលក់ចំពោះវត្ថុទិញដែលមានវិការៈ។ ម្យ៉ាងទៀត អ្នកទិញអាចទាមទារសំណងនៃការខូចខាតបាន ប្រសិនបើអ្នកលក់មានកំហុសចំពោះការខូចខាតនេះ ដោយផ្អែកលើមាត្រា ៣៩៨ (លក្ខខណ្ឌនៃការ

ទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត) ដែលចែងអំពីការមិនអនុវត្តកាតព្វកិច្ច។ ដោយផ្អែកចាប់ពីមាត្រា ៥៤០ ដល់មាត្រា ៥៤៧ អ្នកទិញអាចទាមទារការអនុវត្តពេញលេញចំពោះអ្នកលក់ មានដូចជា :

- ប្រគល់នូវវត្ថុជំនួស
- កាត់បន្ថយតម្លៃ
- ជួសជុលវិការៈ និង
- រំលាយកិច្ចសន្យា ជាដើម ។

ក៏ប៉ុន្តែ ***អ្នកលក់*** មិនទទួលខុសត្រូវក្នុងការធានាទេ ប្រសិនបើអ្នកទិញបានទិញកម្មវត្ថុ ដោយបានដឹងអំពីអត្ថិភាពនៃវិការៈ ឬ ក៏មិនបានដឹងដោយមានកំហុសធ្ងន់ធ្ងរ (មាត្រា ៥៤០ កថាខណ្ឌទី ៤)។ វាមានន័យថា ***អ្នកទិញ*** ត្រូវពិនិត្យពិច័យនូវរាល់វិការៈនៃវត្ថុទិញ ដែលមានលក្ខណៈងាយស្រួលនឹងរកឃើញ មានដូចជា : មើលឃើញនឹងភ្នែក និង បានដឹងមុនថា វត្ថុដែលជាកម្មវត្ថុទិញនោះមានវិការៈ។ ប៉ុន្តែ អ្នកទិញពុំបានពិនិត្យដោយខ្លួនឯងផ្ទាល់ នោះចាត់ទុកថា អ្នកទិញដែលមិនបានដឹងអំពីវិការៈនោះដោយមានកំហុសធ្ងន់ធ្ងរ ហើយក៏មិនអាចរំលាយកិច្ចសន្យាបានទេ ដូច្នេះ គាត់ក៏មិនអាចទាមទារឱ្យអ្នកលក់ទទួលខុសត្រូវក្នុងការធានាវិការៈនេះដែរ ។

### ១. គោលគំនិតនៃវិការៈ

***វិការៈ*** នៅក្នុងការទទួលខុសត្រូវក្នុងការធានាវិការៈ ជាទូទៅគឺសំដៅទៅលើរាល់ចំណុច ដែលមានបញ្ញត្តនៅក្នុងមាត្រា ៥៣៩ កថាខណ្ឌទី ២។ វាមិនអាចត្រូវបានលុបចោលទេ ប្រសិនបើចំណុចនៅក្នុងមាត្រា ៥៣៩ កថាខណ្ឌទី ២ ត្រូវបានទទួលស្គាល់[១] ។ ក៏ប៉ុន្តែ រាល់ចំណុចនៅក្នុងកថាខណ្ឌទី ២ មាត្រា ៥៣៩ គឺគ្រាន់តែជាឧទាហរណ៍នៃ "វិការៈ" តែប៉ុណ្ណោះ ដូច្នេះ វាអាចមានភាពមិនសមស្របដទៃទៀត ដែលក្រៅពីចំណុចនីមួយៗនៅក្នុងកថាខណ្ឌនេះ ត្រូវបានគេទទួលស្គាល់ថាជា "វិការៈ"។

### ២. ពេលវេលានៃការកើតឡើងនៃវិការៈ

ការទទួលខុសត្រូវក្នុងការធានាវិការៈ កើតឡើងនៅក្នុងករណីដែលគូភាគី មិនបានដឹងពីអត្ថិភាពនៃវិការៈនៅពេលផ្ទេរនូវហានិភ័យ ( ជាធម្មតានៅពេលធ្វើការប្រគល់ )។ ឧទាហរណ៍ **ខ** បានទិញអង្ករ ១០ គីឡូក្រាមពី **ក** ប៉ុន្តែ អង្ករ ៥ គីឡូក្រាមនៅក្នុងនោះ គឺខូចរលួយនៅពេលប្រគល់។ ក្នុងករណីនេះ **ក** ត្រូវទទួលខុសត្រូវក្នុងការធានាវិការៈ ដោយផ្អែកទៅលើមាត្រា ៥៤០ ទោះបីជាគាត់បានទុកអង្ករនោះ ដោយគ្មានកំហុសក៏ដោយ ។

***អ្នកលក់*** ត្រូវទទួលខុសត្រូវក្នុងការធានាវិការៈ ក្នុងករណីដែលវិការៈកើតឡើងដោយសារតែការបំពានកាតព្វកិច្ចរបស់អ្នកលក់ ទោះបីជាវិការៈកើតឡើងក្រោយការផ្ទេរហានិភ័យក៏ដោយ ( មាត្រា ៥៤០ កថាខណ្ឌទី ២)។

---

១. សម្រាប់ជាព័ត៌មានបន្ថែម ចំណុច **គ** ត្រូវបានបញ្ញត្ត "ចំពោះអ្នកលក់" គឺមិនមែន "ចំពោះអ្នកទិញ" នៅក្នុងពង្រាងច្បាប់ដើមជាភាសាជប៉ុន ។ ដូច្នេះ ចំណុចនេះ នឹងត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

### ៣. សិទ្ធិជួសជុលរបស់អ្នកលក់

***អ្នកលក់*** អាចជួសជុលវិការៈ ប្រសិនបើគាត់បានប្រគល់វត្ថុនៅមុនពេលកំណត់ត្រូវប្រគល់ លុះត្រាតែមិនបណ្តាលឱ្យមានការខូចខាតផលប្រយោជន៍ហួសហេតុរបស់អ្នកទិញ ( មាត្រា ៥៤១ កថាខណ្ឌទី១) ។ ក្នុងករណីនេះ ទោះបីជាសិទ្ធិជួសជុលវិការៈរបស់អ្នកលក់ត្រូវបានអនុវត្តក៏ដោយ ក៏អ្នកទិញអាចទាមទារសំណងការខូចខាតបាន ប្រសិនបើមាន ( មាត្រា ៥៤១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

ម្យ៉ាងទៀត ***អ្នកលក់*** អាចជួសជុលវិការៈដោយចេញចំណាយដោយខ្លួនឯងបាន ទោះបីជាក្រោយពេលកំណត់ត្រូវប្រគល់ក៏ដោយ លុះត្រាតែមិនបណ្តាលឱ្យមានការខូចខាតផលប្រយោជន៍ហួសហេតុរបស់អ្នកទិញ ( មាត្រា ៥៤១ កថាខណ្ឌទី ២) ។ ហើយនៅក្នុងករណីនេះ ***អ្នកទិញ*** មានសិទ្ធិរំលាយកិច្ចសន្យា ( មាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច **ក**) និង សិទ្ធិទាមទារសំណងនៃការខូចខាត ( មាត្រា ៥៤៥) ដោយចាត់ទុកថា គឺការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ និង ជាការអនុវត្តកាតព្វកិច្ចមិនបានពេញលេញនៅកាលបរិច្ឆេទប្រគល់ ។

### ៤.៣.២. ខ្លឹមសារនៃការទទួលខុសត្រូវ

### ១.ករណីយកិច្ចប្រគល់វត្ថុជំនួស

ក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាលក់ទិញមានវិការៈ អ្នកលក់ត្រូវមានកាតព្វកិច្ចប្រគល់វត្ថុជំនួស ដែលគ្មានវិការៈឱ្យទៅអ្នកទិញសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ។ ក៏ប៉ុន្តែ ប្រសិនបើការរៀបចំវត្ថុដែលមានប្រភេទដូចគ្នានឹងបង្កើតបន្ទុកមិនសមរម្យហួសហេតុដល់អ្នកលក់ នោះអ្នកលក់នឹងមិនមានករណីយកិច្ចប្រគល់វត្ថុជំនួសឡើយ ( មាត្រា ៥៤២ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ប៉ុន្តែ អ្នកលក់ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាត ចំពោះអ្នកទិញ ( មាត្រា ៥៤៥) ។ ឧទាហរណ៍ នៅក្នុងករណីដែល **ខ** បានទិញរថយន្តក្លាសិក ដែលមានតម្លៃខ្ពស់ដែលជាប្រភេទមួយក្នុងចំណោមរថយន្តដែលមានតែពីរ ឬ បី នៅក្នុងពិភពលោកនេះ។ ដូច្នេះ វាមានលក្ខណៈលំបាកសម្រាប់ **ក** ក្នុងការស្វែងរករថយន្តដែលមានប្រភេទដូចគ្នាមកជំនួស។ ក្នុងករណីនេះ **ក** មិនមានករណីយកិច្ចត្រូវប្រគល់រថយន្តជំនួសទេ ប៉ុន្តែ ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាត។

### ២. ករណីយកិច្ចជួសជុល

***អ្នកលក់*** ត្រូវមានកាតព្វកិច្ចជួសជុលវត្ថុដែលមានវិការៈ ចំពោះអ្នកទិញដែលសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ ក្នុងករណីដែលកម្មវត្ថុនោះមានវិការៈ។ ផ្ទុយទៅវិញ ប្រសិនបើការជួសជុលវិការៈ នឹងដាក់បន្ទុកមិនសមរម្យហួសហេតុដល់អ្នកលក់ នោះអ្នកលក់មិនមានករណីយកិច្ចជួសជុលឡើយ ( មាត្រា ៥៤២ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ប៉ុន្តែ អ្នកលក់ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាតចំពោះអ្នកទិញ ( មាត្រា ៥៤៥) ។

ការជ្រើសរើសករណីយកិច្ចចំពោះអ្នកលក់ គឺអាស្រ័យលើអ្នកទិញ ថាតើគាត់ទាមទារឱ្យប្រគល់វត្ថុជំនួស ឬ ទាមទារឱ្យជួសជុល ។

### ៣. ការរំលាយកិច្ចសន្យា

ប្រសិនបើអ្នកទិញមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាបាន ដោយសារវត្ថុដែលត្រូវប្រគល់មាន វិការៈ គាត់អាចធ្វើការរំលាយកិច្ចសន្យានោះបាន ប្រសិនបើអ្នកទិញសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ ។ (មាត្រា ៥៤៣)

ឧទាហរណ៍ **ខ** បានទិញម៉ូតូ ១ គ្រឿងសម្រាប់ជិះ ពីហាងរបស់ **ក**។ ប្រសិនប្រហ៊ុំងម៉ូតូមានវិការៈ និង ធ្វើឱ្យ **ខ** មិនអាចប្រើប្រាស់ម៉ូតូនោះបានប្រកបដោយប្រសិទ្ធិភាព។ គេគិតថា ម៉ូតូនោះ មិនអាចប្រើតាមបំណងរបស់គាត់ នោះគាត់ (**អ្នកទិញ**) អាចរំលាយកិច្ចសន្យាលក់ទិញនោះ ហើយលោក **ក** អាចទៅរកទិញម៉ូតូថ្មីតាមខ្លួនចង់បានដោយពុំចាំបាច់ប្រើពេលវេលាជួសជុលថ្មីឡើយ ។

### ៤. ករណីយកិច្ចបន្ថយថ្លៃលក់

ក្នុងករណីដែលទំនិញដែលត្រូវបានប្រគល់មានវិការៈ អ្នកទិញដែលសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ អាចទាមទារបន្ថយថ្លៃលក់ តាមសមាមាត្រនៃភាពខុសគ្នានៅពេលប្រគល់រវាង តម្លៃនៃវត្ថុដែលគ្មានវិការៈនៅពេលប្រគល់ និង តម្លៃនៃវត្ថុដែលត្រូវបានប្រគល់ បានដែរ។ ឧទាហរណ៍ **ខ** បានទិញអង្ករចំនួន ១០០ គីឡូក្រាម ដែលមានតម្លៃ ១០០ ដុល្លារ ពី **ក** ក៏ប៉ុន្តែ មានអង្ករ ២០ គីឡូក្រាម ខូចរលួយនៅពេលប្រគល់។ នៅក្នុងករណីនេះ **ខ** អាចទាមទារឱ្យសងប្រាក់ ២០ ដុល្លារ វិញ ប្រសិនបើគាត់បានបង់ប្រាក់រួចហើយ ឬ បន្ថយប្រាក់ ២០ ដុល្លារ ពីប្រាក់ថ្លៃទិញ ប្រសិនបើគាត់មិនទាន់បានបង់ប្រាក់។ ប៉ុន្តែ ក្នុងករណីដែលអ្នកលក់បានជួសជុលវិការៈ ដោយផ្អែកលើមាត្រា ៥៤២ ដូច្នេះថ្លៃលក់មិនត្រូវបន្ថយទេ។ ប្រសិនបើអ្នកទិញបានប្រកែកមិនឱ្យអ្នកលក់ជួសជុលវិការៈ ដោយគ្មានហេតុផលត្រឹមត្រូវ នោះក៏មិនអាចបន្ថយតម្លៃបានដែរ (មាត្រា ៥៤៤ វាក្យខណ្ឌទី ២) ។

### ៥. ករណីយកិច្ចសងសំណងនៃការខូចខាត

***អ្នកលក់*** ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាត ប្រសិនបើវត្ថុដែលបានប្រគល់មានវិការៈ។ អ្នកទិញអាចទាមទារសំណងនៃការខូចខាត ដោយស្របតាមមាត្រា ៣៩៨ ដល់ មាត្រា ៤០៦ ។ អ្នកទិញអាចទាមទារឱ្យសងការខូចខាតដោយឯករាជ្យពី ឬ ជាមួយនឹងការសង្គ្រោះណាមួយ ដែលមានបញ្ញត្តចាប់ពីមាត្រា ៥៤២ ដល់មាត្រា ៥៤៤។ មាត្រា ៥៤៥ មិនបានបញ្ញត្តពីភាពសុចរិត ឬ ទុច្ចរិត ឬ មានកំហុស ឬ គ្មានកំហុសរបស់អ្នកទិញទេ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកទិញបានដឹងពីអត្ថិភាពនៃវិការៈនៅពេលប្រគល់នោះ គាត់ត្រូវបានចាត់ទុកថាបានយល់ព្រមទទួលយកកម្មវត្ថុនោះជាការអនុវត្តកាតព្វកិច្ច ដែលបានបំពេញនូវគោលបំណងនៃកាតព្វកិច្ច ។

## ៤.៣.៣. បញ្ញត្តិពិសេសស្តីពីដីដែលមានទំហំខ្វះ ឬ លើស

មាត្រា ៥៤៦ បានចែងអំពីបញ្ញត្តិពិសេសនៃការទទួលខុសត្រូវក្នុងការធានាវិការៈ នៅក្នុងករណីដែលដីមានទំហំលើស ឬក៏ខ្វះ។ ជាទូទៅ ការទិញលក់ដីត្រូវបានធ្វើឡើង យ៉ាងហោចណាស់សម្រាប់តំបន់ពាណិជ្ជកម្ម។ ជាងនេះទៅទៀត ប្រសិនបើគូភាគីបានបញ្ជាក់ពីទំហំដីសរុប និង កំណត់តម្លៃតាមខ្នាតដីច្បាស់លាស់ វាមានលក្ខណៈងាយស្រួលក្នុងការគណនាគម្លាតតម្លៃរវាងទំហំដីពិតប្រាកដ និង ទំហំដីដែលបានបញ្ជាក់។ ដូច្នេះ ក្នុង

ករណីនេះ ប្រសិនបើទំហំដីពិតប្រាកដតិចជាងទំហំដីដែលបានបញ្ជាក់ នោះអ្នកទិញអាចទាមទារឱ្យផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ បន្ថយនូវតម្លៃដី រំលាយកិច្ចសន្យា (ប្រសិនបើដែលអ្នកលក់ មិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យា) និង/ឬ សំណងនៃការខូចខាត (មាត្រា ៥៤៦ កថាខណ្ឌទី ១)។ ផ្ទុយទៅវិញ ប្រសិនបើទំហំដីពិតប្រាកដលើសពីទំហំដីដែលបានបញ្ជាក់ នោះអ្នកលក់ដែលសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ អាចទាមទារបន្ថែមតម្លៃដីដែលលើសនោះបាន លើកលែងតែមានការព្រមព្រៀងផ្សេង (មាត្រា ៥៤៦ កថាខណ្ឌទី ២)។

ផ្ទុយទៅវិញ ប្រសិនបើភាគីបានបញ្ជាក់ពីទំហំដីសរុប និង កំណត់តម្លៃដីទាំងមូល ដូច្នេះវាមានការលំបាកក្នុងការគណនាគម្លាតតម្លៃ រវាងទំហំដីពិតប្រាកដ និង ទំហំដីដែលបានបញ្ជាក់។ ដូច្នេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា អ្នកទិញមិនអាចទាមទារឱ្យផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ បន្ថយតម្លៃដី រំលាយកិច្ចសន្យា ឬ ទាមទារសំណងនៃការខូចខាត ទោះបីជាទំហំដីពិតប្រាកដ តិចជាងទំហំដីដែលបានបញ្ជាក់ក៏ដោយ (មាត្រា ៥៤៦ កថាខណ្ឌទី ៣)។

ក៏ប៉ុន្តែ អ្នកទិញអាចទាមទារការសង្គ្រោះទាំងនេះបាន ប្រសិនបើ

(ក) អ្នកលក់បានដឹងពីការខ្វះទំហំដីនោះ

(ខ) អ្នកលក់បានធានានូវទំហំដីនោះ

(គ) ទំហំខ្វះនោះមានច្រើនជាង ៥ ភាគរយនៃទំហំដែលបានបញ្ជាក់ (មាត្រា ៥៤៦ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២)។

ហើយនៅក្នុងករណីដែលទំហំដីពិតប្រាកដ មានលើសពីទំហំដីដែលបានបញ្ជាក់ នោះអ្នកលក់មិនអាចទាមទារបន្ថែមតម្លៃដីបានឡើយ (មាត្រា ៥៤៦ កថាខណ្ឌទី ៤)។ ក៏ប៉ុន្តែ មានតែអ្នកលក់ដែលសុចរិត និង គ្មានកំហុស ទើបអាចទាមទារឱ្យបន្ថែមតម្លៃដីបាន ប្រសិនបើទំហំដីពិតប្រាកដ លើសពីទំហំដីដែលបានបញ្ជាក់ ចំនួន ៥ ភាគរយ (មាត្រា ៥៤៦ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២)។

ឧទាហរណ៍ ប្រសិនបើ **ខ** បានទិញដីទំហំ ១០០ ម៉ែត្រការ៉េ ក្នុងតម្លៃ ១.០០០ ដុល្លារ ពី **ក** ប៉ុន្តែ ទំហំដីពិតប្រាកដមានតែ ៩៨ ម៉ែត្រការ៉េ។ ប្រសិនបើ គូភាគីបានព្រមព្រៀងថា តម្លៃនៃដីនោះ គឺ ១០ ដុល្លារ ក្នុង ១ ម៉ែត្រការេ នោះ **ខ** អាចទាមទារឱ្យផ្តល់តាវការលិកនូវផ្នែកដែលខ្វះ ឬ បន្ថយតម្លៃដីចំនួន ២០ ដុល្លារ ឬ ក៏រំលាយកិច្ចសន្យា ដែលមានតែក្នុងករណីដែល **ខ** មិនសម្រេចបាននូវគោលបំណងនៃកិច្ចសន្យា និង/ឬ ទាមទារសំណងនៃការខូចខាត លុះត្រាតែ **ខ** បានធ្វើសកម្មភាពដោយសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ។ ប្រសិនបើគូភាគីមិនបានសម្រេចពីតម្លៃតាមខ្នាតដីច្បាស់លាស់ទេ នោះ **ខ** អាចទាមទារការសង្គ្រោះទាំងនេះបានតែក្នុងករណីដែល **ក** បានដឹងពីការខ្វះទំហំដីនោះ **ក** បានធានានូវទំហំដីនោះ។

### ៤.៣.៤. អំឡុងពេលដែលអាចអនុវត្តសិទ្ធិ

សិទ្ធិដែលទាក់ទងនឹងការទទួលខុសត្រូវក្នុងការធានាវិការៈ ត្រូវអនុវត្តក្នុងអំឡុងពេល ១ ឆ្នាំ (មាត្រា ៥៤៧ កថាខណ្ឌទី ១)។ អំឡុងពេលនេះ ត្រូវគិតចាប់ពី :

(ក) សម្រាប់អ្នកទិញ ពេលដែលអ្នកទិញបានដឹង ឬ គួរបានដឹងអំពីវិការៈ និង ការខូចខាត

(ខ) សម្រាប់អ្នកលក់ ពេលដែលធ្វើកិច្ចសន្យា (មាត្រា ៥៤៧ កថាខណ្ឌទី ២) ។

ក៏ប៉ុន្តែ សិទ្ធិទាមទារសំណងនៃការខូចខាត ដែលបានបញ្ញត្តនៅក្នុងមាត្រា ៥៤៦ កថាខណ្ឌទី ១ និង មាត្រា ៥៤៦ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២ ត្រូវរលត់ ស្របតាមមាត្រា ៤៨២ (អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ) ។ ដូច្នេះ អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យសងសំណងនៃការខូចខាត ដែលបានបញ្ញត្តនៅក្នុងមាត្រា ៥៤៦ កថាខណ្ឌទី ១ និង មាត្រា ៥៤៦ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២ គឺ ៥ ឆ្នាំ ហើយវាគិតចាប់ពីពេលដែលអ្នកលក់ អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន (មាត្រា ៤៨១ និង ៤៨២) ។

### ៩.៣.៥. កិច្ចសន្យាពិសេសដែលអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានាវិការៈ

គូភាគីអាចព្រមព្រៀងគ្នា ដើម្បីអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់បាន ។ ក៏ប៉ុន្តែ អ្នកលក់មិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការធានាបានឡើយ ទាក់ទងនឹងករណីដែលអ្នកលក់បានដឹង តែមិនបានប្រាប់ ដោយសារតែមានគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ (មាត្រា ៥) ។

## ៩.៤. ក្នុងករណីដែលសិទ្ធិដែលត្រូវបានលក់ ត្រូវបានកម្រិតដោយច្បាប់

ទោះបីជាអ្នកលក់ គឺជាម្ចាស់កម្មសិទ្ធិលើកម្មវត្ថុនៃកិច្ចសន្យា ក៏មានពេលខ្លះ សិទ្ធិប្រើប្រាស់ក៏ត្រូវបាន កម្រិតដោយសិទ្ធិប្រត្យក្សដែរ ។ ក្នុងករណីនេះ វាមានសារៈសំខាន់ណាស់ក្នុងការកែតម្រូវនូវអតុល្យភាពនេះ ។

### ៩.៤.១. ការទទួលខុសត្រូវក្នុងការធានា ក្នុងករណីដែលមានសិទ្ធិប្រត្យក្សជាផលុបភោគ ជាអាទិ៍

នៅក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ត្រូវបានជាប់បន្ទុកសម្រាប់គោលបំណងនៃសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា ជាអាទិ៍ ហើយម្ចាស់សិទ្ធិផលុបភោគ បានចុះបញ្ជីនូវសិទ្ធិរបស់ខ្លួន នោះកម្មសិទ្ធិករថ្មី មិនអាចប្រើប្រាស់នូវកម្មវត្ថុនោះទាំងស្រុងទេ ។ ឧទាហរណ៍ នៅក្នុងករណីដែល **ខ** បានទិញដីពី **ក** ប៉ុន្តែ **ក** បានជួលដីនោះទៅឱ្យ **គ** រួចទៅហើយ ហើយ **គ** ក៏បានទទួលនូវលក្ខខណ្ឌតាំងរួចរាល់ដែរ ដូច្នេះ **ខ** មិនអាចទាមទារនូវការប្រើប្រាស់ដីនោះ ចំពោះ **គ** បានឡើយ (មាត្រា ៥៩៨ កថាខណ្ឌទី ១) ។

### ៩.៤.២. ក្នុងករណីដែលមានសិទ្ធិប្រត្យក្សជាផលុបភោគ

នៅក្នុងករណីដែលមានសិទ្ធិប្រត្យក្សផលុបភោគ អ្នកទិញដែលសុចរិតអាចទាមទារសំណងការខូចខាត (មាត្រា ៥៣៤ កថាខណ្ឌទី ១) ។ អ្នកទិញដែលសុចរិត ក៏អាចទាមទារឱ្យរំលាយកិច្ចសន្យាបានដែរ ប្រសិនបើគាត់ មិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យា ដោយសារតែមាននូវសិទ្ធិប្រត្យក្សផលុបភោគនោះ ។ អ្នកទិញត្រូវ អនុវត្តសិទ្ធិរំលាយ និង សិទ្ធិសងសំណងការខូចខាត នៅក្នុងរយៈពេល ១ ឆ្នាំ គិតចាប់ពីពេលដែលអ្នកទិញបាន ដឹងការពិត (មាត្រា ៥៣៤ កថាខណ្ឌទី ៤) ។

### ៤.៤.៣. ក្នុងករណីដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស

កម្មសិទ្ធិករលើអចលនវត្ថុ អាចលក់អចលនវត្ថុរបស់ខ្លួនបាន ទោះបីជាអចលនវត្ថុនោះគឺជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្ស ដូចជា ឯកសិទ្ធិ ឬ ហ៊ីប៉ូតែកក៏ដោយ។ ក៏ប៉ុន្តែ នៅក្នុងករណីនេះ អ្នកទិញត្រូវទទួលបន្ទុកហានិភ័យ ក្នុងការបាត់បង់នូវកម្មសិទ្ធិលើអចលនវត្ថុនោះ ដោយសារតែការអនុវត្តនូវសិទ្ធិប្រត្យក្សទាំងនេះ។

ដូច្នេះ អ្នកទិញអាចរំលាយកិច្ចសន្យាលក់ទិញ នៅពេលដែលខ្លួនបានបាត់បង់នូវកម្មសិទ្ធិ ដោយការអនុវត្តនូវសិទ្ធិប្រាតិភោគប្រត្យក្ស (មាត្រា ៥៣៥ កថាខណ្ឌទី ១)។ ជាងនេះទៅទៀត អ្នកទិញអាចរំលាយកិច្ចសន្យា ទោះបីជាអ្នកទិញបានដឹងពីអត្ថិភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សនោះ នៅពេលបង្កើតកិច្ចសន្យាក៏ដោយព្រោះម្ចាស់បំណុលរបស់អ្នកលក់មិនអនុវត្តនូវសិទ្ធិប្រាតិភោគប្រត្យក្សជាចាំបាច់នោះទេ។ វាអាចសមហេតុផលដែលថា អ្នកទិញជឿថា អ្នកលក់នឹងសងបំណុលរបស់ខ្លួន ហើយសិទ្ធិប្រាតិភោគប្រត្យក្សនឹងរំលត់ ក្រោយពីការបង្កើតកិច្ចសន្យាលក់ទិញ ដូច្នេះ អ្នកទិញគឺចាំបាច់ត្រូវការការពារនៅក្នុងកម្រិតខ្ពស់មួយ។ អ្នកទិញអាចបង់ប្រាក់ ហើយធ្វើឱ្យហ៊ីប៉ូតែកនោះរលត់ តាមសំណើរបស់ម្ចាស់បំណុលហ៊ីប៉ូតែក (= ម្ចាស់បំណុល មាត្រា ៨៦៤)។ ឧទាហរណ៍ **ខ** បានទិញដីមួយកន្លែងពី **ក** ហើយដីនោះ គឺជាកម្មវត្ថុនៃហ៊ីប៉ូតែកសម្រាប់ **គ** ក្នុងការធានាបំណុល ១.០០០ ដុល្លារ។ ប្រសិនបើ **គ** ស្នើសុំឱ្យសងប្រាក់ ហើយ **ខ** បានបង់ប្រាក់ ១.០០០ ដុល្លារ នោះហ៊ីប៉ូតែកត្រូវរលត់សម្រាប់ជាផលប្រយោជន៍របស់ **ខ**។

នៅក្នុងករណីនេះ **ខ** អាចទាមទារប្រាក់ ១.០០០ ដុល្លារ ជាការសងនូវការចំណាយ ដើម្បីរក្សានូវកម្មសិទ្ធិ (មាត្រា ៥៣៥ កថាខណ្ឌទី ២)។ **ខ** ក៏អាចទាមទារសំណងចំពោះការខូចខាតដែលមាន (មាត្រា ៥៣៥ កថាខណ្ឌទី ៣)។

ប្រសិនបើអ្នកទិញអចលនវត្ថុដែលភ្ជាប់នូវសិទ្ធិប្រាតិភោគប្រត្យក្ស ដែលបានកំណត់នៅក្នុងមាត្រា ៥៣៥ កថាខណ្ឌទី ១ បានទិញអចលនវត្ថុនោះនៅក្នុងតម្លៃ ដែលបានដកចេញនូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគប្រត្យក្ស នោះអ្នកទិញមិនអាចទាមទារឱ្យសងថ្លៃចំណាយ និង សំណងការខូចខាតបានឡើយ (មាត្រា ៥៣៥ កថាខណ្ឌទី ៤)។ ឧទាហរណ៍ នៅក្នុងករណីខាងលើ ប្រសិនបើតម្លៃដើមនៃដី គឺ ៥.០០០ ដុល្លារ ហើយ **ក** និង **ខ** បានព្រមព្រៀងគ្នាបង់ប្រាក់ថ្លៃដីចំនួន ៤.០០០ ដុល្លារ ដោយគិតពិចារណាទៅលើអត្ថិភាពនៃហ៊ីប៉ូតែក នោះ **ខ** មិនអាចទាមទារឱ្យសងថ្លៃចំណាយ ឬ សំណងការខូចខាត ទោះបីជា **ខ** បានចំណាយអស់ ១.០០០ ដុល្លារ តាមសំណើរបស់ **គ** ក៏ដោយ។

វាមិនមែនជាបញ្ហាទេ ថាតើអ្នកទិញបានធ្វើសកម្មភាពដោយសុចរិត ឬ ទុច្ចរិត ទាក់ទងនឹងការទទួលខុសត្រូវក្នុងការធានា នៅពេលដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស។ ម្យ៉ាងទៀត វាមិនមានការកម្រិតជាពិសេសណាមួយក្នុងការអនុវត្តសិទ្ធិរបស់អ្នកទិញ ហើយវាត្រូវរលត់ ដោយផ្អែកទៅលើបញ្ញត្តិទូទៅនៃអាជ្ញាយុកាលនៃការរលត់ (មាត្រា ៤៨២)។

**ករណីសិក្សា**

តើអ្នកទិញ **ខ** អាចទាមទារអ្វីបានចំពោះ **ក** ទាក់ទងនឹងការទទួលខុសត្រូវក្នុងការធានា នៅក្នុងករណីខាងក្រោមនេះ?

(១) **ក** បានលក់រថយន្តទៅឱ្យ **ខ** ប៉ុន្តែ រថយន្តនោះ គឺជាកម្មសិទ្ធិរបស់ **គ**។ **ក** មិនបានពន្យល់ **ខ** អំពីអង្គហេតុដែលថារថយន្តនោះ គឺជាកម្មសិទ្ធិរបស់ **គ** ទោះបីជា **ក** បានដឹងអំពីអង្គហេតុនេះក៏ដោយ។ **ខ** បានដឹងពីអង្គហេតុនេះក្រោយពីការបង្កើតកិច្ចសន្យា ហើយបានទាមទារឱ្យប្រគល់រថយន្តនៅកាលបរិច្ឆេទ។ ក៏ប៉ុន្តែ **គ** បានបំផ្លាញរថយន្តនោះចោល នៅមុនកាលបរិច្ឆេទប្រគល់។

(២) **ក** បានលក់ដីដែលជាកម្មសិទ្ធិអវិភាគរបស់ **ក** និង **ឃ** (ដែលមានចំណែកស្មើគ្នា) ប៉ុន្តែ **ក** មិនបានទទួលនូវការយល់ព្រមពី **ឃ** ឡើយ។ **ខ** បានដឹងថា ដីនោះគឺជាកម្មសិទ្ធិអវិភាគរបស់ **ក** និង **ឃ**។ ក្រោយពីការបង្កើតកិច្ចសន្យា **ក** បានស្នើសុំឱ្យ **ឃ** លក់នូវចំណែករបស់ខ្លួនមកឱ្យ **ក** ប៉ុន្តែ **ឃ** បានបដិសេធយ៉ាងដាច់ខាត។

(៣) **ខ** បានទិញដីដើម្បីសាងសង់រោងចក្រ។ ក៏ប៉ុន្តែ ដីនោះបានភ្ជាប់នឹងសិទ្ធិជួលអចិន្ត្រៃយ៍របស់ **ខ** ហើយ **ខ** បានចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍របស់ខ្លួន។ **ខ** បានប្រើប្រាស់ដីទាំងមូលសម្រាប់ធ្វើកសិដ្ឋាន។ **ខ** មិនបានដឹងថា ដីនេះគឺមានភ្ជាប់នឹងសិទ្ធិជួលអចិន្ត្រៃយ៍ នៅពេលបង្កើតកិច្ចសន្យាឡើយ។

(៤) **ខ** បានទិញរថយន្តមួយពីឈ្មួញលក់រថយន្ត **ក** ហើយបានបង់ប្រាក់ថ្លៃទិញរួចរាល់ហើយ ដើម្បីជាថ្នូរនឹងការប្រគល់រថយន្ត។ ក៏ប៉ុន្តែ ហ្វ្រាំងរបស់រថយន្តនោះ មិនដំណើរការទាល់តែសោះ។ ទាំង **ក** និង **ខ** មិនបានដឹងពីវិការៈនេះ ដោយគ្មានកំហុសធ្ងន់ធ្ងរ។

(៥) **ក** និង **ខ** បានចុះកិច្ចសន្យាលក់ទិញ ដែល **ក** ត្រូវផ្ទេរការចុះបញ្ជីដីជាមួយនឹងផ្ទះរបស់ខ្លួន នៅថ្ងៃទី 0១ ខែមីនា ឆ្នាំ ២០១១ ហើយធ្វើការប្រគល់ដី និង ផ្ទះទៅឱ្យ **ខ** ដើម្បីជាថ្នូរនឹងការបង់ប្រាក់នៅថ្ងៃទី 0១ ខែ មេសា។ **ក** បានផ្ទេរនូវការចុះបញ្ជីនៅថ្ងៃទី 0១ ខែ មីនា។ ក៏ប៉ុន្តែនៅមុនពេលប្រគល់ដី និង ផ្ទះនោះ សសរសំខាន់មួយនៅក្នុង ផ្ទះនោះ បានពុក ដោយសារតែកំហុសរបស់ **ក** ហើយការពុកផុយនេះ គឺស្ថិតនៅក្នុងកម្រិតមួយដែល **ខ** មិនអាចរស់នៅក្នុងផ្ទះនោះបាន ប្រសិនបើសសរនោះមិនត្រូវបានចាក់បេតុងសាជាថ្មី។ ទាំង **ក** និង **ខ** មិនបានដឹងពីវិការៈ នេះ រហូតដល់ពេលប្រគល់។

(៦) **ខ** បានទិញដីដែលមានទំហំ ១00 ម៉ែត្រការ៉េ ពី **ក** ដើម្បីប្រើប្រាស់ជាដីកសិដ្ឋាន។ ពួកគេបានព្រមព្រៀងគ្នាថាតម្លៃសរុបនៃដីនោះ គឺ ១0.000 ដុល្លារ សម្រាប់ដីទំហំ ១00 ម៉ែត្រការ៉េ ហើយ ១00 ដុល្លារ ក្នុងមួយម៉ែត្រការ៉េ។ **ខ** បានបង់ប្រាក់ ១0.000 ដុល្លារ រួចរាល់ហើយ ហើយ **ក** ក៏បានប្រគល់ដីនោះ។ ប៉ុន្តែ គេរកឃើញថាទំហំដីពិតប្រាកដ គឺមានតែ ៩0 ម៉ែត្រការ៉េ។ **ខ** មិនបានដឹងពីការខ្វះនូវទំហំដីនេះ នៅពេលធ្វើកិច្ចសន្យាឡើយ។

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

(១) ខ អាចទាមទារឱ្យរំលាយកិច្ចសន្យា និង សំណងនៃការខូចខាត។

ក មានកាតព្វកិច្ចក្នុងការផ្ទេរលទ្ធកម្មនូវកម្មសិទ្ធិពី គ ហើយធ្វើការផ្ទេរកម្មសិទ្ធិនេះទៅឱ្យ ខ (មាត្រា ៥៣១ កថាខណ្ឌទី ២)។ ក៏ប៉ុន្តែ ក មិនអាចទទួលបាននូវកម្មសិទ្ធិទៀតទេ ព្រោះ គ បានបំផ្លាញរថយន្តនោះចោលហើយ។

ដូច្នេះ ខ អាចរំលាយកិច្ចសន្យានេះ និង ទាមទារសំណងនៃការខូចខាត ព្រោះ ខ បានធ្វើសកម្មភាពដោយសុចរិត (មាត្រា ៥៣១ កថាខណ្ឌទី ៣)។

(២) ខ អាចទាមទារបានតែការបន្ថយថ្លៃប៉ុណ្ណោះ។

នៅក្នុងករណីនេះ ក បានលក់ដីដែលជាកម្មសិទ្ធិមួយផ្នែករបស់ ឃ។ ដូច្នេះ ក ត្រូវមានកាតព្វកិច្ចទទួលយកនូវចំណែករបស់ ឃ ហើយធ្វើការផ្ទេរទៅឱ្យ ខ។ ប៉ុន្តែ ឃ បដិសេធក្នុងការផ្ទេរចំណែករបស់ខ្លួនទៅឱ្យ ក ដូច្នេះ កាតព្វកិច្ចរបស់ ក ក្នុងការទទួលយកនូវចំណែករបស់ ឃ ក្លាយជាអលទ្ធភាព។ ក៏ប៉ុន្តែ នៅក្នុងករណីនេះ ខ បានដឹងថា ដីនោះគឺជាកម្មសិទ្ធិអវិភាគរបស់ ក និង ឃ។ ដូច្នេះ ខ មិនអាចទាមទារឱ្យរំលាយកិច្ចសន្យា ឬ សងសំណងនៃការខូចខាត (មាត្រា ៥៣៣ កថាខណ្ឌទី ២ និង ៣) ប៉ុន្តែ អាចទាមទារបន្ថយ ៥០ ភាគរយពីប្រាក់ថ្លៃទិញ (មាត្រា ៥៣៣ កថាខណ្ឌទី ១)។

(៣) ខ អាចទាមទារឱ្យរំលាយកិច្ចសន្យា និង សងសំណងការខូចខាត។

នៅក្នុងករណីនេះ កម្មវត្ថុនៃកិច្ចសន្យាលក់ទិញ គឺត្រូវបានភ្ជាប់ទៅនឹងសិទ្ធិជួលអចិន្ត្រៃយ៍សម្រាប់ ខ។ ខ អាចទាមទារសំណងនៃការខូចខាត (មាត្រា ៥៣៤ កថាខណ្ឌទី ១) ព្រោះ ខ មិនបានដឹងពីអត្ថិភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍ នៅពេលបង្កើតកិច្ចសន្យា។ ហើយម្យ៉ាងទៀត គោលបំណងរបស់ ខ នៅក្នុងការទិញដីនេះ គឺដើម្បីសាងសង់រោងចក្រ ប៉ុន្តែ វាមិនអាចធ្វើទៅបាន ដោយសារតែ ង បានប្រើដីនោះទាំងមូលសម្រាប់ធ្វើកសិដ្ឋាន។ ដូច្នេះ ខ អាចរំលាយកិច្ចសន្យា ដោយផ្អែកទៅតាមមាត្រា ៥៣៤ កថាខណ្ឌទី ២។

(៤) ខ អាចទាមទារសំណងការខូចខាតដោយឡែកពី ឬក៏ជាមួយនឹងការប្រគល់វត្ថុជំនួស ការជួសជុល ការរំលាយកិច្ចសន្យា ឬ ការបន្ថយថ្លៃទិញ។

ជាធម្មតា ប្រសិនបើមានវិការៈជាមួយនឹងហ្វ្រាំងរបស់រថយន្តនៅពេលប្រគល់ វាត្រូវបានគេចាត់ទុកថា ជាឡានដែលមានវិការៈ ព្រោះហ្វ្រាំងរបស់រថយន្ត គឺមានតួនាទីយ៉ាងសំខាន់។ ដូច្នេះ ក ត្រូវមានករណីយកិច្ចប្រគល់វត្ថុជំនួស ជួសជុល រំលាយកិច្ចសន្យា ឬ បន្ថយថ្លៃ (មាត្រា ៥៤០ កថាខណ្ឌទី ១) និង/ឬ សំណងនៃការខូចខាត (មាត្រា ៥៤៥)។ មាត្រា ៥៤២ រហូតដល់មាត្រា ៥៤៥ បញ្ញត្តអំពីលក្ខខណ្ឌដើម្បីបង្កើតអានុភាព។

ជាដំបូង ខ អាចទាមទារឱ្យ ក ត្រូវប្រគល់វត្ថុជំនួស។ នៅក្នុងករណីនេះ កាតព្វកិច្ចក្នុងការផ្តល់នូវរថយន្ត ថ្មី មិនត្រូវបានចាត់ទុកថាជាករណី "ដែលការរៀបចំផ្តល់ឱ្យវត្ថុដែលមានប្រភេទដូចគ្នា នឹងដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរ ទៅដល់អ្នកលក់ទេ (មាត្រា ៥៤២ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២)" ព្រោះ ក គឺជាឈ្មួញលក់រថយន្ត។

បន្ទាប់មក ខ អាចទាមទារឱ្យ ក ធ្វើការជួសជុលរថយន្ត (មាត្រា ៥៤២ កថាខណ្ឌទី ៣)។ នៅក្នុងករណីនេះ ខ ត្រូវជួលជុលហ្វ្រាំងរថយន្តដោយខ្លួនឯងផ្ទាល់ ឬ ឱ្យហាងជួសជុលធ្វើការជួសជុលរថយន្តនោះ។

ទាក់ទងនឹងការរំលាយកិច្ចសន្យា បញ្ហាគឺថាតើ អ្នកលក់មិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាលក់ទិញ ដោយសារវិការៈនោះដែរ ឬ ទេ។ វាមានលក្ខណៈគ្រោះថ្នាក់ណាស់ ហើយអ្នកទិញត្រូវតែបោះបង់នូវការបើកបររបស់ខ្លួន ប្រសិនបើហ្វ្រាំងមិនដំណើរការទាល់តែសោះ។ ដូច្នេះ នៅក្នុងករណីនេះអ្នកទិញអាចរំលាយកិច្ចសន្យាបាន។

ហើយ ខ អាចទាមទារឱ្យបន្ថយថ្លៃ ដោយស្របទៅនឹងមាត្រា ៥៤៤។ ប៉ុន្តែ ប្រសិនបើ ក បានជួសជុលនូវវិការៈនោះរួចរាល់ហើយ នោះ ខ មិនអាចទាមទារឱ្យបន្ថយថ្លៃបានទេ។

ប្រសិនបើ ខ ទទួលរងនូវការខូចខាត នោះ ខ អាចទាមទារនូវសំណងនៃការខូចខាតឱ្យស្របទៅនឹងមាត្រាដែលពាក់ព័ន្ធនឹងសំណងនៃការខូចខាត។

(៥) ខ អាចទាមទារឱ្យជួសជុល បន្ថយថ្លៃលក់ទិញ រំលាយកិច្ចសន្យា និង/ឬ សំណងនៃការខូចខាត។

នៅក្នុងករណីនេះ នៅពេលដែល ក ផ្ទេរការចុះបញ្ជី នោះហានិភ័យក៏ត្រូវបានផ្ទេរដែរ (មាត្រា ៤១៦ កថាខណ្ឌទី ២ ចំណុច ក)។ ក្នុងករណីនេះ មាត្រា ៥៤០ កថាខណ្ឌទី ១ មិនអាចយកមកអនុវត្តបានឡើយ ព្រោះ វិការៈមិនបានកើតឡើងនៅឡើយ នៅពេលចុះបញ្ជី។ ក៏ប៉ុន្តែ អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការធានា នៅក្រោយការប្រគល់ ក្នុងករណីដែលវិការៈកើតឡើងដោយសារកំហុសរបស់អ្នកលក់ (មាត្រា ៥៤០ កថាខណ្ឌទី ២)។

កម្មវត្ថុនៃកិច្ចសន្យាលក់ទិញនេះ គឺជាវត្ថុដែលបានកំណត់ជាក់លាក់។ ខ មិនអាចទាមទារឱ្យប្រគល់វត្ថុជំនួសបានទេ ព្រោះវត្ថុដែលបានកំណត់ជាក់លាក់ មិនមានវត្ថុជំនួសទេ (មាត្រា ៥៤២ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២)។ ផ្ទុយទៅវិញ ខ អាចទាមទារឱ្យជួសជុល ព្រោះគេអាចជួសជុលសសរផ្ទះនោះបាន (មាត្រា ៥៤២ កថាខណ្ឌទី ៣)។

ខ ក៏អាចទាមទារឱ្យរំលាយកិច្ចសន្យាបានដែរ ព្រោះ ខ មិនអាចចូលស្នាក់នៅក្នុងផ្ទះនោះ ប្រសិនបើសសរមិនត្រូវបានចាក់បេតុងជាថ្មីនោះទេ។

ក ត្រូវមានកាតព្វកិច្ចថែរក្សាកម្មវត្ថុនោះ ដោយយកចិត្តទុកដាក់ក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលដែលវត្ថុនោះត្រូវបានប្រគល់ (មាត្រា ៥២២ កថាខណ្ឌទី ១)។ ក្នុងករណីនេះ វិការៈកើតឡើងដោយសារកំហុសរបស់ ក ដូច្នេះ ក មានកាតព្វកិច្ចសងនូវសំណងនៃការខូចខាត។

(៦) ខ អាចទាមទារឱ្យបន្ថយថ្លៃ ប្រគល់នូវផ្នែកដែលខ្វះ និង/ឬ សងសំណងនៃការខូចខាត។

ក្នុងករណីនេះ មាត្រា ៥៤៦ កថាខណ្ឌទី ១ អាចយកមកអនុវត្ត ដោយសារភាគីទាំងសងខាង បានសម្រេច អំពីទំហំសរុបនៃដីដែលបានកំណត់ជាក់លាក់ ហើយកំណត់តម្លៃតាមខ្នាតដី។ ដូច្នេះ ខ អាចទាមទារឱ្យប្រគល់ផ្នែក ដែលខ្វះ បន្ថយថ្លៃទិញ ឬ រំលាយកិច្ចសន្យា និង/ឬ សំណងនៃការខូចខាត ដោយស្របនឹងមាត្រា ៥៤២ ដល់ មាត្រា ៥៤៥។

ជាដំបូង ក ត្រូវមានកាតព្វកិច្ចប្រគល់ដីដែលនៅខ្វះចំនួន ១០ ម៉ែត្រការ៉េ។ ឧទាហរណ៍ ប្រសិនបើផ្នែក ដែលខ្វះ គឺជាកម្មសិទ្ធិរបស់តតិយជន នោះ ក ត្រូវទទួលយកកម្មសិទ្ធិពីតតិយជន ហើយធ្វើការប្រគល់ទៅឱ្យ ខ។ ក៏ប៉ុន្តែ ប្រសិនបើវាជាក់ជាបន្ទុកមិនសមហេតុផលទៅដល់ ក ឧទាហរណ៍ដូចជា តតិយជន បដិសេធមិនព្រម ផ្ទេរកម្មសិទ្ធិលើផ្នែកដែលខ្វះ ឬ ផ្នែកដែលខ្វះនេះ គឺជាកម្មសិទ្ធិរបស់រដ្ឋ នោះ ក នឹងមិនបំពេញកាតព្វកិច្ចនេះទេ។

ហើយ ខ អាចទាមទារឱ្យបន្ថយថ្លៃចំនួន ១.០០០ ដុល្លារ ដោយផ្អែកលើមាត្រា ៥៤៤។

ម្យ៉ាងវិញទៀត ខ មិនអាចទាមទារឱ្យរំលាយកិច្ចសន្យាបានទេ ព្រោះគោលបំណងនៃការទិញដីនេះ គឺ ដើម្បីប្រើប្រាស់ជាកសិដ្ឋាន ហើយ ខ នៅតែអាចប្រើប្រាស់ដីនោះ សម្រាប់ធ្វើកសិដ្ឋានបានដដែល ទោះបីទំហំដីខ្វះ ១០ ភាគរយ ក៏ដោយ។

ប្រសិនបើ ខ មានការខូចខាត ដោយសារការខ្វះទំហំដី នោះ ខ អាចទាមទារសំណងនៃការខូចខាតបាន។

## ៥. ករណីយកិច្ច និង សិទ្ធិរបស់អ្នកទិញ

### ៥.១. ករណីយកិច្ចទូទៅរបស់អ្នកទិញ

ក្រោយពីបង្កើតកិច្ចសន្យាលក់ទិញ អ្នកទិញត្រូវមានករណីយកិច្ចបង់ថ្លៃជាប្រាក់ ដែលបានសន្យាក្នុង កិច្ចសន្យា និងមានករណីយកិច្ចទទួលវត្ថុដែលអ្នកទិញបានទិញពីអ្នកលក់។

#### ៥.១.១. ករណីយកិច្ចបង់ថ្លៃទិញ

អ្នកទិញ មានករណីយកិច្ចបង់ថ្លៃទិញជាប្រាក់ តាមកាលបរិច្ឆេទ និង នៅទីកន្លែងដែលបានកំណត់ក្នុង កិច្ចសន្យា (មាត្រា ៥៥៥)។ កាលបរិច្ឆេទ និង ទីកន្លែងនៃការបង់ប្រាក់ ត្រូវបានសម្រេចដោយផ្អែកលើការព្រម ព្រៀងរបស់គូភាគីក្នុងកិច្ចសន្យា។

ក្នុងករណីដែលអ្នកទិញ បង់ប្រាក់ក្រោយកាលបរិច្ឆេទដែលកំណត់ នោះអ្នកទិញត្រូវទទួលខុសត្រូវចំពោះ ការយឺតយ៉ាវនៅក្នុងការអនុវត្ត។

អ្នកទិញ មិនចាំបាច់បង់ការប្រាក់នៃថ្លៃទិញ ឬ ប្រាក់សំណងនៃការខូចខាត ដោយសារការយឺតយ៉ាវ រហូត ដល់ពេលដែលវត្ថុ ដែលជាកម្មវត្ថុត្រូវបានប្រគល់ ទោះបីជាកាលបរិច្ឆេទប្រគល់បានកន្លងហួសក៏ដោយ (មាត្រា ៥៥៦)។ អ្នកទិញ មិនអាចទទួលផលពីកម្មវត្ថុ រហូតដល់ពេលប្រគល់ (មាត្រា ៥៥៣)។

ឧទាហរណ៍ ក បានធ្វើកិច្ចសន្យាលក់រថយន្ត ០១ គ្រឿង ទៅឱ្យ ខ ក្នុងតម្លៃ ២០.០០០ ដុល្លារ ហើយបាន កំណត់ថ្ងៃបង់ប្រាក់ថ្លៃរថយន្ត នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ និង បានកំណត់យកទីកន្លែងប្រគល់ប្រាក់នៅ

ផ្ទះរបស់ **ក**។ ដូច្នេះ **ខ** ត្រូវមានករណីយកិច្ចបង់ប្រាក់ថ្លៃទិញរថយន្តចំនួន ២០.០០០ ដុល្លារ ទៅឱ្យ **ក** នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ នៅផ្ទះរបស់ **ក** ដែលបានកំណត់ក្នុងកិច្ចសន្យា។

ប្រសិនបើកិច្ចសន្យាលក់ទិញចលនវត្ថុ បានកំណត់តែពេលសម្រាប់ធ្វើការប្រគល់កម្មវត្ថុ ពេលនោះត្រូវបានសន្មតថាជាពេលសម្រាប់បង់ប្រាក់ថ្លៃទិញដែរ។ ទន្ទឹមនឹងនេះ ក្នុងករណីដែលកិច្ចសន្យាលក់ទិញអចលនវត្ថុកំណត់តែពេលសម្រាប់ធ្វើសកម្មភាពចាំបាច់ក្នុងការចុះបញ្ជីអចលនវត្ថុ ពេលនោះត្រូវបានសន្មតថាជាពេលសម្រាប់បង់ប្រាក់ថ្លៃទិញ ( មាត្រា ៥៥៥ កថាខណ្ឌទី ២) ។

តាមឧទាហរណ៍ខាងលើ ប្រសិនបើ **ក** និង **ខ** បានព្រមព្រៀងកំណត់ពេលប្រគល់រថយន្ត នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១០ ប៉ុន្តែ មិនកំណត់ពេលនៃការបង់ថ្លៃលក់រថយន្ត នោះពេលកំណត់ដែលត្រូវបង់ថ្លៃរថយន្តរបស់ **ខ** ទៅឱ្យ **ក** គឺនៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១០។

ក្នុងករណីដែលភាគីមិនបានកំណត់ពេលប្រគល់ចលនវត្ថុ ឬ ពេលធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុ នោះអ្នកទិញមានករណីយកិច្ចបង់ថ្លៃទិញទៅឱ្យអ្នកលក់ នៅពេលដែលអ្នកលក់ទាមទារឱ្យបង់ប្រាក់ ( មាត្រា ៥៥៥ កថាខណ្ឌទី ៣) ។

ក្នុងករណីដែលមិនមានកំណត់ទីកន្លែងដែលត្រូវបង់ថ្លៃទិញនៅក្នុងកិច្ចសន្យាទេ ប្រសិនបើការបង់ថ្លៃ ត្រូវធ្វើព្រមគ្នានឹងការប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ព្រមគ្នានឹងការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុនោះ អ្នកទិញត្រូវបង់ថ្លៃនៅទីកន្លែងដែលអ្នកលក់ ត្រូវប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ត្រូវធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុ ( មាត្រា ៥៥៥ កថាខណ្ឌទី ៤) ។

### ៥.១.២. កាតព្វកិច្ចបង់ការប្រាក់

ក្នុងករណីដែលអ្នកទិញ បានទទួលការប្រគល់កម្មវត្ថុនៃកិច្ចសន្យាពីអ្នកលក់រួចហើយ នោះអ្នកទិញត្រូវបង់ការប្រាក់នៃថ្លៃទិញ រហូតដល់ពេលបង់ប្រាក់ថ្លៃទិញចប់សព្វគ្រប់ ឬ បង់ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ( មាត្រា ៥៥៦) ។ ប៉ុន្តែករណីដែល អ្នកទិញមិនទាន់បានទទួលការប្រគល់កម្មវត្ថុពីអ្នកលក់ នោះអ្នកទិញមិនចាំបាច់ត្រូវបង់ការប្រាក់ ឬ ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវទេ។

ជាការពិត គូភាគីអាចបង្កើតកិច្ចព្រមព្រៀងពិសេស ដែលកំណត់ថា អ្នកទិញត្រូវទទួលខុសត្រូវបង់ការប្រាក់នៃប្រាក់ថ្លៃទិញ ឬ បង់ប្រាក់សំណងនៃការខូចខាតដែលកើតឡើង ដោយសារការយឺតយ៉ាវ នៅក្រោយកាលបរិច្ឆេទកំណត់បាន។

### ៥.១.៣. ករណីយកិច្ចទទួលវត្ថុដែលខ្លួនបានទិញ

អ្នកទិញ មានករណីយកិច្ចទទួលកម្មវត្ថុដែលខ្លួនបានទិញ ( មាត្រា ៥៥៤) ។ ប្រសិនបើអ្នកលក់ បានប្រគល់កម្មវត្ថុនៃកិច្ចសន្យាមកឱ្យអ្នកទិញ ប៉ុន្តែ អ្នកទិញ បដិសេធក្នុងការទទួលវត្ថុដែលបានប្រគល់ នោះអ្នកទិញត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវនៅក្នុងការទទួល ( មាត្រា ៥៥៩) ។ ដូច្នេះ ប្រសិនបើអ្នកទិញ បដិសេធក្នុងការ

ទទួលនូវសំណើផ្តល់ការអនុវត្តកាតព្វកិច្ច ដោយសារកំហុសរបស់អ្នកទិញ នោះអ្នកលក់អាចទាមទារសំណងនៃការខូចខាត និង អ្នកលក់អាចរំលាយកិច្ចសន្យានេះ ក្នុងករណីដែលការមិនទទួលយកការអនុវត្តកាតព្វកិច្ចរបស់អ្នកលក់ គឺជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ( មាត្រា ៥៥៩ កថាខណ្ឌទី ១) ។

ក្នុងករណីដែល កម្មវត្ថុ ត្រូវបានបាត់បង់ ឬ ខូចខាត ដោយគ្មានកំហុសរបស់អ្នកលក់ នោះវា គឺជាបញ្ហានៃ "ការទទួលបន្ទុកហានិភ័យ"។ នៅក្នុងករណីនេះ អ្នកទិញ ត្រូវទទួលបន្ទុកហានិភ័យចំពោះការខូចខាត ឬ ការបាត់បង់ ( មាត្រា ៥៥៩ កថាខណ្ឌទី ២) ។

ទន្ទឹមនឹងនេះ ក្នុងករណីដែលអ្នកលក់ បានផ្តល់នូវការសង តែអ្នកទិញនៅតែមិនព្រមទទួលវត្ថុដែលជាកម្មវត្ថុ អ្នកលក់អាចតំកល់ ឬ លក់វត្ថុដែលជាកម្មវត្ថុនោះ តាមបញ្ញត្តិនៃមាត្រា ៤៥៧ និង មាត្រា ៤៥៨ ( មាត្រា ៥៥៩ កថាខណ្ឌទី ៣) ។

### ៥.២. សិទ្ធិទូទៅរបស់អ្នកទិញ

អ្នកទិញ មានសិទ្ធិទាមទារឱ្យប្រគល់កម្មវត្ថុ ។

ក្រោយពេលដែលអ្នកទិញ បានបង់ថ្លៃទិញហើយ នោះអ្នកទិញ អាចទទួលផល ( ការបកស្រាយផ្ទុយនឹងមាត្រា ៥៥៣) ។

### ៥.៣. សិទ្ធិបដិសេធមិនបង់ថ្លៃទិញ

ក្នុងកិច្ចសន្យាលក់ទិញ ភាគីអ្នកទិញ មានករណីយកិច្ចបង់ថ្លៃទិញទៅឱ្យអ្នកលក់ ( មាត្រា ៥៥៥) ។ ក៏ប៉ុន្តែក្នុងករណីខ្លះ ភាគីអ្នកទិញ ក៏មានសិទ្ធិបដិសេធមិនបង់ថ្លៃទិញបានដែរ ។ ករណីទាំងនោះ មានដូចជា :

#### ៥.៣.១. ក្នុងករណីដែលតតិយជន អះអាងពីសិទ្ធិរបស់ខ្លួនលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ

ប្រសិនបើអ្នកទិញ នឹងបាត់បង់នូវសិទ្ធិទាំងអស់ ឬ មួយភាគដែលខ្លួនបានទិញ ដោយសារតែមានតតិយជនអះអាងពីសិទ្ធិ ដូចជា កម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍នៅលើកម្មវត្ថុ នោះអ្នកទិញអាចបដិសេធមិនបង់ថ្លៃទិញទាំងអស់ ឬ មួយភាគទៅតាមសមាមាត្រនៃទំហំនៃហានិភ័យនោះ ( មាត្រា ៥៥៧) ។ ប៉ុន្តែ អ្នកទិញ មិនអាចបដិសេធមិនបង់ថ្លៃទិញ ប្រសិន បើអ្នកលក់ បានដាក់នូវប្រាតិភោគសមរម្យទៅឱ្យអ្នកទិញ ។

អ្នកទិញ អាចទាមទារឱ្យអ្នកលក់ ត្រូវទទួលខុសត្រូវក្នុងការធានា ( ការរំលាយកិច្ចសន្យា ការបន្ថយថ្លៃទិញ ការជួសជុល ការប្រគល់វត្ថុជំនួស ការសងសំណងនៃការខូចខាត) ប្រសិនបើតតិយជន មានសិទ្ធិ ដូចជាកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍លើកម្មវត្ថុនោះ។ ហើយ ថាតើតតិយជន មានសិទ្ធិលើកម្មវត្ថុនោះ ឬ អត់ គឺត្រូវសម្រេចដោយតុលាការ តាមនីតិវិធីច្បាប់ ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកទិញ ត្រូវបង់ប្រាក់ថ្លៃទិញនៅមុនពេលកំណត់សិទ្ធិនោះវានឹងដាក់បន្ទុកមិនសមហេតុផលទៅលើអ្នកទិញ ព្រោះគាត់ ត្រូវទាមទារឱ្យអ្នកលក់សងប្រាក់ថ្លៃទិញមកវិញដោយផ្អែកលើការរំលាយកិច្ចសន្យា ឬ ការបន្ថយប្រាក់ថ្លៃទិញ។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានទទួលស្គាល់នូវសិទ្ធិបដិសេធបង់ថ្លៃទិញ តាមសមាមាត្រទៅនឹងទំហំនៃហានិភ័យ ។

លក្ខខណ្ឌនៃសិទ្ធិនេះ គឺ

(ក). អត្ថិភាពនៃហានិភ័យ ដែលអ្នកទិញ នឹងអាចបាត់បង់សិទ្ធិដែលខ្លួនបានទិញ

(ខ). អ្នកលក់ ទាមទារឱ្យបង់ប្រាក់

(គ). អ្នកលក់ មិនបានផ្តល់នូវប្រាតិភោគសមរម្យ

"ទំហំនៃហានិភ័យ" សំដៅទៅលើ ថាតើគាត់នឹងអាចបាត់បង់កម្មវត្ថុទំហំប៉ុន្មាន មិនមែនសំដៅទៅលើហានិភ័យខ្ពស់កម្រិតណា ដែលគាត់ នឹងអាចបាត់បង់សិទ្ធិនោះទេ។ ឧទាហរណ៍ នៅក្នុងករណីដែលមានតតិយជនដែលអះអាងពីកម្មសិទ្ធិ នៅលើផ្នែកពាក់កណ្តាលនៃកម្មវត្ថុនោះ អ្នកទិញ អាចបដិសេធមិនបង់ប្រាក់ថ្លៃទិញទាំងអស់បាន ប្រសិនបើ គេទទួលស្គាល់ អ្នកទិញ នឹងមិនទិញកម្មវត្ថុ នៅពេលវាមាននៅសល់តែពាក់កណ្តាល (មាត្រា ៥៣៣ កថាខណ្ឌទី ២)។

ជាងនេះទៅទៀត សិទ្ធិបដិសេធមិនបង់ថ្លៃទិញនេះ គឺមានតួនាទីជាការតវ៉ា។ ដូច្នេះ អ្នកទិញ មិនចាំបាច់លើកឡើងពីសិទ្ធិនេះ រហូតដល់អ្នកលក់ ទាមទារឱ្យបង់ប្រាក់ថ្លៃទិញ។

### ៥.៣.២. ការតវ៉ាឱ្យអនុវត្តព្រមគ្នា

អ្នកទិញ អាចមិនព្រមបង់ថ្លៃទិញបាន រហូតដល់ពេលដែលអ្នកលក់ បានផ្តល់នូវការសងចំពោះកាតព្វកិច្ចរបស់ខ្លួន (មាត្រា ៥៥៨ កថាខណ្ឌទី ១)។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកលក់ មិនទាន់ដល់ពេលកំណត់ត្រូវសង ឬ ករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តកាតព្វកិច្ចបង់ថ្លៃជាមុន។

### ៥.៣.៣. ការតវ៉ាដោយមានការបារម្ភ

ទោះបីជាអ្នកទិញ បានអនុញ្ញាតឱ្យអ្នកលក់មានពេលកំណត់ដើម្បីអនុវត្តកាតព្វកិច្ចក៏ដោយ ប្រសិនបើមានការបារម្ភ យ៉ាងជាក់ស្តែងថា អ្នកលក់ នឹងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក៏អ្នកទិញ អាចប្រកែកមិនបង់ថ្លៃទិញបានដែរ (មាត្រា ៥៥៨ កថាខណ្ឌទី ២)។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកលក់បានដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការដើម្បីរំលត់ការបារម្ភនោះ ។

ករណីសិក្សា

**ក** បានលក់ទូរទស្សន៍មួយគ្រឿងទៅឱ្យ **ខ** ហើយ **ក** បានប្រគល់ទូរទស្សន៍នៅផ្ទះរបស់ **ខ** ពេលកាលបរិច្ឆេទបានមកដល់។ ក៏ប៉ុន្តែ **ខ** មិននៅផ្ទះនាកាលបរិច្ឆេទនោះ ព្រោះ **ខ** ភ្លេចថា **ក** នឹងមកប្រគល់ទូរទស្សន៍ ហើយក៏បានធ្វើដំណើរកំសាន្តទៅឆ្ងាយបាត់ទៅ។ បន្ទាប់មក **ក** បានយកទូរទស្សន៍ត្រឡប់ទៅវិញ ហើយបានទុកនៅក្នុងឃ្លាំងដែល **ក** បានជួលពី **គ**។ ហើយ **ក** បានបង់ប្រាក់ ១០ ដុល្លារ ទៅឱ្យ **គ** សម្រាប់ជាថ្លៃជួល។ តើ **ក** អាចទាមទារអ្វីបាន ចំពោះ **ខ** ?

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

តាមសម្មតិកម្មខាងលើនេះ យើងឃើញថា **ខ** មានការយឺតយ៉ាវក្នុងការទទួលទូរទស្សន៍ពី **ក** នៅកាលបរិច្ឆេទតាមកិច្ចសន្យា ដោយសារកំហុសរបស់ **ខ**។ ផ្ទុយទៅវិញ **ក** បានបង់ប្រាក់ថ្លៃជួលឃ្លាំងចំនួន ១០ ដុល្លារ ទៅឱ្យ **គ**។ ដូចនេះ **ក** អាចទាមទារពី **ខ** នូវថ្លៃជួលឃ្លាំងចំនួន ១០ ដុល្លារ បាន ដោយសារការយឺតយ៉ាវក្នុងការទទួលរបស់ **ខ** ដោយផ្អែកតាមមាត្រា ៥៥៩ កថាខណ្ឌទី១។ ក៏ប៉ុន្តែ កំហុសរបស់ **ខ** មិនអាចត្រូវបានចាត់ទុកថាជា ការបំពានកិច្ចសន្យាធ្ងន់ធ្ងរទេ (មាត្រា ៤០៨) ព្រោះ **ក** ចាំបាច់ត្រូវធ្វើការដាស់តឿនឱ្យ **ខ** ទទួលយកទូរទស្សន៍ ដោយកំណត់អំឡុងពេលសមរម្យ ដើម្បីធ្វើឱ្យ **ខ** ស្ថិតក្នុងស្ថានភាពបំពានកិច្ចសន្យាធ្ងន់ធ្ងរ (មាត្រា ៤០៨ កថាខណ្ឌ ទី ១ ចំណុច **ក**)។ ដូច្នេះ **ក** អាចរំលាយកិច្ចសន្យាបានតែក្នុងករណីដែល **ខ** មិនទទួលយកទូរទស្សន៍នោះ នៅក្នុងអំឡុងពេលនោះ។

## ផ្នែកទី ២

## ប្រទានកម្ម

### ១. គោលគំនិតនៃប្រទានកម្ម

ប្រទានកម្ម សំដៅទៅលើកិច្ចសន្យាមួយ ដែលត្រូវមានអានុភាព ដោយភាគីម្ខាង (=ទាយក) បង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀត (=បដិគ្គាហក) នូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀត យល់ព្រមទទួល ( មាត្រា ៥៦៨) ។

**- កិច្ចសន្យាមិនយកតម្លៃថ្នូរ**

ប្រទានកម្ម គឺជាកិច្ចសន្យាមួយប្រភេទ ឧទាហរណ៍ដូចជា ភាគីម្ខាងផ្តល់ទូរស័ព្ទរបស់ខ្លួន ទៅឱ្យភាគីម្ខាងទៀត ដោយមិនទាមទារតាវកាលិកតប ។ នេះ មានន័យថា ប្រទានកម្ម គឺជាកិច្ចសន្យាមិនយកតម្លៃថ្នូរ ។

**- កិច្ចសន្យាឯកតោភាគី**

ប្រទានកម្ម គឺជាកិច្ចសន្យាឯកតោភាគី ពីព្រោះ មានតែទាយក ទទួលនូវកាតព្វកិច្ចតែឯកឯង លើការប្រគល់នូវកម្មវត្ថុនៃប្រទានកម្មទៅឱ្យបដិគ្គាហក ។ ចំណែកឯ បដិគ្គាហក មិនបំពេញកាតព្វកិច្ចតបទៅវិញទេ គឺគ្រាន់តែបង្ហាញឆន្ទៈយល់ព្រមទទួលនូវកម្មវត្ថុនៃប្រទានកម្មប៉ុណ្ណោះ ។

**- បញ្ញត្តិនៃកិច្ចសន្យាលក់ទិញ មិនត្រូវយកមកអនុវត្ត**

បញ្ញត្តិទាក់ទងនឹងកិច្ចសន្យាលក់ទិញ មិនត្រូវយកមកអនុវត្តដូចគ្នាទេ ព្រោះ ប្រទានកម្ម គឺជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ មិនមែនជាកិច្ចសន្យាដែលយកតម្លៃថ្នូរនោះទេ ។

### ២. លក្ខខណ្ឌ

**គោលការណ៍ : ការព្រមព្រៀង**

ប្រទានកម្ម គឺជាកិច្ចសន្យា ដែលតម្រូវឱ្យមានការព្រមព្រៀងរវាងទាយក និងបដិគ្គាហក ហើយកិច្ចសន្យាប្រទានកម្មនេះ អាចត្រូវបានបង្កើតឡើងដោយគ្រាន់តែមានការព្រមព្រៀងរវាងគូភាគីប៉ុណ្ណោះ ។

ក៏ប៉ុន្តែ នៅក្នុងករណីនៃកិច្ចសន្យាប្រទានកម្មអចលនវត្ថុ វានឹងមានអានុភាព លុះត្រាតែបានធ្វើជាលិខិតយថាភូត ( មាត្រា ៥៦៩ និង មាត្រា ៣៣៦ កថាខណ្ឌទី ២) ។

## ៣. ករណីយកិច្ចរបស់ទាយក

### ៣.១. កាតព្វកិច្ចផ្ទេរសិទ្ធិ

នៅក្នុងកិច្ចសន្យាប្រទានកម្ម ទាយក មានកាតព្វកិច្ចត្រូវផ្ទេរសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃប្រទានកម្មទៅឱ្យបដិគ្គាហក ដោយមិនយកថ្លៃ ( មាត្រា ៥៦៨) ។ ចំពោះ ប្រទានកម្មលើទ្រព្យសម្បត្តិ យើងឃើញថា សិទ្ធិលើទ្រព្យសម្បត្តិ ត្រូវបានផ្ទេរពីទាយកទៅបដិគ្គាហក ហើយក្នុងចំណោមសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះ សិទ្ធិចម្បងជាងគេ គឺជាកម្មសិទ្ធិ។ ដូចនេះ ប្រសិនបើកម្មសិទ្ធិត្រូវបានផ្ទេរ តាមរយៈប្រទានកម្ម គឺត្រូវយកមាត្រា ១៣៣ មាត្រា ១៣៤ មាត្រា ១៣៥ មាត្រា ១៦០ និង មាត្រា ១៨៧ នៃក្រមរដ្ឋប្បវេណី មកអនុវត្ត ( មាត្រា ៥៦៩) ។

ឧទាហរណ៍: **ក** ធ្វើប្រទានកម្មផ្ទះមួយល្វែងទៅឱ្យ **ខ** ហើយ **ខ** យល់ព្រមទទួលនូវប្រទានកម្មនោះ ដូចនេះ កិច្ចសន្យាប្រទានកម្ម ត្រូវបានបង្កើតឡើង។ បន្ទាប់ពីកិច្ចសន្យាប្រទានកម្ម ត្រូវបានបង្កើតឡើងហើយនោះ **ក** ត្រូវមានកាតព្វកិច្ចប្រគល់សិទ្ធិនៃកម្មសិទ្ធិលើផ្ទះល្វែងនោះទៅ **ខ**។ ការប្រគល់សិទ្ធិនៃកម្មសិទ្ធិលើផ្ទះនោះ ត្រូវធ្វើដោយមានការចុះបញ្ជីត្រឹមត្រូវ។

ផ្ទុយទៅវិញ បដិគ្គាហក មិនត្រូវទទួលបន្ទុកកាតព្វកិច្ចអ្វីទេ លើកលែងតែ ប្រទានកម្មដោយមានភ្ជាប់បន្ទុក ( មាត្រា ៥៧៦) ។ ដូច្នេះ គេអាចនិយាយថា ប្រទានកម្ម គឺសកម្មភាពអនុគ្រោះ។

### ៣.២. ការបន្ធូរបន្ថយនូវការទទួលខុសត្រូវក្នុងការធានា

ទាយក មិនត្រូវទទួលខុសត្រូវក្នុងការធានាចំពោះវិការៈនៃគុណភាពនៃវត្ថុ ដែលជាកម្មវត្ថុនៃប្រទានកម្ម ឬ វិការៈនៃសិទ្ធិនោះ ជាទូទៅឡើយ ( មាត្រា ៥៧៤) ។ ចំពោះកិច្ចសន្យាប្រទានកម្ម ដែលជាកិច្ចសន្យាមិនយកតម្លៃថ្នូរ ខុសគ្នាពីកិច្ចសន្យាលក់ទិញ និង កិច្ចសន្យាផ្សេងទៀត ដែលយកតម្លៃថ្នូរ ទោះបីជាវត្ថុ ដែលជាកម្មវត្ថុនៃប្រទានកម្មមានវិការៈនៅពេលធ្វើកិច្ចសន្យាក៏ដោយ ក៏វាមិនសមរម្យដែរ ដែលដាក់បន្ទុកធ្ងន់ទៀតទៅលើទាយកបន្ថែមពីលើបន្ទុកចំពោះការប្រគល់នូវវត្ថុ ទៅតាមស្ថានភាពបច្ចុប្បន្នរបស់វានោះ។

ក៏ប៉ុន្តែ ប្រសិនបើទាយក បានដឹងអំពីអត្ថិភាពនៃវិការៈ ឬ ការខ្វះនោះ ប៉ុន្តែ មិនបានផ្ដល់ដំណឹង ទាយក មិនអាចរួចផុតពីការទទួលខុសត្រូវទេ (វាក្យខណ្ឌទី ២ នៃមាត្រា ៥៧៤) ។ នេះ គឺជាសញ្ញាមួយនៃគោលការណ៍នៃភាពសុចរិត និង ស្មោះត្រង់ ( មាត្រា ៥) ។ នៅក្នុងករណីនេះ គេអាចចាត់ទុកថា វាមិនមានលក្ខណៈសមរម្យទេ ដែលទាយក ត្រូវទទួលខុសត្រូវដូចគ្នាទៅនឹងអ្នកលក់ដែរ ព្រោះប្រទានកម្ម គឺជាកិច្ចសន្យាមិនយកតម្លៃថ្នូរ។ ឬ និយាយម្យ៉ាងទៀត គេអាចថា ការទទួលខុសត្រូវរបស់អ្នកទាយក ដែលធ្វើសកម្មភាពដោយទុច្ចរិត ត្រូវបានបន្ធូរបន្ថយ បើប្រៀបធៀបទៅនឹងអ្នកលក់។

## ៩. ការលុបចោលប្រទានកម្ម

### ៩.១. នៅក្នុងករណីប្រទានកម្ម ដែលមិនធ្វើជាលាយលក្ខណ៍អក្សរ

ដោយសារប្រទានកម្ម ទាមទារឱ្យមានតែការព្រមព្រៀងរវាងគូភាគីតែប៉ុណ្ណោះ ដូចនេះ ប្រទានកម្មមិនតម្រូវឱ្យធ្វើជាលិខិតអ្វីនោះទេ ហើយភាគច្រើន ត្រូវបានធ្វើដោយផ្ទាល់មាត់។ ប្រសិនបើភាគី មិនបានធ្វើជាលិខិតទាក់ទងនឹងប្រទានកម្ម នោះភាគីណាមួយ ក៏អាចលុបចោលកិច្ចសន្យា ដោយដកការបង្ហាញឆន្ទៈរបស់ខ្លួន (មាត្រា ៥៧០ វាក្យខណ្ឌទី ១)។ អានុភាពនៃការលុបចោល ត្រូវបង្កើតឡើងដោយឯកតោភាគី ហើយមិនចាំបាច់មានការយល់ព្រមទេ។ គោលដៅនៃមាត្រានេះ គឺដើម្បីធ្វើការលុបចោល ដោយមានលក្ខណៈងាយស្រួល ប្រសិនបើទាយកបានឱ្យទ្រព្យសម្បត្តិរបស់ខ្លួន ដោយមិនបានគិតគូរឱ្យជិតដល់។ ឬនិយាយម្យ៉ាងទៀត ប្រសិនបើឆន្ទៈរបស់ទាយក ត្រូវបានបង្ហាញតាមរូបភាពជាលាយលក្ខណ៍អក្សរ ការបង្ហាញឆន្ទៈរបៀបនេះ គឺជាលទ្ធផលនៃការវិនិច្ឆ័យដោយប្រុងប្រយ័ត្នរបស់ទាយក ហើយឆន្ទៈនោះអាចត្រូវបានធ្វើការបញ្ជាក់យ៉ាងច្បាស់លាស់ តាមលិខិតជាលាយលក្ខណ៍អក្សរនោះ។ ដោយហេតុនេះ បដិគ្គាហក អាចបង្ខំឱ្យទាយកអនុវត្តនូវកិច្ចសន្យាប្រទានកម្មបាន ប្រសិនបើគូភាគី បានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។

ក៏ប៉ុន្តែ គូភាគី មិនអាចដកការបង្ហាញឆន្ទៈ ចំពោះផ្នែកដែលបានអនុវត្តហើយនោះទេ (មាត្រា ៥៧០ វាក្យខណ្ឌទី ២)។ មូលហេតុ ដែលក្រមរដ្ឋប្បវេណីចែងអំពីបញ្ហានេះ គឺថាប្រសិនបើទាយក បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនហើយ នោះឆន្ទៈរបស់ទាយកក្នុងការឱ្យទ្រព្យសម្បត្តិ បានលេចចេញឡើងកាន់តែច្បាស់។ ដូច្នេះ "ការអនុវត្តកាតព្វកិច្ចត្រូវបានបញ្ចប់" មិនមែនចាំបាច់មានន័យថា ទាយក បានបញ្ចប់នូវកាតព្វកិច្ចរបស់ខ្លួនទាំងអស់នោះទេ ប៉ុន្តែ គ្រាន់តែផ្នែកចម្បងនៃកាតព្វកិច្ច ដែលត្រូវបានអនុវត្ត។ ជាទូទៅ ការផ្ទេរចលនវត្ថុ ឬ ការចុះបញ្ជីអចលនវត្ថុ ដោយគ្មានការផ្ទេរ អាចត្រូវបានចាត់ទុកថា "ការអនុវត្តកាតព្វកិច្ច ត្រូវបានបញ្ចប់"។

**ឧទាហរណ៍ : ក** សន្យាប្រគល់សៀវភៅ ១០ ក្បាល ដែលជាវត្ថុដែលមិនបានកំណត់ជាក់លាក់ទៅឱ្យ **ខ** ប៉ុន្តែពួកគេ មិនបានធ្វើជាលាយលក្ខណ៍អក្សរទេ ទាក់ទងនឹងប្រទានកម្មនេះ។ នៅក្នុងករណីដែល **ក** បានធ្វើការកំណត់សៀវភៅ ១០ ក្បាល ចេញពីសៀវភៅដទៃទៀត **ក** អាចលុបចោលកិច្ចសន្យានេះ ព្រោះគេមិនអាចនិយាយថា គាត់បានបញ្ចប់នូវកាតព្វកិច្ចចម្បងទេ។ ប៉ុន្តែ ប្រសិនបើ **ក** បានប្រគល់សៀវភៅ ១០ ក្បាល ឱ្យទៅ **ខ** នោះ **ក** មិនអាចលុបចោលកិច្ចសន្យាបានទៀតទេ។

មាត្រា ៥៧០ បានប្រើពាក្យ "ភាគីនៃកិច្ចសន្យា" ដូចនេះ មានន័យថា ទាំងទាយក និង បដិគ្គាហក អាចលុបចោលកិច្ចសន្យាប្រទានកម្មបាន។ បដិគ្គាហក មានសិទ្ធិលុបចោលកិច្ចសន្យាប្រទានកម្មបាន ដោយគ្រាន់តែដកការបង្ហាញឆន្ទៈក្នុងការព្រមព្រៀងទទួលយកប្រទានកម្មនោះប៉ុណ្ណោះ។

### ៤.២. នៅក្នុងករណីនៃការរំលោភលើទំនុកចិត្ត ជាអាទិ៍

ជាទូទៅ ប្រទានកម្ម ត្រូវបានធ្វើឡើងរវាងគូភាគី ដែលមានទំនាក់ទំនងជាពិសេស ដូចជា ឪពុកម្ដាយ និង កូន បងប្អូន ឬ អ្នកស្គាល់គ្នាជិតស្និទ្ធ។ ដោយផ្អែកទៅលើគំនិតនេះ ទាយក អាចលុបចោលប្រទានកម្ម នៅក្នុងករណីដែលបដិគ្គាហក ធ្វើអំពើរំលោភលើទំនុកចិត្តធ្ងន់ធ្ងរ ចំពោះទាយក (មាត្រា ៥៧១ កថាខណ្ឌទី ១)។ "អំពើរំលោភធ្ងន់ធ្ងរ" មានន័យថាជា សកម្មភាពអកត្តញ្ញូធ្ងន់ធ្ងរ ដូចជា អំពើធ្វើទុក្ខបុកម្នេញ ឬ មិនបានបំពេញករណីយកិច្ចចិញ្ចឹមទំនុកបម្រុងឪពុកម្ដាយ នៅពេលដែលពួកគាត់ មិនអាចរកស៊ីចិញ្ចឹមជីវិតបាន។ ឧទាហរណ៍ ឪពុក **ក** បានសន្យាប្រគល់ផ្ទះទៅឱ្យកូនប្រុសរបស់ខ្លួន **ខ**។ តែ **ខ** មិនបានបំពេញករណីយកិច្ចចិញ្ចឹមទំនុកបម្រុងឪពុកម្ដាយ ហើយតែងតែរករឿងបង្កជម្លោះជាមួយ **ក** ដូចនេះ **ក** អាចលុបចោលប្រទានកម្មផ្ទះបាន។

នៅក្នុងករណីខាងលើ ទាយក អាចលុបចោលប្រទានកម្មដែលកាតព្វកិច្ច ត្រូវបានអនុវត្តរួចរាល់ហើយ នៅក្នុងរយៈពេល ៥ ឆ្នាំ គិតចាប់ពីពេលដែលកើតមានការរំលោភលើទំនុកចិត្តធ្ងន់ធ្ងរ ប្រសិនបើកាតព្វកិច្ច ត្រូវបានអនុវត្តរួចរាល់ហើយ (មាត្រា ៥៧១ កថាខណ្ឌទី ២)។

ឧទាហរណ៍ នៅក្នុងករណីខាងលើ **ក** មានសិទ្ធិលុបចោលប្រទានកម្មដែលបានធ្វើរួច ក្នុងអំឡុងពេល ៥ ឆ្នាំ គិតចាប់ពីដែល **ខ** មិនបានបំពេញករណីយកិច្ចទំនុកបម្រុងឪពុកម្ដាយរបស់ខ្លួន។ នៅក្រោយពេលលុបចោល **ក** អាចទាមទារឱ្យ **ខ** សងមកខ្លួនវិញនូវផ្ទះ ដែលខ្លួនបានធ្វើប្រទានកម្មនោះ តាមបញ្ញត្តិស្ដីពីការសងនៃសេចក្ដីចម្រើនដោយឥតហេតុ (មាត្រា ៥៧៣)។

### ៤.៣. នៅក្នុងករណីភាពទីទ័លក្ររបស់ទាយក

នៅក្នុងករណីដែលទាយក បានបង្ហាញឆន្ទៈរបស់ខ្លួន ក្នុងការធ្វើប្រទានកម្ម ហើយបដិគ្គាហក បានយល់ព្រមទទួលហើយ នោះទាយក ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ព្រោះប្រទានកម្មគឺជាកិច្ចសន្យា ហើយលទ្ធិដែលមានលក្ខណៈជារូបភាព ត្រូវយកមកអនុវត្ត។

ផ្ទុយទៅវិញ ការធ្វើប្រទានកម្ម គឺសំដៅលើសកម្មភាពមិនយកកម្រៃថ្នូរ ដោយផ្អែកលើសន្ដានចិត្ត ហើយទាយក ប្រហែលជាមិនរំពឹងទុកនូវការបំពេញកាតព្វកិច្ចតបឡើយ។ ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការរៀបចំឱ្យមានការលុបចោលប្រទានកម្មសម្រាប់ទាយក នៅក្នុងករណីដែលទាយក បានធ្លាក់ខ្លួនក្នុងស្ថានភាពទីទ័លក្រ ទោះបីជាក្នុងករណីដែលប្រទានកម្ម ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរក៏ដោយ។ ដូច្នេះប្រសិនបើមានស្ថានភាពផ្លាស់ប្ដូរក្រោយពេលធ្វើប្រទានកម្ម នោះទាយកអាចទាមទារឱ្យយកអំណោយនោះសងត្រឡប់មកវិញ តាមបញ្ញត្តិនៃមាត្រា ៥៧២ ។ វាមានន័យថា ទាយកអាចលុបចោលប្រទានកម្ម នៅក្នុងករណី :

ក. ទាយក ធ្លាក់ខ្លួនក្នុងស្ថានភាពទីទ័លក្រ ក្រោយការបង្ហាញឆន្ទៈធ្វើប្រទានកម្ម

**និង**

ខ. កម្រិតនៃភាពទីទ័លក្រ បានដល់កម្រិតមួយ ដែលទាយក មិនអាចរក្សាជីវភាពរស់នៅរបស់ខ្លួនផ្ទាល់ និង បុគ្គលដែលគាត់ ត្រូវមានកាតព្វកិច្ចផ្តល់អាហារកាតព្វកិច្ច។

បុគ្គល ដែលទាយក មានកាតព្វកិច្ចផ្តល់អាហារកិច្ច គឺជាធម្មតា មានចែងនៅក្នុងមាត្រា ១១៨០។

គោលបំណងនៃបញ្ញត្តិនេះ គឺដើម្បីជៀសវាងក្នុងការដែលឱ្យទាយកបំពេញកាតព្វកិច្ច ដោយធ្វើការលះបង់នូវជីវិតរបស់ខ្លួន ឬ បុគ្គលដែលខ្លួនមានកាតព្វកិច្ចផ្តល់អាហារកាតព្វកិច្ច នៅក្នុងករណីដែលទាយក បានធ្លាក់ខ្លួនក្នុងភាពទីទ័លក្រ។

នៅក្នុងករណីខាងលើ បដិគ្គាហក អាចលុបចោលប្រទានកម្ម ដែលបានអនុវត្តនៅក្នុងរយៈពេល ៥ ឆ្នាំ គិតចាប់ពីពេលដែលបានអនុវត្ត បើយោងតាមបញ្ញត្តិនៃមាត្រា ៥៧២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី។

ប្រសិនបើទាយក បានធ្លាក់ខ្លួនទៅក្នុងស្ថានភាពទីទ័លក្រ នៅពេលធ្វើកិច្ចសន្យាប្រទានកម្ម ឬ នៅក្រោយពេលធ្វើកិច្ចសន្យា នោះមាត្រា ៥៧២ កថាខណ្ឌទី ១ មិនត្រូវយកមកអនុវត្តឡើយ។

### ៤.៤. *អានុភាពនៃការលុបចោលប្រទានកម្ម*

ការលុបចោលប្រទានកម្ម គឺសំដៅទៅលើសកម្មភាពរបស់ទាយក ក្នុងការទាមទារឱ្យបដិគ្គាហកសងទ្រព្យសម្បត្តិ ដែលបានធ្វើប្រទានកម្មនោះមកវិញ ដោយផ្អែកតាមបញ្ញត្តិស្តីពីការសងនៃសេចក្តីចម្រើនដោយឥតហេតុ (មាត្រា ៥៧៣)។ ហើយនៅក្នុងករណីនៃការលុបចោលប្រទានកម្មនេះ ត្រូវយកមកអនុវត្ត តាមបញ្ញត្តិនៃមាត្រា ៥៧១ និង មាត្រា ៥៧២ នៃក្រមរដ្ឋប្បវេណី។

## ៥. ប្រភេទពិសេសនៃប្រទានកម្ម

### ៥.១. ប្រទានកម្មដោយមានកំណត់ពេល

ប្រទានកម្មដោយមានកំណត់ពេល គឺសំដៅទៅលើប្រទានកម្ម ដែលទាយកផ្តល់នូវទ្រព្យសម្បត្តិជាបន្តបន្ទាប់។ ឧទាហរណ៍ កិច្ចសន្យាប្រទានកម្ម ដែលចែងថា ឪពុក ឱ្យប្រាក់ ២០០ ដុល្លារ ទៅកូនប្រុសរបស់ខ្លួនជារៀងរាល់ខែ។ ស្ទើរតែទាំងអស់នៃប្រទានកម្មប្រភេទនេះ មានគោលដៅដើម្បីផ្គត់ផ្គង់អ្នកណាម្នាក់ ដោយផ្អែកលើទំនាក់ទំនងជាពិសេស ដូចជាឪពុកម្តាយ និង កូន។

*ប្រទានកម្មដែលធ្វើឡើងក្នុងគោលបំណងផ្តល់តាវកាលិកដោយមានកំណត់ពេល ត្រូវបាត់បង់អានុភាពដោយមរណភាពរបស់ទាយក ឬ បដិគ្គាហក* (មាត្រា ៥៧៥)។ ជាទូទៅ សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន (មាត្រា ១១៤៧ កថាខណ្ឌទី ១)។ ក៏ប៉ុន្តែនៅក្នុងករណីប្រទានកម្មដោយមានកំណត់ពេល វាមានលក្ខណៈត្រឹមត្រូវ ដែលគ្មានបុគ្គលណាម្នាក់ ត្រូវទទួលបន្តនូវសិទ្ធិ និង កាតព្វកិច្ច ទាក់ទងនឹងប្រទានកម្មដោយមានកំណត់ពេល ប្រសិនបើមានភាគីណាម្ខាង ទទួលមរណ-

ភាព។ ឧទាហរណ៍ ក្នុងករណីខាងលើ ប្រសិនបើឪពុកទទួលមរណភាព សន្តតិជនដទៃទៀត ដូចជា ប្រពន្ធរបស់មតកជន ឬ បងប្អូនរបស់ទាយក មិនត្រូវទទួលបន្តនូវកាតព្វកិច្ចនៃប្រទានកម្មដោយមានកំណត់ពេលឡើយ។ មូលហេតុគឺថាប្រទានដោយមានកំណត់ពេល ជាទូទៅគឺ ត្រូវបានបង្កើតឡើង ដោយផ្អែកលើទំនាក់ទំនងជាពិសេស រវាងទាយក និង បដិគ្គាហក ដូចដែលបានរៀបរាប់ខាងលើ ដូច្នេះ វាអាចត្រូវបានគេចាត់ទុកថាការបាត់បង់អានុភាពនៃប្រទានកម្ម ក្នុងករណីនៃមរណភាពរបស់ទាយក ឬ បដិគ្គាហក ត្រូវបំពេញនូវឆន្ទៈរបស់ភាគី។

### ៥.២. ប្រទានកម្មដែលមានភ្ជាប់បន្ទុក

ប្រទានកម្មដែលមានភ្ជាប់បន្ទុក គឺសំដៅទៅលើប្រទានកម្ម ដែលបដិគ្គាហក ត្រូវអនុវត្តកាតព្វកិច្ចជាកំណត់ជាក់លាក់ណាមួយ ដើម្បីទទួលបាននូវប្រទានកម្ម។ "បន្ទុក" ដែលបដិគ្គាហក ត្រូវអនុវត្តនៅក្នុងករណីនៃប្រទានកម្មដោយមានភ្ជាប់បន្ទុក មិនមានតំលៃស្មើនឹងកាតព្វកិច្ចរបស់ទាយកឡើយ ព្រោះប្រទានកម្មដែលមានភ្ជាប់បន្ទុកគឺកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ។ ឧទាហរណ៍ នៅក្នុងករណីដែល **ក** និង **ខ** បានបង្កើតកិច្ចព្រមព្រៀងគ្នាថា **ក** ត្រូវឱ្យផ្ទះរបស់ខ្លួនទៅ **ខ** ជាថ្នូរនឹងការអនុញ្ញាតរបស់ **ខ** ឱ្យកូនប្រុសរបស់ **ក** រស់នៅក្នុងផ្ទះនោះ ដែលនេះគឺជាប្រទានកម្មដោយមានភ្ជាប់បន្ទុក។

ប្រសិនបើ បន្ទុក មានតម្លៃស្មើនឹងកាតព្វកិច្ចរបស់ទាយក នោះវា គឺជាកិច្ចសន្យាដែលយកតម្លៃថ្នូរ ដូចជាកិច្ចសន្យាលក់ទិញ ជាអាទិ៍។

ផ្ទុយទៅវិញ នៅក្នុងករណីនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក ភាគីទាំងពីរ ត្រូវទទួលបន្ទុកនូវករណីយកិច្ចក្នុងការផ្តល់តាវកាលិក ហេតុដូចនេះ ភាគីទាំងពីរ ត្រូវមានសិទ្ធិ និង ការទទួលខុសត្រូវ ស្រដៀងគ្នាទៅនឹងបញ្ញត្តិដែលទាក់ទងនឹងកិច្ចសន្យាលក់ទិញ។

#### ១. ការទទួលខុសត្រូវក្នុងការធានា (មាត្រា ៥៧៦ កថាខណ្ឌទី ២)

នៅក្នុងករណីនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក ទាយក ត្រូវទទួលខុសត្រូវក្នុងការធានា ដូចអ្នកលក់ នៅក្នុងទំហំនៃបន្ទុក។ ឧទាហរណ៍ ឪពុក **ក** បានបង្កើតកិច្ចព្រមព្រៀងជាមួយនឹងកូនរបស់គាត់ **ខ** ថា **ក** ត្រូវឱ្យដីរបស់ខ្លួន ដែលមានតម្លៃ ១០.០០០ ដុល្លារ ជាថ្នូរនឹង **ខ** ត្រូវឱ្យប្រាក់ ៣.០០០ ដុល្លារ សម្រាប់ការចំណាយក្នុងការរស់នៅរបស់ **ក**។ ក្រោយមក គេបានដឹងថា ដីនោះ គឺជាកម្មសិទ្ធិអវិភាគរបស់ **ក** និង បងប្រុសរបស់ខ្លួន **គ** ហើយចំណែករបស់ **ក** មានតែមួយភាគបួន តែប៉ុណ្ណោះ (វា មានន័យថា តម្លៃនៃចំណែករបស់ **ក** គឺមានតែ ២.៥០០ ដុល្លារ តែប៉ុណ្ណោះ)។ នៅក្នុងករណីនេះ តម្លៃនៃបន្ទុករបស់ **ខ** គឺធំជាងតម្លៃនៃកម្មវត្ថុនៃប្រទានកម្មដែលមានភ្ជាប់បន្ទុកទៀត។ ដូច្នេះ ដោយផ្អែកលើមាត្រា ៥៧៦ កថាខណ្ឌទី ២ **ខ** អាចបដិសេធក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងទំហំនៃតម្លៃដែលលើស ប្រសិនបើគាត់ មិនទាន់បានអនុវត្តនូវបន្ទុករបស់ខ្លួន នៅឡើយទេ ដូច្នេះ **ខ** អាចបដិសេធក្នុងការបង់ប្រាក់ចំនួន ៥០០ ដុល្លារ។ ប្រសិនបើ គាត់ បានអនុវត្តបន្ទុករបស់ខ្លួនរួចរាល់ហើយ គាត់អាចទាមទារឱ្យ **ក** សងប្រាក់ ៥០០ ដុល្លារ មកវិញ ដែលជាសេចក្តីចម្រើនដោយឥតហេតុ។

### ២. សិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ( មាត្រា ៥៧៦ កថាខណ្ឌទី ៣)

ប្រសិនបើភាគីម្ខាង បានផ្តល់តាវកាលិកហើយ នោះគាត់ មានសិទ្ធិទាមទារចំពោះភាគីម្ខាងទៀត ឱ្យផ្តល់តាវកាលិកបាន។ ចំពោះប្រទានកម្មទូទៅ មានតែទាយកទេដែលត្រូវអនុវត្តកាតព្វកិច្ច ហើយគេសន្មតថា ទាយក មិនអាចទាមទារអ្វីបានទាំងអស់ពីបដិគ្គាហក។ ក៏ប៉ុន្តែ នៅក្នុងករណីនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក ទាយក អាចទាមទារឱ្យ បដិគ្គាហក ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ប្រសិនបើទាយក បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនរួចរាល់ហើយ។

### ៣. ការតវ៉ាឱ្យអនុវត្តព្រមគ្នា ( មាត្រា ៥៧៦ កថាខណ្ឌទី ៤)

ជាទូទៅ ការតវ៉ាឱ្យអនុវត្តព្រមគ្នា ត្រូវបានទទួលស្គាល់នៅក្នុងកិច្ចសន្យាទ្វេភាគី ( មាត្រា ៣៨៦)។ ក៏ប៉ុន្តែ ភាគីនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក មានការតវ៉ាឱ្យអនុវត្តព្រមគ្នា ព្រោះភាគីទាំងពីរមានករណីយកិច្ច ផ្តល់តាវកាលិក ហើយវាស្រដៀងគ្នាទៅនឹងកិច្ចសន្យាទ្វេភាគី។

### ៤. សិទ្ធិរំលាយកិច្ចសន្យារបស់ទាយក ( មាត្រា ៥៧៦ កថាខណ្ឌទី ៥)

ជាទូទៅ សិទ្ធិរំលាយ ត្រូវបានទាញចេញពីលក្ខណៈនៃតម្លៃសមមូលនៃកិច្ចសន្យាទ្វេភាគី។ ក៏ប៉ុន្តែ នៅក្នុងករណីដែល បដិគ្គាហក មិនអនុវត្តបន្ទុករបស់ខ្លួន ទាយក អាចរំលាយកិច្ចសន្យាប្រទានកម្ម ដោយផ្អែកលើបញ្ញត្តិទាក់ទងនឹងការរំលាយ។ ឬនិយាយម្យ៉ាងទៀត ទាយក អាចរំលាយកិច្ចសន្យាបាន តែក្នុងករណីដែលការមិនអនុវត្តកាតព្វកិច្ចរបស់បដិគ្គាហក ចាត់ចូលជា "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ"។ ឧទាហរណ៍ ឪពុក **ក** បានផ្តល់ដីមួយកន្លែងឱ្យទៅកូនប្រុសរបស់ខ្លួន **ខ** ដោយតាមលក្ខខណ្ឌថា **ខ** ត្រូវរស់នៅជាមួយនឹង **ក** ប៉ុន្តែ **ខ** បដិសេធមិនព្រមរស់នៅជាមួយ **ក** ក្រោយពីការចុះបញ្ជី។ នៅក្នុងករណីនេះ **ក** អាចរំលាយកិច្ចសន្យាប្រទានកម្ម ព្រោះការមិនអនុវត្តកាតព្វកិច្ចរបស់ **ខ** អាចត្រូវបានចាត់ទុកថាជា "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ"។

## ៥.៣. ប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក

ប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក សំដៅទៅលើប្រទានកម្ម ដែលយកមរណភាពរបស់ទាយកជាលក្ខខណ្ឌ ដើម្បីបង្កើតអានុភាព។ បញ្ញត្តិទាក់ទងនឹងអច្ច័យទាន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃប្រទានកម្មដោយមូលហេតុមរណភាព ( មាត្រា ៥៧៧ កថាខណ្ឌទី ២)។

អច្ច័យទាន ( មាត្រា ១១៩៩) គឺជាប្រទានកម្ម ដែលម្ចាស់បណ្តាំឱ្យនូវទ្រព្យសម្បត្តិរបស់ខ្លួន តាមរយៈមតកសាសន៍។ មតកសាសន៍ នឹងបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ( មាត្រា ១១៩៤ កថាខណ្ឌទី ១)។ ដូច្នេះ ប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក និង អច្ច័យទាន មានលក្ខណៈ ដូចគ្នា គឺថា វា មានអានុភាពចាប់ពីពេលមរណភាពរបស់ម្ចាស់បណ្តាំ។

ក៏ប៉ុន្តែ នៅក្នុងករណីនៃប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក ការព្រមព្រៀងរវាងទាយក និង បដិគ្គាហក គឺតម្រូវឱ្យមាន ដើម្បីបង្កើតប្រទានកម្មនេះ ព្រោះវា គឺជាកិច្ចសន្យា។ ផ្ទុយទៅវិញ ការព្រមព្រៀង គឺមិនតម្រូវឱ្យមានទេ នៅក្នុងករណីនៃអច្ច័យទាន ព្រោះវាគឺជាសកម្មភាពឯកតោភាគី។ ជាងនេះទៅទៀត បញ្ញត្តិ

ទាក់ទងនឹងការបោះបង់ ( មាត្រា ១២០១) ឬ ការទទួលស្គាល់ ( មាត្រា ១២០២ និង ១២០៣) មិនត្រូវយកមកអនុវត្តដូចគ្នា ចំពោះប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយកឡើយ ព្រោះវាមិនអាចទទួលស្គាល់នូវការអនុវត្តបញ្ញត្តិទាំងនេះ។

**ករណីសិក្សា**

ឪពុកម្តាយ បានឱ្យដីមួយកន្លែងទៅកូនប្រុសរបស់ខ្លួន ហើយបន្ទាប់មកកូនប្រុសនោះ បានសាងសង់ផ្ទះនៅលើដីនោះ។ ការផ្ទេរកម្មសិទ្ធិត្រូវបានចុះបញ្ជី។ ក្រោយមក ឪពុកម្តាយទាមទារឱ្យប្រគល់ដីត្រឡប់មកវិញ ព្រោះពួកគាត់ បានខឹងនឹងកូនប្រុសនោះ។ តើឪពុកម្តាយ អាចលុបចោលប្រទានកម្មបានដែរ ឬ ទេ?

(១) នៅក្នុងករណីដែល ឪពុកម្តាយ ខឹងជាមួយនឹងកូនប្រុសរបស់ខ្លួន ព្រោះ កូនប្រុសនោះ តែងតែផ្លាស់ប្តូរការងារពីមួយកន្លែង ទៅមួយកន្លែងទៀត។

(២) នៅក្នុងករណីដែល ឪពុកម្តាយ ខឹងជាមួយនឹងកូនប្រុសរបស់ខ្លួន ព្រោះ ឪពុកម្តាយ បានឱ្យដីនោះ ជាមួយនឹងការសន្យាថា កូនប្រុសរបស់គាត់ នឹងត្រូវមើលថែរក្សាពួកគាត់។ ប៉ុន្តែ កូនប្រុសរបស់គាត់ បានបដិសេធមិនព្រមចិញ្ចឹម និង ថែរក្សាពួកគាត់ទេ។

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

ជាគោលការណ៍ ការផ្ទេរកម្មសិទ្ធិនៃអចលនវត្ថុ តាមរយៈកិច្ចសន្យាប្រទានកម្ម ត្រូវអនុលោមតាមមាត្រា ១៣៥ ( មាត្រា ៥៦៩)។ ដូច្នេះ ការផ្ទេរកម្មសិទ្ធិត្រូវបង្កើតអានុភាព នៅពេលដែលការផ្ទេរកម្មសិទ្ធិនោះ ត្រូវបានចុះបញ្ជី។ នៅក្នុងករណីនេះ ការចុះបញ្ជី ត្រូវបានធ្វើរួចរាល់ហើយ។

(១) ឪពុកម្តាយ មិនអាចលុបចោលប្រទានកម្មបានទេ។

នៅក្នុងករណីទី ១ នេះ ឪពុកម្តាយ ខឹងនឹងកូនប្រុសរបស់គាត់ គ្រាន់តែដោយសារតែមូលហេតុ ដែលកូនប្រុសរបស់គាត់ ឧស្សាហ៍ផ្លាស់ប្តូរការងារពីកន្លែងមួយទៅកន្លែងមួយទៀត។ ហើយវាក៏មិនមានលក្ខខណ្ឌក្នុងការឱ្យដីនោះដែរ ដូច្នេះ ពួកគាត់ មិនអាចលុបចោលប្រទានកម្មនេះ ដោយផ្អែកលើមាត្រា ៥៧១ បានទេ។

(២) ឪពុកម្តាយ អាចលុបចោល ឬ រំលាយកិច្ចសន្យាប្រទានកម្មបាន។

នៅក្នុងករណីទី ២ នេះ គឺមានមធ្យោបាយពីរ ដែលអាចធ្វើទៅបាន។ ប្រសិនបើ សកម្មភាពរបស់កូនប្រុសនោះ ត្រូវគ្នានឹងមាត្រា ៥៧១ នោះ ពួកគាត់ អាចលុបចោលប្រទានកម្មបាន។ ដូចដែលបានរៀបរាប់ ដើម្បីទទួលស្គាល់នូវ "ការបំពានធ្ងន់ធ្ងរ" វាមិនទាន់គ្រប់គ្រាន់ទេ ដែលគ្រាន់តែបដិគ្គាហកប្រឆាំងនឹងឆន្ទៈរបស់ទាយក លុះត្រាតែបដិគ្គាហកប្រព្រឹត្តអំពើអកត្តញ្ញូ ធ្ងន់ធ្ងរ។ នៅក្នុងករណីទី ២ គេអាចចាត់ទុកថាឪពុកម្តាយរំពឹងទុក នូវការចិញ្ចឹម និង ការមើលថែរក្សាពីកូនប្រុសរបស់ពួកគាត់ ហើយកូនប្រុសរបស់គាត់ក៏បានដឹងអំពីចំណុចនេះដែរ។ ដូច្នេះ ការ

មិនអនុវត្តករណីយកិច្ចចិញ្ចឹម និង មើលថែរក្សាពួកគាត់ត្រូវបានចាត់ទុកថា គឺជាការបំពានយ៉ាងធ្ងន់ធ្ងរទៅលើទំនុកចិត្តរបស់ឪពុកម្តាយ ។

គំនិតដែលអាចមានផ្សេងមួយទៀត គឺថាករណីយកិច្ចក្នុងការចិញ្ចឹម និង មើលថែរក្សា គឺជាបន្ទុកនៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក ។ ប្រសិនបើ បដិគ្គាហក មិនអនុវត្តករណីយកិច្ចរបស់ខ្លួនទេ នោះ គេ នឹងចាត់ទុកថា វា គឺជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ហើយឪពុកម្តាយអាចរំលាយកិច្ចសន្យាប្រទានកម្មបាន (មាត្រា ៥៧៦ កថាខណ្ឌទី ៥) ។ នៅក្នុងករណីនេះ កូនប្រុសបានសន្យាថានឹងចិញ្ចឹម និង មើលថែរក្សាពួកគាត់ ប៉ុន្តែ កូនប្រុស នោះបែរជាបដិសេធមិនអនុវត្តករណីយកិច្ចរបស់ខ្លួនទៅវិញ ហើយដែលជាទូទៅ វាត្រូវបានចាត់ទុកថាជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។ ដូច្នេះ ឪពុកម្តាយ អាចរំលាយកិច្ចសន្យាប្រទានកម្ម ដោយផ្អែកលើបញ្ញត្តិទាក់ទងនឹងការរំលាយកិច្ចសន្យា ។

## ផ្នែកទី ៣

## ភតិសន្យា

### ១. គោលគំនិតនៃភតិសន្យា

#### ១.១. និយមន័យ

ភតិសន្យា សំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាង អនុញ្ញាតឱ្យភាគីម្ខាងទៀត ប្រើប្រាស់ និង អាស្រ័យផលពីវត្ថុណាមួយ ដោយយកថ្លៃ ( មាត្រា ៥៩៦) ។ ភតិបតី មិនចាំបាច់ត្រូវតែមានកម្មសិទ្ធិនោះទេ ប៉ុន្តែ គ្រាន់តែមានសិទ្ធិប្រើ និង អាស្រ័យផល។ ឧទាហរណ៍ អ្នកជួលអចិន្ត្រៃយ៍ ម្ចាស់សិទ្ធិផលុបភោគ ឬ ភតិកៈ អាចជួលបន្តនូវកម្មវត្ថុនោះបាន ដោយស្ថិតនៅក្រោមលក្ខខណ្ឌកំណត់ជាក់លាក់ ( មាត្រា ២៥២ កថាខណ្ឌទី ២ មាត្រា ២៦៤ និង មាត្រា ៦០៨ កថាខណ្ឌទី ១) ។

#### ១.២. លក្ខខណ្ឌ

ភតិសន្យា ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងគូភាគី។ ការធ្វើជាលាយលក្ខណ៍អក្សរ មិនតម្រូវឱ្យមាននោះទេ។

ទោះបីជាភាគី មិនបានកំណត់ពីអំឡុងពេលនៃការជួលក៏ដោយ ក៏កិច្ចសន្យានោះ នៅតែមានសុពលភាព។ ក៏ប៉ុន្តែ ការកំណត់តម្លៃឈ្នួល គឺតម្រូវឱ្យមាន។

#### ១.៣. លក្ខខណ្ឌតតាំង

ភតិបតី មានកម្មសិទ្ធិនៅលើកម្មវត្ថុនៃការជួល ដូច្នេះ ភតិបតីអាចធ្វើអនុប្បទានកម្មវត្ថុនៃការជួលបាន។ ម្ចាស់កម្មសិទ្ធិថ្មី ត្រូវទទួលបាននូវកម្មសិទ្ធិ ហើយអាចអះអាងពីកម្មសិទ្ធិរបស់ខ្លួនបាន ចំពោះគ្រប់បុគ្គលទាំងអស់។ ផ្ទុយទៅវិញ ភតិសន្យា គឺគ្រាន់តែជាកិច្ចសន្យា ដែលភតិកៈ អាចអះអាងពីសិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ខ្លួន បានចំពោះតែភតិបតីប៉ុណ្ណោះ។ ដូច្នេះ ប្រសិនបើម្ចាស់កម្មសិទ្ធិថ្មីទាមទារឱ្យភតិកៈប្រគល់មកវិញនូវកម្មវត្ថុនៃកិច្ចសន្យា នោះជាទូទៅ ភតិកៈ ត្រូវតែប្រគល់ត្រឡប់ទៅវិញ។

ក៏ប៉ុន្តែ វានឹងធ្វើឱ្យភតិកៈស្ថិតនៅក្នុងស្ថានភាពដែលចាញ់ប្រៀប ឬ ខូចខាតផលប្រយោជន៍ ជាពិសេសក្នុងករណីនៃភតិសន្យាអចលនវត្ថុ។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានបញ្ញត្តថានៅក្នុងករណីនៃភតិសន្យាអចលនវត្ថុ ភតិកៈ អាចអះអាងពីសិទ្ធិរបស់ខ្លួនទាក់ទងនឹងភតិសន្យា ចំពោះជនដែលធ្វើលទ្ធកម្មបន្តនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុនោះបាន ដោយផ្អែកទៅលើអង្គហេតុថា ភតិកៈ បានកាន់កាប់ និង ប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុជួលនោះ ជាបន្តបន្ទាប់ ( មាត្រា ៥៩៨ កថាខណ្ឌទី ១) ។

### ១.៩. អំឡុងពេលជួល

អំឡុងពេលជួល អាចត្រូវបានកំណត់ដោយកិច្ចសន្យា។ ប្រសិនបើគ្មានអំឡុងពេល ត្រូវបានកំណត់នៅក្នុងកិច្ចសន្យាទេ នោះវា ត្រូវបានចាត់ទុកថាជាភតិសន្យា ដែលមិនកំណត់អំឡុងពេល។ ហើយម្យ៉ាងទៀត ចំពោះភតិសន្យាអចលនវត្ថុ ដែលមិនបានធ្វើជាលាយលក្ខណ៍អក្សរ ត្រូវបានចាត់ទុកថាជា ភតិសន្យាដែលគ្មានកំណត់អំឡុងពេល ( មាត្រា ៥៩៩ កថាខណ្ឌទី ២) ។

## ២. សិទ្ធិ និង ករណីយកិច្ចរបស់ភតិបតី

### ២.១. ករណីយកិច្ចធ្វើឱ្យភតិកៈប្រើប្រាស់ និង អាស្រ័យផល ដោយផ្អែកតាមវិធីប្រើប្រាស់

ភតិកៈ មានសិទ្ធិក្នុងការប្រើប្រាស់ និង អាស្រ័យផល ដោយផ្អែកទៅតាមវិធីប្រើប្រាស់ ( មាត្រា ៦០០ កថាខណ្ឌទី ១) ។ ផ្ទុយទៅវិញ ភតិបតី មិនត្រូវរាំងស្ទះក្នុងការប្រើប្រាស់ និង អាស្រ័យផល ដែលភតិកៈ ធ្វើឡើងដោយផ្អែកតាមវិធីប្រើប្រាស់។ ករណីយកិច្ចក្នុងការជួសជុលរបស់ភតិបតី ( មាត្រា ៦០២) ក៏ត្រូវបានទាញចេញពីគំនិតនេះដែរ។

### ២.២. ករណីយកិច្ចជួសជុល

ភតិបតី តម្រូវឱ្យធ្វើការជួសជុល ដូច្នេះ ភតិកៈ អាចប្រើប្រាស់ និង អាស្រ័យផលពីវត្ថុជួលបាន ( មាត្រា ៦០២) ។ ឧទាហរណ៍ នៅក្នុងករណី ដែលផ្នែកមួយនៃកម្រាលឥដ្ឋនៅក្នុងផ្ទះជួល បានខូចខាត ភតិបតី មិនចាំបាច់ជួសជុលទេ ប្រសិនបើ ភតិកៈ អាចរស់នៅក្នុងផ្ទះនោះបានជាធម្មតា។ ប៉ុន្តែផ្ទុយមកវិញ ប្រសិននៅក្នុងផ្ទះជួលនោះមានលិចទឹកពីពិដាន នោះភតិបតី ត្រូវមានករណីយកិច្ចជួសជុល ទោះបីវាជាផ្នែកមួយនៃពិដានក៏ដោយ ព្រោះជាធម្មតា វា គឺជាឧបសគ្គក្នុងការរាំងស្ទះនូវការស្នាក់នៅ នៅក្នុងផ្ទះនោះ។

នៅក្នុងករណីខ្លះ ដើម្បីកំណត់ថាតើការខូចខាតឆ្លើយតបទៅនឹង "ចាំបាច់សម្រាប់ប្រើប្រាស់ និង អាស្រ័យផល" ឬអត់ គឺមានលក្ខណៈពិបាក។ ឧទាហរណ៍ នៅក្នុងករណីដែល ក ជួលផ្ទះចាស់បាក់បែកមួយទៅឱ្យ ខ ដោយយកតម្លៃទាប ហើយការដាក់បន្ទុកឱ្យជួសជុលនូវគ្រប់ផ្នែក ដែលបានខូចខាត គឺមានលក្ខណៈតឹងតែងបំផុតចំពោះភតិបតី។ នៅក្នុងករណីនេះ ថាតើភតិបតីត្រូវមានករណីយកិច្ចជួសជុល ឬ អត់ ត្រូវបានសម្រេចដោយធ្វើការពិចារណាទៅលើអង្គហេតុ ដែលថា គឺមានលក្ខណៈសមរម្យ ឬ អត់ ក្នុងការឱ្យទទួលខុសត្រូវចំពោះការ ជួសជុល។

ការព្រមព្រៀងគ្នាពិសេស ដែលចែងថា ភតិកៈ ត្រូវមានករណីយកិច្ចជួសជុល គឺមានសុពលភាព ព្រោះមាត្រា ៦០២ គឺជាបញ្ញត្តិតាមការស្ម័គ្រចិត្ត។

ជាងនេះទៅទៀត ភតិកៈ មិនត្រូវបង្កជាឧបសគ្គ ឬ រារាំងដល់សកម្មភាពរបស់ភតិបតី ដែលចាំបាច់ក្នុងការថែរក្សាវត្ថុជួលនោះទេ ( មាត្រា ៦០៣) ។ វត្ថុជួល គឺជាកម្មសិទ្ធិរបស់ភតិបតី ហើយ ភតិបតី មានសិទ្ធិថែរក្សាវាដោយរាប់បញ្ចូលទាំងការជួសជុលផងដែរ។ ឧទាហរណ៍ នៅក្នុងករណីដែល ភតិបតី បានជួលជុលពិដាន ដែលលិចទឹក នៅក្នុងបន្ទប់មួយនៅក្នុងផ្ទះល្វែង (អាផាតមែន) ដែលជួល នោះ ភតិកៈ មិនអាចបដិសេធការជួសជុលនេះ

បានទេ ទោះបីជាគាត់ មិនអាចប្រើប្រាស់បន្ទប់នោះ បាននៅក្នុងរយៈពេលជួសជុលក៏ដោយ។ ក៏ប៉ុន្តែប្រសិនបើភតិកៈ មិនអាចសម្រេចនូវគោលបំណងនៃភតិសន្យា ដោយសារ ការជួសជុលនោះ ឧទាហរណ៍ដូចជា នៅក្នុងករណីខាងលើ ផ្ទះល្វែង (អាផាតមែន) នោះ មានតែមួយបន្ទប់ នោះ ភតិកៈ អាចទាមទារឱ្យបន្ថយថ្លៃឈ្នួល ឬ រំលាយកិច្ចសន្យាបាន (មាត្រា ៦០៣ កថាខណ្ឌទី ២ ឃ្លាខាងក្រោយ)។

## ២.៣. ករណីយកិច្ចសងវិញនូវសោហ៊ុយចំណាយ

### ២.៣.១. ករណីយកិច្ចសងនូវសោហ៊ុយចំណាយចាំបាច់

មាត្រា ៦០៤ កថាខណ្ឌទី ១ បានបញ្ញត្តថា ប្រសិនបើ ភតិកៈ បានចេញនូវសោហ៊ុយចំណាយចាំបាច់ ដែលគួរជាបន្ទុករបស់ភតិបតី នោះភតិកៈអាចទាមទារឱ្យសងវិញជាបន្ទាន់ពីភតិបតី។ ឧទាហរណ៍ ការចំណាយជួសជុលវត្ថុជួល ដែលភតិបតីត្រូវទទួលបន្ទុក ត្រូវបានរាប់បញ្ចូលទាំង "សោហ៊ុយចាំបាច់" ផងដែរ។ ហើយការចំណាយដែលក្រៅពីការជួសជុល អាចត្រូវបានចាត់បញ្ចូលទៅក្នុងការចំណាយចាំបាច់ ព្រោះភតិបតីមានកាតព្វកិច្ចក្នុងការធ្វើឱ្យភតិកៈ អាចប្រើប្រាស់ និង អាស្រ័យផលពីវត្ថុជួល។ ឧទាហរណ៍ ប្រសិនបើជណ្តើរនៅខាងមុខបន្ទប់ជួលមានការខូចខាត នោះភតិបតីត្រូវមានករណីយកិច្ចជួសជុលវា ទោះបីវាមិនមែនជាវត្ថុជួលនោះផ្ទាល់ ក៏ដោយ។ ហើយប្រសិនបើភតិកៈបានជួសជុលវាហើយ នោះភតិបតីត្រូវមានករណីយកិច្ចសងនូវថ្លៃចំណាយ ដែលជាសោហ៊ុយចាំបាច់។

ពាក្យថា "ជាបន្ទាន់" មានន័យថា ពេលជាមួយនឹងការចំណាយនៃថ្លៃឈ្នួលចាំបាច់។

### ២.៣.២. ករណីយកិច្ចសងសោហ៊ុយដែលបង្កើនតម្លៃ

នៅពេលខ្លះ ភតិកៈ បានកែលំអវត្ថុជួលនៅក្នុងអំឡុងពេលជួល។ ភតិកៈ មានកាតព្វកិច្ចក្នុងការធ្វើបដិទាននៃវត្ថុជួលទៅស្ថានភាពដើមវិញ ហើយប្រគល់នូវវត្ថុជួលនោះទៅឱ្យភតិបតីវិញ នៅចុងបញ្ចប់នៃភតិសន្យា (មាត្រា ៦១៨ កថាខណ្ឌទី ១)។ នៅក្នុងន័យម្យ៉ាងទៀត ភតិកៈត្រូវដកចេញនូវរាល់វត្ថុ ដែលខ្លួនបានភ្ជាប់ទៅនឹងវត្ថុជួល។ ក៏ប៉ុន្តែ ការដកចេញនូវផ្នែកទាំងអស់នោះ អាចធ្វើឱ្យបាត់បង់នូវតម្លៃជាសេដ្ឋកិច្ចបាន។ ផ្ទុយទៅវិញ ប្រសិនបើភតិបតី អាចទទួលបាននូវផលប្រយោជន៍ទាំងអស់ តាមរយៈការកែលំអនោះ វាក៏ផ្ទុយនឹងគោលការណ៍នៃសមភាព។

ដូច្នេះ មាត្រា ៦០៤ កថាខណ្ឌទី ២ បានបញ្ញត្តថា ភតិកៈ អាចទាមទារឱ្យសងវិញនូវសោហ៊ុយ ដើម្បីបង្កើនតម្លៃ

(i) ដរាបណា ការបង្កើនតម្លៃនៃវត្ថុជួលនោះនៅតែមាន

(ii) នៅចុងបញ្ចប់នៃភតិសន្យា

(iii) ផ្អែកតាមការជ្រើសរើសរបស់ភតិបតីនូវចំនួនប្រាក់ ដែលបានចំណាយពិតប្រាកដ ឬ តម្លៃដែលកើននោះ។

ឧទាហរណ៍ ប្រសិនបើ ភតិកៈ បានដំឡើងនូវម៉ាស៊ីនត្រជាក់ ដែលជាប់ក្នុងជញ្ជាំង តំលៃ ១.០០០ ដុល្លារ ហើយ តម្លៃនៃអាគារនោះ បានកើន ៥០០ ដុល្លារ បន្ថែមទៀត នៅពេលបញ្ចប់ភតិសន្យា នោះ ភតិបតី អាចបង់ប្រាក់ ៥០០ ដុល្លារ ហើយរួចផុតពីករណីយកិច្ចនេះ ដោយជម្រើសរបស់ខ្លួន។ ផ្ទុយទៅវិញ ប្រសិនបើតម្លៃនៃអាគារជួល បានកើន ១.២០០ ដុល្លារ នៅក្នុងករណីដដែលខាងលើនេះ ភតិបតី អាចបង់ប្រាក់ ១.០០០ ដុល្លារ តាមជម្រើស របស់គាត់ផងដែរ ។

ប្រសិនបើភតិបតី ត្រូវទទួលបន្ទុកសងនូវសោហ៊ុយដើម្បីបង្កើនតម្លៃ នោះភតិកអាចអះអាងនូវសិទ្ធិឃាត់ទុកបាន ( មាត្រា ៧៧៤) ។ នៅពេលខ្លះ ចំណាយបង្កើនតម្លៃ អាចមានចំនួនច្រើន ហើយភតិបតីមិនអាចទទួលបាននូវវត្ថុជួលទេនៅក្នុងករណីនេះ ប្រសិនបើភតិបតីមិនអាចសងនូវសោហ៊ុយចំណាយនោះជាបន្ទាន់។ ដូច្នេះ មាត្រា ៦០៤ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ បានបញ្ញត្តថាតុលាការអាចអនុញ្ញាតឱ្យកំណត់អំឡុងពេលសមរម្យឱ្យសងវិញនូវសោហ៊ុយចំណាយ តាមការទាមទាររបស់ភតិបតី ។ ឬនិយាយម្យ៉ាងទៀតភតិបតីមិនចាំបាច់សងវិញនូវ សោហ៊ុយចំណាយដើម្បីបង្កើនតម្លៃ រហូតដល់កាលបរិច្ឆេទដែលតុលាការទទួលស្គាល់ ។ នៅក្នុងករណីនេះ ភតិកៈមិនអាចអះអាងពីសិទ្ធិឃាត់ទុក ឬ ការតវ៉ាឱ្យអនុវត្តព្រមគ្នាទេ ។

**ករណីសិក្សា**

**ខ** បានជួលអាគារមួយសម្រាប់បើកភោជនីយដ្ឋានពី **ក** ។ អំឡុងពេលនៃភតិសន្យា គឺមានរយៈពេល ៥ ឆ្នាំ ហើយតម្លៃឈ្នួល គឺ ៥០០ ដុល្លារ ក្នុងមួយខែ ។ ហើយវា មិនមានការព្រមព្រៀងពិសេស ទាក់ទងនឹងការជួសជុល ឬ សោហ៊ុយចំណាយ ។

តើ **ខ** អាចទាមទារឱ្យសងនូវសោហ៊ុយពី **ក** បានដែរ ឬ ទេ? ប្រសិនបើបាន តើសោហ៊ុយចំណាយ ប្រភេទណា ដែល **ខ** អាចទាមទារបាន?

(១) ក្រោយពីការប្រគល់ គឺពិដានបានជ្រាបទឹក។ ដូច្នេះ **ខ** បានទិញសំភារៈសម្រាប់ជួសជុល អស់ទឹកប្រាក់ ១០ ដុល្លារ គឺជួសជុលដោយខ្លួនគាត់ ។

(២) **ខ** បានផ្លាស់ប្តូរបំពង់ស្រូបផ្សែង ដោយសារតែបំពង់ស្រូបផ្សែងមុន ដែលមាននៅពេលប្រគល់ គឺចាស់ ហើយពេលខ្លះ មិនដំណើរការទៀត ។ បំពង់ស្រូបផ្សែងថ្មី មានតំលៃ ២៥០ ដុល្លារ ហើយវាគឺជាតម្លៃធម្មតា ។

(៣) នៅមុនពេលរំលាយកិច្ចសន្យា **ខ** បានទិញ និង ដំឡើងទូរទឹកកកភ្ជាប់ជញ្ជាំង ក្នុងតំលៃ ៥.០០០ ដុល្លារ ដែលនាំចូលពីសហរដ្ឋអាមេរិក ។ ហើយបន្ទាប់មកភតិសន្យាត្រូវបានរំលាយ ។

【 សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង 】

(១) **ខ** អាចទាមទារឱ្យសង ១០ ដុល្លារ ដែលជាសោហ៊ុយចាំបាច់

សោហ៊ុយចំណាយ ដែល ខ អាចទាមទារបាននោះ គឺសោហ៊ុយចំណាយចាំបាច់។ នៅក្នុងករណីដែល ខ មិនអាចប្រើប្រាស់ ឬ អាស្រ័យផលពីវត្ថុជួលបានទេ ដោយសារតែការជ្រាបទឹកនេះ។ ដូច្នេះ ខ បានចំណាយសោហ៊ុយចាំបាច់ អស់ ១០ ដុល្លារ ដោយផ្អែកលើមាត្រា ៦០៤ កថាខណ្ឌទី ១។

(២) ខ អាចទាមទារឱ្យសង ២៥០ ដុល្លារ ដែលជាសោហ៊ុយចាំបាច់

ខ ជួលអាគារ ដើម្បីបើកជាភោជនីយដ្ឋាន។ ដូច្នេះ បំពង់ស្រូបផ្សែង គឺជាឧបករណ៍ ដែលមានសារៈសំខាន់ណាស់ ក្នុងការប្រើប្រាស់ និង អាស្រ័យផលពីអាគារ។ ដូច្នេះ សោហ៊ុយ ២៥០ ដុល្លារ អាចត្រូវបានទទួលស្គាល់ថាជា សោហ៊ុយចាំបាច់។

(៣) ខ អាចទាមទារឱ្យសងនូវសោហ៊ុយបង្កើនតម្លៃ

ទាក់ទងនឹងការចំណាយ ៥.០០០ ដុល្លារ របស់ ខ ដើម្បីទិញ និង ដំឡើងទូរទឹកកកភ្ជាប់ជញ្ជាំងនោះ គឺ **ក** មិនអាចទាមទារសោហ៊ុយចំណាយ ដែលជាសោហ៊ុយចាំបាច់នោះបានទេ។ ក៏ប៉ុន្តែ គេ អាចនិយាយបានថា ការដំឡើងទូរទឹកកកភ្ជាប់ជញ្ជាំងនេះ គឺជាសកម្មភាពបង្កើនតម្លៃវត្ថុជួល នៅក្នុងករណីនេះ យោងតាមមាត្រា ៦០៤ កថាខណ្ឌទី ២ ក្នុងករណីដែលនៅពេលកិច្ចសន្យា ត្រូវបានរំលាយ ហើយទូរទឹកកកនោះ នៅមានតម្លៃ នោះ ខ អាចទាមទារឱ្យសងសោហ៊ុយបាន។ នៅក្នុងករណីនេះ ខ អាចទាមទារឱ្យសងនូវសោហ៊ុយ ដែលបានចំណាយពិតប្រាកដ ឬ ការកើនតម្លៃនៃអាគារ ដោយផ្អែកលើជម្រើសរបស់ **ក**។

## ២.៩. ការទទួលខុសត្រូវក្នុងការធានារបស់ភតិបតី

### ២.៩.១. នៅក្នុងករណីដែលវត្ថុជួលជារបស់អ្នកដទៃ

នៅក្នុងករណីនេះ គឺត្រូវផ្តោតទៅលើគោលការណ៍ចំនួនបី។

ទីមួយ ភតិសន្យាដើម គឺមានសុពលភាព នៅក្នុងករណីដែលវត្ថុជួល គឺជារបស់អ្នកដទៃ

ទីពីរ ភតិបតី មានកាតព្វកិច្ចត្រូវទទួលនូវកម្មសិទ្ធិ ឬ ជួលកម្មវត្ថុនោះពីកម្មសិទ្ធិករ

ទីបី ក្នុងករណីដែល ភតិបតីមិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួននោះទេ គឺ ត្រូវអនុវត្តដូចគ្នា ទៅនឹងមាត្រា ៥៣១ ទាក់ទងនឹងករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់ មាត្រា ៥៣២ សិទ្ធិរំលាយកិច្ចសន្យារបស់អ្នកលក់សិទ្ធិអ្នកដទៃ និង មាត្រា ៥៣៣ ការទទួលខុសត្រូវក្នុងការធានា ចំពោះករណីដែលសិទ្ធិមួយភាគជាសិទ្ធិរបស់អ្នកដទៃ។

### ២.៩.២. ការទទួលខុសត្រូវក្នុងការធានាចំពោះវិការៈ

នៅក្នុងករណីដែល កម្មវត្ថុនៃភតិសន្យា មានវិការៈ នោះភតិបតីត្រូវទទួលខុសត្រូវក្នុងការធានាចំពោះវិការៈ ព្រោះភតិសន្យាគឺជាកិច្ចសន្យាយកតម្លៃថ្នូរ។ មាត្រា ៦០៥ ត្រូវបានបែងចែកជាពីរករណី នៅក្នុងករណីដែលវិការៈ អាចមើលឃើញដោយងាយស្រួល និង នៅក្នុងករណីដែលវិការៈមានលក្ខណៈកំបាំង។

(ក) នៅក្នុងករណីដែល វិការៈ អាចដឹងដោយងាយស្រួលបើពិនិត្យ (មាត្រា ៦០៥ កថាខណ្ឌទី ១)

នៅក្នុងករណីដែល

(i) ភតិកៈ មិនបានពិនិត្យស្ថានភាពនៃវត្ថុជួល ដែលជាកម្មវត្ថុនៃភតិសន្យាថា ត្រឹមត្រូវតាមស្ថានភាពដែលបានកំណត់នៅក្នុងលិខិតកិច្ចសន្យា នៅពេលទទួលការប្រគល់

**និង**

(ii) ភាពខុសគ្នាពីស្ថានភាព ដែលបានកំណត់នៅក្នុងលិខិតកិច្ចសន្យា ដែលខ្លួនអាចដឹងដោយងាយស្រួល បើពិនិត្យនោះ ភតិកៈ មិនអាចទាមទារឱ្យភតិបតី ធ្វើការទទួលខុសត្រូវបានឡើយ ។

ឧទាហរណ៍ នៅក្នុងភតិសន្យា ជួលបន្ទប់មួយ នៅក្នុងផ្ទះល្វែង (អាផាតមែន) គេបានចែងនៅក្នុងកិច្ចសន្យាថា មានម៉ាស៊ីនត្រជាក់ចំនួន ៣ ដែលត្រូវដំឡើង ក៏ប៉ុន្តែ តាមការជាក់ស្តែង គឺមានតែម៉ាស៊ីនចំនួន ២ ទេ ដែលបានដំឡើង ដូច្នេះភតិកៈមិនអាចទាមទារឱ្យភតិបតី ដំឡើងម៉ាស៊ីនត្រជាក់មួយទៀតទេ ប្រសិនបើភតិកៈមិនបានពិនិត្យបន្ទប់នោះ ។

(ខ) នៅក្នុងករណីដែលវិការៈ មានលក្ខណៈកំបាំង (មាត្រា ៦០៥ កថាខណ្ឌទី ២ និង ទី ៥)

ប្រសិនបើក្នុងករណីដែលវិការៈមានលក្ខណៈកំបាំង ហើយភតិកៈមិនបានដឹងនៅពេលប្រគល់នោះ គឺភតិកៈអាចទាមទារឱ្យជួសជុលវិការៈ ឬ ទាមទារសំណងការខូចខាតនោះបាន ។ ទន្ទឹមនឹងនេះ នៅក្នុងករណីដែលភតិកៈមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យា ដោយសារតែមានវិការៈ នោះភតិកៈអាចរំលាយកិច្ចសន្យាបាន (មាត្រា ៦០៥ កថាខណ្ឌទី ៥) ។

(គ) ខ្លឹមសារនៃការទទួលខុសត្រូវក្នុងការធានាចំពោះវិការៈ

នៅក្នុងករណីដែលវត្ថុជួលមានវិការៈ ភតិបតីអាចជួសជុលវិការៈនោះ ដោយសោហ៊ុយខ្លួនឯងបានលុះត្រាតែមិនធ្វើឱ្យមានការខូចខាត ដោយមិនត្រឹមត្រូវនូវផលប្រយោជន៍របស់ភតិកៈ (មាត្រា ៦០៥ កថាខណ្ឌទី ៣) ។

ទោះបីជាភតិបតី ជួសជុលវិការៈក៏ដោយ ក៏ភតិកៈអាចទាមទារសំណងនៃការខូចខាតបានដែរ (មាត្រា ៦០៥ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។

ប្រសិនបើភតិបតីមានកាតព្វកិច្ចជួសជុល ដោយផ្អែកទៅលើមាត្រា ៦០៥ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២ នោះភតិកៈអាចទាមទារឱ្យបន្ថយថ្លៃឈ្នួលដែលសមរម្យនឹងវិការៈបាន ដោយគិតចាប់តាំងពីពេលដែលបានប្រគល់ (មាត្រា ៦០៥ កថាខណ្ឌទី ៤) ។

ទន្ទឹមនឹងនេះ ដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើភតិកៈមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាដោយសារអត្ថិភាពនៃវិការៈកំបាំងនេះ នោះភតិកៈអាចរំលាយកិច្ចសន្យាបាន ។

ការទាមទារនានា ដែលទាក់ទងនឹងការទទួលខុសត្រូវក្នុងការធានាចំពោះវិការៈត្រូវអនុវត្តនៅក្នុងអំឡុងពេល ១ ឆ្នាំ គិតចាប់ពីពេលដែលភតិកៈ បានដឹង ឬ ពេលដែលត្រូវដឹងអំពីហេតុនោះបាន ។

## ៣. សិទ្ធិ និង ករណីយកិច្ចរបស់ភតិក:

### ៣.១. ករណីយកិច្ចបង់ថ្លៃឈ្នួល

ជាគោលការណ៍ អ្នកជួល មានករណីយកិច្ចបង់ថ្លៃជួលទៅឱ្យម្ចាស់ចលនវត្ថុ និង ផ្ទះ ឬ អាគារ នៅចុងខែ ហើយសម្រាប់ការជួលដី គឺនៅចុងឆ្នាំ ( មាត្រា ៦១០) ។

យោងទៅលើមាត្រា ៦១០ ភតិក: មានកាតព្វកិច្ចបង់ថ្លៃឈ្នួលទៅឱ្យភតិបតី យោងទៅតាមកិច្ចសន្យាជួលដែលមានកំណត់ពេលបង់ថ្លៃឈ្នួល។ ប៉ុន្តែបើ នៅក្នុងកិច្ចសន្យាជួល ពុំបានកំណត់អំពីពេលវេលាបង់ថ្លៃឈ្នួលនោះទេ គឺកាតព្វកិច្ចបង់ថ្លៃឈ្នួល ត្រូវយោងទៅតាមបញ្ញត្តិច្បាប់ ដូចជាចំពោះចលនវត្ថុ និង ផ្ទះ ឬ អាគារ ត្រូវបង់នៅរៀងរាល់ចុងខែ ហើយចំពោះដីធ្លីវិញ ត្រូវបង់នៅរៀងរាល់ចុងឆ្នាំ។ ហើយចំពោះវត្ថុដែលមានរដូវប្រមូលផល ត្រូវបង់នៅក្រោយពេលដែលរដូវនោះកន្លងផុត ដោយគ្មានការយឺតយ៉ាវ។ សរុបមកការបង់ថ្លៃឈ្នួលត្រូវអនុលោមតាមវិធីចំនួនពីរគឺ ទីមួយ បង់ថ្លៃឈ្នួលដែលមានកំណត់ក្នុងកិច្ចសន្យា ឬ វិធីទីពីរ គឺបង់ថ្លៃឈ្នួលតាមបញ្ញត្តិច្បាប់ ។

ចំណុចនៅត្រង់នេះ គឺថា កាតព្វកិច្ចប្រគល់វត្ថុជួលរបស់ភតិបតី និង កាតព្វកិច្ចបង់ថ្លៃឈ្នួល មិនមានទំនាក់ទំនងទៅនឹងការអនុវត្តព្រមគ្នានោះទេ។ ភតិបតី ត្រូវបញ្ចប់កាតព្វកិច្ចរបស់ខ្លួន នៅក្នុងការប្រគល់វត្ថុជួល នៅមុនពេលបង់ប្រាក់ឈ្នួល ប្រសិនបើ មិនមានការព្រមព្រៀងពិសេស។

ទាំងភតិក: និង ភតិបតី មានទំនាក់ទំនងកាតព្វកិច្ចមួយផ្សេងទៀត គឺក្នុងលក្ខខណ្ឌស្មោះត្រង់ និង សុចរិតបន្ទាប់ពីកិច្ចសន្យាជួលត្រូវបានបញ្ចប់ ភតិក:ត្រូវប្រគល់កម្មវត្ថុជួលទៅឱ្យភតិបតីវិញក្នុងលក្ខខណ្ឌដើម។ ម្យ៉ាងទៀត ប្រសិន ឥភតិក: និង ភតិបតី បន្តកិច្ចសន្យាជួលទំនាក់ទំនងថ្មីមួយទៀត ត្រូវបានបង្កើតឡើងរវាងកាតព្វកិច្ចប្រគល់វត្ថុ និង កាតព្វកិច្ចបង់ថ្លៃឈ្នួល។

### ៣.២. សិទ្ធិ និង ករណីយកិច្ចនៃការប្រើប្រាស់ និង អាស្រ័យផល ផ្អែកតាមវិធីប្រើប្រាស់

ភតិក: មានសិទ្ធិ និង ករណីយកិច្ច ក្នុងការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុជួល ដោយផ្អែកតាមវិធីប្រើប្រាស់ ( មាត្រា ៦០០) ។ វិធីប្រើប្រាស់ ក្នុងមាត្រា ៦០០ មានន័យថា អ្នកជួល មានសិទ្ធិ និង ករណីយកិច្ចប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួល ដែលមានកំណត់ និង បញ្ជាក់ពីរបៀបប្រើប្រាស់ បានសរសេរក្នុងកិច្ចសន្យា ឬ ស្របទៅតាមលក្ខណៈនៃកម្មវត្ថុជួល។ ការប្រើប្រាស់ឱ្យសមស្របទៅតាមលក្ខណៈវត្ថុ គឺសំដៅទៅលើការប្រើប្រាស់តាមគោលគំនិតដែលវត្ថុនោះ ប្រើក្នុងលក្ខខណ្ឌធម្មតា និង ទូទៅ។ ក្នុងករណីដែលភតិក:បានប្រើប្រាស់ និង អាស្រ័យផល ស្របតាមវិធីប្រើប្រាស់ និង អាស្រ័យផលបានត្រឹមត្រូវហើយ នោះភតិបតីមិនអាចធ្វើការរាំងស្ទះ ក្នុងការប្រើប្រាស់ និង អាស្រ័យផលនោះ ឡើយ ។ ឧទាហរណ៍ ភតិក: ខ បានជួលបន្ទប់ នៅក្នុងផ្ទះល្វែង (អាផាត មែន) ពីភតិបតី ក ដើម្បីស្នាក់នៅ នោះគេ ចាត់ទុកថា គឺជាការបំពានករណីយកិច្ចនេះ ប្រសិនបើគាត់ជួសជុលកែបន្ទប់នោះដោយគ្មានការយល់ព្រមពី ក និង បើកជាភោជនីយដ្ឋាន។

ក្នុងករណីដែលភតិកៈ បានធ្វើខុសនឹងករណីយកិច្ចប្រើប្រាស់ និង អាស្រ័យផល ដោយផ្អែកតាមវិធីប្រើប្រាស់នោះ ភតិបតីមានសិទ្ធិរំលាយកិច្ចសន្យាបាន ( មាត្រា ៦០០ កថាខណ្ឌទី ២) ។ ការរំលាយកិច្ចសន្យានេះ ក៏អាចយោងទៅលើបញ្ញត្តិទូទៅនៃការមិនអនុវត្តកាតព្វកិច្ច និង ការបំពានកិច្ចសន្យាបានដែរ ។

### ៣.៣. ករណីយកិច្ចរបស់ភតិកៈ នៅក្នុងការថែរក្សាវត្ថុជួល ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ

ភតិកៈ កាន់កាប់នូវទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់អ្នកដទៃ។ ដូច្នេះ ភតិកៈ ត្រូវមានករណីយកិច្ចថែរក្សាវត្ថុជួល ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ ( មាត្រា ៦០១) ។ ក៏ប៉ុន្តែ ភតិកៈ មិនទទួលខុសត្រូវចំពោះការថយចុះតម្លៃ ដែលកើតឡើងពីការប្រើប្រាស់វត្ថុនោះ ដោយយោងទៅលើវិធីប្រើប្រាស់។ ឧទាហរណ៍ ប្រសិនបើភតិកៈបានជួលឱ្យភតិបតី នោះជាទូទៅភតិកៈមិនចាំបាច់សងការខូចខាត ចំពោះការសឹកសំបកកង់រថយន្តឡើយ ។

ប្រសិនបើភតិកៈបានបំពានករណីយកិច្ចនេះ ភតិបតីអាចរំលាយភតិសន្យាបាន ដោយផ្អែកទៅលើបញ្ញត្តិទូទៅនៃការរំលាយកិច្ចសន្យា។ ភតិបតីចាំបាច់ត្រូវដាស់តឿនភតិកៈឱ្យបញ្ឈប់សកម្មភាព ដែលបំពានទៅលើករណីយកិច្ចនេះ ដោយកំណត់អំឡុងពេលសមរម្យ ។ ហើយភតិបតីអាចរំលាយភតិសន្យា ប្រសិនបើភតិកៈមិនបញ្ឈប់សកម្មភាពនៅក្នុងអំឡុងពេលនោះ។ ក៏ប៉ុន្តែ នៅក្នុងករណីដែលសកម្មភាពរបស់ភតិកៈបានធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងភាគី ហើយមិនអាចជឿជាក់ថានឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន នោះភតិបតីអាចរំលាយភតិសន្យាបានភ្លាមៗ ( មាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច ឃ) ។

### ៣.៤. សិទ្ធិទាមទារឱ្យសងវិញ នូវសោហ៊ុយរបស់ភតិកៈ

ដូចបានរៀបរាប់ ភតិបតី មានកាតព្វកិច្ចសងនូវសោហ៊ុយចាំបាច់ និង សោហ៊ុយបង្កើនតម្លៃ។ បើនិយាយបញ្ច្រាស់មកវិញ គឺ ភតិកៈ មានសិទ្ធិទាមទារឱ្យសងនូវសោហ៊ុយចាំបាច់ និង សោហ៊ុយបង្កើនតម្លៃ ( មាត្រា ៦០៤) ។

### ៣.៥. សិទ្ធិទាមទារឱ្យបន្ថយថ្លៃឈ្នួល ឬ សិទ្ធិរំលាយភតិសន្យា

ភាគី អាចសម្រេចពីចំនួននៃថ្លៃឈ្នួល ដោយការព្រមព្រៀង ដរាបណា វា មិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ។ ក៏ប៉ុន្តែ នៅក្នុងករណីនៃកិច្ចសន្យាដែលមានរយៈពេលវែង ដូចជា ភតិសន្យាស្ថានភាពសេដ្ឋកិច្ច នៅពេលខ្លះ អាចមានការផ្លាស់ប្តូរ។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានបញ្ញត្តថា ភតិកៈ អាចទាមទារឱ្យបន្ថយថ្លៃឈ្នួល នៅក្នុងស្ថានភាពជាក់លាក់មួយចំនួន។ ផ្ទុយទៅវិញ ក្រមរដ្ឋប្បវេណី មិនអាចចែងពីសិទ្ធិទាមទារឱ្យបង្កើនតម្លៃឈ្នួលរបស់ភតិបតីឡើយ ។ មូលហេតុគឺថាភតិបតីអាចធ្វើកិច្ចព្រមព្រៀងថា គូភាគីត្រូវពិគ្រោះជាមួយភតិកៈ ដើម្បីកែប្រែតម្លៃនៅក្នុងរយៈពេលជាកំណត់ណាមួយ ឬ បង្កើតកិច្ចសន្យាដែលបញ្ញត្តពីអំឡុងពេលនៅក្នុងរយៈពេលខ្លី ដូចជា ភតិសន្យាមានអំឡុងពេល ១ ឆ្នាំ ឬ ២ ឆ្នាំ និង កំណត់ការព្រមព្រៀងថ្មីទាក់ទងនឹងថ្លៃឈ្នួល។

ក្រមរដ្ឋប្បវេណី បានបញ្ញត្ត នូវសិទ្ធិទាមទារឱ្យបន្ថយថ្លៃឈ្នួល ឬ រំលាយកិច្ចសន្យា ពីរប្រភេទ។

### ៣.៥.១. នៅក្នុងករណីដែលចំណូលថយចុះ

មាត្រា ៦០៦ កថាខណ្ឌទី ១ បានចែងថាភតិកៈអាចទាមទារឱ្យបន្ថយថ្លៃឈ្នួល រហូតដល់ត្រឹមចំនួនទឹកប្រាក់នៃការអាស្រ័យផលនោះ

(ក) នៅក្នុងករណីដែលភតិកៈ ជួលដីដែលមានគោលបំណងអាស្រ័យផលពីដី

**និង**

(ខ) ភតិកៈ បានទទួលផលតិចជាងថ្លៃឈ្នួល ដោយសារករណីប្រធានសក្តិ

ឧទាហរណ៍ នៅក្នុងករណីដែល **ខ** បានជួលដីពី **ត** ដើម្បីដាំស្រូវ ដែលមានតម្លៃឈ្នួល ១.០០០ ដុល្លារ ក្នុង ១ ឆ្នាំ ប៉ុន្តែ **ខ** អាចទទួលបានប្រាក់ ៦០០ ដុល្លារ ពីការប្រមូលផល នៅក្នុងឆ្នាំនោះ ដូច្នេះ **ខ** អាចទាមទារឱ្យ **ត** បន្ថយថ្លៃឈ្នួលមកត្រឹម ៦០០ ដុល្លារ។

ដើម្បីទទួលស្គាល់នូវសិទ្ធិនេះ វាមានភាពចាំបាច់ណាស់ដែលភតិកៈបានជួល "ដី ដោយមានគោលបំណងអាស្រ័យផលពីដីនោះ"។ វាមានន័យថាភតិកៈបានជួលដីដោយមានគោលបំណងថា នឹងទទួលបានផលពីដីនោះផ្ទាល់តែម្តង។ ឧទាហរណ៍ ប្រសិនបើភតិកៈបានជួលដី និង សាងសង់ភោជនីយដ្ឋាននៅលើដីនោះ បន្ទាប់មកគាត់បានគ្រប់គ្រងភោជនីយដ្ឋាននោះ ប៉ុន្តែ គាត់មិនអាចទទួលបានប្រាក់ចំណូលច្រើនជាងចំនួនថ្លៃឈ្នួល។ នៅក្នុងករណីនេះ ភតិកៈ មិនអាចទាមទារឱ្យបន្ថយថ្លៃឈ្នួល ព្រោះគេមិនអាចនិយាយថា ភតិកៈបានជួលដីដោយមានគោលបំណងអាស្រ័យផលពីដីឡើយ។ គោលបំណងនៃមាត្រានេះ គឺដើម្បីការពារកសិករដែលជួលដីពីគេ។

ប្រសិនបើភតិកៈបានទទួលផលតិចជាងថ្លៃឈ្នួលលើសពី ២ ឆ្នាំ ជាបន្តបន្ទាប់ ដោយសារករណីប្រធានសក្តិ ភតិកៈ អាចរំលាយភតិសន្យាបាន (មាត្រា ៦០៦ កថាខណ្ឌទី ២)។

### ៣.៥.២. នៅក្នុងករណីដែលបាត់បង់ ឬ វិនាសវត្ថុជួលមួយភាគ

ប្រសិនបើវត្ថុជួលមួយភាគ ត្រូវបានបាត់បង់ ឬវិនាស ហើយមិនមែនជាកំហុសរបស់ភតិកៈទេ នោះភតិកៈ អាចសុំបន្ថយថ្លៃឈ្នួលត្រឹមកម្រិតសមាមាត្រនៃភាគដែលបាត់បង់ ឬ វិនាសនោះ។ ប្រសិនបើភតិកៈមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាបានទេ ចំពោះភាគដែលនៅសល់ ដូច្នេះភតិកៈអាចសុំរំលាយកិច្ចសន្យាបាន។ (មាត្រា ៦០៧ កថាខណ្ឌទី ២)

ឧទាហរណ៍ **ខ** បានជួលបន្ទប់ចំនួន ៣ ពី **ត** ក្នុងតំលៃ ៦០០ ដុល្លារ។ ក៏ប៉ុន្តែ បន្ទប់មួយ ត្រូវបានអគ្គិភ័យឆាបឆេះអស់ ដោយមិនមានកំហុសរបស់ **ខ**។ នៅក្នុងករណីនេះ **ខ** អាចទាមទារឱ្យ **ត** បន្ថយថ្លៃឈ្នួល ចំពោះបន្ទប់ជួលទី ៣ នោះ។ ដូច្នេះ **ខ** ត្រូវបង់ត្រឹមតែ ៤០០ ដុល្លារ ទៅឱ្យ **ត** ប៉ុណ្ណោះ។ ប៉ុន្តែប្រសិនជា បន្ទប់ជួលដែលនៅសល់ ២ នោះមិនអាចឱ្យ **ខ** សម្រេចគោលបំណងរបស់ខ្លួនបានទេ នោះ **ខ** អាចរំលាយកិច្ចសន្យាបាន។

## ៣.៦. អនុប្បទានសិទ្ធិជួល និង ការជួលបន្តនូវវត្ថុជួល

លើកលែងតែនៅក្នុងករណីនៃសិទ្ធិជួលអចិន្ត្រៃយ៍ ( មាត្រា ២៥២ កថាខណ្ឌទី ១) ភតិកៈពុំត្រូវបានអនុញ្ញាតឱ្យធ្វើអនុប្បទាន ឬ ជួលបន្តនូវវត្ថុជួលបានឡើយ ប្រសិនជាគ្មានការយល់ព្រមពីភតិបតី ( មាត្រា ៦០៨ កថាខណ្ឌទី ១) ។

**- អត្ថន័យនៃអនុប្បទានសិទ្ធិជួល**

អត្ថន័យនៃអនុប្បទានសិទ្ធិជួល គឺថាភតិកៈ ធ្វើអនុប្បទាននូវឋានៈរបស់ខ្លួនជាភតិកៈ ទៅឱ្យតតិយជន ។

**- អត្ថន័យនៃការជួលបន្តនូវវត្ថុជួល**

ភតិកៈ ជួលនូវវត្ថុជួលឱ្យទៅតតិយជន ។

មាត្រា ៦០៨ ចែងថា បើគ្មានការយល់ព្រមពីភតិបតីទេ ភតិកៈពុំអាចធ្វើអនុប្បទានសិទ្ធិជួល ឬ ជួលបន្តនូវវត្ថុជួលនោះបានឡើយ លើកលែងតែសិទ្ធិជួលអចិន្ត្រៃយ៍ ។

បើភតិកៈ បានឱ្យតតិយជនប្រើប្រាស់ ឬ អាស្រ័យផលពីវត្ថុជួល ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ភតិបតី អាចរំលាយកិច្ចសន្យាបាន ( មាត្រា ៦០៨ កថាខណ្ឌទី ២) ។

មូលហេតុ ដែលភតិកៈ ចាំបាច់ត្រូវមានការយល់ព្រមពីភតិបតី នៅក្នុងករណីនៃការធ្វើអនុប្បទាន ឬ ជួលបន្ត គឺដោយសារតែ វា មានសារៈសំខាន់ណាស់ សម្រាប់ភតិបតី ដែលជាម្ចាស់សិទ្ធិលើការជួល ។ ឬនិយាយម្យ៉ាងទៀត ភតិបតី ជឿជាក់ទៅលើបុគ្គលិកលក្ខណៈរបស់ភតិកៈ ដូចជា មានសមត្ថភាពខាងហិរញ្ញវត្ថុគ្រប់គ្រាន់ ឬ សម្បជញ្ញៈ ហើយ បានជួលនូវទ្រព្យសម្បត្តិរបស់ខ្លួន ដោយផ្អែកលើជំនឿទុកចិត្តនោះ ។ ទន្ទឹមនឹងនេះ ប្រសិនបើ គេអាចធ្វើអនុប្បទាននូវសិទ្ធិជួល ឬ វត្ថុជួលនោះទៅឱ្យតតិយជន ដោយគ្មានការយល់ព្រមពីភតិបតី នោះ ភតិបតីអាចទទួលរងនូវការខូចខាត ដែលមិនបានរំពឹងទុកជាមុន ព្រោះ កាតព្វកិច្ចបង់ថ្លៃឈ្នួល ក៏ត្រូវបានផ្ទេរទៅតតិយជនដែលសមត្ថភាពក្នុងការបង់ថ្លៃឈ្នួល មិនត្រូវបានភតិបតីដឹងឡើយ ។

បើភតិកៈ បានជួលបន្តនូវវត្ថុជួលដោយត្រឹមត្រូវតាមច្បាប់ ភតិកៈបន្ត ត្រូវមានករណីយកិច្ចដោយផ្ទាល់ចំពោះភតិបតី ។ ចំពោះករណីយកិច្ចបង់ថ្លៃឈ្នួលជួលបន្ត ភតិកៈបន្ត ពុំអាចយកការបង់ថ្លៃជាមុនទៅឱ្យភតិកៈមកតតាំងជាមួយភតិបតីបានឡើយ ( មាត្រា ៦០៩ កថាខណ្ឌទី ១) ។

បញ្ញត្តិនៃកថាខណ្ឌខាងលើនេះ ពុំរារាំងដល់ការអនុវត្តសិទ្ធិរបស់ភតិបតីចំពោះភតិកៈឡើយ ( មាត្រា ៦០៩ កថាខណ្ឌទី ២) ។

ឧទាហរណ៍ **ក** បានជួលផ្ទះឱ្យ **ខ** ហើយ **ខ** បានជួលផ្ទះនេះបន្តទៅឱ្យ **គ** ដោយមានការយល់ព្រមពី **ក**។ នៅក្នុងករណីនេះ **ក** ជាភតិបតី **ខ** ជាភតិកៈ រីឯ **គ** គឺជាភតិកៈបន្ត ។

នៅក្នុងករណីដែល **គ** បានបង់ថ្លៃឈ្នួលឱ្យ **ខ** រួចហើយ ហើយ **ខ** មិនបានបង់ថ្លៃឈ្នួលឱ្យ **ក** ទេ នោះ **ក** អាចទាមទារថ្លៃឈ្នួលពី **ខ** ក៏បាន ពី **គ** ក៏បាន ។ ហើយក្នុងករណីដែល **ក** ទាមទារថ្លៃឈ្នួលពី **គ** ក៏ **គ** មិនអាច

បដិសេធបានដែរ នៅក្នុងករណីនេះ។ ដូច្នេះ គ ត្រូវមានកាតព្វកិច្ចបង់ថ្លៃឈ្នួលទៅឱ្យ ក ហើយ ក អាចទាមទារថ្លៃឈ្នួលពី ខ ដោយផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ។

**ករណីសិក្សា :**

ក បានជួលបន្ទប់មួយនៃផ្ទះល្វែង (អាផាតមែន) របស់ខ្លួនទៅឱ្យ ខ។ គ គឺជាមិត្តភក្តិរបស់ ខ។

(១) ខ បានបង្កើតកិច្ចសន្យាជួលបន្តមួយដើម្បីជួលបន្ទប់នោះទៅឱ្យ គ ដោយមិនមានការយល់ព្រមពី ក នៅថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១១ ។ គ មានគោលបំណងរើទៅនៅក្នុងបន្ទប់នោះ នៅថ្ងៃទី ០១ ខែ ឧសភា។ តើ ក ដែលបានដឹងពីអត្ថិភាពនៃកិច្ចសន្យាជួលនេះ នៅថ្ងៃទី ១៥ ខែ មេសា អាចរំលាយកិច្ចសន្យាជាមួយ ខ បានដែរ ឬ ទេ?

(២) ខ បានជួលបន្តនូវបន្ទប់នោះឱ្យទៅ គ ដោយមានការយល់ព្រមពី ក ហើយ គ បានរើចូលទៅនៅក្នុងបន្ទប់នោះដែរ។ ក្រោយមក គ មិនបានបង់ថ្លៃឈ្នួលឱ្យទៅ ក។ គ បានបង់ថ្លៃឈ្នួលរយៈពេល ១ ឆ្នាំ ឱ្យទៅ ខ។ តើ ក អាចទាមទារឱ្យ គ បង់ថ្លៃឈ្នួល បានដែរ ឬ ទេ?

(៣) ខ បានជួលបន្តនូវបន្ទប់នោះទៅឱ្យ គ ដោយមានការយល់ព្រមពី ក ហើយ គ បានរើចូលទៅនៅក្នុងបន្ទប់នោះហើយ។ ក្រោយមក ពិដានបន្ទប់នោះ ចាប់ផ្តើមជ្រាបទឹក។ តើ គ អាចទាមទារឱ្យ ក ជួសជុលបានដែរ ឬ ទេ?

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

(១) ក មិនអាចរំលាយកិច្ចសន្យាបានទេ

ដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៦០៨ ភតិបតី អាចរំលាយកិច្ចសន្យាបាន តែក្នុងករណីដែលភតិកៈបានឱ្យតតិយជន ប្រើប្រាស់ និង អាស្រ័យផល លើវត្ថុជួល ដោយគ្មានការយល់ព្រមពីភតិបតី។ អត្ថន័យនៃ "ការប្រើប្រាស់ ឬ អាស្រ័យផល" គឺមានន័យថាភតិកៈបានឱ្យតតិយជន ប្រើប្រាស់ និង អាស្រ័យផល តាមការជាក់ស្តែង។ នៅក្នុងករណីនេះ ខ បានបង្កើតកិច្ចសន្យាជាមួយ គ ដើម្បីជួលបន្តដោយគ្មានការយល់ព្រមពី ក ប៉ុន្តែ ខ មិនបានឱ្យ គ ប្រើប្រាស់ ឬ អាស្រ័យផលនៅឡើយទេ។ ដូច្នេះ ក មិនអាចរំលាយកិច្ចសន្យានេះភ្លាមបានទេ។

(២) ក អាចទាមទារឱ្យ គ បង់ថ្លៃឈ្នួលបាន។

ប្រសិនបើភតិកៈបានជួលបន្តនូវវត្ថុជួលដោយស្របច្បាប់ នោះភតិកៈបន្តត្រូវមានកាតព្វកិច្ចដោយផ្ទាល់ចំពោះភតិបតី។ ហើយប្រសិនបើភតិកៈបន្តបានបង់ថ្លៃឈ្នួលទៅឱ្យភតិបតីបន្តជាមុន នោះភតិកៈបន្តមិនអាចលើកឡើងពីការបង់ថ្លៃឈ្នួលនេះ ចំពោះភតិបតីបានឡើយ (មាត្រា ៦០៩ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)។ ដូច្នេះ គ មិនអាចលើកយកការបង់ថ្លៃឈ្នួលជាមុន មកតតាំងជាមួយ ក បានទេ។ ហើយ ក អាចទាមទារឱ្យ គ បង់ថ្លៃឈ្នួលបាន។

(៣) **គ** មិនអាចទាមទារឱ្យ **ក** ជួសជុលបានឡើយ។

មាត្រា ៦០៩ កថាខណ្ឌទី ១ បានចែងថា ភតិកៈបន្ត ត្រូវមានកាតព្វកិច្ចដោយផ្ទាល់ ចំពោះភតិបតី ប៉ុន្តែ វាមិនបានបញ្ញត្តនូវអ្វី ដែលទាក់ទងនឹងសិទ្ធិរបស់ភតិកៈបន្ត ក្នុងការទាមទារចំពោះភតិបតីឡើយ។ ជាក់ស្តែង គឺវាមិនមានទំនាក់ទំនងកិច្ចសន្យារវាងភតិបតី និង ភតិកៈបន្តឡើយ។ ដូច្នេះ **គ** មិនអាចទាមទារឱ្យ **ក** បំពេញនូវកាតព្វកិច្ចជាភតិបតី ដោយផ្ទាល់នោះទេ ហើយ មានតែ **ខ** ទេ ដែលអាចទាមទារឱ្យ **ក** ជួសជុលបាន។ ក្នុងករណីដែល **ខ** បានជួសជុលពិដានតាមសំណើររបស់ **គ** ឬ បានសងសោហ៊ុយចំណាយជួសជុល ប្រសិនបើ **គ** បានបង់ប្រាក់ជួសជុលពិដាន ដោយប្រើចំណាយរបស់ខ្លួន នោះ **ខ** អាចទាមទារឱ្យ **ក** សងនូវការចំណាយនោះមកវិញបាន។

## ៤. ការរំលាយភតិសន្យា

ករណីដែលកូនបំណុល មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលកើតចេញពីកិច្ចសន្យាទេ យោងតាមមាត្រា ៣៩០ ភាគីម្ខាងទៀត អាចទាមទារឱ្យអនុវត្តដោយបង្ខំ ទាមទារសំណងការខូចខាត ឬ រំលាយកិច្ចសន្យាបាន។ នៅពេលដែលភាគីណាមួយរំលាយភតិសន្យា ភតិសន្យានោះនឹងត្រូវបញ្ចប់។

ការរំលាយភតិសន្យានេះ ពុំមានអានុភាពប្រតិសកម្មទេ គឺមានអានុភាពឆ្ពោះទៅអនាគតតែម្តង (មាត្រា ៦១៧)។ អានុភាពនៃការរំលាយភតិសន្យានេះ មានលក្ខណៈប្លែកពីកិច្ចសន្យាផ្សេងៗទៀត ដែលមានអានុភាពប្រតិសកម្ម។ ឧទាហរណ៍ **ក** ជួលផ្ទះឱ្យ **ខ** រយៈពេល ១ ឆ្នាំ ដែលមានថ្លៃឈ្នួល ១០០ ដុល្លារ ក្នុង ១ ខែ។ ក៏ប៉ុន្តែក្រោយពីជួលបានរយៈពេលតែ ៥ ខែ ភតិសន្យា ត្រូវរំលាយដោយស្របច្បាប់។ ករណីនេះ **ក** មិនចាំបាច់សងនូវប្រាក់ថ្លៃឈ្នួល ៥ ខែ ទៅឱ្យ **ខ** វិញទេ ព្រោះការរំលាយភតិសន្យាមិនមានអានុភាពប្រតិសកម្មទេ។

### ៤.១. ប្រភពនៃការបញ្ចប់ភតិសន្យា

ភតិសន្យាមួយ នឹងត្រូវបញ្ចប់ ដោយមូលហេតុដូចខាងក្រោម ៖

១. ការបញ្ចប់ដោយសារការផុតអំឡុងពេលកំណត់ (មាត្រា ៦១២)

២. ការស្នើសុំឱ្យរំលាយភតិសន្យា ដែលពុំមានកំណត់អំឡុងពេល (មាត្រា ៦១៥)

៣. ការបាត់បង់ ឬ ការខូចខាតធ្ងន់ធ្ងរនៃវត្ថុជួល

៤. ការរំលាយភតិសន្យា ដោយសារការមិនអនុវត្តកាតព្វកិច្ច

### ៤.២. ការបញ្ចប់ភតិសន្យា ដោយសារការផុតអំឡុងពេលកំណត់

#### ៤.២.១. គោលការណ៍

កាលណាភតិសន្យាមួយ មានកំណត់អំឡុងពេលដែលត្រូវបញ្ចប់ នោះភតិសន្យា នឹងត្រូវបញ្ចប់ដោយការផុតអំឡុងពេលដែលបានកំណត់នោះ (មាត្រា ៦១២)។

ប្រសិនបើ អំឡុងពេល ដែលត្រូវបានកំណត់ដោយកិច្ចព្រមព្រៀង បានកន្លងផុតទៅ នោះ ភតិសន្យា នឹងបាត់បង់អានុភាព ហើយភតិកៈត្រូវសងវត្ថុជួលត្រឡប់មកវិញ ហើយភតិបតីត្រូវមានកាតព្វកិច្ចបង់នូវចំណាយដើម្បីបង្កើនតម្លៃ។

### ៤.២.២. ករណីលើកលែង

ភតិសន្យា គឺជាទំនាក់ទំនងដែលមានលក្ខណៈបន្តបន្ទាប់ឥតដាច់ ដោយផ្អែកទៅលើការជឿទុកចិត្តរវាងភតិកៈ និង ភតិបតី។ ដូចដែលបានរៀបរាប់ខាងលើភតិសន្យា ជាគោលការណ៍ គឺត្រូវបាត់បង់អានុភាពដោយសារតែការកន្លងផុតនៃអំឡុងពេលកំណត់នោះ។

ក៏ប៉ុន្តែ ភាគីនៃភតិសន្យារំពឹងទុកថា កិច្ចសន្យានឹងអាចបន្តនៅក្នុងរយៈពេលវែង ស្ទើរតែគ្រប់ករណីនៅពេលដែលពួកគេ មិនមានបញ្ហានឹងគ្នា។ ដូច្នេះក្រមរដ្ឋប្បវេណីបានបញ្ញត្តពីករណីលើកលែង និង មានគោលបំណងរក្សានូវទំនាក់ទំនងនេះឱ្យបានកាន់តែយូរ តាមដែលអាចធ្វើទៅបាន។

**ក. ក្នុងករណីនៃការជួលអចលនវត្ថុ (មាត្រា ៦១៣)**

ចំពោះការជួលអចលនវត្ថុដែលមានកំណត់អំឡុងពេល ទោះបីជាអំឡុងពេលនៃភតិសន្យានេះដល់កាលកំណត់បញ្ចប់ក៏ដោយ បើភាគីណាម្ខាងនៃភតិសន្យានេះ មិនបានបង្ហាញឆន្ទៈបដិសេធការបន្តជាថ្មីក្នុងអំឡុងពេលមួយដែលបានកំណត់ជាក់លាក់ទេ នោះភតិសន្យាត្រូវបានបន្តសាជាថ្មី ហើយការបន្តថ្មីនេះត្រូវបានកំណត់ថា ជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល។ ហើយដើម្បីបញ្ចប់ភតិសន្យា ដែលពុំមានកំណត់អំឡុងពេលនេះគូភាគីអាចស្នើសុំរំលាយនៅពេលណាក៏បានដោយយោងតាមមាត្រា ៦១៥។ ជាក់ស្តែងមាត្រា ៦១៣ កំណត់ថាដើម្បីបញ្ចប់ភតិសន្យាចំពោះអចលនវត្ថុ ភាគីដែលចង់បញ្ចប់ត្រូវបង្ហាញឆន្ទៈបដិសេធការបន្តជាថ្មី នៅមុនរយៈពេល ៣ ខែ មុនផុតអំឡុងពេលបញ្ចប់ក្នុងភតិសន្យា ចំពោះផ្ទះ ឬ អាគារ និង នៅមុនរយៈពេល ១ ឆ្នាំ មុនផុតអំឡុងពេលបញ្ចប់ក្នុងភតិសន្យាចំពោះដីធ្លី។

មធ្យោបាយ នៅក្នុងការបង្ហាញឆន្ទៈបដិសេធនូវការបន្តភតិសន្យាជាថ្មី គឺមិនត្រូវបានបញ្ញត្តច្បាស់នៅក្នុងជំពូកស្តីពីភតិសន្យាទេ ដូច្នេះ មាត្រា ៣១០ ទាក់ទងនឹងបញ្ញត្តិទូទៅនៃការបង្ហាញឆន្ទៈ ត្រូវយកមកអនុវត្ត។

ឧទាហរណ៍ **ក** ជួលផ្ទះឱ្យទៅ **ខ** រយៈពេល ១ ឆ្នាំ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០។ ប្រសិនបើ **ក** ចង់ឈប់ជួលផ្ទះនោះ **ក** ត្រូវជូនដំណឹងពីឆន្ទៈបដិសេធការជួលបន្តជាថ្មី ទៅ **ខ** ឱ្យបានមុនរយៈពេល ៣ ខែ មុនផុតថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០។

**ខ. ក្នុងករណីនៃការជួលចលនវត្ថុ (មាត្រា ៦១៤)**

ចំពោះការជួលចលនវត្ថុ ដែលមានកំណត់អំឡុងពេល ទោះបីជាអំឡុងពេលនៃភតិសន្យានេះ ដល់កាលកំណត់បញ្ចប់ក៏ដោយ ប្រសិនបើ (១) ភតិបតីបានដឹងថាភតិកៈបន្តប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួលក្រោយអំឡុងពេលនៃការបញ្ចប់បានកន្លងផុត ហើយ (២) ភតិបតីពុំបានធ្វើការតវ៉ាទេ នោះភតិសន្យាត្រូវបានសន្មតថាជា

ភតិសន្យាដែលបានបន្តជាថ្មី ដោយគ្មានកំណត់អំឡុងពេល ហើយមានលក្ខខណ្ឌដូចគ្នានឹងកិច្ចសន្យាដែលបានជួលពីមុនមក លើកលែងតែអំឡុងពេលចេញ។

នៅក្នុងករណីនៃការជួលចលនវត្ថុដោយមានកំណត់អំឡុងពេល ភតិបតីមិនចាំបាច់បង្ហាញឆន្ទៈបដិសេធការបន្តជាថ្មី ជាមុននោះទេ ប្រសិនបើគាត់ ចង់បញ្ចប់ភតិសន្យានោះ។

ឧទាហរណ៍ ២ បានជួលរថយន្តមួយគ្រឿងពី ក រយៈពេល ៦ ខែ ក្នុងតំលៃ ៥០ ដុល្លារ ក្នុង ១ ខែ។ ក្រោយពីរយៈពេល ៦ ខែ បានកន្លងផុតទៅ ខ នៅតែបន្តបើករថយន្តនោះទៀត ហើយ ក មិនបានធ្វើការតវ៉ា ទោះបីជាគាត់ បានដឹងថាហេតុថាអំឡុងពេលត្រូវបានកន្លងហួស ហើយ ខ នៅតែបើកបររថយន្តនោះទៀត។ នៅក្នុងករណីនេះ ភតិសន្យាត្រូវបានសន្មតថាជា ភតិសន្យាដែលបានបន្តសាជាថ្មី ដោយគ្មានកំណត់អំឡុងពេល ហើយថ្លៃឈ្នួល គឺ ៥០ ដុល្លារ ក្នុង ១ ខែ។

គោលគំនិតនៃមាត្រានេះ គឺដើម្បីការពារនូវការរំពឹងទុកជាមុនរបស់ភតិកៈ ក្នុងការបន្តការប្រើប្រាស់លើវត្ថុជួល ប្រសិនបើភតិបតីមិនបានធ្វើការតវ៉ា ទោះបីជាគាត់បានដឹងថាភតិកៈបានបន្តការប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួល ក្រោយពីការកន្លងផុតនៃអំឡុងពេល។ ផ្ទុយទៅវិញ ប្រសិនបើភតិបតីត្រូវធ្វើការតវ៉ានៅក្នុងអំឡុងពេលដ៏ខ្លី ដូចជា ពីរ ឬ បីម៉ោង ឬ ក៏ភតិសន្យា ត្រូវបានសន្មតថាជាភតិសន្យាដែលត្រូវបានបន្តជាថ្មី ហើយវានឹងដាក់បន្ទុកដ៏ធ្ងន់ធ្ងរដល់ភតិបតី។ ដូច្នេះ ចៅក្រមត្រូវធ្វើការសម្រេចពីអំឡុងពេលសមរម្យ ដោយធ្វើការពិចារណាទៅលើស្ថានភាពជាក់ស្តែងនៃភតិសន្យា។ សម្រាប់ជាការយោង ក្រមរដ្ឋប្បវេណីនៃប្រទេសអាឡឺម៉ង់ បានបញ្ញត្តថាភតិបតីត្រូវធ្វើការតវ៉ានៅក្នុងអំឡុងពេល ២ សប្តាហ៍។

## ៤.៣. ការស្នើសុំឱ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល

មានភតិសន្យាខ្លះបានបង្កើតឡើង ដោយពុំមានកំណត់អំឡុងពេលបញ្ចប់ទេ ករណីបែបនេះអាចបង្កជាបញ្ហាដល់ភាគីម្ខាងទៀតដែលទន់ខ្សោយ ព្រោះនៅពេលដែលភាគីម្ខាងចង់រំលាយភតិសន្យា ហើយភាគីដែលទន់ខ្សោយនោះ មិនអាចត្រៀមលក្ខណៈរៀបចំខ្លួនជាមុនបាន។ ដូចនេះ ដើម្បីការពារផលវិបាកដែលកើតមានឡើង ទើបមាត្រា ៦១៥ បានបញ្ញត្តថា បើពុំបានកំណត់អំឡុងពេលជួលនៅក្នុងកិច្ចសន្យាទេ ភាគីម្ខាងទៀត ក៏អាចសុំរំលាយភតិសន្យានៅពេលណាក៏បាន ហើយភតិសន្យានោះ នឹងត្រូវបញ្ចប់នៅក្នុង (១) អំឡុងពេល ១ ថ្ងៃ បានកន្លងផុតទៅគិតចាប់ពីពេលស្នើសុំឱ្យរំលាយ ចំពោះចលនវត្ថុ (២) អំឡុងពេល ៣ ខែ បានកន្លងផុតទៅ គិតចាប់ពីពេលស្នើសុំឱ្យរំលាយចំពោះអាគារ និង (៣) អំឡុងពេល ១ ឆ្នាំ បានកន្លងផុតទៅ គិតចាប់ពីពេលស្នើសុំឱ្យរំលាយចំពោះដីធ្លី។ ហើយបញ្ញត្តិនេះ ក៏បានចែងថា ចំពោះភតិសន្យាដីធ្លី ដែលមានរដូវប្រមូលផល ភតិសន្យានោះនឹងត្រូវបញ្ចប់នៅមុនការចាប់ផ្តើមធ្វើកសិកម្មសម្រាប់រដូវបន្ទាប់។

ហើយទោះបីជាភាគី កំណត់ពេលសុំរំលាយភតិសន្យាតិចជាងអំឡុងពេល ដែលមានចែងនៅក្នុងមាត្រា ៦១៥ ក៏ដោយ ក៏ចាត់ទុកថា ភតិសន្យា នឹងត្រូវបានរំលាយ តាមលក្ខខណ្ឌក្នុងមាត្រា ៦១៥ នេះដដែល។

ឧទាហរណ៍ ក ជួលអាគារមួយពី ខ ដោយពុំមានកំណត់អំឡុងពេលបញ្ចប់ទេ។ ប្រសិនបើ ក ជូនដំណឹងពីការបញ្ចប់ទៅឱ្យ ខ ដែលបានកំណត់ថា ក បញ្ចប់ភតិសន្យា បន្ទាប់ពីរយៈពេល ២ ខែ បានកន្លងផុតទៅ ដូច្នេះ កិច្ចសន្យាមិនត្រូវបានបញ្ចប់ឡើយ នៅមុនរយៈពេល ៣ ខែ បានកន្លងផុត។

ទោះបីជា នៅក្នុងករណីដែលភាគី បានកំណត់អំឡុងពេលសម្រាប់ការជួល ប្រសិនបើភាគីម្ខាង ឬ ភាគីទាំងសងខាងបានរក្សាទុកសិទ្ធិអំណាចក្នុងការអនុវត្តការរំលាយកិច្ចសន្យា ក្នុងអំឡុងពេលជួលនោះបញ្ញត្តិនៃមាត្រា ៦១៥ ត្រូវយកមកអនុវត្តដូចគ្នា ( មាត្រា ៦១៦) ។

### ៤.៤. ការបញ្ចប់ដោយសារបាត់បង់នូវវត្ថុជួល

ដោយសារវត្ថុជួល គឺជាវត្ថុមួយដែលកំណត់ជាក់លាក់ នៅពេលបាត់បង់វត្ថុជួល ភតិសន្យានឹងត្រូវបញ្ចប់ ព្រោះតែគោលបំណងនៃភតិសន្យាមិនអាចសម្រេចទៅបាន។ ទន្ទឹមនឹងនេះ នៅពេលដែលវត្ថុជួលត្រូវបាត់បង់ដោយសារតែកំហុសរបស់ភាគីណាមួយ យោងតាមមាត្រា ៣៩៨ កថាខណ្ឌទី ១ ភាគីដែលមានកំហុសត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតដែលកើតឡើង។

ខុសគ្នាពីកិច្ចសន្យាលក់ទិញ នៅក្នុងករណីនៃកិច្ចសន្យាដែលបន្ត ដូចជាភតិសន្យា គឺមិនមានលទ្ធភាពក្នុងការពិចារណាថា មានតែកាតព្វកិច្ចបង់ថ្លៃឈ្នួលនៅមាន ប្រសិនបើកម្មវត្ថុ ត្រូវបានបាត់បង់។ ដូច្នេះ ភតិសន្យាត្រូវបញ្ចប់ ដោយមិនមានការបង្ហាញឆន្ទៈទេ ប្រសិនបើកម្មវត្ថុនៃភតិសន្យាត្រូវបានបាត់បង់។

ឧទាហរណ៍ ក បានជួលផ្ទះឱ្យទៅ ខ ប៉ុន្តែ ផ្ទះនោះត្រូវភ្លើងឆេះអស់ ដោយសារតែការធ្វេសប្រហែសរបស់ ក ធ្វើឱ្យចង្ក្រានហួសផ្ទុះ។ នៅក្នុងករណីនេះ ភតិសន្យារវាង ក និង ខ ត្រូវបញ្ចប់ ហើយ ខ ត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាតទៅឱ្យ ក។

### ៤.៥. ការរំលាយភតិសន្យា ដោយសារការមិនអនុវត្តកាតព្វកិច្ច

យោងតាមមាត្រា ៤០៧ បើភាគីណាម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញ បំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ភាគីម្ខាងទៀត អាចរំលាយកិច្ចសន្យាបានភ្លាម។ មាត្រានេះ អាចអនុវត្តចំពោះភតិសន្យាបានដោយសារតែភតិសន្យា គឺជាកិច្ចសន្យាអញ្ញមញ្ញ។

ឧទាហរណ៍ នៅក្នុងករណីដែល ភតិក: មិនបង់ថ្លៃឈ្នួលនៃភតិសន្យា អស់រយៈពេលយ៉ាងយូរ នោះភតិបតីមានសិទ្ធិរំលាយកិច្ចសន្យានោះ ព្រោះការមិនបង់ថ្លៃឈ្នួល អាចត្រូវបានចាត់ទុកថាជា ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ។ នៅក្នុងករណីនេះ ការមិនអនុវត្តកាតព្វកិច្ច គឺមានលក្ខណៈជាសារធាតុ ដែលការជឿទុកចិត្តរវាងគូភាគីត្រូវបានបំផ្លាញ និង មិនអាចជឿជាក់ថានឹងមានការអនុវត្តកាតព្វកិច្ចនាពេលអនាគត ដូច្នេះមាត្រា ៤០៨ កថាខណ្ឌទី ១ ចំនុច (ឃ) អាចយកមកអនុវត្ត។ ក៏ប៉ុន្តែ វាអាស្រ័យទៅលើការអនុវត្តនៅប្រទេសកម្ពុជា ដែលថាអំឡុងពេលនៃការមិនបង់ថ្លៃឈ្នួលកម្រិតណា ទើបអាចចាត់ទុកថាជា ការបំពានកិច្ចសន្យាធ្ងន់ធ្ងរនៅក្នុងភតិសន្យា។

## ផ្នែកទី ៤

## ការខ្ចីបរិភោគ

### ១. គោលបំណង

ការខ្ចីបរិភោគ គឺសំដៅលើកិច្ចសន្យាដែលភាគីម្ខាង ហៅថា "អ្នកឱ្យខ្ចី" ដែលមានទ្រព្យផ្ទាល់ខ្លួនបានប្រគល់ទ្រព្យនោះឱ្យទៅភាគីម្ខាងទៀត ហៅថា "អ្នកខ្ចី" ដោយមានការព្រមព្រៀងគ្នាថា អ្នកខ្ចីត្រូវប្រើប្រាស់ទ្រព្យដែលបានខ្ចីនោះ ហើយត្រូវសងទៅវិញ នៅពេលដែលផុតអំឡុងពេលខ្ចីនូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ (មាត្រា ៥៧៨)។ វាគឺជាកិច្ចសន្យាទ្វេភាគី ព្រោះអ្នកឱ្យខ្ចីត្រូវមានកាតព្វកិច្ចប្រគល់វត្ថុ និង អ្នកខ្ចី ត្រូវមានកាតព្វកិច្ចសងវត្ថុវិញផងដែរ។

ឧទាហរណ៍ : អ្នកខ្ចីបានខ្ចីស្រូវ ហើយអ្នកខ្ចីមានសេរីភាពក្នុងការប្រើប្រាស់ស្រូវនោះបាន ហើយអ្នកខ្ចីមានករណីយកិច្ចសងទៅអ្នកឱ្យខ្ចីវិញនូវស្រូវដែលមានប្រភេទ គុណភាព និង បរិមាណដូចគ្នា ក្រោយពីអំឡុងពេលកំណត់សងបានកន្លងផុតទៅ។

កិច្ចសន្យាខ្ចីបរិភោគ ចែកចេញជាពីរប្រភេទ :

- កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ គឺជាកិច្ចសន្យាដែលយកតម្លៃថ្នូរ
- កិច្ចសន្យាខ្ចីបរិភោគដោយមិនយកការប្រាក់ គឺជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ

ភាពខុសគ្នារវាង កិច្ចសន្យាខ្ចីបរិភោគ, ភតិសន្យា និង កិច្ចសន្យាឱ្យប្រើ :

| កិច្ចសន្យាខ្ចីបរិភោគ | ភតិសន្យា | កិច្ចសន្យាខ្ចីប្រើ |
|---|---|---|
| - ប្រគល់វិញនូវវត្ថុដែលមានប្រភេទ គុណភាព និងបរិមាណដូចគ្នា (មិនមែនតែវត្ថុដើមប៉ុណ្ណោះទេ) | - ត្រូវមានកាតព្វកិច្ចប្រគល់វិញនូវវត្ថុដើម (វត្ថុដដែលដូចមុន) | - ត្រូវមានកាតព្វកិច្ចប្រគល់វិញនូវវត្ថុដើម (វត្ថុដដែលដូចមុន) |
| - បានទទួលនូវការផ្ទេរកម្មសិទ្ធិ | - កម្មសិទ្ធិមិនត្រូវបានផ្ទេរ | - កម្មសិទ្ធិ មិនត្រូវបានផ្ទេរ |
| - មិនយក ឬ យកតម្លៃថ្នូរ | - យកតម្លៃថ្នូរ | - មិនយកតម្លៃថ្នូរ |

### ២. លក្ខខណ្ឌ

កិច្ចសន្យាខ្ចីបរិភោគ បង្កើតឡើងដោយការព្រមព្រៀងរបស់ភាគីទាំងសងខាង (មាត្រា ៥៧៩)។ ភាគីក៏អាចបង្កើតកិច្ចសន្យា ដែលមានកម្មវត្ថុជាការសងការប្រាក់តាមការព្រមព្រៀងបាន។ ក៏ប៉ុន្តែ ការព្រមព្រៀងបង្កើត

សិទ្ធិលើបំណុលនៃការប្រាក់ពុំមានអានុភាពឡើយ ប្រសិនបើពុំបានធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់អ្នកខ្ចី (មាត្រា ៥៨៣ កថាខណ្ឌទី ៣)។

ភាគី អាចបង្កើតកិច្ចសន្យាខ្ចីបរិភោគ ដោយមិនកំណត់អំឡុងពេលក្នុងការសងបាន។ ក៏ប៉ុន្តែ វា មានភាពចាំបាច់ក្នុងការកំណត់ពី គុណភាព ចំនួន និង ប្រភេទនៃកម្មវត្ថុ ដើម្បីបង្កើតកិច្ចសន្យាខ្ចីបរិភោគ។

វត្ថុដែលបានកំណត់ជាក់លាក់ ដូចជាអចលនវត្ថុ មិនអាចធ្វើជាកម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគនោះទេ ព្រោះវា មិនអាចជំនួសបាន។

## ៣. ភាតព្វកិច្ច និង សិទ្ធិរបស់អ្នកឱ្យខ្ចី

### ៣.១. ភាតព្វកិច្ចឱ្យខ្ចីវត្ថុដែលជាកម្មវត្ថុ

អ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់វត្ថុឱ្យអ្នកខ្ចី ប្រើប្រាស់វត្ថុ ដោយសមស្របតាមកិច្ចសន្យា រីឯអ្នកខ្ចី អាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុ (លក់) ដោយសេរីបាន (មាត្រា ៥៨៧)។ អ្នកខ្ចី បានទទួលកម្មសិទ្ធិលើវត្ថុនោះ។

### ៣.២. ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចី

#### ៣.២.១. នៅក្នុងករណីដែលអ្នកឱ្យខ្ចី ប្រគល់វត្ថុដែលជារបស់អ្នកដទៃ

***ក. ក្នុងករណីដែលការខ្ចីបរិភោគ ដោយភ្ជាប់ការប្រាក់***

ក្នុងកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់រវាងអ្នកឱ្យខ្ចី និង អ្នកខ្ចី ហើយនៅពេលប្រគល់វត្ថុ ដែលមិនមែនជាវត្ថុរបស់អ្នកឱ្យខ្ចី នោះអ្នកឱ្យខ្ចីត្រូវមានករណីយកិច្ចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះ ហើយផ្ទេរទៅឱ្យអ្នកខ្ចី ឬ ត្រូវប្តូរជាមួយវត្ថុផ្សេងទៀត ដែលមាន ប្រភេទ គុណភាព និង បរិមាណ ដូចគ្នា ហើយដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់អ្នកឱ្យខ្ចី។ ទោះបីវត្ថុ ដែលប្រគល់នោះជារបស់អ្នកផ្សេងក៏ដោយ ក៏កិច្ចសន្យាខ្ចីបរិភោគនោះមិនត្រូវចាត់ទុកជាមោឃៈទេ។ ប៉ុន្តែ អ្នកខ្ចីមិនមានសិទ្ធិទាមទារឱ្យប្រគល់វត្ថុជំនួសទេ នៅក្រោយពេលដែលបរិភោគវត្ថុនោះ រួចហើយ (មាត្រា ៥៨៨ កថាខណ្ឌទី ១)។

ម្យ៉ាងវិញទៀត បើអ្នកឱ្យខ្ចី មិនអាចប្រគល់វត្ថុនោះបាន ឬ មិនអាចរកវត្ថុផ្សេងមកជំនួសបានទេ អ្នកខ្ចីមានសិទ្ធិរំលាយកិច្ចសន្យាខ្ចីបរិភោគនោះបាន ទោះបីអ្នកខ្ចីនោះសុចរិត ឬ ទុច្ចរិតក៏ដោយ (មាត្រា ៥៨៨ កថាខណ្ឌទី ២)។

ទន្ទឹមនឹងនេះ ប្រសិនបើអ្នកខ្ចីដែលបានទទួលការប្រគល់វត្ថុខ្ចី ដោយមិនបានដឹងថា អ្នកឱ្យខ្ចីមិនមានកម្មសិទ្ធិទេ អាចទាមទារសំណងនៃការខូចខាតពីអ្នកឱ្យខ្ចីបាន (មាត្រា ៥៨៨ កថាខណ្ឌទី ៣)។

***ខ. កិច្ចសន្យាខ្ចីបរិភោគដោយមិនយកការប្រាក់***

ចំពោះកិច្ចសន្យាខ្ចីបរិភោគដោយមិនយកការប្រាក់ ប្រសិនបើអ្នកឱ្យខ្ចី បានដឹងថា វត្ថុ ដែលត្រូវប្រគល់នោះជារបស់ដទៃ ប៉ុន្តែ អ្នកឱ្យខ្ចី មិនបានជូនដំណឹងដល់អ្នកខ្ចីទេ នោះ អ្នកឱ្យខ្ចី ក៏ត្រូវទទួលខុសត្រូវ ដូចដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ដល់ ទី ៣ នៃមាត្រា ៥៨៨។

ចំពោះករណីទាំងពីរខាងលើ ចំណុច **ក** និង ចំណុច **ខ** បើអ្នកខ្ចី បានសងវត្ថុ ដែលត្រូវបានប្រគល់ឱ្យ ឬ សងតម្លៃនៃវត្ថុនោះ ឱ្យទៅម្ចាស់កម្មសិទ្ធិនោះ អ្នកខ្ចីត្រូវបានរួចផុតពីករណីយកិច្ចសងចំពោះអ្នកឱ្យខ្ចី (មាត្រា ៥៨៨ កថាខណ្ឌទី ៥) ។

***គ. សិទ្ធិរំលាយរបស់អ្នកឱ្យខ្ចីវត្ថុដទៃ***

ប្រសិនបើអ្នកឱ្យខ្ចី បានប្រគល់វត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ទៅឱ្យអ្នកខ្ចី ដោយមិនបានដឹងថាជាវត្ថុរបស់អ្នកដទៃ ហើយគាត់មិនអាចផ្ទេរកម្មសិទ្ធិលើវត្ថុ ឬ វត្ថុជំនួស ទៅឱ្យអ្នកខ្ចីបាន នោះគាត់អាចរំលាយកិច្ចសន្យា។ ក៏ប៉ុន្តែ ប្រសិនបើអ្នកខ្ចីដែលបានធ្វើសកម្មភាពដោយសុចរិតនៅពេលប្រគល់ មានសិទ្ធិទាមទារសំណងនៃការខូចខាតបាន ដោយផ្អែកលើមាត្រា ៥៨៨ ហើយការរំលាយកិច្ចសន្យានេះត្រូវបានអនុញ្ញាត លុះត្រាតែបានសងសំណងនៃការខូចខាតនោះ (មាត្រា ៥៨៩) ។

ឧទាហរណ៍ **ក** បានប្រគល់អង្ករ ដោយមិនបានដឹងថា អង្ករនោះ គឺជាកម្មសិទ្ធិរបស់ **គ**។ **ខ** គ្រប់គ្រងលើភោជនីយដ្ឋានមួយ ប៉ុន្តែ គាត់ មិនអាចបើកភោជនីយដ្ឋានបានក្នុងរយៈពេល ២ ថ្ងៃ ព្រោះ គាត់ ត្រូវសងអង្ករនោះទៅឱ្យ **គ** វិញ ដោយផ្អែកតាមមាត្រា ៥៨៨ កថាខណ្ឌទី ៣។ នៅក្នុងករណីនេះ **ក** អាចរំលាយកិច្ចសន្យាបាន ប៉ុន្តែ គាត់ ត្រូវសងប្រាក់ចំណូលនៅក្នុងរយៈពេល ២ ថ្ងៃ ទៅឱ្យ **ខ** នៅមុនពេលរំលាយ ។

### ៣.២.២. នៅក្នុងករណីដែលវត្ថុត្រូវបានប្រគល់នោះ មានវិការៈ

***ក. ក្នុងករណីនៃការខ្ចីបរិភោគ ដោយភ្ជាប់ការប្រាក់ ៖***

អ្នកឱ្យខ្ចី ត្រូវមានកាតព្វកិច្ចប្រគល់វត្ថុ ដោយគ្មានវិការៈ (មាត្រា ៥២៣ និង មាត្រា ៥២៩) ។ ដូច្នេះ ប្រសិនបើអ្នកឱ្យខ្ចី បានប្រគល់វត្ថុទៅឱ្យអ្នកខ្ចី តាមកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ហើយវត្ថុដែលប្រគល់នោះមានវិការៈកំបាំង និង អ្នកខ្ចី ដែលបានទទួលវត្ថុនោះ ដោយមិនបានដឹងអំពីវិការៈនោះ អាច ទាមទារឱ្យប្តូរជាមួយនឹងវត្ថុដែលគ្មានវិការៈ ព្រមជាមួយនឹងសំណងការខូចខាតបាន ប្រសិនបើមាន (មាត្រា ៥៩០ កថាខណ្ឌទី ១) ។

***ខ. នៅក្នុងករណីនៃការខ្ចីបរិភោគដែលមិនមានការប្រាក់ ៖***

នៅក្នុងករណីនៃការខ្ចីបរិភោគដែលមិនមានការប្រាក់ ការទទួលខុសត្រូវរបស់អ្នកឱ្យខ្ចីត្រូវបានកាត់បន្ថយ ។

ជាគោលការណ៍ ប្រសិនបើអ្នកឱ្យខ្ចីបានប្រគល់វត្ថុដែលមានវិការៈទៅឱ្យអ្នកខ្ចី នោះអ្នកខ្ចីអាចសងវត្ថុដែលមានវិការៈដូចគ្នាទៅអ្នកឱ្យខ្ចីវិញ។ ក៏ប៉ុន្តែ វាមានការលំបាក និង ពេលខ្លះវាហាក់ដូចជាមិនសមហេតុផលក្នុងការស្វែងរកវត្ថុដែលមានវិការៈប្រហាក់ប្រហែលគ្នា។ ដូច្នេះ ក្រមរដ្ឋប្បវេណីបានចែងថាអ្នកខ្ចីអាចសងជា តម្លៃស្មើនឹងវត្ថុដែលមានវិការៈបាន (មាត្រា ៥៩០ កថាខណ្ឌទី ២) ។ ឧទាហរណ៍ **ក** បានប្រគល់អង្ករ ១០ គីឡូក្រាម ឱ្យទៅ **ខ** តាមរយៈការខ្ចីបរិភោគដោយគ្មានការប្រាក់ ប៉ុន្តែ នៅក្នុងនោះមានអង្ករ ២ គីឡូក្រាម មានគុណភាពអន់ ហើយដែលតម្លៃរបស់វាមានតែ ១ ភាគ ១០ នៃតម្លៃទីផ្សារតែប៉ុណ្ណោះ។ នៅក្នុងករណីនេះ **ខ** អាចសងអង្ករ ៨ គីឡូក្រាម ដែលមានគុណភាពដូចអង្ករដែលគាត់បានទទួល និង តម្លៃ ១ ភាគ ១០ នៃតម្លៃទីផ្សារ។

ទន្ទឹមនឹងនេះ ប្រសិនបើអ្នកឱ្យខ្ចី បានដឹងអំពីវិការៈនៃវត្ថុនោះមុនធ្វើការប្រគល់ ហើយបានលាក់ចំពោះអ្នកខ្ចី នោះអ្នកឱ្យខ្ចីត្រូវមានកាតព្វកិច្ចប្តូរវត្ថុដែលគ្មានវិការៈ ហើយនិងសងសំណងការខូចខាតដល់អ្នកខ្ចីដែលកើត ឡើង ដោយសារវត្ថុដែលមានវិការៈនោះ ( មាត្រា ៥៩០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។

## ៣.៣. ការទាមទារឱ្យសងមកវិញ នៅក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី បានធ្លាក់ចុះយ៉ាងខ្លាំង

នៅពេលកិច្ចសន្យាខ្ចីបរិភោគបានបង្កើតឡើងរវាងអ្នកឱ្យខ្ចី និង អ្នកខ្ចី ហើយស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីក្នុងការអនុវត្តកាតព្វកិច្ចសងក្លាយជាមានឧបសគ្គ នៅមុនពេលប្រគល់វត្ថុដែលជាកម្មវត្ថុ អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យានោះបាន ( មាត្រា ៥៨១) ។

បន្ទាប់មកចុះចំពោះករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីបានធ្លាក់ចុះ **នៅក្រោយពេល**ប្រគល់តើវានឹងទៅជាយ៉ាងណា? តើអ្នកឱ្យខ្ចីអាចទាមទារវត្ថុត្រឡប់មកវិញនៅមុនពេលកំណត់សង ដោយផ្អែកលើមូលហេតុនៃការធ្លាក់ចុះនៃទ្រព្យធនរបស់អ្នកខ្ចីបាន ដែរ ឬ ទេ?

អ្នកខ្ចីមានសិទ្ធិប្រើប្រាស់វត្ថុ ដែលបានផ្តល់ឱ្យរហូតដល់ពេលប្រគល់។ ឬ និយាយម្យ៉ាងទៀត គាត់មិនចាំបាច់ប្រគល់វត្ថុ នៅមុនកាលបរិច្ឆេទសងនោះទេ។ ចំណុចនេះត្រូវបានឱ្យឈ្មោះថា "ផលប្រយោជន៍នៃការកំណត់ពេល"។ យោងតាមមាត្រា ៥៩៤ កថាខណ្ឌទី ១ អ្នកឱ្យខ្ចី មិនត្រូវបានអនុញ្ញាតឱ្យធ្វើការទាមទារសងវត្ថុ នៅមុនកាលបរិច្ឆេទសងឡើយ។ ក៏ប៉ុន្តែ ចំណុចនេះមិនត្រូវយកមកអនុវត្ត ប្រសិនបើអ្នកខ្ចីស្ថិតនៅក្នុងស្ថានភាពនៃចំណុចណាមួយ ដែលមានចែងនៅក្នុងមាត្រា ៣៣១។ ទាក់ទងនឹង "ពេល" ដោយផ្អែកលើ មាត្រា ៣៣០ កថាខណ្ឌទី ១ គឺ ការកំណត់ពេលត្រូវបានសន្មតថា បានជាផលប្រយោជន៍របស់កូនបំណុល។ ដូច្នេះ ទោះបីជាស្ថានភាពទ្រព្យសម្បត្តិរបស់អ្នកខ្ចីធ្លាក់ចុះយ៉ាងណាក៏ដោយ អ្នកឱ្យខ្ចីមិនអាចទាមទារឱ្យសងវត្ថុខ្ចីមកវិញបានទេ នៅមុនកាលបរិច្ឆេទប្រគល់។

ក៏ប៉ុន្តែ នៅក្នុងករណីដែលស្ថានភាព ដែលមានចែងនៅក្នុងរាល់ចំណុចនៃមាត្រា ៣៣១ កើតឡើង នោះកូនបំណុលត្រូវបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល ហើយជាលទ្ធផលគាត់ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនជាបន្ទាន់។ ឧទាហរណ៍ ប្រសិនបើអ្នកខ្ចីត្រូវបានប្រកាសថាក្ស័យធន នោះគាត់ត្រូវសងវត្ថុខ្ចីមកវិញភ្លាម។

ទន្ទឹមនឹងនេះចំណុច **ឃ** នៃមាត្រានេះ ក៏បានចែងថាហេតុដែលគូភាគីបានព្រមព្រៀងគ្នា បានកើតឡើង នោះ កូនបំណុលត្រូវបានបាត់បង់ផលប្រយោជន៍នៃពេលដែរ។

ឧទាហរណ៍ : "ហេតុដែលគូភាគី បានព្រមព្រៀងគ្នាបានកើតឡើង" ត្រូវបានរាប់បញ្ចូល ដូចជា ការព្រមព្រៀងពិសេសដែលចែងថា "ប្រសិនបើមានមូលហេតុដែលអ្នកខ្ចីមិនបានបង់ការប្រាក់ ចំនួន ៣ ខែ នោះអ្នកឱ្យខ្ចីអាចទាមទារឱ្យបង់ភ្លាមនូវប្រាក់បំណុលដែលនៅសល់ទាំងអស់ ដោយមិនចាំបាច់ធ្វើការជូនដំណឹង ជាមុន នោះទេ" ឬ "នៅក្នុងករណីដែលទ្រព្យសម្បត្តិរបស់អ្នកខ្ចី ត្រូវបានរឹបអូសដោយម្ចាស់បំណុលផ្សេងទៀត នោះអ្នកខ្ចីត្រូវបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល និង ត្រូវសងបំណុលភ្លាម" ជាអាទិ៍។

## ៤. កាតព្វកិច្ចរបស់អ្នកខ្ចី

### ៤.១. ករណីយកិច្ចត្រូវសងវត្ថុ

ករណីយកិច្ចត្រូវសង គឺជាករណីយកិច្ចចម្បង និង ទូទៅបំផុតរបស់អ្នកខ្ចី ហើយករណីយកិច្ចនេះ គឺត្រូវតែបំពេញឱ្យបាន នៅពេលដែលពេលវេលាកំណត់នៃការសងបានមកដល់ មិនតែប៉ុណ្ណោះការសងត្រូវធ្វើឡើងដោយគោរពតាមគោលការណ៍មួយចំនួន ដែលត្រូវបានកំណត់នៅក្នុងមាត្រា ៥៩១ រហូតដល់មាត្រា ៥៩៥។

ជាគោលការណ៍ អ្នកខ្ចីត្រូវមានកាតព្វកិច្ចសងទៅអ្នកឱ្យខ្ចីវិញនូវវត្ថុ ដែលមានប្រភេទ គុណភាព និង ចំនួនស្មើនឹងវត្ថុដែលអ្នកខ្ចីបានទទួលការប្រគល់ នៅថ្ងៃ ឬ ពេលវេលាដែលត្រូវសង (មាត្រា ៥៩១ កថាខណ្ឌទី ១)។ ឧទាហរណ៍ថា ប្រសិនបើអ្នកខ្ចី បានខ្ចីស្រូវពូជប្រភេទស្រូវផ្កាម្លិះចំនួន ៥០ គីឡូក្រាម ពីអ្នកឱ្យខ្ចីសម្រាប់រយៈពេល ១ ឆ្នាំ និង សន្យាថានឹងឱ្យការប្រាក់ ១០ ភាគរយ ក្នុងមួយឆ្នាំ។ នោះនៅពេលកំណត់នៃការសងមកដល់អ្នកខ្ចីត្រូវតែសងនូវស្រូវពូជប្រភេទផ្កាម្លិះ ដែលមានគុណភាព ដូចជា ស្រូវពូជដែលខ្លួនបានខ្ចីពីអ្នកឱ្យខ្ចីក្នុងបរិមាណ ៥០ គីឡូក្រាម និង ការប្រាក់ ៥ គីឡូក្រាម សរុប គឺ ៥៥ គីឡូក្រាម នៅថ្ងៃកំណត់សង។ អ្នកខ្ចីមិនអាចសងនូវវត្ថុដែលមានបរិមាណតិចជាង ហើយអ្នកឱ្យខ្ចីក៏មិនអាចទាមទារឱ្យអ្នកខ្ចីផ្តល់នូវការសងវត្ថុ ដែលមានបរិមាណច្រើនជាងបរិមាណដែលបានកំណត់នៅក្នុងកិច្ចសន្យានោះទេ លើកលែងតែភាគីទាំងពីរបានព្រមព្រៀងគ្នា។ ប្រសិនបើការសងមិនបានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់ខាងលើនោះទេ អ្នកឱ្យខ្ចីអាចបដិសេធមិនទទួលយកនូវការសងដោយមូលហេតុណាមួយ ដូចជា ភាពខុសគ្នានៃប្រភេទ ឬ បរិមាណ ឬ គុណភាព ហើយអ្នកឱ្យខ្ចី អាចទាមទារឱ្យអ្នកខ្ចីទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនោះបាន។

មានសំណួរសួរថា តើត្រូវធ្វើដូចម្តេចប្រសិនបើតម្លៃនៃវត្ថុនោះមានការប្រែប្រួលនៅមុនពេលសង?

នៅក្នុងករណីដែលបានចោទឡើងខាងលើនេះ អ្នកខ្ចីក៏នៅតែមានកាតព្វកិច្ចសងនូវវត្ថុ ឬ រូបិយវត្ថុត្រឹមកម្រិតដែលខ្លួនបានខ្ចីដដែល បើទោះជាតម្លៃនៃវត្ថុ ឬ រូបិយវត្ថុមានការកើនឡើង ឬ ថយចុះដល់កម្រិតណាក៏ដោយ (មាត្រា ៥៩៣)។ ជាឧទាហរណ៍ ប្រសិនបើនៅពេលខ្ចី មាស ១ គីឡូក្រាម មានតម្លៃ ៥០០ ដុល្លារ នៅថ្ងៃទទួលការប្រគល់ ហើយអំឡុងពេលសម្រាប់ការខ្ចីបរិភោគ គឺ ២ ឆ្នាំ។ នៅក្នុងករណីនេះ ទោះបីជាតម្លៃមាសកើនដល់ ១.០០០ ដុល្លារ ក្នុង ១ គីឡូក្រាម ក៏អ្នកខ្ចីត្រូវសងមាស ១ គីឡូក្រាម ដដែល។

#### ៤.១.១. ពេលវេលានៃការសង

ដោយហេតុថា ការខ្ចីបរិភោគ ត្រូវបានបែងចែកជា ពីរប្រភេទ គឺ ការខ្ចីបរិភោគ ដែលមានកំណត់អំឡុងពេល និង ការខ្ចីបរិភោគ ដែលពុំមានកំណត់អំឡុងពេល។ ឬនិយាយម្យ៉ាងទៀត វាមិនមានភាពចាំបាច់ក្នុងការកំណត់ពីកាលបរិច្ឆេទសង ដើម្បីបង្កើតកិច្ចសន្យាខ្ចីបរិភោគនោះទេ។

ចំពោះ **ការខ្ចីបរិភោគដែលមានកំណត់អំឡុងពេល** អ្នកឱ្យខ្ចី មិនអាចទាមទារអ្នកខ្ចីឱ្យសងនូវវត្ថុ ដែលបានខ្ចី មុនកាលបរិច្ឆេទ ដែលបានកំណត់នៅក្នុងកិច្ចសន្យានោះបានឡើយ (មាត្រា ៥៩៤ កថាខណ្ឌទី ១)។ ប៉ុន្តែ ក៏នៅ

មានករណីលើកលែងមួយចំនួន ដែលអាចឱ្យ អ្នកឱ្យខ្ចីទាឱ្យសងមុនពេលកំណត់មកដល់បាន ដូចជា : ករណី ដែលកូនបំណុល (អ្នកខ្ចី) ត្រូវបានប្រកាសក្ស័យធន កូនបំណុលបានធ្វើឱ្យខូចខាតប្រាតិភោគ (វត្ថុធានាបំណុល) កូនបំណុលមានករណីយកិច្ចត្រូវដាក់ប្រាតិភោគ ប៉ុន្តែខ្លួនមិនបានបំពេញករណីយកិច្ចនេះ ឬ ហេតុ ដែលគូភាគីបានព្រមព្រៀងគ្នា បានកើតឡើង (មាត្រា ៣៣១)។

ចំពោះ **ការខ្ចីបរិភោគដែលពុំមានកំណត់អំឡុងពេល** អ្នកឱ្យខ្ចី អាចធ្វើការដាស់តឿនដល់អ្នកខ្ចីឱ្យធ្វើការសងដោយកំណត់ "អំឡុងពេលសមរម្យ" បាន (មាត្រា ៥៩៤ កថាខណ្ឌទី ២)។ តើអំឡុងពេលសមរម្យមានរយៈពេលប៉ុន្មាន? វាពុំមានមាត្រាណាមួយ នៅក្នុងក្រមរដ្ឋប្បវេណីដែលចែងអំពីការកំណត់អំឡុងពេលសមរម្យក្នុងការដាស់តឿននេះទេ ហេតុនេះការកំណត់អំឡុងពេលសមរម្យនេះ គឺជាអំឡុងពេលដែលត្រូវការចាំបាច់សម្រាប់អ្នកខ្ចីក្នុងការរៀបចំ និង សងនូវវត្ថុ ក្រោយពីបានទទួលនូវការដាស់តឿនពីអ្នកឱ្យខ្ចី។ វាត្រូវបានសម្រេចដោយធ្វើការពិចារណាទៅលើខ្លឹមសារនៃកិច្ចសន្យា ឬ ចំនួន និង ប្រភេទនៃវត្ថុដែលបានខ្ចី។

ចំពោះ **ការខ្ចីបរិភោគដែលគ្មានការប្រាក់** អ្នកខ្ចីអាចធ្វើការសងវត្ថុទៅអ្នកឱ្យខ្ចីវិញ នៅពេលណាក៏បាន (មាត្រា ៥៩៤ កថាខណ្ឌទី ៣)។ ប៉ុន្តែមានសំណួរមួយលើកឡើងថា នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលគ្មានការប្រាក់ តើអ្នកខ្ចីអាចសងវត្ថុទៅអ្នកឱ្យខ្ចីវិញ មុនពេលកំណត់សងបានដែរ ឬ ទេ? គេអាចយល់បានថា អ្នកខ្ចីមិនអាចសងវត្ថុ នៅមុនកាលបរិច្ឆេទសងបានទេ ព្រោះភាគីត្រូវធ្វើតាមការព្រមព្រៀងប្រសិនបើមាន។ ជាការពិត ប្រសិនបើអ្នកឱ្យខ្ចី យល់ព្រមជាមួយនឹងការសងមុនពេលកំណត់នោះ អ្នកខ្ចីអាចសងវត្ថុនៅមុនកាលបរិច្ឆេទនៃការសង ព្រោះពួកគេបានកំណត់នូវកាលបរិច្ឆេទថ្មីមួយ។

ចំពោះ **ការខ្ចីបរិភោគដែលមានការប្រាក់** អ្នកខ្ចីអាចសងវត្ថុនៅមុនកាលបរិច្ឆេទសងដែលបានកំណត់ដោយកិច្ចសន្យាបាន។ ប៉ុន្តែ នៅក្នុងករណីដែលធ្វើឱ្យមានការខូចខាតដល់អ្នកឱ្យខ្ចី ដោយសារការសងនោះអ្នកខ្ចីត្រូវសងសំណងនៃការខូចខាត (មាត្រា ៥៩៤ កថាខណ្ឌទី ៤)។ ហើយវាគឺជាបញ្ហា ថាតើការប្រាក់ដែលត្រូវបានគណនារហូតដល់កាលបរិច្ឆេទនៃការសង ត្រូវបានគេរាប់បញ្ចូលទៅក្នុងការខូចខាតដែលមានចែងនៅក្នុងមាត្រា ៥៩៤ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២។ ឧទាហរណ៍ ប្រសិនបើអ្នកខ្ចី **ខ** បានខ្ចីប្រាក់ ២០.០០០ ដុល្លារ ដោយមានការប្រាក់ ២០០ ដុល្លារ ក្នុង ១ ខែ (សន្មតថា អត្រាការប្រាក់នេះមិនផ្ទុយនឹងច្បាប់ទេ)។ ការប្រាក់នេះគឺជាចំនួនដ៏ច្រើនសម្រាប់អ្នកឱ្យខ្ចី **ក** ហើយ **ក** បានរំពឹងទុកថា នឹងទទួលបានការប្រាក់យ៉ាងច្រើនពី **ខ**។ ក៏ប៉ុន្តែ **ខ** បានសងប្រាក់ នោះ ១ ឆ្នាំ មុនកាលបរិច្ឆេទសង ព្រោះគាត់មិនចង់ខាតបង់ការប្រាក់ច្រើន ហើយគាត់អាចមានលទ្ធភាពក្នុងការសង។ ចំណុចនេះបានធ្វើឱ្យ **ក** បាត់បង់នូវប្រាក់ដែលរំពឹងថានឹងបានទទួល។ នៅក្នុងករណីនេះ តើ **ខ** ត្រូវបង់ការប្រាក់ ២.៤០០ ដុល្លារ (២០០ ដុល្លារ x ១២ ខែ) ដែល **ក** បានរំពឹងទុកថានឹងបានទទួលដែរ ឬ ទេ? ចំណុចនេះ វាអាស្រ័យទៅលើការអនុវត្តក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែ នៅក្នុងការអនុវត្តនៅប្រទេសជប៉ុន ការប្រាក់មិនត្រូវបានគេចាត់ទុកថាជាការខូចខាតនោះទេ។ ព្រោះការប្រាក់ត្រូវបានចាត់ទុកថាជាតម្លៃថ្នូរនៅក្នុងការប្រើប្រាក់ ២០.០០០ ដុល្លារ។ ដូច្នេះ **ខ** មិនត្រូវបង់ការប្រាក់ ២.៤០០ ដុល្លារ នោះទេ ទោះបីជាគាត់បានសងមុន ១ ឆ្នាំ ក៏ដោយ ព្រោះ **ក** អាចប្រើប្រាក់

២០.០០០ ដុល្លារ នៅមុន ១ ឆ្នាំ ដែរ។ គាត់អាចផ្តល់ប្រាក់នេះទៅឱ្យបុគ្គលដទៃទៀតខ្ចីបាន ហើយអាចទទួលបានការប្រាក់។ ដូច្នេះ នៅក្នុងការអនុវត្តនៅប្រទេសជប៉ុន ការប្រាក់មិនត្រូវបានចាត់ទុកថាជាការខូចខាតទេ។

#### ៤.១.២. ទីកន្លែងនៃការសង

ភាគី អាចព្រមព្រៀងគ្នាក្នុងការកំណត់ អំពីទីកន្លែងជាក់លាក់ណាមួយ ដើម្បីធ្វើការសង ប៉ុន្តែប្រសិនបើភាគី មិនបានព្រមព្រៀងគ្នាកំណត់ អំពីទីកន្លែងនៃការសងទេ នោះទីកន្លែងនៃការសង គឺត្រូវធ្វើឡើងនៅលំនៅដ្ឋានរបស់អ្នកឱ្យខ្ចី (មាត្រា ៥៩៥)។ នេះ គឺជាសេចក្តីបកស្រាយ មាត្រា ៤៤៥ វាក្យខណ្ឌទី ២។

#### ៤.១.៣. ករណីដែលអ្នកខ្ចីមិនអាចសងវត្ថុបាន

ជាទូទៅ អ្នកខ្ចីមានកាតព្វកិច្ចត្រូវបង់ប្រាក់ដែលជាតម្លៃវត្ថុដែលបានខ្ចី នៅកាលបរិច្ឆេទនៃការសងនៅពេលវេលា និង ទីកន្លែង ដែលត្រូវសង ក្នុងករណីដែលអ្នកខ្ចីពុំអាចសងនូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួនស្មើគ្នាបាន (មាត្រា ៥៩២ កថាខណ្ឌទី ១)។ ឧទាហរណ៍ **ក** បានខ្ចី ត្រីសណ្តាយពី **ខ** ចំនួន ១០ គីឡូក្រាម ដោយមាន ឬ គ្មានកំណត់អឡុងពេលនៃការសង។ នៅពេលដែលត្រូវសង **ក** មិនបានសងត្រីសណ្តាយដែលមានប្រភេទ និង គុណភាព ស្មើនឹងត្រីសណ្តាយដែលបានទទួល ចំនួន ១០ គីឡូក្រាម ទៅ **ខ** វិញទេ ប៉ុន្តែ **ក** បែរជាសងប្រាក់ ១០ ម៉ឺនរៀល ទៅ **ខ** វិញ (សន្មតថាត្រីសណ្តាយ ១ គីឡូក្រាម មានតម្លៃ ១ ម៉ឺនរៀល)។ ក្នុងករណីនេះ **ខ** ត្រូវទទួលយកការសងរបស់ **ក** ។

### ៤.២. កាតព្វកិច្ចបង់ការប្រាក់

អ្នកខ្ចីមានកាតព្វកិច្ចត្រូវតែបង់ការប្រាក់ទៅអ្នកឱ្យខ្ចី ចំពោះកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់ ហើយការប្រាក់នេះទៀតសោត អ្នកខ្ចី ត្រូវបង់ដោយយោងទៅតាមប្រភេទនៃការប្រាក់ដែលកំណត់ដោយច្បាប់ ឬ ការប្រាក់ដែលកំណត់តាមកិច្ចសន្យា (មាត្រា ៥៩១ កថាខណ្ឌទី ២)។

## ៥. ការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់

### ៥.១. គោលគំនិត

ការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់នេះ គឺជាការខ្ចីបរិភោគមួយប្រភេទដែលគូភាគីបានព្រមព្រៀងគ្នាបង្កើតនូវសិទ្ធិលើបំណុល ដែលជាការប្រាក់ក្រៅពីប្រាក់ដើម។

**ការប្រាក់** ត្រូវបានគេឱ្យនិយមន័យថា ជាចំនួនទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលត្រូវបង់ទៅឱ្យតាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតម្លៃតបចំពោះការប្រើប្រាស់ប្រាក់ ឬ វត្ថុ ដែលត្រូវបានប្រគល់ទៅឱ្យអ្នកខ្ចី ហើយដែលត្រូវគណនា ដោយយកចំនួនទឹកប្រាក់ ឬ វត្ថុដែលបានខ្ចី មកគុណនឹងអត្រាការប្រាក់ ដែលត្រូវបានកំណត់ (មាត្រា ៥៨៣ កថាខណ្ឌទី ១)។ ឧទាហរណ៍ **ខ** ខ្ចីប្រាក់ពី **ក** ចំនួន ១០០ ដុល្លារ ជាមួយនឹងការប្រាក់ ២ ភាគរយ ក្នុងមួយខែ។ នៅក្នុងករណីនេះការប្រាក់ដែលត្រូវបង់ គឺ ១០០ x 0.0២ = ២ ដុល្លារ ក្នុងមួយខែ។

**ប្រាក់ដើម ឬ វត្ថុដើម** គឺជាប្រាក់ ឬ វត្ថុ ដែលបានខ្ចី និង ត្រូវបានប្រគល់ទៅឱ្យអ្នកខ្ចី។ យោងតាមឧទាហរណ៍ខាងលើប្រាក់ដើម គឺប្រាក់ ១០០ ដុល្លារ ដែល **ក** បានឱ្យ **ខ** ខ្ចី។

ការប្រាក់ គឺជាផលស៊ីវិល (មាត្រា ១២៧)។ ប្រសិនបើ សិទ្ធិលើបំណុលនៃប្រាក់ដើមត្រូវបានផ្ទេរទៅឱ្យបុគ្គលផ្សេងទៀត នោះសិទ្ធិលើបំណុលនៃការប្រាក់ក៏ត្រូវបានផ្ទេរផងដែរ និង ទាំងអ្នកឱ្យខ្ចីមុន និង អ្នកឱ្យខ្ចីក្រោយ អាចទទួលបានការប្រាក់ សមាមាត្រទៅនឹងអំឡុងពេលដែលមានសិទ្ធិទទួល ដោយគណនាតាមចំនួនថ្ងៃ (មាត្រា ១២៨ កថាខណ្ឌទី ២)។

គូភាគីអាចបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ តាមការព្រមព្រៀងបាន។ ក៏ប៉ុន្តែ សិទ្ធិលើបំណុលនៃការប្រាក់នេះ មិនមានអានុភាពឡើយ ប្រសិនបើមិនបានធ្វើជាលិខិតលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់អ្នកខ្ចីនោះទេ (មាត្រា ៥៨៣ កថាខណ្ឌទី ៣)។ មាត្រានេះ មានគោលបំណងក្នុងការការពារអ្នកខ្ចី។ ក៏ប៉ុន្តែ ទោះបីជាភាគី មិនធ្វើជាលិខិតលាយលក្ខណ៍អក្សរទាក់ទងនឹងការបង់ការប្រាក់ ហើយអ្នកខ្ចីបានស្ម័គ្រចិត្តបង់ការប្រាក់ ទោះបីជាបានដឹងការណ៍ ដែលសិទ្ធិលើបំណុលនៃការប្រាក់មិនមានអានុភាពទេនៅក្នុងករណីនេះ ក៏សិទ្ធិលើបំណុលនៃការប្រាក់ត្រូវមានអានុភាពត្រឹមកម្រិតដែលបានបង់។ នេះ គឺជាបង្ហាញនូវលទ្ធិដែលមានលក្ខណៈ ជារូបភាព។

## ៥.២. អត្រាការប្រាក់

យោងតាមមាត្រា ៥៨៤ អត្រាការប្រាក់ត្រូវបានបែងចែកជាពីរប្រភេទ គឺអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់នៅក្នុងកិច្ចសន្យា។

### ៥.២.១. អត្រាការប្រាក់ដែលកំណត់ដោយច្បាប់

នៅក្នុងក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ឆ្នាំ ១៩៨៩ មាត្រា ៥៩ បានកំណត់អំពីអត្រាការប្រាក់ នៅក្នុងកិច្ចសន្យាខ្ចី មិនឱ្យលើសពី ៥ ភាគរយ ក្នុងមួយឆ្នាំឡើយ ប៉ុន្តែដោយយល់ឃើញថា ការកំណត់កម្រិតនៃការប្រាក់បែបនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យជំនួញឯកជន និង សេដ្ឋកិច្ចជាតិ ពីព្រោះយោងតាមស្ថានភាពសង្គមបច្ចុប្បន្ន អត្រាការប្រាក់ត្រឹមកម្រិតនេះ គឺមានកម្រិតទាបពេក ដែលធ្វើឱ្យអ្នកឱ្យខ្ចីមិនហ៊ានផ្តល់ប្រាក់កម្ចី ដោយខ្លួនទទួលបានការប្រាក់ទាបហួសហេតុ និង ប្រឈមមុខជាមួយនឹងហានិភ័យខ្ពស់។ ដើម្បីជាការបំពេញនូវការខ្វះខាតនៅក្នុងច្បាប់ចាស់ ក្រមរដ្ឋប្បវេណី បានបើកឱ្យមានការយកការប្រាក់ ដោយផ្អែកលើឆន្ទៈរបស់គូភាគី ឬ តាមច្បាប់កំណត់ នៅពេលដែលគូភាគីនៃកិច្ចសន្យាខ្ចីបរិភោគមិនបាននិយាយគ្នា។

ប្រសិនបើ គូភាគី បានព្រមព្រៀងគ្នា បង់ការប្រាក់ ប៉ុន្តែ មិនបានកំណត់អំពីអត្រាការប្រាក់ទេ នោះ អត្រាការប្រាក់ ដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ពិសេស ត្រូវយកមកអនុវត្ត (មាត្រា ៥៨៤ កថាខណ្ឌទី ២)។

ក្រមរដ្ឋប្បវេណី បានបញ្ញត្តថាអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ គឺ ៥ ភាគរយ ក្នុង ១ ឆ្នាំ (មាត្រា ៣១៨)។ ហើយគេអាចបញ្ញត្តនូវអត្រាការប្រាក់ផ្សេងពីនេះ ដោយច្បាប់ពិសេស។

### ៥.២.២. អត្រាការប្រាក់នៅក្នុងកិច្ចសន្យា

អត្រាការប្រាក់នៅក្នុងកិច្ចសន្យា គឺជាអត្រាការប្រាក់ដែលបានកំណត់ ដោយផ្អែកតាមការព្រមព្រៀងរបស់គូភាគីនៅក្នុងកិច្ចសន្យាខ្ចីបរិភោគ។

ដូចបានលើកឡើងខាងលើ ដោយសារតែស្ថានភាពសង្គមមានការអភិវឌ្ឍន៍ និង ទំនើបកម្មរបស់ច្បាប់បានអនុញ្ញាតឱ្យបុគ្គលឯកជន អាចធ្វើការកំណត់នូវអត្រាការប្រាក់តាមការព្រមព្រៀងនៅក្នុងកិច្ចសន្យា។

អត្រាការប្រាក់ដែលបានព្រមព្រៀងដោយគូភាគី អាចខ្ពស់ជាងអត្រាការប្រាក់ ដែលកំណត់ដោយច្បាប់ ប៉ុន្តែមិនអាចខ្ពស់ជាងអត្រាការប្រាក់ដែលបានកម្រិតនោះទេ (មាត្រា ៥៨៥ កថាខណ្ឌទី ២)។ អត្រាការប្រាក់ដែលត្រូវបានកម្រិត គឺសំដៅទៅលើអត្រាការប្រាក់អតិបរមាដែលអាចកំណត់បានដោយស្របច្បាប់ តាមការព្រមព្រៀងរបស់គូភាគីដែលកំណត់ដោយច្បាប់ និង បទដ្ឋានគតិយុត្តិផ្សេងទៀត។ អត្រាការប្រាក់ដែលត្រូវបានកម្រិតនឹងត្រូវបានកំណត់នៅក្នុងចន្លោះពី ១០ ភាគរយ ដល់ ៣០ ភាគរយ ក្នុង ១ ឆ្នាំ និងត្រូវបានបញ្ញត្តដោយប្រកាសរួមគ្នារវាងក្រសួងយុត្តិធម៌ និង ធនាគារជាតិនៃកម្ពុជា។

ដោយផ្អែកទៅលើ មាត្រា ៥៨៥ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ១ ប្រសិនបើអ្នកខ្ចីបានសងរួចរាល់នូវការប្រាក់ ប៉ុន្តែការប្រាក់នោះ លើសពីការប្រាក់ដែលត្រូវបានកម្រិត នោះប្រាក់ដែលបានបង់លើសក្នុងនាមជាការប្រាក់ត្រូវបានចាត់ទុកថាជាការកាត់បំណុលទៅលើប្រាក់ដើម។ ឧទាហរណ៍ អត្រាការប្រាក់ដែលត្រូវបានកម្រិត ត្រូវបានបញ្ញត្តដោយច្បាប់ចំនួន ២០ ភាគរយ ក្នុង ១ ឆ្នាំ ប៉ុន្តែ **ក** បានខ្ចីប្រាក់ **ខ** ចំនួន ១០០០ ដុល្លារ ក្នុងរយៈពេល ៥ ឆ្នាំ ដោយមានអត្រាការប្រាក់ ៤០ ភាគរយ ក្នុង ១ ឆ្នាំ។ **ខ** បានបង់ការប្រាក់ ៤០០ ដុល្លារ ជារៀងរាល់ឆ្នាំ។ នៅក្នុងករណីនេះ ២០០ ដុល្លារ គឺជាការប្រាក់ដែលត្រូវបានកម្រិត ក្នុង រយៈពេល ១ ឆ្នាំ ដែលត្រូវបានគណនា ដោយយោងទៅលើអត្រាការប្រាក់ ដែលត្រូវបានកម្រិត។ ដូច្នេះ ប្រាក់ ២០០ ដុល្លារ (៤០០ - ២០០) ត្រូវយកទៅកាត់បំណុលលើប្រាក់ដើម។ បន្ទាប់មក ប្រាក់ដើមនៅក្នុង ឆ្នាំទី ២ គឺ ៨០០ ដុល្លារ (១.០០០ - ២០០) ហើយការប្រាក់ដែលត្រូវបានកម្រិត គឺ ១៦០ ដុល្លារ (៨០០ x 0,២)។ ដូច្នេះ ប្រាក់ដើមនឹងត្រូវបានកាត់បន្ថយ ទោះបីជាអ្នកខ្ចីបានសងតែការប្រាក់ នៅក្នុងករណីដែលអ្នកខ្ចីបានបង់ប្រាក់ដែលលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិត។

ជាងនេះទៅទៀត ប្រសិនបើបានកាត់បំណុលទៅលើប្រាក់ដើម ចំពោះផ្នែកដែលលើសពីការកម្រិតហើយ តែនៅមានសេសសល់ទៀត អ្នកឱ្យខ្ចីត្រូវសងទៅឱ្យអ្នកខ្ចី ដោយភ្ជាប់ជាមួយនូវប្រាក់សំណងនៃការខូចខាត។ ហើយការខូចខាតនេះត្រូវគណនាដោយអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដោយគិតចាប់ពីថ្ងៃបង់ការប្រាក់លើសនោះរហូតដល់ថ្ងៃដែលបានសង (មាត្រា ៥៨៥ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២)។ ឧទាហរណ៍ **ក** បានឱ្យ **ខ** ខ្ចី ប្រាក់ ចំនួន ១.០០០ ដុល្លារ ដោយមានការប្រាក់ ៨០ ភាគរយ ក្នុងមួយឆ្នាំ ទោះបីជាអាត្រាការប្រាក់ដែលត្រូវបានកម្រិត គឺ ២០ ភាគរយ ហើយ **ខ** បានបង់ការប្រាក់អស់រយៈពេល ២ ឆ្នាំ ហើយ។ នៅក្នុងករណីនេះប្រាក់ដើមត្រូវសងអស់ហើយនៅមានសេសសល់ថែមទៀតផង។

(ក) ឆ្នាំទី ១

១.០០០ ដុល្លារ (ប្រាក់ដើម) x ០,៨ (អត្រាការប្រាក់ក្នុងកិច្ចសន្យា) = ៨០០ ដុល្លារ

១.០០០ ដុល្លារ (ប្រាក់ដើម) x ០,២ (អត្រាការប្រាក់ដែលត្រូវបានកម្រិត) = ២០០ ដុល្លារ

៨០០ ដុល្លារ - ២០០ ដុល្លារ = ៦០០ ដុល្លារ (ការប្រាក់ដែលលើស = ចំនួនដែលត្រូវកាត់បំណុលលើប្រាក់ដើម)

(ខ) ឆ្នាំទី ២

១.០០០ ដុល្លារ - ៦០០ ដុល្លារ = ៤០០ ដុល្លារ (ប្រាក់ដើម នៅក្នុងឆ្នាំទី ២)

៤០០ ដុល្លារ x ០,២ = ៨០ ដុល្លារ (ការប្រាក់ដែលត្រូវបានកម្រិត នៅក្នុងឆ្នាំទី ២)

៨០០ ដុល្លារ - ៨០ ដុល្លារ = ៧២០ ដុល្លារ (ការប្រាក់ដែលលើស = ចំនួនដែលត្រូវកាត់បំណុលលើប្រាក់ដើម)

៤០០ ដុល្លារ - ៧២០ ដុល្លារ = - ៣២០ ដុល្លារ (នៅសេសសល់)

នៅក្នុងករណីនេះ អ្នកឱ្យខ្ចី ត្រូវសងប្រាក់ ៣២០ ដុល្លារ ដោយរាប់បញ្ចូលទាំងការប្រាក់ដែលកំណត់ដោយច្បាប់ គិតចាប់ពីថ្ងៃបង់ដែលត្រូវចាត់ទុកថាជាការខូចខាត។

### ៥.២.៣. ការការពារអ្នកខ្ចី

នៅក្នុងករណីនៃការខ្ចីបរិភោគដោយមានការប្រាក់អ្នកឱ្យខ្ចី ដូចជា អ្នកឱ្យខ្ចីដែលមានគោលបំណងអាក្រក់តែងតែព្យាយាមគេចវេស ឬ ទាញយកផលចំណេញពីច្បាប់ ទោះបីជាច្បាប់បានបញ្ញត្តនូវការកម្រិតលើការប្រាក់ក៏ដោយ។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានចែងនូវបញ្ញត្តិចំនួនពីរដើម្បីការពារអ្នកខ្ចី។

#### ក. ការកែប្រែប្រាក់ដើម

ក្នុងករណីដែលចំនួនប្រាក់ដើមលើកិច្ចសន្យា ខុសគ្នាពីចំនួនទឹកប្រាក់នៃវត្ថុ ដែលអ្នកឱ្យខ្ចី បានប្រគល់ដោយជាក់ស្តែង ចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចី បានប្រគល់ដោយជាក់ស្តែងទៅឱ្យអ្នកខ្ចី ត្រូវចាត់ទុកថា ជាចំនួនប្រាក់ដើម (មាត្រា ៥៨៥ កថាខណ្ឌទី ៥)។

ឧទាហរណ៍ **ក** និង **ខ** បានបង្កើតកិច្ចព្រមព្រៀងគ្នាថា **ក** ត្រូវឱ្យ **ខ** ខ្ចីប្រាក់ចំនួន ១.០០០ ដុល្លារ ក្នុងរយៈពេល ៥ ឆ្នាំ ដោយមានអត្រាការប្រាក់ ២០ ភាគរយ ក្នុង ១ ឆ្នាំ (សូមគិតថា អត្រាការប្រាក់នេះ មិនលើសអត្រាការប្រាក់ ដែលត្រូវបានកម្រិត) ប៉ុន្តែ **ក** ប្រគល់ប្រាក់តែ ២០០ ដុល្លារ ទេ ព្រោះ **ក** ព្យាយាមកាត់ប្រាក់ ៨០០ ដុល្លារ ពីប្រាក់ដើម ដែលជាការប្រាក់ ក្នុងរយៈពេល ៤ ឆ្នាំ។ នៅក្នុងករណីនេះ **ខ** មិនអាចប្រើប្រាក់ ១.០០០ ដុល្លារ ទេ ប៉ុន្តែ គាត់បែរជាជាប់បំណុល ចំនួន ១.០០០ ដុល្លារ ទៅវិញ។ ដើម្បីចៀសវាងនូវបញ្ហានេះ មាត្រា ៥៨៥ កថាខណ្ឌទី ៥ បានកំណត់ថាចំនួនទឹកប្រាក់នៃវត្ថុដែលត្រូវបានប្រគល់ដោយជាក់ស្តែង ត្រូវចាត់ទុកថាជាចំនួនប្រាក់ដើម។ ប្រសិនបើអនុវត្តមាត្រានេះ នោះប្រាក់ដើម គឺ ២០០ ដុល្លារ នៅក្នុងករណីខាងលើ។

**ខ. ត្រូវចាត់ទុកជាការប្រាក់**

ប្រាក់ និង វត្ថុផ្សេងទៀត ដែលអ្នកឱ្យខ្ចីបានទទួលក្រៅពីប្រាក់ដើម ទាក់ទងទៅនឹងកិច្ចសន្យាខ្ចីបរិភោគ ត្រូវបានចាត់ទុកថាជាការប្រាក់ ( មាត្រា ៥៨៥ កថាខណ្ឌទី ៦) ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសោហ៊ុយនៃការធ្វើកិច្ចសន្យា និង សោហ៊ុយនៃការសង ( មាត្រា ៥៨៥ កថាខណ្ឌទី ៦ វាក្យខណ្ឌទី ២) ។

ទោះបីជាច្បាប់ដាក់កម្រិតលើអត្រាការប្រាក់ ឬ កាត់នូវការប្រាក់ ក៏អ្នកឱ្យខ្ចីដែលមានគោលបំណងអាក្រក់ តែងតែព្យាយាមទទួលយកប្រាក់ពីអ្នកខ្ចី ដូចជា ប្រាក់កម្រៃជើងសារ កម្រៃស៊ើបអង្កេត ជាអាទិ៍។ ដូច្នេះ ក្រមរដ្ឋប្បវេណី បញ្ញត្តថា ប្រសិនបើអ្នកឱ្យខ្ចីបានទទួលប្រាក់ ឬ វត្ថុផ្សេងទៀត ក្រៅពីប្រាក់ដើម នោះវាត្រូវបានចាត់ទុកថាជាការប្រាក់ ។

## ៥.៣. ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយច្បាប់

### ៥.៣.១. ពេលវេលានៃការបង់ការប្រាក់

គោលការណ៍ : ការប្រាក់ត្រូវបង់នៅរៀងរាល់ពេលដែលពេលវេលា រយៈពេល ១ ឆ្នាំ បានកន្លងផុត គិតចាប់ពីពេលដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ។ នេះពុំមែនជាបញ្ញត្តិអនុវត្តដោយបង្ខំនោះទេ មានន័យថាអាចព្រមព្រៀងផ្សេងពីនេះបាន ។

ករណីលើកលែង : ភាគី អាចព្រមព្រៀងផ្សេងដូចជា បង់រៀងរាល់ខែ បង់កន្លះឆ្នាំម្តង ជាដើម ។ ក៏ប៉ុន្តែ ប្រសិនបើត្រូវសងវត្ថុនោះ ក្នុងអំឡុងពេលវេលា ១ ឆ្នាំ គិតចាប់ពីពេលដែលបានប្រគល់ នោះការប្រាក់ត្រូវបង់នៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនោះ ( មាត្រា ៥៨៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

### ៥.៣.២. ការប្រាក់សមាសដែលកំណត់ដោយច្បាប់

ប្រសិនបើ អ្នកខ្ចី មិនបានបង់ការប្រាក់ សម្រាប់រយៈពេលចាប់ពី ១ ឆ្នាំឡើងទៅ ហើយគាត់នៅតែមិនបង់ការប្រាក់ទៀត ទោះបីជាមានការដាស់តឿនពីអ្នកឱ្យខ្ចីក៏ដោយ នោះអ្នកឱ្យខ្ចីអាចបូកបញ្ចូលការប្រាក់ដែលមិនបានបង់នោះ ចូលទៅក្នុងប្រាក់ដើមបាន ។

ឧទាហរណ៍ **ក** បានឱ្យ **ខ** ខ្ចីប្រាក់ចំនួន ១.០០០ ដុល្លារ ដោយមានការប្រាក់ ២០ ភាគរយ ក្នុង ១ ឆ្នាំ (សូមគិតថាអត្រាការប្រាក់នេះ គឺជាអត្រាការប្រាក់ដែលត្រូវបានកម្រិត) ប៉ុន្តែ **ខ** មិនបានបង់ការប្រាក់ ១ ឆ្នាំ កន្លះ ទោះបីជា **ក** បានដាស់តឿនឱ្យ **ខ** បង់ការប្រាក់ក៏ដោយ ។ នៅក្នុងករណីនេះ **ក** អាចបូកបញ្ចូលការប្រាក់ ដែលមិនទាន់បានបង់ ( ១.០០០ ដុល្លារ x ០.២ = ២០០ ដុល្លារ) ទៅក្នុងប្រាក់ដើមបាន ។ ដូច្នេះ ប្រាក់ដើមសម្រាប់ឆ្នាំទី ២ គឺ ១.២០០ ដុល្លារ ។

ទន្ទឹមនឹងនេះ គូភាគីអាចបង្កើតកិច្ចព្រមព្រៀងដែលកំណត់ថាការប្រាក់ដែលមិនបានបង់ត្រូវបូកបញ្ចូលទៅក្នុងប្រាក់ដើម លើសពី ១ ដង ក្នុង ១ ឆ្នាំ ។ ឧទាហរណ៍ នៅក្នុងករណីខាងលើ **ក** និង **ខ** បានព្រមព្រៀងគ្នាថា **ក** អាចបូកបញ្ចូលនូវការប្រាក់ដែលមិនបានបង់ ជារៀងរាល់កន្លះឆ្នាំម្តង ។ នៅក្នុងករណីនេះ ចំណុចដែលគួរឱ្យកត់ សម្គាល់

គឺថា ប្រសិនបើ ខ មិនបានបង់ការប្រាក់នៅក្នុងរយៈពេល ១ ឆ្នាំ ការប្រាក់នឹងមានចំនួនច្រើនជាងចំនួននៃអត្រាការប្រាក់ដែលត្រូវបានកម្រិត ។

ការប្រាក់ដែលត្រូវបានកម្រិតនៅក្នុងរយៈពេល ១ ឆ្នាំ : ១.០០០ ដុល្លារ x ០,២ = ២០០ ដុល្លារ (ក)

ការប្រាក់ដែលត្រូវបានកម្រិតនៅក្នុងរយៈពេល កន្លះឆ្នាំ : ២០០ ដុល្លារ / ២ = ១០០ ដុល្លារ

ប្រាក់ដើមសម្រាប់រយៈពេលកន្លះឆ្នាំបន្ទាប់ : ១.០០០ ដុល្លារ + ១០០ ដុល្លារ = ១.១០០ ដុល្លារ

ការប្រាក់អតិបរមាសម្រាប់រយៈពេលកន្លះឆ្នាំបន្ទាប់ : ១.១០០ ដុល្លារ x ០,២/២ = ១១០ ដុល្លារ

ការប្រាក់សរុប សម្រាប់រយៈពេល ១ ឆ្នាំ : ១០០ ដុល្លារ + ១១០ ដុល្លារ = ២១០ ដុល្លារ (ខ)

នៅក្នុងករណីនេះ ការប្រាក់សរុបសម្រាប់រយៈពេល ១ ឆ្នាំ (ខ) គឺច្រើនជាងចំនួនអត្រាការប្រាក់ដែលត្រូវបានកម្រិត (ក) ទៀត ។ សេចក្តីសន្និដ្ឋាននេះ វានឹងផ្ទុយពីច្បាប់ ត្រង់ចំណុច អត្រាការប្រាក់ដែលត្រូវបានកម្រិត ។

ដូច្នេះ គេអាចចាត់ទុកថាចំនួនដែលលើសការប្រាក់អតិបរមា (១០ ដុល្លារ នៅក្នុងករណីនេះ) ត្រូវទុកជាមោឃៈ ព្រោះវាគឺជាការគេចវេសពីការកម្រិតនៃអត្រាការប្រាក់ដោយច្បាប់ ប្រសិនបើអ្នកឱ្យខ្ចីអាចទទួលបានការប្រាក់ដែលច្រើនជាង អត្រាការប្រាក់ដែលត្រូវបានកំណត់ តាមការជាក់ស្តែងដោយធ្វើការបូកបញ្ចូលនូវការប្រាក់ទៅក្នុងប្រាក់ដើម ។

# ផ្នែកទី ៥

## អាណត្តិ

### ១. គោលគំនិត

តើអាណត្តិជាអ្វី? មាត្រា ៦៣៧ និយមន័យអាណត្តិ

"អាណត្តិ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា អាណត្តិទាយក ប្រគល់សិទ្ធិអំណាចឱ្យភាគីម្ខាងទៀត ហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក"។

**តើពាក្យថា កិច្ចការ នៅក្នុងអាណត្តិ មានន័យយ៉ាងដូចម្តេច?**

ពាក្យកិច្ចការ នៅក្នុងអាណត្តិ រាប់បញ្ចូលគ្រប់កិច្ចការដូចជា ការធ្វើកិច្ចសន្យា អន្តរការីនៃអចលនវត្ថុ សិទ្ធិក្នុងការធ្វើបណ្តឹង ជាអាទិ៍។ ឧទាហរណ៍ **ក** ផ្តល់សិទ្ធិតំណាងឱ្យ **ខ** ទៅចុះកិច្ចសន្យាទិញរថយន្ត ជាមួយ **គ**។ នេះ គឺជាឧទាហរណ៍នៃការបង្កើតកិច្ចសន្យាអាណត្តិ។ ទន្ទឹមនឹងនេះ ប្រសិនបើ **ក** ស្នើសុំឱ្យ **ខ** ស្វែងរកអ្នកទិញដីរបស់ **ក** ហើយ **ខ** បានធ្វើជាឈ្មួញកណ្តាលរវាង **ក** និង អ្នកទិញ **គ**។ នេះ គឺជាឧទាហរណ៍នៃអន្តរការីនៃអចលនវត្ថុ។ នៅក្នុងករណីដែល **ក** បានផ្តល់សិទ្ធិអំណាចក្នុងការធ្វើបណ្តឹងឱ្យទៅ **ខ** ដែលជាមេធាវី នេះក៏ជាអាណត្តិដែរ។ ហើយម្យ៉ាងទៀត ទំនាក់ទំនងរវាងគ្រូពេទ្យ និង អ្នកជំងឺ ក៏ចាត់ទុកជាអាណត្តិដែរ។ ប៉ុន្តែ ការរក្សាទុកវត្ថុ មិនរាប់បញ្ចូលទៅក្នុងកិច្ចការនៅក្នុងអាណត្តិទេ គឺស្ថិតនៅក្នុងកិច្ចការបញ្ញើ។

**តើអាណត្តិ និង កិច្ចសន្យាបញ្ញើ មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច? (មាត្រា ៦៣៧)**

អាណត្តិ ត្រូវបានគេផ្តល់និយមន័យថាជា "កិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា អាណត្តិទាយក ប្រគល់សិទ្ធិអំណាចឱ្យភាគីម្ខាងទៀតហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក" (មាត្រា ៦៣៧)។ ផ្ទុយមកវិញ **មាត្រា ៦៦៩** បានផ្តល់និយមន័យ បញ្ញើថា "កិច្ចសន្យាដែលភាគីម្ខាង ជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើពីភាគីម្ខាងទៀត ជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលដែលបានកំណត់ ហើយ នៅក្រោយពេលដែលអំឡុងពេលរក្សាទុកនោះត្រូវបានបញ្ចប់ ត្រូវសងវត្ថុដដែលនោះទៅអ្នកផ្ញើវិញ។"

ដូចនេះ អាណត្តិ និង កិច្ចសន្យាបញ្ញើ មានទំនាក់ទំនងគ្នា ត្រង់ជាកិច្ចសន្យាផ្តល់សេវាដូចគ្នា ហើយ ខុសគ្នាត្រង់ បញ្ញើ គឺអ្នកទទួលបញ្ញើត្រូវផ្តល់នោះ គឺ "ការរក្សាទុកវត្ថុដែលបានទទួល" តែប៉ុណ្ណោះ។ ចំណែកឯ សេវាត្រូវផ្តល់នៅក្នុងកិច្ចការអាណត្តិ គឺការចាត់ចែងរាល់គ្រប់កិច្ចការ ដូចជាការធ្វើកិច្ចសន្យា អន្តរការីនៃអចលនវត្ថុ សិទ្ធិអំណាចក្នុងការធ្វើបណ្តឹង ជាអាទិ៍។ នៅក្នុងន័យនេះ គេអាចនិយាយបានថា បញ្ញើ គឺជាប្រភេទមួយនៃកិច្ចសន្យាអាណត្តិ ប៉ុន្តែ វា ត្រូវបានបញ្ញត្តដោយឡែក នៅក្នុងក្រមរដ្ឋប្បវេណី។

**តើអាណត្តិ គឺជាកិច្ចសន្យា ដែលយកតម្លៃថ្នូរ ឬ កិច្ចសន្យាមិនយកតម្លៃថ្នូរ ឬ ជាប្រភេទកិច្ចសន្យាទាំងពីរ?**

មាត្រា ៦៣៨ ចែងថា *អាណត្តិ អាចធ្វើដោយយកកម្រៃ ឬ មិនយកកម្រៃបាន។ បើពុំបានបងាញឆន្ទៈអំពីការធ្វើដោយយកកម្រៃទេ ត្រូវសន្មតថាជាអាណត្តិដោយមិនយកកម្រៃ។* នេះបង្ហាញថា អាណត្តិ អាចជាកិច្ចសន្យាដែលយកតម្លៃថ្នូរ ឬ កិច្ចសន្យាមិនយកតម្លៃថ្នូរក្នុងន័យនេះ ហើយ អាណត្តិ គឺជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ បើភាគី មិនបានបង្កើតការព្រមព្រៀងទាក់ទងនឹងការយកតម្លៃថ្នូរនោះទេ។ ការបង្ហាញឆន្ទៈនេះ អាចធ្វើដោយជាក់លាក់ ឬ ដោយតុណ្ហីភាព ជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ នៅពេលបង្កើតកិច្ចសន្យា។

## ២. លក្ខខណ្ឌ

អាណត្តិ គឺជាកិច្ចសន្យាមានការព្រមព្រៀង ដែលមិនតម្រូវឱ្យធ្វើជាលាយលក្ខណ៍អក្សរ សម្រាប់ជាលក្ខខណ្ឌសុពលភាពនៃអាណត្តិនោះទេ។ វាមានន័យថា ឱ្យតែមានឆន្ទៈត្រូវគ្នារវាងភាគីទាំងសងខាង នោះអាណត្តិនឹងត្រូវបានបង្កើតឡើង។ ឬនិយាយម្យ៉ាងទៀត នៅក្នុងករណីដែលអាណត្តិទាយកប្រគល់សិទ្ធិអំណាចឱ្យអាណត្តិគាហក ធ្វើកិច្ចការណាមួយ ហើយ អាណត្តិគាហក ឯកភាពទទួលធ្វើកិច្ចសន្យានោះ។ ឧទាហរណ៍ **ក** មានដី និង ផ្ទះមួយកន្លែង ហើយគាត់ចង់លក់ដី និង ផ្ទះនេះ។ ដូច្នេះគាត់បានបង្ហាញឆន្ទៈថា គាត់នឹងផ្តល់សិទ្ធិអំណាចឱ្យទៅ **ខ** ដើម្បីចុះកិច្ចសន្យាលក់ទិញ។ នៅពេលដែល **ខ** ទទួលយកសំណើនេះ នោះ អាណត្តិ ត្រូវបានបង្កើតឡើង។

## ៣. ទំនាក់ទំនងជាមួយនឹងការតំណាង

តើអាណត្តិ និង ការតំណាង មានភាពខុសគ្នាយ៉ាងដូចម្តេច? មាត្រា ៦៣៧ បានផ្តល់និយមន័យ អាណត្តិថា "អាណត្តិ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា អាណត្តិទាយក ប្រគល់សិទ្ធិអំណាចឱ្យភាគីម្ខាងទៀត ហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក"។ ផ្ទុយទៅវិញ មាត្រា ៣៦៤ បានចែងថា "ការតំណាង សំដៅទៅលើទំនាក់ទំនងគតិយុត្ត ដែលអានុភាពនៃកិច្ចសន្យា ត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែល អ្នកតំណាង ធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀត ដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះ គឺធ្វើសម្រាប់ម្ចាស់សិទ្ធិ ក្នុងទំហំនៃសិទ្ធិតំណាង"។ ប្រព័ន្ធទាំងពីរនេះ គឺមានលក្ខណៈស្រដៀងគ្នា ប៉ុន្តែ វា មានភាពខុសគ្នាត្រង់ចំនុច ដូចខាងក្រោមនេះ :

**អាណត្តិ**

**ក** ⟶ **ខ** (អាណត្តិគាហក)

(អាណ្តតិទាយក) ↓

**គ** (ភាគីម្ខាងទៀត)

- នៅពេល **ខ** បានចុះកិច្ចសន្យាលក់ទិញរថយន្តជាមួយនឹង **គ** នោះ **ខ** មិនចាំបាច់ប្រាប់ទៅ **គ** ថា ខ្លួនធ្វើសម្រាប់ **ក** ឡើយ

**ការតំណាង**

**ក** ⟶ **ខ** (អ្នកតំណាង)

(ម្ចាស់សិទ្ធិ) ↓

**គ** (ភាគីម្ខាងទៀត)

- នៅពេល **ខ** ចុះកិច្ចសន្យាទិញលក់រថយន្តជាមួយ **គ** ក្នុងនាមជាអ្នកតំណាងរបស់ **ក** នោះ **ខ** ចាំបាច់ត្រូវប្រាប់ **គ** ថា ខ្លួន ធ្វើក្នុងនាម **ក**

| | |
|---|---|
| -អានុភាពនៃកិច្ចសន្យាទិញលក់រវាងយន្តរវាង ខ និង គ មិនមានអានុភាពផ្ទាល់រវាង ក និង គ ឡើយ<br>-ករណីយកិច្ច និង សិទ្ធិ កើតមានរវាង ខ និង គ | - អានុភាពនៃកិច្ចសន្យាទិញលក់ ដែល ខ បានចុះជាមួយ គ គឺមានអានុភាពមានផ្ទាល់ទៅលើ ក<br>- ករណីយកិច្ច និង សិទ្ធិ កើតមានផ្ទាល់រវាង ក និង គ |

តើការតំណាង មានប្រភពមកពីអាណត្តិតែមួយគត់មែនទេ?

សិទ្ធិតំណាង មិនមែនមានប្រភពមកពីអាណត្តិតែមួយគត់នោះទេ វា អាចកើតចេញពីកិច្ចសន្យាការងារ និង កិច្ចសន្យាម៉ៅការ ជាអាទិ៍។

## ៤. កាតព្វកិច្ចរបស់អាណត្តិគាហក

### ៤.១. ករណីយកិច្ចប្រុងប្រយ័ត្ន

ករណីយកិច្ចនេះ មានចែងនៅក្នុង មាត្រា ៦៤០។

ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក ត្រូវបានបញ្ញត្តថា :

អាណត្តិគាហក មានករណីយកិច្ចចាត់ចែងកិច្ចការអាណត្តិដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត ដោយផ្អែកតាមអត្ថន័យនៃអាណត្តិ។ ប៉ុន្តែបញ្ញត្តិនេះ មិនរារាំងចំពោះការបន្ថយករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក តាមការព្រមព្រៀងរបស់ភាគីឡើយ។

កិច្ចសន្យាអាណត្តិ ត្រូវបានបង្កើតឡើងដោយផ្អែកទៅលើទំនាក់ទំនងដែលជឿទុកចិត្តរវាងអាណត្តិទាយក និង អាណត្តិគាហក ហើយអាណត្តិទាយក បានជឿជាក់ថាអាណត្តិគាហក មានការប៉ិនប្រសប់ជាពិសេស ឬ ចំនេះដឹងជំនាញណាមួយ។

កម្រិតនៃទំហំករណីយកិច្ចនេះ ត្រូវបានសម្រេចដោយធ្វើការពិចារណាទៅលើអ្វី ដែលជននៅក្នុងឋានៈនេះ ត្រូវយកចិត្តទុកដាក់ និង ត្រូវយកចិត្តទុកដាក់ដោយវិធីណា ជាទូទៅ។ ឧទាហរណ៍ បុគ្គលដែលមានជំនាញ និង ចំណេះដឹងខ្ពស់ ដូចជា គ្រូពេទ្យ ត្រូវមានករណីយកិច្ចខ្ពស់ក្នុងការចាត់ចែងកិច្ចការ។ ផ្ទុយទៅវិញ កម្រិតស្តង់ដានៃករណីយកិច្ចប្រុងប្រយ័ត្នរបស់បុគ្គល ដែលស្ម័គ្រចិត្តក្នុងការមើលថែទាំកូនរបស់អ្នកជិតខាង គឺត្រូវមានតិចជាងអ្នកជំនាញ។

ទន្ទឹមនឹងនេះ កម្រិត ឬ លំដាប់នៃករណីយកិច្ចប្រុងប្រយ័ត្ននេះ កើតមានមិនថាជា អាណត្តិដោយយកកម្រៃ ឬ អាណត្តិដោយមិនយកកម្រៃ ដោយសារអាណត្តិ ត្រូវបានបង្កើតឡើងដោយឈរលើគោលការណ៍ជឿ ទុកចិត្តគ្នារវាងភាគីអាណត្តិទាយក និង អាណត្តិគាហក។ ប៉ុន្តែ កម្រិតនៃករណីយកិច្ចនេះ អាចត្រូវបានបន្ថយអាស្រ័យទៅតាមការព្រមព្រៀងរបស់ភាគី ( មាត្រា ៦៤០ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)។

ផលវិបាកនៅក្នុងករណីដែលអាណត្តិគាហកបំពានករណីយកិច្ចនេះ

ដោយផ្អែកលើ មាត្រា ៦៤០ កថាខណ្ឌទី ២ ចែងថា "ក្នុងករណី ដែលអាណត្តិគាហក ធ្វើផ្ទុយនឹងករណីយ

កិច្ចប្រុងប្រយ័ត្ននៃកថាខណ្ឌទី ១ ខាងលើនេះ ហើយបានធ្វើឱ្យមានការខូចខាតដល់អាណត្តិទាយក អាណត្តិទាយកអាចទាមទារសំណងនៃការខូចខាតនោះពីអាណត្តិគាហកបាន។ នៅក្នុងករណីនេះ ប្រសិនបើជាអាណត្តិដោយមិនយកកម្រៃ តុលាការអាចបន្ថយចំនួនទឹកប្រាក់សំណងនៃការខូចខាតបាន"។ អត្ថន័យនៃមាត្រានេះ គឺថាអាណត្តិគាហកត្រូវទទួលខុសត្រូវ ដោយយោងតាមគោលការណ៍ទូទៅអំពីការមិនអនុវត្តកាតព្វកិច្ច ដែលតម្រូវឱ្យភាគីដែលបង្កព្យសនកម្មដល់ភាគីម្ខាងទៀត ត្រូវបង់នូវសំណងការខូចខាត នៅក្នុងករណីដែលការបំពាននោះបង្កជាការខូចខាតមកពីការមិនគោរពតាមខសន្យា។ នៅក្នុងករណីនេះទាយកអាចទាមទារឱ្យរំលាយកិច្ចសន្យា និង/ឬ សំណងនៃការខូចខាត។ ប៉ុន្តែបើជា អាណត្តិដែលមិនយកកម្រៃ នោះ តុលាការ អាចបន្ថយចំនួនទឹកប្រាក់សំណងការខូចខាតព្រោះអាណត្តិគាហកមិនបានទទួលផលប្រយោជន៍អ្វីពីកិច្ចសន្យាអាណត្តិនេះទេ។ ដោយឈរលើទស្សនៈសមភាពរវាងភាគី បញ្ញត្តិនេះបានកំណត់អំពីភាពខុសគ្នារវាង អាណត្តិដោយយកកម្រៃ និង អាណត្តិ ដោយមិនយកកម្រៃ។

### ៤.២. ករណីយកិច្ចរាយការណ៍

*បើមានការទាមទាររបស់អាណត្តិទាយក អាណត្តិគាហក ត្រូវរាយការណ៍អំពីស្ថានភាពនៃកិច្ចការចាត់ចែងអាណត្តិ ទោះបីនៅពេលណាក៏ដោយ* (មាត្រា ៦៤១)។

ករណីយកិច្ចនេះ គឺទាញចេញពីករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ។ វាមានសារៈសំខាន់ណាស់សម្រាប់អាណត្តិគាហក ក្នុងការដឹងអំពីដំណើរការនៃកិច្ចការរបស់ខ្លួនដល់កម្រិតណា ដូច្នេះគាត់អាចឆ្លើយតបទៅនឹងបញ្ហានេះ។

តើអាណត្តិគាហក ត្រូវរាយការណ៍អំពីស្ថានភាពដែរ ឬ ទេ ទោះបីជាអាណត្តិទាយកមិនបានស្នើសុំក៏ដោយ? ទោះបីជាអាណត្តិទាយក មិនបានស្នើសុំឱ្យរាយការណ៍ក៏ដោយ គេអាចចាត់ទុកថាអាណត្តិគាហកត្រូវរាយការណ៍អំពីស្ថានភាពបច្ចុប្បន្ននៃការចាត់ចែងនោះ នៅពេលដែលមានភាពចាំបាច់សម្រាប់អាណត្តិទាយក។

ផលវិបាកនៅក្នុងករណីដែលអាណត្តិគាហកបំពានករណីយកិច្ចនេះពីព្រោះតែការរាយការណ៍ ជាករណីយកិច្ចតាមផ្លូវច្បាប់ យោងតាមគោលការណ៍ទូទៅអំពីការមិនអនុវត្តកតព្វកិច្ច នោះអាណត្តិទាយកអាចរំលាយកិច្ចសន្យា ហើយគាត់អាចទាមទារសំណងនៅក្នុងករណីដែលមានការខូចខាតកើតមានឡើង។

### ៤.៣. កាតព្វកិច្ចប្រគល់

មាត្រា ៦៤២ ចែងថា "អាណត្តិគាហក ត្រូវប្រគល់ប្រាក់ និងវត្ថុផ្សេងៗទៀតដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិឱ្យទៅអាណត្តិទាយក។ អាណត្តិគាហក ក៏ត្រូវប្រគល់ផលដែលប្រមូលបានឱ្យទៅអាណត្តិទាយកផងដែរ " (កថាខណ្ឌទី ១) និង "សិទ្ធិដែលអាណត្តិគាហកបានធ្វើលទ្ធកម្មក្នុងនាមរបស់ខ្លួន ដើម្បីអាណត្តិទាយក គឺត្រូវផ្ទេរឱ្យទៅអាណត្តិទាយក" (កថាខណ្ឌទី ២)។

នេះក៏ដោយសារ អាណត្តិទាយកប្រគល់សិទ្ធិអំណាចឱ្យអាណត្តិគាហកចាត់ចែងការងារ ដើម្បីប្រយោជន៍ខ្លួន ដូចនេះនៅពេលអាណត្តិគាហកបញ្ចប់ការងារ គាត់ត្រូវប្រគល់ប្រាក់ និង វត្ថុផ្សេងៗទៀត ដែលទទួលបានតាម

ការចាត់ចែងកិច្ចការអាណត្តិឱ្យទៅអាណត្តិទាយក។ លើសពីនេះ អាណត្តិគាហកក៏ត្រូវប្រគល់ផលដែលប្រមូលបានឱ្យទៅអាណត្តិទាយកផងដែរ។

ឧទាហរណ៍ នៅក្នុងករណីដែល ក បានផ្តល់អាណត្តិឱ្យទៅ ខ ដើម្បីទិញរថយន្តថ្មីមួយពី គ ដែលជាកាតព្វកិច្ចរបស់ខ្លួន ហើយទទួលបានសិទ្ធិទាមទារឱ្យ គ ប្រគល់រថយន្ត។ ប្រសិនបើគ្មានការព្រមព្រៀងពិសេស ខ ត្រូវប្រគល់រថយន្តនោះទៅឱ្យ ក នៅក្នុងករណីដែលខ្លួនបានទទួលរថយន្តនោះរួចហើយ ឬ ក៏ផ្ទេរនូវសិទ្ធិទាមទារឱ្យ គ ប្រគល់រថយន្ត នៅក្នុងករណីដែល គាត់មិនទាន់បានទទួលរថយន្តនោះនៅឡើយទេ។

## ៩.៤. ការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតដែលបានប្រើប្រាក់

ដោយសារអាណត្តិគាហក បានទទួលប្រាក់ពីតតិយជន ទាក់ទងនឹងការចាត់ចែងកិច្ចការអាណត្តិ ប្រាក់នោះត្រូវប្រគល់ទៅឱ្យអាណត្តិទាយក។ ដូច្នេះ មាត្រា ៦៤៣ នេះចែងអំពីករណីយកិច្ចសងការខូចខាតទៅឱ្យអាណត្តិទាយក ប្រសិនបើអាណត្តិគាហកបានប្រើប្រាស់ប្រាក់នោះ សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន។ អាណត្តិគាហកមានករណីយកិច្ចសងការខូចខាត មិនមែនត្រឹមតែការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវប៉ុណ្ណោះទេ គឺថែមទាំងការខូចខាតដទៃទៀតផ្សេងៗទៀតផងដែរ ប្រសិនបើមាន។

នេះ គឺជាទណ្ឌកម្មចំពោះការបំពានករណីយកិច្ច ដែលមានចែងនៅក្នុងមាត្រា ៦៤២។ ទន្ទឹមនឹងនេះ មាត្រានេះ ត្រូវអនុវត្តតែក្នុងករណីដែលអាណត្តិគាហកបានប្រើប្រាក់នោះ។ ប្រសិនបើអាណត្តិគាហកបានប្រើនូវវត្ថុដទៃទៀត ក្រៅពីប្រាក់ដែលត្រូវបានប្រគល់ទៅឱ្យអាណត្តិទាយក នោះគាត់ត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ឬ អំពើអនីត្យានុកូល។

នៅក្នុងករណីនៃអាណត្តិដែលគ្មានសិទ្ធិតំណាង អាណត្តិគាហកត្រូវធ្វើលទ្ធកម្មលើកម្មសិទ្ធិលើប្រាក់ដែលគាត់បានទទួលទាក់ទងនឹងកិច្ចសន្យាអាណត្តិ។ អាណត្តិគាហកមិនចាំបាច់សងប្រាក់ (ក្រដាស់ប្រាក់) ដដែល ដែលគាត់បានទទួលនោះទេ ព្រោះប្រាក់មានលទ្ធភាពដែលអាចជំនួសបាន។ ដូច្នេះទោះបីជាអាណត្តិគាហកបានប្រើប្រាក់ដែលគាត់បានទទួលទាក់ទងនឹងកិច្ចសន្យាអាណត្តិ នោះវាមិនចាំបាច់ក្លាយជាករណី "ប្រើប្រាក់សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួននោះទេ"។ គេអាចសម្រេចដោយធ្វើការពិចារណាទៅលើលក្ខខណ្ឌនៃសមត្ថភាពខាងហិរញ្ញវត្ថុរបស់អាណត្តិគាហក ហើយ ថាតើអាណត្តិគាហក អាចសងនូវចំនួនទឹកប្រាក់ដែលគាត់បានប្រើនោះដែរ ឬ ទេ។

## ៩.៥. ករណីយកិច្ចសង្គ្រោះបន្ទាន់នៅក្រោយពេលបញ្ចប់អាណត្តិ

ជាទូទៅ ប្រសិនបើអាណត្តិ ត្រូវបានរំលាយ កាតព្វកិច្ច និង សិទ្ធិទាមទារទាំងអស់ ត្រូវរលត់។ ក៏ប៉ុន្តែ វា មានសារៈសំខាន់ក្នុងការការពារផលប្រយោជន៍របស់អាណត្តិទាយក ពីការរងការខូចខាត ដែលកើតឡើងដោយសារហេតុការណ៍ណាមួយ ដែលមិនអាចព្យាករបាន ក្នុងអំឡុងពេលចាប់ពីការបញ្ចប់អាណត្តិ រហូតដល់អាណត្តិទាយក ឬ អ្នកផ្សេងទៀត អាចចាត់ចែងកិច្ចការទាំងអស់ ដែលត្រូវបានប្រគល់ទៅឱ្យអាណត្តិគាហក។

ឧទាហរណ៍ នៅក្នុងករណីមរណភាពរបស់អាណត្តិគាហក កិច្ចសន្យាអាណត្តិ ត្រូវបានបញ្ចប់ ( មាត្រា ៦៤៩ កថាខណ្ឌទី ១ ចំណុច ក) ប៉ុន្តែអាណត្តិទាយក អាចមានការលំបាកក្នុងការចាត់ចែងការងាររបស់ខ្លួន។ ដូច្នេះ សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិគាហក ត្រូវធ្វើការចាត់ចែងកិច្ចការអាណត្តិនោះ រហូតដល់ពេលដែលអាណត្តិទាយក សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិទាយក អាចចាត់ចែងកិច្ចការនោះបាន។

ទន្ទឹមនឹងនេះដែរ ឧទាហរណ៍ ក បានផ្តល់អាណត្តិឱ្យទៅ ខ ដើម្បីប្រមូលបំណុលដែលជាប្រាក់ពី គ ហើយ កិច្ចសន្យាអាណត្តិត្រូវបានបញ្ចប់ គ្រាន់តែនៅមុនពេលនៃការបញ្ចប់នូវអាជ្ញាយុកាលនៃការរំលត់។ នៅក្នុងករណីនេះ ដោយផ្អែកទៅលើមាត្រា ៦៥០ ខ ត្រូវចាត់វិធានការណ៍ដើម្បីបង្ការនូវការបញ្ចប់នូវអាជ្ញាយុកាលនៃការរំលត់ ដូចជាធ្វើការទាមទារឱ្យសងប្រាក់ ការផ្អាកអាជ្ញាយុកាលនៃការរំលត់ ( មាត្រា ៤៨៩) ជាអាទិ៍ ទោះជានៅក្រោយការបញ្ចប់អាណត្តិក៏ដោយ។

## ៥. កាតព្វកិច្ចរបស់អាណត្តិទាយក

### ៥.១. ករណីយកិច្ចបង់កម្រៃ

បើគ្មានការកំណត់ពិសេស ដែលត្រូវឱ្យអាណត្តិទាយកបង់កម្រៃមកអាណត្តិគាហក នាំឱ្យអាណត្តិគាហកពុំអាចទាមទារបានឡើយ ព្រោះថាជាគោលការណ៍កិច្ចសន្យាអាណត្តិមិនយកកម្រៃ។ ប៉ុន្តែមាត្រា ៦៤៤ ចែងអំពីសិទ្ធិទាមទារកម្រៃ ក្នុងករណីនៃអាណត្តិដោយយកកម្រៃ និង កំណត់អំពីគោលការណ៍នៃការបង់តាមក្រោយ។

នៅក្នុងករណីនៃអាណត្តិដែលយកកម្រៃ អាណត្តិទាយកមិនចាំបាច់បង់ប្រាក់កម្រៃនៅមុនពេលអនុវត្តកាតព្វកិច្ចដែលត្រូវតាមអាណត្តិនោះទេ ( មាត្រា ៦៤៤ កថាខណ្ឌទី ២)។

នៅពេលដែលបានកំណត់អំឡុងពេលនៃការបង់កម្រៃនាំឱ្យអាណត្តិគាហក អាចទាមទារកម្រៃតាមអំឡុងពេលនោះបាន។

ប៉ុន្តែប្រសិនបើ អាណត្តិត្រូវបានបញ្ចប់ការអនុវត្តនៅពាក់កណ្តាលទី ដោយគ្មានកំហុសរបស់អាណត្តិគាហកទេ នាំឱ្យអាណត្តិគាហកអាចទាមទារកម្រៃបាន តាមសមាមាត្រនៃភាគដែលបានអនុវត្តរួចហើយ ( មាត្រា ៦៤៤ កថាខណ្ឌទី ៣) ព្រោះគោលបំណងនៃអាណត្តិ គឺមិនមែនសម្រេចការងារដែលបានកំណត់នោះទេ ដែលមានលក្ខណៈផ្សេងគ្នាពីកិច្ចសន្យាម៉ៅការ។

### ៥.២. ករណីយកិច្ចបង់សោហ៊ុយជាមុន

ដោយផ្អែកទៅលើមាត្រា ៦៤៥ ប្រសិនបើមានតម្រូវការចាំបាច់លើសោហ៊ុយសម្រាប់ការចាត់ចែងកិច្ចការអាណត្តិ អាណត្តិទាយក ត្រូវបង់សោហ៊ុយនោះជាមុន តាមការទាមទាររបស់អាណត្តិគាហក។ ករណីយកិច្ចរបស់អាណត្តិទាយកក្នុងការបង់សោហ៊ុយនេះ គឺមានគោលបំណងធ្វើឱ្យការចាត់ចែងកិច្ចការអាណត្តិ មានដំណើរការ

យ៉ាងរលូន។ ទោះបីជាអាណត្តិដោយយកកម្រៃ ឬ មិនយកកម្រៃក៏ដោយ ប្រសិនបើអាណត្តិគាហកទាមទារសោហ៊ុយ ក៏អាណត្តិទាយក ត្រូវបង់សោហ៊ុយនោះជាមុនដែរ។

ឧទាហរណ៍ **ក** បានផ្តល់អាណត្តិដែលគ្មានសិទ្ធិតំណាងឱ្យទៅ **ខ** ដើម្បីទិញរថយន្ត។ **ខ** ត្រូវបង់ថ្លៃទិញរថយន្តឱ្យទៅ **គ**។ នៅពេលខ្លះវាគឺជាបន្ទុកដ៏ធ្ងន់ធ្ងរសម្រាប់ **ខ** ដូច្នេះ **ខ** ត្រូវទាមទារឱ្យ **ក** បង់ថ្លៃទិញរថយន្តនោះមកឱ្យខ្លួន ដើម្បីឱ្យខ្លួនអាចបង់ប្រាក់នោះទៅឱ្យ **គ** បាន។

### ៥.៣. ករណីយកិច្ចសងវិញនូវសោហ៊ុយដែលបានចំណាយ

ដោយយោងទៅលើមាត្រា ៦៤៥ អាណត្តិគាហកអាចទាមទារសោហ៊ុយចាំបាច់ជាមុនបាន។ ផ្ទុយទៅវិញ ទោះបីជា អាណត្តិគាហកមិនបានស្នើសុំឱ្យអាណត្តិទាយកបង់សោហ៊ុយជាមុននោះទេ នោះអាណត្តិគាហកក៏មានសិទ្ធិទាមទារឱ្យសងនូវសោហ៊ុយដែលបានចំណាយ និង ការប្រាក់ពីអាណត្តិទាយកបានដែរ ប្រសិនបើគាត់បានចំណាយសោហ៊ុយផ្ទាល់ខ្លួន សម្រាប់ចាត់ចែងកិច្ចការអាណត្តិដែលជាប្រយោជន៍របស់អាណត្តិទាយក។

ទន្ទឹមនឹងនេះ ប្រសិនបើបានអនុវត្តកាតព្វកិច្ចចាំបាច់ដើម្បីចាត់ចែងកិច្ចការអាណត្តិ នោះអាណត្តិគាហកអាចទាមទារឱ្យអាណត្តិទាយកសងកាតព្វកិច្ចជំនួសខ្លួនបាន។

នៅក្នុងអាណត្តិដែលគ្មានសិទ្ធិតំណាង អានុភាពនៃសកម្មភាពរបស់អាណត្តិគាហក ត្រូវមានចំពោះអាណត្តិគាហកខ្លួនឯងផ្ទាល់។ ក៏ប៉ុន្តែ មាត្រានេះបានចែងថាក្នុងករណីដែលអាណត្តិគាហកទទួលបន្ទុកកាតព្វកិច្ចចាំបាច់នោះ គាត់អាចទាមទារឱ្យអាណត្តិទាយក អនុវត្តកាតព្វកិច្ចនោះជំនួសខ្លួន។

ឧទាហរណ៍ **ក** បានផ្តល់អាណត្តិឱ្យទៅ **ខ** ដើម្បីទិញរថយន្ត ក្នុងតម្លៃ ៥.០០០ ដុល្លារ។ ប្រសិនបើ **ខ** បានចុះកិច្ចសន្យាទិញរថយន្តនៅក្នុងតម្លៃ ១.០០០ ដុល្លារ ជាមួយនឹង **គ** នោះ **ខ** អាចទាមទារឱ្យ **ក** បង់ប្រាក់ ១.០០០ ដុល្លារ ទៅឱ្យ **គ**។ ប្រសិនបើ កាតព្វកិច្ច មិនទាន់ដល់ពេលកំណត់នៅឡើយទេ នោះ **ខ** អាចទាមទារឱ្យ **ក** ដាក់ប្រាតិភោគដែលសមរម្យបាន។

**ក** ⟶ **ខ** ទិញឡាន

↓ ៥.០០០ ដុល្លារ

**គ**

- ពេល **ខ** បានបង់ ៥.០០០ ដុល្លារ ទៅឱ្យ **គ**

  ⟹ **ខ** អាចទាមទារឱ្យ **ក** បង់ប្រាក់បាន។

- ប្រសិនបើ **ខ** មិនទាន់បានបង់ប្រាក់

  ⟹ **ខ** អាចទាមទារឱ្យ **ក** បង់ជំនួសខ្លួន ៥.០០០ ដុល្លារ ទៅឱ្យ **គ** តែម្តង ឬ ដាក់នូវប្រាតិភោគដែលសមរម្យ។

### ៥.៤. ករណីយកិច្ចសងសំណងនៃការខូចខាត

ដោយផ្អែកលើ មាត្រា ៦៤៦ កថាខណ្ឌទី ៣ ប្រសិនបើ បានទទួលការខូចខាតដែលមិនមែនបណ្តាលមកពីនោះពីអាណត្តិទាយកបាន។ នេះ គឺជាការទទួលខុសត្រូវដាច់ខាតរបស់អាណត្តិទាយក ព្រោះ អាណត្តិទាយកត្រូវ ទទួលបន្ទុកហានិភ័យនៃអាណត្តិ។ ក៏ប៉ុន្តែ ប្រសិនបើ ការខូចខាតនោះ កើតឡើងដោយចេតនា ឬ កំហុសរបស់តតិយជន ពេលនោះអាណត្តិគាហកអាចទាមទារសំណងចំពោះអាណត្តិទាយកបានត្រឹមតែកម្រិតដែលអាណត្តិគាហកមិនបានទទួលពីតតិយជនតែប៉ុណ្ណោះ។

ឧទាហរណ៍ **ក** បានផ្តល់អាណត្តិឱ្យទៅ **ខ** ដើម្បីមើលថែរក្សាកូនរបស់ **ក** ហើយ ឆ្កែដែលគ្មានម្ចាស់បានមកខាំក្មេងនោះ ហើយ **ខ** ព្យាយាមការពារកូននោះ ដែលបានធ្វើឱ្យគាត់រងរបួស។

**ក** ⟶ **ខ** (ឱ្យ **ខ** មើលថែទាំកូនរបស់ **ក**)

ឆ្កែខាំកូន **ក** ⟹ **ខ** ការពារកូន **ក** ពីឆ្កែខាំ ⟹ **ខ** រងរបួស ⟹ **ខ** អាចទាមទារសំណងពី **ក**

(ការទទួលខុសត្រូវដាច់ខាត)

ប្រសិនបើការខូចខាតបណ្តាលមកពីកំហុសរបស់តតិយជន នោះ **ខ** អាចទាមទារសំណងពី **ក** ត្រឹមកម្រិតដែល **ខ** មិនបានទទួលសំណងពីតតិយជននោះ។ ដូច្នេះ ឧទាហរណ៍ ប្រសិនបើ **គ** បានបង្ឆោតឆ្កែឱ្យខាំកូនរបស់ **ក** នាំឱ្យ **ខ** រងរបួស។ សោហ៊ុយព្យាបាលលើរបួសនេះ អស់ ១០០ ដុល្លារ។ ក៏ប៉ុន្តែ **គ** បានបង់ឱ្យ **ខ** តែ ២០ ដុល្លារទេ។ នៅក្នុងករណីនេះ **ខ** អាចទាមទារពី **ក** ៨០ ដុល្លារ បន្ថែមទៀត ព្រោះថា **ខ** បានរងរបួសដោយសារកិច្ចការពារអាណត្តិ ចំពោះ **ក**។

## ៦. ការរំលាយកិច្ចសន្យាអាណត្តិ

### ៦.១. មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ

មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ មានពីរប្រភេទ គឺការបញ្ចប់ដោយការរំលាយកិច្ចសន្យាអាណត្តិ និង ការបញ្ចប់ដោយផ្អែកលើក្រមរដ្ឋប្បវេណី។

#### ៦.១.១. ការបញ្ចប់ដោយសារការរំលាយកិច្ចសន្យាអាណត្តិដោយភាគី

ការរំលាយកិច្ចសន្យាអាណត្តិ អាចធ្វើឡើងពេលណាក៏បាន (ព្រោះជាបញ្ញត្តិពិសេស)។ ព្រោះកិច្ចសន្យាអាណត្តិ គឺពឹងផ្អែកលើទំនាក់ទំនងនៃការទុកចិត្តគ្នារវាងគូភាគី ប៉ុន្តែ ប្រសិនបើភាគីណាម្ខាងបានបាត់បង់ការទុកចិត្តទៅលើភាគីម្ខាងទៀត នោះពួកគេមិនអាចថែរក្សាទំនាក់ទំនងនេះបានទៀតទេ។ ដូច្នេះ ក្រមរដ្ឋប្បវេណីបានចែងថា ភាគីនីមួយៗ អាចរំលាយកិច្ចសន្យាអាណត្តិបាន ដោយមិនចាំបាច់មានហេតុផលសមរម្យនៅពេលណាក៏បាន (មាត្រា ៦៤៧)។

ក៏ប៉ុន្តែ ប្រសិនបើភាគីបានរំលាយអាណត្តិ នៅក្នុងអំឡុងពេលដែលធ្វើឱ្យខូចខាតដល់ភាគីម្ខាងទៀត ភាគីនោះត្រូវសងសំណងនៃការខូចខាតទៅភាគីម្ខាងទៀត។ ឧទាហរណ៍ អាណត្តិគាហករំលាយកិច្ចសន្យាអាណត្តិ នៅ

ពេលដែលអាណត្តិទាយកមិនអាចរកបានអាណត្តិគាហកថ្មីមួយទៀត នោះអាណត្តិគាហកត្រូវសងសំណងនៃការខូចខាត ប្រសិនបើមាន។ ទោះបីជាមូលហេតុនៃការរំលាយ គឺជាមូលហេតុដែលមិនអាចជៀសវាងបាន ឧទាហរណ៍ ដូចជា នៅក្នុងករណីដែលអាណត្តិគាហកមានជំងឺ ហើយមិនអាចបន្តកិច្ចការអាណត្តិបាន នោះអាណត្តិគាហកមិនចាំបាច់សង សំណងនៃការខូចខាតទេ។

### ៦.១.២. ការបញ្ចប់ដែលបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី

ក្រៅពីការរំលាយកិច្ចសន្យាអាណត្តិ ដែលមានចែងនៅក្នុងមាត្រា ៦៤៧ អាណត្តិ ត្រូវបានបញ្ចប់ ដោយ មូលហេតុដូចខាងក្រោម ( មាត្រា ៦៤៩ កថាខណ្ឌទី ១) :

- មរណភាពរបស់អាណត្តិទាយក ឬ អាណត្តិគាហក ( ចំណុច **ក**)
- ការប្រកាសក្ស័យធនរបស់អាណត្តិទាយក ឬ អាណត្តិគាហក ( ចំណុច **ខ**)
- ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភរបស់ អាណត្តិទាយក ( ចំណុច **គ**)
- ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភរបស់ អាណត្តិគាហក ( ចំណុច **ឃ**)
- អាណត្តិទាយក ឬ អាណត្តិគាហក ជានីតិបុគ្គលបានរលាយ ( ចំណុច **ង**)
- អាណត្តិទាយក ឬ អាណត្តិគាហក ជានីតិបុគ្គលបានរួមបញ្ចូលជាមួយនីតិបុគ្គលផ្សេង ( ចំណុច **ច**)
- មូលហេតុផ្សេងៗ ដែលបានកំណត់តាមការព្រមព្រៀងរបស់ភាគី ( ចំណុច **ឆ**)

មូលហេតុមួយចំនួន គឺមានលក្ខណៈជាន់គ្នាទៅនឹងមូលហេតុនៃការរលត់សិទ្ធិតំណាងដោយកិច្ចសន្យា ( មាត្រា ៣៦៨)

ទន្ទឹមនឹងនេះ ដោយសារបញ្ញត្តិខាងលើនេះមិនមែនជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ដូច្នេះភាគីអាចព្រម ព្រៀងគ្នាផ្សេងបាន។ វាមានន័យថាភាគីអាចសន្យាបានដែរថា ទោះបីជាមានមូលហេតុណាមួយក្នុងចំណោម មូលហេតុដែលមានកំណត់នៅក្នុងមាត្រា ៦៤៩ ក៏ដោយ ក៏អាណត្តិមិនបញ្ចប់ដែរ។ លើសពីនេះ ភាគីអាចលើកយក មូលហេតុផ្សេងក្រៅពីមូលហេតុដែលមានចែងក្នុងមាត្រា ៦៤៩ មកធ្វើជាមូលហេតុនៃការបញ្ចប់អាណត្តិបាន។

## ៦.២. អានុភាពនៃការរំលាយ

មាត្រា ៦៤៨ ចែងថាអានុភាពនៃការរំលាយនោះ កើតមានឡើងដោយឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ហើយ មិនមានអានុភាពប្រតិសកម្ម ដូចកិច្ចសន្យាជាបន្តផ្សេងទៀតទេ។ មូលហេតុដែលការរំលាយអាណត្តិមិនមានអានុភាព ប្រតិសកម្ម គឺថាទំនាក់ទំនងរវាងអាណត្តិទាយក អាណត្តិគាហក និង ភាគីម្ខាងទៀតអាចនឹងមានភាពស្មុគស្មាញ ប្រសិនបើ ការរំលាយ មានអានុភាពប្រតិសកម្មនៅក្នុងករណីនៃអាណត្តិ។

ដូច្នេះ នៅពេលកិច្ចសន្យាអាណត្តិត្រូវបានរំលាយ អាណត្តិគាហក ត្រូវប្រគល់ប្រាក់ ឬ វត្ថុ ដែលខ្លួនបានទទួល ទាក់ទងនឹងការចាត់ចែងកិច្ចការអាណត្តិទៅឱ្យអាណត្តិទាយក ហើយអាណត្តិទាយកត្រូវបង់កម្រៃ (នៅក្នុងករណីដែលមានការព្រមព្រៀងគ្នាពិសេស) ឬ សោហ៊ុយចាំបាច់ ទៅឱ្យអាណត្តិគាហក តាមសមាមាត្រនៃភាគដែលបានអនុវត្តរួចហើយ ។

លក្ខខណ្ឌតតាំងនៃការបញ្ចប់អាណត្តិ (៦៥១) មានគោលបំណងដើម្បីការពារភាគីនៃកិច្ចសន្យាអាណត្តិដែលមិនដឹងអំពីការបញ្ចប់អាណត្តិ ពីការខូចខាតដែលមិនអាចព្យាករបាន។ ដូច្នេះ ប្រសិនបើភាគីណាមួយដែលបានបញ្ចប់អាណត្តិ ដោយមិនបានជូនដំណឹងទៅភាគីម្ខាងទៀតទេ នោះគាត់មិនអាចលើកយកមូលហេតុនៃការបញ្ចប់អាណត្តិនេះមកតតាំងជាមួយនឹងភាគីម្ខាងទៀតបានឡើយ ។

ឧទាហរណ៍ **ក** បានផ្តល់អាណត្តិឱ្យ **ខ** ដើម្បីទិញរថយន្ត។ ក៏ប៉ុន្តែ **ក** ត្រូវបានប្រកាសក្ស័យធន ប៉ុន្តែ គាត់មិនបានជូនដំណឹងអំពីការណ៍នេះទៅ **ខ** ទេ។ **ខ** ដែលមិនបានដឹងអំពីការបញ្ចប់អាណត្តិនេះ បានចុះកិច្ចសន្យាជាមួយនឹង **គ**។ នៅក្នុងករណីនេះ **ក** មិនអាចលើកឡើងអំពីការបញ្ចប់អាណត្តិបានទេ ហើយកិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានសុពលភាព។

# ផ្នែកទី ៦

# កិច្ចសន្យាម៉ៅការ

## ១. គោលគំនិត

យោងតាមមាត្រា ៦៥២ កិច្ចសន្យាម៉ៅការ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថាអ្នកម៉ៅការ មានករណីយកិច្ចសម្រេចការងារដែលបានព្រមព្រៀង ហើយភាគីម្ខាងទៀតហៅថា ម្ចាស់ការមានករណីយកិច្ចផ្តល់កម្រៃចំពោះ លទ្ធផលនៃការងារដែលបានធ្វើនោះ ។

ទន្ទឹមនឹងនេះ កិច្ចសន្យាម៉ៅការ គឺជាកិច្ចសន្យាដែលយកតម្លៃថ្នូរ និង ជាកិច្ចសន្យាទ្វេភាគី ដែលគូភាគីនៃកិច្ចសន្យាត្រូវផ្តល់តាវកាលិកឱ្យគ្នាទៅវិញទៅមក ។

គួរកត់សម្គាល់ថា កិច្ចសន្យាម៉ៅការមានអត្ថន័យខុសគ្នានឹងកិច្ចសន្យាអាណត្តិ និងកិច្ចសន្យាការងារ ។ ភាពខុសគ្នាគឺមានដូចខាងក្រោម :

នៅក្នុងកិច្ចសន្យាការងារ ខ្លឹមសារនៃកិច្ចសន្យាគឺថា និយោជិត សន្យាថានឹងធ្វើពលកម្ម ហើយនិយោជកសន្យាថានឹងផ្តល់ប្រាក់ឈ្នួលទៅលើកិច្ចការពលកម្មនោះ ។ និយោជិតមិនចាំបាច់សម្រេចការងាររបស់ខ្លួនទេ ដែលជាលក្ខណៈខុសគ្នាទៅនឹងកិច្ចសន្យាម៉ៅការ ។

នៅក្នុងកិច្ចសន្យាអាណត្តិ អាណត្តិគាហក ត្រូវចាត់ចែងកិច្ចការដែលត្រូវបានផ្តល់អាណត្តិឱ្យដោយអាណត្តិទាយក ហើយអាណត្តិគាហកមិនចាំបាច់សម្រេចកិច្ចការនោះ ដែលនេះជាចំណុចខុសពីកិច្ចសន្យាម៉ៅការដែរ ។ ទន្ទឹមនឹងនេះ កិច្ចសន្យាអាណត្តិ គឺជាកិច្ចសន្យាមិនយកតម្លៃថ្នូរ ប្រសិនបើមិនមានការព្រមព្រៀងផ្សេងពីនេះ ។

## ២. លក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យាម៉ៅការ

កិច្ចសន្យាម៉ៅការ ពុំមានទាមទារលក្ខខណ្ឌពិសេសណាមួយទេ គឺឱ្យតែគូភាគីមានការព្រមព្រៀង ជាការគ្រប់គ្រាន់នឹងបង្កើតកិច្ចសន្យាបានហើយ ( មាត្រា ៣៣៦ កថាខណ្ឌទី ១) ។

## ៣. ភាតព្វកិច្ចរបស់អ្នកម៉ៅការ

### ៣.១. ករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈ

#### ៣.១.១. គោលគំនិត

យោងតាមមាត្រា ៦៥៤ កថាខណ្ឌទី ១ អ្នកម៉ៅការ មានករណីយកិច្ចសម្រេចការងារ ដោយគ្មានវិការៈចំពោះម្ចាស់ការ ។

វិការៈដែលមានចែងនៅក្នុងមាត្រា ៦៥៤ កថាខណ្ឌទី ២ និង ទី ៣ គឺ :

- ការងារពុំមានលក្ខណៈដូចបានព្រមព្រៀង

- ការងារពុំត្រឹមត្រូវតាមគោលដៅក្នុងការប្រើប្រាស់ដែលបានកំណត់នៅក្នុងកិច្ចសន្យា

- ការងារនោះមិនត្រឹមត្រូវក្នុងការប្រើប្រាស់ជាប្រក្រតី ប្រសិនបើការប្រើប្រាស់ជាក់លាក់ មិនត្រូវបានកំណត់ក្នុងកិច្ចសន្យា

- ការងារដែលបានធ្វើមិនគ្រប់ចំនួន ឬ

- អ្នកម៉ៅការបានធ្វើការផ្ទុយនឹងការបញ្ជា

ជាទូទៅ ខ្លឹមសារនៃកិច្ចសន្យាម៉ៅការ គឺសម្រេចការងារ ដែលមានលក្ខណៈជាក់លាក់។

ឧទាហរណ៍ ម្ចាស់ការឱ្យជាងគំនូរគូររូបរបស់ខ្លួន ដូចនេះគេមិនអាចនិយាយបានទេថាការងារ គឺអនុលោមទៅតាមលក្ខណៈដែលបានព្រមព្រៀង ប្រសិនបើគំនូរនោះមិនដូចនឹងម្ចាស់ការ។ ឧទាហរណ៍មួយទៀត គឺថាអ្នកម៉ៅការបានសង់អាគារ ដោយផ្អែកលើកិច្ចសន្យាថា ម្ចាស់ការនឹងប្រើប្រាស់អាគារនោះ សម្រាប់បើកជាភោជនីយដ្ឋាន ប៉ុន្តែអ្នកម៉ៅការមិនបានបំពាក់ប្រព័ន្ធបង្ហូរទឹកសំអុយចេញ។ នៅក្នុងករណីនេះ ការងារដែលបានសម្រេចរួចគឺមិនស្របទៅ នឹងការប្រើប្រាស់ ដែលបានសន្មតនៅក្នុងកិច្ចសន្យា។

ជាងនេះទៅទៀត ប្រសិនបើម្ចាស់ការ បានឱ្យកាត់ស្បែកជើងមួយគូរ ដោយមិនបានកំណត់ពីវិធី ដែលត្រូវប្រើប្រាស់ ហើយបន្ទាប់មកស្បែកជើងនោះបានរហែកជាពីរផ្នែក នៅក្រោយពេលដែលពាក់ដើរបានម្តង នោះគឺវាមិនឆ្លើយតបទៅនឹង "ប្រសិនបើការងារនេះ មិនត្រឹមត្រូវក្នុងការប្រើប្រាស់ជាប្រក្រតី"។

ឧទាហរណ៍នៃមាត្រា ៦៥៤ កថាខណ្ឌទី ៣ គឺថា អ្នកម៉ៅការ បានកាត់ស្បែកជើងសង្រែកមួយគូរ ដែលតាមពិតទៅម្ចាស់ការបានបញ្ជាគាត់ឱ្យកាត់ស្បែកជើងឃ្លុបមួយគូរ។ នៅក្នុងករណីនេះ ការកាត់ស្បែកជើងសង្រែកមួយគូរ គឺត្រូវបានធ្វើរួចរាល់ហើយ និង ម្ចាស់ការ អាចប្រើស្បែកជើងនេះបានទៀត ប៉ុន្តែ អ្នកម៉ៅការបានសម្រេចការងារ ដែលខុសពីបញ្ជា។

### ៣.១.២. ការទទួលខុសត្រូវរបស់អ្នកម៉ៅការ នៅក្នុងករណីដែលការងារមានវិការៈ

ក្នុងករណីដែលអ្នកម៉ៅការ បំពេញការងារដោយមានវិការៈ ម្ចាស់ការមានសិទ្ធិទាមទារឱ្យអ្នកម៉ៅការធ្វើការអនុវត្តឱ្យត្រឹមត្រូវតាមកិច្ចសន្យា ឬ ជ្រើសរើសវិធីណាមួយតាមការអនុញ្ញាតរបស់ក្រមរដ្ឋប្បវេណី។ សិទ្ធិទាមទារនេះត្រូវយកមកអនុវត្តនៅក្នុងអំឡុងពេល ១ឆ្នាំ ដែលត្រូវផ្តើមគណនាចាប់ពីពេលដែលម្ចាស់ការបានដឹង ឬគួរបានដឹងអំពីអត្ថិភាពនៃវិការៈនោះ (មាត្រា ៦៦១)។

ការរៀបរាប់ខាងលើនេះ មិនអាចឱ្យអ្នកម៉ៅការរួចផុតពីកាតព្វកិច្ចបានឡើយ ទោះបីជាមានកិច្ចសន្យាពិសេសអំពីការអនុគ្រោះ ឬ កម្រិតការទទួលខុសត្រូវក៏ដោយ ប្រសិនបើអ្នកម៉ៅការបានដឹងហើយតែបែរជាមិនបានរាយការណ៍ប្រាប់ម្ចាស់ការ (មាត្រា ៦៦២)។

### ក. ការទាមទារឱ្យអនុវត្តការងារពេញលេញរបស់ម្ចាស់ការ

យោងតាមមាត្រា ៦៥៥ បើរកឃើញថាការងារមានវិការៈ ម្ចាស់ការអាចទាមទារឱ្យអ្នកម៉ៅការបំពេញកិច្ចការរបស់ខ្លួនឱ្យបានពេញលេញ ដោយកំណត់អំឡុងពេលសមរម្យ ( មាត្រា ៦៥៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។

អ្នកម៉ៅការ អាចជ្រើសរើសឱ្យជួសជុលវិការៈនៃការងារនោះ ឬ អាចធ្វើការងារនោះសាជាថ្មីឡើងវិញ តាមការជ្រើសរើសបាន ( មាត្រា ៦៥៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ឧទាហរណ៍ ប្រសិនបើ អ្នកម៉ៅការ បានកាត់ស្បែកជើងឃ្លុបមួយគូរ តែតាមពិតទៅម្ចាស់ការបានបញ្ជាគាត់ឱ្យកាត់ស្បែកជើងស្បែកកវែង ដូច្នេះវាមានលក្ខណៈងាយស្រួល និង ចំណាយតិចសម្រាប់អ្នកម៉ៅការកាត់ស្បែកជើងនោះជាថ្មីម្តងទៀត ជៀសជាងជួសជុលឡើងវិញ។ នៅក្នុងករណីនេះ អ្នកម៉ៅការអាចជ្រើសរើសកាត់ស្បែកជើងនោះម្តងទៀត ។

ប្រសិនបើការអនុវត្តការងារពេញលេញ ត្រូវចំណាយសោហ៊ុយច្រើនហួសហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈ នោះអ្នកម៉ៅការអាចបដិសេធចំពោះការអនុវត្តការងារពេញលេញបាន (មាត្រា ៦៥៥ កថាខណ្ឌទី ២) ។ នៅក្នុងករណីនេះ ម្ចាស់ការមិនអាចទាមទារឱ្យសងចំណាយលើការជួសជុល នៅក្រោយការបញ្ចប់ការជួសជុលដោយខ្លួនឯង (មាត្រា ៦៥៦ កថាខណ្ឌទី ៤) និង មិនអាចទាមទារសំណងនៃការខូចខាត ( មាត្រា ៦៥៩ កថាខណ្ឌទី ២) ។ ដូច្នេះ ប្រសិនបើការអនុវត្តការងារពេញលេញ ចាំបាច់ចំណាយសោហ៊ុយច្រើនហួសហេតុ ប្រៀបធៀបនឹងទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈ នោះម្ចាស់ការត្រូវទទួលរងនូវហានិភ័យនេះ។ ប្រសិនបើម្ចាស់ការចង់ជៀសវាងនូវស្ថានភាពបែបនេះ គាត់ចាំបាច់ត្រូវបង្កើតកិច្ចព្រមព្រៀង ពិសេសជាមួយនឹងអ្នកម៉ៅការ ។

ជាងនេះទៅទៀត កម្មវត្ថុមានវិការៈ និង ចាំបាច់ត្រូវប្រគល់ត្រឡប់មកវិញ នោះអ្នកម៉ៅការអាចទាមទារឱ្យម្ចាស់ការ សងការងារ ដែលមានវិការៈមកឱ្យខ្លួនវិញ ( មាត្រា ៦៥៥ កថាខណ្ឌទី ៣) ។

### ខ. ការជួសជុលវិការៈដោយម្ចាស់ការ

ប្រសិនបើការងារមានវិការៈ ម្ចាស់ការចាំបាច់ដាស់តឿនឱ្យអនុវត្តការងារឱ្យពេញលេញ ដោយកំណត់អំឡុងពេលជាក់លាក់ជាមុនសិន។ ហើយបន្ទាប់មក ប្រសិនបើអ្នកម៉ៅការមិនបានអនុវត្តការងារឱ្យពេញលេញនោះទេ នៅក្នុងអំឡុងពេលនោះ ម្ចាស់ការអាចធ្វើការជួសជុលវិការៈនៃការងារដោយខ្លួនឯងផ្ទាល់ ហើយអាចទាមទារសោហ៊ុយចាំបាច់លើការជួសជុលវិការៈនោះវិញ ( មាត្រា ៦៥៦ កថាខណ្ឌទី ១) ។

ម្ចាស់ការ ក៏អាចជួសជុលវិការៈដោយខ្លួនឯង ហើយអាចទាមទារសោហ៊ុយដែលចាំបាច់ក្នុងការជួសជុលវិការៈ ក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញមិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញដោយអ្នកម៉ៅការ នឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវ ចំពោះម្ចាស់ការ ( មាត្រា ៦៥៦ កថាខណ្ឌទី ២) ។

ម្ចាស់ការអាចទាមទារឱ្យអ្នកម៉ៅការបង់សោហ៊ុយចាំបាច់លើការជួសជុលនេះជាមុនបាន នៅក្នុងករណីដែលម្ចាស់ការ អាចសម្រេចការងារដែលមានវិការៈនោះឱ្យបានពេញលេញ។

ក៏ប៉ុន្តែ នៅក្នុងករណីដែលអ្នកម៉ៅការបានបដិសេធការអនុវត្តការងារឱ្យពេញលេញ ដោយផ្អែកលើមាត្រា ៦៥៥ កថាខណ្ឌទី ២ នោះម្ចាស់ការមិនអាចទាមទារសោហ៊ុយចាំបាច់លើការជួសជុល និង បង់សោហ៊ុយជាមុនឡើយ (មាត្រា ៦៥៦ កថាខណ្ឌទី ៤)។

### ឆ. សិទ្ធិរំលាយរបស់ម្ចាស់ការ

ប្រសិនបើការងារមានវិការៈ ម្ចាស់ការអាចប្រើសិទ្ធិរំលាយកិច្ចសន្យា ដោយផ្អែកតាមបញ្ញត្តិនៃផ្នែកទី ៤ ជំពូកទី ៤ នៃគន្ថីទី ៤ បាន (ការរំលាយកិច្ចសន្យា)។ ឬនិយាយម្យ៉ាងទៀត ម្ចាស់ការអាចរំលាយកិច្ចសន្យាម៉ៅការបានតែក្នុងករណីដែល វិការៈនោះ ត្រូវគ្នានឹង "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ"។ ឧទាហរណ៍ ប្រសិនបើវិការៈមានភាពធ្ងន់ធ្ងរ ហើយការអនុវត្តការងារឱ្យបានពេញលេញមិនអាចធ្វើទៅបាន ឬ ប្រសិនបើការអនុវត្តការងារឱ្យបានពេញលេញគឺអាចធ្វើទៅបាន ប៉ុន្តែ ត្រូវចំណាយពេលវេលាយូរ ដូច្នេះគេអាចនិយាយបានថាវិការៈនៃការងារនេះ គឺជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរ។

ទន្ទឹមនឹងនេះ នៅក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញ មិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញ ដោយអ្នកម៉ៅការ នឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការ នោះម្ចាស់ការអាចរំលាយកិច្ចសន្យា ដោយផ្អែកលើបញ្ញត្តិទូទៅនៃការរំលាយកិច្ចសន្យា (មាត្រា ៦៥៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)។

ក៏ប៉ុន្តែ បញ្ញត្តិខាងលើនេះមិនត្រូវយកមកអនុវត្តចំពោះអាគារ ឬ សំណង់លើដីផ្សេងទៀតឡើយ។ ប្រសិនបើម្ចាស់ការត្រូវបានអនុញ្ញាតឱ្យរំលាយកិច្ចសន្យាម៉ៅការ ដែលកំណត់ថាអ្នកម៉ៅការត្រូវសង់អាគារ ឬ សំណង់លើដីផ្សេងទៀត ហើយដោយសារតែវិការៈ អ្នកម៉ៅការត្រូវរុះរើអាគារចេញនៅក្រោយការរំលាយ ទោះបីជាអាគារនោះត្រូវបានសាងសង់ហើយក៏ដោយ។ វា គឺជាបន្ទុកមួយដ៏ធ្ងន់ធ្ងរចំពោះអ្នកម៉ៅការ ហើយនិងធ្វើឱ្យខាតបង់ដល់វិស័យសេដ្ឋកិច្ចផងដែរ។ ដូច្នេះនៅក្នុងករណីនេះ ម្ចាស់ការមិនអាចរំលាយកិច្ចសន្យា ទោះបីជាការងារមានវិការៈក៏ដោយ ហើយគាត់អាចទាមទារបានតែការអនុវត្តការងារឱ្យបានពេញលេញ និង/ឬ សំណងនៃការខូចខាត។ ប៉ុន្តែប្រសិនបើសំណង់នោះ ពុំមានតម្លៃនឹងប្រើប្រាស់ចំពោះម្ចាស់ការ ដោយសារវិការៈធ្ងន់ធ្ងរពេក នោះគាត់អាចរំលាយកិច្ចសន្យាបាន (មាត្រា ៦៥៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២)។ ឧទាហរណ៍ ម្ចាស់ការបានបញ្ជាឱ្យអ្នកម៉ៅការសាងសង់ផ្ទះសម្រាប់ស្នាក់នៅ ប៉ុន្តែអាគារដែលអ្នកម៉ៅការបានសាងសង់នោះគឺមានគ្រឹះក្រោមមិនរឹងមាំ ហើយដែលប្រឈមមុខនឹងការបាក់រលំ ដូច្នេះអាគារនេះមិនត្រឹមតែគ្មានតម្លៃ ក្នុងការប្រើប្រាស់សម្រាប់ម្ចាស់ការទេ ថែមទាំងមិនអាចនិយាយបានថា ការរុះរើអាគារនេះគឺជាបន្ទុកធ្ងន់ធ្ងររបស់អ្នកម៉ៅការ ឬ ធ្វើឱ្យខាតបង់សេដ្ឋកិច្ចទៀតទេ។ ដូច្នេះ នៅក្នុងករណីនេះម្ចាស់ការអាចរំលាយកិច្ចសន្យាបាន។

### ឃ. សិទ្ធិទាមទារឱ្យបន្ថយថ្លៃរបស់ម្ចាស់ការ

ម្ចាស់ការអាចទាមទារឱ្យបន្ថយថ្លៃ តាមការបង្ហាញឆន្ទៈចំពោះអ្នកម៉ៅការ ដោយយកវិការៈនៃការងារមកធ្វើជាមូលហេតុបាន ប្រសិនបើ ម្ចាស់ការ បានទាមទារឱ្យអនុវត្តការងារពេញលេញ ចំពោះការងារ ដែលមានវិការៈនោះ ដោយកំណត់អំឡុងពេលសមរម្យ ប៉ុន្តែអ្នកម៉ៅការ មិនបានអនុវត្តការងារពេញលេញនៅក្នុងអំឡុងពេលនោះ។ ឬនិយាយម្យ៉ាងទៀត នៅក្នុងករណីនេះ ម្ចាស់ការ អាចជួសជុលវិការៈដោយខ្លួនឯងផ្ទាល់ និង ទាមទារថ្លៃជួសជុល ( មាត្រា ៦៥៦ កថាខណ្ឌទី ១) ឬ ទាមទារឱ្យបន្ថយតម្លៃ។

### ង. សិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ

ម្ចាស់ការអាចទាមទារសំណងនៃការខូចខាត ដោយផ្អែកទៅលើបញ្ញត្តិទូទៅនៃសំណងការខូចខាត និង/ឬ អនុវត្តសិទ្ធិរបស់ខ្លួន ដែលមានចែង ចាប់ពីមាត្រា ៦៥៥ ដល់ មាត្រា ៦៥៨។ ក៏ប៉ុន្តែនៅក្នុងករណីដែល ម្ចាស់ការទាមទារសំណងនៃការខូចខាត ជំនួសឱ្យការអនុវត្តការងារពេញលេញ គាត់អាចធ្វើការទាមទារបាន តែក្នុងករណីដែលក្រោយការកន្លងផុតនៃអំឡុងពេលសមរម្យ សម្រាប់ឱ្យអ្នកម៉ៅការអនុវត្តការងារនោះ ឬ ការអនុវត្តការងារពេញលេញរបស់អ្នកម៉ៅការមិនបានសម្រេច ឬ ករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យបានពេញលេញដោយអ្នកម៉ៅការ នឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការ។ ឬនិយាយម្យ៉ាងទៀត ប្រសិនបើម្ចាស់ការចង់ទាមទារនូវសំណងនៃការខូចខាត គាត់ត្រូវធ្វើការទាមទារឱ្យអនុវត្តពេញលេញជាមុនសិន។

### ច. នៅក្នុងករណីដែលវិការៈកើតឡើងដោយសារសម្ភារៈ ឬ ការបញ្ជារបស់ម្ចាស់ការ

នៅពេលខ្លះម្ចាស់ការបានផ្តល់នូវសម្ភារៈ ឬ ការបញ្ជាជាក់លាក់ណាមួយ សម្រាប់ឱ្យអ្នកម៉ៅការអនុវត្តតាម។ នៅក្នុងករណីដែល វិការៈកើតឡើង ដោយសារសម្ភារៈ ឬ ការបញ្ជារបស់ម្ចាស់ការ នោះ អ្នកម៉ៅការមិនចាំបាច់ទទួលខុសត្រូវ ទាក់ទងនឹងវិការៈនោះទេ។ ហើយ "ការបញ្ជា" ចាំបាច់ត្រូវតែរាប់បញ្ចូលនូវការណែនាំច្បាស់លាស់ មិនមែនគ្រាន់តែ "មានបំណង" នោះទេ។

ប្រសិនបើអ្នកម៉ៅការបានដឹងថា សម្ភារៈ ឬ ការបញ្ជានោះមិនសមស្រប ប៉ុន្តែ គាត់មិនបានផ្តល់ដំណឹងទៅដល់ម្ចាស់ការ នោះ អ្នកម៉ៅការមិនអាចរួចផុតពីការទទួលខុសត្រូវទាក់ទងនឹងវិការៈបានឡើយ។

## ៣.២. ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ

មាត្រា ៦៥៣ បានបញ្ញត្តថាប្រាក់កម្រៃត្រូវបង់ដំណាលគ្នានឹងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ។ នៅក្នុងន័យម្យ៉ាងទៀត អ្នកម៉ៅការត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារក្រោយការបញ្ចប់ការងារ។ បន្ទាប់មកតើនៅពេលណា ដែលត្រូវទទួលបាននូវកម្មសិទ្ធិ? និង តើអ្នកណាដែលត្រូវទទួលបានកម្មសិទ្ធិលើវត្ថុ ដែលជាកម្មវត្ថុនៃការងារនោះ?

នៅក្នុងករណីដែលខ្លឹមសារនៃកិច្ចសន្យាម៉ៅការ គឺត្រូវសាងសង់អាគារ អាគារនេះ មិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិប្រត្យក្សដាច់ដោយឡែកពីដីបានឡើយ (មាត្រា ១២២)។ ដូចនេះ គេអាចនិយាយបានថា ទោះបីជាអ្នកម៉ៅការ បានផ្តល់នូវសម្ភារៈសម្រាប់សាងសង់អាគារក៏ដោយ ក៏កម្មសិទ្ធិនៃអាគារនោះ គឺជារបស់ម្ចាស់ការតាំងពីដើមដំបូងតែម្តង។ នៅក្នុងករណីនេះ គាត់អាចធានានូវសិទ្ធិក្នុងការទាមទារនូវប្រាក់កម្រៃបាន តាមរយៈសិទ្ធិឃាត់ទុក ឬ ឯកសិទ្ធិលើអចលនវត្ថុ។

ចំពោះករណីដែលខ្លឹមសារនៃកិច្ចសន្យា គឺដើម្បីផលិតនូវចលនវត្ថុ ដូចជា សំលៀកបំពាក់ ឬ ស្បែកជើង តើមានលក្ខណៈយ៉ាងដូចម្តេច ? ឧទាហរណ៍ ម្ចាស់ការបានផ្តល់នូវសម្ភារៈសម្រាប់កាត់សំលៀកបំពាក់ទៅឱ្យអ្នកម៉ៅការ ហើយបញ្ជាគាត់ឱ្យកាត់សំលៀកបំពាក់ ដូច្នេះតើអ្នកណាត្រូវទទួលបាននូវកម្មសិទ្ធិ? ហើយនៅក្នុងករណីដែល អ្នកម៉ៅការ បានផ្តល់នូវសម្ភារៈ ឬ ក្រណាត់ សម្រាប់កាត់សំលៀកបំពាក់វិញ តើវានឹងទៅជាយ៉ាងណា?

វា មានគោលគំនិតចំនួន ៣ ដែលអាចទៅរួច គឺ :

គំនិតទី ១ គឺថា ម្ចាស់ការត្រូវទទួលបាននូវកម្មសិទ្ធិ។ មូលដ្ឋានសម្រាប់គំនិតនេះ គឺថាអ្នកម៉ៅការអាចគិតថាគាត់បានផលិតនូវ "ទ្រព្យសម្បត្តិរបស់ម្ចាស់ការ" និង មិនមែនជាទ្រព្យសម្បត្តិផ្ទាល់របស់គាត់ទេ។ ដោយពិចារណាទៅលើឆន្ទៈរបស់អ្នកម៉ៅការ កម្មសិទ្ធិត្រូវបានទៅលើម្ចាស់ការ នៅពេលដែលអ្នកម៉ៅការបានបញ្ចប់ការងារ។

គំនិតទី ២ គឺថាអ្នកម៉ៅការត្រូវទទួលបាននូវកម្មសិទ្ធិ ហើយគាត់ត្រូវផ្ទេរកម្មសិទ្ធិដោយការប្រគល់។ គំនិតនេះមានគោលដៅការពារអ្នកម៉ៅការ នៅក្នុងករណីដែលម្ចាស់ការមិនអាចបង់នូវប្រាក់កម្រៃបាន ដោយសារក្ស័យធន ឬ កង្វះទ្រព្យធន។ នៅក្នុងករណីនេះ អ្នកម៉ៅការ អាចដកទុកនូវសោហ៊ុយ តាមរយៈការលក់នូវវត្ថុ នោះ។

គំនិតទី ៣ គឺថា បុគ្គលដែលផ្តល់នូវសម្ភារៈទាំងអស់ ឬ សម្ភារៈចម្បង ត្រូវទទួលបាននូវកម្មសិទ្ធិ។ នេះគឺជាគំនិតមួយ ដែលសម្របសម្រួលនូវគំនិតពីរខាងលើ។ ការអនុវត្តនៅប្រទេសជប៉ុន ជាគោលការណ៍ គឺយកតាមគំនិតនេះ។ ក៏ប៉ុន្តែ មាត្រានេះប៉ះពាល់ទៅដល់មាត្រាទាក់ទងនឹងការកែច្នៃចលនវត្ថុ។ ខុសពីមាត្រា ១៩៩ នៃក្រមរដ្ឋប្បវេណីកម្ពុជាដែលវាបានបញ្ញត្តថា "ប្រសិនបើអ្នកកែច្នៃបានចូលរួមចំណែកក្នុងការផលិតនូវចលនវត្ថុ ដែលជារបស់អ្នកដទៃ នោះកម្មសិទ្ធិនៅលើវត្ថុនោះ គឺជារបស់ម្ចាស់នៃវត្ថុធាតុដើម ប៉ុន្តែ ប្រសិនបើតម្លៃដែលបានមកពីការងារនោះ ច្រើនជាងតម្លៃនៃវត្ថុធាតុដើម នោះអ្នកកែច្នៃ ត្រូវទទួលបានកម្មសិទ្ធិលើវត្ថុដែលបានកែច្នៃនោះ"។ ដូច្នេះ គំនិតនេះមិនអាចអនុវត្តបានជាចាំបាច់ទៅនឹងករណីនេះទេ ដោយផ្អែកទៅលើក្រមរដ្ឋប្បវេណីកម្ពុជា។

## ៤. កាតព្វកិច្ចរបស់ម្ចាស់ការ

### ៤.១. ករណីយកិច្ចបង់កម្រៃ

ម្ចាស់ការត្រូវបង់កម្រៃទៅឱ្យអ្នកម៉ៅការដំណាលគ្នានឹងការប្រគល់វត្ថុ ដែលជាកម្មវត្ថុនៃការងារ (មាត្រា ៦៥៣)។ ប្រសិនជា ការប្រគល់វត្ថុមិនមែនជាលក្ខខណ្ឌតម្រូវឱ្យមាននោះទេ ម្ចាស់ការត្រូវបង់ប្រាក់កម្រៃនៅពេល

ដែលអ្នកម៉ៅការបានសម្រេចការងារ ។ គូភាគីអាចបង្កើតការព្រមព្រៀងពិសេសទាក់ទងនឹងពេលវេលានៃការបង់កម្រៃ ព្រោះ វាមិនមែនជាបញ្ញត្តិដែលអនុវត្តដោយបង្ខំឡើយ ។

### ៤.២. ករណីយកិច្ចទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា

ម្ចាស់ការមានករណីយកិច្ចទទួលនូវវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ក្រោយពេលដែលអ្នកម៉ៅការបានសម្រេចការងាររបស់ខ្លួន ។ ប្រសិនបើម្ចាស់ការមិនបានទទួលវត្ថុដោយមានកំហុស នោះគាត់ទទួលបន្ទុកកាតព្វកិច្ច នៅក្នុងករណីមានការយឺតយ៉ាវក្នុងការទទួល (មាត្រា ៤៥៦) ។

## ៥. ការបញ្ចប់កិច្ចសន្យាម៉ៅការ

### ៥.១. សិទ្ធិរំលាយរបស់ម្ចាស់ការ ក្នុងពេលដែលការងារមិនទាន់បានសម្រេច

ម្ចាស់ការអាចរំលាយកិច្ចសន្យា នៅពេលណាក៏បានរហូតដល់ពេលដែលអ្នកម៉ៅការបានសម្រេចការងារ (មាត្រា ៦៦៣) ។ គោលបំណងនៃបញ្ញត្តិនេះ គឺដើម្បីឱ្យម្ចាស់ការ និង អ្នកម៉ៅការរួចផុតពីកាតព្វកិច្ច ប្រសិនបើម្ចាស់ការមិនចង់បន្តការងារនោះទៀតទេ ។ ក៏ប៉ុន្តែ ម្ចាស់ការត្រូវសងសំណងនៃការខូចខាតទៅឱ្យអ្នកម៉ៅការ ។ ឧទាហរណ៍ ប្រសិនបើម្ចាស់ការរំលាយកិច្ចសន្យាដែលបានបញ្ញត្តថា អ្នកម៉ៅការត្រូវផ្តល់នូវសម្ភារៈសម្រាប់កាត់ស្បែកជើង និង ត្រូវកាត់ស្បែកជើង នោះម្ចាស់ការត្រូវបង់នូវចំណាយលើសោហ៊ុយសម្ភារៈ និង ប្រាក់កម្រៃ រហូតដល់ពេលរំលាយកិច្ចសន្យា ។

### ៥.២. ការរំលាយកិច្ចសន្យា ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច

ទាំងម្ចាស់ការ និង អ្នកម៉ៅការ អាចរំលាយកិច្ចសន្យាម៉ៅការ ដោយផ្អែកលើបញ្ញត្តិទូទៅនៃការរំលាយកិច្ចសន្យាបាន ប្រសិនបើភាគីម្ខាងទៀត បានបំពានកិច្ចសន្យាធ្ងន់ធ្ងរ ។ ក៏ប៉ុន្តែ ការសម្រេចការងារភ្លាម ឬ បន្ទាន់ គឺជាខ្លឹមសារនៃកិច្ចសន្យា ដូចជាការកាត់សក់ ឬ ការជូសជុលទៅដល់កន្លែង នោះ ភាគី មិនអាចរំលាយកិច្ចសន្យាបានទេ ក្រោយពីការសម្រេចការងារ ។

# ជំពូកទី ៥
# កាតព្វកិច្ចដែលកំណត់ដោយច្បាប់
## ផ្នែកទី ១
## ការគ្រប់គ្រងដោយឈឺឆ្អាល

### ១. សេចក្ដីផ្ដើម

ក្រមរដ្ឋប្បវេណី បានកំណត់អំពីកាតព្វកិច្ចចំនួន បីយ៉ាង ដែលតម្រូវឱ្យមានការទទួលខុសត្រូវដែលមិនមែនកើតឡើងពីកិច្ចសន្យា។

① – ការគ្រប់គ្រងដោយឈឺឆ្អាល ( ការគ្រប់គ្រងកិច្ចការ)

② – សេចក្ដីចម្រើនដោយឥតហេតុ

③ – អំពើអនីត្យានុកូល

ឥឡូវនេះយើងនឹងសិក្សាអំពីកាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចទាំងបី គឺការគ្រប់គ្រងដោយឈឺឆ្អាល ។

ជាទូទៅ បុគ្គលមានសេរីភាពខាងឆន្ទៈ ( មាត្រា ៣ នៃក្រមរដ្ឋប្បវេណី) ដូច្នេះកាលណាគ្មានឆន្ទៈ គឺគ្មានកាតព្វកិច្ច ហេតុនេះគ្មាននរណាម្នាក់អាចចាប់បង្ខំបុគ្គលណាមួយឱ្យមានកាតព្វកិច្ចចំពោះអំពើអ្វីមួយបានឡើយ បើគេគ្មានឆន្ទៈ នេះយោងទៅតាមទ្រឹស្ដីនៃស្វ័យភាពបុគ្គល ។

ក៏ប៉ុន្តែ ប្រសិនបើបុគ្គលណាម្នាក់បានធ្វើអ្វីមួយក្នុងនាមអ្នកដទៃ ហើយមានឆន្ទៈក្នុងការបំពេញ ក្នុងន័យ ការពារ ឬ ធ្វើឱ្យមានប្រយោជន៍ដល់បុគ្គលម្នាក់ទៀត នោះបុគ្គលដែលត្រូវបានគេគ្រប់គ្រងដោយឈឺឆ្អាល ត្រូវមានកាតព្វកិច្ចចំពោះបុគ្គលនោះវិញ តាមការកំណត់របស់ច្បាប់ដែលត្រូវបានគេហៅថា ការគ្រប់គ្រងដោយឈឺឆ្អាល ។

**– ករណីសិក្សា :**

**ក).** បុគ្គលម្នាក់បានដឹងថា បង្អួចរបស់អ្នកជិតខាងម្នាក់ទទួលរងនូវការខូចខាត ដោយសារខ្យល់ព្យុះ ខណៈពេលដែលអ្នកជិតខាងនោះមិននៅផ្ទះ ។ បុគ្គលនោះមិនបានធ្វើអ្វីនោះទេ ហើយនៅខាងក្នុងផ្ទះរបស់អ្នកជិតខាងនោះបានលិចទឹក ។ អ្នកជិតខាងនោះបានត្រឡប់មកផ្ទះវិញ ហើយបានស្ដីបន្ទោសឱ្យបុគ្គលនោះ ។

**ខ).** បុគ្គលម្នាក់បានដឹងថា បង្អួចរបស់អ្នកជិតខាងម្នាក់ទទួលរងនូវការខូចខាត ដោយសារខ្យល់ព្យុះ ខណៈពេលដែលអ្នកជិតខាងនោះមិននៅផ្ទះ ។ បុគ្គលនោះបានជួសជុលបង្អួចដែលខូចខាតនោះ ដើម្បីការពារផ្ទះនោះកុំឱ្យលិចទឹកដោយចំណាយទៅលើកញ្ចក់ និង កម្លាំងពលកម្មរបស់គាត់ ។ បុគ្គលនោះបានរងរបួសម្រាមដៃខណៈពេលដែលគាត់ជួសជុលបង្អួចនោះ ។ តើបុគ្គលនោះអាចទាមទារអ្វីពីអ្នកជិតខាងនោះ?

ដូចជាករណីសិក្សាខាងលើ (ចំណុច ក) គឺគ្មាននរណាម្នាក់ ត្រូវបានគេចាប់បង្ខំឱ្យបំពេញការងារនោះទេ ដូច្នេះបុគ្គលនោះមិនត្រូវបានគេបន្ទោសទេ តាមទស្សនៈវិស័យច្បាប់នោះទេ (បញ្ហាខាងសីលធម៌នឹងមាន ប៉ុន្តែនេះគឺជាបញ្ហាមួយផ្សេងទៀត)។

ប៉ុន្តែ ករណី (ខ) កាលណាបុគ្គលណាម្នាក់ដែលបានគ្រប់គ្រងដោយឈឺឆ្អាលនោះ ទោះបីគ្មានកិច្ចសន្យា ឬការព្រមព្រៀងណាមួយក៏ដោយ បុគ្គលដែលបានទទួលផលប្រយោជន៍ ត្រូវមានកាតព្វកិច្ចធ្វើត្រឹមកម្រិតមួយជាក់លាក់ ដែលជាករណីលើកលែងចំពោះគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ នេះគឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់។

## ២. លក្ខខណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្អាល

① – ការគ្រប់គ្រងធ្វើឡើងដោយគ្មានសិទ្ធិអំណាច (កថាខណ្ឌទី ១)

② – ការគ្រប់គ្រងធ្វើឡើងដើម្បីបុគ្គលដទៃ (កថាខណ្ឌទី ១)

③ – អ្នកគ្រប់គ្រងចាប់ផ្តើមគ្រប់គ្រងកិច្ចការ (កថាខណ្ឌទី ១)

④ – ការគ្រប់គ្រងធ្វើឡើងទៅតាមវិធីដែលសមរម្យជាងគេ ឬ ផ្អែកតាមឆន្ទៈរបស់បុគ្គលជាសាមីខ្លួន (កថាខណ្ឌទី ២)

### ២.១. គ្មានសិទ្ធិអំណាច

ប្រសិនបើមានសិទ្ធិអំណាចក្នុងការគ្រប់គ្រង ដូចជា កិច្ចសន្យាអាណត្តិជាដើម នោះការគ្រប់គ្រងដោយឈឺឆ្អាលមិនត្រូវបានអនុវត្តទេ គឺភាគីត្រូវអនុវត្តដោយអនុលោមតាមសិទ្ធិអំណាចនៃការគ្រប់គ្រងនោះ ហើយនោះមិនមែនជាបញ្ហានៃការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ។

**ឧទាហរណ៍ :** អ្នកមានអំណាចមេបា ឬ អ្នកស្ថិតក្រោមអាណាព្យាបាលទូទៅ។ល។

### ២.២. ដើម្បីបុគ្គលដទៃ

កាគ្រប់គ្រង ត្រូវបានធ្វើឡើងដើម្បីបុគ្គលដទៃ។

**ឧទាហរណ៍ :** ដីជាកម្មសិទ្ធិរបស់ ក ដែលបានទុកចោល។ ខ បានយកដីនោះធ្វើជាកន្លែងផ្ញើកង់ម៉ូតូ ក្នុងនាមខ្លួន ដូច្នេះ នៅករណីនេះ ខ មិនអាចអនុវត្តការគ្រប់គ្រងដោយឈឺឆ្អាលបានទេ ពីព្រោះ ខ មានបំណងយកជាប្រយោជន៍ខ្លួនឯង។ នេះប្រហែលជាបញ្ហាខាងច្បាប់ស្តីអំពីអំពើអនីត្យានុកូល។

### ២.៣. អ្នកគ្រប់គ្រងចាប់ផ្តើមគ្រប់គ្រង

ការចាប់ផ្តើមសកម្មភាពគតិយុត្ត

ការចាប់ផ្តើមសកម្មភាពដទៃផ្សេងទៀត

- សកម្មភាពគតិយុត្ត សំដៅទៅលើកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី (មាត្រា ៣៥៦)។

- សកម្មភាពដទៃផ្សេងទៀត ជាសកម្មភាពដែលបុគ្គលម្នាក់ចាប់ផ្ដើមជួសជុល ឬ បំពេញជាដើម ។

ចំពោះករណីបង្ហូចខូច ប្រសិនបើភាគីបង្កើតកិច្ចសន្យាជាមួយអ្នកជួសជុលថា អ្នកជួសជុលត្រូវជួសជុលបង្ហូច នោះវាអាចជាការគ្រប់គ្រងសកម្មភាពគតិយុត្ត ។

ប្រសិនបើគាត់ជួសជុលបង្ហូចដោយខ្លួនគាត់ផ្ទាល់ វាមិនមែនជាសកម្មភាពគតិយុត្តនោះទេ ប៉ុន្តែវានៅតែជាការគ្រប់គ្រងដដែល ។

## ២.៤. ការគ្រប់គ្រងដោយធ្វើឡើងតាមវិធីដែលសមរម្យជាងគេ និង ដោយផ្អែកតាមឆន្ទៈ

លក្ខខណ្ឌនេះ គឺការពារដល់សាមីខ្លួនក្នុងការបង់សោហ៊ុយច្រើនហួសហេតុ ដោយការគ្រប់គ្រងដោយឈឺឆ្អាលនោះ ឬ ក៏ជាការធ្វើឱ្យបានត្រឹមត្រូវ និង យុត្តិធម៌ក្នុងនាមជាអ្នកជួយគ្រប់គ្រងដោយភាពសុចរិត និង ឆ្លើយតបទៅនឹងអំពើមនុស្សធម៌ ប្រកបដោយសីលធម៌ និង សមធម៌រវាងបុគ្គលឯកជន ។

ជារួម អ្នកគ្រប់គ្រងត្រូវធ្វើការគ្រប់គ្រងឱ្យសមស្របទៅតាមលក្ខណៈនៃការគ្រប់គ្រងនោះ ។

ចំពោះវិធីដែលសមរម្យជាងគេ ប្រសិនបើអ្នកគ្រប់គ្រងបានដឹង ឬ អាចដឹងអំពីឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រងនោះត្រូវគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ យោងតាមមាត្រា ៧២៩ កថាខណ្ឌទី ៣ ។ ប៉ុន្តែ ប្រសិនបើអ្នកគ្រប់គ្រងមិនអាចដឹងអំពីឆន្ទៈពិតប្រាកដទេ អ្វីដែលសមស្របជាងគេនោះ គឺត្រូវកំណត់ដោយសត្យានុម័ត ។

**ឧទាហរណ៍ :** នៅពេល **ក** បានជួយសង្គ្រោះជនលង់ទឹក **ខ** ដែលបានធ្វើអត្តឃាតដោយមិនបានដឹងអំពីឆន្ទៈរបស់ **ខ** ការជួយសង្គ្រោះបែបនេះ គឺត្រូវបានចាត់ទុកថាជាវិធីដែលសមស្របជាងគេ ពីព្រោះការជួយសង្គ្រោះបុគ្គលណាម្នាក់ដែលលង់ទឹក គឺស្របទៅតាមវិធីដែលសមរម្យជាងគេតាមការជាក់ស្ដែង ។

ប៉ុន្តែ ក៏មានករណីលើកលែងផងដែរ មាត្រា ៧៣០ ។

**ឧទាហរណ៍ :** ក្នុងករណីបន្ទាន់ ទោះបីជាការគ្រប់គ្រងនោះ បណ្ដាលឱ្យមានការខូចខាតក៏ដោយ ក៏នៅតែជាការគ្រប់គ្រងដោយឈឺឆ្អាលដែរ ។

**ឧទាហរណ៍ : ក** សន្លប់ ហើយ **ខ** បានបញ្ជូន **ក** ទៅមន្ទីរពេទ្យដែលនៅជិត តែមន្ទីរពេទ្យនោះគ្មានគ្រូពេទ្យជំនាញ ដូច្នេះក៏ធ្វើឱ្យ **ក** មានជម្ងឺកាន់តែធ្ងន់ធ្ងរ ។

ចំពោះការគោរពតាមឆន្ទៈ ប្រសិនបើអ្នកគ្រប់គ្រងបានដឹង ឬ អាចដឹងពីឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រងត្រូវធ្វើការគ្រប់គ្រង ដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួននោះ មាត្រា ៧២៩ កថាខណ្ឌទី ៣ ។

ប៉ុន្តែក៏នៅតែមានករណីលើកលែងផងដែរ ។ ក្នុងករណីដែលសាមីខ្លួនចង់ធ្វើអត្តឃាត ដោយលោតទឹក ហើយដោយបានដឹងថាសាមីខ្លួនធ្វើអត្តឃាត អ្នកគ្រប់គ្រងបានជួយសង្គ្រោះដោយយកគាត់ទៅព្យាបាលនៅឯមន្ទីរពេទ្យ និង បានបង់សោហ៊ុយព្យាបាលអស់ចំនួន ១០០ ដុល្លារ ប៉ុន្តែសាមីខ្លួនបដិសេធមិនបង់សោហ៊ុយព្យាបាលទេ ដោយអះអាងថាការជួយសង្គ្រោះគាត់ គឺផ្ទុយនឹងឆន្ទៈរបស់គាត់ ។ បើយើងគោរពតាមឆន្ទៈរបស់សាមីខ្លួននោះ សាមីខ្លួននឹងស្លាប់ ប៉ុន្តែបើយើងមិនគោរពតាមឆន្ទៈរបស់សាមីខ្លួនទេ គឺយើងបកស្រាយបានថាសាមីខ្លួនត្រូវសងតម្លៃឱ្យអ្នកគ្រប់

គ្រងដែលផ្ទុយនឹងឆន្ទៈរបស់គាត់ដែលបានបង្ហាញ។ នេះគឺជាបញ្ហាលំបាកមួយ ហើយប្រហែលជាបញ្ហាខាងសីលធម៌។ ការបកស្រាយមួយដែលអាចមាន គឺអ្នកគ្រប់គ្រងមិនអាចទាមទារសំណងទេ ដោយសារតែការជួយសង្គ្រោះនេះ គឺផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន។ ហើយការបកស្រាយមួយទៀតដែលអាចមានដែរ គឺអ្នកគ្រប់គ្រងមិនត្រូវធ្វើតាមឆន្ទៈធ្វើអត្តឃាតនោះទេ ពីព្រោះវាផ្ទុយនឹងសីលធម៌ដ៏ល្អ ( មាត្រា ៣៥៤) ។ បញ្ហានេះ ត្រូវបានសម្រេចដោយយោងទៅតាមការគិតពិចារណារបស់កម្ពុជា។

## ៣. ករណីយកិច្ច

### ៣.១. ករណីយកិច្ចគ្រប់គ្រងតាមវិធីដែលសមស្របជាងគេដើម្បីជាប្រយោជន៍ និង អនុវត្តតាមឆន្ទៈរបស់សាមីខ្លួន

ដូចដែលបានពន្យល់ក្នុងមាត្រា ៧២៩ និង មាត្រា ៧៣០ រួចហើយ ជាទូទៅ គឺត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្នក្នុងនាមអ្នកគ្រប់គ្រងដោយសុចរិត។

### ៣.២. ករណីយកិច្ចជូនដំណឹង

អ្នកគ្រប់គ្រងត្រូវជូនដំណឹងទៅសាមីខ្លួន ដោយហេតុថាការគ្រប់គ្រងនេះគ្មានការព្រមព្រៀង និង មិនអាចដឹងពីឆន្ទៈរបស់សាមីខ្លួន។ ហេតុនេះហើយ អ្នកគ្រប់គ្រងត្រូវមានករណីយកិច្ចជូនដំណឹងទៅសាមីខ្លួនឱ្យដឹងពីការគ្រប់គ្រងរបស់ខ្លួន ( មាត្រា ៧៣១) ក៏ដូចជាដើម្បីឱ្យបានដឹងពីឆន្ទៈរបស់សាមីខ្លួនផង និង បង្ហាញពីភាពសុចរិត និង ការគ្រប់គ្រងរបស់ខ្លួនផង។

ប្រសិនបើសាមីខ្លួននៅឆ្ងាយមិនអាចជូនដំណឹងបាន អ្នកគ្រប់គ្រងត្រូវជូនដំណឹងជាបន្ទាន់ នៅពេលដែលសាមីខ្លួនអាចទទួលការជូនដំណឹង។

### ៣.៣. ករណីយកិច្ចបន្តការគ្រប់គ្រង

ប្រសិនបើអ្នកគ្រប់គ្រងបានធ្វើការគ្រប់គ្រងហើយ តែសាមីខ្លួនមិនទាន់ត្រឡប់មកវិញ ឬ ក៏មិនទាន់អាចគ្រប់គ្រងបានទេ នោះអ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបន្តការគ្រប់គ្រងនោះតទៅទៀតក្នុងន័យការពារ និង ធ្វើឱ្យបានប្រយោជន៍ដល់សាមីខ្លួនដដែល រហូតដល់ពេលដែលសាមីខ្លួនអាចធ្វើការគ្រប់គ្រងវិញបាន។

ប៉ុន្តែក៏មានករណីលើកលែងផងដែរ ប្រសិនបើការបន្តការគ្រប់គ្រងផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬ ធ្វើឱ្យខូចប្រយោជន៍ចំពោះសាមីខ្លួន។ មាត្រាដែលពាក់ព័ន្ធគឺ មាត្រា ៧៣២ ។

### ៣.៤. ករណីយកិច្ចធ្វើសេចក្ដីរាយការណ៍

ការគ្រប់គ្រងដោយឈឺឆ្អាលមានលក្ខណៈស្រដៀងគ្នាទៅនឹងអាណត្តិដែរ ហើយមានកាតព្វកិច្ចដូចគ្នាត្រូវធ្វើដើម្បីជាប្រយោជន៍របស់សាមីខ្លួន និង រាយការណ៍អំពីដំណើរការនៃកិច្ចសន្យាផ្សេងៗដែលខ្លួនគ្រប់គ្រង។

### ៣.៥. ករណីយកិច្ចទាមទារសំណងចំពោះប្រាក់ដែលបានចំណាយ

ករណីយកិច្ចនេះ ត្រូវបានដាក់បន្ទុកដោយផ្អែកលើការត្រិះរិះពិចារណាមើល ដូចគ្នានឹងករណីយកិច្ចធ្វើសេចក្ដីរាយការណ៍ផងដែរ ។

## ៤. អានុភាព

### ៤.១. សិទ្ធិទាមទារឱ្យសងសោហ៊ុយ ជាអាទិ៍

- អ្នកគ្រប់គ្រងអាចទាមទារឱ្យសងមកវិញ បាននូវសោហ៊ុយចាំបាច់ដែលបានចំណាយសម្រាប់ការគ្រប់គ្រង (មាត្រា ៧៣៤ កថាខណ្ឌទី ១) ។

- អ្នកគ្រប់គ្រងក៏អាចទាមទារពីសាមីខ្លួនឱ្យរួចផុតពីកាតព្វកិច្ច ឬ ឱ្យផ្ដល់ប្រាតិភោគដែលសមរម្យបាន (មាត្រា ៧៣៤ កថាខណ្ឌទី ២) ។

- ប្រសិនបើអ្នកគ្រប់គ្រងបានធ្វើការគ្រប់គ្រងផ្ទុយពីឆន្ទៈរបស់សាមីខ្លួន ចំនួននៃសំណងគឺត្រូវបានកម្រិតត្រឹមតែផលប្រយោជន៍ដែលសាមីខ្លួនបានទទួលជាក់ស្ដែងប៉ុណ្ណោះ (មាត្រា ៧៣៤ កថាខណ្ឌទី ៣) ។

- ថាតើសំណងនៃការខូចខាតដែលទទួលរងក្នុងអំឡុងពេលគ្រប់គ្រង ត្រូវបានរួមបញ្ចូលនៅក្នុងសោហ៊ុយចាំបាច់ ឬ ក៏អត់នោះ គឺមិនត្រូវបានបង្ហាញច្បាស់លាស់នោះទេ នៅក្នុងពាក្យពេចន៍ ដូច្នេះវា គឺជាបញ្ហាលំបាកមួយ ។

**ឧទាហរណ៍ :** នៅពេលអ្នកគ្រប់គ្រងជួសជុលការគ្រប់គ្រងនេះដោយប្រើកញ្ចក់ ហើយបណ្ដាលឱ្យមុតដៃរបស់គាត់ ករណីនេះចាត់ទុកថាតម្លៃព្យាបាលរបួស ១០០ ដុល្លារ គឺជាការខូចខាត ។ ចំពោះតម្លៃកញ្ចក់ ១.០០០ ដុល្លារ អ្នកគ្រប់គ្រងអាចទាមទារ ១.០០០ ដុល្លារ នេះដែលជាសោហ៊ុយចាំបាច់នៃការគ្រប់គ្រង ។ ថាតើថ្លៃព្យាបាលរបួសចំនួន ១០០ ដុល្លារ អាចបូកបញ្ចូល ឬ អត់ គឺអាស្រ័យលើការបកស្រាយ ។

- ***មូលហេតុមិនបូកបញ្ចូល :*** វាមិនត្រូវបានរាប់បញ្ចូលទៅក្នុងសោហ៊ុយចាំបាច់នោះទេ ។ ជាងនេះទៅទៀត គឺចាំបាច់ត្រូវដកវាចេញដើម្បីរារាំងកុំឱ្យសាមីខ្លួនទទួលបន្ទុកច្រើនជាងគាត់រំពឹងទុក (សាមីខ្លួន អាចត្រៀមរៀបចំសងសោហ៊ុយកញ្ចក់ ប៉ុន្តែមិនមែនសម្រាប់សោហ៊ុយព្យាបាលនោះទេ) ។ ការខូចខាតនេះមិនត្រូវបានគេទាមទារឡើយ ។

- ***មូលហេតុបញ្ចូលគ្នា :*** ការគ្រប់គ្រងនេះ គឺស្របនឹងឆន្ទៈរបស់សាមីខ្លួន ហើយក្នុងពេលគ្រប់គ្រងនោះមានការខូចខាត ដែលមិនអាចជៀសវាងបាន ដូច្នេះតម្លៃនេះក៏អាចបញ្ចូលក្នុងការទាមទារនូវសោហ៊ុយចាំបាច់ដែរ (នេះ គឺជាជាការបកស្រាយ) ។

ដោយផ្អែកលើគំនិតនេះ ប្រសិនបើការខូចខាតអាចជៀសវាងបាន នោះអ្នកគ្រប់គ្រងមិនអាចធ្វើការទាមទារសំណងនៃការខូចខាតនេះជាសោហ៊ុយចាំបាច់នៃការគ្រប់គ្រងបានទេ ។

### ៤.២. សិទ្ធិទាមទារកម្រៃ

ជាទូទៅ កម្រៃមិនអាចទាមទារបានទេ ដោយសារការគ្រប់គ្រងដោយឈឺឆ្អាលត្រូវបានចាប់ផ្ដើមឡើង

ដោយគ្មានការយល់ព្រម (ដែលជាមូលហេតុចម្បងសម្រាប់លើកឡើងនូវកាតព្វកិច្ចដើម្បីសងកម្រៃ) របស់សាមីខ្លួន។ ប៉ុន្តែ នៅក្នុងករណីដែលការគ្រប់គ្រងត្រូវបានបញ្ចូលទៅក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រងសាមីខ្លួននឹងដឹងអំពីបញ្ហានេះ ហើយមិនបានបដិសេធទេ នោះវាហាក់ដូចជាអយុត្តិធម៌ដែលសាមីខ្លួនត្រូវអនុវត្តកាតព្វកិច្ច ប្រសិនបើគាត់ដឹងថាការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងត្រូវបានដាក់បញ្ចូលទៅក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រង។

# ផ្នែកទី ២
# សេចក្ដីចម្រើនដោយឥតហេតុ

## ១. សេចក្ដីផ្ដើម

ក្រមរដ្ឋប្បវេណី បានចែងអំពីសេចក្ដីចម្រើនដោយឥតហេតុ ដែលជាមូលហេតុមួយនៅក្នុងចំណោមមូលហេតុជាច្រើន សម្រាប់ការកើតឡើងនូវកាតព្វកិច្ច ដូចជា កិច្ចសន្យា អំពើអនីត្យានុកូល និង ការគ្រប់គ្រងដោយឈឺឆ្អាល ដែលដាក់បន្ទុកឱ្យបុគ្គលណាដែលគ្មានមូលហេតុគតិយុត្តក្នុងការទទួលបាននូវផលប្រយោជន៍ សងត្រឡប់នូវអ្វីដែលខ្លួនបានទទួលឱ្យទៅបុគ្គលដែលបានបាត់បង់ផលប្រយោជន៍ និង ផ្ដល់សិទ្ធិឱ្យភាគីដែលបាត់ប្រយោជន៍ ទាមទារយកមកវិញនូវអ្វីដែលបានបាត់បង់ដោយគ្មានមូលហេតុតាមផ្លូវច្បាប់។

ជាទូទៅ វិធានស្ដីពីសេចក្ដីចម្រើនដោយឥតហេតុ ចាប់ផ្ដើមដំណើរការនៅពេលដែលកិច្ចសន្យាត្រូវបានរកឃើញថាមោឃៈត្រូវបានលុបចោល និង ត្រូវបានរំលាយជាដើម ប៉ុន្តែវាមិនមែនមានតែករណីទាំងនេះតែប៉ុណ្ណោះទេ។

ករណីជាច្រើនផ្សេងទៀត ដែលទ្រព្យសម្បត្តិចម្ងាដែលពាក់ព័ន្ធនឹងបញ្ញត្តិដែលមានមុខងារមិនប្រក្រតី ក៏ត្រូវបានគ្រប់គ្រង ដោយវិធានស្ដីពីសេចក្ដីចម្រើនដោយឥតហេតុផងដែរ។ នោះគឺជាមូលហេតុដែលសេចក្ដីចម្រើនដោយឥតហេតុ ជួនកាលត្រូវបានគេហៅថាគោលការណ៍ Clean Up។ ដោយប្រៀបធៀបទៅនឹងវិស័យគ្រប់គ្រងដទៃផ្សេងទៀត វិធានស្ដីពីសេចក្ដីចម្រើនដោយឥតហេតុ គឺមានលក្ខណៈសាមញ្ញបន្តិច។ លក្ខណៈសាមញ្ញនេះទុកលទ្ធភាព ដើម្បីធ្វើការអនុវត្តដែលមានលក្ខណៈសមរម្យមួយ ចំពោះករណីទាំងឡាយណាដែលមិនអាចរំពឹងទុកចំពោះនីតិពន្ធ។

ករណីដូចជា **ក** ជំពាក់ប្រាក់ **ខ** ចំនួន ១.០០០ ដុល្លារ។ **ខ** និង **គ** ជាបងប្អូនភ្លោះ។ **ក** បានសងលុយឱ្យ **គ** ដោយស្មានថា **គ** ជា **ខ**។ សេចក្ដីចម្រើនដោយឥតហេតុ ត្រូវបានយកមកអនុវត្តនៅក្នុងករណីនេះ ពីព្រោះ **ក** ទទួលរងនូវការបាត់បង់ផលប្រយោជន៍ ខណៈពេលដែល **គ** មិនមានមូលហេតុដើម្បីរក្សាទុកផលប្រយោជន៍នោះ។

## ២. លក្ខខណ្ឌទូទៅ

ផ្អែកតាមមាត្រា ៧៣៦ កថាខណ្ឌទី ១ លក្ខខណ្ឌទូទៅ គឺមានដូចខាងក្រោម :

**២-១** ផលប្រយោជន៍

**២-២** ការបាត់បង់ផលប្រយោជន៍

**២-៣** ទំនាក់ទំនងហេតុ និង ផលរវាងការទទួលផលប្រយោជន៍ និង ការបាត់បង់ផលប្រយោជន៍

**២-៤** ភាពមិនមានមូលហេតុលើផ្លូវច្បាប់ក្នុងការទទួលបានផលប្រយោជន៍

ចូរធ្វើការសិក្សា អំពីលក្ខខណ្ឌទាំងនេះមួយម្ដងៗ ជាមួយនឹងឧទាហរណ៍ខាងក្រោមនេះ។ ករណីខាងក្រោមនេះ គឺត្រូវបានចាត់ទុកថាជាប្រភេទករណី ពីរយ៉ាង ដែលកើតមានញឹកញាប់ ដែលសេចក្ដីចម្រើនដោយឥតហេតុ ត្រូវបានយកមកអនុវត្ត។

ករណីទី ១ គឺ ករណីដែលសេចក្ដីចម្រើនដោយឥតហេតុ ដែលផ្អែកលើទំនាក់ទំនងដែលអាចមើលឃើញ ដូចជា កិច្ចសន្យាដែលត្រូវបានលុបចោល។ ករណីមួយផ្សេងទៀត គឺសេចក្ដីចម្រើនដោយឥតហេតុត្រូវបានយកមកអនុវត្ត ដោយផ្អែកលើការរំលោភសិទ្ធិរបស់អ្នកដទៃ ដូចជា កម្មសិទ្ធិជាក់ស្ដែង។

សូមកត់សម្គាល់ថាករណីទាំងពីរនេះ គឺគ្រាន់តែជាករណីមួយចំនួនទៅក្នុងចំណោមករណីដែលកើតមានញឹកញាប់ជាច្រើន ហើយសេចក្ដីចម្រើនដោយឥតហេតុ អាចយកមកអនុវត្តនៅក្នុងន័យទូលាយជាងនេះ។

**I- ក** និង **ខ** បានបង្កើតកិច្ចសន្យាមួយដែល **ក** ត្រូវលក់រថយន្តទៅឱ្យ **ខ**។ **ក** បានប្រគល់រថយន្តនោះឱ្យ **ខ** ហើយ **ខ** បានបង់ថ្លៃលក់ចំនួន ១០.០០០ ដុល្លារ ឱ្យ **ក**។ បន្ទាប់មក **ក** បានលុបកិច្ចសន្យានោះចោល ដោយសារតែ **ខ** បានឆបោក។ តើ **ក** និង **ខ** អាចទាមទារអ្វីពីគ្នាបាន?

**II- ខ** បានយករថយន្តដែលចតនៅក្នុងជីឡូតិ៍មួយកន្លែង ដោយគ្មានការយល់ព្រម ខណៈពេលដែលម្ចាស់រថយន្ត **ក** មិននៅ។ **ខ** បានបើករថយន្តនោះអស់រយៈពេល ១ ខែ ហើយបានទុករថយន្តនោះវិញ មុនពេលដែល **ក** បានដឹងហេតុការណ៍នោះ។ រថយន្តនោះមិនខូចខាតទេ ហើយសាំងក៏មិនត្រូវបានប្រើដែរ **ខ** ព្រោះគាត់បានប្រើសាំងដែលបានទិញដោយខ្លួនឯង។ តើ **ក** អាចទាមទារពី **ខ** បានដែរ ឬ ទេ?

### ២.១. ផលប្រយោជន៍

ភាគីម្ខាងទទួលបានផលប្រយោជន៍ពីភាគីម្ខាងទៀត ដែលបាត់នូវផលប្រយោជន៍។ ផលប្រយោជន៍ដែលទទួលបាន គឺជាផលប្រយោជន៍ដែលបាត់បង់ ហើយវាអាចជាផលប្រយោជន៍រូបី និង ផលប្រយោជន៍អរូបី។ ផលប្រយោជន៍រូបី នៅក្នុងករណីនៃសេចក្ដីចម្រើនដោយឥតហេតុ គឺធម្មតាជាប្រាក់ ឬ ទំនិញ។ ម្យ៉ាងទៀត ផលប្រយោជន៍អរូបី អាចជាផលប្រយោជន៍ក្នុងការប្រើប្រាស់ ឬ សិទ្ធិនៃការចាត់ចែង។

នៅក្នុងករណីទី ១ វា គឺជាផលប្រយោជន៍រូបី ដែល **ក** ទទួលបានលុយចំនួន ១០.០០០ ដុល្លារ ពី **ខ** ហើយ **ខ** ទទួលបានរថយន្តពី **ក**។

នៅក្នុងករណីទី ២ វា គឺជាផលប្រយោជន៍អរូបីដែល **ខ** ទទួលបានការប្រើប្រាស់រថយន្តរបស់ **ក** អស់រយៈពេល ១ ខែ។ តម្លៃនៃផលប្រយោជន៍បែបនេះ ជានិច្ចកាលមិនមានភាពច្បាស់លាស់នោះទេ ប៉ុន្តែដើម្បីដឹងថា តើផលប្រយោជន៍ដែល **ក** ទទួលបានមានទំហំប៉ុណ្ណានោះ យើងត្រូវយោងទៅលើថ្លៃឈ្នួលប្រចាំខែ ចំពោះរថយន្តដែលមានប្រភេទដូចគ្នា ថាតើមានចំនួនប៉ុន្មានក្នុង ១ ខែ?

### ២.២. ការបាត់បង់ផលប្រយោជន៍

ទំហំនៃផលប្រយោជន៍ដែលបាត់បង់ ត្រូវសមាមាត្រទៅនឹងទំហំនៃផលប្រយោជន៍ដែលទទួលបាន។ នេះគឺជាគោលការណ៍នៃការសងត្រឡប់មកវិញនូវផលប្រយោជន៍ ដែលបានទទួលត្រឹមទំហំនៃផលប្រយោជន៍ដែលត្រូវបានបាត់បង់។ ជាទូទៅ ការបាត់បង់នូវផលប្រយោជន៍ គឺឆ្លើយតបទៅនឹងទស្សនៈនៃផលប្រយោជន៍ នៅក្នុងករណីភាគច្រើន។

នៅក្នុងករណីទី ១ វាមានលក្ខណៈងាយស្រួលក្នុងការដឹងថា តើអ្វីជាការបាត់បង់ ដោយសារថាវាជាវត្ថុរូបី ដែលមានលក្ខណៈខុសគ្នាពីទស្សនៈ ដូចជា សិទ្ធទាមទារ និង កាតព្វកិច្ច។ ការបាត់បង់ និង ការទទួលបានទូវផល ប្រយោជន៍ ឆ្លើយតបគ្នាយ៉ាងច្បាស់ គឺ **ក** បាត់បង់រថយន្ត ហើយ **ខ** បាត់បង់លុយ។

ផលប្រយោជន៍របស់ **ខ** គឺការបាត់បង់របស់ **ក** ហើយផលប្រយោជន៍របស់ **ក** គឺការបាត់បង់របស់ **ខ** ប៉ុន្តែ វាខុសគ្នាចំពោះករណីទី ២។

ជាពិសេស បញ្ហាអាចត្រូវបានដោះស្រាយដូចខាងក្រោម។ តើអ្វីដែលជាការបាត់បង់ បើសិនជាបុគ្គលណា មួយប្រើប្រាស់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ខណៈពេលដែលម្ចាស់សិទ្ធិមិនមានឆន្ទៈប្រើ ឬ ចាត់ចែងទ្រព្យសម្បត្តិ របស់ខ្លួនទាល់តែសោះ? ទាក់ទងនឹងការបាត់បង់នេះ មានទស្សនៈពីរមានវិវាទនឹងគ្នា។ ទស្សនៈទី ១ យល់ឃើញ ថា **ក** មិនបាត់បង់ផលប្រយោជន៍ទេ ដោយសារ **ក** ទុករថយន្តមិនប្រើប្រាស់ ហើយរថយន្តមិនមានខូចខាតអ្វីទេ (បរិមាណសាំងនៅដដែល)។ ចំពោះទស្សនៈទី ២ យល់ឃើញថា **ក** បាត់បង់នូវផលប្រយោជន៍ ដោយសារ **ក** អាច ប្រើប្រាស់រថយន្ត នៅពេលណាមួយក្នុងអំឡុងពេលដែលគាត់ទុករថយន្តចោលនោះ និង ការបាត់បង់ដែលកើតឡើង ដោយសារការសឹករិចរិលលើរថយន្តនោះ។

## ២.៣. ទំនាក់ទំនងហេតុ និង ផល

លក្ខខណ្ឌនេះ គឺមិនខុសគ្នាទៅនឹងលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌផ្សេងៗទៀត ដើម្បីអាចទាមទារ សំណងនៃការខូចខាតដោយសារអំពើអនីត្យានុកូល ដូចជា ទំនាក់ទំនងហេតុ និង ផលរវាងព្យសនកម្ម និង អំពើ បំពានដោយខុសច្បាប់នូវសិទ្ធិ និងផលប្រយោជន៍។ ចំពោះសេចក្តីចម្រើនដោយឥតហេតុ ដើម្បីទទួលស្គាល់នូវសិទ្ធិ ក្នុងការទាមទារយកមកវិញនូវផលប្រយោជន៍ដែលបានបាត់បង់ បញ្ហាគឺស្ថិតនៅត្រង់ថា តើមានអ្នកទទួលបាននូវ ផលប្រយោជន៍នោះដែរ ឬ ទេ? តើមានអ្នកដែលបានបាត់បង់ផលប្រយោជន៍ ដោយសារតែមានបុគ្គលម្នាក់ទៀត ទទួលបាននូវផលប្រយោជន៍ដែរ ឬ យ៉ាងណា?

ជាទូទៅទំនាក់ទំនងហេតុ និង ផល ត្រូវបានទទួលស្គាល់ ប្រសិនបើបានបង្ហាញថាមានអ្នកទទួលបាន ផលប្រយោជន៍ ដោយសារការបាត់បង់ផលប្រយោជន៍របស់បុគ្គលម្នាក់ទៀត ដោយគ្មានមូលហេតុ។ ទំនាក់ទំនង ហេតុ និង ផល នៅក្នុងសេចក្តីចម្រើនដោយឥតហេតុ គឺភាគច្រើនមិនសូវចោទជាបញ្ហាធំដុំនោះទេ ដោយសារតែ ការបាត់បង់ នៅក្នុងករណីភាគច្រើនត្រូវបានភ្ជាប់ជាមួយនឹងការទទួលបានផលប្រយោជន៍ ស្ទើរតែមិនអាចជៀសរួច។

នៅក្នុងករណីទី ១ **ក** បានលុបកិច្ចសន្យាជាមួយ **ខ** ដោយសារការឆបោក នៅក្រោយពេលប្រគល់វត្ថុ និង ការបង់ថ្លៃលក់។ នៅក្នុងករណីនេះ បើសិនជា **ក** មិនបានប្រគល់រថយន្តនោះ **ខ** ក៏មិនទទួលបានផលប្រយោជន៍ជា រថយន្ត។ ដូចគ្នានេះដែរ បើសិនជា **ខ** មិនបានបង់លុយឱ្យ **ក** ក៏ **ក** មិនទទួលបានផលប្រយោជន៍ជាប្រាក់ផងដែរ។

ហេតុដូច្នេះ ទំនាក់ទំនងហេតុ និង ផល ត្រូវបានគេទទួលស្គាល់ រវាងផលប្រយោជន៍របស់ **ក** និង ការបាត់ បង់របស់ **ខ** ព្រមទាំងការបាត់បង់របស់ **ក** និង ផលប្រយោជន៍របស់ **ខ**។

នៅក្នុងករណីទី ២ ខ បានយករថយន្តដែល ក ចតនៅក្នុងដីឡូតិ៍មួយកន្លែង ប្រើប្រាស់អស់រយៈពេល ១ ខែ។ បើសិនបើ ខ មិនយករថយន្តរបស់ ក ប្រើប្រាស់ ក៏ ក មិនបាត់ផលប្រយោជន៍ពីការប្រើប្រាស់រថយន្ត ហើយ ខ ក៏មិនទទួលបានផលប្រយោជន៍ជាការប្រើប្រាស់រថយន្តដែរ។ ហេតុដូច្នេះ ទំនាក់ទំនងហេតុ និង ផល ត្រូវបានចាត់ទុកថាបានភ្ជាប់គ្នា។

### ២.៤. ការទទួលផលប្រយោជន៍ដោយគ្មានមូលហេតុលើផ្លូវច្បាប់

"គ្មានមូលហេតុលើផ្លូវច្បាប់" មានន័យថា គ្មានមូលហេតុត្រឹមត្រូវសម្រាប់រក្សាផលប្រយោជន៍។ វាគឺជារឿងមិនសមហេតុផល ដែលអនុញ្ញាតឱ្យបុគ្គលដែលមិនមានមូលហេតុគតិយុត្ត ក្នុងការទទួលបានផលប្រយោជន៍អាចរក្សាទុកនូវផលប្រយោជន៍ដែលបានទទួលពីភាគីម្ខាងទៀត ដែលបាត់បង់ផលប្រយោជន៍នោះ។

នៅក្នុងករណីទី ១ ក បានលុបចោលកិច្ចសន្យាជាមួយ ខ ដោយសារការឆបោក។ នៅក្នុងករណីនេះ ក គ្មានមូលហេតុគតិយុត្ត ក្នុងការរក្សាទុកនូវប្រាក់ចំនួន ១០.០០០ ដុល្លារ ដែល ខ បានបង់ ហើយ ខ ក៏មិនមានមូលហេតុរក្សាទុកនូវរថយន្តដែល ក បានប្រគល់នោះដែរ។ ដូច្នេះ ក មានករណីយកិច្ចសងលុយចំនួន ១០.០០០ ដុល្លារ ឱ្យ ខ វិញ ហើយ ខ ត្រូវប្រគល់រថយន្តឱ្យ ក វិញដែរ។

នៅក្នុងករណីទី ២ ខ បានយករថយន្តដែល ក ចតនៅក្នុងដីឡូតិ៍មួយកន្លែង ប្រើប្រាស់អស់រយៈពេល ១ ខែ។ គ្មានបុគ្គលណាម្នាក់អាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ខណៈពេលដែលម្ចាស់សិទ្ធិមិនមានឆន្ទៈឱ្យប្រើ ឬ ចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនទាល់តែសោះ។ ដូចនេះ មានន័យថា ខ ខ្វះនូវមូលហេតុគតិយុត្តក្នុងការទទួលបាននូវផលប្រយោជន៍ ដែលជាការប្រើប្រាស់រថយន្តរបស់ ខ។ ជាលទ្ធផល ខ ត្រូវសងថ្លៃជាការប្រើប្រាស់រថយន្តក្នុងរយៈពេល ១ ខែ ឱ្យទៅ ក។

## ៣. អានុភាព

អានុភាពសំខាន់ គឺការលើកឡើងនូវកាតព្វកិច្ចក្នុងការសងផលប្រយោជន៍។ ប៉ុន្តែ ទំហំនៃការសងគឺខុសគ្នា យោងទៅតាមស្ថានភាពជាអត្តនោម័តរបស់បុគ្គលដែលទទួលផលប្រយោជន៍។

### ៣.១. បទប្បញ្ញត្តិទូទៅ

ជាគោលការណ៍ទូទៅ ទំហំនៃការសង គឺត្រូវកម្រិតត្រឹមទំហំដែលផលប្រយោជន៍មាន។ មូលហេតុ ដែលនាំឱ្យមានការកម្រិតទំហំនៃការសង គឺដោយសារថាជាញឹកញាប់បុគ្គលដែលបានទទួលផលប្រយោជន៍ តែងតែប្រើប្រាស់ផលប្រយោជន៍នោះ ហេតុនេះវាស្តែងឱ្យឃើញថាមានភាពអយុត្តិធម៌ ប្រសិនបើបុគ្គលដែលបានទទួលផលប្រយោជន៍ត្រូវសងផលប្រយោជន៍ទាំងអស់ នៅពេលដែលបុគ្គលនោះប្រើប្រាស់ផលប្រយោជន៍នោះដោយមិនបានដឹង ឬ ដោយគ្មានកំហុស អំពីភាពគ្មានមូលហេតុលើផ្លូវច្បាប់ (មាត្រា ៧៣៦ កថាខណ្ឌទី ១)។

បញ្ហាបន្ទាប់មកទៀត គឺរបៀបកំណត់ថាតើផលប្រយោជន៍នោះ មាន ឬ អត់។ ចំពោះបញ្ហាថាតើផលប្រយោជន៍មាន ឬ គ្មាន គឺអាស្រ័យទៅលើការវិនិច្ឆ័យរបស់តុលាការ។ ប៉ុន្តែជាឧទាហរណ៍ ក្នុងករណីទាក់ទងនឹង

ផលប្រយោជន៍ជាប្រាក់វិញ ទោះបីជាផលប្រយោជន៍ដើមដែលទទួលបានត្រូវបាត់បង់ ឬ ប្រើប្រាស់អស់ក៏ដោយ ក៏ការបាត់បង់នេះ ជូនកាលអាចបណ្ដាលឱ្យបុគ្គលនោះទទួលបានផលប្រយោជន៍ថ្មី។ ហេតុនេះ ផលប្រយោជន៍ត្រូវបានចាត់ទុកថាបានផ្ទេរ ហើយនៅតែមានដដែលនៅក្នុងករណីបែបនោះ។

**ឧទាហរណ៍ :**

**១- ក** និង **ខ** បានបង្កើតកិច្ចសន្យាមួយដែល **ក** ត្រូវលក់គ្រឿងអលង្ការទៅឱ្យ **ខ**។ **ក** បានប្រគល់គ្រឿងអលង្ការ ហើយ **ខ** បានបង់ថ្លៃលក់ចំនួន ១០.០០០ ដុល្លារ។ បន្ទាប់មក **ក** បានលុបកិច្ចសន្យានោះចោល ដោយសារតែសមត្ថភាពរបស់គាត់ត្រូវបានកម្រិត (ជននៅក្រោមអាណាព្យាបាលទូទៅ) រហូតដល់ពេលកិច្ចសន្យាត្រូវបានលុប **ក** បានទិញភាគហ៊ុនចំនួន ១០.០០០ ដុល្លារ ដូច្នេះ តើផលប្រយោជន៍មានដែរ ឬ អត់?

**២-** នៅក្នុងករណីទី ១ **ក** បានបង់ថ្លៃឈ្នួលរបស់គាត់ចំនួន ១០០ ដុល្លារ ពីការបង់រហូតដល់ពេលលុបចោលកិច្ចសន្យាដែលមានន័យថា គាត់អាចសង្គ្រោះនូវទ្រព្យសម្បត្តិដើមរបស់គាត់បាន។ តើផលប្រយោជន៍មាន ឬ អត់?

**៣-** នៅក្នុងករណីទី ១ **ក** បានធ្វើពិធីជប់លៀងមួយ ដែលចំណាយប្រាក់យ៉ាងខ្ជះខ្ជាយ (គាត់មិនអាចធ្វើពិធីជប់លៀងបានទេ បើសិនជាគាត់មិនបានទទួលនូវការបង់ប្រាក់)។ តើផលប្រយោជន៍មានដែរ ឬ អត់?

**ចម្លើយ :**

**ឧទាហរណ៍ ១** នៅក្នុងករណីនេះ **ក** បានបាត់បង់នូវផលប្រយោជន៍ដើមដែលជាប្រាក់ ប៉ុន្តែគេបានចាត់ទុកថាបានប្ដូរទៅជាភាគហ៊ុន។ ហេតុដូច្នេះ គេអាចចាត់ទុកថាមានផលប្រយោជន៍។

**ឧទាហរណ៍ ២** ទោះជា **ក** បានបាត់បង់ផលប្រយោជន៍ ដោយសារ **ក** បានបង់ថ្លៃឈ្នួលក៏ដោយ ក៏ **ក** អាចសង្គ្រោះទ្រព្យសម្បត្តិដើមរបស់គាត់បានដែរ។ ហេតុនេះផលប្រយោជន៍ ត្រូវបានចាត់ទុកថានៅតែមាន។

**ឧទាហរណ៍ ៣** នៅក្នុងករណីនេះ ផលប្រយោជន៍អាចត្រូវបានចាត់ទុកថាបានបាត់បង់ ដោយសារផលប្រយោជន៍ត្រូវបានចំណាយ ហើយបាត់បង់ទាំងអស់។

### ៣.២. បញ្ញត្តិពិសេសនៅក្នុងករណីទុច្ចរិត

ក្នុងករណីបុគ្គលដែលបានទទួលផលប្រយោជន៍ បានដឹងថាគ្មានមូលហេតុលើផ្លូវច្បាប់ ឬ ដឹងថាកិច្ចសន្យានោះ ពុំមានអានុភាព បុគ្គលដែលបានទទួលផលប្រយោជន៍នោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ដែលមាននៅពេលដែលបានដឹង និង ការប្រាក់ គិតចាប់ពីពេលបានដឹងរហូតដល់ពេលសង (មាត្រា ៧៣៧ កថាខណ្ឌទី១)។ ជាទូទៅ ទំហំនៃការសងត្រូវបានកម្រិត គឺដើម្បីការពារបុគ្គលដែលបានទទួលផលប្រយោជន៍ដោយមិនបានដឹង។ ប៉ុន្តែ ប្រសិនបើបុគ្គលដែលបានទទួលផលប្រយោជន៍បានដឹងថា ផលប្រយោជន៍ដែលខ្លួនទទួលបាន គ្មានមូលហេតុលើផ្លូវច្បាប់ នោះយើងអាចនិយាយបានថា ជននោះបានដឹងថាផលប្រយោជន៍នោះជារបស់អ្នកដទៃ ហើយវាគឺមិនមានភាពចាំបាច់ដើម្បីការពារជននោះទេ។ ដូច្នេះ ទំហំនៃការសងមិនត្រូវបានកម្រិតឡើយ ហើយជននោះត្រូវសង

ផលប្រយោជន៍ទាំងអស់ដោយភ្ជាប់ជាមួយនឹងការប្រាក់ ចាប់ពីពេលដែលបានដឹងថាខ្លួនគ្មានមូលហេតុលើផ្លូវច្បាប់ ចំពោះផលប្រយោជន៍ដែលខ្លួនបានទទួល ។

បុគ្គលដែលបានទទួលផលប្រយោជន៍ មានចេតនា ឬ កំហុស ចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបានបាត់បង់ បុគ្គលដែលបានទទួលផលប្រយោជន៍នោះមានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ដោយភ្ជាប់ជាមួយនឹងការប្រាក់ ( មាត្រា ៧៣៧ កថាខណ្ឌទី ២) ។

**ឧទាហរណ៍ :** នៅពេលដែលបុគ្គលម្នាក់បានដឹងថា កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈ បុគ្គលនោះត្រូវសងជាទំហំនៃផលប្រយោជន៍ទាំងអស់ដែលទទួលតាមរយៈកិច្ចសន្យានេះ ។

**ឧទាហរណ៍ :** កិច្ចសន្យាមួយត្រូវបានរំលាយ ឬ ត្រូវបានចាត់ទុកជាមោឃៈ ដោយសារកំហុសដោយចេតនា ឬ អចេតនា របស់ភាគីណាមួយជននោះ ត្រូវសងផលប្រយោជន៍ដែលខ្លួនទទួលបានទាំងអស់ ។

**ឧទាហរណ៍ : ក** បានឆបោក **ខ** ឱ្យធ្វើកិច្ចសន្យាមួយ ។ **ខ** សុំរំលាយកិច្ចសន្យាដើម្បីធ្វើឱ្យកិច្ចសន្យានោះបាត់បង់អានុភាព ហេតុនេះ **ក** ត្រូវទទួលខុសត្រូវចំពោះមោឃភាពនៃកិច្ចសន្យានោះ ហើយ **ក** ត្រូវសងផលប្រយោជន៍ដែលខ្លួនទទួលបានទាំងអស់ ។

## ៤. ករណីពិសេស

### ៤.១. ការសងដោយគ្មានកាតព្វកិច្ច

បុគ្គលដែលបានសងកាតព្វកិច្ចដែលខ្លួនគ្មាន ក្នុងករណីដឹងថាគ្មានកាតព្វកិច្ចនៅពេលសងនោះទេ បុគ្គលដែលបានសង មិនអាចទាមទារឱ្យសងតាវកាលិកនៃការសងនោះមកវិញបានឡើយ ( មាត្រា ៧៣៨ វាក្យខណ្ឌទី ២) ។ វាមិនសមហេតុផលទេក្នុងការដែលដឹងថាគ្មានកាតព្វកិច្ច ហើយនៅតែបំពេញកាតព្វកិច្ចនោះទៀត ។ ហេតុដូច្នេះច្បាប់ដាក់បន្ទុកទៅលើសកម្មភាពដែលមិនសមហេតុផលបែបនេះ ទោះបីជាអ្នកសងទទួលរងនូវការខាតបង់ដែលធ្វើឱ្យអ្នកដទៃទទួលបានផលប្រយោជន៍ក៏ដោយ ។

**ឧទាហរណ៍ : ក** បានសង **ខ** ចំនួន ១.00 ដុល្លារ ដោយ **ក** យល់ច្រឡំថា ខ្លួនជាកូនបំណុលរបស់ **ខ** ។ ដោយពិនិត្យទៅលើលក្ខខណ្ឌដែលបានកំណត់ក្នុងមាត្រា ៧៣៦ ទង្វើរបស់ **ក** បានបង្កើតឱ្យមានសេចក្ដីចម្រើនដោយឥតហេតុដោយហេតុថា :

**១-** **ខ** បានទទួលផលប្រយោជន៍ គឺប្រាក់ចំនួន ១.000 ដុល្លារ

**២-** **ក** បានបាត់បង់ប្រាក់ ១.000 ដុល្លារ

**៣-** **ខ** បានទទួលប្រាក់ពី **ក** ដោយគ្មានមូលហេតុលើផ្លូវច្បាប់ ព្រោះ **ក** មិនមែនជាកូនបំណុល

**៤-** **ខ** បានទទួលផលប្រយោជន៍ ដោយសារការបាត់បង់របស់ **ក**

ហេតុនេះ **ក** ហាក់បីដូចជាអាចទាមទារឱ្យសងតាវកាលិកនៃការសងពី **ខ** មកវិញបាន ។ តែមាត្រា ៧៣៨ វាក្យខណ្ឌទី ២ បានកំណត់ករណីលើកលែង ។ ដូចឧទាហរណ៍ទាំងបីខាងលើ បើ **ក** បានដឹងថាខ្លួនមិនមែនជាកូនបំណុល

ហើយនៅតែប្រគល់ប្រាក់ ១.០០០ ដុល្លារ ទៅ **ខ** ទៀត។ ដូច្នេះ **ក** មិនអាចទាមទារ **ខ** ឱ្យសងត្រឡប់មកវិញបានឡើយ។

កត់សម្គាល់ថា មាត្រា ៧៤០ ក៏អាចអនុវត្តបានចំពោះករណី ដែលមាត្រា ៧៣៨ វាក្យខណ្ឌទី ១ ត្រូវយកមកអនុវត្ត ប្រសិនបើអ្នកសងបានជឿដោយភាន់ច្រឡំថាកាតព្វកិច្ចរបស់អ្នកដទៃ គឺជាកាតព្វកិច្ចរបស់ខ្លួននោះ គាត់អាចទាមទារឱ្យសងត្រឡប់មកវិញ ប៉ុន្តែការសងនេះត្រូវបានកម្រិតដោយមាត្រា ៧៤០ គឺថាទោះបីជាការសងត្រូវបាន ធ្វើឡើងដោយភាន់ច្រឡំក្តីនោះ វាមានករណីលើកលែងដែលអ្នកសងមិនអាចទាមទារឱ្យប្រគល់មកវិញបានទេ។

### ៤.២. ការសងមុនកំណត់ពេល

ជាទូទៅ កូនបំណុលមិនបាច់សងរហូតដល់ពេលកំណត់ ព្រោះកូនបំណុលមានផលប្រយោជន៍នៃការកំណត់ពេល។ ប៉ុន្តែ ប្រសិនបើកូនបំណុលបានសងនៅមុនពេលកំណត់សង គឺចាត់ទុកថាកូនបំណុលបានសងកាតព្វកិច្ច ដោយបោះបង់នូវផលប្រយោជន៍នៃការកំណត់ពេល។ ដូច្នេះ ទោះបីជាកូនបំណុលបានសងកាតព្វកិច្ចមុនពេលកំណត់ក៏ដោយ ក៏កូនបំណុលមិនត្រូវបានអនុញ្ញាតឱ្យទាមទារការសងតាវកាលិកឡើយ (មាត្រា ៧៣៩ វាក្យខណ្ឌទី ១)។

ប៉ុន្តែ ក្នុងករណីដែលកូនបំណុលបានសងកាតព្វកិច្ច ដោយមិនបានដឹងថាកាតព្វកិច្ចមិនទាន់ដល់ពេលកំណត់សងនៅឡើយ កូនបំណុលអាចទាមទារឱ្យសងផលប្រយោជន៍ ដែលម្ចាស់បំណុលអាចប្រើប្រាស់តាវកាលិកដែលខ្លួនបានទទួលនៅមុនកាលកំណត់សងរហូតដល់ពេលកំណត់សងពីម្ចាស់បំណុលបាន។

**ឧទាហរណ៍ : ក** ខ្ចីលុយពី **ខ** ចំនួន ១.០០០ ដុល្លារ កំណត់ថ្ងៃសង គឺថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១១។ **ក** សងប្រាក់ **ខ** ចំនួន ១.០០០ ដុល្លារ នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១។

ក្រមរដ្ឋប្បវេណី មាត្រា ៧៣៩ ជាគោលការណ៍ **ក** មិនអាចទាមទារឱ្យ **ខ** ប្រគល់ប្រាក់ ដែលបានសងរួចហើយមកវិញបានឡើយ។ ប៉ុន្តែ នៅក្នុងករណី **ក** ជឿជាក់ដោយភាន់ច្រឡំថាដល់ពេលកំណត់សង ហើយក្រោយពេលសង ទើបបានដឹង។ នោះ **ក** អាចទាមទារឱ្យ **ខ** សងផលប្រយោជន៍ ដែលទទួលបានចន្លោះពេលមួយខែ ដែល **ខ** អាចប្រើប្រាស់ប្រាក់ ១.០០០ ដុល្លារនោះ (ដូចជា ការប្រាក់)។

### ៤.៣. ការសងកាតព្វកិច្ចអ្នកដទៃ

ក្នុងករណីដែលបុគ្គលក្រៅពីកូនបំណុល បានផ្តល់តាវកាលិកនៃការសងដោយភាន់ច្រឡំអំពីកាតព្វកិច្ចរបស់អ្នកដទៃថាជាកាតព្វកិច្ចរបស់ខ្លួន បុគ្គលនោះអាចទាមទារឱ្យសងតាវកាលិកនោះមកវិញបាន (មាត្រា ៧៤០ កថាខណ្ឌទី១)។ នៅក្នុងករណីខាងលើដែលបុគ្គលណាម្នាក់បានផ្តល់តាវកាលិកនៃការសងជាកាតព្វកិច្ចរបស់អ្នកដទៃ ម្ចាស់បំណុលនឹងទទួលបានផលប្រយោជន៍ ហើយបុគ្គលដែលបានផ្តល់តាវកាលិកនៃការសងនឹងបាត់បង់ផលប្រយោជន៍។ ហេតុនេះ ការទាមទារឱ្យសងការបាត់បង់ផលប្រយោជន៍នោះអាចត្រូវបានធ្វើឡើង ដែលជាសេចក្តីចម្រើនដោយឥតហេតុ វាគឺដូចទៅនឹងបញ្ញត្តិទូទៅដែរ។

ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលមិនបានដឹងអំពីការភាន់ច្រឡំរបស់អ្នកសងទេ ហើយបានបំផ្លាញភស្តុតាងជាឯកសារ ឬ បានបោះបង់ប្រាតិភោគចោលដោយជឿជាក់ថាជាការសងដែលមានសុពលភាព បុគ្គលដែលបានផ្តល់តាវកាលិកនោះ មិនអាចទាមទារឱ្យសងតាវកាលិកនោះមកវិញបានទេ ( មាត្រា ៧៤០ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ នេះគឺជាករណីលើកលែង ព្រោះប្រសិនបើការទាមទារឱ្យសងវិញត្រូវបានអនុញ្ញាតនោះ ម្ចាស់បំណុលត្រូវស្ថិតក្នុងស្ថានភាពលំបាកដែលត្រូវប្រគល់ផលប្រយោជន៍នឹងវិញ ហើយត្រូវទាមទារឱ្យកូនបំណុលសងដោយគ្មានភស្តុតាង ឬ ប្រាតិភោគ ។

នៅក្នុងករណីបែបនេះច្បាប់ការពារដល់ម្ចាស់បំណុល ហើយអ្នកសងមិនអាចទាមទារឱ្យប្រគល់តាវកាលិកនៃការសងនោះមកវិញបានទេ ព្រោះវាអយុត្តិធម៌សម្រាប់ម្ចាស់បំណុលដែលត្រូវទទួលបន្ទុកហានិភ័យដោយសារកំហុស ឬ ការភាន់ច្រឡំរបស់អ្នកដទៃ ។

សូមកត់សម្គាល់ថា ក្នុងករណីដែលអ្នកសងមិនអាចទាមទារឱ្យប្រគល់វិញបាន ការសងរបស់បុគ្គលនោះត្រូវបានចាត់ទុកថាជាការសងរបស់តតិយជន ( មាត្រា ៤៣៤ កថាខណ្ឌទី ១) ហើយបុគ្គលនោះអាចទាមទារឱ្យកូនបំណុលពិតប្រាកដ សងមកវិញបាន ( មាត្រា ៧៤០ កថាខណ្ឌទី ២) ។

**ឧទាហរណ៍ :** **ក** បានសងប្រាក់ ១០ ដុល្លារ ទៅ **គ** ។ ដោយ **ក** ច្រឡំថាប្រាក់ដែល **ខ** ជំពាក់ **គ** ១០០ ដុល្លារ ថាខ្លួនជាអ្នកជំពាក់ ។

ជាគោលការណ៍ទូទៅ **ក** អាចទាមទារ **គ** ប្រគល់ប្រាក់មកឱ្យខ្លួនវិញបាន ដោយសារការពិនិត្យទៅលើលក្ខខណ្ឌនៃការបង្កើតសេចក្តីចម្រើនដោយឥតហេតុ ។

**១-** **គ** បានទទួលប្រយោជន៍ ១០០ ដុល្លារ

**២-** **ក** បាត់បង់ប្រយោជន៍ ១០០ ដុល្លារ

**៣-** មិនមានមូលហេតុលើផ្លូវច្បាប់ព្រោះ **ក** មិនមានកាតព្វកិច្ចចំពោះ **គ** ដែលមានន័យថា វាគ្មានមូលហេតុលើផ្លូវច្បាប់ដែល **គ** ត្រូវទុកប្រាក់ ១០០ ដុល្លារនេះ ។

**៤-** **គ** ទទួលប្រយោជន៍ ដោយសារការបាត់បង់របស់ **ក**

ប៉ុន្តែ នៅក្នុងករណីដែល **គ** បំផ្លាញភស្តុតាងជាឯកសារ ឬ បោះបង់ចោលប្រាតិភោគ ដោយជឿជាក់ថាការសងរបស់ **ក** គឺជាការសងដោយមានសុពលភាពនោះ **ក** មិនអាចទាមទារឱ្យ **គ** ប្រគល់ប្រាក់មកឱ្យខ្លួនវិញបានឡើយ ( មាត្រា ៧៤០ កថាខណ្ឌទី ២) ។ ចំពោះករណីនេះ ទោះជា **ក** មិនអាចទាមទារឱ្យ **គ** ប្រគល់ប្រាក់មកវិញបាន ក៏ពិតមែនតែ **ក** អាចអនុវត្តសិទ្ធិទាមទារឱ្យសងពី **ខ** មកវិញបាន ( មាត្រា ៧៤០ កថាខណ្ឌទី ២) ។

## ៤.៤. ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់

ក្នុងករណីដែលការទាមទារឱ្យសងមកវិញ ដោយផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ ផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬ ច្បាប់ដែលទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈ ការទាមទារឱ្យសងរបៀបនេះមិនត្រូវបានអនុញ្ញាតឡើយ ( មាត្រា ៧៤១) ។

ភាពចាំបាច់ក្នុងការបដិសេធនូវការទាមទារឱ្យសងតាវកាលិក ដែលបានផ្តល់ក្នុងគោលបំណងធ្វើសកម្មភាពប្រឆាំងនឹងសង្គម គឺដើម្បីទប់ស្កាត់នូវសកម្មភាពផ្សេងៗដែលប្រឆាំងនឹងសង្គម ដោយការធ្វើឱ្យសកម្មភាពនោះទុកជាមោឃៈ ដើម្បីឱ្យអ្នកដែលបានធ្វើសកម្មភាពផ្តល់តាវកាលិកមិនមានលទ្ធភាពប្រមូលនូវសោហ៊ុយចំណាយនោះមកវិញបាន ។

នេះ គឺជាការឆ្លុះបញ្ចាំងនូវទស្សនៈនៃគោលការណ៍នៃភាពស្អាតស្អំ ដែលជាគោលការណ៍នៃភាពសុចរិត និង ស្មោះត្រង់ ហើយទប់ស្កាត់តុលាការមិនឱ្យផ្តល់ជំនួយផ្នែកច្បាប់ដល់អ្នកទាមទារទុច្ចរិត ។

ប៉ុន្តែ នៅក្នុងករណីខ្លះទោះបីជាតាវកាលិកណាមួយ ដែលត្រូវបានផ្តល់មានគោលបំណងប្រឆាំងនឹងសង្គមក៏ដោយតែជាក់ស្តែងអ្នកទទួលតាវកាលិកនោះប្រឆាំងនឹងសង្គម ច្រើនជាងអ្នកទាមទារឱ្យសងតាវកាលិកនោះទៅទៀត ហេតុនេះការបដិសេធនូវការទាមទារឱ្យសងតាវកាលិក នឹងជំរុញឱ្យមានសកម្មភាពប្រឆាំងនឹងសង្គមកាន់តែច្រើន។ ហេតុនេះការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការទាមទារឱ្យសងមិនមែនអាស្រ័យ ថាតើមូលហេតុនៃសេចក្តីចម្រើនដោយឥតហេតុប្រឆាំងនឹងសង្គមដែរឬអត់នោះទេ គឺអាស្រ័យទៅលើបញ្ហាថាតើការទាមទារឱ្យសងនោះប្រឆាំងនឹងសង្គមដែរ ឬ ទេ ហើយនេះមិនមែនជាបញ្ហាធម្មតានោះទេ។

**ឧទាហរណ៍ :**

**១-** **ក** និង **ខ** បានបង្កើតកិច្ចសន្យា ដែលមានខ្លឹមសារថា **ក** ត្រូវសម្លាប់ **គ** ដើម្បីបានប្រាក់ ធានារ៉ាប់រង ហើយ **ខ** ឱ្យរង្វាន់ ១.០០០ ដុល្លារ ទៅឱ្យ **ក** ហើយ **ខ** បានឱ្យ ១.០០០ ដុល្លារ ជាមុនរួចហើយ ។ មុនពេល **ក** សម្លាប់ **គ** គឺ **ខ** បានដាក់ពាក្យបណ្តឹងទាមទារឱ្យប្រគល់ប្រាក់ ១.០០០ ដុល្លារ មកវិញ ដោយផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ ព្រោះកិច្ចសន្យាសម្លាប់មនុស្សបែបនេះគឺជាកិច្ចសន្យាដែលគ្មានសុពលភាព ( មាត្រា ៣៥៤ កថាខណ្ឌទី ១) ។

**២-** នៅក្នុងករណីទី ១ តើវាយ៉ាងម៉េចទៅវិញ ប្រសិនបើកិច្ចសន្យាបែបនេះត្រូវធ្វើឡើងដោយការគំរាមកំហែងរបស់ **ក** ហើយ **ខ** ត្រូវបានគេបង្ខំឱ្យបង់ប្រាក់?

**ចំពោះករណីទី ១ :** កិច្ចសន្យារវាង **ក** រវាង **ខ** ត្រូវទុកជាមោឃៈ ដោយសារវាផ្ទុយនឹងច្បាប់ ។

ចំពោះការទាមទាររបស់ **ខ** បញ្ហា គឺនៅត្រង់ថា តើការទាមទាររបស់ **ខ** នេះ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អដែរ ឬ អត់?

ទី ១ តាមទស្សនៈនៃគោលការណ៍នៃភាពស្អាតស្អំ **ខ** ដែលបានទាមទារ គឺជាជនទុច្ចរិត ។ ហេតុនេះ **ខ** មិនអាចទាមទារឱ្យ **ក** ប្រគល់ប្រាក់ ១.០០០ ដុល្លារ នោះមកវិញបានទេ ។

ទី ២ តាមទស្សនៈនៃការទទួលស្គាល់ការទាមទារ គឺថា ត ដែលជាអ្នកបានទទួលតាវកាលិក ក៏ជាជនទុច្ចរិតផងដែរ ហេតុនេះប្រសិនបើ ខ មិនអាចទាមទារឱ្យ ត ប្រគល់ប្រាក់មកវិញបានទេ នោះវាអាចជំរុញឱ្យ ត ធ្វើសកម្មភាពប្រឆាំងនឹងសង្គមបន្ថែមទៀត។

ពោលគឺ ក្នុងករណីដែល ត មិនចាំបាច់សងប្រាក់ត្រឡប់វិញ នោះ ត អាចទទួលបានប្រាក់ដោយមិនបានធ្វើអ្វីមួយ ដោយប្រាប់គេថាគាត់អាចសម្លាប់មនុស្សដែលគេចង់សម្លាប់ដោយបង់លុយឱ្យគាត់ ១.០០០ ដុល្លារ តែគាត់មិនបានធ្វើអ្វីសោះ។

ហេតុនេះប្រសិនបើ ខ មិនអាចទាមទារឱ្យ ត ប្រគល់ប្រាក់មកវិញទេ នោះវាជំរុញឱ្យ ត ធ្វើរបៀបនេះបន្តទៀតដោយ ត អាចទទួលប្រាក់បានដោយមិនចាំបាច់ទទួលខុសត្រូវអ្វីទាំងអស់។ នៅក្នុងករណីនេះ វាគឺជាការជំរុញឱ្យមានសកម្មភាពប្រឆាំងនឹងសង្គមផងដែរ។

ដូចដែលបានឃើញ នេះមិនមែនជាបញ្ហាធម្មតានោះទេ ហើយខ្ញុំសូមបង្ហាញនូវដំណោះស្រាយមួយដែលអាចធ្វើបាន។ នៅក្នុងករណីនេះ ទោះបីជាការទាមទារត្រូវបានអនុញ្ញាតឱ្យធ្វើ ឬ មិនឱ្យធ្វើក៏ដោយ នៅតែមានបញ្ហាដដែល ប៉ុន្តែបញ្ហាក្រោយនេះ (ត អាចទទួលបានប្រាក់ដោយមិនបានធ្វើអ្វីសោះ) អាចត្រូវបានដោះស្រាយតាមរយៈនីតិវិធីព្រហ្មទណ្ឌ (ត អាចត្រូវបានគេដាក់ទោសដោយបទឧក្រិដ្ឋ)។ ដូច្នេះ ពាក់ព័ន្ធនឹងបញ្ហារដ្ឋប្បវេណីគោលការណ៍នៃភាពស្អាតស្អំសំខាន់ជាងនៅទីនេះ។

**ចំពោះករណីទី ២ :** ទោះបីជាកិច្ចសន្យានេះ កើតឡើងដោយសារការគំរាមកំហែងរបស់ ត ក៏ដោយ ក៏កិច្ចសន្យានេះមិនមានសុពលភាពទេ ព្រោះកម្មវត្ថុនៃកិច្ចសន្យាគឺឱ្យ ត សម្លាប់ គ។

សំណួរសួរថា តើ ខ អាចទាមទារឱ្យ ត ប្រគល់ប្រាក់មកវិញបាន ឬ ទេ ?

ស្ថានភាពគឺដូចគ្នាទៅនឹងករណីទី ១ ប៉ុន្តែនៅក្នុងករណីនេះ ខ ត្រូវបានគេទិតៀនតិចជាងករណីទី ១ ដូច្នេះការទាមទារទំនងជាត្រូវបានគេអនុញ្ញាតតាមទស្សនៈនៃគោលការណ៍នៃភាពស្អាតស្អំ។

# ផ្នែកទី ៣

## អំពើអនីត្យានុកូល

### ១. តើអ្វី គឺជាការទទួលខុសត្រូវខាងអំពើអនីត្យានុកូល?

អំពើអនីត្យានុកូល គឺជារបបឱ្យសងនូវសំណងនៃការខូចខាត ក្នុងករណីដែលបានបំពានទៅលើសិទ្ធិ ឬ ផលប្រយោជន៍របស់អ្នកដទៃ ដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា។ ដូចនេះ បុគ្គលដែលសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនត្រូវបានគេបំពានមានសិទ្ធិទាមទារនូវសំណងនៃការខូចខាតចំពោះចារី។

**ឧទាហរណ៍ :** ក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ **ក** បើកឡានទៅបុកផ្ទះ **ខ** បណ្តាលឱ្យបាក់ទ្វារផ្ទះ។ ដូចនេះ អំពើរបស់ **ក** ដែលបុកផ្ទះ **ខ** បណ្តាលឱ្យមានការខូចខាតនោះ គឺជាអំពើអនីត្យានុកូល ដូចនេះ **ខ** មានសិទ្ធិទាមទារសំណងនៃការខូចខាតពី **ក** វិញបាន។

អំពើអនីត្យានុកូល មានច្រើនបែបច្រើនយ៉ាងណាស់ ហើយមិនត្រឹមតែជាគ្រោះថ្នាក់ចរាចរណ៍ ឬ ការបង្ខូចបរិស្ថាន ឬ កំហុសក្នុងការព្យាបាលនោះទេ គឺនៅមានការបំពានលើផលចំណេញ (ការដណ្តើមអតិថិជនរបស់គេ) ការកាត់មុខយកកិច្ចសន្យាជាដើមផងដែរ។ ម្យ៉ាងវិញទៀត កម្មវត្ថុនៃសំណងនៃការខូចខាតមិនត្រឹមតែមានការខូចខាតផ្នែកទ្រព្យសម្បត្តិប៉ុណ្ណោះទេ មានរួមទាំងការខូចខាតខាងផ្លូវចិត្ត (ដែលហៅថាជំងឺចិត្ត) ផងដែរ។

### ២. ទស្សនៈជាមូលដ្ឋាននៃការទទួលខុសត្រូវខាងអំពើអនីត្យានុកូល

អំពើអនីត្យានុកូលតម្រូវឱ្យចារីសងសំណងការខូចខាតខាងសេដ្ឋកិច្ច និង ខាងផ្លូវចិត្ត ចំពោះជនរងគ្រោះដើម្បីទទួលបាននូវយុត្តិធម៌។ ការទទួលខុសត្រូវលើអំពើអនីត្យានុកូល គឺយោងទៅតាម**គោលការណ៍នៃការទទួលខុសត្រូវកំហុស** មានន័យថា នៅក្នុងសង្គមដែលមានសេរីភាព សេរីភាពខាងអំពើ ត្រូវបានធានា។ បុគ្គលម្នាក់ៗជាគោលការណ៍មិនត្រូវទទួលខុសត្រូវនោះទេ ហើយបុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវចំពោះលទ្ធផលដែលនឹងកើតមានឡើងពីសកម្មភាពដែលត្រូវបាន ឬ អាចត្រូវបានព្យាករទុកជាមុនបាន ក្នុងការបំពាននូវសិទ្ធិ ឬ ផលប្រយោជន៍របស់អ្នកដទៃ។ ចំពោះសកម្មភាពដែលមិនអាចព្យាករដឹងពីលទ្ធផលនៃសកម្មភាពនោះ ជាទូទៅច្បាប់មិនតម្រូវឱ្យទទួលខុសត្រូវនោះទេ ពីព្រោះវានឹងរារាំងដល់សកម្មភាពដោយសេរីទៅវិញ ដូចនេះជាទូទៅគោលការណ៍នៃអំពើអនីត្យានុកូលគឺមិនតម្រូវឱ្យមានការទទួលខុសត្រូវទេ ទោះបីជាមានការខូចខាតក៏ដោយ ប្រសិនបើអ្នកធ្វើសកម្មភាពនោះមិនធ្វើអំពើដោយមានកំហុសចេតនា ឬ កំហុសអចេតនានោះ (ករណីលើកលែងគឺទម្រង់ពិសេសមួយចំនួននៃអំពើអនីត្យានុកូល)។

**មាត្រា ៧៤២ នៃក្រមរដ្ឋប្បវេណី ចែងថា** *"នៅក្នុងជំពូកទី ១៦ (អំពើអនីត្យានុកូល) នេះអំពើដោយមានកំហុសចេតនា ឬ អចេតនា សំដៅទៅលើ អំពើដែលត្រូវនឹងចំណុចណាមួយខាងក្រោមនេះ :*

*ក- ធ្វើអំពើបំពានដោយព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយដោយទទួលយកការកើត*

*ឡើងនៃលទ្ធផលនោះ ។*

*ខ- ធ្វើអំពើដែល បើតាមប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬ បទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះ អាចព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ ។"*

តាមរយៈទស្សនៈនេះ ជនដែលបានធ្វើឱ្យអ្នកដទៃរងរបួសដោយគ្មានការប្រុងប្រយ័ត្នសមហេតុផលទេ ត្រូវទទួលខុសត្រូវចំពោះការរងរបួសនោះ ចំណែកឯគោលការណ៍នេះធ្វើឱ្យបុគ្គលម្នាក់ៗមុននឹងធ្វើសកម្មភាពអ្វីមួយត្រូវគិតពិចារណាឱ្យបានម៉ត់ចត់នូវសកម្មភាពរបស់ខ្លួន ដើម្បីជៀសវាងនូវការកើតឡើងនូវលទ្ធផលដែលអាចបង្កជាគ្រោះថ្នាក់ដល់អ្នកដទៃ។

## ៣. លក្ខខណ្ឌ

មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណីចែងពី **លក្ខខណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ :**

**១-** *បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ ។*

**២-** *បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើង ដោយសារមានករណីយកិច្ចធ្វើអំពើណាមួយតែមិនបានធ្វើអំពើនោះ ។*

**៣-** *ចំពោះកំហុសចេតនា ឬ កំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និង ការកើតឡើងនៃការខូចខាត និង ការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនោះ ត្រូវបញ្ជាក់បង្ហាញលើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀត ។*

យោងតាមមាត្រា ៧៤៣ លក្ខខណ្ឌនៃអំពើអនីត្យានុកូលទូទៅ គឺមានដូចខាងក្រោមនេះ :

ក- កំហុសចេតនា ឬ អចេតនា

ខ- ភាពខុសច្បាប់

គ- ការខូចខាត

ឃ- ទំនាក់ទំនងហេតុ និង ផល

### ៣.១. អំពើដោយកំហុសចេតនា ឬ កំហុសអចេតនា

#### ៣.១.១. កំហុសចេតនា

កំហុសចេតនានៅក្នុងប្រព័ន្ធនៃអំពើអនីត្យានុកូលរបស់កម្ពុជា គឺជាការព្យាករទុកជាមុននូវហេតុការណ៍ និង ការទទួលយកការកើតឡើងនៃលទ្ធផលនោះ។

| |
|---|
| **ក** និង **ខ** មានជម្លោះជាមួយគ្នា។ **ក** បានចាក់សម្លាប់ **ខ** ចំដើមទ្រូងដោយច្រឡោតខឹង។ |

សុភវិនិច្ឆ័យរបស់យើងអាចប្រាប់យើងថា **ក** សម្លាប់ **ខ** ***ដោយកំហុសចេតនា***។ ត្រូវហើយពិតប្រាកដណាស់ ប៉ុន្តែសូមធ្វើការសាកល្បងវិភាគ ដោយយោងទៅតាមពាក្យពេចន៍នៅក្នុងក្រមរដ្ឋប្បវេណី។

ក្នុងករណីនេះមនុស្សដែលមានការយល់ដឹងអាចព្យាករទុកជាមុនអំពីការស្លាប់ ប្រសិនបើបុគ្គលណាម្នាក់ យកកាំបិតចាក់ចំដើមទ្រូងរបស់បុគ្គលម្នាក់ផ្សេងទៀត។ ហេតុដូច្នេះនៅក្នុងករណីភាគច្រើន **ក** ត្រូវបានគេចាត់ទុក ថាបានព្យាករទុកជាមុន ហើយបានទទួលយកនូវលទ្ធផលនៃការស្លាប់នោះ។ នេះគឺជាករណីយ៉ាងសាមញ្ញមួយនៃ កំហុសចេតនា។

ប៉ុន្តែ ករណីលើកលែងក៏អាចមានផងដែរ ដែលថា **ក** មិនមែនជាអ្នកសម្លាប់ដោយកំហុសចេតនា។

**ឧទាហរណ៍ :** **ក** មិនអាចត្រូវបានគេចាត់ទុកថា មានកំហុសចេតនានោះទេ ករណីប្រសិនបើ **ក** មានវិបត្តិ ខាងស្មារតីយ៉ាងធ្ងន់ធ្ងរ ដូចជា ការភាន់វិញ្ញាណ ហើយមិនដឹងថាការចាក់ចំដើមទ្រូងបណ្តាលឱ្យស្លាប់នោះទេ។

#### ៣.១.២. កំហុសអចេតនា

កំហុសអចេតនា គឺជាការបំពានករណីយកិច្ចព្យាករទុកជាមុន និង ករណីយកិច្ចជៀសវាង ហើយករណីយ កិច្ចទាំងពីរនេះដាក់បន្ទុកលើភាគី តែនៅក្នុងករណីដែលការព្យាករទុកជាមុន និង ការជៀសវាងអាចមានតែប៉ុណ្ណោះ (ច្បាប់មិនដែលចាប់បង្ខំភាពអលទ្ធភាពនោះទេ)។

សូមពិចារណាអំពីករណីគ្រោះថ្នាក់ចរាចរណ៍ :

ក្នុងករណីនៃគ្រោះថ្នាក់ចរាចរណ៍ដែលកើតមានជាញឹកញាប់ ការបើករថយន្តបុកអ្នកថ្មើរជើង គឺមិនបាន បង្ហាញពីចេតនារបស់អ្នកបើកបរខក្នុងការបើកបុកសម្លាប់អ្នកថ្មើរជើងនោះទេ។ ប៉ុន្តែ វាអាចជាការធ្វេសប្រហែស របស់អ្នកបើកបរដែលមិនបានមើលទៅមុខនៅពេលដែលបើកមកដល់ផ្លូវសម្រាប់ថ្មើរជើងដើរ ដូចនេះវាអាចជាអំ ពើដោយកំហុសអចេតនារបស់អ្នកបើកបរ ព្រោះបើយើងពិចារណាពីទិដ្ឋភាពទូទៅក្នុងសង្គមវិញ យើងឃើញថាជា ទូទៅអ្នកបើកបរ នៅពេលបើកមកដល់ផ្លូវសម្រាប់ថ្មើរជើងដើរត្រូវប្រុងប្រយ័ត្ន ដោយសំឡឹងមើលថាតើមានមនុស្ស ដើរលើផ្លូវសម្រាប់ថ្មើរជើងដើរដែរឬទេ ដើម្បីជៀសវាងកុំឱ្យមានគ្រោះថ្នាក់កើតមានឡើង។ ចំពោះអង្គហេតុយើងវិញ ឃើញថា អ្នកបើកបរមិនបានប្រុងប្រយ័ត្នគ្រប់គ្រាន់ក្រឡេកមើលថា តើមានមនុស្សដើរលើផ្លូវសម្រាប់ថ្មើរជើងដើរ

នោះទេ គឺអ្នកបើកបរនោះមើលទៅខាងម្ខាងវិញដែលទង្វើនេះគឺជាការធ្វេសប្រហែសដែល អ្នកបើកបរអាចព្យាករទុកជាមុនថា ប្រសិនបើខ្លួនងាកមើលទៅម្ខាងដោយមិនមើលទៅមុខនោះ ហើយបើមានមនុស្សកំពុងដើរលើផ្លូវនោះ ខ្លួននឹងបុកមនុស្សនោះទេ។

### ៣.១.២.១. ករណីយកិច្ចត្រូវព្យាករទុកជាមុន

នៅក្នុងករណីភាគច្រើនវាមិនមានបញ្ហាធ្ងន់ធ្ងរនោះទេ អំពីលទ្ធភាពក្នុងការយល់ដឹងជាមុននោះ។ ប៉ុន្តែតាមការពិត គឺវាមានករណីលើកលែង។

សូមពិចារណាអំពីករណីលើកលែងដែលជាបញ្ហាស្មុគស្មាញ : រឿងក្តីខាងក្រោមនេះគឺជារឿងប្រឌិតដោយផ្អែកតាមរឿងក្តីជាក់ស្តែងដែលនៅក្នុងនោះករណីយកិច្ចត្រូវយល់ដឹងជាមុន គឺជាបញ្ហាមួយនៅក្នុងចំណោមបញ្ហាចម្បង។

អ្នកជំងឺដែលមានរោគបណ្តាលឱ្យឈាមក្រខន់ (P's) ធ្លាប់ត្រូវការផលិតផលឈាមដែលផលិតឡើងដោយឈាមមនុស្ស ដែលជាវិធីព្យាបាលមួយដែលមានសារៈសំខាន់។ ប៉ុន្តែជួនកាលផលិតផលឈាមដែលមិនកំដៅមួយចំនួនមានផ្ទុកដោយវីរុស AIDS កាលពីអតីតកាល ហេតុដូច្នេះហើយអ្នកជំងឺជាច្រើនបានឆ្លងកាត់មេរោគ AI-DS។ P's បានដាក់ពាក្យបណ្តឹងចំពោះអ្នកផ្តល់ផលិតផលឈាម (BPP) និង រដ្ឋាភិបាលជាសហបណ្តឹងដោយសំអាងថា (BPP) និង រដ្ឋាភិបាលត្រូវដឹងជាមុនថាផលិតផលឈាមគឺមានផ្ទុកមេរោគ AIDS ហើយត្រូវបញ្ចៀសនូវការចម្លងរោគរបស់ (P's) (BPP ត្រូវបញ្ឈប់នូវការផ្តល់ឈាម ហើយរដ្ឋាភិបាលត្រូវហាមឃាត់នូវផលិតផលឈាមដែលមិនបានកំដៅ)។(BPP) និង រដ្ឋាភិបាល បានអះអាងថាខ្លួនមិនអាចដឹងមុនទេ អំពីហានិភ័យនៃផលិតផលឈាមដែលមិនបានកំដៅ។ តាមពិត AIDS គឺជាជំងឺដែលទើបត្រូវបានរកឃើញថ្មី ហើយទាល់តែដល់ពេលកំណត់ណាមួយនោះ ទើបមនុស្សបានដឹងថាមានជំងឺនេះ និង ថាតើជំងឺនេះឆ្លងតាមវិធីណា។

តើលក្ខខណ្ឌបែបណាដែលលោក លោកស្រី តម្រូវឱ្យមានដើម្បីដឹងអំពីការទាមទាររបស់ P's?

**សូមកត់សម្គាល់ថា** រឿងក្តីនេះ រួមបញ្ចូលនូវបញ្ហាជាច្រើន ប៉ុន្តែសូមផ្តោតការយកចិត្តទុកដាក់តែទៅលើថាតើចុងចម្លើយមានកំហុសអចេតនាដែរ ឬ អត់។

ជាទូទៅ ដើម្បីទទួលស្គាល់ការទាមទាររបស់ P's ចាំបាច់ត្រូវធ្វើការបញ្ជាក់ថា ចុងចម្លើយគួរត្រូវបានដឹងជាមុន និង គួរតែបានបញ្ចៀសនូវលទ្ធផលផងដែរ។

នៅក្នុងករណីនេះ វាហាក់បីដូចជាងាយស្រួលក្នុងការបញ្ជាក់ថា (BPP) និង រដ្ឋាភិបាល គួរតែបានបញ្ចៀសនូវលទ្ធផលនៃការចម្លងរោគ AIDS ប៉ុន្តែការជៀសវាង គឺអាចធ្វើទៅបានតែក្នុងករណី ប្រសិនបើពួកគេបានព្យាករទុកជាមុន ឬ អាចព្យាករទុកជាមុនអំពីហានិភ័យនៃផលិតផលឈាម និង អាចប្រើប្រាស់ការព្យាបាលជំនួស (ផលិតផល

ឈាមដែលមានសុវត្ថិភាព និង ត្រូវបានកំដៅត្រូវបានបង្កើតឡើង ក្រោយពេលដែលបានដឹងអំពីហានិភ័យនៃផលិតផលឈាមដែលមិនបានកំដៅ) ។

ហេតុដូច្នេះ បញ្ហាគឺថាតើអាចដឹងអំពីបញ្ហានោះ ដែរ ឬ អត់ ហើយដឹងនៅពេលណា ។

ជាពិសេស P's ត្រូវធ្វើការបញ្ជាក់ថាចុងចម្លើយគួរតែបានដឹងថា ផលិតផលឈាមដែលមិនកំដៅមានផ្ទុកមេរោគ AIDS ហើយអាចចម្លងដល់អ្នកជំងឺ ។

ដូច្នេះលិខិតវេជ្ជសាស្ត្រជាច្រើនទាក់ទងនឹងលទ្ធភាព ឬ ឧទាហរណ៍ដែលអាចធ្វើឱ្យឆ្លងជំងឺ AIDS តាមរយៈឈាមដែលមិនកំដៅត្រូវបានធ្វើការស៊ើបអង្កេតនៅក្នុងនីតិវិធីបណ្តឹងដើម្បីធ្វើការបញ្ជាក់ពីពេលវេលាថា តើចាប់ពីពេលណាដែល BPP គួរតែអាចបានដឹងពីការប្រឈមមុខនឹងគ្រោះថ្នាក់នៃការប្រើប្រាស់ឈាម ។

ហើយនៅចុងបញ្ចប់ តុលាការបានធ្វើការបញ្ជាក់ពីពេលវេលាដែលចុងចម្លើយ អាចនឹងព្យាករបានពីការប្រឈមមុខនឹងគ្រោះថ្នាក់ក្នុងការប្រើប្រាស់ឈាម ដែលគឺពេលដែលការប្រឈមមុខនឹងមេរោគ HIV អាចត្រូវបានដឹងពីលិខិតវេជ្ជសាស្ត្រ ហើយផលិតផលឈាមដែលមានសុវត្ថិភាព និង ត្រូវបានកំដៅត្រូវបានគេរកឃើញ និង ដាក់ឱ្យប្រើប្រាស់ ។




### ៣.១.២.២. ករណីយកិច្ចត្រូវជៀសវាងកុំឱ្យកើតមាននូវលទ្ធផល

ករណីយកិច្ចជៀសវាងនេះ គឺស្ទើរតែជាន់គ្នាជាមួយនឹងភាពខុសច្បាប់ ព្រោះមូលហេតុដែលលទ្ធផលមួយចំនួនគួរត្រូវជៀសវាង នោះគឺដោយសារតែលទ្ធផលបែបនេះត្រូវបានចាត់ទុកថាជាលទ្ធផលអាក្រក់ ហើយអ្វីដែលអាក្រក់ ឬ មិនអាក្រក់នោះ គឺស្ទើរតែដូចគ្នានឹងអ្វីដែលខុសច្បាប់ ឬ មិនខុសច្បាប់នោះ ។

### ៣.១.២.៣. កម្រិតនៃករណីយកិច្ច

ថាតើករណីយកិច្ចព្យាករជាមុន និង ករណីយកិច្ចជៀសវាង ត្រូវបានបំពេញ ឬ អត់នោះ គឺត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋានមួយដោយប្រៀបធៀបថា តើបុគ្គលដែលមានវិជ្ជាជីវៈ ឬ បទពិសោធន៍ដូចគ្នានោះអាចព្យាករដឹងជាមុននូវលទ្ធផល ឬ អាចជៀសវាងនូវគ្រោះថ្នាក់បានដែរ ឬ ទេ ពោលគឺមិនមែនអ្នកដែលបានធ្វើសកម្មភាពដោយផ្ទាល់នោះអាចដឹងជាមុន ឬ អត់នោះទេ ។

ចូរពិចារណាមើលថា តើអ្វីដែលជាការលំបាកក្នុងការកំណត់ដោយផ្អែកលើមូលដ្ឋាននៃសមត្ថភាពជាក់ស្តែងរបស់អ្នកប្រព្រឹត្ត ប្រសិនបើមានការបំពានករណីយកិច្ចនោះ?

ផ្អែកលើមូលដ្ឋានខាងសមត្ថភាពរបស់អ្នកប្រព្រឹត្ត បុគ្គលដែលមានការប្រុងប្រយ័ត្នខ្ពស់ និង មានប្រាជ្ញាឆ្លាតវៃជាងគេគឺទំនងជាត្រូវទទួលខុសត្រូវ ព្រោះបុគ្គលនោះត្រូវបានគេចាត់ទុកថាមានសមត្ថភាពល្អដើម្បីព្យាករដឹងពីលទ្ធផលនៃអំពើប្រព្រឹត្តរបស់ខ្លួនជាមុន។ ផ្ទុយទៅវិញ ជនដែលជឿជាក់ និង ធ្វេសប្រហែស គឺទំនងជារួចផុតពីការទទួលខុសត្រូវ។

វាហាក់ដូចជាអយុត្តិធម៌ ហើយនឹងធ្វើឱ្យការដោះស្រាយបណ្តឹងចំណាយពេលវែងដោយមិនសមហេតុផល ព្រោះចៅក្រមត្រូវដឹងអំពីសមត្ថភាពពិតប្រាកដរបស់អ្នកប្រព្រឹត្តអំពើនៅក្នុងគ្រប់បណ្តឹងទាំងអស់។ ចៅក្រមត្រូវកំណត់ថាតើកម្រិតត្រឹមណាដែលសមរម្យ ឬ សមហេតុសមផល តាមរយៈការសម្រេចសេចក្តីជាច្រើន។

## ៣.២. ភាពខុសច្បាប់

ជាថ្មីម្តងទៀត ករណីយកិច្ចជៀសវាង គឺស្ទើរតែជាន់គ្នាជាមួយនឹងភាពខុសច្បាប់ ព្រោះមូលហេតុដែលលទ្ធផលមួយចំនួនគួរត្រូវជៀសវាង នោះគឺដោយសារតែលទ្ធផលបែបនេះត្រូវបានចាត់ទុកថាជាលទ្ធផលអាក្រក់ ហើយអ្វីដែលល្អ ឬ អាក្រក់ នោះគឺស្ទើរតែដូចគ្នានឹងអ្វីដែលខុសច្បាប់ ឬ មិនខុសច្បាប់នោះ។

សូមកត់សម្គាល់ថា ទោះបីជាអំពើអនីត្យានុកូលភាគច្រើន គឺជាបទឧក្រិដ្ឋក៏ដោយភាពខុសច្បាប់ គឺមិនចាំបាច់កម្រិតត្រឹមអំពើទាំងនោះទេ។

ខ្ញុំសូមផ្តល់ឧទាហរណ៍ ករណីនៅប្រទេសជប៉ុន។

**ឧទាហរណ៍ :** ប្រសិនបើបុគ្គលណាមួយសម្លាប់បុគ្គលមួយផ្សេងទៀតដោយចេតនា ការសម្លាប់បែបនេះត្រូវតែជាបទឧក្រិដ្ឋ ហើយអំពើអនីត្យានុកូលកើតមាននៅពេលជាមួយគ្នានោះដែរ ជាទូទៅនៅប្រទេសជប៉ុន។

នៅប្រទេសជប៉ុនឥឡូវនេះការបញ្ឆោតគឺមិនមែនជាបទឧក្រិដ្ឋទេ ប៉ុន្តែវានៅតែត្រូវបានគេចាត់ទុកថាជាអំពើអនីត្យានុកូល ចំពោះសហព័ទ្ធដែលត្រូវបានបោកបញ្ឆោតនោះ ព្រោះវាអាចបំពានដល់ជីវិតអាពាហ៍ពិពាហ៍ដ៏សុខសាន្តរបស់សហព័ទ្ធ។

ខ្ញុំដឹងថា ករណីអំពើអនីត្យានុកូលភាគច្រើន ត្រូវបានវិនិច្ឆ័យនៅក្នុងក្រមព្រហ្មទណ្ឌនៅកម្ពុជា ប៉ុន្តែថាតើវាជាបទឧក្រិដ្ឋ ឬ អត់ និង ថាតើវាជាអំពើអនីត្យានុកូល ឬ អត់ គឺជាសំណួរខុសគ្នា ហេតុដូច្នេះគឺត្រូវសម្រេចដាច់ដោយឡែកពីគ្នា។

ជាការពិតណាស់ ប្រជាពលរដ្ឋមានសិទ្ធិទទួលបាននូវការជំនុំជម្រះខាងរដ្ឋប្បវេណី។

### ៣.២.១. ទស្សនៈជាមូលដ្ឋាន

ផ្អែកតាមមាត្រា ៧៤៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី បានចែងថា " *បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ* "។

នៅទីនេះ ការបំពានដោយខុសច្បាប់ត្រូវបានយល់នៅក្នុងន័យទូលំទូលាយ។ ការបំពានដោយខុសច្បាប់មានន័យថា មិនត្រឹមតែការបំពានច្បាប់ព្រហ្មទណ្ឌតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអំពើផ្ទុយនឹងវិន័យសង្គម។ ដូច្នេះ ករណីយកិច្ចដែលត្រូវជៀសវាង គឺស្មើរតែជាន់គ្នាជាមួយនឹងភាពខុសច្បាប់ ព្រោះថាមូលហេតុដែលករណីយកិច្ចដែលត្រូវជៀសវាងនោះត្រូវបានដាក់បន្ទុក ពីព្រោះថាវាផ្ទុយទៅនឹងវិន័យសង្គម។

សូមកត់សម្គាល់ថា ទោះបីជាអំពើអនីត្យានុកូលភាគច្រើន គឺជាអំពើឧក្រិដ្ឋក៏ដោយ ក៏ភាពខុសច្បាប់ គឺមិនចាំបាច់កម្រិតត្រឹមអំពើឧក្រិដ្ឋទាំងនោះទេ។

**ឧទាហរណ៍ :** ប្រសិនបើបុគ្គលណាមួយសម្លាប់បុគ្គលមួយផ្សេងទៀតដោយកំហុសចេតនា ការសម្លាប់បែបនេះ គឺជាបទឧក្រិដ្ឋ ហើយក៏ជាអំពើអនីត្យានុកូលផងដែរ នៅក្នុងបរិបទរដ្ឋប្បវេណីនៅពេលជាមួយគ្នានេះ។ ផ្ទុយទៅវិញនៅប្រទេសជប៉ុនបច្ចុប្បន្ននេះ ការបោកបញ្ឆោតគឺមិនមែនជាបទឧក្រិដ្ឋទេ ប៉ុន្តែអំពើនេះត្រូវបានគេចាត់ទុកថាជាអំពើអនីត្យានុកូលក្នុងការបោកបញ្ឆោតសហព័ទ្ធនោះ ព្រោះវាអាចបំពានដល់ជីវិតអាពាហ៍ពិពាហ៍ដ៏សុខសាន្តរបស់សហព័ទ្ធនៅក្នុងបរិបទរដ្ឋប្បវេណី។

បទឧក្រិដ្ឋត្រូវបានវិនិច្ឆ័យនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ប៉ុន្តែ ថាតើអំពើនោះជាបទឧក្រិដ្ឋដែរ ឬ អត់ និង ថាតើអំពើនោះជាអំពើអនីត្យានុកូលដែរ ឬ អត់ គឺជាបញ្ហាដាច់ដោយឡែកពីគ្នា។

ចំពោះអំពើអនីត្យានុកូល ប្រជាពលរដ្ឋមានសិទ្ធិទទួលបាននូវការជំនុំជម្រះខាងរដ្ឋប្បវេណី ដាច់ដោយឡែកពីការជំនុំជម្រះរឿងព្រហ្មទណ្ឌជាពិសេស គឺនៅពេលដែលអំពើអនីត្យានុកូលមិនមែនជាបទល្មើសព្រហ្មទណ្ឌ។

### ៣.២.២. ការរួចផុតពីភាពផ្ទុយច្បាប់

ជាទូទៅ ការបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍ត្រឹមត្រូវរបស់ជនដទៃ ដោយកំហុសចេតនាក្តី ឬ កំហុសអចេតនាក្តីគឺជាអំពើផ្ទុយច្បាប់ ក៏ប៉ុន្តែ ប្រភេទនៃការបំពានមួយចំនួនមិនអាចចាត់ទុកថាផ្ទុយច្បាប់ទេ។ ដូច្នេះ មានករណីដែលការបំពានសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ មិនមែនជាអំពើផ្ទុយច្បាប់។ **ឧទាហរណ៍ :** ករណីដែលជនម្នាក់ត្រូវគេវាយប្រហារមកលើខ្លួនជាមុន ហើយជននេះបានការពារខ្លួនចំពោះការវាយប្រហារដោយបានធ្វើឱ្យអ្នកដែលវាយប្រហារនោះរងរបួសទៅវិញ នេះអាចចាត់ទុកថាជាករណីការការពារជាធម្មានុរូប។

ដូច្នេះ មានមូលហេតុមួយចំនួនដែលធ្វើឱ្យការបំពានសិទ្ធិ ឬ ផលប្រយោជន៍របស់អ្នកដទៃ មានភាពត្រឹមត្រូវតាមច្បាប់ដែលហៅថា "ការរួចផុតពីភាពផ្ទុយច្បាប់"។

មាត្រា ៧៥៦ នៃក្រមរដ្ឋប្បវេណី បានចែងអំពីមូលហេតុនៃការរួចផុតពីភាពផ្ទុយច្បាប់ ដែលកថាខណ្ឌទី ១ ចែងអំពី "*ការយល់ព្រមពីសំណាក់ជនរងគ្រោះ និង ការទទួលយកគ្រោះថ្នាក់*" កថាខណ្ឌទី ២ ចែងអំពី "*អំពើការការពារជាធម្មានុរូប និង អំពើដោយស្ថានភាពចាំបាច់*" និង កថាខណ្ឌទី ៣ មានចែងអំពី "*អំពើដែលសង្គមទទួលស្គាល់*" ដែលចំណុចទាំងអស់នេះនឹងពន្យល់ជាបន្តបន្ទាប់ ដូចខាងក្រោម ៖

### ៣.២.២.១. ការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់

ជាគោលការណ៍ ការយល់ព្រម និង ការទទួលយកនូវគ្រោះថ្នាក់របស់ជនរងគ្រោះ ធ្វើឱ្យការបំពានសិទ្ធិ ឬ ផលប្រយោជន៍មានលក្ខណៈស្របច្បាប់ ដោយហេតុថាបុគ្គលគ្រប់រូបមានសិទ្ធិចាត់ចែងនូវផលប្រយោជន៍របស់ខ្លួន ដោយសេរីរាប់បញ្ចូលទាំងការធ្វើឱ្យអន្តរាយផងដែរ។ ក៏ប៉ុន្តែ ការយល់ព្រម និង ទទួលយកខាងលើនេះអាចធ្វើទៅបានទាល់តែជនរងគ្រោះអាចចាត់ចែងនូវសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួន ដោយមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ។ ការយល់ព្រមចាត់ចែងនូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនរងគ្រោះ មិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អរបស់សង្គម។ **ឧទាហរណ៍ ៖** ការយល់ព្រមឱ្យកាត់កូនដៃរបស់ជនរងគ្រោះក្នុងក្រុមជនពាល (នេះគឺជាវិន័យជប៉ុននៅក្នុងសង្គមជនអន្ធពាលសម្រាប់ការសុំអភ័យទោស) គឺផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អរបស់សង្គម ហេតុនេះហើយអំពើនេះ មិនអាចរួចផុតពីភាពផ្ទុយច្បាប់ទេ។

ប៉ុន្តែ ប្រសិនបើការវះកាត់ខាងផ្នែកវេជ្ជសាស្ត្រដែលត្រូវការបច្ចេកទេសខ្ពស់ ហើយមានគ្រោះថ្នាក់គ្រូពេទ្យបានពន្យល់លម្អិតជាមុនពីស្ថានភាពនៃជម្ងឺរបស់ជនរងគ្រោះ និង វិធីសាស្ត្រក្នុងការព្យាបាល ហើយជនរងគ្រោះបានយល់ព្រមឱ្យគ្រូពេទ្យនោះវះកាត់ ក្រោយពីគ្រូពេទ្យធ្វើការវះកាត់ជនរងគ្រោះបានស្លាប់។ ចំពោះការវះកាត់ដែលបណ្តាលឱ្យស្លាប់ជនរងគ្រោះនេះ ជាទូទៅគ្រូពេទ្យរួចផុតពីភាពផ្ទុយច្បាប់ ។

### ៣.២.២.២. ការការពារជាធម្មានុរូប និង ស្ថានភាពចាំបាច់

ការការពារជាធម្មានុរូប និង ស្ថានភាពចាំបាច់ គឺមានលក្ខណៈស្រដៀងគ្នានឹងទស្សនៈដែលឆ្លើយតបគ្នានៅក្នុងករណីព្រហ្មទណ្ឌ។

#### ក. ការការពារជាធម្មានុរូប

ការការពារជាធម្មានុរូប គឺជាអំពើការការពារខ្លួនចំពោះអំពើបំពានដោយមិនត្រឹមត្រូវរបស់អ្នកដទៃ។ ការការពារជាធម្មានុរូបត្រូវស្របនឹងលក្ខខណ្ឌ ដូចខាងក្រោម ៖

១- អំពើបំពានដោយមិនត្រឹមត្រូវ

២- ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ របស់អ្នកដទៃ

៣- អំពើដែលមិនអាចជៀសវាងបាន

៤- ពេលវេលានៃអំពើបំពាន និង ពេលវេលានៃអំពើដែលធ្វើឱ្យគេរងគ្រោះនោះ ជិតគ្នា

៥- មានតុល្យភាពរវាងវិធីការពារខ្លួន និង កម្រិតនៃអំពើបំពាន

**ឧទាហរណ៍ :** **ត** បានហក់មកវាយ **ខ** (នេះ ជាអំពើបំពានមិនត្រឹមត្រូវ) ភ្លាមនោះ **ខ** បានវាយទៅលើ **ត** វិញដើម្បីការពារខ្លួនគាត់ (ដើម្បីការពារខ្លួនគាត់)។ ការវាយតបភ្លាមនេះធ្វើឡើងដោយប្រើដៃដូចគ្នា (ពេលវេលានៃការបំពាន និង ពេលវេលានៃអំពើដែលធ្វើឱ្យគេរងគ្រោះជិតគ្នា ហើយមានតុល្យភាពរវាងវិធីការពារខ្លួន និង កម្រិតនៃអំពើបំពាន)។ ដូច្នេះ ការវាយតបទៅវិញរបស់ **ខ** គឺជាការការពារជាធម្មានុរូបដែលអំពើបំពាននេះរួចផុតពីភាពផ្ទុយច្បាប់ ហើយវាមិនមែនជាអំពើអនីត្យានុកូលទេ។

ផ្ទុយទៅវិញ ក្នុងករណីប្រសិនបើ **ខ** បានវាយតបទៅលើ **ត** ក្រោយពេលបីថ្ងៃ ដើម្បីសងសឹកការវាយរបស់ **ខ** នេះខ្វះលក្ខខណ្ឌនៃពេលវេលាជិតគ្នា ហេតុដូច្នេះ គេមិនចាត់ទុកថាជាការការពារជាធម្មានុរូបនោះទេ។ និយាយម្យ៉ាងទៀត ការវាយប្រហាររបស់ **ត** និង **ខ** គឺខុសច្បាប់។

**ឧទាហរណ៍មួយទៀត :** ប្រសិនបើ **ខ** វាយបកទៅលើ **ត** វិញ ដោយកាំភ្លើងចំពោះការវាយប្រហាររបស់ **ត** ដោយដៃនោះ វាខ្វះនូវលក្ខខណ្ឌនៃតុល្យភាព ហេតុនេះវាក៏ខុសច្បាប់ដែរ។

**ខ. ស្ថានភាពចាំបាច់**

អំពើបំពានដោយស្ថានភាពចាំបាច់ គឺជាអំពើត្រឹមត្រូវតាមច្បាប់ដើម្បីការពារមនុស្សកុំឱ្យមានគ្រោះថ្នាក់។ អំពើបំពានដោយស្ថានភាពចាំបាច់ត្រូវស្របនឹងលក្ខខណ្ឌដូចខាងក្រោម :

**១-** មហន្តរាយបច្ចុប្បន្ន ឬ អច្ចាសន្ន

**២-** ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ របស់អ្នកដទៃ

**៣-** អំពើដែលធ្វើឱ្យគេរងគ្រោះដោយមិនអាចជៀសវាងបាន

**៤-** ពេលវេលានៃអំពើបំពាន និង ពេលវេលានៃគ្រោះថ្នាក់នោះជិតគ្នា

**៥-** មានតុល្យភាពរវាងវិធីការពារ និង កម្រិតនៃគ្រោះថ្នាក់

**ឧទាហរណ៍ :** ពេលមានអគ្គិភ័យ (មហន្តរាយបច្ចុប្បន្ន ឬ អច្ចាសន្ន) ដើម្បីការពារកុំឱ្យអគ្គិភ័យនោះ ឆ្លងរាលដាលទៅផ្ទះប្រជាជនផ្សេងទៀត (ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ របស់អ្នកដទៃ) ក្រុមពន្លត់អគ្គិភ័យបានកម្ទេចផ្ទះដែលនៅជាប់នឹងផ្ទះដែលឆេះនោះ (អំពើការពារដែលមិនអាចជៀសវាងបានពេលវេលានៃការបំពាន និង ពេលវេលានៃគ្រោះថ្នាក់នោះជិតគ្នា ហើយមានតុល្យភាពរវាងវិធីការពារ និង កម្រិតនៃគ្រោះថ្នាក់)។

ដូច្នេះភាពខុសគ្នារវាងការការពារជាធម្មានុរូប និង ការការពារដោយស្ថានភាពចាំបាច់ គឺការការពារជាធម្មានុរូប ដែលជាអំពើធ្វើឱ្យគេរងគ្រោះចំពោះអំពើបំពានមិនត្រឹមត្រូវ រីឯការការពារដោយស្ថានភាពចាំបាច់វិញ គឺជាអំពើបច្ចុប្បន្ន ឬ គ្រោះថ្នាក់អច្ចាសន្នមិនមែនមានតែអំពើបំពានមិនត្រឹមត្រូវប៉ុណ្ណោះទេ។

### ៣.២.២.៣. សកម្មភាពដែលសង្គមទទួលស្គាល់ថាសមហេតុផល

មាត្រា ៧៩៦ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី បានចែងថាចំពោះការខូចខាត ដោយសារអំពើដែលត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល អ្នកប្រព្រឹត្តអំពើបំពានមិនត្រូវទទួលខុសត្រូវឡើយ។ ប៉ុន្តែ អ្វីដែលជា

អំពើដែលសង្គមទទួលស្គាល់ថា សមហេតុផល និង អាចទទួលយកបាននោះ គឺមានលក្ខណៈពិបាកក្នុងការបញ្ជាក់ណាស់ ហើយបញ្ហានេះត្រូវអាស្រ័យទៅលើអត្ថន័យនៃភាពយុត្តិធម៌នៅកម្ពុជា។

ជាទូទៅ អំពើដែលបណ្តាលឱ្យមានការខូចខាត នៅក្នុងប្រភេទកីឡាប៉ះគ្នាមួយចំនួន ដូចជា កីឡាប្រដាល់ ឬ កីឡាបាល់ឱប អាចត្រូវបានចាត់ទុកថាជាសកម្មភាពដែលសង្គមទទួលស្គាល់ថាសមហេតុផល។

## ៣.៣. ការខូចខាត

ចំណាត់ថ្នាក់នៃការខូចខាត គឺមានដូចខាងក្រោមនេះ ៖

- ការខូចខាត
  - ការខូចខាតដែលជាទ្រព្យសម្បត្តិ
    - ចំណាយជាក់ស្តែង
    - ផលប្រយោជន៍ដែលបាត់បង់
  - ការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ

ការខូចខាតដែលជាទ្រព្យសម្បត្តិ ត្រូវបានបែងចែកជាពីរ ៖ ទី ១ គឺសោហ៊ុយជាក់ស្តែង ដែលជនរងគ្រោះមិនអាចជួយបង់បានដោយសារអំពើអនីត្យានុកូល ដូចជា សោហ៊ុយព្យាបាល ហើយមួយទៀតគឺផលប្រយោជន៍ដែលបានបាត់បង់ ដូចជា ប្រាក់បៀវត្សរ៍ដែលត្រូវទទួលបាន ប្រសិនបើជនរងគ្រោះបន្តធ្វើការងារនៅក្នុងករណីដែលជនរងគ្រោះត្រូវបានគេបណ្តេញចេញ ដោយសារអំពើអនីត្យានុកូល។

ការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិដែលមានជាញឹកញាប់បំផុត (ឬ ប្រហែលជាមានតែមួយ) គឺការខូចខាតខាងផ្លូវចិត្ត ដែលតុលាការត្រូវធ្វើការវាយតម្លៃជាចំនួនទឹកប្រាក់ជាក់លាក់មួយចំនួន។

## ៣.៤. ទំនាក់ទំនងរវាងហេតុ និង ផល

ដើម្បីឱ្យជនណាម្នាក់ទទួលខុសត្រូវសងសំណងការខូចខាត លុះត្រាតែមានទំនាក់ទំនងហេតុផលរវាងអំពើ និង ការខូចខាតដែលបញ្ជាក់ថា ការខូចខាតនោះពិតជាកើតចេញពីអំពើអនីត្យានុកូលយ៉ាងពិតប្រាកដ ហើយអ្នកទាមទារការខូចខាតមានករណីយកិច្ចបញ្ជាក់អំពីកស្តុតាងនេះ។ **ឧទាហរណ៍ ៖ ក** បានប្តឹងទាមទារសំណងការខូចខាតដែលខ្លួនត្រូវរបួសដោយសារ **ខ**។ ក្នុងករណីនេះ **ក** ត្រូវធ្វើការបង្ហាញថា **ខ** ជាអ្នកបានធ្វើឱ្យខ្លួនរងរបួស ហើយបណ្តាលឱ្យមានការខូចខាត។ ប្រសិនបើការខូចខាតនោះ មិនបង្កឡើងដោយអំពើអនីត្យានុកូល អាចនិយាយម្យ៉ាងទៀតថា ការខូចខាតនឹងមិនត្រូវបានសងទេ។

## ៣.៥. សមត្ថភាពក្នុងការទទួលខុសត្រូវ

ជាគោលការណ៍ ក្រមរដ្ឋប្បវេណីផ្តល់នូវការការពារដល់ជនដែលមានសមត្ថភាពទាប ហើយដែលមិនអាចវិនិច្ឆ័យ និង ធ្វើសកម្មភាពតាមលក្ខណៈសមហេតុផលបាន។ ទាក់ទងនឹងការទទួលខុសត្រូវខាងអំពើអនីត្យានុកូល

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ឬ ជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី ត្រូវរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ។

ផ្ទុយទៅវិញ ច្បាប់តម្រូវឱ្យមានការទទួលខុសត្រូវជាពិសេសមួយ ពីអ្នកគ្រប់គ្រងដែលជាការសង្គ្រោះមួយដល់ជនរងគ្រោះ ។

### ៣.៥.១. អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ

ល្បឿននៃការលូតលាស់ គឺអាស្រ័យទៅតាមបុគ្គលនីមួយៗ ហេតុដូច្នេះហើយសមត្ថភាពអាចត្រូវបានកំណត់តាមករណីនីមួយៗ ។ មានន័យថា ទោះជាក្មេងដែលមានអាយុត្រឹម ១៣ ឆ្នាំ ក៏ដោយ ក៏អាចមានប្រាជ្ញាគ្រប់គ្រាន់ដើម្បីទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលបានដែរ ហើយជនដែលមានអាយុ ២១ ឆ្នាំ ក៏នៅតែអាចត្រូវការការការពារដោយសារតែខ្វះសមត្ថភាព ប៉ុន្តែដើម្បីធ្វើការបញ្ជាក់អំពីលក្ខណៈវិនិច្ឆ័យឱ្យបានច្បាស់ ច្បាប់បានបញ្ញត្តនូវលក្ខណៈវិនិច្ឆ័យយ៉ាងច្បាស់លាស់គឺអាយុ ។

ហេតុដូច្នេះ ជនរងគ្រោះមិនអាចអះអាងថា បុគ្គលមួយចំនួនដែលមានអាយុក្រោម ១៤ ឆ្នាំ ត្រូវទទួលខុសត្រូវនោះទេ ទោះបីជាបុគ្គលនោះ មានប្រាជ្ញាខ្ពស់មិនចាំបាច់ផ្តល់នូវការការពារក៏ដោយ ។

### ៣.៥.២. ជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី

ជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី ដែលអសមត្ថភាពយល់ដឹងផ្នែកច្បាប់ ត្រូវរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ក៏ដូចជាជនដែលមានអាយុកក្រោម ១៤ ឆ្នាំដែរ ។ ប៉ុន្តែ មិនដូចជនដែលមានអាយុក្រោម ១៤ ឆ្នាំនោះទេ ជនបែបនេះនៅតែទទួលខុសត្រូវ នៅក្នុងករណីដែលជននេះអសមត្ថភាពដោយកំហុសចេតនា ឬដោយកំហុសអចេតនា ។

**ឧទាហរណ៍ :** ករណីបើសិនជា **ក** បានដឹងថាគាត់នឹងប្រើហិង្សា ហើយទំនងជានឹងវាយនរណាម្នាក់នៅពេលដែលស្រវឹងស្រា ហើយជំនួសឱ្យបញ្ឈប់នោះ **ក** បានស្រវឹងដោយចេតនា ហើយបានធ្វើឱ្យ **ខ** ដែលជាអ្នកជូនដំណើររងរបួស **ក** មិនអាចអះអាងអំពីការរួចផុតពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ ទោះបីជាគាត់មានវិបត្តិផ្នែកបញ្ញាស្មារតីនៅពេលដែលវាយទៅលើ **ខ** ក៏ដោយ ។

### ៣.៥.៣. ការសង្គ្រោះជនរងគ្រោះ

ក្នុងករណីដែលជនណាម្នាក់ បានប្រព្រឹត្តអំពើអនីត្យានុកូល ប៉ុន្តែជននោះស្ថិតក្នុងស្ថានភាពអសមត្ថភាពនោះ អ្នកដែលមានករណីយកិច្ចត្រួតពិនិត្យ ត្រូវទទួលខុសត្រូវសងការខូចខាតលើអំពើបំពានរបស់អសមត្ថជនទាំងនោះ ។

មាត្រា ៧៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងអំពីការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យជាពីរ ដូចខាងក្រោម :

**ករណីទី ១ :** បុគ្គលដែលមានករណីយកិច្ច ដែលបានកំណត់ដោយច្បាប់ ក្នុងការត្រួតពិនិត្យអនីតិជនអាយុក្រោម ១៤ ឆ្នាំ ឬ បុគ្គលដែលស្ថិតនៅក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវ

ចំពោះអំពើរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មានករណីយកិច្ចត្រូវសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើងដោយអំពើបំពានរបស់បុគ្គលដែលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននោះ។

**ករណីទី ២ :** បុគ្គលដែលមានករណីយកិច្ច ដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជន អាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជន ចំពោះការខូចខាតរបស់អ្នកដទៃដែលកើតឡើងដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ។

ប៉ុន្តែ បុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យ ដែលទទួលខុសត្រូវក្នុងការសងការខូចខាត តាមករណីទី ២ ខាងលើនេះ អាចរួចខ្លួនពីការទទួលខុសត្រូវក្នុងការសងការខូចខាតបាន ដោយបញ្ជាក់បង្ហាញថាខ្លួនបានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី ឬ ដោយត្រឹមត្រូវហើយ។

## ៤. អានុភាព

### ៤.១. គោលការណ៍នៃសំណងការខូចខាតជាប្រាក់

យោងតាមខ្លឹមសារនៃមាត្រា ៧៥៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី បានចែងយ៉ាងច្បាស់លាស់ថា *ជាគោលការណ៍ សំណងនៃការខូចខាតត្រូវសងជាប្រាក់។* គោលការណ៍នេះ មានន័យថា ការខូចខាតដែលទទួលរងដោយជនរងគ្រោះត្រូវតែវាយតម្លៃជាទឹកប្រាក់ រួចហើយចារីត្រូវសងជាទឹកប្រាក់តាមចំនួនដែលបានគណនា។

ទន្ទឹមនឹងគោលការណ៍នៃសំណងការខូចខាតជាប្រាក់នេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តនូវករណីលើកលែងផងដែរ ប្រសិនបើមិនអាចទទួលបាននូវការសង្គ្រោះត្រឹមត្រូវដោយសំណងជាប្រាក់។ មាត្រា ៧៥៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី បានចែងអំពីវិធីសង្គ្រោះចំនួន ពីរយ៉ាងទៀត គឺ *ការធ្វើបដិទាន* និង *ការហាមឃាត់មិនឱ្យធ្វើអំពើណាមួយ*។ ជាក់ស្តែង ក្នុងករណីដែលមានការរំខានដែលបានបង្កឡើងដោយអ្នកជិតខាង សំណងការខូចខាតជាប្រាក់តែមួយមុខ ជួនកាលមិនមានលក្ខណៈគ្រប់គ្រាន់ឡើយ។ ហេតុដូច្នេះ ជនរងគ្រោះអាចទាមទារឱ្យហាមឃាត់មិនឱ្យធ្វើអំពើរំខាននោះ ដើម្បីបញ្ឈប់ការពង្រីកនូវការខូចខាតតទៅទៀត។ នេះគឺជាវិធីសង្គ្រោះដ៏សមរម្យសម្រាប់ករណីនៃការរំខានដែលបង្កឡើងដោយចារី។

ក្រៅពីនេះ ក្រមរដ្ឋប្បវេណីក៏បានផ្តល់នូវបទបញ្ញត្តិពិសេស អំពីករណីបរិហាកេរ្តិ៍ផងដែរ នៅត្រង់មាត្រា ៧៥៧ កថាខណ្ឌទី ៣ ដែលបានបញ្ជាក់ថា " *ចំពោះការបរិហាកេរ្តិ៍ ក្រៅពីសំណងការខូចខាត ជនរងគ្រោះអាចទាមទារវិធានការស្តារកិត្តិយសឡើងវិញ ដូចជា ការផ្សព្វផ្សាយសេចក្តីសុំអភ័យទោសជាសាធារណៈបាន* "។ ជាការពិត ការស្តារកិត្តិយស គឺជាការធ្វើបដិទានមួយក្នុងចំណោមការធ្វើបដិទានជាច្រើនទៀត ដែលមានចែងនៅក្នុងមាត្រា ៧៥៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីរួចហើយ។ ក៏ប៉ុន្តែ ទោះបីជាយ៉ាងដូច្នោះក្តី ក្រមរដ្ឋប្បវេណីបានផ្តល់នូវបទបញ្ញត្តិពិសេស ដូចមាត្រា ៧៥៧ កថាខណ្ឌទី ៣ ជាការបន្ថែមទៀត គឺក្នុងគោលដៅសម្របសម្រួលជាមួយនឹងសេរីភាពបញ្ចេញមតិ ឬ ជំនឿ បានសេចក្តីថា ការស្តារកិត្តិយសតាមរយៈការផ្សព្វផ្សាយនូវសេចក្តីសុំអភ័យទោសជាសាធារណៈ គឺជាវិធីសង្គ្រោះមួយដែលប៉ះពាល់តិចតួចដល់សេរីភាពក្នុងការបញ្ចេញមតិ ប្រៀបធៀបទៅនឹងវិធី

សង្គ្រោះផ្សេងពីនេះ។ លើសពីនេះទៅទៀត ការផ្សព្វផ្សាយនូវសេចក្តីសុំអភ័យទោសជាសាធារណៈ គឺជាវិធីដែលអាចអនុវត្តបានដោយការអនុវត្តជំនួស។

### ៤.២. ទំហំនៃការខូចខាត

ជាធម្មតា ការខូចខាតមាន ពីរប្រភេទ គឺ***ការខូចខាតលើទ្រព្យសម្បត្តិ*** និង ***ការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ***។ ការខូចខាតលើទ្រព្យសម្បត្តិ រួមបញ្ចូលនូវចំណាយជាក់ស្តែង (Actual cost) និង ការបាត់បង់ផលប្រយោជន៍ (Lost of benefit)។ ចំណែកឯការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ មានដូចជា ការឈឺចាប់ខាងផ្លូវចិត្ត ឬ ការថយចុះនូវការវាយតម្លៃ។ បញ្ហាដែលចោទឡើងសម្រាប់ការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ គឺការវាយតម្លៃ ឬ ការគណនាជាប្រាក់។ **ឧទាហរណ៍ដ៏សាមញ្ញមួយនៃបញ្ហានេះគឺថា** តើជីវិតមានតម្លៃប៉ុន្មាននៅក្នុងករណីដែលការខូចខាត គឺជាការបាត់បង់ជីវិតមនុស្ស។ បើទោះបីជាក់ស្តែង ជីវិតមានតម្លៃដ៏សែនលើសលុបមិនអាចធ្វើការគណនាបានក៏ដោយ ក៏ចៅក្រមត្រូវតែធ្វើការវាយតម្លៃជីវិតជាប្រាក់ ដើម្បីកំណត់ពីចំនួននៃសំណងដែលចារីត្រូវសងដែរ។

លើសពីនេះ បញ្ហាមួយទៀតដែលអាចចោទឡើងបានដែរគឺថា តើការខូចខាតត្រឹមទំហំណាដែលអាចទាមទារឱ្យចារីសងបាននោះ? ចំណុចនេះត្រូវបានហៅថា ***ទំហំនៃទំនាក់ទំនងហេតុ និង ផល*** ពោលគឺរបៀបនៃការវាយតម្លៃ ដោយកំណត់ថា តើវាគឺការខូចខាតដែលចារីត្រូវសងដែរ ឬ ទេ ដោយផ្អែកលើទំនាក់ទំនងហេតុ និង ផលរវាងអំពើ និង ការខូចខាតដែលបានកើតឡើង។

ដើម្បីសម្រួលដល់ការពិចារណាលើចំណុចទាំងពីរខាងលើនេះ សូមធ្វើការពិចារណាលើឧទាហរណ៍មួយដូចតទៅ:

**ក** បានធ្វើឱ្យ **ខ** ដែលជាក្មេងអាយុ ៩ ឆ្នាំ រងរបួសដោយកំហុសអចេតនា នៅក្នុងគ្រោះថ្នាក់ចរាចរណ៍មួយ។

ដោយសារតែ **គ១** ដែលជាឪពុករបស់ **ខ** បានដឹងពីគ្រោះថ្នាក់ ហើយបានធ្វើដំណើរត្រឡប់ពីការធ្វើជំនួញរបស់ខ្លួន។ គាត់បានចំណាយសោហ៊ុយលើការហោះហើរត្រឡប់មកវិញ ហើយគាត់ក៏បានបាត់បង់នូវឱកាសធ្វើជំនួញធំមួយ ដោយសារតែលុបចោលនូវការណាត់ជួបជាមួយអតិថិជន។ ក្រុមហ៊ុនរបស់គាត់បានក្ស័យធន ដោយសារតែការខកខានមិនបានជួបក្នុងកិច្ចការជំនួញលើកនេះ។

**គ២** ដែលជាម្តាយរបស់ **ខ** ក្រៀមក្រំចិត្តយ៉ាងខ្លាំង ហើយបានរលូតកូនថែមទៀត ដោយសារតែភាពស្មុគស្មាញតានតឹងខាងផ្លូវចិត្ត ដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍នេះ។ ប៉ុន្តែ **គ២** គឺជាមនុស្សដែលងាយនឹងទទួលរងនូវការវាយប្រហារខាងផ្លូវចិត្តណាស់ ហើយនេះគឺជាផ្នែកមួយផងដែរក្នុងការធ្វើឱ្យគាត់ក្រៀមក្រំចិត្តយ៉ាងខ្លាំង និង រលូតកូន។

**ខ** បានក្លាយជាមនុស្សរុក្ខជាតិអស់រយៈពេល ៣ ឆ្នាំ នៅក្នុងមន្ទីរពេទ្យ ហើយចុងក្រោយ **ខ** បានទទួលមរណភាព ដោយសារតែគ្រោះថ្នាក់ចរាចរណ៍នេះ និង ការព្យាបាលខាងផ្នែកវេជ្ជសាស្ត្រមិនត្រឹមត្រូវ។ **គ១** និង **គ២**

ជឿជាក់ថា ខ អាចនឹងចូលរៀននៅមហាវិទ្យាល័យបាន ហើយអាចរកប្រាក់បានច្រើនជាងមនុស្សធម្មតា ចំនួន ៣ ដង ដោយសារតែ ខ ជាក្មេងប្រុសដែលឆ្លាតណាស់ ។

ក្នុងករណីនេះ តើ ក ត្រូវសងអ្វីខ្លះ? ចំនួនប៉ុន្មាន?

ដោយផ្អែកលើសម្មតិកម្មខាងលើនេះ ការខូចខាតដែលអាចកើតមានឡើង គឺមានដូចតទៅ :

**១- ការខូចខាតលើទ្រព្យសម្បត្តិ**

- ចំណាយជាក់ស្តែង (Actual cost) រួមមាន : សោហ៊ុយព្យាបាលសម្រាប់ ខ សោហ៊ុយព្យាបាលសម្រាប់ គ២ សោហ៊ុយលើការហោះហើរ ដែល គ១ បានចំណាយដើម្បីវិលត្រឡប់មកមើលកូនប្រុសដែលទទួលរង គ្រោះថ្នាក់ ។

- ការបាត់បង់ផលប្រយោជន៍រួមមាន : ការបាត់បង់ផលប្រយោជន៍របស់ក្រុមហ៊ុន គ១ ដោយសារតែ ការបាត់បង់ឱកាសធ្វើជំនួញដ៏ធំ និង ការក្ស័យធនក្រុមហ៊ុន ព្រមទាំងការបាត់បង់នូវផលប្រយោជន៍ (ប្រាក់ចំណូល) ដែលអាចផ្តល់ដោយ ខ ប្រសិនបើ ខ នៅរស់រានមានជីវិត ។

**២- ការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ**

- ការឈឺចាប់ខាងផ្លូវចិត្តរបស់ ខ ដែលទទួលរង ដោយសារតែគ្រោះថ្នាក់ចរាចរណ៍ ។
- ការឈឺចាប់ខាងផ្លូវចិត្តរបស់ គ១ និង គ២ ដែលជាឪពុកម្តាយរបស់ ខ ។

យោងលើសម្មតិកម្មខាងលើនេះ យើងនឹងពិនិត្យមើលថា តើត្រូវគណនាការខូចខាតខាងលើនេះ ជាប្រាក់ យ៉ាងដូចម្តេច ហើយតើការខូចខាតណាមួយដែលមានទំនាក់ទំនងហេតុ និង ផល?

ប្រហែលជាមនុស្សជាច្រើនអាចព្រមព្រៀងទៅនឹងគំនិតដែលសោហ៊ុយសម្រាប់ព្យាបាល ខ ហើយការ ខូចខាតខាងសតិអារម្មណ៍របស់ ខ គ១ និង គ២ ត្រូវរួមបញ្ចូលទៅក្នុងចំណុចដែលត្រូវបានគេសងសំណង ។

ប៉ុន្តែ ចុះចំពោះសោហ៊ុយព្យាបាលសម្រាប់ គ២ សោហ៊ុយហោះហើររបស់ គ១ និង ការបាត់បង់ផល ប្រយោជន៍របស់ក្រុមហ៊ុន តើយ៉ាងណាវិញ? នេះ គឺជាបញ្ហាមួយដ៏លំបាកទាក់ទងទៅនឹងទំហំនៃសំណងការខូច ខាត ។

មួយផ្សេងទៀត មនុស្សជាច្រើនអាចឯកភាពទៅនឹងគំនិតដែលការខូចខាតខាងផ្លូវចិត្តរបស់ គ១ និង គ២ គឺត្រូវតែសង ប៉ុន្តែបញ្ហាគឺថា តើអ្នកប្រព្រឹត្តអំពើបំពានត្រូវសងចំនួនប៉ុន្មាន ។ នេះ គឺជាបញ្ហានៃការគណនា ហើយ ក៏ជាបញ្ហាមួយដ៏លំបាកផងដែរ ។

បញ្ហាទាំង ពីរយ៉ាងនេះ គឺជាបញ្ហាលំបាកនៅក្នុងរបៀបដែលមិនមានចម្លើយតែមួយប៉ុណ្ណោះនោះទេ ។ ប្រហែលជាចម្លើយអាចមានផ្សេងៗ ពីគ្នានៅក្នុងចំណោមបទដ្ឋានសង្គមខុសៗគ្នា ។ ហេតុដូច្នេះ បញ្ហានៅក្នុងប្រទេស កម្ពុជាត្រូវដោះស្រាយទៅតាមបរិបទនៃសង្គម ។

**៤.២.១. ការគណនាជាប្រាក់**

មាត្រា ៧៥៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី បានកំណត់នូវគោលការណ៍នៃការគណនាចំនួនទឹកប្រាក់ នៃការខូចខាតដូចតទៅ : *"ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតលើទ្រព្យសម្បត្តិ ដោយសារអំពើអនីត្យានុ-*

*កូល ភាពខុសគ្នារវាងស្ថានភាពនៃទ្រព្យសម្បត្តិដែលត្រូវបានសន្មតថានឹងមាន ប្រសិនបើគ្មានអំពើអនីត្យានុកូល និង ស្ថានភាពនៃទ្រព្យសម្បត្តិជាក់ស្តែង ក្រោយពេលដែលអំពើអនីត្យានុកូលបានកើតឡើង ត្រូវបានវាយតម្លៃដោយ ប្រើប្រាស់នូវស្ថិតិ និង ឯកសារផ្សេងទៀត* "។ តាមរយៈបទបញ្ញត្តិនេះ យើងឃើញថាក្រមរដ្ឋប្បវេណីបានយកវិធី ប្រៀបធៀបធ្វើជាមូលដ្ឋាននៃការគណនាចំនួនទឹកប្រាក់នៃការខូចខាត។

បន្ថែមពីលើនេះទៀត ក្រមរដ្ឋប្បវេណីបានផ្តល់នូវបទបញ្ញត្តិពិសេសសម្រាប់ជាមូលដ្ឋាននៃការគណនាចំនួន ទឹកប្រាក់នៃការខូចខាត។

ផ្អែកតាមមាត្រា ៧៥៩ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា "*នៅពេលដែលវត្ថុបានបាក់បែកដោយអំពើ អនីត្យានុកូល អ្នករងគ្រោះអាចទាមទារសំណង ដូចជា តម្លៃនៃវត្ថុដែលបាក់បែក ឬ សោហ៊ុយជួសជុលវត្ថុនោះ ជាអាទិ៍* "។ ឧបមាថា អំពើអនីត្យានុកូលបានធ្វើឱ្យរថយន្តមួយទទួលរងនូវការខូចខាត ហើយរថយន្តនោះមាន តម្លៃ ១.០០០ ដុល្លារ ក៏ប៉ុន្តែប្រសិនបើធ្វើការជួសជុលរថយន្តនោះ គឺអស់សោហ៊ុយត្រឹមតែ ៥០០ ដុល្លារ ប៉ុណ្ណោះ។ ក្នុងករណីនេះ តុលាការនឹងទទួលស្គាល់ការទាមទារសំណងត្រឹមតែ ៥០០ ដុល្លារ ដែលជាតម្លៃនៃការជួសជុលតែប៉ុណ្ណោះ ដោយយោងតាមខ្លឹមសារនៃមាត្រា ៧៥៩ នៃក្រមរដ្ឋប្បវេណី។ ជាងនេះទៅទៀត សម្រាប់ការបាក់បែកវត្ថុ ជាទូទៅ តុលាការមិនគួរគប្បីទទួលស្គាល់នូវការខូចខាតសតិអារម្មណ៍ទេ ព្រោះការបាក់បែកវត្ថុគឺជាការបាត់បង់នូវទ្រព្យ សម្បត្តិសុទ្ធសាធ ហើយសំណងនៃការខូចខាតនេះនឹងត្រូវបានទទួលមកវិញ នៅពេលដែលវត្ថុនោះត្រូវបានជួសជុលរួច ឬ នៅពេលដែលម្ចាស់កម្មសិទ្ធិ បានទទួលនូវវត្ថុថ្មីជាជំនួសរួចហើយនោះ។ ក៏ប៉ុន្តែ ក្នុងករណីដែលវត្ថុដែលបានបាក់ បែកនោះមានតម្លៃផ្ទាល់ខ្លួន ដូចជា អំណោយពីឪពុកម្តាយដែលបានទទួលមរណភាពទៅ ឬ អ្នកដែលជាទីស្រលាញ់ ជាដើម តុលាការក៏អាចទទួលស្គាល់នូវការខូចខាតសតិអារម្មណ៍ ដោយសារតែអំពើអនីត្យានុកូលបានដែរ។

ម្យ៉ាងវិញទៀត សម្រាប់ការខូចខាតដែលកើតឡើងដោយសារតែការបំពានលើរូបរាងកាយ មាត្រា ៧៦១ នៃក្រមរដ្ឋប្បវេណី បានរៀបរាប់អំពីការខូចខាត ដែលជនរងគ្រោះ អាចទាមទារសំណងបាន រួមមានដូចតទៅ :

- **ការខូចខាតលើទ្រព្យសម្បត្តិ**
  - សោហ៊ុយព្យាបាលដែលបានចំណាយហើយ
  - សោហ៊ុយព្យាបាលដែលប្រមាណថា នឹងត្រូវចំណាយនាពេលអនាគត
  - ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលកំពុងព្យាបាល
  - ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលអនាគត ដោយសារផលវិបាកដែលបន្សល់ក្រោយពី ការព្យាបាល ជាអាទិ៍។ ចំពោះចំណុចនេះពេលខ្លះ គឺមានការលំបាកនឹងគណនាពីចំនួនប្រាក់ចំណូលដែលអាច ទទួលបាន នៅពេលអនាគត ជាពិសេសនៅក្នុងករណីដែលជនរងគ្រោះមិនមានការងារធ្វើនៅពេលដែលអំពើ អនីត្យានុកូលបានកើតឡើង។ ត្រង់ចំណុចនេះ តុលាការនៃប្រទេសជប៉ុនជាទូទៅកំណត់យកស្ថិតិនៃប្រាក់ខែ របស់ប្រជាជនជប៉ុនដើម្បី ធ្វើការវាយតម្លៃអំពីប្រាក់ចំណូលដែលជនរងគ្រោះបានទទួល ប្រសិនបើជន រងគ្រោះមិនទទួលរងការខូចខាត។ មួយវិញទៀត តុលាការត្រូវពិចារណាលើកត្តាជាច្រើនផ្សេងទៀត ដើម្បី

គណនាពីការខូចខាតប្រភេទនេះ ដូចជា វិជ្ជាជីវៈ ការងារ ប្រវត្តិនៃការសិក្សាដែលអាចរំពឹងថានឹងទទួលបានជោគជ័យក្នុងវិជ្ជាជីវៈ និង គុណវឌ្ឍិក្នុងវិជ្ជាជីវៈជាដើម ។

**- ការខូចខាតសតិអារម្មណ៍ :** ក្នុងករណីនេះ ប្រាក់សំណងជំងឺចិត្ត នឹងត្រូវកំណត់ដោយផ្អែកតាមកម្រិតនៃការរងរបួស និង ផលវិបាកដែលបន្សល់ទុក ដោយរួមបញ្ចូលទាំងការឈឺចាប់ផ្នែកសតិអារម្មណ៍នៅពេលព្យាបាល និង ពេលអនាគតទៀតផង ។

ក្រៅពីនេះ ចំពោះការខូចខាតដែលកើតឡើងដោយសារតែការបំពានលើជីវិត មាត្រា ៧៦០ នៃក្រមរដ្ឋប្បវេណី បានកំណត់អំពីការខូចខាតដែលអាចទាមទារសំណងបានរួមមានដូចតទៅ :

- **ការខូចខាតដែលទទួលរងដោយអ្នករងគ្រោះផ្ទាល់**

- សោហ៊ុយព្យាបាល និង សោហ៊ុយចំណាយផ្សេងទៀតដែលជនរងគ្រោះបានបង់ ឬ មានករណីយកិច្ចត្រូវបង់ ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ។

- ប្រាក់ចំណូលដែលជនរងគ្រោះ មិនបានទទួលចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ជាអាទិ៍ ។

- **ការខូចខាតដែលទទួលរងដោយបុគ្គលដែលទទួលជីវព្រឹត្តិ**

- ចំនួនទឹកប្រាក់នៃជីវព្រឹត្តដែលបុគ្គលនេះ លែងបានទទួលតទៅទៀត ដោយសារតែមរណភាពនៃជនរងគ្រោះ ។

- សោហ៊ុយដែលចេញជំនួសជនរងគ្រោះ សោហ៊ុយធ្វើបុណ្យសពជាដើម ។

**- ការខូចខាតសតិអារម្មណ៍ :** យោងតាមមាត្រា ៧៦០ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី អ្នកដែលអាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើង ដោយសារតែមរណភាពនៃជនរងគ្រោះ រួមមានសហព័ទ្ធ ញាតិនៅក្នុង ១ ថ្នាក់ និង ញាតិដែលរស់នៅជាមួយជនរងគ្រោះ ។

ដោយឡែក សម្រាប់ការខូចខាតដែលកើតឡើង ដោយសារការបរិហារកេរ្តិ៍វិញ មាត្រា ៧៦២ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា " *បើមានការបរិហារកេរ្តិ៍ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ ដោយសារការអាប់ឱនកេរ្តិ៍ឈ្មោះក្នុងសង្គម* " ។

នៅក្នុងការគណនាអំពីចំនួនទឹកប្រាក់នៃសំណងជំងឺចិត្តសម្រាប់ការខូចខាតសតិអារម្មណ៍ រមែងតែចោទជាបញ្ហាយ៉ាងច្រើនសម្រាប់ចៅក្រម ។ ក៏ប៉ុន្តែទោះបីជាយ៉ាងនេះក្តី យុត្តិសាស្ត្ររបស់តុលាការនឹងធ្វើការកំណត់ទៅតាមករណីនីមួយៗ។ សូមធ្វើការកត់សម្គាល់ថា តុលាការនៃប្រទេសជប៉ុនមិនបានយកស្ថានភាពទ្រព្យសម្បត្តិរបស់ចារីដើម្បីធ្វើជាកត្តាកំណត់អំពីចំនួនទឹកប្រាក់នៃសំណងជំងឺចិត្ត សម្រាប់ការខូចខាតសតិអារម្មណ៍ឡើយ (ចារីមិនត្រូវបានគេបង្គាប់ឱ្យសងច្រើនដោយគ្រាន់តែគាត់ គឺជាអ្នកមានទ្រព្យសម្បត្តិច្រើននោះទេ) ។

### ៩.២.២. ទំហំនៃការខូចខាត

យើងត្រូវសិក្សាទៅលើអំពើអនីត្យានុកូលដែលកើតមានឡើង ព្រមទាំងបណ្តាលឱ្យមានការខូចខាត។ ការខូចខាតនេះ មានរួមទាំងការខូចខាតទ្រព្យសម្បត្តិ និង កាខូចខាតខាងផ្លូវចិត្តផង។ ដូច្នេះ ការបង្កើតសិទ្ធិទាមទារនូវសំណងនៃការខូចខាត ដោយអំពើអនីត្យានុកូលចំពោះជនរងគ្រោះ គឺមានចែងជាអាទិ៍ ក្នុងបញ្ញត្តិមាត្រា ៧៥៧ ៧៥៨ ៧៦០ និង មាត្រា ៧៦១ នៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែ បញ្ហាចម្បងគឺនៅត្រង់ថា តើអ្វីដែលជាទំហំនៃការខូចខាតសមហេតុផល? តើការខូចខាតជាក់លាក់ណា ត្រូវបានរាប់បញ្ចូលទៅក្នុងទំហំនៃសំណងនោះ? រាល់សំណួរខាងលើនេះ គឺជាបញ្ហាលំបាកដែលត្រូវដោះស្រាយតាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងករណីនីមួយៗ សម្រាប់ជាយុត្តិសាស្ត្រនាពេលអនាគតនេះ។ ម្យ៉ាងទៀត មាត្រា ៤០១ ស្តីពីទំហំនៃសំណងការខូចខាតក្នុងករណីបំពានករណីយកិច្ចអាចយកមកអនុវត្តស្រដៀងគ្នាទៅនឹងករណីនៃអំពើអនីត្យានុកូលផងដែរ។

ពោលគឺការខូចខាតអាចត្រូវបានបែងចែកជា ពីរគឺ :

ក- ការខូចខាតដែលកើតឡើងជាធម្មតា និង

ខ- ការខូចខាតពិសេស

ដោយផ្អែកលើទស្សនៈនេះ ការខូចខាតដែលកើតឡើងជាធម្មតា គឺត្រូវបានរាប់បញ្ចូលទៅក្នុងទំហំនៃសំណងនៃការខូចខាត ព្រោះវាយុត្តិធម៌ដែលការខូចខាតដែលបានកើតឡើង អាចត្រូវបានព្យាករទុកជាមុនយ៉ាងសមហេតុផលដោយភាគីដែលពាក់ព័ន្ធ នៅពេលដែលអំពើអនីត្យានុកូលកើតឡើង។ **ឧទាហរណ៍ :** នៅក្នុងករណីគ្រោះថ្នាក់ចរាចរណ៍រថយន្តជិះកៀវបុគ្គលម្នាក់តែបន្តិចបន្តួច ហើយបុគ្គលនោះមានឡើងនូវស្នាមជាំ។ នៅក្នុងករណីនេះ ការកើតមានឡើងនូវស្នាមជាំអាចត្រូវបានគេព្យាករទុកជាមុនយ៉ាងសមហេតុផលដោយភាគីដែលពាក់ព័ន្ធ ហេតុដូច្នេះការខូចខាតនេះ គឺត្រូវបានចាត់ទុកថាជាការខូចខាតធម្មតា។ ផ្ទុយទៅវិញ ពាក់ព័ន្ធនឹងការខូចខាតពិសេស ជាគោលការណ៍វាមិនមែនជាកម្មវត្ថុនៃសំណងទេ ពីព្រោះវាជាបន្ទុកមួយដ៏ធ្ងន់ធ្ងរណាស់ចំពោះចារីដើម្បីឱ្យទទួលខុសត្រូវសងសំណងដែលមិនអាចកើតមានឡើងនៅក្នុងករណីធម្មតា ប៉ុន្តែ កើតមានឡើងនៅក្នុងស្ថានភាពពិសេស ហើយគេចាត់ទុកថាចាំបាច់ត្រូវកម្រិតនូវទំហំនៃសំណងការខូចខាតនៅក្នុងករណីបែបនេះ។ នៅក្នុងករណីខាងលើ ប្រសិនបើជនណាម្នាក់បានស្លាប់ដោយគ្រាន់តែរថយន្តកៀវបន្តិចបន្តួច ដែលតាមធម្មតាមិនបណ្តាលឱ្យស្លាប់បាត់បង់ជីវិតនោះ ទេ តាមស្ថានភាពពិសេសដែលបុគ្គលមានជំងឺភ្នំរ៉ៃ វាមិនយុត្តិធម៌នោះទេដែលចារីត្រូវទទួលខុសត្រូវចំពោះការស្លាប់នោះ។ ប៉ុន្តែការខូចខាតពិសេសត្រូវបានគេសងនៅពេលដែលចារីអាចព្យាករទុកជាមុន ដោយឈរលើទស្សនៈយុត្តិធម៌ដូចជា ករណីដែលចារីដឹងអំពីជំងឺភ្នំរ៉ៃ នៅក្នុងឧទាហរណ៍នេះ។

គំនិតនេះត្រូវបានគេរិះគន់យ៉ាងខ្លាំង ហើយគំនិតមួយទៀត គឺគ្រាន់តែកំណត់ពីទំហំសមហេតុផលប៉ុនណាសម្រាប់អ្នកប្រព្រឹត្តអំពើបំពានក្នុងការសង មានលក្ខណៈសមហេតុផល ឬ អត់ តាមមូលដ្ឋាននៃរឿងក្តីនីមួយៗ។

ចំណុចនេះវាអាចមានសារៈប្រយោជន៍ ក្នុងការប្រមូលយុត្តិសាស្ត្រឱ្យបានកាន់តែច្រើន ដើម្បីឱ្យអាចរកឃើញនូវទំហំនៃសំណងការខូចខាតសមរម្យ។ និយាយម្យ៉ាងទៀត ការអនុវត្តគឺសំខាន់ជាងទ្រឹស្តី។

## ៤.៣. ការបន្ថយសំណងនៃការខូចខាត

យើងត្រូវសិក្សាលើទស្សនៈ ស្តីពីវិសាលភាពនៃសំណងការខូចខាត ដែលកើតចេញពីអំពើអនីត្យានុកូល ហើយត្រូវធ្វើការវាយតម្លៃជាប្រាក់នូវការខូចខាតនៃទ្រព្យសម្បត្តិ ឬ ការខូចខាតខាងផ្លូវចិត្តជាដើម ដែលតម្រូវឱ្យសងសំណង។ ប៉ុន្តែ មានករណីដែលចំនួនទឹកប្រាក់មួយចំនួនត្រូវកាត់បន្ថយពីសំណងការខូចខាត ដោយឈរលើទស្សនៈយុត្តិធម៌។ ការទូទាត់ប្រាក់ចំណេញ និង ខាតការទូទាត់នូវកំហុស គឺជាឧទាហរណ៍ដែលការកាត់បន្ថយនូវសំណងការខូចខាតត្រូវបានចាត់ទុកថាមានភាពចាំបាច់។

### ៤.៣.១. ការទូទាត់ប្រាក់ចំណេញ និង ខាត

មាត្រា ៧៦៣ បានចែងថា *"ប្រសិនបើជនរងគ្រោះ បានទទួលផលចំណេញដោយសារអំពើអនីត្យានុកូល ចំនួនប្រាក់ចំណេញនោះត្រូវដកចេញ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត "*។

ករណីនេះគឺមានភាពចាំបាច់ ពីព្រោះគោលបំណងនៃការទទួលខុសត្រូវខាងអំពើអនីត្យានុកូល គឺជាការទទួលបានមកវិញនូវអ្វីដែលបានបាត់បង់ពីការរងរបួស ចំពោះស្ថានភាពដែលត្រូវបានសន្មតថាមាន ប្រសិនបើអំពើអនីត្យានុកូលមិនបានកើតមានឡើង (ប្រៀបធៀបមាត្រា ៧៥៨)។ មានន័យថា ជនរងគ្រោះមិនត្រូវទទួលរងនូវការបាត់បង់ ឬ ទទួលផលចំណេញ បន្ទាប់ពីទទួលបានមកវិញហើយនោះទេ។

ឧទាហរណ៍ដែលកើតមានជាញឹកញាប់នៃការទូទាត់ប្រាក់ចំណេញ និង ខាត គឺសោហ៊ុយសម្រាប់ជីវភាពរស់នៅ។

នៅក្នុងករណីនៃការស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ សន្តតិជនរបស់ជនរងគ្រោះ អាចទាមទារសំណងការខូចខាត ចំពោះប្រាក់ដែលជនរងគ្រោះ អាចរកបាននៅពេលដែលមានជីវិតរស់នៅ ប្រសិនបើគ្មានគ្រោះថ្នាក់ចរាចរណ៍ ប៉ុន្តែ មិនមែនអាចទាមទារគ្រប់ចំនួនបានទេ ព្រោះជនរងគ្រោះអាចទទួលបានប្រាក់ឈ្នួល (ឧទាហរណ៍ ១០០ ដុល្លារ ក្នុងមួយខែ) ប៉ុន្តែ ជនរងគ្រោះ ក៏មិនអាចជួយចំណាយសោហ៊ុយសម្រាប់ជីវភាពរស់នៅទេ (ឧទាហរណ៍ ៣០ ដុល្លារ)។ ហេតុដូច្នេះ សោហ៊ុយសម្រាប់ជីវភាពរស់នៅបែបនេះត្រូវដកចេញ ដើម្បីកុំឱ្យសន្តតិជនរបស់ជនរងគ្រោះអាចទទួលផលប្រយោជន៍បានច្រើនជាងអ្វីដែលគាត់អាចទទួលបាន ប្រសិនបើអំពើអនីត្យានុកូលមិនបានកើតមានឡើងនោះ។

### ៤.៣.២. ការទូទាត់នូវកំហុស

មាត្រា ៧៦៤ បានចែងថា *"បើកំហុសរបស់ជនរងគ្រោះ ឬ កំហុសរបស់អ្នកដែលមានករណីយកិច្ចត្រូវត្រួតពិនិត្យជនរងគ្រោះ បានរួមចំណែកក្នុងការកើតឡើង ឬ រីករាលដាលនៃការខូចខាត តុលាការអាចគិតពិចារណានូវកម្រិតនៃការរួមចំណែកនោះ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត"*។

**ឧទាហរណ៍ :** បញ្ហាដែលកើតមានជាញឹកញាប់នៃការអនុវត្តមាត្រា ៧៦៤ នៅប្រទេសជប៉ុន គឺករណីគ្រោះថ្នាក់ចរាចរណ៍ ពីព្រោះស្ទើរតែគ្រប់គ្រោះថ្នាក់ចរាចរណ៍ បានកើតឡើងដោយសារតែកំហុសរបស់ភាគីច្រើន។

រថយន្តរបស់ **ក** និង កង់របស់ **ខ** បានបុកគ្នា។ ទាំងរថយន្ត និង កង់ គឺទទួលរងនូវការខូចខាតទាំងស្រុង ហើយតម្លៃខាងផ្នែកសេដ្ឋកិច្ចនៃរថយន្តរបស់ **ក** គឺមានចំនួន ១០.០០០ ដុល្លារ ហើយតម្លៃខាងផ្នែកសេដ្ឋកិច្ចនៃកង់របស់ **ខ** គឺមានចំនួន ១.០០០ ដុល្លារ។ ជាសំណាងល្អ ភាគីទាំងពីរមិនទទួលរងរបួសរាងកាយនោះទេ។

**ក** ដាក់ពាក្យប្តឹង **ខ** ទាមទារសំណងការខូចខាតចំពោះរថយន្តរបស់គាត់។ **ក** បានអះអាងថា **ខ** មានកំហុសអចេតនា ដោយសារតែ **ខ** បានមើលទៅម្ខាង។

**ខ** ក៏បានដាក់ពាក្យប្តឹង **ក** តបវិញ ទាមទារសំណងការខូចខាត ចំពោះកង់របស់គាត់ផងដែរ។ **ខ** បានអះអាងថា **ក** មានកំហុសដោយសារតែ **ក** បានបើករថយន្តលឿនពេក។

តុលាការបានរកឃើញថា កំហុសអចេតនារបស់ **ក** និង **ខ** បានរួមចំណែកក្នុងការកើតមានឡើងនូវគ្រោះថ្នាក់ចរាចរណ៍នេះ ហើយភាគរយនៃការរួមចំណែកក្នុងការកើតមានឡើងនូវគ្រោះថ្នាក់ចរាចរណ៍របស់ **ក** និង **ខ** គឺ ៣ ទល់នឹង ១។ តើតុលាការត្រូវបង្គាប់ឱ្យ **ក** និង **ខ** សងចំពោះគ្នាទៅវិញទៅមកចំនួនប៉ុន្មាន?

ចំណុចនៅក្នុងបញ្ញត្តិ គឺមានដូចខាងក្រោមនេះ :

មាត្រា ៧៦៤ បានចែងថា តុលាការ ***អាចពិចារណា*** ទៅលើកំហុស ប៉ុន្តែមិនមែនមានន័យថាតុលាការ ***ត្រូវ*** ធ្វើយ៉ាងដូច្នោះទេ។ ហេតុដូច្នេះ ប្រសិនបើការពិចារណាលើកំហុសត្រូវបានចាត់ទុកថា មិនមានភាពយុត្តិធម៌ទេ តុលាការមិនចាំបាច់ធ្វើយ៉ាងដូច្នោះនោះទេ។

**ឧទាហរណ៍ :** នៅប្រទេសជប៉ុន ប្រសិនបើភាគីម្ខាងបានធ្វើឱ្យភាគីម្ខាងទៀតទទួលរងរបួសដោយចេតនាជាទូទៅ យើងជាចៅក្រមជប៉ុនមិនពិចារណាទៅលើកំហុសរបស់ជនរងគ្រោះនោះទេ ពីព្រោះគិតថាវាមិនយុត្តិធម៌ទេក្នុងការធ្វើដូច្នោះ ក្នុងករណីនៃអំពើអនីត្យានុកូលដោយកំហុសចេតនា ទល់នឹងកំហុសអចេតនារបស់ជនរងគ្រោះ។

ប៉ុន្តែ ជាការពិតណាស់វាក៏ជាបញ្ហាមួយផងដែរនៅក្នុងចំណោមបញ្ហាជាច្រើន ដែលអាស្រ័យទៅលើការអនុវត្តនៅប្រទេសកម្ពុជា។

### ៩.៣.៣. មូលហេតុផ្សេងៗទៀត

មូលហេតុនៃការរួមចំណែករបស់ជនរងគ្រោះ គឺជាឧទាហរណ៍មួយ នៅក្នុងចំណោមឧទាហរណ៍ជាច្រើន ដែលមិនត្រូវបានចែងនៅក្នុងបញ្ញត្តិទេ ប៉ុន្តែត្រូវបានគេទទួលស្គាល់ថាជាការតវ៉ាទៅវិញនៅក្នុងយុត្តិសាស្ត្រនៃប្រទេសជប៉ុន។ ទស្សនៈនេះអាចមានភាពចាំបាច់នៅក្នុងករណីដែលមូលហេតុ (ប៉ុន្តែមិនមែនកំហុសអចេតនានោះទេ) ខាងជនរងគ្រោះបានរួមចំណែកក្នុងការកើតមានឡើងចំពោះលទ្ធផល។

## ៥. ទម្រង់ពិសេសនៃអំពើអនីត្យានុកូល

### ៥.១. សេចក្តីផ្តើម

ទម្រង់ទូទៅនៃការទទួលខុសត្រូវខាងអំពើអនីត្យានុកូល មិនមែនតម្រូវឱ្យមានតែការកើតឡើងនូវការខូចខាតតែប៉ុណ្ណោះទេ គឺតម្រូវឱ្យមានកំហុសចេតនា ឬ កំហុសអចេតនា ថែមទៀតផង ។

លក្ខខណ្ឌដែលតម្រូវឱ្យមានកំហុសចេតនា ឬ កំហុសអចេតនា អាចធានានូវសេរីភាពរបស់បុគ្គលឯកជន ព្រោះបុគ្គលម្នាក់មិនចាំបាច់ត្រូវទទួលខុសត្រូវចំពោះការខូចខាត សូម្បីតែនៅពេលដែលខ្លួនបានធ្វើឱ្យនរណាម្នាក់ទៀតរងរបួសក៏ដោយ ប៉ុន្តែខ្លួនបានធ្វើអំពើដោយប្រុងប្រយ័ត្នគ្រប់គ្រាន់ ហើយគ្មានកំហុសចេតនា ឬ កំហុសអចេតនានោះទេ ។

លើសពីនេះទៅទៀត បុគ្គលម្នាក់មិនទទួលខុសត្រូវចំពោះការខូចខាតដែលបានកើតឡើងដោយសារអ្នកដទៃ ដែលនេះឆ្លុះបញ្ចាំងពីបុគ្គលនិយមនោះទេ ។

បញ្ហាទាំងពីរនេះ គឺជាលទ្ធិមួយដែលមានសារៈសំខាន់ណាស់ ប៉ុន្តែជួនកាលបញ្ហាទាំងនេះធ្វើឱ្យមានការសន្និដ្ឋានមួយដែលមានភាពអយុត្តិធម៌ នៅក្នុងសង្គមទំនើបនេះ ហេតុដូច្នេះហើយត្រូវធ្វើការសម្របសម្រួល ។

**ករណីសិក្សា I :**

**ក** បានបើកក្រុមហ៊ុនមួយដែលមានស្តុកទុកនូវសារធាតុគីមី ដោយរួមមានសារធាតុពុលផងដែរ ។

ថ្ងៃមួយដោយសារតែរញ្ជួយដីដ៏ធំមួយ សារធាតុពុលមួយចំនួនបានលេចចេញមកក្រៅ ហើយបានធ្វើឱ្យអ្នកដែលរស់នៅជុំវិញនោះទទួលរងនូវសារធាតុពុល ។ អ្នកទទួលរងនូវសារធាតុពុល **ខ** ចង់ទាមទារសំណង ប៉ុន្តែ **ក** បានអះអាងថា ការរញ្ជួយដីដែលមិនអាចព្យាករទុកជាមុននេះបានបណ្តាលឱ្យមានការសាយភាយនូវសារធាតុពុលនោះ ដូច្នេះគាត់គ្មានទាំងកំហុសអចេតនា និង កំហុសចេតនា ចំពោះការសាយភាយនូវសារធាតុពុលនោះ ។

**ករណីសិក្សា II :**

**គ** បានជួលអ្នកបើករថយន្តតាក់ស៊ីជាច្រើននាក់មកធ្វើការឱ្យគាត់ ។ **ឃ** ដែលជាអ្នកបើកតាក់ស៊ីម្នាក់ នៅក្នុងចំណោមអ្នកបើកតាក់ស៊ីទាំងនោះបានបើកបុក **ខ** ដោយចៃដន្យ ។ **ខ** មានបំណងចង់ទាមទារសំណង ប៉ុន្តែ **ឃ** មិនមានទ្រព្យសម្បត្តិអ្វីនោះទេ ។ **គ** គឺជាអ្នកមាន និង ជាម្ចាស់បើកក្រុមហ៊ុនតាក់ស៊ី ប៉ុន្តែ **គ** បានបដិសេធនឹងមិនព្រមសងសំណងនោះទេ ព្រោះ **គ** មិនបានធ្វើឱ្យ **ខ** រងរបួស ហើយក៏គ្មានកំហុសអចេតនាទាល់តែសោះចំពោះគ្រោះថ្នាក់ចរាចរណ៍នោះ ។

ប្រសិនបើយើងប្រកាន់យកគំនិតដែលបានរៀបរាប់ខាងលើនេះ (បុគ្គលនិយម និង លក្ខខណ្ឌនៃកំហុសអចេតនា) **ខ** ឬ **ខ** មិនអាចទទួលបាននូវសំណងនោះទេ ចំណែកឯ **ក** និង **គ** វិញ រួចផុតពីការទទួលខុសត្រូវ ប៉ុន្តែវាមើលទៅហាក់បីដូចជាអយុត្តិធម៌ណាស់ ហើយក្រមរដ្ឋប្បវេណីបានផ្តល់នូវដំណោះស្រាយចំពោះបញ្ហានេះ ។ នោះគឺទម្រង់ពិសេសមួយចំនួននៃអំពើ ។

មូលហេតុដែលការរួចផុតរបស់ ត និង គ ត្រូវបានចាត់ទុកថាអយុត្តិធម៌ ប្រហែលមកពីមូលហេតុ ពីរយ៉ាង ដូចខាងក្រោមនេះ :

ទី ១ គឺថា ត បានបើកក្រុមហ៊ុនមួយរកស៊ីលក់វត្ថុដែលមានគ្រោះថ្នាក់ ហេតុដូច្នេះគាត់ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងចំពោះអ្នកដទៃ សូម្បីតែគ្មានកំហុសដែលរួមចំណែកដោយផ្ទាល់ក្នុងការកើតមាននូវគ្រោះថ្នាក់ក៏ដោយ ។

និយាយម្យ៉ាងទៀត នៅក្នុងករណីនេះ ត ត្រូវបានគេចាត់ទុកថាត្រូវទទួលខុសត្រូវដោយមិនមែនផ្អែកលើកំហុសអចេតនានោះទេ ប៉ុន្តែដោយផ្អែកលើការពិតដែលថាចារីរកស៊ីជាមួយនឹងសារធាតុដែលមានគ្រោះថ្នាក់ ។

មួយទៀតគឺថា គ ទទួលផលប្រយោជន៍ពីអ្វីដែល ឃ បានធ្វើ ហេតុដូច្នេះ គ ក៏ត្រូវទទួលរងនូវការបាត់បង់ពីអ្វីដែល ឃ បានធ្វើផងដែរ ។

គំនិតណាមួយនៅក្នុងចំណោមគំនិតទាំងពីរនេះ ដែលបុគ្គលម្នាក់ត្រូវទទួលខុសត្រូវ ក្នុងករណីប្រសិនបើគាត់រកស៊ីជាមួយនឹងអ្វីដែលមានគ្រោះថ្នាក់នោះ និង បុគ្គលម្នាក់ត្រូវទទួលខុសត្រូវចំពោះការបាត់បង់ដែលបណ្តាលមកពីអ្នកដទៃ ប្រសិនបើគាត់ទទួលផលប្រយោជន៍ពីអ្នកនោះ គឺជាមូលហេតុនៃទម្រង់ពិសេសនៃអំពើអនីត្យានុកូល ។

## ៥.២. ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ

### ៥.២.១. អ្នកត្រួតពិនិត្យអនីតិជនអាយុក្រោម ១៤ ឆ្នាំ ឬ អ្នកត្រួតពិនិត្យបុគ្គលដែលស្ថិតក្នុងស្ថានភាពមិនអាចយល់ដឹង និង វិនិច្ឆ័យអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី

នៅក្នុងករណីដែលអំពើអនីត្យានុកូលកើតឡើងដោយសារអនីតិជន អាយុក្រោម ១៤ ឆ្នាំ ដែលជាជនអសមត្ថភាពក្នុងការទទួលខុសត្រូវ ជននេះមិនត្រូវទទួលខុសត្រូវទេ។ ប៉ុន្តែ បុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យជនអសមត្ថជន គឺជាអ្នកទទួលខុសត្រូវនូវសំណងនៃការខូចខាតដោយពុំគិតអំពីកំហុសអចេតនា ឬ កំហុសចេតនាណាមួយក្នុងការត្រួតពិនិត្យនោះទេ ដូចមានចែងក្នុងមាត្រា ៧៤៦ កថាខណ្ឌទី១ ។

### ៥.២.២. អ្នកត្រួតពិនិត្យអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ

នៅក្នុងករណីនេះ អ្នកត្រួតពិនិត្យអាចរួចផុតពីការទទួលខុសត្រូវដោយធ្វើការបញ្ជាក់ថាខ្លួនបានបំពេញករណីយកិច្ចក្នុងការត្រួតពិនិត្យជាប់ជាប្រចាំដោយគ្មានការធ្វេសប្រហែស ។

## ៥.៣. ការទទួលខុសត្រូវរបស់និយោជក

### ៥.៣.១. លក្ខខណ្ឌ

យោងតាមមាត្រា ៧៤៧ លក្ខខណ្ឌនៃការទទួលខុសត្រូវរបស់និយោជក គឺមានដូចខាងក្រោមនេះ :

**ក-** បុគ្គលដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ឬ បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក ។

ខ- ការខូចខាត

គ- និយោជិតមានកំហុសចេតនា ឬ កំហុសអចេតនា។

### ៥.៣.២. ការតវ៉ា

និយោជកត្រូវទទួលខុសត្រូវ ទោះបីជាខ្លួនគ្មានកំហុសក៏ដោយ។ នោះ គឺជាប្រភេទនៃ "ការទទួលខុសត្រូវដែលមានលក្ខណៈតឹងតែង"។

នៅក្នុងករណីដែលមានអ្នកត្រួតពិនិត្យជំនួសនិយោជក គាត់នឹងរួចផុតពីការទទួលខុសត្រូវក្នុងករណីដែលអ្នកត្រួតពិនិត្យនោះបានត្រួតពិនិត្យដោយត្រឹមត្រូវ។

### ៥.៣.៣. អានុភាព

#### ៥.៣.៣.១. ការខូចខាត

និយោជក ឬ អ្នកត្រួតពិនិត្យ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយនឹងនិយោជិត ចំពោះការខូចខាតដែលបង្កឡើងដោយនិយោជិត។

#### ៥.៣.៣.២. សំណងពីនិយោជិត

ដោយសារតែនិយោជិត គឺជាចារីផ្ទាល់ ដូចនេះនិយោជក ឬ អ្នកត្រួតពិនិត្យ អាចទាមទារសំណងពីនិយោជិតបាននៅក្នុងករណីដែលនិយោជក ឬ អ្នកត្រួតពិនិត្យ បានសងសំណងទៅភាគីរងគ្រោះ។ ប៉ុន្តែ និយោជក ឬ អ្នកត្រួតពិនិត្យ មិនអាចទទួលបានមកវិញនូវប្រាក់ទាំងអស់នោះទេ ប៉ុន្តែ អាចទទួលបានដោយយោងទៅតាមកម្រិតនៃកំហុសជាក់ស្តែងរបស់និយោជិត។

ស្តីពីអំពើអនីត្យានុកូលដែលធ្វើឡើងដោយនិយោជិត (បុគ្គលដែលនិយោជកបានប្រើដើម្បីប្រកបអាជីវកម្មរបស់ខ្លួន) សាមីខ្លួនដែលជានិយោជិតត្រូវទទួលខុសត្រូវ ហើយថែមពីលើនេះ និយោជក ឬ អ្នកដែលត្រួតពិនិត្យជំនួសនិយោជក (អ្នកតំណាងអ្នកត្រួតពិនិត្យ) ក៏ត្រូវទទួលខុសត្រូវជាមួយនឹងនិយោជិតនោះដែរ ដោយគ្មានពាក់ព័ន្ធនឹងកំហុសចេតនា ឬ អចេតនារបស់និយោជិតទេ។

ការឱ្យនិយោជកទទួលខុសត្រូវនេះ គឺដោយផ្អែកលើគំនិតថាការបាត់បង់ ក៏ស្ថិតនៅកន្លែងដែលផលប្រយោជន៍ស្ថិតនៅ។

ក្នុងករណីដែលអ្នកតំណាងអ្នកត្រួតពិនិត្យ បានធ្វើការត្រួតពិនិត្យនិយោជិតបានត្រឹមត្រូវ អ្នកតំណាងនោះនឹងរួចផុតពីការទទួលខុសត្រូវនេះ ប៉ុន្តែ និយោជកខ្លួនឯងផ្ទាល់មិនអាចរួចផុតពីការទទួលខុសត្រូវនោះទេ។

## ៥.៤. អំពើអនីត្យានុកូលរបស់នីតិបុគ្គល

អំពើអនីត្យានុកូលរបស់នីតិបុគ្គល គឺជាបញ្ញត្តិដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងការទទួលខុសត្រូវរបស់និយោជកដែរ។ ប៉ុន្តែភាពខុសគ្នា គឺមានដូចខាងក្រោមនេះ :

**ក-** ក្នុងករណីអំពើអនីត្យានុកូលរបស់នីតិបុគ្គល អ្នកប្រព្រឹត្តអំពើបំពានគឺត្រូវបានកម្រិតចំពោះសមាជិកនាយក ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ចំណែកឯក្នុងករណីនៃការទទួលខុសត្រូវរបស់និយោជក គ្មានការកំណត់បែបនេះទេ។

**ខ-** នីតិបុគ្គលមិនអាចធ្វើការតវ៉ា ដូចការតវ៉ានៅក្នុងករណីនៃការទទួលខុសត្រូវរបស់និយោជកបានឡើយ (ការគ្រប់គ្រងត្រឹមត្រូវ)។

អំពើអនីត្យានុកូលដែលបានប្រព្រឹត្តដោយអ្នកតំណាងរបស់នីតិបុគ្គល គឺសាមីខ្លួនអ្នកតំណាងនោះជាអ្នកទទួលខុសត្រូវ ហើយក្រៅពីនេះនីតិបុគ្គលក៏ត្រូវទទួលខុសត្រូវផងដែរ។

ចំពោះនីតិបុគ្គលពាក់ព័ន្ធនឹងអំពើអនីត្យានុកូលរបស់អ្នកតំណាងត្រូវអនុវត្តតាមមាត្រា ៧៤៨ ហើយបើពាក់ព័ន្ធនឹងអំពើរបស់បុគ្គលិក ឬ និយោជិតក្រៅពីអ្នកតំណាង ត្រូវអនុវត្តតាមមាត្រា ៧៤៧។

ពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់នីតិបុគ្គលពុំមានបញ្ញត្តិលើកលែង ដូចការទទួលខុសត្រូវរបស់និយោជិតទេ នេះគឺដោយសារតែការទទួលខុសត្រូវរបស់នីតិបុគ្គលតឹងតែងជាង បើប្រៀបធៀបនឹងនិយោជិតធម្មតា និង ទំនាក់ទំនងរវាងអ្នកតំណាងនឹងនីតិបុគ្គល គឺមានភាពជិតស្និទ្ធណាស់។ លើសពីនេះអំពើរបស់ស្ថាប័នតំណាង គឺជាអំពើរបស់នីតិបុគ្គលនោះផ្ទាល់តែម្តង។ ហេតុនេះហើយ បានជាត្រូវមានការទទួលខុសត្រូវខុសគ្នាពីនិយោជិត។

ក្នុងករណីដែលនីតិបុគ្គលបានសងសំណងនៃការខូចខាត នីតិបុគ្គលនោះអាចទាមទារសំណងពីអ្នកតំណាងបាន។

## ៥.៥. អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ

### ៥.៥.១. ប្រវត្តិ

កាលដើមឡើយ នៅប្រទេសមួយចំនួនធំ គេមិនទទួលស្គាល់នូវការទទួលខុសត្រូវរបស់រដ្ឋទេ។ **ឧទាហរណ៍** ដូចសុភាសិតច្បាប់បុរាណនៅប្រទេសអង់គ្លេសបានពោលថា **"ស្តេច មិនអាចប្រព្រឹត្តខុសឡើយ"** គេបានបដិសេធនូវការទទួលខុសត្រូវរបស់រដ្ឋ។ ក៏ប៉ុន្តែក្រោយមក នៅសឹងតែគ្រប់ប្រទេសគេបានទទួលស្គាល់នូវការទទួលខុសត្រូវរបស់រដ្ឋវិញ។

ដូចបណ្តាប្រទេសដទៃទៀតដែរ មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬ ប្តឹងទាមទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់រដ្ឋ របស់អង្គការសង្គម និង បុគ្គលិកនៃអង្គការទាំងនេះ"។

### ៥.៥.២. លក្ខខណ្ឌ

មាត្រា ៧៤៩ តម្រូវឱ្យមានលក្ខខណ្ឌ ដូចខាងក្រោមនេះ :

**ក-** មន្ត្រីរាជការ

**ខ-** ទទួលនូវការអនុវត្តនូវអំណាចសាធារណៈ

**គ-** បង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា

លក្ខខណ្ឌ (**ខ**) គឺតម្រូវឱ្យមានជាដាច់ខាត ដូច្នេះសកម្មភាពឯកជនរបស់មន្ត្រីរាជការមិនបណ្តាលឱ្យមានការទទួលខុសត្រូវរបស់រដ្ឋ។

### ៥.៥.៣. អានុភាព

យោងតាមមាត្រា ៧៤៩ កថាខណ្ឌទី ១ មន្ត្រីសាធារណៈផ្ទាល់មិនទទួលខុសត្រូវចំពោះអំពើបំពានទេ ប៉ុន្តែមានតែរដ្ឋតែប៉ុណ្ណោះ ដែលត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល នៅពេលដែលអនុវត្តមាត្រា ៧៤៩។

រដ្ឋ ឬ ស្ថាប័នសាធារណៈ អាចទាមទារសំណងបានតែនៅពេលដែលមន្ត្រីរាជការបានបំពានករណីយកិច្ចធ្ងន់ធ្ងរ (មាត្រា ៧៤៩ កថាខណ្ឌទី ២)។

ចំណុចខុសគ្នាទៅនឹងការទទួលខុសត្រូវរបស់និយោជក គឺពុំមានបញ្ញត្តិលើកលែងសម្រាប់រដ្ឋ ឬ អង្គការសង្គមទេ ហើយការទាមទារសំណងដោយរដ្ឋ ឬ ដោយអង្គការសង្គមចំពោះសាមីខ្លួនជាមន្ត្រីរាជការអាចធ្វើទៅបាន តែក្នុងករណីដែលមានការធ្វើសកម្មភាពផ្ទុយនឹងករណីយកិច្ចធ្ងន់ធ្ងរតែប៉ុណ្ណោះ។

## ៥.៦. ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ

មាត្រា ៧៥០ មិនតម្រូវឱ្យមានកំហុសចេតនា ឬ កំហុសអចេតនានោះទេ ដូច្នេះអ្នកកាន់កាប់សត្វត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ប្រសិនបើមាននៅពេលដែលអ្នកកាន់កាប់នោះបានគ្រប់គ្រងត្រឹមត្រូវដោយគ្មានកំហុស។

### ៥.៦.១. លក្ខខណ្ឌ

**ក-** អ្នកកាន់កាប់សត្វ

**ខ-** បណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ

**គ-** ទំនាក់ទំនងរវាងហេតុ និង ផល។

### ៥.៦.២. អានុភាព

អ្នកដែលទទួលខុសត្រូវ ជាគោលការណ៍ គឺអ្នកកាន់កាប់សត្វដោយមិនចាំបាច់ពិចារណាលើលក្ខខណ្ឌ ថាតើអ្នកកាន់កាប់សត្វ មានកំហុស ឬ គ្មានកំហុសនោះទេ គឺមានន័យថាអ្នកកាន់កាប់សត្វត្រូវទទួលខុសត្រូវដោយគ្មានកំហុស គឺពុំមានការអនុគ្រោះឱ្យរួចផុតពីការទទួលខុសត្រូវទេ។

បញ្ញត្តិនៃមាត្រានេះ គឺមិនមែនសំដៅតែទៅលើ "***អ្នកកាន់កាប់សត្វ***" តែម្នាក់នោះទេ ប៉ុន្តែថែមទាំងទៅលើករណីមួយចំនួនទៀតផងដែរ ប្រសិនបើសត្វដែលគេចិញ្ចឹមបានរត់ចេញទៅខាំអ្នកដទៃ នោះពាក្យអ្នកកាន់កាប់

សត្វនោះមិនមែនកំណត់ត្រឹមតែម្ចាស់សត្វនោះទេ គឺមានរួមទាំងអ្នកចិញ្ចឹមផងដែរ ដែលត្រូវទទួលខុសត្រូវនូវសំណង នៃការខូចខាត ។

## ៥.៧. ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ

### ៥.៧.១. លក្ខខណ្ឌ

**ក-** មានវិការៈនាំឱ្យមានគ្រោះថ្នាក់មិនសមហេតុផល

**ខ-** ចលនវត្ថុ

**គ-** បណ្ដាលឱ្យមានការខូចខាតដល់អ្នកដទៃ ។

### ៥.៧.២. អានុភាព

អ្នកដែលទទួលខុសត្រូវ ជាគោលការណ៍ គឺជាផលិតករ និង រាប់បញ្ចូល ដូចជា :

**ក-** អ្នកដែលផលិតចលនវត្ថុដែលផ្សំដោយគ្រឿង ឬ វត្ថុធាតុដើមដែលមានវិការៈ

**ខ-** អ្នកនាំចូល

**គ-** បុគ្គលដែលបានដាក់សញ្ញានៃនាមករណ៍របស់ខ្លួននៅលើចលនវត្ថុ ក៏ត្រូវបានចាត់ទុកថាជាអ្នកផលិតដែរ ហើយត្រូវទទួលខុសត្រូវផងដែរ ( មាត្រា ៧៥១ កថាខណ្ឌទី ២ ទី ៣ និងទី ៤) ។

ក្នុងករណីដែលអ្នកប្រើប្រាស់ ឬ អ្នកបរិភោគ ឬ អ្នកដទៃទៀត មានការខូចខាតដោយសារតែទំនិញមានវិការៈ (ផលិតផល) ដែលអ្នកផលិតបានលក់តាមរយៈហាងលក់រាយ អ្នកផលិតត្រូវទទួលខុសត្រូវនូវសំណងនៃការខូចខាត ។ នេះ គឺជាការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ ។

មាត្រា ៧៥១ បញ្ញត្តិឡើងដើម្បីឱ្យអ្នកប្រើប្រាស់ ឬ អ្នកបរិភោគ ឬ អ្នកដទៃទៀត ដែលទទួលរងការខូចខាតដោយសារតែទំនិញ (ផលិតផល) អាចទាមទារឱ្យអ្នកផលិតទទួលខុសត្រូវ ដោយគ្រាន់តែបញ្ជាក់ភស្តុតាងអំពី "**វិការៈ**" ប៉ុណ្ណោះ គឺមិនចាំបាច់បញ្ជាក់ភស្តុតាងថា អ្នកផលិតមានកំហុសនោះទេ ។

## ៥.៨. ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់

វត្ថុទាំងឡាយ ដែលមានចែងនៅក្នុងមាត្រា ៧៥២ នេះ គឺសុទ្ធសឹងតែជាវត្ថុដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ ។ ដូច្នេះបុគ្គលដែលជាកម្មសិទ្ធិករ ឬ អ្នកគ្រប់គ្រងវត្ថុទាំងនោះ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កដល់អ្នកដទៃ ដោយសារវត្ថុគ្រោះថ្នាក់ដែលខ្លួនមានកម្មសិទ្ធិ ឬ គ្រប់គ្រង ទោះបីជាគ្មានកំហុសចេតនា ឬ កំហុសអចេតនាក៏ដោយ ។

**ការតវ៉ាដែលបានបញ្ញត្តិឡើងគឺមានដូចខាងក្រោមនេះ :**

**ក-** ករណីប្រធានសក្តិ ( កម្លាំងដែលមិនអាចជៀសវាងបាន)

**ខ-** ករណីដែលការគ្រប់គ្រងវត្ថុគ្រោះថ្នាក់ គ្មានវិការៈ ហើយការខូចខាតបណ្ដាលមកពីអំពើរបស់ជនរងគ្រោះ ឬ តតិយជន ។

## ៩.៩. ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី

មាត្រា ៧៥៣ គឺជាបញ្ញត្តិដែលចែងអំពីការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី ។

**ឧទាហរណ៍ :** សំណង់ដែលជាប់លើដី គឺអគារ ឬ របងជាដើម បានធ្វើឱ្យអ្នកដទៃមានការខូចខាត ។ មាត្រានេះតម្រូវឱ្យម្ចាស់សំណង់ ឬ អ្នកគ្រប់គ្រងទទួលខុសត្រូវនូវសំណងនៃការខូចខាតនេះ ។

**ឧទាហរណ៍ :** ក្នុងករណីរបងផ្ទះជួលបានរលំ ហើយបានធ្វើឱ្យអ្នកដើររងរបួសម្ចាស់ផ្ទះ (ភតិបតី) និង អ្នកជួល (ភតិកៈ) ត្រូវទទួលបន្ទុកនូវសំណងនៃការខូចខាតដោយសាមគ្គីភាព ។

បើសិនជាអ្នកគ្រប់គ្រង (ភតិកៈ) បានបញ្ជាក់ភស្តុតាងថា ខ្លួនបានគ្រប់គ្រងត្រឹមត្រូវនឹងអាចរួចផុតពីការទទួលខុសត្រូវនេះបាន ។ ប៉ុន្តែចំពោះម្ចាស់កម្មសិទ្ធិវិញ ពុំមានបញ្ញត្តិឱ្យលើកលែងដូចនេះទេ ។ បើទោះបីជា របងនោះរលំដោយសារក្រុមហ៊ុនសំណង់បានសាងសង់មិនត្រឹមត្រូវក៏ដោយ ក៏ម្ចាស់កម្មសិទ្ធិត្រូវទទួលខុសត្រូវដែរ ។

## ៩.១០. អំពើអនីត្យានុកូលរួម

### ៩.១០.១. បញ្ញត្តិទូទៅស្តីពីអំពើអនីត្យានុកូលរួម

ប្រសិនបើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើនីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព។ ចំពោះទំហំនៃសំណងនៃការខូចខាតវិញ បើសិនជាអំពើរួមគ្នាពាក់ព័ន្ធជិតស្និទ្ធ ដូចជា ករណីនៃការសមគំនិតគ្នា ជាដើម ចារីម្នាក់ៗត្រូវទទួលខុសត្រូវដោយសាមគ្គីភាពនូវសំណងនៃការខូចខាតទាំងអស់ ក៏ប៉ុន្តែ ក្នុងករណីដែលទំនាក់ទំនងមិនសូវជិតស្និទ្ធទេ អ្នកប្រព្រឹត្តអំពើបំពានអាចទទួលខុសត្រូវក្នុងការសងការខូចខាតតាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក យោងតាមបញ្ញត្តិមាត្រា ៧៥៤ នៃក្រមរដ្ឋប្បវេណី ។ សូមកត់សម្គាល់ថា សូម្បីតែនៅក្នុងករណីដែលគ្មានទំនាក់ទំនងគ្នាជិតស្និទ្ធ ប៉ុន្តែ អ្នកប្រព្រឹត្តអំពើបំពានមិនអាចបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាតទេ ជននោះមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតទាំងអស់បានទេ ។

**ឧទាហរណ៍ទី ១ :** រោងចក្រ **ក** បានបញ្ចេញសារធាតុ **ក១** ហើយរោងចក្រ **ខ** បានបញ្ចេញសារធាតុ **ខ១** ។ ទាំងសារធាតុ **ក១** និង **ខ១** មិនបង្កឱ្យមានការខូចខាត ឬ ប៉ះពាល់ដល់អ្នកដទៃរៀងៗខ្លួននោះទេ ប៉ុន្តែ សារធាតុទាំងនោះបានក្លាយទៅជាសារធាតុពុលដោយសារប្រតិកម្មគីមី ហើយសារធាតុនេះបានបង្កផលប៉ះពាល់ដល់អ្នកដែលរស់នៅជិតរោងចក្រនោះ ។ រោងចក្រនីមួយៗបានអះអាងថា ពួកគេមិនទទួលខុសត្រូវចំពោះការខូចខាតដែលបានកើតឡើងនោះទេ ពីព្រោះរោងចក្រនីមួយៗគ្រាន់តែបញ្ចេញនូវសារធាតុដែលមិនបង្កឱ្យមានគ្រោះថ្នាក់នោះទេ ។ តើ លោក/ លោកស្រី សម្រេចយ៉ាងដូចម្តេចដែរ?

**សន្និដ្ឋាន :**

**ឧទាហរណ៍ទី ១** : រោងចក្រ **ក** ដែលបានបញ្ចេញសារធាតុ **ក១** ហើយរោងចក្រ **ខ** ដែលបានបញ្ចេញសារធាតុ **ខ១** ទទួលខុសត្រូវរួមគ្នា ក្នុងការសងសំណងនៃការខូចខាតដល់ជនរងគ្រោះ តាមបញ្ញត្តិមាត្រា ៧៥៤

នៃក្រមរដ្ឋប្បវេណី ព្រោះអំពើបំពានដែលបង្កឱ្យមានការខូចខាតដល់អ្នកដែលរស់នៅក្បែររោងចក្រ បណ្តាលមកពីអំពើរួមគ្នារបស់រោងចក្រទាំងពីរ។ នៅក្នុងករណីនេះ អ្នកប្រព្រឹត្តអំពើបំពានទាំងនោះ មិនបានឃុបឃិតគ្នានោះទេ ប៉ុន្តែវាមុខជាមិនអាចទៅរួចទេ សម្រាប់រោងចក្រ ក និង រោងចក្រ ខ ក្នុងការបញ្ជាក់ អំពីភាគនៃអំពើរបស់ខ្លួននីមួយៗ ដែលខ្លួនបានបង្កឱ្យមានការខូចខាត ហើយប្រសិនបើដូច្នោះមែន រោងចក្រទាំងពីរត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព។

**ឧទាហរណ៍ទី ២ :** ក និង ខ បានបើករថយន្ត ហើយបានបុក គ នៅពេលដំណាលគ្នានោះ ហើយ គ ក៏បានបាត់បង់ជីវិត។

**១-** ក និង ខ បានបុក គ ដោយកំហុសអចេតនា ហើយមិនមានភាពច្បាស់លាស់ទេ ថាតើអ្នកណាបានបុកចំណុច ដែលបានបណ្តាលឱ្យបាត់បង់ជីវិតនោះ។ តើនរណាត្រូវទទួលខុសត្រូវ ចំពោះករណីនេះ (ក ឬ ខ ឬ ទាំងពីរនាក់តែម្តង)? ហើយ តើអ្នកដែលត្រូវទទួលខុសត្រូវនោះ ត្រូវសងសំណងជាទឹកប្រាក់ចំនួនប៉ុន្មាន?

**២-** ក និង ខ បានបុក គ ដោយកំហុសអចេតនា ហើយរកឃើញថា ការរងរបួសដែលបណ្តាលមកពី ក ដែលបានរួមចំណែកក្នុងការបង្កឱ្យកើតមានឡើងចំពោះការស្លាប់របស់ គ គឺមានចំនួន ៣០% ហើយការរងរបួសដែលបណ្តាលមកពី ខ ដែលបានរួមចំណែកក្នុងការបង្កឱ្យកើតមានឡើងចំពោះការស្លាប់របស់ គ គឺមានចំនួន ៧០% តើនរណាត្រូវទទួលខុសត្រូវ? ហើយតើអ្នកដែលត្រូវទទួលខុសត្រូវនោះ ត្រូវសងសំណងជាទឹកប្រាក់ចំនួនប៉ុន្មាន?

**៣-** ក និង ខ បានរួមគំនិតគ្នាបុក គ ហើយ ពេលរកឃើញថាការរងរបួសដែលបណ្តាលមកពី ក ដែលបានរួមចំណែកក្នុងការបង្កឱ្យកើតមានឡើងចំពោះការស្លាប់របស់ គ គឺមានចំនួន ៣០% ហើយការរងរបួសដែលបណ្តាលមកពី ខ ដែលបានរួមចំណែកក្នុងការបង្កឱ្យកើតមានឡើងចំពោះការស្លាប់របស់ គ គឺមានចំនួន ៧០% ។ តើនរណាត្រូវទទួលខុសត្រូវ? ហើយតើអ្នកដែលទទួលខុសត្រូវនោះត្រូវសងសំណងជាទឹកប្រាក់ចំនួនប៉ុន្មាន?

**សន្និដ្ឋាន :**

១- សន្តតិជនរបស់ គ អាចទាមទារសំណងនៃការខូចខាតដែលបង្កឡើងដោយ ក និង ខ តាមបញ្ញត្តិមាត្រា ៧៥៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ហេតុដូច្នេះ ក និង ខ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព។

២- ការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតរបស់ ក និង ខ ត្រូវសងតាមភាគនីមួយៗ គឺ : ក ចំនួន ៣០% ហើយ ខ ចំនួន ៧០% តាមបញ្ញត្តិមាត្រា ៧៥៤ កថាខណ្ឌទី ២។

៣- ចំពោះអំពើដែលបានបង្កឡើងរួមគ្នាដោយ ក និង ខ គឺយើងត្រូវអនុវត្តតាមបញ្ញត្តិមាត្រា ៧៥៤ កថាខណ្ឌទី ១ និង ទី ២ ហេតុដូច្នេះទាំង ក និង ខ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតទាំងអស់ ដោយសាមគ្គីភាព ដោយមិនគិតភាគដែលរួមចំណែកបង្កឱ្យមានការខូចខាតនីមួយៗនោះទេ។

## ៦. បញ្ញត្តិដែលទាក់ទងនឹងចំណុចផ្សេងទៀតស្តីពីអំពើអនីត្យានុកូល

### ៦.១. ទារកក្នុងគភ៌

ទារកដែលនៅក្នុងគភ៌នាពេលមានអំពើអនីត្យានុកូល បើទារកនេះមានកំណើតនៅពេលក្រោយអាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួននៅក្នុងគភ៌ ដោយអំពើអនីត្យានុកូលនោះបានតាមបញ្ញត្តិមាត្រា ៩ កថាខណ្ឌទី ១។ ជាពិសេសជាងនេះទៅទៀត ទារកដែលនៅក្នុងគភ៌អាចទាមទារសំណងការខូចខាតខាងផ្លូវចិត្ត ដោយយោងតាមបញ្ញត្តិមាត្រា ៧៦០ កថាខណ្ឌទី ៣។

### ៦.២. អាជ្ញាយុកាលនៃការរំលត់

សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូលត្រូវរលត់ បើផុតអំឡុងពេលដូចខាងក្រោម :

**ក-** អំឡុងពេល ៣ ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះបានដឹងថាអាចទាមទារសំណងការខូចខាត ចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬ

**ខ-** បើអំឡុងពេល ១០ ឆ្នាំ បានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើងបញ្ញត្តិនេះត្រូវបញ្ញត្តឡើង ដើម្បីជាប្រយោជន៍នៃស្ថិរភាពគតិយុត្ត។

- *<u>ចូរធ្វើការកត់សម្គាល់ចំពោះមាត្រា</u> ៧៦៥ ស្តីពីអាជ្ញាយុកាលនៃការរំលត់ (បញ្ញត្តិពិសេស) និងមាត្រា ៤៨២ ស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ។*

# ជំពូកទី ៦

# ការធានាកាតព្វកិច្ច

## ផ្នែកទី ១

## ហ៊ីប៉ូតែក

### សេចក្ដីផ្ដើម

ហ៊ីប៉ូតែក គឺជាប្រភេទមួយនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលកូនបំណុល ឬ តតិយជនដែលបានយកទ្រព្យសម្បត្តិមកដាក់ហ៊ីប៉ូតែក និង ម្ចាស់បំណុលបានព្រមព្រៀងបង្កើតជាបន្ទុកមួយនៅលើអចលនទ្រព្យរបស់ខ្លួន ដើម្បីធានាកាតព្វកិច្ចដែលមានចំពោះម្ចាស់បំណុលដោយមិនមានការផ្ទេរនូវការកាន់កាប់ទ្រព្យនោះ ទៅឱ្យម្ចាស់បំណុលឡើយ។

ហ៊ីប៉ូតែក ជារបបគតិយុត្តមួយនៃការធានាបំណុលដោយវត្ថុ ដែលត្រូវបានដាក់ជាប្រាតិភោគ។ សារប្រយោជន៍ដ៏ធំបំផុតមួយរបស់ហ៊ីប៉ូតែក គឺថាកូនបំណុលមិនចាំបាច់ផ្ទេរនូវការកាន់កាប់ទ្រព្យដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ទៅឱ្យម្ចាស់បំណុលឡើយ ពីព្រោះករណីនេះធ្វើឱ្យកូនបំណុលអាចបន្តការរស់នៅ ឬ ការធ្វើអាជីវកម្ម នៅលើទ្រព្យរបស់ខ្លួននោះជាធម្មតា ទោះបីជាទ្រព្យនោះកំពុងតែជាប់ហ៊ីប៉ូតែកក៏ដោយ ដែលចំណុចនេះហើយនាំឱ្យវាមានការខុសប្លែកពីការបញ្ចាំ និង ប្រាតិភោគដោយអនុប្បទានដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ដែលកូនបំណុលត្រូវតែផ្ទេរនូវការកាន់កាប់វត្ថុទៅឱ្យម្ចាស់បំណុល និង ខុសប្លែកពីការធានាដោយវត្ថុ (យោងតាមច្បាប់ភូមិបាល ឆ្នាំ ២០០១) ដែលកូនបំណុលត្រូវតែផ្ទេរនូវប័ណ្ណកាន់កាប់វត្ថុនោះទៅឱ្យម្ចាស់បំណុល។

សារប្រយោជន៍មួយទៀតនៃហ៊ីប៉ូតែក គឺថាកូនបំណុលអាចបង្កើតហ៊ីប៉ូតែកច្រើននៅលើទ្រព្យនោះបានចំពោះម្ចាស់បំណុលច្រើនគ្នាទៀតផង ហើយដែលលំដាប់នៃការទទួលបានសំណង គឺអាស្រ័យទៅលើពេលវេលានៃការចុះបញ្ជីសុរិយោដីនៃបន្ទុកហ៊ីប៉ូតែកនោះ។

ហេតុដូច្នេះ ការយល់អំពីការបង្កើតកិច្ចសន្យាហ៊ីប៉ូតែក និង អានុភាពនៃកិច្ចសន្យាហ៊ីប៉ូតែកនោះ គឺមានសារៈសំខាន់ណាស់ ព្រោះបើកិច្ចសន្យាហ៊ីប៉ូតែកមួយត្រូវបានបង្កើតឡើង ប៉ុន្តែមិនស្របទៅនឹងលក្ខខណ្ឌដែលច្បាប់បានកំណត់ទេនោះ នាំឱ្យកិច្ចសន្យាហ៊ីប៉ូតែកនោះមិនមានអានុភាពតាមផ្លូវច្បាប់ទាល់តែសោះ ហើយម្ចាស់បំណុលក៏មិនមានសិទ្ធិប្រាតិភោគប្រត្យក្សនៅលើវត្ថុដែលដាក់ហ៊ីប៉ូតែក ដោយកូនបំណុលនោះដែរ។ ពោលគឺម្ចាស់បំណុលមិនអាចអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួន ឬ ទទួលបាននូវអាទិភាពនៃការសងបំណុលរបស់ខ្លួនមុនម្ចាស់បំណុលដទៃទៀតបានទេ។

អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា ហ៊ីប៉ូតែកដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនេះ គឺអាចអនុវត្តបានតែលើអចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគតែប៉ុណ្ណោះ។ ចំពោះហ៊ីប៉ូតែកលើចលនវត្ថុ គឺឋិតនៅក្នុងក្របខណ្ឌ

នៃច្បាប់ពិសេសដោយឡែក ។

## ១. និយមន័យហ៊ីប៉ូតែក

មាត្រា ៨៤៣ នៃក្រមរដ្ឋប្បវេណី បានឱ្យនិយមន័យ "*ហ៊ីប៉ូតែក*" ជាសិទ្ធិមួយដែលម្ចាស់បំណុលទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតចំពោះអចលនវត្ថុ ដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ចដោយកូនបំណុល ឬ តតិយជនដោយមិនផ្ទេរការកាន់កាប់ ។

ក្នុងន័យនេះ យើងឃើញថាហ៊ីប៉ូតែកជារបបគតិយុត្តមួយ ដែលបង្កើតឡើងដើម្បីការពារនូវផលប្រយោជន៍របស់ម្ចាស់បំណុល ។ ហើយម្ចាស់បំណុលដែលមានសិទ្ធិហ៊ីប៉ូតែកដើម្បីធានានូវបំណុលរបស់ខ្លួន មានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតដែលគ្មានសិទ្ធិហ៊ីប៉ូតែក ។

> **ឧទាហរណ៍ :** **ខ** គឺជាម្ចាស់បំណុលរបស់ **ក** ចំនួន ១០.០០០ ដុល្លារ ។ **ក** បានយកដីទៅដាក់ហ៊ីប៉ូតែកឱ្យ **ខ** ដើម្បីធានាបំណុល ។ **ក** ក៏មានម្ចាស់បំណុលផ្សេងទៀតដែរគឺ **គ** និង **ឃ** ។ បើដល់ពេលកំណត់សងហើយ **ក** មិនមានប្រាក់សងទេនោះ **ខ** អាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះដីរបស់ **ក**។ សន្មតថា ដីនោះលក់បានតម្លៃតែ ១០.០០០ ដុល្លារ ។ ប្រាក់ដែលបានមកពីការលក់នេះ ត្រូវយកទៅសងតែ **ខ** តែប៉ុណ្ណោះ ។ រីឯម្ចាស់បំណុលផ្សេងទៀតនឹងមិនទទួលបាននូវសំណងដែលកើតចេញមកពីការលក់ដីនោះទេ ។ ប៉ុន្តែ **គ** និង **ឃ** នៅតែអាចទាមទារសំណងពី **ក** ។

## ២. ការបង្កើតហ៊ីប៉ូតែក

### ២.១. លក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាហ៊ីប៉ូតែករវាងគូភាគី

ដូចដែលបានលើកឡើងខាងលើហើយថា ការយល់អំពីលក្ខខណ្ឌសុពលភាពចំពោះគូភាគីក្នុងការបង្កើតកិច្ចសន្យាហ៊ីប៉ូតែកមួយ គឺមានសារៈសំខាន់ណាស់ ដើម្បីឱ្យម្ចាស់បំណុលអាចអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបាន ។

មាត្រា ៨៤៤ នៃក្រមរដ្ឋប្បវេណីបានចែងថា ហ៊ីប៉ូតែកនឹងត្រូវបានបង្កើតឡើងដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង កូនបំណុល ឬ តតិយជនដែលយកអចលនវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគ ។

យោងតាមមាត្រានេះ យើងឃើញថាលក្ខខណ្ឌសុពលភាពចំពោះគូភាគីក្នុងការបង្កើតកិច្ចសន្យាហ៊ីប៉ូតែកមួយ គឺការព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុល ឬ តតិយជនដែលយកអចលនវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគតែប៉ុណ្ណោះ ប៉ុន្តែវាមិនតម្រូវឱ្យមានការចុះបញ្ជីឡើយ ។

សួរថា តើកិច្ចសន្យាហ៊ីប៉ូតែកមួយ តម្រូវឱ្យគូភាគីធ្វើដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរទើបមានសុពលភាព? ដោយសារតែមាត្រា ៨៤៤ ខាងលើមិនបានកម្រិតអំពីលក្ខខណ្ឌទម្រង់ ក្នុងការបង្កើតកិច្ចសន្យាហ៊ីប៉ូតែករបស់គូភាគីទេ ការព្រមព្រៀងអាចត្រូវបានធ្វើឡើងតាមទម្រង់ណាមួយក៏បាន គឺដោយផ្ទាល់មាត់ក៏បាន ឬ

ជាលាយលក្ខណ៍អក្សរក៏បាន។ ប៉ុន្តែ ក្រមនេះបានកម្រិតនូវលក្ខខណ្ឌទម្រង់របស់កិច្ចសន្យាហ៊ីប៉ូតែក ដើម្បីឱ្យគូភាគីអាចយកហ៊ីប៉ូតែករបស់ខ្លួនទៅតតាំងនឹងតតិយជនបាន គឺកិច្ចសន្យាហ៊ីប៉ូតែកនោះត្រូវធ្វើក្រោមទម្រង់ជាលិខិតយថាភូត និង ត្រូវយកទៅចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី (មាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណី)។ ដូចនេះ លិខិតយថាភូត ឬ ការចុះបញ្ជីមិនមែនជាលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាហ៊ីប៉ូតែកចំពោះគូភាគីទេ មានន័យថាកិច្ចសន្យាដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរក៏ដោយ ក៏មានសុពលភាពចំពោះគូភាគីដែរ។ ទោះបីជា គូភាគីមិនបានបង្កើតកិច្ចសន្យា ហ៊ីប៉ូតែកនោះជាលាយលក្ខណ៍អក្សរក៏ដោយ ក៏កិច្ចសន្យាហ៊ីប៉ូតែកនៅតែមានអានុភាពដដែល។ ប៉ុន្តែ វាអាចបង្កឱ្យមានការលំបាកសម្រាប់ភាគីក្នុងការបង្ហាញភស្តុតាងនៅចំពោះមុខតុលាការ ហើយអ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺថាវាអាចមានបញ្ហាលំបាកសម្រាប់ម្ចាស់បំណុលហ៊ីប៉ូតែក ក្នុងការអនុវត្តហ៊ីប៉ូតែករបស់ខ្លួន ពីព្រោះយោងតាមមាត្រា ៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីគឺតម្រូវឱ្យមានលិខិតអនុវត្ត ដែលលិខិតអនុវត្តមួយនៅក្នុងចំណោមលិខិតអនុវត្តទាំងនោះ គឺជាលិខិតយថាភូតដែលធ្វើឡើងដោយសារការី។ ហេតុនេះ ទោះបីជាក្រមរដ្ឋប្បវេណីមិនតម្រូវឱ្យមានលក្ខខណ្ឌទម្រង់នៃកិច្ចសន្យាហ៊ីប៉ូតែកក៏ដោយ ក៏ភាគីត្រូវបង្កើតកិច្ចសន្យាហ៊ីប៉ូតែករបស់ខ្លួនក្រោមទម្រង់ជាលិខិតយថាភូតដើម្បីធានាឱ្យបាននូវភាពឆាប់រហ័ស និងងាយស្រួលក្នុងការអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួន។

**ឧទាហរណ៍ :** **ក** ចង់ខ្ចីប្រាក់ **ខ** ចំនួន ១០.០០០ ដុល្លារ។ **ក** មានដីមួយកន្លែងដើម្បីធានានូវការសងបំណុលរបស់ខ្លួន។ **ខ** ទាមទារឱ្យ **ក** ដាក់ដីនោះជាប្រាតិភោគមកឱ្យខ្លួន។ **ក** និង **ខ** បានចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរជាមួយគ្នា ប៉ុន្តែកិច្ចសន្យានោះត្រូវបានធ្វើត្រឹមជាលិខិតឯកជន មិនបានធ្វើជាលិខិតយថាភូត ហើយក៏មិនបានយកកិច្ចសន្យាហ៊ីប៉ូតែកនោះទៅចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីទេ។ នៅក្នុងករណីនេះមិនត្រឹមតែកិច្ចសន្យាខ្ចីបរិភោគ តែប៉ុណ្ណោះទេដែលមានអានុភាពនោះ គឺថែមទាំងការព្រមព្រៀងគ្នាក្នុងការបង្កើតហ៊ីប៉ូតែក ក៏មានសុពលភាពដែរ ចំពោះ **ក** និង **ខ**។ បើ **ក** មិនមានប្រាក់ដើម្បីសងបំណុលទៅ **ខ** នៅពេលកំណត់ត្រូវសងទេ នោះ **ខ** អាចដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួនទៅតុលាការបាន។ម្យ៉ាងទៀត ទោះបីជាលិខិតយថាភូត និង ការចុះបញ្ជី មិនតម្រូវឱ្យមានក្នុងការបង្កើតហ៊ីប៉ូតែកក៏ដោយ ក៏លិខិតយថាភូត សាលក្រម ឬ សាលដីកា ឬ ឯកសារ ដែលមានអានុភាពដូចគ្នា គឺតម្រូវឱ្យមានដែរ នៅពេលអនុវត្តដើម្បីបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ។ ហេតុដូច្នេះ ជាថ្មីម្តងទៀតវាជាការល្អ និង ងាយស្រួលសម្រាប់ម្ចាស់បំណុលក្នុងការមានលិខិតយថាភូត។

បញ្ហានឹងកើតមានឡើងនៅពេលដែល **ក** មានម្ចាស់បំណុលផ្សេងទៀត ដូចជា **គ** និង **ឃ** ហើយ **ក** មិនមានអចលនវត្ថុណាផ្សេងទៀតក្រៅពីដីនោះ។ តើ **ខ** អាចយកហ៊ីប៉ូតែករបស់ខ្លួនទៅតតាំងជាមួយ **គ** និង **ឃ** បានដែរ ឬ ទេ? នៅក្នុងករណីនេះ តើ **ខ** អាចទទួលបាននូវសិទ្ធិបុរិមា ឬ អាទិភាពនៃសំណងដែលកើតចេញពីការលក់ដោយបង្ខំលើដីនោះមុនម្ចាស់បំណុល **គ** និង **ឃ** ដែរ ឬ ទេ?

ហើយតើវានឹងក្លាយទៅជាយ៉ាងណាវិញ នៅពេលដែល ខ និង គ មិនបានចុះបញ្ជីហ៊ីប៉ូតែករបស់ខ្លួនទេ តែបែរជា ឃ ដែលជាម្ចាស់បំណុលបានចុះបញ្ជីហ៊ីប៉ូតែកនោះ? ដើម្បីឆ្លើយតបទៅនឹងសំណួរនេះ សូមពិនិត្យមើលលក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែកចំពោះតតិយជនដូចខាងក្រោមនេះ។

## ២.២. លក្ខខណ្ឌតតាំងនៃកិច្ចសន្យាហ៊ីប៉ូតែក

តើអ្វី គឺជាលក្ខខណ្ឌតតាំងនៃកិច្ចសន្យាហ៊ីប៉ូតែក?

ទំនាក់ទំនងគតិយុត្ត ជួនកាលមានលក្ខខណ្ឌ ២ ផ្សេងគ្នា គឺលក្ខខណ្ឌសុពលភាពសម្រាប់គូភាគី និង លក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែកសម្រាប់តតិយជនដែលមិនមែនជាគូភាគី។ ហ៊ីប៉ូតែកដែលជាសិទ្ធិមួយដែលកើតឡើងតាមកិច្ចសន្យារបស់គូភាគីនោះ ក៏មានលក្ខខណ្ឌដោយឡែកសម្រាប់តតាំងជាមួយតតិយជនដែរ។ ដោយសារតែហ៊ីប៉ូតែកជាសិទ្ធិដែលមិនមែនមានឥទ្ធិពលចំពោះតែម្ចាស់បំណុល និង កូនបំណុលនោះទេ ប៉ុន្តែថែមទាំងមានឥទ្ធិពលចំពោះតតិយជនផ្សេងទៀត ដូចជា ជនដែលទិញដីដែលជាប់ហ៊ីប៉ូតែកនោះ និង ម្ចាស់បំណុលផ្សេងទៀត ដែលមិនមែនជាម្ចាស់បំណុលហ៊ីប៉ូតែក។

ហេតុនេះ ការយល់ដឹងអំពីលក្ខខណ្ឌតម្រូវតាមច្បាប់សម្រាប់ឱ្យម្ចាស់សិទ្ធិហ៊ីប៉ូតែក អាចតតាំងនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនជាមួយនឹងតតិយជនបាន ជាប្រការមួយដែលចាំបាច់។

មាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណីបានចែងថា *"ម្ចាស់បំណុលហ៊ីប៉ូតែក មិនអាចយកហ៊ីប៉ូតែកនោះមកតតាំងចំពោះតតិយជន ក្រៅពីអ្នកដែលបង្កើតហ៊ីប៉ូតែកបានឡើយ ប្រសិនបើមិនបានធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនោះដោយលិខិតយថាភូត និង មិនបានចុះបញ្ជីនៅក្នុងសៀវភៅបញ្ជីដីធ្លីទេ"*។

ហេតុផលដែលតម្រូវឱ្យមានការចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីយ៉ាងដូច្នេះ គឺដើម្បីជូនដំណឹងដល់សាធារណជនឱ្យបានដឹង ពីព្រោះនៅពេលដែលអចលនវត្ថុមួយចំនួនត្រូវបានដាក់ជាហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកនឹងទទួលបាននូវការសងសិទ្ធិលើបំណុលរបស់ខ្លួនពីអចលនវត្ថុហ៊ីប៉ូតែកនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។ ហេតុនេះ វាទាមទារឱ្យមានការប្រកាសជាសាធារណៈនូវសិទ្ធិនោះ តាមរយៈការចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ដើម្បីឱ្យតតិយជនក្រៅពីគូភាគីនៃកិច្ចសន្យាអាចមើលឃើញ និង បានដឹងអំពីសិទ្ធិនោះ។ នៅពេលដែលមានការចុះបញ្ជីហ៊ីប៉ូតែកនោះហើយ សូម្បីតែអ្នកដែលទិញអចលនវត្ថុដែលជាប់ហ៊ីប៉ូតែក ដោយការចុះបញ្ជីនោះមិនអាចបដិសេធនូវអានុភាពនៃហ៊ីប៉ូតែកនោះបានទេ។ និយាយម្យ៉ាងទៀត អ្នកទិញអាចធ្វើលទ្ធកម្មនូវដីដែលមានជាប់បន្ទុកហ៊ីប៉ូតែកតែប៉ុណ្ណោះ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកអាចតតាំងនូវហ៊ីប៉ូតែករបស់ខ្លួន។

ជាសរុបមក លក្ខខណ្ឌដែលត្រូវតែគោរពដើម្បីតតាំងហ៊ីប៉ូតែកចំពោះតតិយជន រួមមានដូចតទៅ :

- ត្រូវមានកិច្ចសន្យាហ៊ីប៉ូតែក ជាលាយលក្ខណ៍អក្សរ
- កិច្ចសន្យាហ៊ីប៉ូតែកនោះត្រូវធ្វើជាទម្រង់លិខិតយថាភូត
- ត្រូវយកកិច្ចសន្យាហ៊ីប៉ូតែកនោះទៅចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។

**ឧទាហរណ៍ ៖**

១- **ក** គឺជាម្ចាស់កម្មសិទ្ធិនៃដីដែលមានតម្លៃ ៣.០០០ ដុល្លារ ហើយបានជួលដីនោះទៅឱ្យតតិយជន។ **ក** ចង់ខ្ចីប្រាក់ចំនួន ១.០០០ ដុល្លារពី **ខ** ។ **ខ** ស្នើសុំឱ្យដាក់ហ៊ីប៉ូតែកលើដីនោះ។

តើ **ក** ត្រូវប្រគល់ប័ណ្ណកម្មសិទ្ធិទៅឱ្យ **ខ** ដែរ ឬ ទេ ដើម្បីធានាបំណុលរបស់ខ្លួន?

**ចម្លើយ ៖** **ក** មិនចាំបាច់ប្រគល់ប័ណ្ណកម្មសិទ្ធិនៃដីរបស់ខ្លួនទៅឱ្យ **ខ** ទេ ក្នុងករណីដែល **ក** និង **ខ** បានព្រមព្រៀងគ្នាថាដីត្រូវដាក់ហ៊ីប៉ូតែក។

២-តើ **ក** អាចរំពឹងថា ខ្ចីប្រាក់បានចំនួនប៉ុន្មានដែលសមរម្យតាមរយៈការដាក់ដីជាប្រាតិភោគ?

**ចម្លើយ ៖** គឺក្រោមតម្លៃ ៣.០០០ ដុល្លារ ដែលជាតម្លៃនៃដី។

៣- **ក** និង **ខ** បានព្រមព្រៀងគ្នាថា **ក** ត្រូវដាក់ដីជាហ៊ីប៉ូតែក ហើយ **ខ** ឱ្យ **ក** ខ្ចីចំនួន ១.០០០ ដុល្លារ។ បន្ទាប់មក **ក** បានឱ្យដីនោះទៅ **គ**។ តើ **ខ** អាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបានដែរ ឬ ទេ? ប្រសិនបើមិនអាច តើ **ខ** ត្រូវធ្វើយ៉ាងដូចម្ដេច?

**ចម្លើយ ៖** **ខ** មិនអាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះ **គ** បានទេ ពោលគឺ **ខ** មិនអាចទាមទារដីនោះពី **គ** វិញ ដើម្បីយកមកលក់ឡាយឡុងសងបំណុលរបស់ខ្លួនបានទេ បើ **ខ** មិនបានធ្វើកិច្ចសន្យាជាលិខិតយថាភូត និងចុះបញ្ជីនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនទេនោះ ពីព្រោះ **គ** គឺជាតតិយជន។ ហេតុនេះ ដើម្បីអាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបាន **ខ** ត្រូវតែយកសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនទៅចុះបញ្ជី បើមិនដូច្នេះទេ **ខ** បានត្រឹមតែអាចដាក់ពាក្យបណ្ដឹងធម្មតាដើម្បីឱ្យ **ក** សងបំណុលរបស់ខ្លួនតែប៉ុណ្ណោះ។

៤- **ក** បានយកដីទៅដាក់ហ៊ីប៉ូតែកដើម្បីធានាបំណុល ១.០០០ ដុល្លារ។ ការដាក់ហ៊ីប៉ូតែកនេះ ត្រូវបានធ្វើឡើងដោយលិខិតយថាភូត និង បានចុះបញ្ជី។ **ក** ចង់លក់ដីនោះទៅឱ្យ **គ**។ តើគាត់អាចលក់បានដែរ ឬ ទេ?

**ចម្លើយ ៖** **ក** អាចលក់ដីនោះបាន។ ប៉ុន្តែ ទោះបីជា **ក** បានលក់ដីនោះទៅឱ្យ **គ** ហើយក៏ដោយ ក៏ **គ** អាចធ្វើលទ្ធកម្មនូវដីនោះដោយមានជាប់បន្ទុកហ៊ីប៉ូតែក។ ហេតុដូច្នេះ តម្លៃលក់ដីនោះត្រូវទាបជាង ៣.០០០ ដុល្លារ ដោយសារហានិភ័យដែល **ខ** អាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់គាត់។

## ៣. អានុភាពនៃហ៊ីប៉ូតែក

### ៣.១. ទំហំនៃអានុភាពហ៊ីប៉ូតែក

នៅពេលដែលហ៊ីប៉ូតែកមួយត្រូវបានបង្កើតឡើងនៅលើដីមួយកន្លែង ហ៊ីប៉ូតែកនោះមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីនោះរួមទាំងអគារ ដែលមាននៅលើដីដែលជាប់ហ៊ីប៉ូតែកនោះផងដែរ ទោះបីជាអគារនោះត្រូវបានសង់នៅមុនពេល ឬ ក្រោយពេលបង្កើតហ៊ីប៉ូតែកក៏ដោយ (មាត្រា ៨៤៦)។

ចំណុចនេះគឺដោយហេតុថា យោងតាមមាត្រា ១២២ នៃក្រមរដ្ឋប្បវេណី វត្ថុដែលនៅជាប់នឹងដី ឬ វត្ថុដែល

ក្លាយជាភាគមួយនៃដី ជាពិសេស អគារ ឬ សំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរកន្លែងបាន គឺជាសមាសភាគនៃដី។ ហេតុនេះ នាំឱ្យសិទ្ធិហ៊ីប៉ូតែក នឹងមានអានុភាពទៅលើអ្វីដែលជាសមាសភាគនៃដីនោះដែរ។

**ឧទាហរណ៍ : ក** គឺជាម្ចាស់ដីមួយកន្លែង។ **ក** បានសាងសង់អគារមួយនៅលើដីនោះ មុនការបង្កើតសិទ្ធិលើហ៊ីប៉ូតែក។ ក្រោយមក **ក** បានបង្កើតសិទ្ធិហ៊ីប៉ូតែកនៅលើដីនោះទៅឱ្យ **ខ**។ ពេលនោះ អានុភាពនៃហ៊ីប៉ូតែករបស់ **ខ** គឺមាននៅលើដីផង និង អគារផង។

សិទ្ធិហ៊ីប៉ូតែកនៅលើអចលនវត្ថុ មិនមានអានុភាពទៅលើផលស៊ីវិល ឬ ផលធម្មជាតិដែលកើតចេញពីអចលនវត្ថុនោះទេ (មាត្រា ៨៤៨)។ ដោយសារតែហ៊ីប៉ូតែកត្រូវបានបង្កើតជាថ្នូរទៅនឹងតម្លៃនៅលើអចលនវត្ថុមួយដើម្បីធានាកាតព្វកិច្ច ប៉ុន្តែអ្នកបង្កើតហ៊ីប៉ូតែកនៅលើអចលនវត្ថុមួយ គឺនៅតែមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុនោះដដែល ដូចនេះផលជាកម្មសិទ្ធិរបស់អ្នកបង្កើតហ៊ីប៉ូតែក។ មានន័យថា ទោះបីជាដី ឬ អគារ ត្រូវបានដាក់ហ៊ីប៉ូតែកហើយក៏ដោយ ក៏ថ្លៃឈ្នួលដែលកើតចេញពីដី ឬ អគារនោះនៅតែជារបស់អ្នកបង្កើតហ៊ីប៉ូតែក។ ប៉ុន្តែនៅពេលដែលអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះត្រូវបានលក់ដោយការអនុវត្តហ៊ីប៉ូតែក អ្នកទិញនឹងធ្វើនូវលទ្ធកម្មកម្មសិទ្ធិពេញលេញ ហើយអ្នកបង្កើតហ៊ីប៉ូតែកនឹងត្រូវបាត់បង់កម្មសិទ្ធិលើអចលនវត្ថុនោះ។ សិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុរបស់អ្នកបង្កើតហ៊ីប៉ូតែកនោះ ក៏ត្រូវរលត់ដែរ។ ហេតុដូច្នេះហើយបានជាមាត្រា ៨៤៨ និង មាត្រា ៨៤៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីចែងថាហ៊ីប៉ូតែកនឹងមានអានុភាពចំពោះផល តែនៅពេលដែលអចលនវត្ថុជាប់ហ៊ីប៉ូតែកនោះត្រូវបានរឹបអូស ហើយម្ចាស់បំណុលហ៊ីប៉ូតែកអាចរឹបអូសផលនោះ។ ចំណែកនីតិវិធីអនុវត្តចំពោះផលក្រោយការរឹបអូសអចលនវត្ថុ មានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥១៦។

### ៣.២. ឧបាទេសកម្ម

ដូចដែលបានពន្យល់រួចមកហើយថា ហ៊ីប៉ូតែក គឺជាសិទ្ធិដើម្បីប្តូរនឹងតម្លៃនៃកម្មវត្ថុជាក់លាក់ណាមួយ។ ដូច្នេះម្ចាស់សិទ្ធិហ៊ីប៉ូតែកអាចអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួន ចំពោះប្រាក់ ឬ វត្ថុផ្សេងទៀត ដែលអ្នកបង្កើតហ៊ីប៉ូតែកមានសិទ្ធិទទួល ដោយមូលហេតុនៃការលក់ ឬ ការបាត់បង់ ឬ ការខូចខាតកម្មវត្ថុនៃហ៊ីប៉ូតែកនោះ (មាត្រា ៨៤៩ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ព្រោះមូលហេតុទាំងនោះ ត្រូវបានគេចាត់ទុកជាការបំប្លែងនូវតម្លៃនៃអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះ។ ប៉ុន្តែ ម្ចាស់សិទ្ធិហ៊ីប៉ូតែកពុំអាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងទៀត ត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើតនោះទេ (មាត្រា ៨៤៩ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)។ ដោយសារតែហ៊ីប៉ូតែកត្រូវបានបង្កើតឡើង និង អាចអនុវត្តបានតែចំពោះកម្មវត្ថុណាមួយជាក់លាក់តែប៉ុណ្ណោះ ដូច្នេះប្រាក់ ឬ វត្ថុផ្សេងទៀត មិនអាចត្រូវបានគេបែងចែកពីទ្រព្យសម្បត្តិផ្សេងទៀតបានទេ នៅក្រោយដែលប្រាក់ ឬ វត្ថុផ្សេងទៀតនោះ ត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើតហ៊ីប៉ូតែក។ ហេតុនេះ ហ៊ីប៉ូតែកមិនអាចអនុវត្ត

ចំពោះទ្រព្យនោះបានទៀតទេ។ ដូច្នេះ ប្រសិនម្ចាស់បំណុលចង់អនុវត្តសិទ្ធិហ៊ីប៉ូតែកតាមរយៈឧបាទេសកម្មលើវត្ថុ ម្ចាស់បំណុលត្រូវអនុវត្តឧបាទេសកម្មលើហ៊ីប៉ូតែករបស់ខ្លួនឱ្យបានមុនការប្រគល់ប្រាក់ ឬ វត្ថុដែលកើតចេញពីមូលហេតុនៃការលក់ ឬ ការបាត់បង់ ឬ ការខូចខាតចំពោះកម្មវត្ថុ នោះទៅឱ្យកូនបំណុលហ៊ីប៉ូតែក។

> **ឧទាហរណ៍ ៖ ក** បានបង្កើតសិទ្ធិហ៊ីប៉ូតែកនៅលើអគារមួយកន្លែងរបស់ខ្លួនទៅឱ្យ **ខ** ដើម្បីធានាបំណុលរបស់ខ្លួនចំនួន ១០.០០០ ដុល្លារ។ ប៉ុន្តែ **គ** បានធ្វើឱ្យអគារនោះឆេះ។ ដូចនេះ **ខ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកអាចប្តឹងទាមទារប្រាក់ដែលជាថ្លៃសំណងខូចខាតអគារពី **គ** បានតាមរយៈឧបាទេសកម្មលើវត្ថុនៃម្ចាស់សិទ្ធិហ៊ីប៉ូតែកលើវត្ថុនោះ។ តែបើ **គ** បានផ្តល់ប្រាក់សំណងខូចខាតនៃអគារនោះទៅឱ្យ **ក** រួចហើយ **ខ** មិនអាចប្តឹងទាមទារប្រាក់ពី **ក** តាមរយៈឧបាទេសកម្មលើវត្ថុបានទៀតទេ ព្រោះថាប្រាក់ដែលជាសំណងថ្លៃខូចខាតនៃអគារដែល **ក** ទទួលបាននោះ ក្លាយទៅជាទ្រព្យទូទៅរបស់ **ក** ហើយ។ តែ **ខ** នៅតែអាចទាមទារប្រាក់ជំពាក់ពី **ក** ក្នុងនាមជាម្ចាស់បំណុលធម្មតាបាន។

### ៣.៣. សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ចនោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើដីហ៊ីប៉ូតែកដោយសារការអនុវត្តហ៊ីប៉ូតែកនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណងពីកូនបំណុល ដោយយោងទៅតាមបញ្ញត្តិស្តីពីការធានា (មាត្រា ៨៥០ នៃក្រមរដ្ឋប្បវេណី)។ បញ្ញត្តិនេះឆ្លើយតបទៅនឹងមាត្រា ៩១១ និង បញ្ញត្តិមាត្រាដែលទាក់ទងមួយចំនួនផ្សេងទៀតនៃក្រមរដ្ឋប្បវេណី ។

> **ឧទាហរណ៍ ៖ ក** គឺជាកូនបំណុលដែលបានជំពាក់ប្រាក់គេចំនួន ១.០០០ ដុល្លារ។ **ខ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែក ហើយ **គ** គឺជាអ្នកធានាដោយវត្ថុដែលបានធានាបំណុលចំនួន ១.០០០ ដុល្លារនេះ។
>
> **ខ** អនុវត្តហ៊ីប៉ូតែករបស់ខ្លួន ហើយបានទទួលនូវការសងគ្រប់ចំនួន ហើយ **គ** បានបាត់បង់នូវកម្មសិទ្ធិរបស់ខ្លួន (អ្នកផ្សេងទទួលកម្មសិទ្ធិនោះ)។
>
> នៅក្នុងករណីនេះ **គ** ទទួលនូវសិទ្ធិទាមទារសំណងចំនួន ១.០០០ ដុល្លារពី **ក** ។
>
> **ចំណុចខុសប្លែកគ្នារវាងអ្នកធានាដោយវត្ថុ និង អ្នកធានាធម្មតា**
>
> ភាពខុសប្លែកគ្នាដ៏សំខាន់រវាងសិទ្ធិ និង កាតព្វកិច្ចរបស់អ្នកធានាដោយវត្ថុ និង អ្នកធានាធម្មតា មានពីរ។ ទី ១ គឺអ្នកធានាធម្មតាមានករណីយកិច្ច រីឯអ្នកធានាដោយវត្ថុវិញមិនមានករណីយកិច្ចទេ ហើយមួយទៀត គឺអ្នកធានាធម្មតាទទួលខុសត្រូវចំពោះរាល់ចំនួនប្រាក់ធានា ចំណែកឯការទទួលខុសត្រូវរបស់អ្នកធានាដោយវត្ថុវិញ ត្រូវបានកម្រិតត្រឹមតែការបាត់បង់នូវវត្ថុដែលត្រូវបានដាក់ធានាតែប៉ុណ្ណោះ សូមពិនិត្យមើលឧទាហរណ៍ដូចខាងក្រោមនេះ ៖

ក ជាម្ចាស់បំណុល ហើយ ខ ជាកូនបំណុល។ គ មានអចលនវត្ថុមួយកន្លែង ហើយបានយកអចលនវត្ថុនោះទៅដាក់ហ៊ីប៉ូតែកដើម្បីធានាបំណុលឱ្យ ខ។ ពេលនោះ គេហៅ គ ថាជាអ្នកធានាដោយវត្ថុនៅក្នុងករណីនេះ។ គ មានឋានៈស្រដៀងគ្នានឹងអ្នកធានាធម្មតាដែរ តែខុសគ្នាត្រង់ថា ក ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិត្រឹមតែទាមទារឱ្យ ខ ដែលជាកូនបំណុលសងបំណុលមកខ្លួនមិនមែនទាមទារឱ្យ គ សងទេ។ បើ ខ សងបំណុលទៅ ក ហើយ ក មិនអាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបានទៀតទេ។ តែបើ ខ មិនអាចសងបំណុលទៅ ក បានទេ អចលនវត្ថុរបស់ គ នឹងត្រូវបានរឹបអូសដោយ ក។

ចំណុចដែលខុសគ្នាពីកិច្ចធានា គឺនៅត្រង់ថាបើសិនជា គ គឺជាអ្នកធានា ក ដែលជាម្ចាស់បំណុលមានសិទ្ធិលើបំណុលចំពោះលោក ខ ផង និង លោក គ ផង។ នេះមានន័យថា ក មានសិទ្ធិទាមទារឱ្យ ខ សងក៏បាន ឬ លោក គ សងក៏បាន។

## ៣.៤. លំដាប់នៃហ៊ីប៉ូតែក

ដូចដែលបានលើកឡើងពីខាងដើមហើយថា កូនបំណុលអាចបង្កើតហ៊ីប៉ូតែកលើទ្រព្យតែមួយទៅឱ្យម្ចាស់បំណុលច្រើនគ្នា ដែលនេះជាចំណុចមួយដែលមានប្រយោជន៍បំផុតនៅក្នុងចំណោមចំណុចជាច្រើន បើប្រៀបធៀបទៅនឹងការធានា។

មាត្រា ៨៥១ នៃក្រមរដ្ឋប្បវេណី បានចែងថា ក្នុងករណីដែលមានការបង្កើតហ៊ីប៉ូតែកនៅលើអចលនវត្ថុ តែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើនលំដាប់នៃហ៊ីប៉ូតែកនោះ ត្រូវអនុលោមតាមពេលវេលាដែលបានចុះបញ្ជី។

### ៣.៤.១. អត្ថន័យលំដាប់នៃហ៊ីប៉ូតែក

ក្នុងការអនុវត្តហ៊ីប៉ូតែកចំពោះអចលនវត្ថុនេះដែរ មានបញ្ញត្តិមួយចំនួនដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងប្រធានបទនេះដែលនឹងត្រូវលើកយកមកធ្វើការពិភាក្សា ទោះបីជាយើងកំពុងសិក្សាពីច្បាប់សារធាតុក៏ដោយ។ នីតិវិធីនៃការអនុវត្តនេះ គឺដើម្បីដោះស្រាយនូវវិវាទរវាងហ៊ីប៉ូតែកច្រើន ឬ វិវាទនានារវាងហ៊ីប៉ូតែកជាមួយនឹងម្ចាស់សិទ្ធិប្រត្យក្ស ឬ សិទ្ធិប្រាតិភោគប្រត្យក្សផ្សេងទៀត នៅលើអចលនវត្ថុតែមួយដែលជាកម្មវត្ថុនៃការអនុវត្តហ៊ីប៉ូតែកនោះ។ ចំណុចទាំងនេះ នឹងត្រូវលើកយកមកបង្ហាញដូចខាងក្រោមនេះ :

ជាគោលការណ៍ ការអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្ស គឺធ្វើឡើងតាមវិធីលក់ដោយបង្ខំដើម្បីទទួលសំណងជាអាទិភាពពីប្រាក់ដែលបានមកពីការលក់នេះ។ តើសិទ្ធិប្រាតិភោគប្រត្យក្សផ្សេងទៀត ក្រៅពីសិទ្ធិប្រាតិភោគប្រត្យក្សដែលត្រូវបានអនុវត្តលើអចលនវត្ថុនោះ ដូចជា ហ៊ីប៉ូតែកនឹងត្រូវរលត់ក្រោយការលក់ ឬ យ៉ាងណា? យោងតាមមាត្រា ៥១០ កថាខណ្ឌទី ១ និង ទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី *សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុ សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុ និង សិទ្ធិជួលអចលនវត្ថុដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគ*

*របស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបន្តអត្ថិភាពក្រោយការលក់ដោយបង្ខំ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ។ ក្រៅពីសិទ្ធិដែលបានកំណត់ខាងលើនេះ សិទ្ធិលើអចលនវត្ថុត្រូវរលត់ដោយការលក់ ។*

តាមរយៈមាត្រានេះ យើងឃើញថា បើពាក្យសុំឱ្យចាប់ផ្តើមនីតិវិធីអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវបានធ្វើឡើងដោយម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគប្រត្យក្សណាមួយ ជាមុននោះ សិទ្ធិប្រត្យក្សផ្សេងៗទៀតរួមទាំងសិទ្ធិប្រាតិភោគប្រត្យក្សផងដែរ ដែលឋិតនៅក្នុងលំដាប់អាទិភាពខ្ពស់ជាងម្ចាស់សិទ្ធិប្រាតិភោគប្រត្យក្សដែលដាក់ពាក្យសុំអនុវត្តមុននោះមិនរលត់ដោយនីតិវិធីអនុវត្តទេ (មាត្រា ៥១០ កថាខណ្ឌទី ១) ផ្ទុយទៅវិញ បើសិទ្ធិប្រត្យក្ស ឬ សិទ្ធិប្រាតិភោគប្រត្យក្សផ្សេងៗនោះ មានលំដាប់អាទិភាពទាបជាងសិទ្ធិប្រាតិភោគប្រត្យក្សដែលដាក់ពាក្យសុំអនុវត្តមុននោះ ពេលនោះសិទ្ធិប្រត្យក្ស ឬ សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុនោះ ត្រូវរលត់ដោយការអនុវត្ត ( មាត្រា ៥១០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

**ឧទាហរណ៍ : ក ខ** និង **គ** សុទ្ធតែជាម្ចាស់បំណុលហ៊ីប៉ូតែកនៅលើដីមួយកន្លែង។ **ក** ជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ១។ **ខ** ជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ២។ **គ** ជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ៣។ បើសិនជា **ក** ដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួនបានមុននោះ ពេលនោះ **ខ** និង **គ** អាចចូលរួមចែកចំណែកដែរ។ តែបើសិនជា **ខ** ឬ **គ** ដាក់ពាក្យសុំអនុវត្តបានមុននោះ ពេលនោះ **ក** មិនអាចចូលរួមក្នុងការចែកចំណែកទេ។ ព្រោះសិទ្ធិហ៊ីប៉ូតែករបស់ **ក** មិនរលត់ទេ។ **ក** នៅតែអាចដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួនពីតតិយជនដែលបានធ្វើលទ្ធកម្មលើដីនោះ តាមរយៈការលក់ដោយបង្ខំដដែល ។

ដូច្នេះ ក្រមរដ្ឋប្បវេណីកម្ពុជា បានអនុម័តយកគោលការណ៍ទទួលបន្តចំពោះសិទ្ធិប្រាតិភោគប្រត្យក្សមានន័យថាកំណត់ឱ្យអ្នកទិញនូវអចលនវត្ថុនៃការអនុវត្ត ទទួលបន្តនូវបន្ទុកទាំងឡាយដែលមានលើអចលនវត្ថុនោះ ក្រោយពេលអនុវត្តដោយបង្ខំ។ គោលការណ៍នេះ យកចិត្តទុកដាក់លើការការពារអ្នកដែលមានសិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុ។ ចំពោះគោលការណ៍ទទួលបន្តចំពោះសិទ្ធិប្រាតិភោគប្រត្យក្សនេះដែរ អ្នកទិញអាចទិញអចលនវត្ថុក្នុងតម្លៃមួយថោកជាងតម្លៃពិតប្រាកដនៃអចលនវត្ថុនោះ ដោយគ្មានជាប់បន្ទុកសិទ្ធិប្រត្យក្ស ឬ សិទ្ធិប្រាតិភោគប្រត្យក្សផ្សេងទៀតនោះទេ ដោយសារខ្លួនត្រូវទទួលបន្តនូវបន្ទុកនៃកាតព្វកិច្ចដែលត្រូវធានាដោយសិទ្ធិប្រាតិភោគប្រត្យក្សជាលក្ខខណ្ឌមូលដ្ឋាន។

ព្រមជាមួយគ្នានេះដែរ មាត្រា ៤៤៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា អ្នកទិញត្រូវទទួលខុសត្រូវក្នុងការសងនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគដែលអ្នកទិញបានទទួលបន្ត។

ហើយអ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា ម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលឋិតក្នុងលំដាប់ទី ១ អាចទទួលនូវការសងដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកដែលឋិតក្នុងលំដាប់បន្ទាប់។ ម្ចាស់បំណុលហ៊ីប៉ូតែកមិនទទួលបានការសងតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលឡើយ ។

**ករណីសិក្សា ៖**

**ក** គឺជាម្ចាស់សិទ្ធិហ៊ីប៉ូតែកលំដាប់ទី ១ ដែលត្រូវបានធានាដោយទឹកប្រាក់ចំនួន ៤០០ ដុល្លារ ដោយ **ឃ** ។

**ខ** គឺជាម្ចាស់សិទ្ធិហ៊ីប៉ូតែកលំដាប់ទី ២ ដែលត្រូវបានធានាដោយទឹកប្រាក់ចំនួន ៣០០ ដុល្លារ ដោយ **ឃ** ។

**គ** គឺជាម្ចាស់សិទ្ធិហ៊ីប៉ូតែកលំដាប់ទី ៣ ដែលត្រូវបានធានាដោយទឹកប្រាក់ចំនួន ២០០ ដុល្លារ ដោយ **ឃ** ។

កម្មវត្ថុនៃសិទ្ធិហ៊ីប៉ូតែក គឺដី **(១)** ដែលជាកម្មសិទ្ធិរបស់ **ឃ** ។

១-១ **ក** បានដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួន។ ដី **(១)** ត្រូវបានលក់នៅក្នុងតម្លៃ ៦០០ ដុល្លារ ។

តើនរណាត្រូវទទួលប្រាក់ដែលបានមកពីការលក់នោះ? តើត្រូវទទួលចំនួនប៉ុន្មាន? តើសិទ្ធិណាខ្លះដែលត្រូវបន្តអត្ថិភាព ហើយសិទ្ធិណាខ្លះដែលត្រូវរលត់?

**ចម្លើយ ៖** តាមរយៈការដាក់ពាក្យសុំឱ្យអនុវត្តរបស់ **ក** ហ៊ីប៉ូតែករបស់គាត់ និង ហ៊ីប៉ូតែកដែលស្ថិតនៅលំដាប់ទាបជាងនឹងត្រូវរលត់។ បន្ទាប់មកប្រាក់ដែលបានមកពីការលក់ដោយបង្ខំចំនួន ៤០០ ដុល្លារ នឹងត្រូវចែងទៅឱ្យ **ក** ហើយប្រាក់ដែលនៅសល់ចំនួន ២០០ ដុល្លារ នឹងត្រូវចែកទៅឱ្យ **ខ** ប៉ុន្តែមិនមែនចែកទៅឱ្យ **គ** នោះទេ។ ការចែកចំណែកត្រូវចែកឱ្យគ្រប់ចំនួននៃសិទ្ធិលើបំណុលទាំងអស់របស់ **ក** និង ផ្នែកនៃសិទ្ធិលើបំណុលរបស់ **ខ**។ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលនៅសល់របស់ **ខ** គឺមានចំនួន ១០០ ដុល្លារ ហើយរបស់ **គ** ចំនួន ២០០ ដុល្លារ ។

១-២ តើវាខុសគ្នាយ៉ាងណាទៅវិញ ប្រសិនបើថ្លៃលក់មានចំនួន ២.០០០ ដុល្លារ?

ហ៊ីប៉ូតែកទាំងអស់នឹងត្រូវរលត់។ ប្រាក់ដែលបានមកពីការលក់ត្រូវចែកទៅឱ្យម្ចាស់បំណុលទាំងអស់ ពីព្រោះទឹកប្រាក់មានចំនួនគ្រប់គ្រាន់ ដើម្បីសងសិទ្ធិលើបំណុលទាំងអស់។ ហើយបន្ទាប់មកទៀត ប្រាក់ដែលនៅសល់ចំនួន ១.១០០ ដុល្លារ ត្រូវប្រគល់ឱ្យ **ឃ**។ គ្មានសិទ្ធិលើបំណុលណាមួយត្រូវបន្តអត្ថិភាពនោះទេ ដោយសារតែការចែកចំណែកគ្រប់ចំនួន។

២- **ខ** បានដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួន។ ដី **(១)** ត្រូវបានលក់ក្នុងតម្លៃ ៦០០ ដុល្លារ ។ តើនរណាត្រូវទទួលប្រាក់ដែលបានមកពីការលក់នេះ ហើយត្រូវទទួលបានចំនួនប៉ុន្មាន? តើសិទ្ធិណាខ្លះដែលត្រូវបន្តអត្ថិភាព និងសិទ្ធិណាខ្លះត្រូវរលត់?

**ចម្លើយ ៖** ការដាក់ពាក្យសុំឱ្យអនុវត្តរបស់ **ខ** នឹងធ្វើឱ្យហ៊ីប៉ូតែករបស់គាត់ និង ហ៊ីប៉ូតែករបស់ **គ** រលត់ពីព្រោះហ៊ីប៉ូតែករបស់ **គ** ស្ថិតនៅលំដាប់ទាបជាងហ៊ីប៉ូតែករបស់ **ខ** ប៉ុន្តែការដាក់ពាក្យសុំឱ្យអនុវត្តរបស់ **ខ** នេះនឹងមិនធ្វើឱ្យហ៊ីប៉ូតែករបស់ **ក** រលត់នោះទេ។ **ខ** នឹងទទួលបានប្រាក់ចំនួន ៣០០ ដុល្លារមុនគេ ហើយបន្ទាប់មក **គ** នឹងទទួលបាន ២០០ ដុល្លារ ហើយប្រាក់នៅសល់ចំនួន ១០០ ដុល្លារ នឹងត្រូវបានទៅ **ឃ**។ សិទ្ធិលើបំណុល និង ហ៊ីប៉ូតែករបស់ **ក** នឹងបន្តអត្ថិភាព។

៣- **គ** បានដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួន។ ដី (**១**) ត្រូវបានលក់ក្នុងតម្លៃ ៦០០ ដុល្លារ។ តើនរណាត្រូវទទួលប្រាក់ដែលបានមកពីការលក់នោះ? តើត្រូវទទួលចំនួនប៉ុន្មាន? តើសិទ្ធិណាខ្លះដែលត្រូវបន្តអត្ថិភាព ហើយសិទ្ធិណាខ្លះដែលត្រូវរលត់?

**ចម្លើយ :** ការដាក់ពាក្យសុំឱ្យអនុវត្តរបស់ **គ** នឹងធ្វើឱ្យរលត់តែហ៊ីប៉ូតែករបស់គាត់មួយតែប៉ុណ្ណោះ ព្រោះហ៊ីប៉ូតែកពីរផ្សេងទៀត ស្ថិតនៅក្នុងលំដាប់ខ្ពស់ជាងហ៊ីប៉ូតែករបស់ **គ**។ បន្ទាប់មក ប្រាក់ចំនួន ២០០ ដុល្លារ នឹងចែកឱ្យទៅ **គ** ហើយប្រាក់ដែលនៅសល់ចំនួន ៤០០ ដុល្លារ ទៀតនឹងបានទៅ **ឃ**។ សិទ្ធិលើបំណុល និង ហ៊ីប៉ូតែករបស់ **ក** និង **ខ** នឹងបន្តអត្ថិភាព។

រឿងក្ដីខាងក្រោមនេះ គឺដាច់ដោយឡែកពីរឿងក្ដីខាងលើ។

**ក** គឺជាម្ចាស់សិទ្ធិហ៊ីប៉ូតែកលំដាប់ទី ១ ដែលត្រូវបានធានាដោយទឹកប្រាក់ចំនួន ៤០០ ដុល្លារ។

**ខ** គឺជាម្ចាស់សិទ្ធិហ៊ីប៉ូតែកលំដាប់ទី ២ ដែលត្រូវបានធានាដោយទឹកប្រាក់ចំនួន ៣០០ ដុល្លារ។

កម្មវត្ថុនៃសិទ្ធិហ៊ីប៉ូតែកទាំងនេះ គឺដី (**១**) ដែលជាកម្មសិទ្ធិរបស់ **គ**។ ផ្អែកលើការពិនិត្យរបស់ **ឃ** តម្លៃនៃដី (**១**) គឺមានតម្លៃ ១.០០០ ដុល្លារ តើ **គ** រំពឹងថានឹងអាចខ្ចីប្រាក់ពី **ឃ** បានចំនួនប៉ុន្មាន តាមរយៈការយកដី (**១**) នោះមកដាក់ជាប្រាតិភោគ?

**ចម្លើយ :** ប្រសិនបើតម្លៃនៃដីដែលត្រូវបានប៉ាន់ប្រមាណទៅ គឺមានចំនួន ១.០០០ ដុល្លារ នោះ **ឃ** អាចរំពឹងទទួលបានប្រាក់ចំនួន ៣០០ ដុល្លារ ពីដី (១) ពីព្រោះថា តម្លៃចំនួន ៧០០ ដុល្លារ ត្រូវបានដាក់ជាប្រាតិភោគរួចហើយ។ ហេតុដូច្នេះ ក្នុងករណីប្រសិនបើមិនគិតពីការប្រាក់ទេ **ឃ** អាចឱ្យ **គ** ខ្ចីប្រាក់ច្រើនបំផុតត្រឹមចំនួន ៣០០ ដុល្លារ។

## ៣.៥. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

យោងតាមមាត្រា ៨៥២ កថាខណ្ឌទី ២ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារការប្រាក់ ឬ ធនលាភផ្សេងទៀត ម្ចាស់បំណុលហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែកនោះបានតែចំពោះចំនួននៃការសងដែលដល់កំណត់ពេលសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំ ចុងក្រោយតែប៉ុណ្ណោះ។ ប៉ុន្តែ ចំពោះធនលាភដែលមានពីមុនមក ប្រសិនបើបានចុះបញ្ជីពិសេស ក្រោយពីបានដល់ពេលកំណត់ត្រូវសង ហ៊ីប៉ូតែកនេះអាចអនុវត្តបានចាប់ពីពេលដែលបានចុះបញ្ជីនោះ។ មាត្រា ៨៥២ កថាខណ្ឌទី ១ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះប្រាក់ដែលត្រូវបង់សម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំចុងក្រោយ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារឱ្យសងសំណងនៃការខូចខាតដែលបានកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច។ ប៉ុន្តែ ក្នុងករណីនេះ ចំនួនសរុបនៃសំណងការខូចខាតព្រមទាំងការប្រាក់ និង ធនលាភផ្សេងទៀត មិនអាចលើសចំនួនសរុបសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំ បានឡើយ។

បានជាច្បាប់មានការកំណត់ដូច្នេះ ពីព្រោះវាមានភាពចាំបាច់សម្រាប់ការពារម្ចាស់បំណុលហ៊ីប៉ូតែកដទៃទៀតដែលស្ថិតនៅក្នុងលំដាប់ទាបជាង ដើម្បីឱ្យដឹងថាតើតម្លៃនៃអចលនវត្ថុដែលត្រូវបានយកមកដាក់ជាប្រាតិភោគនោះមានចំនួនប៉ុន្មាន។

**ឧទាហរណ៍ ៖ គ** បានយកដីរបស់ខ្លួនមួយកន្លែងដែលមានតម្លៃចំនួន ២.០០០ ដុល្លារ ទៅដាក់ហ៊ីប៉ូតែកឱ្យ **ខ** ដើម្បីធានាបំណុលចំនួន ១.០០០ ដុល្លារ នៅថ្ងៃទី ០៦ ខែ ០៧ ឆ្នាំ ២០០៦ ដោយយកការប្រាក់ ១០ ភាគរយ ក្នុងមួយ ឆ្នាំ។ ការយឺតយ៉ាវក្នុងការបង់ការប្រាក់ គឺ ២០ ភាគរយ។ កាលបរិច្ឆេទដែលត្រូវសងនៅថ្ងៃទី ០៦ ខែ ០៧ ឆ្នាំ ២០១១។ **គ** ចង់ខ្ចីប្រាក់ពី **គ** បន្ថែមទៀត។ ឧទាហរណ៍ ៖ ថ្ងៃនេះគឺជាថ្ងៃទី ០៦ ខែ ០៧ ឆ្នាំ ២០១៥។ ដូច្នេះរយៈពេល ២ ឆ្នាំចុងក្រោយ ដែលត្រូវយកមកគណនា គឺនៅឆ្នាំ ២០១៣។ ហេតុដូច្នេះ **ខ** អាចទទួលបានប្រាក់ច្រើនបំផុតចំនួន ១.៤០០ ដុល្លារ ពីហ៊ីប៉ូតែក ហើយ **គ** ត្រូវឱ្យខ្ចីច្រើនបំផុតចំនួន ៦០០ ដុល្លារ (ករណីប្រសិនបើ **គ** គិតការប្រាក់ **គ** ត្រូវឱ្យខ្ចីតិចជាងចំនួន ៦០០ ដុល្លារ)។

**ឧទាហរណ៍ ៖ គ** គឺជាកូនបំណុលដែលមានដីមួយកន្លែងតម្លៃ ៥០០ ដុល្លារ។ **គ** បានយកដីនោះទៅដាក់ហ៊ីប៉ូតែកឱ្យ **ខ** ដើម្បីធានាបំណុលរយៈពេលពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០១១ ចំនួន ១០០ ដុល្លារ ដោយយកការប្រាក់ ១០ ភាគរយ ក្នុងមួយឆ្នាំ។ **គ** ក៏បានខ្ចីប្រាក់ពី **គ** ដែរ ដោយយកដីដដែលនោះទៅដាក់ហ៊ីប៉ូតែកឱ្យ **គ** ដើម្បីធានាបំណុលរយៈពេលពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០១១ ចំនួន ២០០ ដុល្លារ ដោយមានការប្រាក់ ១០ ភាគរយ ក្នុងមួយឆ្នាំដូចគ្នា។ **គ** មិនបានបង់ការប្រាក់ឱ្យ **ខ** ចំនួន ៥ ឆ្នាំ ស្មើនឹងទឹកប្រាក់ចំនួន ៥០ ដុល្លារ។ **គ** ក៏មិនបានបង់ការប្រាក់ឱ្យ **គ** ចំនួន ៥ ឆ្នាំដែរ ស្មើនឹងទឹកប្រាក់ចំនួន ១០០ ដុល្លារ។ សន្មតថាដីនោះលក់បានតម្លៃ ៥០០ ដុល្លារ។

នៅក្នុងករណីនេះ តាមរយៈការដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ **ខ** យើងឃើញថា **ខ** ទទួលបាន = ១០០ + (១០០ x ការប្រាក់ ១០% x ២ ឆ្នាំ) = ១២០ ដុល្លារ។

**គ** ទទួលបាន = ២០០ + (២០០ x ការប្រាក់ ១០% x ២ ឆ្នាំ) = ២៤០ ដុល្លារ។

សូមកត់សម្គាល់ថា **គ** នៅតែជំពាក់ការប្រាក់ **ខ** ចំនួន ៣០ ដុល្លារ និង **គ** ចំនួន ៦០ ដុល្លារ។ **ខ** និង **គ** នៅតែអាចទាមទារការប្រាក់នេះពី **គ** ក្នុងនាមជាម្ចាស់សិទ្ធិលើបំណុល ប៉ុន្តែមិនអាចទាមទារក្នុងនាមជាម្ចាស់បំណុលហ៊ីប៉ូតែកបានទេ ពាក់ព័ន្ធនឹងចំនួនទឹកប្រាក់ដែលនៅសល់។

### ៤. ការអនុវត្តហ៊ីប៉ូតែក

យោងតាមបញ្ញត្តិដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី បើកូនបំណុលហ៊ីប៉ូតែកមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេ ម្ចាស់បំណុលហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនតាមរយៈការដាក់ពាក្យសុំឱ្យលក់ ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែកទៅតុលាការបាន។ អាចនិយាយបានម្យ៉ាងទៀតថា ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនបានឡើយ ក្នុងករណីប្រសិនបើកាតព្វកិច្ចត្រូវបានអនុវត្ត (មាត្រា ៨៥៣ នៃក្រមរដ្ឋប្បវេណី)។ ចំពោះនីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក គឺមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

**ឧទាហរណ៍ ៖ ខ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកចំនួន ១.០០០ ដុល្លារ នៅលើដី **(១)** មួយកន្លែងរបស់ **គ**។ បើដល់ពេលកំណត់សងហើយ **គ** មិនមានប្រាក់សងទេ នោះ **ខ** អាចដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ។ សន្មតថា អចលន

វត្ថុ (១) នោះលក់បានតម្លៃ ១.២០០ ដុល្លារ ។ ដូចនេះ ថ្លៃដែលលក់ចំនួន ១.០០០ ដុល្លារ ត្រូវយកទៅសងម្ចាស់បំណុលដែលជា ខ ។ តែបើដីនោះលក់បានតែ ៨០០ ដុល្លារ នោះ ក នៅជំពាក់ ខ ចំនួន ២០០ ដុល្លារ ទៀត ។ បំណុលដែលនៅសល់ចំនួន ២០០ ដុល្លារនេះ ខ នៅតែមានសិទ្ធិទាមទារពី ក ដដែល តែមិនមែនទាមទារក្នុងនាមជាម្ចាស់បំណុលហ៊ីប៉ូតែកទៀតទេ ព្រោះហ៊ីប៉ូតែករបស់ ខ ត្រូវរលត់ដោយការលក់អចលនវត្ថុហ៊ីប៉ូតែកនោះ ទៅតាមនីតិវិធីអនុវត្តដោយបង្គំរបស់តុលាការហើយ ។ ដូចនេះ សិទ្ធិទាមទារបំណុលដែលនៅសល់របស់ ខ នេះ គឺជាសិទ្ធិទាមទារបំណុលធម្មតា ។

### ៤.១. អ្នកទិញ

ពាក់ព័ន្ធនឹងការអនុវត្តហ៊ីប៉ូតែកនេះដែរ មានចំនុចមួយចំនួនដែលអ្នកដាក់ពាក្យសុំអនុវត្តគួរយល់ដឹង :

ក- កូនបំណុលមិនអាចក្លាយជាអ្នកទិញអចលនវត្ថុដែលខ្លួនបានដាក់ហ៊ីប៉ូតែកទេ ពីព្រោះថាបើកូនបំណុលមានលុយគ្រប់គ្រាន់ដើម្បីទិញអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះ គាត់គួរតែសងបំណុលទៅម្ចាស់បំណុលវិញ ហើយវាប្រសើរជាងការខាតបង់ពេលវេលា និង សោហ៊ុយចំណាយទៅលើការអនុវត្តហ៊ីប៉ូតែកនោះ ( មាត្រា ៤៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

ខ- ផ្ទុយទៅវិញ ម្ចាស់បំណុលហ៊ីប៉ូតែក ឬ អ្នកធានាដោយវត្ថុ អាចទិញអចលនវត្ថុដែលដាក់ហ៊ីប៉ូតែកនោះបាន ពីព្រោះពុំមានបទប្បញ្ញត្តិណាមួយដែលហាមឃាត់ម្ចាស់បំណុលហ៊ីប៉ូតែក ឬ អ្នកធានាដោយវត្ថុមិនឱ្យធ្វើការទិញ ជាទូទៅនោះទេ ។

គ- បើសិនជាតម្លៃដែលបានមកពីការលក់អចលនវត្ថុនោះ មិនគ្រប់គ្រាន់សម្រាប់សោហ៊ុយនីតិវិធីនៃការអនុវត្តទេ នីតិវិធីបែបនេះត្រូវបានចាត់ទុកថាមិនត្រឹមត្រូវ និង គ្មានប្រយោជន៍ ។ ហេតុដូច្នេះ មាត្រា ៤៣៥ តម្រូវឱ្យម្ចាស់បំណុលនៃការអនុវត្តធ្វើការស្នើថាខ្លួននឹងទិញអចលនវត្ថុក្នុងតម្លៃស្នើសុំ ក្នុងអំឡុងពេលមួយសប្តាហ៍ក្រោយពេលជូនដំណឹងទៅម្ចាស់បំណុលនៃការអនុវត្ត ក្នុងករណីដែលគ្មានលទ្ធភាពសល់ទេនោះ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ ។ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តមិនបានធ្វើសកម្មភាពដូច្នោះទេ តុលាការត្រូវលុបចោលពាក្យសុំការអនុវត្តនោះ ។ ដូចនេះ មុននឹងអនុវត្តហ៊ីប៉ូតែក តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃអចលនវត្ថុ ដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និង ស្ថានភាពបច្ចុប្បន្នឯទៀត ។ ម្ចាស់បំណុលដែលដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែក ត្រូវទទួលបន្ទុកបង់ជាមុនទៅតុលាការនូវសោហ៊ុយសម្រាប់ការអនុវត្ត និង សោហ៊ុយសម្រាប់នីតិវិធី យោងតាមមាត្រា ៣៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ៤.២. វិធានដើម្បីសម្របសម្រួលការអនុវត្តដោយបង្ខំ នៅពេលដែលមានម្ចាស់សិទ្ធិលើបំណុលច្រើនលើអចលវត្ថុដែលជាកម្មវត្ថុហ៊ីប៉ូតែក

ដូចដែលបានលើកឡើងពីខាងដើមហើយថា ការអនុវត្តដោយបង្ខំចំពោះហ៊ីប៉ូតែកមិនមានភាពស្មុគស្មាញខ្លាំងទេ នៅក្នុងករណីដែលមានតែកម្មវត្ថុនៃហ៊ីប៉ូតែកតែមួយ និង ម្ចាស់បំណុលហ៊ីប៉ូតែកតែម្នាក់នោះ ប៉ុន្តែការអនុវត្តនឹងកាន់តែស្មុគស្មាញ នៅពេលដែលមានម្ចាស់បំណុលហ៊ីប៉ូតែកច្រើននាក់ ឬ កម្មវត្ថុហ៊ីប៉ូតែកមានច្រើន ជាងមួយនោះ ដែលនេះចាំបាច់ត្រូវមានបញ្ញត្តិ ដើម្បីសម្របសម្រួលក្នុងការអនុវត្ត។

### ៤.២.១. ការអនុវត្តដោយបង្ខំក្នុងករណីដែលមានម្ចាស់បំណុលហ៊ីប៉ូតែកច្រើននាក់

ពាក់ពន្ធ័នឹងការអនុវត្តដោយបង្ខំ ក្នុងករណីដែលមានម្ចាស់សិទ្ធិហ៊ីប៉ូតែកច្រើននាក់ នៅលើអចលនវត្ថុតែមួយបែបនេះ មានសំណួរជាច្រើនត្រូវបានលើកឡើងដូចជា "តើមានតែម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលនៅលំដាប់ទី ១ តែប៉ុណ្ណោះដែលអាចដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែកបាន?" "តើម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលឋិតនៅក្នុងលំដាប់ទី ២ ឬ លំដាប់ចុងក្រោយ អាចដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុនម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលឋិតនៅក្នុងលំដាប់ទី ១ ដែរ ឬ ទេ?" "តើការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំរបស់ម្ចាស់សិទ្ធិហ៊ីប៉ូតែកលំដាប់ទី ១ ធ្វើឱ្យ មានអានុភាពយ៉ាងដូចម្ដេច?" "តើសិទ្ធិហ៊ីប៉ូតែកទាំងនេះត្រូវរលត់ព្រមគ្នា ឬ មានសិទ្ធិហ៊ីប៉ូតែកខ្លះត្រូវនៅបន្តអត្ថិភាពក្រោយការលក់ដោយបង្ខំនោះ?" " តើម្ចាស់សិទ្ធិហ៊ីប៉ូតែកម្នាក់ៗ ត្រូវទទួលចំណែកប៉ុន្មានពីថ្លៃលក់ដោយបង្ខំនោះ?" ជាដើម។

ដើម្បីឆ្លើយតបទៅនឹងសំណួរដែលបានលើកឡើងខាងលើនេះ មាត្រា ៥១០ កថាខណ្ឌទី ១ និង ទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា *សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបន្តអត្ថិភាពក្រោយការលក់ដោយបង្ខំ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគនោះ។ ក្រៅពីសិទ្ធិដែលបានកំណត់ខាងលើនេះ សិទ្ធិលើអចលនវត្ថុត្រូវរលត់ដោយការលក់*។ ម្យ៉ាងវិញទៀត មាត្រា ៤៤៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា *អ្នកទិញត្រូវទទួលខុសត្រូវក្នុងការសងនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ ដែលអ្នកទិញបានទទួលបន្ត*។

គ្មានបញ្ញត្តិណាមួយនៃច្បាប់សារធាតុ និង ច្បាប់នីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្ស ហាមមិនឱ្យម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ទាបជាងគេ ដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំមុនម្ចាស់បំណុលហ៊ីប៉ូតែក ដែលមានលំដាប់ខ្ពស់ជាងគេនោះទេ។

នេះមានន័យថា បើសិនជាម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់អាទិភាពបានដាក់ពាក្យសុំឱ្យអនុវត្ត នោះហ៊ីប៉ូតែកដែលមានលំដាប់ទាបជាង នឹងត្រូវរលត់ជាបន្តបន្ទាប់។ តែផ្ទុយទៅវិញ បើសិនជាម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់បន្ទាប់ដាក់ពាក្យសុំឱ្យអនុវត្តមុន នោះហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាងនឹងមិនរលត់ទេ។ សួរថា តើលក្ខខណ្ឌតតាំងសំដៅទៅលើអ្វី។ វាសំដៅទៅលើលំដាប់នៃការចុះបញ្ជីសិទ្ធិប្រាតិភោគប្រត្យក្ស។ សំណួរសួរថា តើប្រាក់ដែលបានមកពីការលក់ត្រូវបែងចែកយ៉ាងដូចម្ដេច បើហ៊ីប៉ូតែកច្រើនត្រូវបានរលត់? ចំពោះការបែងចែកចំណែក

នៃប្រាក់ដែលបានពីការលក់ដោយបង្ខំនោះ គឺត្រូវផ្តល់ឱ្យទៅតាមលំដាប់នៃសិទ្ធិដែលមានអាទិភាពមិនមែន ទៅតាមសមាមាត្រទេ។

ដើម្បីឱ្យយល់កាន់តែច្បាស់អំពីនីតិវិធីនៃការអនុវត្តនេះ សូមពិនិត្យមើលករណីសិក្សាខាងក្រោមនេះ :

**ករណីដែលមានម្ចាស់បំណុលហ៊ីប៉ូតែកច្រើននាក់ :**

ឧបមាថាតម្លៃនៃដី (១) ដែលជាកម្មសិទ្ធិរបស់ **ក** ត្រូវបានគេវាយតម្លៃថាមានតម្លៃចំនួន ១.០០០ ដុល្លារ ហើយដើម្បីឱ្យងាយស្រួល គឺមិនចាំបាច់គិតពីសោហ៊ុយនៃនីតិវិធីនោះទេ។

**ខ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ១ ដែលត្រូវបានធានាដោយបំណុលចំនួន ៥០០ ដុល្លាររបស់ **ក**។

**គ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ២ ដែលត្រូវបានធានាដោយបំណុលចំនួន ៤០០ ដុល្លាររបស់ **ក**។

**ឃ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ៣ ដែលត្រូវបានធានាដោយបំណុលចំនួន ៣០០ ដុល្លាររបស់ **ក**។

១- តើហ៊ីប៉ូតែកណាដែលនៅបន្តអត្ថិភាព ហើយហ៊ីប៉ូតែកណាដែលត្រូវរលត់ នៅក្រោយពេលដែលហ៊ីប៉ូតែករបស់ **ខ** ត្រូវបានអនុវត្ត? តើដី (**១**) ត្រូវបានគេវាយតម្លៃថា អាចលក់បានតម្លៃប៉ុន្មាន? ហើយតើម្ចាស់បំណុលហ៊ីប៉ូតែកនីមួយៗ នឹងទទួលបានចំណែកចំនួនប៉ុន្មាន?

**ចម្លើយ :** យោងតាមមាត្រា ៥១០ កថាខណ្ឌទី ១ និង ទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី បើសិនជា **ខ** ដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុនគេ នោះហ៊ីប៉ូតែករបស់ **គ** និង **ឃ** ត្រូវរលត់ដោយការលក់ដោយបង្ខំ ព្រោះហ៊ីប៉ូតែករបស់ពួកគេ មិនអាចយកមកតតាំងចំពោះហ៊ីប៉ូតែករបស់ **ខ** បានឡើយ។ ហើយ **គ** និង **ឃ** អាចចូលរួមក្នុងការចែកចំណែកដោយស្វ័យប្រវត្តិ ជំនួសឱ្យការរលត់នៃហ៊ីប៉ូតែករបស់ពួកគេ។ តម្លៃលក់អប្បបរមានៃដី (**១**) គឺ ១.០០០ ដុល្លារ ព្រោះតម្លៃដើមនៃដី (**១**) មានចំនួន ១.០០០ ដុល្លារ ហើយហ៊ីប៉ូតែកទាំងអស់ត្រូវរលត់អស់ហើយដោយការអនុវត្ត។ នៅពេលដែលអ្នកទិញ ទិញដី (**១**) នៅក្នុងតម្លៃអប្បបរមា នោះ **ខ** ត្រូវទទួលបានចំណែក ៥០០ ដុល្លារ **គ** ត្រូវទទួលបានចំណែក ៤០០ ដុល្លារ និង **ឃ** ត្រូវទទួលបានចំណែក ១០០ ដុល្លារ។

២- តើហ៊ីប៉ូតែកណាដែលនៅបន្តអត្ថិភាព ហើយហ៊ីប៉ូតែកណាដែលត្រូវរលត់ នៅក្រោយពេលដែលហ៊ីប៉ូតែករបស់ **គ** ត្រូវបានអនុវត្ត? តើដី (**១**) ត្រូវបានគេវាយតម្លៃថាអាចលក់បានតម្លៃប៉ុន្មាន? ហើយតើម្ចាស់បំណុលហ៊ីប៉ូតែកនីមួយៗ នឹងទទួលបានចំណែកចំនួនប៉ុន្មាន?

**ចម្លើយ :** ប្រសិនបើ **គ** ដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុន នោះ ហ៊ីប៉ូតែករបស់ **ឃ** ត្រូវរលត់ជាមួយគ្នា ដោយផ្អែកលើមាត្រា ៥១០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប៉ុន្តែហ៊ីប៉ូតែករបស់ **ខ** មិនរលត់ទេ ដោយផ្អែកលើមាត្រា ៥១០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ **ឃ** ក៏អាចចូលរួមក្នុងការចែកចំណែកជាមួយ **គ** បានដែរ។ ប៉ុន្តែ **ខ** មិនអាចចូលរួមក្នុងការចែកចំណែកបានទេ ផ្ទុយទៅវិញ **ខ** អាចដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួននៅពេលក្រោយបាន។ តម្លៃលក់អប្បបរមានៃដី (**១**) គឺ ៥០០ ដុល្លារ ព្រោះអ្នកទិញ នឹងធ្វើលទ្ធកម្មដីនោះដោយមានជាប់បន្ទុកហ៊ីប៉ូតែក ដែលត្រូវបានធានាដោយបំណុលចំនួន ៥០០ ដុល្លារ។

នៅពេលដែលអ្នកទិញ ទិញដី (**១**) នៅក្នុងតម្លៃអប្បបរមា នោះ **គ** ត្រូវទទួលបានចំណែក ៤០០ ដុល្លារ ហើយ **ឃ** ត្រូវទទួលបានចំណែក ១០០ ដុល្លារ។

៣- តើហ៊ីប៉ូតែកណាដែលនៅបន្តអត្ថិភាព ហើយហ៊ីប៉ូតែកណាដែលត្រូវរលត់ នៅក្រោយពេលដែលហ៊ីប៉ូតែករបស់ **ឃ** ត្រូវបានអនុវត្ត? ហើយម្ចាស់បំណុលនីមួយៗនឹងទទួលបានចំណែកចំនួនប៉ុន្មាន ?

**ចម្លើយ :** បើសិនជា **ឃ** ដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុន នោះហ៊ីប៉ូតែករបស់ **ឃ** ត្រូវរលត់។ ប៉ុន្តែ ហ៊ីប៉ូតែករបស់ **ខ** និង **គ** មិនរលត់ទេ ដោយផ្អែកលើមាត្រា ៥១០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ **ខ** និង **គ** មិនអាចចូលរួមក្នុងការចែកចំណែកបានទេ។ ផ្ទុយទៅវិញ **ខ** និង **គ** អាចដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួន ចំពោះអ្នកដែលបានធ្វើលទ្ធកម្មលើដី (**១**) នៅពេលក្រោយបាន។ តម្លៃលក់អប្បបរមានៃដី (**១**) គឺ ១០០ ដុល្លារ ព្រោះអ្នកទិញ ត្រូវទទួលបន្ទុកហ៊ីប៉ូតែករបស់ **ខ** និង **គ** ដែលត្រូវធានាបំណុល ៩០០ ដុល្លារ។ នៅពេលអ្នកទិញ ទិញដី (**១**) នៅក្នុងតម្លៃលក់អប្បបរមា នោះ **ឃ** ទទួលបានប្រាក់តែ ១០០ ដុល្លារ តែប៉ុណ្ណោះ។

យោងតាមករណីសិក្សាខាងលើ មិនថាម្ចាស់បំណុលហ៊ីប៉ូតែកនៅក្នុងលំដាប់ណាបាន ដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែកមុននោះទេ ចំណែក **ឃ** បានទទួលចំណែក គឺមានចំនួនទឹកប្រាក់ដូចគ្នាដដែល ប្រសិនបើ ដី (**១**) ត្រូវបានគេលក់នៅក្នុងតម្លៃអតិបរមា។

### ៩.២.២. ការអនុវត្តដោយបង្ខំចំពោះអាគារជាកម្មសិទ្ធិរបស់តតិយជន

មាត្រា ៨៥៤ នៃក្រមរដ្ឋប្បវេណីបានចែងថា *បើអ្នកបង្កើតហ៊ីប៉ូតែក មានកម្មសិទ្ធិលើអាគារដែលអ្នកបង្កើតហ៊ីប៉ូតែកនោះ ឬ តតិយជនបានសាងសង់នៅលើដីហ៊ីប៉ូតែក នៅក្រោយពេលហ៊ីប៉ូតែកនោះត្រូវបានបង្កើត ហើយម្ចាស់បំណុលហ៊ីប៉ូតែកអាចលក់ដោយបង្ខំនូវអាគារនោះ ព្រមជាមួយនឹងដីហ៊ីប៉ូតែកនោះបាន។ ប៉ុន្តែ បើចំនួនថ្លៃលក់ដី និង អាគារនោះ ទាបជាងថ្លៃលក់ដីដែលគ្មានអាគារលើនោះ ម្ចាស់បំណុលហ៊ីប៉ូតែកអាចទាមទារឱ្យអ្នកបង្កើតហ៊ីប៉ូតែករុះរើអាគារនោះ មុនពេលលក់ដោយបង្ខំ។* ការចែងបែបនេះ ដោយអនុលោមទៅតាមមាត្រា ១២២ នៃក្រមរដ្ឋប្បវេណី ដែលបានកំណត់ថាវត្ថុដែលនៅជាប់នឹងដី ឬ វត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេសអាគារ ឬ សំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរកន្លែងបាន គឺជាសមាសភាគនៃដី។ ក្នុងករណីដែលតតិយជនមានកម្មសិទ្ធិលើអាគារលើដីហ៊ីប៉ូតែក ដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួល បើតតិយជននោះមិនអាចយកសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួលរបស់ខ្លួនមកតតាំងចំពោះម្ចាស់បំណុលហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកអាចលក់ដោយបង្ខំនូវអាគារនោះ ព្រមជាមួយនឹងដីហ៊ីប៉ូតែកបាន។

**គំនូសបង្ហាញអំពីវិធីក្នុងការពិចារណាពាក់ព័ន្ធទៅនឹងការអនុវត្តដោយបង្ខំនូវអាគារថាកម្មសិទ្ធិរបស់តតិយជន**




### ៤.២.៣. សិទ្ធិរបស់តតិយជនដែលបានធ្វើលទ្ធកម្ម

មាត្រា ៨៥៥ និង ៨៥៦ នៃក្រមរដ្ឋប្បវេណី បានចែងថា តតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក ដែលមិនមែនតាមរយៈការលក់ដោយបង្ខំ អាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំបាន ហើយក៏អាចទាមទារសំណងនៃចំណាយចាំបាច់ពីថ្លៃលក់ដោយបង្ខំនូវអចលនវត្ថុ ដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកទៀតផង ។

**ឧទាហរណ៍ទី ១ :** **ក** គឺជាម្ចាស់បំណុលហ៊ីប៉ូតែក ដែលត្រូវបានធានាដោយសិទ្ធិលើបំណុលចំនួន ១.០០០ ដុល្លារ ។ **ខ** ជាអ្នកបង្កើតហ៊ីប៉ូតែកលើដី (១) ដែលមានតម្លៃចំនួន ៣.០០០ ដុល្លារ ។ **គ** បានទិញដីនោះពី **ខ** ក្នុងតម្លៃ ២.០០០ ដុល្លារ ។ **គ** បានចេញចំណាយសោហ៊ុយចំនួន ៥០០ ដុល្លារ ដើម្បីបង្កើនតម្លៃនៃដីនោះ ហើយតម្លៃនៃដីនោះបានកើនឡើងចំនួន ៣.៥០០ ដុល្លារ ។ ក្រោយមក **ក** ទាមទារឱ្យមានការលក់ដោយបង្ខំនូវដីនោះ ។

ឧបមាថា តម្លៃនៃដីដែលត្រូវបានវាយតម្លៃគឺមានចំនួន ៣.៥០០ ដុល្លារ ហើយ **គ** អាចទិញដីនោះ ប្រសិនបើគាត់ចង់ទិញ ។ នៅក្នុងករណីនេះ ថ្លៃលក់ដោយបង្ខំនៃដីនោះមានចំនួន ៣.៥០០ ដុល្លារ ។ បើសិនជា **គ** ជាអ្នកទិញដីនេះ ពេលនោះសិទ្ធិទាមទារសំណងនឹងត្រូវរលត់ ពីព្រោះអ្នកទិញអចលនវត្ថុដោយការលក់ដោយបង្ខំ ឬ តតិយជនដែលបានធ្វើលទ្ធកម្ម និង ម្ចាស់បំណុលហ៊ីប៉ូតែក គឺជាមនុស្សតែម្នាក់ ។

ករណីប្រសិនបើ **គ** មិនទិញទេ **គ** គ្រាន់តែអាចអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីទាមទារសំណងចំនួន ៥០០ ដុល្លារ ពី **ក** ពីព្រោះ **គ** បានធ្វើឱ្យកើនតម្លៃដីនោះ ។

**ឧទាហរណ៍ទី ២ :** **ក** បានបង្កើតហ៊ីប៉ូតែកនៅលើដី (១) មួយកន្លែងឱ្យ **ខ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ១។ ក្រោយមក **ក** បានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍នៅលើដី (១) នោះទៅឱ្យ **គ** ដោយមានការចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។ **ក** បានធ្វើអនុប្បទានដី (១) ដដែលនោះទៅឱ្យ **ឃ**។ **ខ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ១ បានអនុវត្តហ៊ីប៉ូតែកនៅលើដី (១) នោះ ហើយ **ង** គឺជាអ្នកទិញដីនោះតាមរយៈការលក់ដោយបង្ខំ។

នៅពេលដែល **ខ** អនុវត្តហ៊ីប៉ូតែកនៅលើដី (១) នោះសិទ្ធិជួលអចិន្ត្រៃយ៍មិនអាចតតាំងចំពោះម្ចាស់បំណុលហ៊ីប៉ូតែកបានទេ ដោយសារតែសិទ្ធិជួលអចិន្ត្រៃយ៍នេះ ត្រូវបានបង្កើតក្រោយហ៊ីប៉ូតែក ដូចនេះសិទ្ធិជួលអចិន្ត្រៃយ៍របស់ **គ** មិនអាចយកទៅតតាំងជាមួយនឹងហ៊ីប៉ូតែករបស់ **ខ** បានឡើយ។ ដូចនេះ **ង** ដែលជាអ្នកទិញដីនោះតាមរយៈការលក់ដោយបង្ខំមានឋានៈស្មើ **ខ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែក។ មានន័យថា **ង** អាចធ្វើលទ្ធកម្មកម្មសិទ្ធិលើដី (១) នេះ ដោយមិនមានជាប់បន្ទុកនៃសិទ្ធិជួលអចិន្ត្រៃយ៍។

ចំពោះ **ឃ** វិញ (ការណីដែលខ្លួនបានទទួលដីនេះតាមរយៈអនុប្បទានពី **ក**) មិនអាចធ្វើឱ្យ **ឃ** បានទទួលកម្មសិទ្ធិលើដីនេះឡើយ ពីព្រោះដីនេះជាប់ទាំងបន្ទុកនៃហ៊ីប៉ូតែកផង និង សិទ្ធិជួលអចិន្ត្រៃយ៍ផង។ បើសិនជា **ឃ** ចង់ធ្វើលទ្ធកម្មកម្មសិទ្ធិលើដី (១) នោះដោយមិនជាប់បន្ទុកអ្វីទាំងអស់ **ឃ** ត្រូវអនុវត្តតាមមាត្រា ៨៩៥ ដែលស្តីអំពីការស្នើសុំទិញដោយតតិយជនដែលបានធ្វើលទ្ធកម្ម មានន័យថា **ឃ** អាចដាក់ពាក្យសុំទិញនូវដី (១) នេះ តាមរយៈការលក់ដោយបង្ខំដូចជា **ង** ដែរ។ បើមិនដូច្នោះទេ **ឃ** អាចបាត់បង់នូវកម្មសិទ្ធិលើដីនោះ។

### ៩.២.៤. ការចែកចំណែកព្រមគ្នា និង ការចែកចំណែកមិនព្រមគ្នា ក្នុងករណីនៃហ៊ីប៉ូតែករួម

ហ៊ីប៉ូតែករួម គឺជាហ៊ីប៉ូតែកមួយប្រភេទ ដែលកម្មវត្ថុរបស់វាមានច្រើនជាងមួយ ប៉ុន្តែត្រូវបានគេយកមកធានាសិទ្ធិលើបំណុលតែមួយ។

យោងតាមមាត្រា ៨៩៧ នៃក្រមរដ្ឋប្បវេណី *ក្នុងករណីដែលម្ចាស់បំណុលមានហ៊ីប៉ូតែកលើអចលនវត្ថុច្រើនដើម្បីធានាសិទ្ធិលើបំណុលតែមួយ បើចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ដោយបង្ខំនៅពេលជាមួយគ្នា បន្ទុកនៃសិទ្ធិលើបំណុលត្រូវចែកទៅតាមសមាមាត្រនៃតម្លៃអចលនវត្ថុនីមួយៗនោះ។*

បើចែកចំណែកតែប្រាក់ដែលបានពីការលក់ដោយបង្ខំនូវអចលនវត្ថុណាមួយ ម្ចាស់បំណុលហ៊ីប៉ូតែកអាចទទួលការសងចំពោះសិទ្ធិលើបំណុលទាំងអស់ ដោយប្រាក់ដែលបានមកពីការលក់ដោយបង្ខំនោះបាន។ ក្នុងករណីនេះ ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់បន្ទាប់ អាចអនុវត្តហ៊ីប៉ូតែករបស់ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់នៅខាងលើដោយឧបាទេសកម្មបានរហូតដល់ចំនួនទឹកប្រាក់ ដែលម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាង នោះត្រូវទទួលការសងចំពោះអចលនវត្ថុផ្សេងទៀត ដើម្បីបញ្ចៀសនូវភាពអយុត្តិធម៌ដែលប្រាក់ដែលបានមកពីការលក់អាចត្រូវបានផ្លាស់ប្តូរតាមអំពើចិត្តរបស់ម្ចាស់បំណុលហ៊ីប៉ូតែកដែលស្ថិតនៅក្នុងលំដាប់ខ្ពស់ជាង។ និយាយម្យ៉ាងទៀតតាម

រយៈឧបាទេសកម្ម រាល់ម្ចាស់បំណុលហ៊ីប៉ូតែកនីមួយៗដែលស្ថិតនៅក្នុងលំដាប់ទាបជាងម្ចាស់បំណុលហ៊ីប៉ូតែករួម អាចទទួលចំនួនទឹកប្រាក់ដូចគ្នានៅចុងបញ្ចប់។ សូមមើលឧទាហរណ៍ខាងក្រោមនេះ :

**ឧទាហរណ៍ :** **ក** ជាម្ចាស់បំណុលហ៊ីប៉ូតែកនៅលើដី ២ កន្លែង ដែលជារបស់ **ខ** ចំនួន ៦០០ ដុល្លារ។ ដីទី ១ មានតម្លៃ ៨០០ ដុល្លារ។ ដីទី ២ មានតម្លៃ ១.២០០ ដុល្លារ។ នៅពេលដែល **ខ** មិនមានលទ្ធភាពសងតាមកាលបរិច្ឆេទដែលត្រូវសងទេ **ក** អាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនចំពោះដីទាំង ២ កន្លែងរបស់ **ខ** ក៏បាន ឬ ជ្រើសរើសការ អនុវត្តតែទៅលើដីមួយណាក៏បាន។ តែ **គ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ២ នៅលើដីទី ១ ចំនួន ៦០០ ដុល្លារ។ **ឃ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ២ នៅលើដីទី ២ ចំនួន ៩០០ ដុល្លារ។

នៅក្នុងករណីដែល **ក** អនុវត្តហ៊ីប៉ូតែកទាំងពីរព្រមគ្នា ដោយសារតែហ៊ីប៉ូតែកដែលមានលំដាប់ទាបជាងត្រូវរំលត់ចំនួនទឹកប្រាក់ដែលបានមកពីការលក់ដីទាំងពីរអាចបូករួមទៅមានចំនួន ២.០០០ ដុល្លារ។ បន្ទាប់មកយោងតាមមាត្រា ៨៥៧ កថាខណ្ឌទី ១ **ក** ទទួលបានចំនួន ២៤០ ដុល្លារ ពីដីទី ១ និង ៣៦០ ដុល្លារ ពីដីទី ២។ ហេតុដូច្នេះ **គ** ទទួលបានចំនួន ៥៦០ ដុល្លារ ដែលនៅសល់ពីដីទី ១ និង **ឃ** ទទួលបានចំនួន ៨៤០ ដុល្លារ ពីដីទី ២។

ក្នុងករណីដែល **ក** អនុវត្តហ៊ីប៉ូតែករបស់ខ្លួនតែចំពោះដីទី ១ ប្រាក់ដែលបានមកពីការលក់នោះមានចំនួនប្រហែល ៨០០ ដុល្លារ។ ពេលនោះ **ក** ត្រូវទទួលបាន ៦០០ ដុល្លារ ចេញពីថ្លៃដីទី ១ មិនមែនទទួលបាន ២៤០ ដុល្លារតាមមាត្រា ៨៥៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ ហើយនៅសល់ចំនួន ២០០ ដុល្លារទៀត ត្រូវបានទៅ **គ** ហើយនៅក្នុងករណីនេះ ដោយគ្មានមាត្រា ៨៥៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ ទេ **គ** មិនអាចទទួលបានអ្វីទៀតពីដីទី ២ នោះទេពីព្រោះហ៊ីប៉ូតែករបស់គាត់ត្រូវរំលត់បាត់ទៅ ហើយចំណែកឯ **ឃ** វិញ អាចទទួលបាននូវការសងគ្រប់ចំនួន ៩០០ ដុល្លារពីព្រោះ **ក** បានទទួលការសងសិទ្ធិលើបំណុលរបស់គាត់គ្រប់ចំនួនហើយ។

វាក្យខណ្ឌទី ២ នៃមាត្រា ៨៥៧ កថាខណ្ឌទី ២ អនុញ្ញាតឱ្យ **គ** ធ្វើឧបាទេសកម្មហ៊ីប៉ូតែករបស់ **ក** លើដីទី ២ ត្រឹមកម្រិតដែល **ក** អាចទទួលបានពីប្រាក់ដែលបានមកពីការលក់ដីទី ២ (៣៦០ ដុល្លារ)។ ហេតុដូច្នេះ សរុបមក **គ** អាចទទួលបានចំនួន ៥៦០ ដុល្លារ ហើយ **ឃ** ទទួលបានប្រាក់ដែលនៅសល់តែចំនួន ៨៤០ ដុល្លារ តែប៉ុណ្ណោះ។

ក្នុងករណីដែល **ក** អនុវត្តហ៊ីប៉ូតែករបស់ខ្លួនចំពោះដីទី ២ មុនវិញ ដោយលក់បានតម្លៃ ១.២០០ ដុល្លារ។ ពេលនោះ **ក** ត្រូវទទួលបាន ៦០០ ដុល្លារ ចេញពីថ្លៃដីទី ២ នេះយោងតាមមាត្រា ៨៥៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ ហើយនៅសល់ចំនួន ៦០០ ដុល្លារ ទៀតត្រូវបានទៅ **ឃ**។ នៅក្នុងករណីនេះ យោងតាមមាត្រា ៨៥៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ **ឃ** អាចធ្វើឧបាទេសកម្មហ៊ីប៉ូតែករបស់ **ក** លើដីទី ១ ត្រឹមកម្រិតចំនួនទឹកប្រាក់ដែល **ក** អាចទទួលបានពីដីទី ១ (២៤០ ដុល្លារ)។ ហេតុដូច្នេះ តាមរយៈឧបាទេសកម្មនេះ **ឃ** អាចទទួលបាន ២៤០ ដុល្លារ ពីដីទី ១ ហើយ **គ** អាចទទួលប្រាក់ចំនួន ៥៦០ ដុល្លារ ដែលនៅសល់ដែលស្មើទៅនឹងលទ្ធផលនៃការអនុវត្តហ៊ីប៉ូតែកព្រមគ្នា។

## ៥. ការចាត់ថែងហ៊ីប៉ូតែក

### ៥.១. ហ៊ីប៉ូតែកបន្ត

ម្ចាស់បំណុលហ៊ីប៉ូតែក អាចយកហ៊ីប៉ូតែកនេះធ្វើជាប្រាតិភោគសម្រាប់កាតព្វកិច្ចរបស់ខ្លួន ឬ តតិយជនបាន។ ករណីនេះហៅថា ហ៊ីប៉ូតែកបន្ត។

នៅពេលចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត អាចទទួលការសងចំពោះសិទ្ធិលើបំណុលត្រឹមកម្រិតនៃចំនួនទឹកប្រាក់នៃចំណែកដែលត្រូវចែកទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែក។ ប៉ុន្តែ បើសិទ្ធិលើបំណុលនោះមិនទាន់ដល់កំណត់ពេលត្រូវសងទេ ម្ចាស់បំណុលហ៊ីប៉ូតែកបន្តគ្រាន់តែអាចទាមទារឱ្យតម្កល់ចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងប៉ុណ្ណោះ។

**ឧទាហរណ៍ :** **ក** ជាម្ចាស់បំណុលហ៊ីប៉ូតែកដោយមានការធានាបំណុលរបស់ **ខ** ចំនួន ១.០០០ ដុល្លារ ចំពោះដី (១) ដែលជាកម្មសិទ្ធិរបស់ **ខ**។ **ក** បានជំពាក់បំណុល **គ** ចំនួន ២.០០០ ដុល្លារ ហើយបានយកហ៊ីប៉ូតែករបស់ខ្លួនធ្វើជាប្រាតិភោគដើម្បីធានាបំណុលរបស់ខ្លួនចំពោះ **គ**។

ករណីនេះ **គ** អាចទទួលបានប្រាក់ចំនួន ១.០០០ ដុល្លារ ពីការលក់ដី (១) ដោយមានអាទិភាព។

ប្រសិនបើកាលបរិច្ឆេទនៃការកំណត់សងនៃកាតព្វកិច្ចរបស់ **ក** មិនទាន់បានមកដល់នៅឡើយទេ **គ** អាចទាមទារឱ្យតម្កល់ប្រាក់ចំនួន ១.០០០ ដុល្លារ។

លក្ខខណ្ឌដើម្បីឱ្យមានអានុភាព : ហ៊ីប៉ូតែកបន្តមិនមានអានុភាពឡើយ ប្រសិនបើមិនបានធ្វើឡើងដោយលិខិតយថាភូត និង មិនបានចុះបញ្ជីបន្ថែម។

ហ៊ីប៉ូតែកបន្ត មិនអាចតតាំងចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា អ្នកបង្កើតហ៊ីប៉ូតែក និង ប្រតិសិទ្ធិរបស់ជនទាំងនោះបានឡើយ បើម្ចាស់បំណុលហ៊ីប៉ូតែកមិនបានជូនដំណឹងទៅកូនបំណុលដែលមានកាតព្វកិច្ចចម្បង ឬ ទទួលការយល់ព្រមពីកូនបំណុលនោះទេ។ ការជូនដំណឹង ឬ ការយល់ព្រមនេះ គឺមានភាពចាំបាច់ដើម្បីឱ្យពួកគេអាចដឹងថា តើនរណាជាម្ចាស់បំណុលហ៊ីប៉ូតែកពិតប្រាកដ។

### ៥.២. អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក

ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់នូវហ៊ីប៉ូតែកបានដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុល (ផ្សេងទៀត) ចំពោះកូនបំណុលតែម្នាក់។

អនុប្បទានិកនៃហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកដែលខ្លួនបានទទួល ដោយយកមកធ្វើជាប្រាតិភោគនៃសិទ្ធិលើបំណុលរបស់ខ្លួនបាន។ មានន័យថា ប្រសិនបើហ៊ីប៉ូតែកត្រូវបានធ្វើអនុប្បទាន ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើអនុប្បទានហ៊ីប៉ូតែកនោះនឹងក្លាយជាម្ចាស់បំណុលដែលគ្មានហ៊ីប៉ូតែក ចំណែកឯម្ចាស់បំណុលដែលបានទទួលអនុប្បទានហ៊ីប៉ូតែកនឹងក្លាយជាម្ចាស់បំណុលដែលមានហ៊ីប៉ូតែក។ និយាយឱ្យខ្លី ភាគីនៃអនុប្បទានហ៊ីប៉ូតែកសិទ្ធិលើបំណុលរបស់អនុប្បទានិក មានអាទិភាពជាងសិទ្ធិលើបំណុលរបស់អនុប្បទាយី។

បុគ្គលដែលបានបោះបង់ហ៊ីប៉ូតែក ពុំអាចអះអាងអានុភាពនៃហ៊ីប៉ូតែកនោះចំពោះបុគ្គលដែលបានទទួលនូវការបោះបង់នោះឡើយ ។ មានន័យថារវាងគូភាគីនៃការបោះបង់ហ៊ីប៉ូតែក ភាគីទាំងសងខាងមិនអាចអះអាងពីសិទ្ធិអាទិភាពទៅវិញទៅមកបានឡើយ ។

សរុបមក អនុប្បទាន និង ការបោះបង់នូវហ៊ីប៉ូតែក គឺជាទស្សនៈដែលមានលក្ខណៈស្រដៀងគ្នា ប៉ុន្តែវាមានភាពខុសគ្នា ។ អ្វីដែលត្រូវបានធ្វើអនុប្បទាន ឬ បោះបង់នោះ គឺមានអាទិភាពចំពោះគ្នា ។

**ឧទាហរណ៍ :** **ក** មានហ៊ីប៉ូតែកលំដាប់ទី ១ ចំពោះដី (១) ដែលត្រូវបានធានាដោយបំណុលចំនួន ៤០០ ដុល្លារ ។ **ខ** មានហ៊ីប៉ូតែកលំដាប់ទី ២ ដែលត្រូវបានធានាដោយបំណុលចំនួន ២០០ ដុល្លារ ។ **គ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ៣ ដែលមានសិទ្ធិលើបំណុលចំនួន ៦០០ ដុល្លារ ។ **ឃ** ជាម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលចំនួន ៤០០ ដុល្លារ ដោយគ្មានប្រាតិភោគ ។ **ខ** គឺជាកូនបំណុល និង អ្នកបង្កើតហ៊ីប៉ូតែកនៃដី (១) ។ ឧបមាថាតម្លៃនៃដី (១) គឺមានចំនួន ១.០០០ ដុល្លារ ។

១- **ក** បានបោះបង់ហ៊ីប៉ូតែករបស់ខ្លួនដើម្បីជាប្រយោជន៍របស់ **ឃ** ហើយការបោះបង់នោះត្រូវបានចុះបញ្ជី ។ បន្ទាប់មក **ក** បានអនុវត្តហ៊ីប៉ូតែករបស់ខ្លួន ។ តើអ្នកណាអាចទទួលនូវការចែកចំណែក ហើយទទួលបានចំនួនប៉ុន្មាន?

២- **ក** បានធ្វើអនុប្បទានហ៊ីប៉ូតែករបស់ខ្លួនដើម្បីប្រយោជន៍របស់ **ឃ** ហើយអនុប្បទាននេះត្រូវបានចុះបញ្ជី ។ បន្ទាប់មក **ឃ** បានអនុវត្តហ៊ីប៉ូតែករបស់ខ្លួន ។ តើអ្នកណាអាចទទួលនូវការចែកចំណែក ហើយទទួលបានចំនួនប៉ុន្មាន?

**សន្និដ្ឋាន**

១- ការចែកចំណែកធម្មតា ត្រូវធ្វើឡើងដូចខាងក្រោមនេះ ។ (**ក** = ៤០០, **ខ** = ២០០, **គ** = ៤០០) តាមរយៈការបោះបង់ **ក** មិនអាចអះអាងអំពីអាទិភាពរបស់ខ្លួនចំពោះ **ឃ** ចំពោះផលប្រយោជន៍ដែលខ្លួនបានបោះបង់ហ៊ីប៉ូតែកនោះទេ ប៉ុន្តែ **ក** នៅតែអាចអះអាងអំពីហ៊ីប៉ូតែករបស់ខ្លួនចំពោះ **ខ** និង **គ** ។

ដូច្នេះ ការចែកចំណែករបស់ **ក** ត្រូវចែកទៅឱ្យ **ក** និង **ឃ** តាមសមាមាត្រនៃសិទ្ធិលើបំណុលរបស់ពួកគេ ហើយចំណែកដែលនៅសល់ត្រូវចែកទៅឱ្យ **ខ** និង **គ** ដូចធម្មតា ។

២- ក្នុងករណីធ្វើអនុប្បទាន អនុប្បទាយីបាត់បង់នូវសិទ្ធិ ហើយអនុប្បទានិកត្រូវទទួលបាននូវសិទ្ធិនោះជំនួសវិញ ។ ហេតុដូច្នេះលទ្ធផល គឺមានដូចខាងក្រោមនេះ :

| **សិទ្ធិលើបំណុល** | **ការចែកចំណែកធម្មតា** | **ការបោះបង់ហ៊ីប៉ូតែក** | **អនុប្បទានហ៊ីប៉ូតែក** |
|---|---|---|---|
| លោក **ក** : ៤០០ | ៤០០ | ២០០ | ០ |
| លោក **ខ** : ២០០ | ២០០ | ២០០ | ២០០ |
| លោក **គ** : ៦០០ | ៤០០ (សល់ ២០០) | ៤០០ | ៤០០ |
| លោក **ឃ១** : ៤០០ | ០ (សល់ ៤០០) | ២០០ | ៤០០ |

## ៥.៧. អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក

*ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់លំដាប់នៃហ៊ីប៉ូតែកបាន ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀតចំពោះកូនបំណុលតែម្នាក់ ។ ម្ចាស់បំណុលហ៊ីប៉ូតែក ក៏អាចផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែកនោះបាន ដោយការព្រមព្រៀងជាមួយម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀត ។ ប៉ុន្តែ បើមានបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ចំពោះការផ្លាស់ប្តូរនោះ ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវទទួលការយល់ព្រមពីបុគ្គលនោះ ។*

*ម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលអនុប្បទាននូវលំដាប់នៃហ៊ីប៉ូតែក អាចទទួលការសងដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើអនុប្បទាននូវលំដាប់នោះ នូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលទាំងអស់ពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែកនោះ ត្រឹមកម្រិតនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកឱ្យទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ ។*

*ម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលនូវការបោះបង់លំដាប់នៃហ៊ីប៉ូតែក អាចទទួលការសងដោយមានសមភាពជាមួយម្ចាស់បំណុលដែលបានលះបង់លំដាប់ហ៊ីប៉ូតែកនោះ តាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនៅក្នុងទំហំនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកឱ្យទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ ។*

*ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានព្រមព្រៀងក្នុងការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកបានតាមការព្រមព្រៀងនោះ ។*

អនុប្បទាន និង ការបោះបង់លំដាប់ហ៊ីប៉ូតែក មានលក្ខណៈស្រដៀងគ្នាទៅនឹងអនុប្បទាន និង ការបោះបង់ហ៊ីប៉ូតែក ។ ប៉ុន្តែ អ្វីដែលខុសគ្នានោះ គឺកម្មវត្ថុនៃអនុប្បទាន និង ការបោះបង់លំដាប់ គឺលំដាប់ ។ ជនដែលបានបោះបង់ ឬ ធ្វើអនុប្បទាននូវលំដាប់នៃផលប្រយោជន៍ផ្ទាល់ខ្លួន គឺជាម្ចាស់បំណុលហ៊ីប៉ូតែកផងដែរ ។

**ឧទាហរណ៍ :** **ក** មានហ៊ីប៉ូតែកលំដាប់ទី ១ ចំពោះដី **(១)** ដែលធានាបំណុលចំនួន ៤០០ ដុល្លារ ។ **ខ** មានហ៊ីប៉ូតែកលំដាប់ទី ២ ដែលធានាបំណុលចំនួន ២០០ ដុល្លារ ។ **គ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ៣ ដែលមានសិទ្ធិលើបំណុលចំនួន ៦០០ ដុល្លារ ។ **ឃ** ជាម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលចំនួន ៤០០ ដុល្លារ ដោយគ្មានប្រាតិភោគ ។ **ខ** គឺជាអ្នកបង្កើតហ៊ីប៉ូតែក(កូនបំណុល) នៃដី **(១)** ។ ឧបមាថាតម្លៃនៃដី **(១)** គឺមានចំនួន ១.០០០ ដុល្លារ ។

១- **ក** បានបោះបង់លំដាប់នៃហ៊ីប៉ូតែករបស់ខ្លួនដើម្បីជាប្រយោជន៍របស់ **គ** ហើយការបោះបង់នោះ ត្រូវបានចុះបញ្ជី ។ បន្ទាប់មក **ក** បានអនុវត្តហ៊ីប៉ូតែករបស់ខ្លួន ។ តើអ្នកណាអាចទទួលនូវការចែកចំណែក ហើយទទួលបានចំនួនប៉ុន្មាន?

២- **ក** បានធ្វើអនុប្បទានលំដាប់នៃហ៊ីប៉ូតែករបស់ខ្លួនដើម្បីប្រយោជន៍របស់ **គ** ហើយអនុប្បទាននេះ ត្រូវបានចុះបញ្ជី ។ បន្ទាប់មក **គ** បានអនុវត្តហ៊ីប៉ូតែកដែលត្រូវបានផ្ទេរ ។ តើអ្នកណាអាចទទួលនូវការចែកចំណែក ហើយទទួលបានចំនួនប៉ុន្មាន?

៣- **ក ខ** និង **គ** បានព្រមព្រៀងគ្នាអំពីការផ្លាស់ប្តូរលំដាប់ ។ លំដាប់ដែលបានព្រមព្រៀងគ្នាថ្មីៗ នេះគឺ **ខ** លំដាប់ទី ១ **គ** លំដាប់ទី ២ និង **ក** លំដាប់ទី ៣។ តើអាចធ្វើការចែកចំណែកទៅឱ្យម្ចាស់បំណុលនីមួយៗនោះបានប៉ុន្មានម្នាក់?

**សន្និដ្ឋាន**

១- នៅក្នុងករណីនេះ តាមរយៈការបោះបង់ **ក** និង **គ** ទទួលការចែកចំណែកតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលត្រឹមកម្រិតនៃការចែកចំណែកដើមចំពោះពួកគេ (៨០០ ដុល្លារ) ។ ហេតុដូច្នេះ ប្រាក់ចំនួន ៣២០ ដុល្លារ នៃប្រាក់ ៨០០ ដុល្លារ ត្រូវចែកទៅឱ្យ **ក** ហើយនៅសល់ចំនួន ៤៨០ ដុល្លារ ត្រូវចែកទៅ **គ**។ ករណីនេះ មិនមានផលប៉ះពាល់ដល់ចំនួនប្រាក់នៃការចែកចំណែកចំពោះម្ចាស់បំណុលហ៊ីប៉ូតែកដទៃទៀតនោះទេ (**គ**) ។

២- មិនដូចការបោះបង់នោះ អនុប្បទានិកធ្វើលទ្ធកម្មនូវអាទិភាពចំពោះអនុប្បទាយី ហេតុដូច្នេះ ការចែកចំណែកត្រូវចែកទៅឱ្យ **គ** មុន ដើម្បីសងសិទ្ធិលើបំណុលរបស់គាត់ ហើយបន្ទាប់មកប្រាក់ដែលនៅសល់ចំនួន ២០០ ដុល្លារ ត្រូវចែកទៅឱ្យ **គ**។

៣- ការផ្លាស់ប្តូរលំដាប់ មានអានុភាពនៅក្នុងចំណោមភាគីដែលបានព្រមព្រៀងគ្នា ហើយការចែកចំណែកត្រូវចែកតាមការព្រមព្រៀង។

| **សិទ្ធិលើបំណុល** | **ការចែកចំណែកធម្មតា** | **ការបោះបង់** | **អនុប្បទាន** | **ការផ្លាស់ប្តូរ** |
|---|---|---|---|---|
| លោក **ក** : ៤០០ | ៤០០ | ៣២០ | ២០០ | ទី ៣ = ២០០ |
| លោក **ខ** : ២០០ | ២០០ | ២០០ | ២០០ | ទី ១ = ២០០ |
| លោក **គ** : ៦០០ | ៤០០ (សល់ ២០០) | ៤៨០ | ៦០០ | ទី ២ = ៦០០ |
| លោក **គ១**: ៤០០ | ០ (សល់ ៤០០) | ០ | ០ | ០ |

## ៦. ការរលត់ហ៊ីប៉ូតែក

### ៦.១. សេចក្តីផ្តើម

យោងតាមមាត្រា ៧៦៩ កថាខណ្ឌទី ៤ *ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានា បានរលត់ដោយសារការសង ឬ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ឬ ហេតុផលផ្សេងៗទៀត សិទ្ធិប្រាតិភោគប្រត្យក្សក៏ត្រូវរលត់ដែរ* ។ ករណីនេះត្រូវបានគេហៅថា លក្ខណៈបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស។

ប៉ុន្តែ ត្រូវកត់សម្គាល់ផងដែរថា សិទ្ធិប្រាតិភោគប្រត្យក្សមិនរលត់ទេ ប្រសិនបើចំនួននៃសិទ្ធិលើបំណុលដែលត្រូវបានធានាទាំងអស់មិនរលត់ ។ នេះគេហៅថា អវិភាគភាពនៃសិទ្ធិប្រាតិភោគប្រត្យក្ស ផ្អែកតាមមាត្រា ៧៧១។

### ៦.២. ការសងឲ្យថ្លៃលក់

*ក្នុងករណីដែលតតិយជនដែលទិញកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ចំពោះអចលនវត្ថុហ៊ីប៉ូតែក បានសងថ្លៃលក់នោះទៅម្ចាស់បំណុលហ៊ីប៉ូតែក តាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក ហើយហ៊ីប៉ូតែកត្រូវរលត់សម្រាប់តតិយជននោះ ។*

ហ៊ីប៉ូតែកនឹងត្រូវរលត់ ប្រសិនបើតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក សងថ្លៃលក់អចលនវត្ថុដែលខ្លួនត្រូវបង់ដើម្បីធ្វើលទ្ធកម្មនូវអចលនវត្ថុនោះ តាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក។ មានន័យថា ហ៊ីប៉ូតែកនឹងត្រូវរលត់ ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែក ទាមទារឱ្យតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែកនោះសងថ្លៃលក់អចលនវត្ថុ ហើយតតិយជនដែលបានធ្វើលទ្ធកម្មនោះ ត្រូវសងថ្លៃលក់អចលនវត្ថុតាមការទាមទារ ។

### ៦.៣. អាជ្ញាយុកាលនៃការរលត់

#### ៦.៣.១. មាត្រា ៨៦៥

មាត្រា ៨៦៥ បានបញ្ញត្តថា *ហ៊ីប៉ូតែកមិនត្រូវរលត់ដោយអាជ្ញាយុកាលចំពោះកូនបំណុល និង អ្នកដែលបានបង្កើតហ៊ីប៉ូតែកឡើយ ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះមិនរលត់ព្រមគ្នាទេ ។*

ដោយហេតុថា ហ៊ីប៉ូតែកត្រូវបានបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុលនោះ ហ៊ីប៉ូតែកអាចត្រូវរលត់ដោយអាជ្ញាយុកាល នៅពេលសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវរលត់ (លក្ខណៈបន្ទាប់បន្សំ) ។

ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែក បានធ្វើនីតិវិធីផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានធានា (មាត្រា ៤៨៩) ទោះបីជាម្ចាស់បំណុលមិនបានធ្វើនីតិវិធីផ្អាកអាជ្ញាយុកាលនៃការរំលត់ហ៊ីប៉ូតែកក៏ដោយ ក៏ហ៊ីប៉ូតែកមិនរលត់ដោយឯកឯងឡើយ យោងតាមមាត្រា ៨៦៥ ។

#### ៦.៣.២. ការរលត់ហ៊ីប៉ូតែកដោយលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែកដោយអាជ្ញាយុកាល

ហ៊ីប៉ូតែកត្រូវរលត់នៅពេលដែលតតិយជនក្រៅពីកូនបំណុល ឬ អ្នកបង្កើតហ៊ីប៉ូតែកបានបំពេញលក្ខខណ្ឌសម្រាប់អាជ្ញាយុកាលនៃលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក (មាត្រា ៨៦៦ វាក្យខណ្ឌទី ១) ។ បញ្ញត្តិនេះត្រូវបានរៀបចំឡើង ដោយសារលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល គឺមិនមែនជាលទ្ធកម្មបន្តទេ តែវាជាលទ្ធកម្មកម្មសិទ្ធិដំបូង។ មានន័យថា លទ្ធកម្មកម្មសិទ្ធិតាំងពីដំបូង គឺជាការធ្វើលទ្ធកម្មកម្មសិទ្ធិពេញលេញដោយគ្មានជាប់បន្ទុកដែលមាននោះទេ។

**ឧទាហរណ៍ :** **ក** បានខ្ចីប្រាក់ពី **ខ** ដោយដាក់ហ៊ីប៉ូតែកលើអចលនវត្ថុដែលកាន់កាប់ដោយ **គ** ។ ប្រសិនបើ **គ** មិនដឹងថាអចលនវត្ថុនោះមានជាប់បន្ទុកហ៊ីប៉ូតែក ហើយ **គ** បានបំពេញលក្ខខណ្ឌនៃការកាន់កាប់ដោយអាជ្ញាយុកាលតាមការកំណត់ក្នុងច្បាប់នោះ **គ** អាចធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុនោះបាន។ ករណីនេះ ហ៊ីប៉ូតែកត្រូវរលត់ ។

ចំណែកឯលទ្ធកម្មបន្ត ដូចជា លទ្ធកម្មកម្មសិទ្ធិតាមរយៈការលក់ទិញ ប្រសិនបើអ្នកទិញបានទិញដីដែលមានជាប់បន្ទុកហ៊ីប៉ូតែក អ្នកទិញនោះអាចធ្វើលទ្ធកម្មកម្មសិទ្ធិដែលមានបន្ទុកហ៊ីប៉ូតែក។ ម្យ៉ាងទៀត ហ៊ីប៉ូតែកជាសិទ្ធិ

ប្រត្យក្ស ហើយត្រូវបានយកមកតតាំងចំពោះតតិយជននៅពេលចុះបញ្ជី ។ ដូច្នេះ ទោះបីជាអ្នកទិញមិនបានដឹងអំពីអត្ថិភាពនៃហ៊ីប៉ូតែកក៏ដោយ ក៏ម្ចាស់បំណុលហ៊ីប៉ូតែកអាចអះអាងពីហ៊ីប៉ូតែករបស់ខ្លួន ចំពោះអ្នកទិញអចលនវត្ថុ ដែលមានជាប់ហ៊ីប៉ូតែកបានដែរ ។ ប៉ុន្តែ មានករណីបុគ្គលមួយចំនួន ធ្វើលទ្ធកម្មកម្មសិទ្ធិតាមរយៈការលក់ទិញតែបែរជាអះអាងថា ខ្លួនបានបំពេញលក្ខខណ្ឌនៃអាជ្ញាយុកាលលទ្ធកម្មនៃកម្មសិទ្ធិនៅពេលជាមួយគ្នានោះ ។ ក្នុងករណីនេះ តតិយជនអាចធ្វើលទ្ធកម្មកម្មសិទ្ធិ ប៉ុន្តែហ៊ីប៉ូតែកមិនត្រូវរលត់ទេ ប្រសិនបើតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកបានដឹងថាហ៊ីប៉ូតែកត្រូវបានបង្កើតឡើងលើអចលនវត្ថុនោះ ( មាត្រា ៨៦៦ វាក្យខណ្ឌទី ២) ។

# ផ្នែកទី ២

# សិទ្ធិឃាត់ទុក

## ១. និយមន័យ

សិទ្ធិឃាត់ទុក គឺជាសិទ្ធិប្រាតិភោគប្រត្យក្សមួយប្រភេទ ដែលមានបញ្ញត្តនៅក្នុងក្រមរដ្ឋប្បវេណី។ សិទ្ធិនេះ សំដៅលើសិទ្ធិដែលអាចឃាត់ទុកនូវវត្ថុមួយបាន រហូតដល់ពេលដែលទទួលបានការសងចំពោះសិទ្ធិលើបំណុល ប្រសិនបើអ្នកកាន់កាប់វត្ថុរបស់អ្នកដទៃ មានសិទ្ធិលើបំណុលដែលបានកើតឡើងដោយទាក់ទងនឹងវត្ថុនោះ (មាត្រា ៧៧៤ នៃក្រមរដ្ឋប្បវេណី)។

ម្ចាស់សិទ្ធិឃាត់ទុក ពុំមានសិទ្ធិទទួលការសងដោយមានអាទិភាពទេ។ ក៏ប៉ុន្តែ ប្រសិនបើមានតតិយជនបានទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃការឃាត់ទុកនោះក៏ដោយ ក៏ម្ចាស់សិទ្ធិឃាត់ទុកអាចបដិសេធមិនប្រគល់វត្ថុដែលឃាត់ទុកនោះបាន រហូតដល់ពេលដែលខ្លួនបានទទួលការសងនូវសំណងរបស់ខ្លួនរួចហើយ (អានុភាពនៃការឃាត់ទុក)។ ដូច្នេះ ជាលទ្ធផលជាក់ស្តែង ម្ចាស់សិទ្ធិឃាត់ទុកអាចទទួលបាននូវការសងសិទ្ធិលើបំណុល ជាលក្ខណៈសារធាតុដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន។

## ២. លក្ខខណ្ឌនៃសិទ្ធិឃាត់ទុក

សិទ្ធិឃាត់ទុកអាចកើតមានឡើង លុះត្រាតែមានលក្ខខណ្ឌទាំងអស់នេះ :

(ក) ការកាន់កាប់វត្ថុរបស់អ្នកដទៃ (ខ) សិទ្ធិលើបំណុលបានកើតដោយទាក់ទងនឹងវត្ថុដែលកាន់កាប់នោះ (គ) សិទ្ធិលើបំណុលដល់ពេលកំណត់ត្រូវសង និង (ឃ) ការកាន់កាប់មិនត្រូវបានចាប់ផ្តើម ដោយសារអំពើអនីត្យានុកូល។

### ២.១. ការកាន់កាប់វត្ថុរបស់អ្នកដទៃ

"ការកាន់កាប់" មានន័យថាវត្ថុត្រូវស្ថិតនៅក្នុងដៃរបស់ម្ចាស់បំណុល។ ក្នុងករណីដែលម្ចាស់សិទ្ធិឃាត់ទុក បានបាត់បង់នូវការកាន់កាប់វត្ថុឃាត់ទុក នោះសិទ្ធិឃាត់ទុកត្រូវរលត់ដែរ។ ប៉ុន្តែទោះជាម្ចាស់សិទ្ធិឃាត់ទុក ពុំបានកាន់កាប់វត្ថុឃាត់ទុក ក៏សិទ្ធិនេះនៅតែមានដដែលក្នុងករណីខ្លះ ដូចជា ម្ចាស់សិទ្ធិឃាត់ទុកបានយកវត្ថុនោះ ទៅបញ្ចាំ ឬ ជួលដោយមានការយល់ព្រមពីកូនបំណុល (មាត្រា ៧៨០ នៃក្រមរដ្ឋប្បវេណី)។ "វត្ថុ" គឺជាចលនវត្ថុ ឬ អចលនវត្ថុ។

**ឧទាហរណ៍ : ក** និង **ខ** បានបង្កើតកិច្ចសន្យាម៉ៅការដែល **ក** ជួសជុលរថយន្តរបស់ **ខ** នៅរោងចក្ររបស់ខ្លួន។ នៅក្រោយពេលដែលរថយន្ត ត្រូវបានយកទៅដល់រោងចក្រ នោះ **ក** កំពុងតែកាន់កាប់រថយន្តរបស់ **ខ**។

សិទ្ធិឃាត់ទុក ក៏អាចអនុវត្តលើវត្ថុ ដែលជាកម្មសិទ្ធិរបស់តតិយជន មិនមែនជារបស់កូនបំណុល។

ឧទាហរណ៍នៃករណីជួសជុលរថយន្តខាងលើ ប្រសិនបើ រថយន្តនោះ ត្រូវបាន **ខ** ជួលពី **គ** នោះ **ក** ក៏អាចអនុវត្តសិទ្ធិឃាត់ទុកចំពោះថ្លៃជួសជុលរថយន្តនោះបានដែរ។

### ២.២. សិទ្ធិលើបំណុលបានកើតឡើងដោយទាក់ទងនឹងវត្ថុនោះ

ដើម្បីបង្កើតសិទ្ធិឃាត់ទុក ចាំបាច់ត្រូវមានទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង វត្ថុនោះ ។

**ឧទាហរណ៍ :** នៅក្នុងករណីការជួសជុលរថយន្តខាងលើ សិទ្ធិលើបំណុលនៃថ្លៃជួសជុលរថយន្ត បានកើតឡើងដោយទាក់ទងនឹងរថយន្តនោះ ។ ដូច្នេះ **ក** អាចឃាត់ទុករថយន្តដែលបានជួសជុលនោះ រហូតដល់ពេលដែលខ្លួនបានទទួលការបង់ថ្លៃជួសជុលរថយន្តដោយអនុវត្តនូវសិទ្ធិឃាត់ទុកចំពោះ **ខ** ។

**ឧទាហរណ៍មួយទៀត :** **ក** និង **ខ** បានចុះភតិសន្យាមួយ ។ នៅក្នុងអំឡុងពេលនៃការជួលនោះ ភតិកៈ **ខ** បានចំណាយប្រាក់ផ្ទាល់ខ្លួនដើម្បីជួសជុលផ្ទះនោះ ។ នៅពេលដែលអំឡុងពេលនៃការជួលបានកន្លងផុត ហើយភតិបតី **ក** បានទាមទារឱ្យប្រគល់ផ្ទះមកវិញ ។ ក្នុងករណីនេះ ចំពោះសិទ្ធិទាមទារថ្លៃជួសជុលផ្ទះដែល **ខ** បានចំណាយ គឺ **ខ** មានសិទ្ធិឃាត់ទុកផ្ទះដែលបានជួសជុលនោះ ។

### ២.៣. សិទ្ធិលើបំណុលដល់ពេលកំណត់ត្រូវសង

អ្នកកាន់កាប់វត្ថុដែលមានសិទ្ធិលើបំណុលលើវត្ថុនោះ មានសិទ្ធិឃាត់ទុក លុះត្រាតែសិទ្ធិលើបំណុលនោះ ដល់ពេលកំណត់ត្រូវសង ( មាត្រា ៧៧៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ នៅក្នុងករណីជួសជុលរថយន្តខាងលើ ប្រសិនបើ **ក** និង **ខ** បានធ្វើការសន្យាពិសេសថា **ខ** ត្រូវបង់ថ្លៃជួសជុលរថយន្ត ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីរថយន្តត្រូវបានជួសជុលរួចរាល់ ។ នោះ **ក** មិនមានសិទ្ធិឃាត់ទុកលើរថយន្តរបស់ **ខ** រហូតដល់ពេល ១០ ថ្ងៃ បានកន្លងផុត ។

### ២.៤. ការកាន់កាប់មិនត្រូវបានចាប់ផ្ដើមដោយសារអំពើអនីត្យានុកូល

សិទ្ធិឃាត់ទុកអាចកើតមានឡើងចំពោះការកាន់កាប់លើវត្ថុដែលកើតចេញពីច្បាប់ ពោលគឺមិនមែនកើតឡើងដោយការកាន់កាប់លើវត្ថុដែលកើតចេញពីអំពើអនីត្យានុកូលនោះទេ ( មាត្រា ៧៧៤ កថាខណ្ឌទី ២) ។

**ឧទាហរណ៍ :** **ក** បានលួចចិញ្ចៀនខូចពី **ខ** ហើយ **ក** បានជួសជុលចិញ្ចៀននោះ ។ ក្រោយមក **ខ** រកឃើញថា **ក** គឺជាចោរដែលបានលួចចិញ្ចៀននោះ ក៏បានទាមទារឱ្យ **ក** ប្រគល់ចិញ្ចៀនមកវិញ ។ ប៉ុន្តែ ក្នុងករណីនេះ **ក** មិនមានសិទ្ធិឃាត់ទុកលើថ្លៃជួសជុលទេ ព្រោះការកាន់កាប់លើចិញ្ចៀននោះ គឺកើតចេញពីអំពើអនីត្យានុកូល ។

## ៣. អានុភាព

### ៣.១. សិទ្ធិឃាត់ទុក

អ្នកកាន់កាប់អាចឃាត់ទុក (= រក្សាការកាន់កាប់)នូវវត្ថុ ។

នៅប្រទេសជប៉ុន ចំណុចនេះគេហៅថា "អានុភាពនៃការឃាត់ទុក" ។ តាមរយៈអានុភាពនេះ កូនបំណុលត្រូវបានបង្ខំឱ្យអនុវត្តកាតព្វកិច្ច ដើម្បីទទួលបានមកវិញនូវវត្ថុដែលត្រូវបានកាន់កាប់ ។

### ៣.២. សិទ្ធិទទួលសំណងពីផលដោយមានអាទិភាព

មិនដូចសិទ្ធិប្រាតិភោគប្រត្យក្សដទៃទៀត ដូចជា ហ៊ីប៉ូតែកនោះទេ ម្ចាស់សិទ្ធិឃាត់ទុកមិនអាចលក់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក ដើម្បីទទួលបានប្រាក់ពីវត្ថុនោះទេ។

ប៉ុន្តែ ម្ចាស់សិទ្ធិអាចទទួលផល និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុល យោងតាមមាត្រា ៧៧៥។

មាត្រា ៧៧៥ កថាខណ្ឌទី ២ តម្រូវឱ្យយកផលនោះមកកាត់ការប្រាក់។ ឧទាហរណ៍ : យ៉ាងសាមញ្ញនៃផលអាចជាកូនគោ ឬ ក្របី និង ថ្លៃឈ្នួលនៅក្នុងករណីដែលកម្មវត្ថុត្រូវបានជួលដោយមានការយល់ព្រមពីកូនបំណុល។

### ៣.៣. ករណីយកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុក

ម្ចាស់សិទ្ធិឃាត់ទុកត្រូវកាន់កាប់វត្ថុដែលឃាត់ទុកនោះដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត (មាត្រា ៧៧៦ កថាខណ្ឌទី ១)។ ពិសេសជាងនេះទៅទៀត ការជួល ការប្រើប្រាស់ ឬ ការយកវត្ថុនោះទៅដាក់ប្រាតិភោគដោយគ្មានការយល់ព្រមពីកូនបំណុល ត្រូវបានហាមឃាត់ (មាត្រា ៧៧៦ កថាខណ្ឌទី ២)។

ការបំពានទៅនឹងបញ្ញត្តិនេះ នឹងឈានទៅដល់ការរំលត់សិទ្ធិឃាត់ទុក (មាត្រា ៧៧៦ កថាខណ្ឌទី ៣)។

### ៣.៤. សិទ្ធិទាមទារឱ្យសងសោហ៊ុយមកវិញ

ចំណាយជាចាំបាច់ដែលបានចេញ ត្រូវសងវិញដោយកម្មសិទ្ធិករនៃវត្ថុ (មាត្រា ៧៧៧ កថាខណ្ឌទី ១)។

ចំណាយបង្កើនតម្លៃ ត្រូវសងនៅពេលដែលតម្លៃប្រាក់កំណើននោះនៅតែមាន។ ចំនួនទឹកប្រាក់នៃសោហ៊ុយត្រូវសង គឺជាចំនួនទឹកប្រាក់ដែលបានចំណាយ ឬ ចំនួនទឹកប្រាក់នៃតម្លៃប្រាក់កំណើនដោយផ្អែកលើជម្រើសរបស់ម្ចាស់កម្មសិទ្ធិ (ហេតុដូច្នេះ តាមការអនុវត្ត ចំនួនទឹកប្រាក់ដែលមានតម្លៃទាបជាងគេ អាចត្រូវបានសង)។ តុលាការត្រូវផ្តល់អំឡុងពេលសមរម្យ។

## ៤. អាជ្ញាយុកាលនៃការរំលត់សិទ្ធិ

សិទ្ធិឃាត់ទុក អាចត្រូវបានអនុវត្តតែនៅពេលមានសិទ្ធិលើបំណុលដែលត្រូវបានធានាតែប៉ុណ្ណោះ។

ប៉ុន្តែ ការអនុវត្តសិទ្ធិឃាត់ទុក គឺខុសពីការអនុវត្តសិទ្ធិលើបំណុល (មាត្រា ៧៧៨)។ ម្ចាស់បំណុល - ម្ចាស់សិទ្ធិឃាត់ទុក ត្រូវចាត់វិធានការផ្សេងទៀតដើម្បីផ្អាកអាជ្ញាយុកាល។

## ៥. ការរំលត់សិទ្ធិឃាត់ទុក

ដូចដែលបានពន្យល់រួចមកហើយ ការបំពានមាត្រា ៧៧៦ នឹងនាំឱ្យរលត់សិទ្ធិឃាត់ទុក។

លើសពីនេះ ក៏មានមូលហេតុមួយចំនួនទៀតដែលនាំឱ្យរលត់សិទ្ធិឃាត់ទុក។

ទី ១ ការរលត់នូវសិទ្ធិលើបំណុលដែលត្រូវបានធានា ក៏ជាមូលហេតុនៃការរំលត់សិទ្ធិឃាត់ទុកដែរ។ ជាថ្មីម្តងទៀត នេះគេហៅថាលក្ខណៈបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគ។

ទី ២ កូនបំណុល អាចរំលត់សិទ្ធិឃាត់ទុកដោយដាក់ប្រាតិភោគសមរម្យផ្សេងទៀត (មាត្រា ៧៧៩)។

ទី ៣ ការបាត់បង់នូវការកាន់កាប់ ក៏អាចនាំឱ្យរលត់សិទ្ធិឃាត់ទុកដែរ ពីព្រោះការកាន់កាប់ គឺជាកត្តាយ៉ាងសំខាន់នៃសិទ្ធិឃាត់ទុក។

ករណីលើកលែងចំពោះបញ្ញត្តិនេះ គឺករណីដែលកម្មវត្ថុត្រូវបានជួល ឬ បញ្ចាំដោយមានការយល់ព្រមពីកូនបំណុល និង ករណីដែលម្ចាស់សិទ្ធិឃាត់ទុក ទទួលបាននូវការកាន់កាប់មកវិញ តាមមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់ វត្ថុកាន់កាប់មកវិញ) មើលមាត្រា ៧៨០ កថាខណ្ឌទី ១ និង ទី ២។

# ផ្នែកទី ៣

# សិទ្ធិលើការបញ្ចាំ

## ១. សេចក្ដីផ្ដើម

*ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬ តតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និង ទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ។*

## ២. ប្រភេទនៃកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ

យោងតាមមាត្រា ៨១៦ ពាក្យវត្ថុត្រូវបានប្រើជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ប៉ុន្តែមាត្រានេះពុំមានបញ្ជាក់ច្បាស់លាស់ច្រើននោះទេ ។ ដូច្នេះ កម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ គឺចលនវត្ថុ ( មាត្រា ៨២៩) អចលនវត្ថុ ( មាត្រា ៨៣៤) និង សិទ្ធិលើទ្រព្យសម្បត្តិ ( មាត្រា ៨៤០) ។

## ៣. លក្ខណៈទូទៅ

### ៣.១. លក្ខខណ្ឌ

មាត្រា ៨១៨ កថាខណ្ឌទី ១ ចែងថា *សិទ្ធិលើការបញ្ចាំត្រូវកើតឡើងដោយកូនបំណុល ឬ តតិយជន ដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។*

មាត្រានេះមានន័យថា ការបញ្ចាំកើតឡើងដោយការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ ដោយមិនទាមទារឱ្យមានទម្រង់ពិសេសណាមួយឡើយ ។ លើសពីនេះទៅទៀត ការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ក៏ជាលក្ខខណ្ឌចាំបាច់ ដើម្បីឱ្យការបញ្ចាំមានអានុភាពផងដែរ ព្រោះថាច្បាប់បានហាមឃាត់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ កាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំដោយផ្ទាល់ ។

### ៣.២. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

*សិទ្ធិលើការបញ្ចាំត្រូវធានានូវប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ ។*

### ៣.៣. អានុភាព

#### ៣.៣.១. សិទ្ធិឃាត់ទុក

ការបញ្ចាំត្រូវធ្វើឡើងដោយការព្រមព្រៀង និង ការប្រគល់វត្ថុបញ្ចាំរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬ តតិយជនទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។ ហេតុនេះ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិកាន់កាប់វត្ថុបញ្ចាំ។ ម្ចាស់សិទ្ធិ

លើការបញ្ចាំ មានសិទ្ធិឃាត់ទុកវត្ថុតាមរយៈការកាន់កាប់នេះ ហើយកូនបំណុលត្រូវបានបង្ខំតាមផ្លូវចិត្តឱ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដើម្បីទទួលបាននូវវត្ថុបញ្ចាំនោះមកវិញតាមរយៈអានុភាពនេះ ។

### ៣.៣.២. ភាពមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតពីវត្ថុបញ្ចាំ និង សិទ្ធិទទួលសំណង ពីផលដោយមានអាទិភាព

ម្ចាស់សិទ្ធិលើការបញ្ចាំ អាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។ ផលដែលបានមកនោះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយបើមានសំណល់ត្រូវយកទៅកាត់ប្រាក់ដើម ។

### ៣.៣.៣. ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។ ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំមិនគោរពតាមកាតព្វកិច្ចនេះទេ កូនបំណុលអាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំនោះបាន។ មានន័យថា កូនបំណុលអាចទាមទារឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ប្រគល់វត្ថុបញ្ចាំមកវិញបាន ក្នុងករណីបំពានករណីយកិច្ចនេះ ។

### ៣.៣.៤. សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

*ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំ បានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន* ( មាត្រា ៨២៤ កថាខណ្ឌទី ១) ។

*ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះ សងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើននោះវិញ តាមជម្រើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសងតាមការទាមទាររបស់កម្មសិទ្ធិករបាន* ( មាត្រា ៨២៤ កថាខណ្ឌទី ២) ។

## ៣.៤. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

ការប្រើសិទ្ធិលើការបញ្ចាំ មានន័យខុសគ្នាពីការអនុវត្តសិទ្ធិលើបំណុល ដោយសារការប្រើសិទ្ធិលើការបញ្ចាំមិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវចាត់វិធានការផ្សេងទៀតដើម្បីផ្អាកអាជ្ញាយុកាល ។

### ៣.៥. ការបញ្ចាំបន្ត

#### ៣.៥.១ ការបញ្ចាំបន្តដោយមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

*ម្ចាស់សិទ្ធិលើការបញ្ចាំ អាចយកវត្ថុបញ្ចាំនោះ ទៅដាក់បញ្ចាំបន្តទៀតបានដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ ដើម្បីធានានូវកាតព្វកិច្ចរបស់ខ្លួន ។*

#### ៣.៥.២. ការបញ្ចាំបន្តក្រោមការទទួលខុសត្រូវរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ទោះបីជាគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំក៏ដោយ ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះ ទៅបញ្ចាំបន្តទៀតបាន ទោះបីជាមានករណីប្រធានសក្តិក៏ដោយ ។

**ឧទាហរណ៍ : ក** បានដាក់បញ្ចាំគ្រឿងអលង្ការ (១) នៅនឹង **ខ** ដើម្បីធានាបំណុលចំនួន ១.០០០ ដុល្លារ ។ **ខ** បានយកគ្រឿងអលង្ការ (១) ទៅដាក់បញ្ចាំបន្តនៅនឹង **គ** ដើម្បីធានាបំណុលចំនួន ២.០០០ ដុល្លារ ដោយគ្មានការយល់ព្រមពី **ក** នោះទេ ។

១- **ខ** មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះទេ ហើយ **គ** ក៏បានអនុវត្តសិទ្ធិលើការបញ្ចាំបន្តរបស់ខ្លួន ។ តើ **គ** អាចទទួលបានប្រាក់ចំនួនប៉ុន្មាន? ករណីនេះ **គ** អាចទទួលបានប្រាក់ចំនួន ១.០០០ ដុល្លារ ដែលជាកម្រិតនៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។

២- **គ** បានធ្វើឱ្យគ្រឿងអលង្ការនោះខូច ដោយសារតែកំហុសរបស់ខ្លួន ។ តើ **ក** អាចទាមទារអ្វីបានពី **ខ** ប្រសិនបើ **ក** បានដឹងពីករណីនេះ? ករណីនេះ **ខ** ត្រូវទទួលខុសត្រូវចំពោះការខូចខាតនេះ ( មាត្រា ៨២៦ កថាខណ្ឌទី ២) ។

### ៣.៦. ការហាមកិច្ចសន្យាបញ្ចាំផ្តាច់

ថ្វីត្បិតតែកិច្ចសន្យាបញ្ចាំ ត្រូវបានធ្វើឡើងដោយផ្អែកលើការព្រមព្រៀងរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតកិច្ចសន្យាបញ្ចាំតាម "គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន " ក៏ដោយ ក៏ច្បាប់បានកម្រិតនូវសិទ្ធិមួយចំនួនចំពោះភាគីនៃការបញ្ចាំ មិនឱ្យបង្កើតនូវកិច្ចសន្យាបញ្ចាំផ្តាច់ ដែលបានធ្វើមុនកំណត់ពេលត្រូវសងតាមការព្រមព្រៀងរបស់ភាគីទេ បើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ។ មូលហេតុដែលច្បាប់មិនឱ្យបង្កើតកិច្ចសន្យាបញ្ចាំផ្តាច់នៅមុនកំណត់ពេលត្រូវសង គឺក្នុងគោលបំណងដើម្បីការពារដល់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ និង ហាមឃាត់ម្ចាស់សិទ្ធិលើការបញ្ចាំមិនឱ្យទទួលបានផលប្រយោជន៍ច្រើនហួសប្រមាណ ។ ផ្ទុយមកវិញបើកិច្ចសន្យា ឬ សកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំដែលនាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំ ធ្វើក្រោយពេលកំណត់សងនៃកិច្ចសន្យាបញ្ចាំ គឺមិនត្រូវបានហាមឃាត់ទេ ( មាត្រា ៨២៧) ។

## ៩. ការបញ្ចាំចលនវត្ថុ

### ៩.១. លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ

កិច្ចសន្យាបញ្ចាំចលនវត្ថុ មិនតម្រូវឱ្យមានការចុះបញ្ជីទេ គឺគ្រាន់តែអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ប្រគល់វត្ថុបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ដើម្បីធ្វើការកាន់កាប់ដោយផ្ទាល់ នោះកិច្ចសន្យាបញ្ចាំនឹងមានអានុភាពហើយ ។ ហេតុដូច្នេះ បើម្ចាស់សិទ្ធិលើការបញ្ចាំបានកាន់កាប់វត្ថុបញ្ចាំជានិរន្តរ៍នៅក្នុងដៃរបស់ខ្លួន ម្ចាស់សិទ្ធិលើការបញ្ចាំនឹងអាចយកសិទ្ធិនេះទៅធ្វើការតតាំងជាមួយនឹងតតិយជនបាន ( មាត្រា ៨២៩) ។

យ៉ាងណាមិញ បើម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុបាត់បង់ការកាន់កាប់វត្ថុបញ្ចាំ តាមរយៈការដកហូតរបស់តតិយជន ម្ចាស់សិទ្ធិលើការបញ្ចាំនៅតែអាចតតាំងជាមួយនឹងតតិយជនដែលបានដកហូតនោះ និង អាចយកវត្ថុបញ្ចាំមកវិញតាមរយៈបណ្ដឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ ( មាត្រា ៨៣០) ។

ដូច្នេះ លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ គឺការកាន់កាប់វត្ថុបញ្ចាំ ។

### ៩.២. ការប្រើប្រាស់ ឬ ការអាស្រ័យផលពីវត្ថុបញ្ចាំដោយម្ចាស់សិទ្ធិលើការបញ្ចាំ

ជាគោលការណ៍ ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចយកវត្ថុដែលដាក់បញ្ចាំមកប្រើប្រាស់ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ឬ ជួលបានទេ ប៉ុន្តែបើមានការអនុញ្ញាត និង យល់ព្រមពីសំណាក់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ អាចប្រើប្រាស់ និង ជួលវត្ថុបញ្ចាំនោះបាន ព្រោះយើងត្រូវគោរពនូវឆន្ទៈសេរីរបស់បុគ្គលឯកជន ។ លើសពីនេះទៅទៀត ដើម្បីថែរក្សាវត្ថុបញ្ចាំ និង ជៀសវាងនូវការខូចខាតផ្សេងៗ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់វត្ថុបញ្ចាំ ត្រឹមកម្រិតចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះ ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ប៉ុន្តែមិនអាចជួលវត្ថុបញ្ចាំនោះបានទេ ។ បើម្ចាស់សិទ្ធិលើការបញ្ចាំប្រើប្រាស់ ឬ ជួលវត្ថុបញ្ចាំ ដោយគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬ មិនមានភាពចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះទេ អ្នកបង្កើតសិទ្ធិលើការបញ្ចាំអាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំបាន យោងតាមបញ្ញត្តិនៃមាត្រា ៨៣១ នៃក្រមរដ្ឋប្បវេណី ។

### ៩.៣. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេបនេះ គឺសំដៅទៅលើការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការទទួលបានវត្ថុបញ្ចាំមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនតាមរយៈតុលាការតែម្ដង ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីនៃការអនុវត្តដោយបង្ខំ មានន័យថា នៅពេលដល់កំណត់សងសិទ្ធិលើបំណុលហើយ ម្ចាស់សិទ្ធិលើការបញ្ចាំមិនបានទទួលការសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំអាចទាមទារឱ្យតុលាការយកវត្ថុបញ្ចាំនោះមកសងខ្លួនផ្ទាល់តែម្ដង ដើម្បីកាត់សិទ្ធិលើបំណុល ( មាត្រា ៨៣២) ។

បើយើងមើលទៅ វាហាក់បីដូចជាការបញ្ចាំផ្ដាច់ដែលក្រមបានហាមមិនឱ្យធ្វើក្នុងមាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណីដែរ ប៉ុន្តែការអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុដោយសង្ខេបក្នុងមាត្រា ៨៣២ មិនដូចការហាមការបញ្ចាំផ្ដាច់ក្នុងមាត្រា ៨២៧ ទេ ពីព្រោះមាត្រា ៨២៧ ហាមមិនឱ្យភាគីធ្វើកិច្ចសន្យាដែលនាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ

ទទួលបាននូវកម្មសិទ្ធិលើវត្ថុបញ្ចាំដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើនៅមុនពេលកំណត់ត្រូវសង វិឯមាត្រា ៨៣២ វិញ គឺម្ចាស់សិទ្ធិលើការបញ្ចាំទទួលបាននូវកម្មសិទ្ធិលើវត្ថុបញ្ចាំ មិនមែនដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនពេលកំណត់ត្រូវសងទេ គឺបានតាមរយៈតុលាការ ហើយត្រូវបំពេញលក្ខខណ្ឌយ៉ាងតឹងរឹងចំនួន ៤ ដូចជា តាមរយៈតុលាការ មានការវាយតម្លៃត្រឹមត្រូវការជូនដំណឹងដល់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល) និង មានមូលហេតុត្រឹមត្រូវ។ មូលហេតុដែលតម្រូវឱ្យមានលក្ខខណ្ឌតឹងរឹងយ៉ាងនេះ គឺដើម្បីការពារប្រយោជន៍របស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ និង អ្នកធានាដោយវត្ថុ។

### ៤.៤. លំដាប់នៃសិទ្ធិលើការបញ្ចាំ

ជាធម្មតា នៅពេលដែលយកចលនវត្ថុមួយទៅដាក់បញ្ចាំដើម្បីធានាសិទ្ធិលើបំណុល ចលនវត្ថុនោះត្រូវផ្ទេរឱ្យម្ចាស់សិទ្ធិលើការបញ្ចាំធ្វើការកាន់កាប់ ហេតុនេះកូនបំណុលមិនទំនងជាអាចយកចលនវត្ថុនោះទៅដាក់បញ្ចាំនៅនឹងម្ចាស់សិទ្ធិលើការបញ្ចាំផ្សេងទៀតបានទេ។ ប៉ុន្តែ មានករណីខ្លះចលនវត្ថុអាចយកទៅដាក់បញ្ចាំ ដើម្បីធានាសិទ្ធិលើបំណុលចំពោះម្ចាស់បំណុលច្រើន ដែលជាហេតុនាំឱ្យយើងត្រូវគិតពិចារណាពីលំដាប់នៃសិទ្ធិលើការបញ្ចាំ។ ជាគោលការណ៍ លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំនោះ ត្រូវអនុលោមទៅតាមពេលវេលាដែលបានបង្កើតសិទ្ធិលើការបញ្ចាំ (មាត្រា ៨៣៣)។

**ឧទាហរណ៍ : ក** យកកង់ទៅបញ្ចាំឱ្យ **ខ** ហើយកង់នោះ ត្រូវបានយកទៅផ្ញើនឹង **គ**។ **ក** បានផ្ទេរការកាន់កាប់កង់នោះ ដោយការបញ្ជាទៅឱ្យ **គ** (មើលមាត្រា ២២៩ កថាខណ្ឌទី ៤) បន្ទាប់មក **ក** យកកង់នោះទៅបញ្ចាំឱ្យ **ឃ** ទៀត។ ករណីនេះ លំដាប់នៃសិទ្ធិលើការបញ្ចាំគឺ **ខ** ស្ថិតក្នុងលំដាប់ទី១ ព្រោះ **ខ** បានកង់នោះមុន **ឃ**។

## ៥. ការបញ្ចាំអចលនវត្ថុ

### ៥.១. សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ជាគោលការណ៍ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចយកវត្ថុបញ្ចាំទៅប្រើប្រាស់ ឬ អាស្រ័យផលដោយគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល) ទេ ដូចជាការប្រើប្រាស់ចលនវត្ថុដាក់បញ្ចាំ គឺត្រូវមានការយល់ព្រមពីកូនបំណុលដែលបានបញ្ញត្តក្នុងមាត្រា ៨៣១។ ប៉ុន្តែមានការប្រែប្រួលមួយយ៉ាងខ្លាំង ដែលអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់ និង អាស្រ័យផល ដោយពុំចាំបាច់មានការយល់ព្រមពីកូនបំណុល ក្នុងករណីដែលកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ គឺជាអចលនវត្ថុ (មាត្រា ៨៣៤ កថាខណ្ឌទី ១)។

**ឧទាហរណ៍ : ក** យកដីស្រែបញ្ចាំឱ្យ **ខ**។ **ខ** អាចប្រើប្រាស់ និង អាស្រ័យផលលើដីស្រែនោះ ដោយមិនចាំបាច់មានការយល់ព្រមពី **ក** ទេ។

ទោះបីជាម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលក៏ដោយ ក៏ការប្រើប្រាស់ និង អាស្រ័យផលនោះត្រូវធ្វើ

ឡើងដោយគោរពតាមវិធីនៃការប្រើប្រាស់អចលនវត្ថុនោះ ឬ សិទ្ធិលើបំណុលដែលគ្មានកំណត់ពេល និង មានកំណត់ពេលត្រូវសងទាក់ទិននឹងបទប្បញ្ញត្តិពិសេសស្តីពីដីសម្រាប់ធ្វើកសិកម្ម។

### ៩.២. ការគោរពតាមវិធីប្រើប្រាស់ធម្មតា

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនបានទៅតាមវិធីប្រើប្រាស់ធម្មតានៃអចលនវត្ថុនោះ។ វិធីប្រើប្រាស់ធម្មតានៃអចលនវត្ថុ សំដៅលើការប្រើប្រាស់តាមលក្ខណៈដើមនៃអចលនវត្ថុ។ ក្នុងករណីដែលដីប្រើសម្រាប់ធ្វើកសិកម្មនោះត្រូវយកដីនោះទៅធ្វើកសិកម្ម មិនអាចយកដីកសិកម្មទៅធ្វើជាផ្ទះសម្រាប់ជួលបានទេ។ មូលហេតុដែលនាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំត្រូវអនុវត្តតាមវិធីប្រើប្រាស់ធម្មតានៃអចលនវត្ថុ គឺដើម្បីជៀសវាងនូវការខូចខាតធ្ងន់ធ្ងរដល់កូនបំណុល ក្នុងករណីម្ចាស់បំណុលកែប្រែ និង ផ្លាស់ប្តូរវិធីប្រើប្រាស់ធម្មតានៃអចលនវត្ថុនោះ។

### ៩.៣. បទបញ្ញត្តិពិសេសស្តីពីដីសម្រាប់ធ្វើកសិកម្ម

#### ៩.៣.១. សិទ្ធិលើបំណុលដែលគ្មានកំណត់ពេល

បើសិទ្ធិលើបំណុលត្រូវបានកំណត់ច្បាស់លាស់ ម្ចាស់បំណុលនឹងធ្វើការត្រៀមខ្លួនរួចជាស្រេចក្នុងការប្រគល់ដីសម្រាប់ធ្វើកសិកម្មឱ្យទៅកូនបំណុលវិញនៅពេលដល់កំណត់នៃកិច្ចសន្យា ដែលវាមិនធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ម្ចាស់បំណុលទេ។ ផ្ទុយទៅវិញ សិទ្ធិលើបំណុលដែលគ្មានកំណត់ពេល អ្នកធានាដោយវត្ថុអាចធ្វើការរំលត់សិទ្ធិលើការបញ្ចាំ នៅពេលណាក៏បាន ដោយអនុវត្តកាតព្វកិច្ចដែលត្រូវបានធានាដោយសិទ្ធិលើការបញ្ចាំនោះ។ ដូច្នេះ បើកូនបំណុលរំលត់សិទ្ធិលើការបញ្ចាំ ក្នុងពេលដែលម្ចាស់បំណុលបានដាំដំណាំនៅលើដីសម្រាប់ធ្វើកសិកម្ម ហើយច្បាប់តម្រូវឱ្យម្ចាស់បំណុលប្រគល់ដីនោះឱ្យកូនបំណុលវិញ នោះវានឹងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រយោជន៍របស់ម្ចាស់បំណុល។ កត្តានេះហើយទើបច្បាប់ ផ្តល់សិទ្ធិដល់ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ អាចប្រើដីសម្រាប់ធ្វើកសិកម្មនោះ ទោះបីជាសិទ្ធិលើបំណុលរលត់ ដោយការសងចំពោះសិទ្ធិលើបំណុលដែលគ្មានកំណត់ពេលក៏ដោយ បើរដូវប្រមូលផលដំណាំដែលម្ចាស់បំណុលបានសាប ឬ ដាំពីមុននឹងដល់នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ម្ចាស់បំណុលអាចប្រើដីនោះរហូតដល់រដូវប្រមូលផល (មាត្រា ៨៣៤ កថាខណ្ឌទី ២)។

#### ៩.៣.២. សិទ្ធិលើបំណុលដែលមានកំណត់ពេល

ទាក់ទងនឹងសិទ្ធិលើបំណុលដែលមានកំណត់ពេលច្បាស់លាស់វិញ ទោះបីជាម្ចាស់បំណុលបានសាប ឬ ដាំដំណាំនៅលើដីសម្រាប់ធ្វើកសិកម្ម បើពេលកំណត់បានមកដល់ ហើយកូនបំណុលបានសង ដែលធ្វើឱ្យរលត់សិទ្ធិលើបំណុល ម្ចាស់បំណុល ត្រូវប្រគល់ដីនោះមកឱ្យកូនបំណុលវិញ។ ម្ចាស់បំណុលមិនអាចអះអាង មិនប្រគល់ដីដោយមូលហេតុរដូវប្រមូលផលនឹងដល់ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដូចសិទ្ធិលើបំណុលដែលគ្មានកំណត់ពេលទេ។ ប៉ុន្តែ ប្រសិនបើសិទ្ធិលើបំណុលបានរលត់មុនពេលកំណត់ដោយការសង នោះម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះដើម្បីធ្វើកសិកម្ម

បើរដូវប្រមូលផលពីដំណាំដែលខ្លួនបានសាប ឬ ដាំពីមុននឹងដល់ក្នុងអំឡុងពេលមួយឆ្នាំរហូតដល់រដូវប្រមូលផល ព្រោះសិទ្ធិលើបំណុលបានរលត់មុនពេលកំណត់ និង មិនមែនជាកំហុសរបស់ម្ចាស់បំណុល។

ប៉ុន្តែ ទោះបីជានៅក្នុងករណីនេះក៏ដោយ ប្រសិនបើកាលបរិច្ឆេទនៃការកំណត់សងនឹងដល់មុនពេលប្រមូលផល បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ពីព្រោះការបាត់បង់នូវការប្រមូលផល គឺអាចរំពឹងទុកបាន ចាប់តាំងពីពេលចាប់ផ្តើម ( មាត្រា ៨៣៤ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។

## ៥.៤. បន្ទុកសោហ៊ុយគ្រប់គ្រងវត្ថុបញ្ចាំ

ក្រមរដ្ឋប្បវេណីកម្ពុជា តម្រូវឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ ( ម្ចាស់បំណុល) ចេញសោហ៊ុយគ្រប់គ្រង និង ត្រូវទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ ព្រោះម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលដែលកើតចេញពីអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមិនទទួលខុសត្រូវក្នុងការបង់ពន្ធលើអចលនវត្ថុនោះទេ ព្រោះការបង់ពន្ធជាបន្ទុករបស់កម្មសិទ្ធិករនៃដី។

## ៥.៥. ការប្រាក់នៃសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ពីព្រោះខ្លួនអាចទទួលបាននូវផលប្រយោជន៍ដែលចេញពីការប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះហើយ ( មាត្រា ៨៣៦ នៃក្រមរដ្ឋប្បវេណី) ។

## ៥.៦. ការសន្យាពិសេសនៅក្នុងកិច្ចសន្យាបញ្ចាំ

ដូចដែលបានលើកឡើងហើយថា ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ និង ត្រូវចេញសោហ៊ុយគ្រប់គ្រង និង ទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ ហើយមិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ភាគីទាំងពីរនៃកិច្ចសន្យាបញ្ចាំ អាចធ្វើការព្រមព្រៀងទាក់ទងទៅនឹងលក្ខខណ្ឌទាំងនោះខុសពីចំណុចដែលមានចែងក្នុងកិច្ចសន្យាបញ្ចាំរបស់ខ្លួនបាន ដោយផ្អែកលើបញ្ញត្តិពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ( មាត្រា ៨៣៧) ។

**ឧទាហរណ៍ :** បើសិនជាមានកិច្ចព្រមព្រៀងមួយត្រូវបានធ្វើឡើង ដែលម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចរួចផុតពីការចេញសោហ៊ុយគ្រប់គ្រង ឬ បន្ទុកផ្សេងទៀតទាក់ទងនឹងអចលនវត្ថុ ទោះបីជាម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផល។ ករណីស្រដៀងគ្នានេះដែរ បើសិនជាមានកិច្ចព្រមព្រៀងមួយដែលអនុញ្ញាតឱ្យម្ចាស់បំណុលទាមទារការប្រាក់នៃសិទ្ធិលើបំណុល ទោះបីជាម្ចាស់បំណុលមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំក៏ដោយ កិច្ចព្រមព្រៀងនោះនឹងត្រូវបានទទួលស្គាល់អានុភាព ហើយម្ចាស់បំណុលអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលនោះបាន។

### ៥.៧. អំឡុងពេលនៃសិទ្ធិលើការបញ្ចាំដែលមានអត្ថិភាព

*អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីអំឡុងពេលនេះ អំឡុងពេលត្រូវបន្ថយមកត្រឹម ៥ (ប្រាំ) ឆ្នាំ ។ កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន ។ ប៉ុន្តែ អំឡុងពេលនៃការបន្តនេះ មិនអាចធ្វើឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ* (មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណី) ។

### ៥.៨. ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក

យោងតាមមាត្រា ៨៣៩ នៃក្រមរដ្ឋប្បវេណីបានចែងថា *ក្រៅពីបញ្ញត្តិនៃផ្នែកទី ៣ ដែលស្តីអំពីការបញ្ចាំអចលនវត្ថុ បញ្ញត្តិនៃជំពូកទី ៥ (ដែលស្តីអំពីហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ ។*

ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួនស្តីពីការអនុវត្តដូចគ្នានៃបញ្ញត្តិទាក់ទងនឹងហ៊ីប៉ូតែក ។

បញ្ញត្តិស្តីពីការតតាំងនៃហ៊ីប៉ូតែក ដែលមានចែងនៅក្នុងមាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណី ក៏ត្រូវយកមកអនុវត្តដូចគ្នានឹងការបញ្ចាំដែរ ។ ហេតុនេះ ដើម្បីឱ្យការបញ្ចាំមួយអាចតតាំងនឹងតតិយជនបាន សិទ្ធិលើការបញ្ចាំនោះត្រូវធ្វើឡើងដោយលិខិតយថាភូត និង ត្រូវចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

ហើយចំពោះទំហំនៃអានុភាពហ៊ីប៉ូតែក ដែលមានចែងនៅក្នុងមាត្រា ៨៤៦ ក៏ត្រូវយកមកអនុវត្តដូចគ្នាជាមួយនឹងការបញ្ចាំដែរ ពោលគឺនៅពេលដែលការបញ្ចាំមួយត្រូវបានបង្កើតឡើងនៅលើដីមួយកន្លែង ការបញ្ចាំនោះមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីនោះ រួមទាំងអាគារដែលមាននៅលើដីដែលជាប់ការបញ្ចាំនោះផងដែរ ។ ទោះបីជាអាគារនោះត្រូវបានសង់នៅមុនពេល ឬ ក្រោយពេលបង្កើតសិទ្ធិលើការបញ្ចាំក៏ដោយ ហើយដែលភាគីមិនអាចកំណត់នូវលក្ខខណ្ឌផ្សេងពីនេះនៅក្នុងកិច្ចសន្យាបញ្ចាំរបស់ខ្លួនបានឡើយ (មាត្រា ៨៤៦ នៃក្រមរដ្ឋប្បវេណី) ដោយហេតុថា ជាទូទៅយោងតាមមាត្រា ១២២ នៃក្រមរដ្ឋប្បវេណី វត្ថុដែលនៅជាប់នឹងដី ឬ វត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេសអាគារ ឬ សំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរកន្លែងបានគឺជាសមាសភាគនៃដី ។ ហេតុនេះ នាំឱ្យសិទ្ធិលើការបញ្ចាំដែលមាននៅលើដីមួយកន្លែង នឹងមានអានុភាពទៅលើអ្វីដែលជាសមាសភាគនៃដីនោះដែរ ។

ទន្ទឹមនឹងនេះ មាត្រា ៨៥១ ដែលស្តីអំពីលំដាប់នៃហ៊ីប៉ូតែក ក៏ត្រូវយកមកអនុវត្តដូចគ្នានឹងការបញ្ចាំដែរ មានន័យថា អាទិភាពនៃសិទ្ធិលើការបញ្ចាំ គឺអាស្រ័យលើពេលវេលានៃការចុះបញ្ជីនៃសិទ្ធិទាំងនោះ ។

ដូចគ្នាដែរ មាត្រា ៨៥២ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ដែលអនុវត្តចំពោះហ៊ីប៉ូតែក ក៏ត្រូវអនុវត្តចំពោះសិទ្ធិលើការបញ្ចាំដែរ ។ មានន័យថា ក្នុងករណីដែលម្ចាស់បំណុលនៃសិទ្ធិលើការបញ្ចាំមានសិទ្ធិទាមទារការប្រាក់ ឬ ធនលាភផ្សេងទៀត ម្ចាស់បំណុលនៃសិទ្ធិលើការបញ្ចាំអាចអនុវត្តសិទ្ធិលើការបញ្ចាំនោះ បានតែចំពោះចំនួននៃការសងដែលដល់កំណត់ពេលសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំ ចុងក្រោយតែប៉ុណ្ណោះ ។ ប៉ុន្តែ ចំពោះ

ធនលាភដែលមានពីមុនមក ប្រសិនបើបានចុះបញ្ជីពិសេសក្រោយពីបានដល់ពេលកំណត់ត្រូវសង សិទ្ធិលើការបញ្ចាំនេះអាចអនុវត្តបានចាប់ពីពេលដែលបានចុះបញ្ជីនោះ ។

ការកំណត់ដូច្នេះ ពីព្រោះវាមានភាពចាំបាច់សម្រាប់ការពារម្ចាស់បំណុលនៃសិទ្ធិប្រាតិភោគប្រត្យក្សផ្សេងទៀត ដែលស្ថិតនៅក្នុងលំដាប់ទាបជាង ដើម្បីឱ្យដឹងថាតើនៅសល់ចំនួនប៉ុន្មានដែលមិនត្រូវបានធានា ដូច្នេះ អាចឱ្យពួកគេ ដឹងថាតើពួកគេត្រូវឱ្យខ្ចីប្រាក់ចំនួនប៉ុន្មាន ។

## ៦. ការបញ្ចាំសិទ្ធិ

ដូចដែលយើងបានដឹងហើយថា ការបញ្ចាំអាចត្រូវបានធ្វើឡើងក្រោមរូបភាពបីយ៉ាងគឺ ការបញ្ចាំចលនវត្ថុ ការបញ្ចាំអចលនវត្ថុ និង ការបញ្ចាំសិទ្ធិ ។

ការបញ្ចាំចលនវត្ថុ ឬ អចលនវត្ថុ គឺត្រូវយកចលនវត្ថុ ឬ អចលនវត្ថុដែលជាកម្មវត្ថុនោះ ទៅប្រគល់ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ ផ្ទុយទៅវិញ ការបញ្ចាំសិទ្ធិ សំដៅលើការណ៍ដែលកូនបំណុលយកសិទ្ធិលើបំណុលរបស់ខ្លួន ដែលមានចំពោះកូនបំណុលទី ៣ ទៅដាក់បញ្ចាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំរបស់ខ្លួនដើម្បីធានានូវការសងបំណុលនោះ ។

**ឧទាហរណ៍ :** **ក** ជាម្ចាស់បំណុលរបស់លោក **គ** ចំនួន ២.០០០ ដុល្លារ ។ តែ **ក** ចង់ខ្ចីបំណុលពី **ខ** ចំនួន ១.០០០ ដុល្លារ ។ បើសិនជា **ក** គ្មានទ្រព្យអ្វីផ្សេងយកមកបញ្ចាំឱ្យ **ខ** ដើម្បីធានាបំណុលទេ **ក** អាចយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះ **គ** ទៅដាក់បញ្ចាំឱ្យ **ខ** ដើម្បីធានានូវការសងបំណុលដែលខ្លួនមានចំពោះ **ខ** បាន ។

**តើការបញ្ចាំសិទ្ធិលើបំណុលមានសារប្រយោជន៍យ៉ាងណា?**




តើការបញ្ចាំសិទ្ធិលើបំណុលមានសារប្រយោជន៍យ៉ាងណា?

**ឧទាហរណ៍ :** **ក** ជាម្ចាស់បំណុលរបស់ **គ** ចំនួន ២.០០០ ដុល្លារ ។ តែ **ក** ចង់ខ្ចីបំណុលពី **ខ** ចំនួន ១.០០០ ដុល្លារ ។ **ក** បានយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះ **គ** ចំនួន ១.០០០ ដុល្លារ (ក្នុងចំនួនទឹកប្រាក់ ២.០០០ ដុល្លារ ដែល **គ** ជំពាក់) ទៅដាក់បញ្ចាំឱ្យ **ខ** ដើម្បីធានានូវការសងបំណុលដែលខ្លួនមានចំពោះ **ខ** ។

សារប្រយោជន៍ចំពោះការបញ្ចាំសិទ្ធិលើបំណុលនេះកើតមានចំពោះម្ចាស់សិទ្ធិលើការបញ្ចាំ ជាពិសេសនៅពេលដែលមានម្ចាស់បំណុលធម្មតាផ្សេងទៀត ដូចជា **ឃ** និង **ង** ។

ក្នុងករណីនេះ បើសិនជា **គ** បានយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះ **គ** ចំនួន ១.០០០ ដុល្លារ (នៅក្នុងសិទ្ធិលើបំណុលចំនួន ២.០០០ ដុល្លារ) ទៅដាក់បញ្ចាំឱ្យ **ខ** នោះ **ខ** នឹងទទួលបាននូវសិទ្ធិជាអាទិភាពនៃទឹកប្រាក់ចំនួន ១.០០០ ដុល្លារ ដែល **គ** សងទៅ **ក** មុន **ឃ** និង **ខ** ដែលជាម្ចាស់បំណុលធម្មតារបស់ **ក**។

ប៉ុន្តែ តើម្ចាស់សិទ្ធិលើការបញ្ចាំអាចយកការបញ្ចាំសិទ្ធិលើបំណុលមកតតាំងចំពោះម្ចាស់បំណុលផ្សេងទៀតបានយ៉ាងដូចម្តេច? បញ្ហានេះ នឹងត្រូវលើកយកមកបង្ហាញនៅក្នុងប្រធានបទខាងក្រោមនេះ។

### ៦.១. លក្ខខណ្ឌសុពលភាព/អានុភាពនៃការបញ្ចាំសិទ្ធិលើបំណុលចំពោះគូភាគី

ពាក់ព័ន្ធនឹងការបញ្ចាំសិទ្ធិ ជាទូទៅ ការព្រមព្រៀងត្រូវបានចាត់ទុកថាជាលក្ខខណ្ឌដើម្បីបង្កើតអានុភាពសម្រាប់ការបង្កើតសិទ្ធិលើការបញ្ចាំ ព្រោះសិទ្ធិ គឺជាទ្រព្យអរូបី ហើយមិនអាចប្រគល់បានទេ។ ជាករណីលើកលែង ប្រសិនបើការអនុវត្តសិទ្ធិនោះ តម្រូវឱ្យមានការកាន់កាប់នូវឯកសារដែលបញ្ជាក់ពីសិទ្ធិនោះ ដូចជា មូលប្បទានប័ត្រ ការបង្កើតសិទ្ធិនោះតម្រូវឱ្យមានការប្រគល់នូវឯកសារនោះតាមលក្ខណៈនៃការបញ្ចាំ។

### ៦.២. លក្ខខណ្ឌតតាំងនៃការបញ្ចាំសិទ្ធិលើបំណុលចំពោះតតិយជន

ដើម្បីឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ អាចតតាំងជាមួយនឹងកូនបំណុលទី ៣ (ករណីខាងលើ គឺ **គ**) និង តតិយជនផ្សេងទៀត (ករណីខាងលើ គឺ **ឃ** និង **ខ**) អ្នកដែលយកសិទ្ធិលើបំណុលដែលមានចំពោះកូនបំណុលទី ៣ ទៅដាក់បញ្ចាំនោះ ត្រូវតែជូនដំណឹងអំពីការបង្កើតការបញ្ចាំសិទ្ធិលើបំណុលរបស់ខ្លួនដល់កូនបំណុលទី ៣ ឬ មានការយល់ព្រមពីកូនបំណុលទី ៣ នោះ។ ហើយការជូនដំណឹង ឬ ការយល់ព្រមខាងលើនេះ មិនអាចយកមកតតាំងចំពោះតតិយជនក្រៅពីកូនបំណុលទី ៣ បានឡើយ ប្រសិនបើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ។

នៅក្នុងករណីខាងលើនេះ **គ** អាចបដិសេធមិនសងប្រាក់ទៅ **ខ** បានដោយគ្មានការយល់ព្រម ឬ ការជូនដំណឹងណាមួយនោះ ពីព្រោះ **ខ** មិនអាចតតាំងសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះ **គ** បានទេ។ បន្ទាប់មកដើម្បីឱ្យ **ខ** អាចតតាំងសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះ **គ** បាន **ខ** ត្រូវការនូវការយល់ព្រម ឬ ការជូនដំណឹង ហើយ **គ** មិនអាចបដិសេធនូវការសងចំពោះ **ខ** បានទេ។

ដោយគ្មានការយល់ព្រម ឬ ការជូនដំណឹងដោយគ្មានកាលបរិច្ឆេទស្ថាពរ **ខ** មិនអាចតតាំងអំពីអាទិភាពរបស់ខ្លួនចំពោះ **ឃ** និង **ខ** បានទេ ជាឧទាហរណ៍។ ហេតុដូច្នេះ **ឃ** និង **ខ** អាចរឹបអូសសិទ្ធិលើបំណុល ហើយទទួលបាននូវការចែកចំណែកតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ពីព្រោះ **ខ** មិនអាចអះអាងអំពីអាទិភាពរបស់ខ្លួនបាន។ ប្រសិនបើ **ខ** ចង់អះអាងអំពីសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះ **ឃ** និង **ខ** បន្ថែមលើ **គ** នោះ **ខ** ត្រូវការនូវការជូនដំណឹង ឬ ការយល់ព្រមដោយមានកាលបរិច្ឆេទស្ថាពរ។

យោងតាមមាត្រា ៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី លិខិតដែលមានកាលបរិច្ឆេទស្ថាពរ សំដៅដល់ :

*ក- លិខិតយថាភូត : ចំពោះលិខិតយថាភូត កាលបរិច្ឆេទនៃការធ្វើលិខិតនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។*

*ខ- លិខិតឯកជនដែលសារការី ឬ ក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះ និង ចុះហត្ថលេខា ។ ក្នុងករណីនេះ កាលបរិច្ឆេទនោះត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។*

*គ- លិខិតឯកជនដែលមានជនណាម្នាក់ក្នុងចំណោមជនដែលបានចុះហត្ថលេខាលើលិខិតនោះ បានទទួលមរណភាព ។ ក្នុងករណីនេះ ថ្ងៃដែលជននោះទទួលមរណភាព ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។*

*ឃ- លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាន នៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។ ក្នុងករណីនេះ កាលបរិច្ឆេទនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ សម្រាប់លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាននោះ ។*

តើលិខិតអ្វីខ្លះ ត្រូវចាត់ទុកជាលិខិតយថាភូតនោះ? ចំណុចនេះមានចែងនៅក្នុងមាត្រា ៩ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី គឺសំដៅដល់លិខិតដែលធ្វើឡើងដោយសារការី ឬ កុងស៊ុល ឬ ជាលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ។

## ៦.៣. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយប្រមូលសិទ្ធិលើបំណុល

ផ្អែកតាមមាត្រា ៨៤២ កថាខណ្ឌទី ១ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនចាំបាច់ដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ដើម្បីប្រមូលប្រាក់នោះទេ ។

ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលជាប្រាក់ ទំហំនៃការប្រមូលត្រូវបានកម្រិតត្រឹមចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា ( មាត្រា ៨៤២ កថាខណ្ឌទី ២) ។

បើកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុល ដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំបានមកដល់មុនកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ កូនបំណុលទី ៣ អាចដាក់ប្រាក់តម្កល់ ហើយសិទ្ធិលើការបញ្ចាំមានអត្ថិភាពលើប្រាក់តម្កល់នោះ ( មាត្រា ៨៤២ កថាខណ្ឌទី ៣) ។

ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលមិនមែនជាប្រាក់ទេ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិលើការបញ្ចាំលើវត្ថុដែលខ្លួនបានទទួលជាការសង ( មាត្រា ៨៤២ កថាខណ្ឌទី ៤) ។

| | **ការបញ្ចាំចលនវត្ថុ** | **ការបញ្ចាំអចលនវត្ថុ** | **ការបញ្ចាំសិទ្ធិលើបំណុល** |
|---|---|---|---|
| **កម្មវត្ថុនៃការបញ្ចាំ** | ចលនវត្ថុ | អចលនវត្ថុ | សិទ្ធិលើបំណុល |
| **លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាចំពោះគូភាគី** | ការព្រមព្រៀង | ការព្រមព្រៀង | ការព្រមព្រៀង |
| **លក្ខខណ្ឌតតាំងនៃកិច្ចសន្យាចំពោះតតិយជន** | ការកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ | លិខិតយថាភូត និង ការចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី | ការជូនដំណឹងទៅកូនបំណុលទី ៣ ឬ ការយល់ព្រមពីកូនបំណុល ទី ៣ ដែលត្រូវធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ |
| **លំដាប់នៃអាទិភាពក្នុងករណីប្រជែងជាមួយសិទ្ធិប្រត្យក្សផ្សេងទៀត** | អាស្រ័យទៅលើលំដាប់នៃការចាប់ផ្ដើមការកាន់កាប់ | អាស្រ័យលើពេលវេលានៃការចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី | អាស្រ័យទៅលើ កាលបរិច្ឆេទស្ថាពរនៃលិខិតជូនដំណឹងនោះ |

# ផ្នែកទី ៤

# ប្រាតិភោគដោយអនុប្បទាន

## ១. សេចក្តីផ្តើម

ជាឧទាហរណ៍ **ក** គឺជាអ្នកលក់ដុំ ហើយគាត់មានបំណងចង់ខ្ចីប្រាក់ពី **ខ** ។ **ខ** ទាមទារឱ្យដាក់ប្រាតិភោគ ទើបខ្លួនព្រមឱ្យខ្ចីប្រាក់ ។

**ក** មិនមានអចលនវត្ថុនោះទេ ហេតុដូច្នេះ **ក** មិនអាចបង្កើតហ៊ីប៉ូតែកបានទេ ហើយទ្រព្យសម្បត្តិរបស់គាត់ គឺមានតែទំនិញដែលស្តុកទុកនៅក្នុងឃ្លាំងតែប៉ុណ្ណោះ ។ គាត់មិនអាចធ្វើជំនួញបានទេ ប្រសិនបើគាត់យកទំនិញនៅក្នុងឃ្លាំងនោះទៅដាក់បញ្ចាំឱ្យ **ខ** ដោយសារថាទំនិញទាំងនោះ គឺជាទំនិញដែលនឹងត្រូវលក់ទៅឱ្យអ្នកលក់រាយ ។

លើសពីនេះ ទំនិញនីមួយៗត្រូវបានប្តូរពីមួយថ្ងៃទៅមួយថ្ងៃ ហេតុដូច្នេះវាហាក់បីដូចជាមិនអាចយកមកដាក់ជាប្រាតិភោគបានទេ ។ តើ **ក** ត្រូវធ្វើយ៉ាងដូចម្តេច?

ប្រាតិភោគដោយគ្មានការផ្ទេរការកាន់កាប់ គឺមានសារប្រយោជន៍ខ្លាំងណាស់ចំពោះកូនបំណុល នៅក្នុងករណីដែលកូនបំណុលទទួលផលប្រយោជន៍ពីវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ ។

ពាក់ព័ន្ធនឹងអចលនវត្ថុ ហ៊ីប៉ូតែកអាចត្រូវបានបង្កើតឡើងដោយគ្មានការផ្ទេរការកាន់កាប់ ។

ចំណែកឯចលនវត្ថុវិញ ប្រាតិភោគដោយអនុប្បទាន អាចត្រូវបានបង្កើតឡើងដោយគ្មានការផ្ទេរការកាន់កាប់ដោយចំពោះ ហើយប្រាតិភោគដោយអនុប្បទាននេះ អាចត្រូវបានបង្កើតឡើងលើចលនវត្ថុច្រើនជាងមួយ ដោយមានការព្រមព្រៀងតែមួយប៉ុណ្ណោះ ដើម្បីឱ្យកូនបំណុលអាចបន្តទទួលផលប្រយោជន៍ពីចលនវត្ថុនោះ ។

ទោះបីមើលទៅហ៊ីប៉ូតែក និង ប្រាតិភោគដោយអនុប្បទានមានលក្ខណៈខុសគ្នាក៏ដោយ ក៏នៅមានលក្ខណៈរួមដែរ ។ ឧទាហរណ៍ : មានតតិយជនដែលមានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់ ចំពោះវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ។ នៅក្នុងករណីនៃហ៊ីប៉ូតែក មានប្រព័ន្ធចុះបញ្ជីដើម្បីឱ្យតតិយជនដឹងអំពីស្ថានភាពគតិយុត្តនៃវត្ថុដែលជាកម្មវត្ថុ ។

ផ្ទុយទៅវិញ ទាក់ទងនឹងចលនវត្ថុ វាគ្មានប្រព័ន្ធចុះបញ្ជីដូចគ្នានឹងអចលនវត្ថុ ដើម្បីជូនដំណឹងអំពីស្ថានភាពគតិយុត្តជាសាធារណៈនោះទេ ។ ហេតុដូច្នេះ ចាំបាច់ត្រូវមានវិធាននៅក្នុងករណីដែលមានទំនាក់ទំនងផលប្រយោជន៍តាមផ្លូវច្បាប់របស់តតិយជន និង កម្មវត្ថុ ដូចជា ករណីដែលតតិយជនទិញវត្ថុដែលជាកម្មវត្ថុ ជាពិសេស ករណីដែលតតិយជននោះមិនបានដឹងថាវត្ថុនោះ គឺជាកម្មវត្ថុនៃប្រាតិភោគ ។

## ២. លក្ខខណ្ឌ

យោងតាមមាត្រា ៨៨៨ និងមាត្រា ៨៨៩ លក្ខខណ្ឌដើម្បីបង្កើតប្រាតិភោគដោយអនុប្បទាន គឺមានដូចខាងក្រោមនេះ :

ក- ចលនវត្ថុមួយ ឬ ច្រើនជាងមួយ

ក្នុងករណីដែលមានចលនវត្ថុច្រើនជាងមួយ ចលនវត្ថុទាំងនោះត្រូវកំណត់ទំហំតាមមាត្រដ្ឋាន ដូចជា ប្រភេទនៃចលនវត្ថុ ឬ កន្លែងស្ថិតនៅនៃចលនវត្ថុ ជាចលនវត្ថុផ្គុំគ្នា។ ប្រាតិភោគដោយអនុប្បទាន ចំពោះចលនវត្ថុផ្គុំគ្នា មានសារប្រយោជន៍នៅពេលដែលជនណាម្នាក់ ដូចជា ពាណិជ្ជករ ឬ អាជីវករចង់យកទំនិញមកដាក់ជាប្រាតិភោគ ពីព្រោះពាណិជ្ជករ ឬ អាជីវករនោះ អាចដាក់ប្រាតិភោគជាចលនវត្ថុផ្គុំគ្នាបាន។

ខ- ការព្រមព្រៀង

គ- ការផ្ទេរការកាន់កាប់ ដើម្បីតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះតតិយជន។

ទាក់ទងនឹងការផ្ទេរការកាន់កាប់ លក្ខខណ្ឌនេះមិនដកចេញនូវទម្រង់ណាមួយ នៅក្នុងចំណោមទម្រង់ទាំងបួននៃការផ្ទេរការកាន់កាប់នោះទេ ហេតុដូច្នេះការប្តូរលក្ខណៈនៃការកាន់កាប់អាចបំពេញនូវលក្ខខណ្ឌនេះបាន។

នៅក្នុងករណីដែល **ក** និង **ខ** បានព្រមព្រៀងគ្នាថា **ក** ត្រូវធ្វើអនុប្បទានកម្មសិទ្ធិនៃចលនវត្ថុនៅក្នុងឃ្លាំងជាប្រាតិភោគ ហើយ **ក** ផ្ទេរការកាន់កាប់ (ដោយប្រយោល) ទៅឱ្យ **ខ** តាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ **ខ** អាចតតាំងអនុប្បទាននេះចំពោះតតិយជនបាន។

## ៣. អានុភាព

### ៣.១. ទំហំនៃអានុភាព

សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទានមុន ឬ ក្រោយការបង្កើតសិទ្ធិប្រាតិភោគប្រត្យក្ស យោងតាមមាត្រា ៨៩១ កថាខណ្ឌទី ១។

ភាគីអាចធ្វើការសន្យាពិសេសដែលផ្ទុយនឹងបញ្ញត្តិមាត្រា ៨៩១ កថាខណ្ឌទី ១។

### ៣.២. អានុភាពចំពោះផល

ក្នុងករណីដែលអ្នកបង្កើតប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ អានុភាពមិនមានចំពោះផលឡើយ។ ចំណុចនេះ គឺជាចំណុចដែលមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងហ៊ីប៉ូតែក។

មូលហេតុដែលមិនឱ្យមានអានុភាព ព្រោះថាអ្នកបង្កើត និង តតិយជនដែលទទួលការបញ្ជា មានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលពីវត្ថុដែលខ្លួនកំពុងកាន់កាប់ដោយចំពោះ។

**ឧទាហរណ៍ : ក** បានយកម៉ូតូជាច្រើនគ្រឿងដែលខ្លួនទុកសម្រាប់ជួលឱ្យអ្នកដទៃនោះទៅបង្កើតប្រាតិភោគដោយអនុប្បទានជាមួយ **ខ** ហើយបានផ្ទេរការកាន់កាប់ដោយការព្រមព្រៀង ដើម្បីខ្ចីប្រាក់ពី **ខ**។ **ក** ជាអ្នកកាន់កាប់ដោយចំពោះលើម៉ូតូដែលជាកម្មវត្ថុនៃប្រាតិភោគនោះ។ ហេតុដូច្នេះ **ក** មានសិទ្ធិទទួលផលពីកម្មវត្ថុនោះតាមរយៈការជួលម៉ូតូទាំងនោះ ហើយ **ខ** មិនអាចទទួលផល ដូចជា ថ្លៃឈ្នួលឡើយ (អានុភាពនៃប្រាតិភោគដោយអនុប្បទានមិនមានចំពោះផលឡើយ)។

ផ្ទុយទៅវិញ ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជោកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ មាត្រា ៨២២ (សិទ្ធិទទួលការសងពីផលដោយមានអាទិភាព) ត្រូវយកមកអនុវត្តដូចគ្នា។ មានន័យថា ផលដែលបានពីកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាននេះ ត្រូវយកមកកាត់សិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន។ ចំពោះវិធីនៃការកាត់សិទ្ធិលើបំណុលនោះ គឺត្រូវកាត់ការប្រាក់ជាមុនសិន ហើយប្រសិនបើមានសល់ត្រូវយកទៅកាត់ប្រាក់ដើម។

### ៣.៣. ឧបាទេសកម្ម

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចធ្វើឧបាទេសកម្មចំពោះប្រាក់ ឬ វត្ថុផ្សេងទៀត ដែលត្រូវទទួលដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន។

មានករណីលើកលែងចំនួន ពីរ ចំពោះបញ្ញត្តិនេះ :

ទី ១ គឺម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើឧបាទេសកម្មបានទេ ក្រោយពេលដែលប្រាក់ ឬ វត្ថុផ្សេងទៀតនោះត្រូវបានសង ឬ ប្រគល់ទៅឱ្យអ្នកបង្កើតរួចហើយ។

ទី ២ ក្នុងករណីចលនវត្ថុផ្តុំគ្នា ហើយចលនវត្ថុនោះត្រូវមានគម្រោងលក់តាំងពីដំបូងនូវចលនវត្ថុនេះ ទៅឱ្យអ្នកផ្សេងទៀត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើឧបាទេសកម្មបានទេ។

**ឧទាហរណ៍ទី ១ : ក** បានយកទំនិញរបស់ខ្លួន ទៅបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានជាមួយ **ខ**។ ក្រោយមក **ក** បានលក់សាងទំនិញទាំងអស់នោះទៅឱ្យ **គ** ។

ក្នុងករណីនោះ **ខ** អាចធ្វើឧបាទេសកម្មលើប្រាក់ដែលជាថ្លៃសាងទំនិញនោះពី **គ** បាន។ ប៉ុន្តែ ក្នុងករណីដែលប្រាក់នោះត្រូវប្រគល់ទៅឱ្យ **ក** ហើយនោះ គឺ **ខ** មិនអាចធ្វើឧបាទេសកម្មបានទេ។

**ឧទាហរណ៍ទី ២ : ក** បានយកទំនិញរបស់ខ្លួននៅក្នុងឃ្លាំងជាចលនវត្ថុផ្តុំគ្នាដែលគ្រោងនឹងលក់ ទៅបង្កើតប្រាតិភោគដោយអនុប្បទានជាមួយ **ខ**។ នៅក្នុងករណីនេះ មិនថាទំនិញដែលទើបនឹងនាំចូល ឬ ទំនិញដែលបានលក់ចេញនោះទេ គឺទំនិញដែលមាននៅក្នុងឃ្លាំងនាពេលនេះត្រូវបានចាត់ទុកថាជាចលនវត្ថុផ្តុំគ្នា។ ហេតុដូច្នេះ អានុភាពនៃប្រាតិភោគមិនមានចំពោះវត្ថុដែលត្រូវបានយកចេញនោះទេ។

ក្នុងករណីនេះ **ខ** មិនអាចធ្វើឧបាទេសកម្មលើទឹកប្រាក់ដែលបានពីការលក់ទំនិញនោះទេ។

### ៣.៤. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានារួមមាន ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ យោងមាត្រា ៨៩៥។ វា មានន័យថានៅពេលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ធ្វើការអនុវត្តសិទ្ធិប្រាតិភោគ ដោយអនុប្បទាន តើទំហំសិទ្ធិលើបំណុលមានដល់កម្រិតណា? ដូចបានលើកឡើងខាងលើ វាមានអានុភាពធានាដល់ប្រាក់

ដើម ការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ។ មាត្រានេះ ដូចគ្នាជាលក្ខណៈសារធាតុនឹងបញ្ញត្តិស្តីអំពីសិទ្ធិលើការបញ្ចាំមានចែងក្នុងមាត្រា ៨២០។

## ៣.៥. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ និង ម្ចាស់សិទ្ធិប្រាតិភោគប្រត្យក្ស

### ៣.៥.១. ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ

#### ៣.៥.១.១. ចលនវត្ថុចម្បង

នៅក្នុងករណីដែលចលនវត្ថុត្រូវបានធ្វើអនុប្បទានជាប្រាតិភោគ ចលនវត្ថុនោះនៅតែអាចស្ថិតនៅក្រោមការកាន់កាប់របស់អ្នកធានាដោយវត្ថុ។ នៅក្នុងករណីនេះ ដោយឆ្លៀតឱកាសដែលខ្លួនកំពុងតែកាន់កាប់ជាក់ស្តែង អ្នកធានាដោយវត្ថុអាចធ្វើអនុប្បទាននូវចលនវត្ថុនោះទៅឱ្យតតិយជន ឬ ដាក់ជាប្រាតិភោគបាន។ នៅក្នុងករណីនេះ គេចាំបាច់ត្រូវកំណត់ថា តើម្ចាស់សិទ្ធិប្រាតិភោគ ឬ តតិយជនអាចអះអាងអំពីអាទិភាពអំពីចលនវត្ថុចំពោះអ្នកដទៃបាន។

**ឧទាហរណ៍ :** យោងតាមមាត្រា ៨៩៤ បញ្ហាគឺនៅត្រង់ចំណុចថា តើតតិយជនបានបំពេញលក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុដែរ ឬ ទេ។ នៅក្នុងករណីដែល **ក** បានជំពាក់បំណុល **ខ** បន្ទាប់មក **ក** បានធ្វើអនុប្បទានឡានរបស់ខ្លួនជាប្រាតិភោគ ប៉ុន្តែ **ក** នៅតែបន្តការកាន់កាប់។ បន្ទាប់មក **ក** បានលក់ឡាននោះទៅឱ្យ **គ** ដែលមិនបានដឹងអំពីការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ នៅក្នុងករណីនេះ ដោយផ្អែកតាមលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើអចលនវត្ថុ **គ** អាចធ្វើលទ្ធកម្មកម្មសិទ្ធិ ហើយវាឆ្លុះបញ្ចាំងពីការបាត់បង់ប្រាតិភោគចំពោះ **ក**។ ក្នុងករណីនេះ **ខ** មិនអាចអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះឡាននោះបានទេ។ ផ្ទុយទៅវិញ នៅក្នុងករណីដែល **គ** មិនបានបំពេញលក្ខខណ្ឌលទ្ធកម្មដោយសុចរិតទេ **ខ** អាចអះអាងពីអាទិភាព ជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដោយផ្អែកតាមមាត្រា ៧៧២។

តើមានវិធីណាដើម្បីការពារ **ខ** ពីការណីដែល **គ** ធ្វើលទ្ធកម្មនូវកម្មវត្ថុ? វិធីដែលអាចធ្វើបាន គឺអាចជាការដាក់ជាសញ្ញាសម្គាល់លើឡាននោះ ដើម្បីបង្ហាញថាជាកម្មវត្ថុដោយអនុប្បទាន។ តាមរយៈការធ្វើបែបនេះ **ខ** អាចធ្វើឱ្យតតិយជនដែលមានបំណងទិញរថយន្តនោះក្លាយជាជនទុច្ចរិត និង មានកំហុស។

#### ៣.៥.១.២. ចលនវត្ថុផ្តុំគ្នា

នៅក្នុងករណីដែលចលនវត្ថុផ្តុំគ្នា អ្នកធានាដោយវត្ថុអាចចាត់ចែងវត្ថុដែលមានគម្រោងនឹងលក់បាន ដោយសេរី យោងតាមមាត្រា ៨៩៤ កថាខណ្ឌទី ២។

**ឧទាហរណ៍ :** នៅក្នុងករណី **ក** បានជំពាក់បំណុល **ខ** **ក** បានធ្វើអនុប្បទានទំនិញក្នុងហាង ដែលជាចលនវត្ថុផ្តុំគ្នាជាប្រាតិភោគ ដោយ **ក** នៅតែបន្តការកាន់កាប់ដោយចំពោះ។ បន្ទាប់មក **ក** បានលក់ទំនិញដែលមានគម្រោងនឹង

លក់តាំងពីដំបូងនោះ ទៅឱ្យ គ ដែលបានដឹងអំពីការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានដោយ ក។ នៅក្នុងករណីនេះយោងតាមមាត្រា ៨៩៤ កថាខណ្ឌទី ២ ទោះបីជា គ បានដឹងអំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សរបស់ ខ ក៏ដោយ ក៏ គ អាចធ្វើលទ្ធកម្មកម្មសិទ្ធិនៃទំនិញបានដែរ។ នេះក៏ព្រោះតែទំនិញទាំងនោះ នឹងលែងជាផ្នែកនៃចលនវត្ថុផ្តុំគ្នា នៅពេលដែលនៅក្រៅទំហំនៃចលនវត្ថុផ្តុំគ្នា។

### ៣.៥.២. ការចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

ក្នុងករណីវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលគាត់បានកាន់កាប់ដោយផ្ទាល់ នោះមាត្រា ៨៩៧ ត្រូវយកមកអនុវត្ត។

នៅក្នុងករណីនៃការចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន វាមានលក្ខណៈស្រដៀងគ្នាទៅនឹងការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ បញ្ហាគឺនៅត្រង់ថាតើតតិយជនបានបំពេញលក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុដែរ ឬ ទេ។ នៅក្នុងករណីខាងលើ ខ បានធ្វើលទ្ធកម្មនូវការកាន់កាប់ទំនិញនៅក្នុងឃ្លាំងពី ក ហើយដោយគ្មានការយល់ព្រមពី ក ខ បានលក់ទំនិញនោះទៅឱ្យ គ។ គ មិនបានដឹងថាវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញនេះ ជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាននោះទេ។ ក្នុងករណីនេះ គ អាចទទួលបាននូវកម្មសិទ្ធិនៃចលនវត្ថុនោះដោយស្របច្បាប់ ដោយ ក គ្រាន់តែអាចទាមទារសំណងពី ខ។ ផ្ទុយទៅវិញ បើសិនជា គ មានកំហុស ឬ ជាជនទុច្ចរិត ក អាចទទួលបាននូវចលនវត្ថុនោះត្រឡប់មកវិញបាន។

### ៣.៦. បញ្ញត្តិពិសេសនៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុ

មាត្រា ៨៩៦ ចែងថា បញ្ញត្តិនៃមាត្រា ៨២១ (អានុភាពនៃការឃាត់ទុក) មាត្រា ៨២៣ (ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ) និង មាត្រា ៨២៤ (សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) ត្រូវយកមកអនុវត្តដូចគ្នាចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ។ មូលហេតុ គឺដោយសារទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន គឺស្រដៀងគ្នានឹងទំនាក់ទំនងរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និង វត្ថុដែលជាកម្មវត្ថុ។

## ៤. ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

មានវិធីពីរយ៉ាង ក្នុងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន។ ទី ១ គឺការប្តូរវត្ថុដែលជាកម្មវត្ថុជាប្រាក់ ហើយទី ២ គឺអនុប្បទានជាស្ថាពរ យោងតាមមាត្រា ៨៩៨ កថាខណ្ឌទី ១។

**ឧទាហរណ៍ :** ក គឺជាអ្នកលក់ដុំ ហើយគាត់មានបំណងចង់ខ្ចីប្រាក់ពី ខ។ ខ ទាមទារឱ្យដាក់ប្រាតិភោគទើបខ្លួនព្រមឱ្យខ្ចីប្រាក់។ ក មិនមានអចលនវត្ថុនោះទេ ហេតុដូច្នេះ ក និង ខ បានព្រមព្រៀងគ្នាថា ក ធ្វើអនុប្បទានកម្មសិទ្ធិលើចលនវត្ថុនៅក្នុងឃ្លាំងជាប្រាតិភោគ ហើយ ក បានផ្ទេរការកាន់កាប់ដោយប្រយោលទៅឱ្យ ខ តាមរយៈ

ការប្តូរលក្ខណៈនៃការកាន់កាប់ ដើម្បីតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះតតិយជន។ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានាមានចំនួន ២០០ ដុល្លារ ប៉ុន្តែ ក មិនបានសងនោះទេ។ ខ មានបំណងចង់អនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួន។ ដូចនេះ មានវិធី ២ យ៉ាងដែល ខ អាចជ្រើសរើសបាន។

### ៩.១. ការប្តូរជាប្រាក់

ក្នុងករណីដល់កាលបរិច្ឆេទកំណត់សង តែ ក មិនសងទេនោះ ខ អាចធ្វើការចាត់ចែងវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ដោយខ្លួនគាត់បាន ដោយគ្រាន់តែជូនដំណឹងទៅអ្នកបង្កើតសិទ្ធិប្រាតិភោគ។

### ៩.២. អនុប្បទានជាស្ថាពរ

ក្រៅពីជម្រើសនៃការចាត់ចែងដោយការប្តូរជាប្រាក់ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្រើជម្រើសដោយធ្វើអនុប្បទានជាស្ថាពរ មានន័យថាយកវត្ថុដែលជាកម្មវត្ថុជាកម្មសិទ្ធិតែម្តង។

### ៩.៣. ករណីយកិច្ចត្រូវបង់ទឹកប្រាក់ដែលលើស

ផ្អែកតាមមាត្រា ៨៩៨ កថាខណ្ឌទី ៣ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបង់នូវចំនួនទឹកប្រាក់ដែលលើសពីចំនួនទឹកប្រាក់កាតព្វកិច្ចទៅអ្នកបង្កើតវិញដោយចាត់ទុកជាប្រាក់ជម្រះ។ មានន័យថា ទោះបីជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានប្រើជម្រើសណាមួយក៏ដោយ ក៏ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមានករណីយកិច្ចត្រូវបង់ចំនួនទឹកប្រាក់ដែលលើសដោយចាត់ជាប្រាក់ជម្រះ បើតម្លៃនៃវត្ថុមានចំនួនលើសទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង យោងតាមមាត្រា ៨៩៨ កថាខណ្ឌទី៣។

### ៩.៤. សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត

ជាគោលការណ៍ បើដល់កាលបរិច្ឆេទសងហើយ ប៉ុន្តែនៅមិនទាន់បានទទួលសំណងនោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្រើជម្រើសណាមួយក៏បាន ដើម្បីអនុវត្ត តែបើអ្នកបង្កើតបានសង ទោះបីជានៅក្រោយពេលកំណត់សងក៏ដោយ ប៉ុន្តែនៅមុនពេលបង់ប្រាក់ដែលលើសនោះ កម្មសិទ្ធិត្រូវផ្ទេរទៅឱ្យអ្នកបង្កើតវិញ។

ក្រោយដល់ពេលកំណត់សង ខ បានជូនដំណឹងទៅ ក ហើយបានយកទំនិញនោះពីក្នុងឃ្លាំងដើម្បីប៉ាន់ស្មានតម្លៃ ហើយលក់ទំនិញទាំងនោះ។ មុនពេលបញ្ចប់ការវាយតម្លៃ ក ពិតជាមានសំណាងដោយមានទឹកប្រាក់គ្រប់គ្រាន់ដើម្បីសងបំណុល ហើយបានទាមទារឱ្យ ខ ប្រគល់ទំនិញនោះត្រឡប់មកវិញ។ ក្នុងករណីនេះ ក អាចមានសិទ្ធិទាមទារបាន។ ប៉ុន្តែបើ ខ លក់ឱ្យ គ ហើយនោះ ក ពុំអាចទាមទារមកវិញទេ តែអាចទាមទារសំណងបាន ពីព្រោះសិទ្ធិទទួលបានមកវិញត្រូវរលត់ ដោយការបញ្ចប់ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន។

# ផ្នែកទី ៥

## ការធានា

### ១. សេចក្តីផ្តើម

ការធានា គឺជាកិច្ចសន្យាដែលត្រូវបានធ្វើឡើងដោយបុគ្គល ដូចមានចែងក្នុងមាត្រា ៩០០ កថាខណ្ឌទី ១ នៃ ក្រមរដ្ឋប្បវេណីដែលបានបញ្ញត្តថា *អ្នកធានា បានសន្យាជាមួយនឹងម្ចាស់បំណុលថាខ្លួននឹងអនុវត្តកាតព្វកិច្ចមួយផ្នែក ឬ ទាំងមូលជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បង នៅក្នុងករណីដែលកូនបំណុលមានកាតព្វកិច្ចចម្បងនោះ ពុំអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយម្ចាស់បំណុលបានយល់ព្រមអំពីការសន្យានោះ។* ប្រសិនបើកូនបំណុលដែលមានកាតព្វកិច្ចចម្បង ក្លាយជាអសាធនីយ៍ ឬ មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន នោះម្ចាស់បំណុលសង្ឃឹមថា ខ្លួននឹងមានកូនបំណុលម្នាក់ទៀតមកជំនួស ដែលគេហៅថាអ្នកធានា។

ករណីនេះស្រដៀងគ្នាទៅនឹងសិទ្ធិប្រាតិភោគប្រត្យក្សដូចជា ហ៊ីប៉ូតែក ប៉ុន្តែមានផ្នែកមួយចំនួនខុសគ្នា។ នៅក្នុងករណីហ៊ីប៉ូតែក ប្រាតិភោគដោយអនុប្បទាន ឬ សិទ្ធិលើការបញ្ចាំ អ្វីដែលត្រូវបានធានា គឺជាតម្លៃនៃវត្ថុជាក់លាក់ណាមួយ ចំណែកឯអ្នកធានាវិញ គឺធានាបំណុលជាមួយនឹងទ្រព្យសម្បត្តិរបស់ខ្លួន នៅក្នុងចំនួនទឹកប្រាក់ដែលត្រូវបានធានា។

### ២. ការបង្កើតកិច្ចសន្យាធានា

#### ២.១. លក្ខខណ្ឌជាមូលដ្ឋាន

យោងតាមមាត្រា ៩០០ កថាខណ្ឌទី ១ ការព្រមព្រៀងរវាងបុគ្គលដែលមានបំណងធ្វើជាអ្នកធានា និង ម្ចាស់បំណុល គឺជាលក្ខខណ្ឌដែលតម្រូវឱ្យមាន ប៉ុន្តែឆន្ទៈរបស់កូនបំណុលមិនមែនជាលក្ខខណ្ឌតម្រូវឱ្យមាននោះទេ។ អាចនិយាយម្យ៉ាងទៀតថា ប្រសិនបើកូនបំណុលមិនយល់ព្រមចំពោះការធានាទេ នោះកិច្ចសន្យាធានាក៏អាចយកមកអនុវត្តបានដែរ។ កិច្ចសន្យាធានាត្រូវបានបង្កើតឡើងដោយកិច្ចសន្យាដែលបង្កើតអានុភាពតាមការព្រមព្រៀងរវាងអ្នកធានា និង ម្ចាស់បំណុល។

#### ២.២. ការការពារអ្នកធានា

ដូចដែលបានពន្យល់នៅក្នុងសេចក្តីផ្តើមរួចមកហើយ អ្នកធានាត្រូវធានាក្នុងទំហំនៃការធានាជាមួយនឹងទ្រព្យសម្បត្តិទាំងអស់របស់គាត់ ដែលជួនកាលវាជាបន្ទុកមួយយ៉ាងធ្ងន់ចំពោះអ្នកធានា។ ដូច្នេះ ក្រមរដ្ឋប្បវេណីការពារអ្នកធានាដើម្បីកុំឱ្យទទួលរងនូវការបាត់បង់ដែលមិនអាចរំពឹងទុកតាមវិធីមួយចំនួន។

### ២.២.១. ការផ្ដល់ពត៌មានសំខាន់ៗ

យោងតាមមាត្រា ៩០០ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី *ក្នុងករណីដែលអ្នកដែលមានបំណងធ្វើជាអ្នកធានា មិនមែនជាអ្នកដែលមានអាជីវកម្មធានា ម្ចាស់បំណុលត្រូវផ្ដល់នូវព័ត៌មានសំខាន់ៗ ស្ដីពីការណ៍ដែលអ្នកនោះក្លាយជាអ្នកធានាទៅឱ្យអ្នកដែលមានបំណងធ្វើជាអ្នកធានានោះ និង ត្រូវផ្ដល់ឱកាសឱ្យអ្នកនោះគិតពិចារណាឱ្យបានហ្មត់ចត់*។ មានន័យថា ម្ចាស់បំណុលត្រូវផ្ដល់ព័ត៌មានសំខាន់ៗ និង ត្រូវផ្ដល់ឱកាសឱ្យអ្នកនោះគិតពិចារណាឱ្យបានហ្មត់ចត់សម្រាប់អ្នកធានាដែលមិនមែនជាអ្នកមានបទពិសោធន៍ក្នុងការធានា។ បើពុំបានធ្វើដូចនោះទេ អ្នកធានាអាចលុបចោលកិច្ចសន្យាធានានោះបាន។

### ២.២.២. លិខិតជាលាយលក្ខណ៍អក្សរ

យោងតាមមាត្រា ៩០១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី កិច្ចសន្យាធានាអាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ប៉ុន្តែអ្នកធានាមានសិទ្ធិដកការធានាវិញនៅពេលណាក៏បាន។ ប៉ុន្តែ បើសិនជាអ្នកធានាបានចាប់ផ្ដើមអនុវត្តកាតព្វកិច្ចធានាដោយស្ម័គ្រចិត្តហើយនោះ អ្នកធានាមិនអាចដកវិញបានទេ។ ប៉ុន្តែជាគោលការណ៍ កិច្ចសន្យាធានាត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ លិខិតជាលាយលក្ខណ៍អក្សរនៃការធានា ត្រូវមានបញ្ជាក់ឱ្យច្បាស់លាស់អំពីខ្លឹមសារនៃកាតព្វកិច្ចធានា។

### ២.២.៣. ការសរសេរជាអក្សរដោយផ្ទាល់ដៃ

យោងតាមមាត្រា ៩០១ កថាខណ្ឌទី ២ បើកាតព្វកិច្ចធានាជាកាតព្វកិច្ច ដែលមានគោលបំណងសងជាប្រាក់នោះ ចំនួនទឹកប្រាក់នៃកាតព្វកិច្ចធានាត្រូវសរសេរជាអក្សរដោយផ្ទាល់ដៃរបស់អ្នកធានា។ មានន័យថាចំនួនទឹកប្រាក់នៃកាតព្វកិច្ចធានា គឺដើម្បីបង្ហាញថាជាការសម្រេចចិត្តយ៉ាងហ្មត់ចត់ និង ច្បាស់លាស់របស់អ្នកធានា។ ហេតុនេះគេទាមទារឱ្យអ្នកធានាសសេរចំនួនទឹកប្រាក់ជាអក្សរដោយផ្ទាល់ដៃ ដែលនេះជាចំនុចដែលសំខាន់មួយ ដើម្បីឱ្យអ្នកធានាទទួលស្គាល់ចំណងនៃកិច្ចសន្យាធានា។ ដូច្នេះ ក្នុងករណីដែលការធានាកាតព្វកិច្ចមានគោលបំណងសងជាប្រាក់នោះអ្នកធានាអាចដកកិច្ចសន្យាធានានោះនៅពេលណាក៏បាន បើអ្នកធានាមិនបានសរសេរនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចធានាជាអក្សរដោយផ្ទាល់ដៃទេនោះ។

## ៣. អានុភាពនៃកិច្ចសន្យាធានា

### ៣.១. ទំហំនៃកាតព្វកិច្ចធានា

ជាទូទៅ កាតព្វកិច្ចធានាត្រូវរាប់បញ្ចូលទាំងការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា និង សំណងការខូចខាត ដែលទាក់ទងនឹងកាតព្វកិច្ចចម្បង និង អ្វីដែលកើតឡើងបន្ទាប់បន្សំពីកាតព្វកិច្ចចម្បងនោះ ដោយគ្មានការសន្យាពិសេសណាមួយ។ លើសពីនេះ កិច្ចសន្យាធានាអាចកំណត់ពីចំនួនទឹកប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ឬ ប្រាក់សំណងការខូចខាតចំពោះការមិនអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាធានា ក្រៅពីការមិនអនុវត្តកាតព្វកិច្ចចម្បង។ ដោយយោងតាមមាត្រា ៩០៣ កថាខណ្ឌទី ១ អ្នកធានាត្រូវរាប់បញ្ចូលកាតព្វកិច្ចធាននូវប្រាក់

នោះជាការប្រាក់នៃប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា និង សំណងការខូចខាតដែលទាក់ទងនឹងកាតព្វកិច្ចចម្បង ព្រមទាំងអ្វីដែលកើតឡើងបន្ទាប់បន្សំពីកាតព្វកិច្ចចម្បងនេះ។ ប្រសិនបើភាគីនៃកិច្ចសន្យាធ្វើការសន្យាពិសេសទៀតនោះ ពួកគេត្រូវគោរពតាមការសន្យាពិសេសនោះ។

បើយោងតាមមាត្រា ៩០៣ កថាខណ្ឌទី ២ កិច្ចសន្យាធានាអាចកំណត់នូវចំនួនទឹកប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ឬ ប្រាក់សំណងការខូចខាតចំពោះការមិនអនុវត្តកាតព្វកិច្ចធានា ដាច់ដោយឡែកបានពីកាតព្វកិច្ចចម្បង។

**ឧទាហរណ៍ : ក** មានកាតព្វកិច្ចសងជាប្រាក់ចំនួន ១០.០០០ ដុល្លារ ចំពោះ **ខ**។ ការប្រាក់ និង ប្រាក់សំណង (ក្នុងករណីយឺតយ៉ាវ) ត្រូវបានព្រមព្រៀងគ្នារៀង១ខ្លួន គឺចំនួន ៧ %។

- **គ** មិនត្រឹមតែធានាចំពោះប្រាក់ដើមចំនួន ១០.០០០ ដុល្លារ ទេ គឺថែមទាំងការប្រាក់ និង ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យាដែលអាចមានថែមទៀតផង ក្នុងករណីប្រសិនបើ **គ** និង **ខ** បង្កើតកិច្ចសន្យាធានាដោយគ្មានការសន្យាពិសេសណាមួយនោះ។

- តាមរយៈកិច្ចសន្យាពិសេស **គ** អាចធានាត្រឹមតែប្រាក់ដើម ឬ ការប្រាក់ដែលអាចមាន។

- ក៏ដូចជាការធានាមួយផ្នែកដែរ **គ** និង **ខ** អាចធ្វើការសន្យាពិសេសអំពីការប្រាក់ ក្នុងករណីយឺតយ៉ាវចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន។ **ឧទាហរណ៍ : ខ** និង **គ** អាចសន្យាថា **គ** ត្រូវបង់ការប្រាក់ចំនួន ១០ % ចំពោះការយឺតយ៉ាវនៃកាតព្វកិច្ចធានា។ ក្នុងករណីនេះ **គ** មានកាតព្វកិច្ចបង់ប្រាក់ចំនួន ១០.០០០ ដុល្លារ ដែលជាប្រាក់ដើម ការប្រាក់ចំនួន ៥ % និង ការប្រាក់ក្នុងករណីយឺតយ៉ាវចំនួន ៧ % ដែលកើតចេញពីប្រាក់ដើម ហើយប្រសិនបើគាត់ អនុវត្តកាតព្វកិច្ចធានាមានភាពយឺតយ៉ាវ គាត់ត្រូវបង់ការប្រាក់ចំនួន ១០ % ចំពោះការយឺតយ៉ាវនៃកាតព្វកិច្ចធានា។

### ៣.២. លក្ខណៈនៃការធានា

យោងតាមមាត្រា ៩០៤ កថាខណ្ឌទី ១ បញ្ជាក់ថា *កិច្ចសន្យាធានាមិនអាចកើតឡើងបានឡើយ នៅក្នុងករណីដែលគ្មានកាតព្វកិច្ចចម្បងទេ*។ វាបានបញ្ជាក់យ៉ាងច្បាស់លាស់អំពីលទ្ធផលមួយចំនួនដែលកើតឡើង ដោយសារលក្ខណៈនៃការធានាដែលត្រូវបានគេហៅថា លក្ខណៈបន្ទាប់បន្សំនៃកាតព្វកិច្ចចម្បង។ ប៉ុន្តែ មានកិច្ចសន្យាធានាការខូចខាតដែលមិនមានភាពបន្ទាប់បន្សំ។

អ្នកធានាក៏មិនត្រូវមានកាតព្វកិច្ចធានាធ្ងន់ធ្ងរជាងកាតព្វកិច្ចចម្បងរបស់កូនបំណុលដែរ យោងតាមមាត្រា ៩០៤ កថាខណ្ឌទី ២។ ក្នុងករណីដែលកាតព្វកិច្ចចម្បងរលត់ កាតព្វកិច្ចធានាក៏ត្រូវរលត់ផងដែរ ព្រោះការអនុវត្តកាតព្វកិច្ចធានា គឺជាការធានាកាតព្វកិច្ចចម្បង ហេតុនេះបើកាតព្វកិច្ចចម្បងរលត់ ដោយសារមូលហេតុណាមួយនោះកាតព្វកិច្ចធានាក៏រលត់តាមផងដែរ យោងតាមមាត្រា ៩០៤ កថាខណ្ឌទី ៣។

ដើម្បីកុំឱ្យកាតព្វកិច្ចធានារលត់មុនកាតព្វកិច្ចចម្បង និង ដើម្បីឱ្យអាចប្រមូលសិទ្ធិលើបំណុលចម្បងបាននោះ ចាំបាច់ត្រូវផ្អាកអាជ្ញាយុកាលចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ដូចជាការទាមទារឱ្យកូនបំណុលអនុវត្ត ក៏មានអានុភាពចំពោះអ្នកធានាដែរ យោងតាមមាត្រា ៩០៤ កថាខណ្ឌទី ៤។

នៅពេលដែលសិទ្ធិលើបំណុលដែលមានកាតព្វកិច្ចធានាត្រូវបានធ្វើអនុប្បទាន នោះសិទ្ធិលើបំណុលដែលមានលើអ្នកធានា ក៏ត្រូវបានផ្ទេរដែរ លើកលែងតែមានការសន្យាពិសេស ( មាត្រា ៩០៤ កថាខណ្ឌទី ៥) ។ នេះ គឺដោយសារតែសិទ្ធិលើបំណុលចំពោះអ្នកធានា គឺជាសិទ្ធិបន្ទាប់បន្សំដែរ ។

## ៣.៣. សិទ្ធិរបស់អ្នកធានា

មូលហេតុមួយចំនួនទាក់ទងនឹងកាតព្វកិច្ចចម្បង គឺមានឥទ្ធិពលទៅលើកាតព្វកិច្ចធានា។ ចំណុចនេះ ក៏ឆ្លុះបញ្ចាំងអំពីលក្ខណៈបន្ទាប់បន្សំនៃកាតព្វកិច្ចធានាផងដែរ ។

សូមមើលឧទាហរណ៍មួយចំនួនដូចខាងក្រោម :

អង្គហេតុជាមូលដ្ឋាន : **ក** មានសិទ្ធិលើបំណុលចំពោះ **ខ** ហើយ **គ** គឺជាអ្នកធានាកាតព្វកិច្ចរបស់ **ខ**។

១- ក្នុងករណីដែលអំឡុងពេលអាជ្ញាយុកាលនៃកាតព្វកិច្ចចម្បងត្រូវបានបញ្ចប់ **គ** ក៏អាចលើកឡើងពីអាជ្ញាយុកាលដើម្បីរំលត់កាព្វកិច្ចធានាបានដែរ ស្របតាមមាត្រា ៩០៥ កថាខណ្ឌទី ១។

២- នៅក្នុងករណីទី ១ ទោះបីជា **ក** បោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាល **គ** នៅតែអាចលើកឡើងពីអាជ្ញាយុកាលដើម្បីផលប្រយោជន៍របស់ខ្លួនគាត់ផ្ទាល់ ផ្អែកតាមមាត្រា ៩០៥ កថាខណ្ឌទី ២។

៣- នៅក្នុងករណីដែល **ខ** មានសិទ្ធិតវ៉ា ដូចជា ការតវ៉ាឱ្យអនុវត្តព្រមគ្នា នោះ **គ** ក៏អាចអះអាងអំពីសិទ្ធិតវ៉ាដូចគ្នាផ្អែកតាមមាត្រា ៩០៥ កថាខណ្ឌទី ៣។ ដូចគ្នានេះដែរ បើ **ខ** មានសិទ្ធិលើបំណុលចំពោះ **ក** នោះ **គ** ក៏អាចបដិសេធនូវការអនុវត្តកាតព្វកិច្ចធានាបាន ត្រឹមតែកម្រិតដែលកាតព្វកិច្ចចម្បងត្រូវរលត់ដោយការទូទាត់ ផ្អែកតាមមាត្រា ៩០៥ កថាខណ្ឌទី ៥។

៤- ក្នុងករណីដែល **ខ** បានទទួលកាតព្វកិច្ចដោយសារការគំរាមកំហែង ការឆបោករបស់ **ក** ជាដើម ប៉ុន្តែមិនទាន់បានលុបចោលនៅឡើយ នោះ **គ** អាចបដិសេធនូវការអនុវត្តកាតព្វកិច្ចធានាបានតាមមាត្រា ៩០៥ កថាខណ្ឌទី ៤។

**កំណត់សម្គាល់ ១ :**

**គ** អាចបដិសេធនូវការអនុវត្តកាតព្វកិច្ចធានា ប៉ុន្តែ **គ** មិនអាចអនុវត្តសិទ្ធិលុបចោលបានទេ ពីព្រោះវាអាស្រ័យទៅលើកូនបំណុលដែលមានកាតព្វកិច្ចចម្បង ថាតើកូនបំណុលនោះត្រូវលុបចោល ឬ មិនលុបចោលដោយឈរលើទស្សនៈនៃគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។

**កំណត់សម្គាល់ ២ :**

ក្នុងករណីដែល **គ** បានដឹងថាកិច្ចសន្យារវាង **ក** និង **ខ** អាចលុបចោលបាន ហើយបានធានាកាតព្វកិច្ចជាផ្នែកមួយនៃជំនួញរបស់គាត់ នោះ **គ** ត្រូវទទួលបន្ទុកនូវកាតព្វកិច្ចឯករាជ្យមួយផ្សេងទៀត ដែលមានគោលបំណងដូចគ្នានឹងកាតព្វកិច្ចចម្បង តាមមាត្រា ៩០៦។

### ៣.៤. លក្ខណៈសម្បត្តិរបស់អ្នកធានា

*ក្នុងករណីដែលកូនបំណុលទទួលបន្ទុកនូវករណីយកិច្ចត្រូវរកអ្នកធានា អ្នកធានានេះត្រូវតែជាសមត្ថជន និងត្រូវមានសាធនភាពដើម្បីសងបំណុល* យោងតាមមាត្រា ៩០៧ កថាខណ្ឌទី ១ ហើយ*ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលដាក់ប្រាតិភោគផ្សេងទៀតបាន* តាមមាត្រា ៩០៧ កថាខណ្ឌទី ៣។

ក្នុងករណីដែលអ្នកធានាបានបាត់បង់នូវលក្ខណសម្បត្តិ ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលរកអ្នកធានាផ្សេងទៀតដែលមានលក្ខណសម្បត្តិដូចខាងលើមកជំនួសបាន តាមមាត្រា ៩០៧ កថាខណ្ឌទី ២។

គោលបំណងនៃបញ្ញត្តិទាំងនេះ គឺតម្រូវឱ្យកូនបំណុលដាក់ប្រាតិភោគឱ្យបានគ្រប់គ្រាន់ដើម្បីសង ចំណែកឯមាត្រា ៩០៧ កថាខណ្ឌទី ៤ បានចែងថា *បញ្ញត្តិនៃមាត្រានេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បំណុលបានជ្រើសតាំងអ្នកធានា* ពីព្រោះថាម្ចាស់បំណុលត្រូវទទួលខុសត្រូវចំពោះការជ្រើសតាំងរបស់ខ្លួនផ្ទាល់។

### ៣.៥. គោលការណ៍នៃការធានាដោយសាមគ្គីភាព

*បុគ្គលដែលទទួលបន្ទុកកាតព្វកិច្ច ត្រូវធានាដោយសាមគ្គីភាពជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បង មិនអាចទាមទារឱ្យម្ចាស់បំណុលទាមទារពីកូនបំណុលដែលមានកាតព្វកិច្ចចម្បងជាមុនសិន ឬ មិនអាចរួចផុតពីការអនុវត្តចំពោះខ្លួនផ្ទាល់ដោយសំអាងថា កូនបំណុលមានសាធនភាពគ្រប់គ្រាន់ដើម្បីសង និង អាចអនុវត្តចំពោះកូនបំណុលនោះដោយងាយស្រួលបានឡើយ* ។

អ្នកធានា មានសិទ្ធិតវ៉ាដូចខាងក្រោមនេះ តែក្នុងករណីដែលពួកគេបានធ្វើការសន្យាពិសេស :

១- ទាមទារឱ្យម្ចាស់បំណុលទាមទារពីកូនបំណុលដែលមានកាតព្វកិច្ចចម្បងមុនអ្នកធានា

២- រួចផុតពីការអនុវត្តចំពោះខ្លួន នៅពេលដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បង មានសាធនភាពគ្រប់គ្រាន់ដើម្បីសង និង អាចអនុវត្តចំពោះកូនបំណុលនោះដោយងាយស្រួលបាន។

### ៣.៦. អានុភាពនៃហេតុដែលកើតឡើងចំពោះអ្នកធានា

ផ្ទុយពីហេតុដែលកើតឡើងចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ហេតុដែលកើតឡើងចំពោះអ្នកធានាពុំមានអានុភាពចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បងនោះទេ យោងតាមមាត្រា ៩០៩។

ករណីលើកលែងមួយ គឺចំពោះ *ការទាមទារ ឬ ហេតុផ្សេងនៃការផ្អាកអាជ្ញាយុកាល ចំពោះអ្នកធានាដែលទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង* យោងតាមមាត្រា ៩០៩ វាក្យខណ្ឌទី ២ ។

**ឧទាហរណ៍ :** ករណីដែលម្ចាស់បំណុលទាមទារ ចំពោះអ្នកធានាដែលទទួលអាណត្តិពីកូនបំណុលដែលមាន កាតព្វកិច្ចចម្បង នោះអំឡុងពេលអាជ្ញាយុកាលទាក់ទងនឹងកាតព្វកិច្ចចម្បងត្រូវផ្អាក រីឯការទាមទារចំពោះអ្នកធានា ដែលមិនទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង មិនផ្អាកអាជ្ញាយុកាលនោះទេ។

### ៣.៧. អ្នកធានារួម

ជាទូទៅ *ក្នុងកិច្ចសន្យាដែលមានអ្នកធានាច្រើននាក់ អ្នកធានាម្នាក់ៗមានករណីយកិច្ចចំពោះចំនួនទឹកប្រាក់ ទាំងអស់នៃកាតព្វកិច្ចចម្បង* យោងតាមមាត្រា ៩១០ កថាខណ្ឌទី ១។

ផ្ទុយទៅវិញ តាមរយៈការសន្យាពិសេសចំពោះការបែងចែកការធានា អ្នកធានារួមអាចកម្រិតនូវការ ទទួលខុសត្រូវរបស់ខ្លួនបាន។ បន្ទុកត្រូវបានសន្មតថាស្មើៗគ្នា ប្រសិនបើគ្មានការសន្យាពិសេស (មាត្រា ៩១០ កថាខណ្ឌទី ២)។

ភាពខុសគ្នារវាង ***ការបែងចែក*** និង ***បន្ទុក*** គឺមានដូចខាងក្រោមនេះ :

| |
|---|
| **ក** បានខ្ចីប្រាក់ ៣.០០០ ដុល្លារ ពី **ខ**។ **គ១ គ២** និង **គ៣** ជាអ្នកធានាកាតព្វកិច្ចរបស់ **ក**។ នៅកាល បរិច្ឆេទនៃការសង **ខ** ទាមទារឱ្យ **ក** សង ប៉ុន្តែ **ក** មិនអាចសងទេ។ |
| ១- ករណីដែល **ខ** ទាមទារប្រាក់ចំនួន ៣.០០០ ដុល្លារ ពី **គ១** នោះ **គ១** មិនអាចតវ៉ាថា **គ១** ត្រូវបង់តែ ចំនួន ១.០០០ ដុល្លារ នោះទេ។ |
| ២- ក្រោយពីការសងចំនួន ៣.០០០ ដុល្លារ ហើយ **គ១** ត្រូវទាមទារប្រាក់ពី **គ២** និង **គ៣** ក្នុងម្នាក់ចំនួន ១.០០០ ដុល្លារ យោងតាមចំនួនភាគនៃបន្ទុក។ |

យោងតាមមាត្រា ៩១០ បើមិនមានការសន្យាពិសេសទេ អ្នកធានាម្នាក់ៗមានករណីយកិច្ចទទួលបន្ទុកនូវ ចំនួនទឹកប្រាក់ទាំងអស់នៃកាតព្វកិច្ចចម្បង។ មានន័យថា ម្ចាស់បំណុលអាចទាមទារពីអ្នកធានាមួយណាក៏បាន ឬ ទាមទារពីអ្នកធានាច្រើននាក់ក៏បាន។

បើគ្មានការសន្យាពិសេស បន្ទុករបស់អ្នកធានាត្រូវសន្មតថាស្មើៗគ្នា។ ដូច្នេះ បើអ្នកធានាណាម្នាក់បានចំណាយ នូវសោហ៊ុយរបស់ខ្លួនលើសពីបន្ទុករបស់គាត់ គាត់អាចទាមទារពីអ្នកធានាផ្សេងទៀតបាន ឱ្យសងនូវផ្នែកដែលបាន បង់លើសនោះ (មាត្រា ៩១៥ កថាខណ្ឌទី ១)។

តាមឧទាហរណ៍ខាងលើ **ក** បានទាមទារពី **គ១** ចំនួន ៣.០០០ ដុល្លារ ក្នុងករណីនេះ **គ១** បានចេញលើសពី ចំនួនបន្ទុករបស់ខ្លួន ១.០០០ ដុល្លារ ផ្ទុយទៅវិញ **គ២** និង **គ៣** មិនទាន់បានបំពេញបន្ទុករបស់ខ្លួននៅឡើយ ដូច្នេះ **គ១** មានសិទ្ធិទាមទារចំណែកដែលគាត់បានចំណាយលើស ពី **គ២** និង **គ៣** បាន។ ជាពិសេស **គ១** អាចទាមទារ ក្នុងម្នាក់ៗចំនួន ១.០០០ ដុល្លារ ពី **គ២** និង **គ៣** បាន។

## ៤. ប្រភេទនៃការធានា

### ៤.១. ការធានាធម្មតា

ការធានាធម្មតា សំដៅទៅលើទម្រង់ជាគោលការណ៍នៃការធានាបំណុល និង ប្រាក់ដើម។ **ឧទាហរណ៍ :** **ក** បានឱ្យ **ខ** ខ្ចីប្រាក់ចំនួន ២០.០០០ ដុល្លារ ដោយមាន **គ** ជាអ្នកធានា។ មួយឆ្នាំក្រោយមក នៅពេលដែលកាលកំណត់សងបានមកដល់ ម្ចាស់បំណុល **ក** មិនចាំបាច់ទាមទារប្រាក់ ២៤.០០០ ដុល្លារ (ប្រាក់ដើម និង ការប្រាក់) ពីកូនបំណុល **ខ** ដែលមានកាតព្វកិច្ចចម្បងទេ គឺ **ក** អាចទាមទារប្រាក់ ២៤.០០០ ដុល្លារ នោះ ពី **គ** បានភ្លាមតែម្តង ហើយប្រសិនបើ **គ** មិនព្រមសងទេ ម្ចាស់បំណុល **ក** មានសិទ្ធិអនុវត្តដោយបង្ខំចំពោះ **គ** ដោយផ្អែកលើសិទ្ធិលើបំណុលជាប្រាក់បាន។

### ៤.២. ការធានាការខូចខាត

តាមធម្មតា កាតព្វកិច្ចធានាមិនអាចកើតឡើងបានឡើយ នៅក្នុងករណីដែលគ្មានកាតព្វកិច្ចចម្បងទេ (មាត្រា ៩០៤ កថាខណ្ឌទី ១)។ កាតព្វកិច្ចរបស់អ្នកធានា ត្រូវបន្ថយមកត្រឹមកម្រិតនៃកាតព្វកិច្ចចម្បង (មាត្រា ៩០៤ កថាខណ្ឌទី ២) ហើយក្នុងករណីដែលកាតព្វកិច្ចចម្បងរលត់ កាតព្វកិច្ចធានាក៏ត្រូវរលត់ផងដែរ (មាត្រា ៩០៤ កថាខណ្ឌទី ៣)។ ទាំងនេះ គឺជាការឆ្លុះបញ្ចាំងពីលក្ខណៈបន្ទាប់បន្សំ។

ផ្ទុយទៅវិញ នៅក្នុងករណីនៃការធានាការខូចខាត អ្នកធានាត្រូវទទួលបន្ទុកកាតព្វកិច្ចដាច់ដោយឡែក។ នៅក្នុងន័យនេះ ការធានាការខូចខាតជាករណីលើកលែង ចំពោះលក្ខណៈបន្ទាប់បន្សំ។

**ឧទាហរណ៍ :** **ក** បានខ្ចីប្រាក់ពី **ខ** ហើយ **គ** គឺជាអ្នកធានា។ ក្នុងករណីដែលកាតព្វកិច្ចធានា ជាកាតព្វកិច្ចធានាធម្មតា ហើយកាតព្វកិច្ចរបស់ **គ** នឹងមិនត្រូវបានបង្កើតឡើងនោះទេ នៅពេលដែលកាតព្វកិច្ចចម្បង ត្រូវបានលុបចោលដូចមានចែងក្នុងមាត្រា ៩០៤ កថាខណ្ឌទី ១។ ប៉ុន្តែផ្ទុយទៅវិញ **គ** ត្រូវទទួលបន្ទុកកាតព្វកិច្ច ក្នុងករណីដែលការធានា គឺជាការធានាការខូចខាត។

### ៤.៣. ការធានាបំណុលអណ្តែត

នៅក្នុងកិច្ចសន្យាធានាធម្មតា ខ្លឹមសារ និង ចំនួនទឹកប្រាក់នៃកាតព្វកិច្ចចម្បងត្រូវបញ្ជាក់ឱ្យច្បាស់លាស់ (មាត្រា ៩០១ កថាខណ្ឌទី ៣)។ ករណីនេះ អាចជួយការពារអ្នកធានាកុំឱ្យទទួលបន្ទុកនូវការបាត់បង់ ដែលមិនអាចរំពឹងទុកបាន។

ការធានាបំណុលអណ្តែត គឺជាករណីលើកលែងចំពោះបញ្ញត្តិជាគោលការណ៍ ហើយអ្នកធានាត្រូវធានាកាតព្វកិច្ចមិនកំណត់ ដែលអាចកើតមានឡើងនៅពេលអនាគត ដោយសារទំនាក់ទំនងគតិយុត្តជានិរន្តរ៍។

នេះគឺជាកិច្ចសន្យាដែលមានលក្ខណៈប្រថុយប្រថានច្រើនចំពោះអ្នកធានា។ ហេតុដូច្នេះ អ្នកធានាត្រូវបានគេផ្តល់នូវការការពារមួយចំនួន។

**ឧទាហរណ៍ ៖ ក** និង **ខ** បានធ្វើជំនួញជាមួយគ្នាជាញឹកញាប់ ហើយ **គ** គឺជាអ្នកធានាកាតព្វកិច្ចរបស់ **ក** ដែលបានកើតឡើងពីការធ្វើជំនួញនោះ ។

១- ក្នុងករណីដែលការធ្វើជំនួញនោះ ត្រូវបានបញ្ជាក់ច្បាស់លាស់ ដូចជា កិច្ចសន្យាលក់ទិញចំណីអាហារ ការធានាបំណុលអណ្ដែតនឹងមានសុពលភាព។ ផ្ទុយទៅវិញ ការធានាបែបនេះនឹងគ្មានសុពលភាពនោះទេ ប្រសិនបើ **គ** ធានារាល់កាតព្វកិច្ចទាំងអស់ដែលកើតឡើងពីប្រភេទណាមួយនៃទំនាក់ទំនងគតិយុត្តរវាងពួកគេ (ប្រៀបធៀប មាត្រា ៩០២ កថាខណ្ឌទី ១) ។ ការធានាបំណុលអណ្ដែត តម្រូវឱ្យមានទំនាក់ទំនងគតិយុត្តជាក់លាក់ ។

២- ក្នុងករណីដែលអំឡុងពេលធានាបំណុលអណ្ដែត មិនត្រូវបានបញ្ជាក់ច្បាស់លាស់ទេ **គ** អាចរំលាយកិច្ចសន្យាធានាបំណុលអណ្ដែតនោះបាន ក្រោយពីហួសអំឡុងពេលសមរម្យ ។ អំឡុងពេលសមរម្យត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋាននៃករណីនីមួយៗ (ប្រៀបធៀបមាត្រា ៩០២ កថាខណ្ឌទី ២) ។

៣- នៅក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់ **ក** ធ្លាក់អន់ថយយ៉ាងខ្លាំង **គ** អាចរំលាយកិច្ចសន្យាធានាបំណុលអណ្ដែតសម្រាប់អនាគតនោះភ្លាមៗបាន (ប្រៀបធៀបមាត្រា ៩០២ កថាខណ្ឌទី ៣) ។

៤- ដើម្បីការពារសន្តតិជន ការធានាបំណុលអណ្ដែតមិនចងសន្តតិជននោះទេ។ មានតែកាតព្វកិច្ចធានាបំណុលអណ្ដែត ចំពោះកាតព្វកិច្ចចម្បងដែលបានកើតឡើងមកត្រឹមពេលអ្នកធានានោះទទួលមរណភាពទេ ទើបត្រូវបន្តដោយសន្តតិកម្ម ។

## ៥. សិទ្ធិទាមទារសំណង

អ្នកធានាអាចទាមទារសំណង នៅក្នុងករណីមួយចំនួន ប៉ុន្តែ ចំនួន និង ពេលវេលានៃការទាមទារសំណងខុសគ្នា យោងតាមអត្ថិភាពនៃអាណត្តិ និង កត្តាផ្សេងៗមួយចំនួនទៀត ។

### ៥.១. លក្ខខណ្ឌនៃការទាមទារសំណង

#### ៥.១.១. ការជូនដំណឹងជាមុន

ក្នុងករណីដែលអ្នកធានាមិនបានជូនដំណឹងទៅកូនបំណុលដែលមានកាតព្វកិច្ចចម្បងថា ម្ចាស់បំណុលបានទាមទារពីខ្លួន តែអ្នកធានានោះបានរួចផុតពីបំណុលដោយការសង ឬ ការចេញចំណាយរបស់ខ្លួន ហើយកូនបំណុលដែលមានកាតព្វកិច្ចចម្បង មានហេតុដែលអាចតតាំងចំពោះម្ចាស់បំណុលបាន កូនបំណុលដែលមានកាតព្វកិច្ចចម្បងអាចយកហេតុនោះទៅតតាំងនឹងការទាមទាររបស់អ្នកធានាបាន (មាត្រា ៩១៣ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។

#### ៥.១.២. ការជូនដំណឹងក្រោយពេលសង

**ឧទាហរណ៍ ៖ ក** បានទិញរថយន្តមួយគ្រឿងពី **ខ** ។ **គ** ធានាកាតព្វកិច្ចចំពោះការបង់ថ្លៃលក់ ។

១- ឝ បានបង់ថ្លៃលក់ដោយមិនបានជូនដំណឹងជាមុនទេ។ ជាក់ស្តែង ឝ មានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ពីព្រោះរថយន្តមិនទាន់ត្រូវបានប្រគល់ឱ្យនៅឡើយទេ។ នៅក្នុងករណីនេះតាមមាត្រា ៩១៣ កថាខណ្ឌទី ១ ឝ អាចបដិសេធនូវការបង់ប្រាក់ រហូតដល់ពេលដែលគាត់បានទទួលរថយន្ត។

២- ឝ បានជូនដំណឹងដល់ ឝ អំពីការទាមទាររបស់ ខ ជាមុនរួចហើយ ហើយបានបង់ថ្លៃលក់រួចហើយដែរ ប៉ុន្តែ ឝ មិនបានជូនដំណឹងដល់ ឝ អំពីការបង់ថ្លៃលក់នេះទេ។ ឝ ក៏បានបង់ថ្លៃលក់នោះដែរ ដោយសារតែមិនបានដឹងថា ឝ បានបង់ថ្លៃលក់នោះ (ខ ស្ងៀមស្ងាត់អំពីបញ្ហានេះ)។ នៅក្នុងករណីនេះ តាមមាត្រា ៩១៣ កថាខណ្ឌទី ២ ឝ អាចបដិសេធនូវការទាមទារសំណង ពីព្រោះថាការសងរបស់ ឝ មានអាទិភាពជាង។

ឝ ត្រូវទាមទារឱ្យ ខ ត្រូវប្រគល់ថ្លៃលក់ដែលបានបង់រួចហើយនោះមកវិញ ដោយផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ។

## ៥.២. ទំហំនៃការទាមទារសំណង

ក្នុងករណីដែលអ្នកធានាដែលបានទទួលអាណត្តិ ទំហំនៃការទាមទារសំណង រាប់បញ្ចូលទាំងចំនួនទឹកប្រាក់ជាកំណត់ ការប្រាក់ និង សំណងការខូចខាត ចំណែកឯអ្នកធានាដោយស្ម័គ្រចិត្ត (អ្នកធានាដោយគ្មានអាណត្តិ) អាចទាមទារសំណងត្រឹមតែកម្រិតនៃផលប្រយោជន៍ ដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បងបានទទួលតែប៉ុណ្ណោះ។

ជាងនេះទៅទៀត ប្រសិនបើការធានាត្រូវបានធ្វើឡើង ដោយផ្ទុយពីឆន្ទៈរបស់កូនបំណុលដែលមានកាតព្វកិច្ចចម្បង ទំហំនៃការទាមទារសំណង ត្រូវបានកម្រិតត្រឹមតែផលប្រយោជន៍ជាក់ស្តែងដែលនៅតែមានតែប៉ុណ្ណោះ។

## ៥.៣. ការទាមទារសំណងជាមុន

ជួនកាលអ្នកដែលធានាដែលបានទទួលអាណត្តិ អាចទាមទារសំណងជាមុនផងដែរ យោងតាមមាត្រា ៩១១។

ករណីមួយចំនួនដែលការទាមទារសំណងជាមុនអាចធ្វើបាន គឺ :

ក- ករណីដែលសាលក្រម ឬ សាលដីកាស្ថាពរបានបង្គាប់ឱ្យអ្នកធានាសងទៅម្ចាស់បំណុល

ខ- ករណីកូនបំណុលដែលមានកាតព្វកិច្ចចម្បងក្ស័យធន

គ- កាតព្វកិច្ចចម្បងដល់ពេលកំណត់ត្រូវសង

ឃ- ករណីដែលពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចចម្បងនោះ មិនច្បាស់លាស់ ហើយអំឡុងពេល ៥ ឆ្នាំបានកន្លងហួស។

នៅក្នុងករណីនេះ កូនបំណុលដែលមានកាតព្វកិច្ចចម្បង អាចទាមទារឱ្យអ្នកធានាដាក់ប្រាតិភោគ ឬ ទាមទារឱ្យខ្លួនរួចផុតពីកាតព្វកិច្ចបាន (មាត្រា ៩១១ កថាខណ្ឌទី ៤) ឬ អាចតម្កល់ ឬ ធ្វើឱ្យអ្នកធានារួចផុតពីកាតព្វកិច្ច (មាត្រា ៩១១ កថាខណ្ឌទី ៥)។

## ៥.៤. សិទ្ធិទាមទាររបស់អ្នកធានារួម

មាត្រា ៩១៥ ជាបញ្ញត្តិពាក់ព័ន្ធទៅនឹងការទាមទារសំណងនៅក្នុងចំណោមអ្នកធានារួម។

ពាក្យពេចន៍នៅក្នុងមាត្រានេះ មានភាពស្មុគ្រស្មាញ ពិបាកយល់ ប៉ុន្តែ លទ្ធផលជាក់ស្តែងនៃការអនុវត្តមាត្រា ៩១៥ គឺដូចខាងក្រោមនេះ :

**អង្គហេតុជាមូលដ្ឋាន :** **ក** ខ្ចីប្រាក់ចំនួន ១.០០០ ដុល្លារ ពី **ខ** ហើយ **គ១ គ២ គ៣** និង **គ៤** គឺជាអ្នកធានារួមនូវកាតព្វកិច្ចរបស់ **ក**។ បន្ទុកនៃការធានាកាតព្វកិច្ចរបស់ពួកគេម្នាក់ៗ គឺ **គ១** ៤០ % **គ២** ៣០ % **គ៣** ២០ % និង **គ៤** ១០ %។

១- ប្រសិនបើ **គ១** បានសងនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចទាំងអស់ ជាការពិតណាស់ **គ១** អាចទាមទារសំណង ពី **ក** បាន ឬ **គ១** ក៏អាចទាមទារសំណងពីអ្នកធានារួមឯទៀតៗបាន យោងតាមមាត្រា ៩១៥ កថាខណ្ឌទី ១។ ចំនួនទឹកប្រាក់នៃសំណង គឺ ៣០០ ដុល្លារ ពី **គ២** ២០០ ដុល្លារ ពី **គ៣** និង ១០០ ដុល្លារពី **គ៤**។ លើសពីនេះ **គ១** អាចទាមទារការប្រាក់ តាមមាត្រា ៩១៥ កថាខណ្ឌទី ២។

២- ក្នុងករណីដែល **គ១** បានសងដើម្បីឱ្យរួចផុតពីកាតព្វកិច្ចមួយផ្នែក ដូចជាការសងកាតព្វកិច្ចចំនួន ៦០០ ដុល្លារ **គ១** អាចទាមទារសំណងពី **ក** ឬ **គ១** ក៏អាចទាមទារពីអ្នកធានារួមឯទៀតបានផងដែរ។ ចំនួនទឹកប្រាក់នៃការសងគឺ ១៨០ ដុល្លារ ពី **គ២** ១២០ ដុល្លារពី **គ៣** និង ៦០ ដុល្លារពី **គ៤** ។

៣- ក្នុងករណីដែលមានការសន្យាពីការបែងចែកបន្ទុក អ្នកធានារួមនីមួយៗត្រូវបង់ច្រើនជាងចំនួននៃបន្ទុករបស់ខ្លួន។ **ឧទាហរណ៍ :** ប្រសិនបើ **គ១** បង់ចំនួន ៦០០ ដុល្លារ **គ១** អាចទាមទារសំណងតែ ១០០ ដុល្លារ ពីអ្នកធានាឯទៀតៗ យោងតាមមាត្រា ៩១៥ កថាខណ្ឌទី ៣។

### ៦. ឧបាទេសកម្ម

ឧបាទេសកម្ម គឺជាប្រព័ន្ធគតិយុត្តមួយដើម្បីធានានូវការទាមទារសំណងចំពោះផលប្រយោជន៍របស់អ្នកធានា (ប្រៀបធៀបមាត្រា ៩១៦ កថាខណ្ឌទី ១)។

ជាការអនុវត្ត វាមានប្រយោជន៍ណាស់ នៅពេលដែលម្ចាស់បំណុលមានសិទ្ធិប្រាតិភោគចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ពីព្រោះអ្នកធានាអាចធ្វើឧបាទេសកម្មនូវសិទ្ធិប្រាតិភោគបែបនេះ។

# ឧបសម្ព័ន្ធ

【ឧបសម្ព័ន្ធ ៤】 ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់

| | ភាពសុចរិត និងគ្មានកំហុសរបស់អ្នកទិញ | បន្ថយថ្លៃ | រំលាយកិច្ចសន្យាដោយអ្នកទិញ | ទាមទារសំណងការខូចខាត | ទាមទារប្រគល់វត្ថុជំនួស | ទាមទារឱ្យជួសជុល | អំឡុងពេលសំរាប់អនុវត្តសិទ្ធិ | |
|---|---|---|---|---|---|---|---|---|
| នៅពេលដែលសិទ្ធិទាំងមូលជាសិទ្ធិរបស់តតិយជន (531,532) | សុចរិត | - | ○ | ○ | - | - | គ្មានការកំរិតជាពិសេស | |
| | ទុច្ចរិត | - | ○ | × | - | - | គ្មានការកំរិតជាពិសេស | ・**អ្នកលក់**សុចរិត មានសិទ្ធិរំលាយ (532) |
| នៅពេលដែលសិទ្ធិមួយភាគជាសិទ្ធិរបស់តតិយជន (533) | សុចរិត | ○ | ○※ | ○ | - | - | អំឡុងពេល ១ឆ្នាំ គិតពីពេលដែលអ្នកទិញ បានដឹងការពិត (533-4) | ※ មានតែក្នុងករណីដែលអ្នកទិញនឹងមិនទិញតែភាគដែលនៅសល់ (533-2) |
| | ទុច្ចរិត | ○ | × | × | - | - | អំឡុងពេល ១ ឆ្នាំ គិតពីពេលបង្កើតកិច្ចសន្យា (533-4) | |
| នៅពេលដែលមានសិទ្ធិប្រត្យក្សជាផលុបភោគ (534) | សុចរិត | - | ○ (មានតែករណីដែលអ្នកទិញមិនអាចសំរេចគោលបំណងនៃកិច្ចសន្យា) | ○ | - | - | អំឡុងពេល ១ឆ្នាំ គិតពីពេលដែលអ្នកទិញ បានដឹងការពិត (534-4) | |
| | ទុច្ចរិត | - | × | × | - | - | - | |
| នៅពេលមានសិទ្ធិប្រាតិភោគប្រត្យក្ស (535) | សុចរិត | - | ○ (មានតែករណីដែលអ្នកទិញបាត់បង់កម្មសិទ្ធិ) | ○ | - | - | គ្មានការកំរិតជាពិសេស | ・**អ្នកទិញ** អាចទាមទារអោយសងថ្លៃចំណាយដែល គាត់ បានចំណាយសំរាប់រក្សាកម្មសិទ្ធិ (535-2) |
| | ទុច្ចរិត | - | | | - | - | | |

| | ភាពសុចរិត និងគ្មានកំហុសរបស់អ្នកទិញ | បន្ថយថ្លៃ | រំលាយកិច្ចសន្យាដោយអ្នកទិញ | ទាមទារសំណងការខូចខាត | ទាមទារប្រគល់វត្ថុជំនួស | ទាមទារឱ្យជួសជុល | អំឡុងពេលសំរាប់អនុវត្តសិទ្ធិ | |
|---|---|---|---|---|---|---|---|---|
| នៅពេលដែលមានវិការៈ (540) | សុចរិត | O | O (មានតែករណីដែលអ្នកទិញមិនអាចសំរេចគោលបំណងនៃកិច្ចសន្យា) | O | O | O | អំឡុងពេល ១ឆ្នាំ គិតពីពេលដែលអ្នកទិញបានដឹង ឬ គួរបានដឹងពីវិការៈ (547) | |
| | ទុច្ចរិត/កំហុសធ្ងន់ធ្ងរ | × | × | × | × | × | - | |

| | | | ភាពសុចរិត និងគ្មានកំហុសរបស់អ្នកទិញ | បន្ថយថ្លៃ | រំលាយកិច្ចសន្យាដោយអ្នកទិញ | ទាមទារសំណងការខូចខាត | ទាមទារប្រគល់វត្ថុជំនួស | ទាមទារឱ្យជួសជុល | អំឡុងពេលសំរាប់អនុវត្តសិទ្ធិ | |
|---|---|---|---|---|---|---|---|---|---|---|
| បញ្ញត្តិពិសេសស្តីពីដីដែលមានទំហំខ្វះ ឬលើស (546) | ការលក់ទិញ បានធ្វើឡើងដោយផ្អែកទៅលើតំលៃសរុប និងតំលៃតាមខ្នាតដី | នៅក្នុងករណីដែលទំហំដីពិតគឺខ្វះ (546-1) | សុចរិត | ○ | ○ (មានតែករណីដែលអ្នកទិញមិនអាចសំរេចគោលបំណងនៃកិច្ចសន្យា) | ○※2 | × | ○ (ផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ) | អំឡុងពេល ១ឆ្នាំ គិតពីពេលដែលអ្នកទិញបានដឹង ឬ គួរបានដឹងពីវិការៈ (547)※2 | ※2 មាត្រា ៤៨២ ត្រូវយកមកអនុវត្តចំពោះសិទ្ធិទាមទារសំណងការខូចខាត |
| | | | ទុច្ចរិត/កំហុសធ្ងន់ធ្ងរ | × | × | × | × | × | - | |
| | | នៅក្នុងករណីដែលទំហំដីពិតគឺលើស (546-2) | សុចរិត | - | - | - | - | - | - | ・ **អ្នកលក់**សុចរិត អាចទាមទារឱ្យបន្ថែមតំលៃនៅក្នុងរយៈពេល ១ ឆ្នាំ គិតចាប់ពីពេលបង្កើតកិច្ចសន្យា (546-2) |
| | | | ទុច្ចរិត/កំហុសធ្ងន់ធ្ងរ | × | × | × | × | × | - | |
| | ការលក់ទិញ បានធ្វើឡើងដោយ | នៅក្នុងករណីដែលទំហំដីពិតគឺខ្វះ (546-3) | សុចរិត | × (លើកលែងតែករណីដែលអ្នកលក់ ជាជនទុច្ចរិត, ឬអ្នកលក់ បានធានាភាពត្រឹមត្រូវនៃទំហំដីដែលបានបញ្ជាក់, ឬ ទំហំដែលខ្វះមានច្រើនជាង ៥ភាគរយ មាត្រា 546 កថាខណ្ឌទី 3 វាក្យខណ្ឌទី 2) ※2 | | | | | (ប្រសិនបើសិទ្ធិ ត្រូវបានទទួលស្គាល់តាមមាត្រា ៥៤៦ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២ អំឡុងពេល ១ឆ្នាំ គិតពីពេលដែលអ្នកទិញបានដឹង ឬ គួរបានដឹងពីវិការៈ (547)※2) | ※2 មាត្រា ៤៨២ ត្រូវយកមកអនុវត្តចំពោះសិទ្ធិទាមទារសំណងការខូចខាត |

| | | | ភាពសុចរិត និងគ្មានកំហុសរបស់អ្នកទិញ | បន្ថយថ្លៃ | រំលាយកិច្ចសន្យាដោយអ្នកទិញ | ទាមទារសំណងការខូចខាត | ទាមទារប្រគល់វត្ថុជំនួស | ទាមទារឱ្យជួសជុល | អំឡុងពេលសំរាប់អនុវត្តសិទ្ធិ | |
|---|---|---|---|---|---|---|---|---|---|---|
| | ផ្អែកទៅលើតែតំលៃសរុបតែប៉ុណ្ណោះ | | ទុច្ចរិត/កំហុសធ្ងន់ធ្ងរ | × | × | × | × | × | - | |
| | | នៅក្នុងករណីដែលទំហំដីពិតគឺលើស (546-4) | សុចរិត | - | - | - | - | - | - | · **អ្នកលក់** សុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ អាចទាមទារឱ្យបន្ថែមតំលៃដី ក្នុងរយៈពេល ១ ឆ្នាំ គិតចាប់ពីពេលបង្កើតកិច្ចសន្យា ចំពោះករណីដែលទំហំដែលលើសនោះ មានច្រើនជាង ៥ ភាគរយនៃទំហំដែលបានបញ្ជាក់ (546-4) |
| | | | ទុច្ចរិត/កំហុសធ្ងន់ធ្ងរ | - | - | - | - | - | - | |

**សំគាល់ :**

| | |
|---|---|
| ○ | មានន័យថា អាចធ្វើបាន |
| × | មានន័យថា មិនអាចធ្វើបាន |
| - | មានន័យថា មិនមានបញ្ញត្តិក្នុងក្រម ឬ មិនមានលទ្ធភាពក្នុងការពិចារណា |